

ឯកសារគម្ពីរព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ដុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ួច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (ក្លូវេ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា រ៉ានី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (ក្លូវេ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ

# ត្រៃបិដកបាលី

## និង

# សេចក្ដីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# បឋមភាគ

# ៦៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៤

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

## បឋមភាគ

៦៤

ព.ស. ២៥០៤

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

# តេរសមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

## អដ្ឋកវគ្គិកោ

## បឋមោ កាមសុត្តនិទ្ទេសោ

(១) កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
អទ្ធា បីតិមនោ ហោតិ លទ្ធា មច្ចោ យទិច្ឆតិ។

(២) កាមំ កាមយមានស្សាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច។

កតមេ វត្ថុកាមា។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា អត្ថរណា បាវុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យំ កិញ្ចិ រជនីយំ វត្ថុ វត្ថុកាមា។ អបិច អតីតា កាមា អនាគតា កាមា

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# តេរសមភាគ

---

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## អដ្ឋកវគ្គិកៈ

## កាមសុត្តនិទ្ទេស ទី ១

(១) (ព្រះមានព្រះភាគត្រាស់ថា) កាលសត្វប្រាថ្នាកាម បើវត្ថុនោះសម្រេចដល់សត្វនោះ សត្វរមែងមានចិត្តប្រកបដោយបីតិពិត (ព្រោះ) សត្វប្រាថ្នានូវវត្ថុណា បាន (នូវវត្ថុនោះ) ។

(២) ពាក្យថា កាម ក្នុងពាក្យថា កាលសត្វប្រាថ្នាកាម ដូច្នេះ បើតាមឧទ្ទាន បានដល់កាម ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។

ពួកវត្ថុកាម ដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង និងវត្ថុដែលគួរត្រេកអរ ណាមួយ ឈ្មោះថា វត្ថុកាម ។ មួយទៀត កាមទាំងឡាយជាអតីត កាមទាំងឡាយជាអនាគត

បច្ចុប្បន្នា កាមា អជ្ឈត្តា កាមា ពហិទ្ធា កាមា អជ្ឈត្តពហិទ្ធា កាមា ហីនា កាមា មជ្ឈិមា កាមា បណីតា កាមា អាបាយិកា កាមា មានុសិកា កាមា ទិព្វា កាមា បច្ចុបដ្ឋិតា កាមា និម្មិតា កាមា បរនិម្មិតា កាមា បរិគ្គហិតា កាមា អបរិគ្គហិតា កាមា មមាយិតា កាមា អមមាយិតា កាមា សព្វេបិ កាមាវចរា ធម្មា សព្វេបិ រូបាវចរា ធម្មា សព្វេបិ អរូបាវចរា ធម្មា តណ្ហាវត្ថុកា តណ្ហារម្មណា កាមនីយដ្ឋេន រជនីយដ្ឋេន មទនីយដ្ឋេន កាមា ឥមេ វុច្ចន្តិ វត្ថុកាមា ។

កតមេ កិលេសកាមា ។ ឆន្ទោ[1] កាមោ រាគោ[2] កាមោ ឆន្ទរាគោ កាមោ សង្កប្បោ កាមោ រាគោ កាមោ សង្កប្បរាគោ កាមោ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា

---

១ តត្ថ ឆន្ទោតិ ទុព្វលរាគោ ។ ២ រាគោតិ តតោ ពលវតរោ ។ អដ្ឋកថា ។

កាមទាំងឡាយជាបច្ចុប្បន្ន កាមទាំងឡាយជាខាងក្នុង កាមទាំងឡាយជាខាងក្រៅ កាមទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ កាមទាំងឡាយថោកទាប កាមទាំងឡាយជាកណ្តាល កាមទាំងឡាយដ៏ខ្ពង់ខ្ពស់ កាមទាំងឡាយ មានក្នុងអបាយ កាមទាំងឡាយ មានក្នុងមនុស្ស កាមទាំងឡាយជាទិព្វ កាមទាំងឡាយ ដែលតាំងឡើងឯង កាមទាំងឡាយ ដែលខ្លួននិម្មិត កាមទាំងឡាយ ដែលអ្នកដទៃនិម្មិត កាមទាំងឡាយ ដែលបុគ្គលហួងហែង កាមទាំងឡាយ ដែលបុគ្គលមិនបានហួងហែង កាមទាំងឡាយ ដែលបុគ្គលរាប់អានថាជារបស់អញ កាមទាំងឡាយ ដែលបុគ្គលមិនរាប់អានថាជារបស់អញ ពួកធម៌ជាកាមាវចរទាំងអស់ក្តី ពួកធម៌ជារូបាវចរទាំងអស់ក្តី ពួកធម៌ជាអរូបាវចរទាំងអស់ក្តី ដែលជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយអត្ថថា គួរប្រាថ្នា ដោយអត្ថថា គួរត្រេកអរ ដោយអត្ថថាគួរស្រវឹង ទាំងនេះហៅថា វត្ថុកាម ។

ពួកកិលេសកាម ដូចម្តេច ។ សេចក្តីប្រាថ្នា ឈ្មោះថាកាម សេចក្តីត្រេកអរ ឈ្មោះថា កាម សេចក្តីត្រេកអរដ៏មានកម្លាំង ឈ្មោះថាកាម សេចក្តីត្រិះរិះ ឈ្មោះថាកាម តម្រេក ឈ្មោះថាកាម តម្រេកដោយការត្រិះរិះ ឈ្មោះថាកាម បានដល់ សេចក្តីប្រាថ្នាក្នុងកាម ក្នុងកាមទាំងឡាយ សេចក្តីត្រេកអរក្នុងកាម សេចក្តីរីករាយក្នុងកាម តណ្ហាក្នុងកាម

កាមស្នេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោ-
សានំ កាមោឃោ កាមយោគោ កាមុបាទានំ កាម-
ច្ឆន្ទនីវរណំ ។

អទ្ទសំ កាម តេ មូលំ សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ ឯវំ កាម ន ហោហិសិ[១] ។

ឥមេ វុច្ចន្តិ កិលេសកាមា ។ កាមំ កាមយមានស្សាតិ
កាមំ កាមយមានស្ស ឥច្ឆមានស្ស សាទិយមានស្ស
បត្ថយមានស្ស បិហយមានស្ស អភិជប្បមានស្សាតិ
កាមំ កាមយមានស្ស ។

(៣) តស្ស ចេ តំ សមិជ្ឈតីតិ តស្ស ចេតិ តស្ស ខត្តិ-
យស្ស វា ព្រាហ្មណស្ស វា វេស្សស្ស វា សុទ្ទស្ស វា
គហដ្ឋស្ស វា បព្វជិតស្ស វា ទេវស្ស វា មនុស្សស្ស វា ។
តន្តិ វត្ថុកាមា វុច្ចន្តិ មនាបិកា រូបា មនាបិកា សទ្ទា
មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ។
សមិជ្ឈតីតិ ឥជ្ឈតិ សមិជ្ឈតិ លភតិ បដិលភតិ អធិគ-
ច្ឆតិ វិន្ទតីតិ តស្ស ចេ តំ សមិជ្ឈតិ ។

---

១ ឱ.ម. ហោហិសីតិ ។

សេចក្តីស្នេហាក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម ការជ្រប់ក្នុងកាម ការងប់ងុះក្នុងកាម អន្ទង់គឺកាម គ្រឿងប្រកបគឺកាម ការជ្លក់ជាប់គឺកាម នីវរណៈគឺកាមច្ឆន្ទៈ (ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា)

ម្នាលកាម តថាគត បានឃើញឫសគល់ របស់អ្នកហើយ

ម្នាលកាម អ្នកឯងកើតអំពីសេចក្តីត្រិះរិះ តថាគត មិនត្រិះរិះ

ចំពោះអ្នកទេ ម្នាលកាម អ្នកនឹងមិនមានយ៉ាងនេះទេ ។

ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា កាលសត្វប្រាថ្នាកាម គឺ កាលត្រូវការ កាលចង់បាន កាលត្រេកអរ កាលតាំងទុក កាលស្រឡាញ់ កាលជាប់ចំពាក់ ចំពោះកាម ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) កាលសត្វប្រាថ្នាកាម ។

(៣) អធិប្បាយពាក្យថា បើវត្ថុនោះ សម្រេចដល់សត្វនោះ ត្រង់ពាក្យថា បើ ..ដល់សត្វនោះ គឺដល់សត្វនោះ ទោះក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា វត្ថុនោះ លោកសំដៅយកវត្ថុកាម គឺ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត ។ ពាក្យថា សម្រេច គឺស្រេច ស្រេចបាច់ បាន បានចំពោះ បានសើប បានប្រទះ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បើវត្ថុនោះ សម្រេចដល់សត្វនោះ ។

(៨) អត្តា បីតិមនោ ហោតីតិ អត្តាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខវចនំ អទ្វេជ្ឈវចនំ អទ្វេឡ្ហកវចនំ និយោគវចនំ អបណ្ណកវចនំ អវត្ថាបនវចនមេតំ អត្តាតិ ។ បីតីតិ យា បញ្ចកាមគុណបដិសញ្ញុត្តា បីតិ បាមុជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ តុដ្ឋិ ឱទគ្យំ អត្តមនតា អភិបូរណតា ចិត្តស្ស ។ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ អយំ វុច្ចតិ មនោ ។ អយំ មនោ ឥមាយ បីតិយា សហគតោ ហោតិ សហជាតោ សំសដ្ឋោ សម្បយុត្តោ ឯកុប្បាទោ ឯកនិរោធោ ឯកវត្ថុកោ ឯការម្មណោ ។ បីតិមនោ ហោតីតិ តុដ្ឋមនោ ហដ្ឋមនោ បហដ្ឋមនោ អត្តមនោ ឧទគ្គមនោ សមុទិតមនោ[1] ហោតីតិ អត្តា បីតិមនោ ហោតិ ។

---

១ ឱ.ម. មុទិតមនោ បមោទិតមនោ

(៤) អធិប្បាយពាក្យថា សត្វមែនមានចិត្តប្រកបដោយបីតិពិត ត្រង់ពាក្យថា ពិត គឺជាពាក្យប្រាប់សេចក្តីដោយដាច់ខាត ប្រាប់សេចក្តីដោយមិនមានសង្ស័យ ប្រាប់សេចក្តីមិនមានងឿងឆ្ងល់ ប្រាប់ដំណើរមិនមានពីរ ប្រាប់ហេតុមិនបែកជាពីរ ប្រាប់ការប្រកបដោយទៀងទាត់ ប្រាប់ហេតុមិនខុស ពាក្យថា ពិត នុ៎ះជាពាក្យប្រាប់សេចក្តីកំណត់ ។ ពាក្យថា បីតិ បានដល់ បីតិ ភាពនៃចិត្តរីករាយ ការរីករាយខ្លួនទៅ ការរីករាយសព្វគ្រប់ សេចក្តីស្រស់ស្រាយ សេចក្តីស្រស់ស្រាយសព្វគ្រប់ សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ភាពនៃចិត្តអបអរ ភាពនៃចិត្តត្រេកត្រអាល ភាពនៃចិត្តដ៏ពេញលេញក្រៃលែង ដែលប្រកបដោយកាមគុណ ៥ ។ ពាក្យថា ចិត្ត គឺចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីធម៌ មានផស្សៈជាដើម នោះ ណា នេះ លោកហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយ កើតជាមួយ ប្រឡំ ប្រកប មានការកើតឡើងក្នុងទីជាមួយ មានការរលត់ក្នុងទីមួយ មានវត្ថុតែមួយ មានអារម្មណ៍តែមួយ ជាមួយ នឹងបីតិនេះ ។ ពាក្យថា មានចិត្តប្រកបដោយបីតិ គឺមានចិត្តត្រេកអរ មានចិត្តរីករាយ មានចិត្តរីករាយខ្លាំង មានចិត្តជារបស់ខ្លួន មានចិត្តខ្ពស់ មានចិត្តស្រស់ស្រាយ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) មានចិត្តប្រកបដោយបីតិពិត ។

(៤) លទ្ធា មច្ចោ យទិច្ឆតីតិ លទ្ធាតិ លទ្ធា លភិត្វា បដិលភិត្វា អធិគន្ត្វា វិន្ទិត្វា ។ មច្ចោតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាគុ[១] ជន្តុ ឥន្ទគូ[២] មនុជោ ។ យទិច្ឆតីតិ យំ ឥច្ឆតិ យំ សាទិយតិ យំ បត្ថេតិ យំ បិហេតិ យំ អភិជប្បតិ រូបំ វា សទ្ទំ វា គន្ធំ វា រសំ វា ផោដ្ឋព្វំ វាតិ លទ្ធា មច្ចោ យទិច្ឆតិ ។ តេនាហ ភគវា

កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
អទ្ធា បីតិមនោ ហោតិ លទ្ធា មច្ចោ យទិច្ឆតីតិ ។

(៦) តស្ស ចេ កាមយមានស្ស[៣] ឆន្ទជាតស្ស ជន្តុនោ
តេ កាមា បរិហាយន្តិ សល្លវិទ្ធោវ រុប្បតិ ។

(៧) តស្ស ចេ កាមយមានស្សាតិ តស្ស ចេតិ តស្ស ខត្តិយស្ស វា ព្រាហ្មណស្ស វា វេស្សស្ស វា

---

១ ម. ជគុ ។ ឱ. ជគូ ។ ២ ហិន្ទគូតិបិ បាឋោ ។ ៣ ឱ. កាមយានស្ស ។

(៥) អធិប្បាយពាក្យថា សត្វប្រាថ្នានូវវត្ថុណា បាន (នូវវត្ថុនោះ) ត្រង់ពាក្យថា បាន គឺបានហើយ បានរួចហើយ បានស៊ប់ហើយ បានសម្រេចហើយ បានប្រាកដហើយ ។ ពាក្យថា សត្វ គឺសត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា សត្វប្រាថ្នានូវវត្ថុណា គឺសត្វប្រាថ្នាវត្ថុណា ត្រេកអរវត្ថុណា កួចកាន់វត្ថុណា ស្រឡាញ់វត្ថុណា ជាប់ចំពាក់ចំពោះវត្ថុណា ទោះជារូបក្តី សំឡេងក្តី ក្លិនក្តី រសក្តី ផ្សព្វក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វប្រាថ្នានូវវត្ថុណា បាន (នូវវត្ថុនោះ) ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កាលសត្វប្រាថ្នាកាម បើវត្ថុនោះសម្រេចដល់សត្វនោះ
សត្វរមែងមានចិត្តប្រកបដោយបីតិពិត (ព្រោះ) សត្វ
ប្រាថ្នានូវវត្ថុណា បាន (នូវវត្ថុនោះ) ។

(៦) បើកាលសត្វនោះ មានឆន្ទៈកើតហើយ កំពុងប្រាថ្នា
កាមទាំងឡាយនោះ សាបសូន្យទៅវិញ សត្វរមែងក្តៅ
ក្រហាយ ដូចត្រូវព្រួញមុត ។

(៧) អធិប្បាយពាក្យថា បើកាលសត្វនោះកំពុងប្រាថ្នា ត្រង់ពាក្យថា បើកាលសត្វនោះ គឺកាលសត្វនោះ ទោះជាក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី

សុទ្ទស្ស វា គហដ្ឋស្ស វា បព្វជិតស្ស វា ទេវស្ស វា មនុស្សស្ស វា ។ កាមយមានស្សាតិ កាមយមានស្ស ឥច្ឆមានស្ស សាទិយមានស្ស បត្ថយមានស្ស បិហយមានស្ស អភិជប្បមានស្ស ។ អថវា កាមតណ្ហាយ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតិ ។ យថា ហត្ថិយានេន វា អស្សយានេន វា គោយានេន វា អជយានេន វា មេណ្ឌកយានេន វា ឱដ្ឋយានេន វា ខរយានេន វា យាយតិ និយ្យតិ វុយ្ហតិ សំហរិយតិ ឯវមេវ កាមតណ្ហាយ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតីតិ តស្ស ចេ កាមយមានស្ស ។

(៨) ឆន្ទជាតស្ស ជន្តុនោតិ ឆន្ទោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមស្នេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ តស្ស សោ កាមច្ឆន្ទោ ជាតោ ហោតិ សញ្ជាតោ និព្វត្តោ អភិនិព្វត្តោ បាតុភូតោ ។ ជន្តុនោតិ សត្តស្ស នរស្ស មាណវស្ស បោសស្ស បុគ្គលស្ស ជីវស្ស ជាតុស្ស(១) ជន្តុស្ស ឥន្ទគុស្ស មនុជស្សាតិ ឆន្ទជាតស្ស ជន្តុនោ ។

---

១ ឱ.ម. ជិតុស្ស ។

សុទ្រៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា
កំពុងប្រាថ្នា គឺ កំពុងត្រូវការ កំពុងប៉ងប៉ាន កំពុងត្រេកអរ កំពុងតាំង
ទុក កំពុងស្រឡាញ់ កំពុងជាប់ចំពាក់ ។ មួយទៀត សត្វរមែងទៅ
ចេញទៅ រសាត់ទៅ ប្រមូលទៅ តាមកាមតណ្ហា ។ បុគ្គលតែងទៅ
ចេញទៅ រសាត់ទៅ ប្រមូលទៅ ដោយយានដំរី យានសេះ យានគោ
យានពពែ យានចៀម យានអូដ្ឋ ឬយានលា យ៉ាងណា សត្វរមែងទៅ
ចេញទៅ រសាត់ទៅ ប្រមូលទៅ ដោយកាមតណ្ហា យ៉ាងនោះដែរ
ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បើកាលសត្វនោះ កំពុងប្រាថ្នា ។

(៨) ពាក្យថា ឆន្ទៈ ក្នុងពាក្យថា កាលសត្វមានឆន្ទៈកើតហើយ គឺ
សេចក្តីប្រាថ្នាក្នុងកាម សេចក្តីត្រេកអរក្នុងកាម សេចក្តីរីករាយក្នុងកាម
តណ្ហាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម ការ
ស្រូបក្នុងកាម ការងប់ងុះក្នុងកាម អន្លង់គឺកាម គ្រឿងប្រកបគឺកាម ការថ្ពក់
ជាប់គឺកាម នីវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយណា កាមច្ឆន្ទៈនោះ
របស់សត្វនោះ ជាសភាពកើតហើយ កើតព្រមហើយ កើតឡើងហើយ
កើតចំពោះហើយ កើតប្រាកដហើយ ។ ពាក្យថា កាលសត្វ គឺកាល
សត្វ ជន មាណព បុរស បុគ្គល ជីវសត្វ សត្វមានជាតិ សត្វមានជក
សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ព្រោះហេតុនោះ (ទ្រង់
ត្រាស់ថា) កាលសត្វមានឆន្ទៈកើតហើយ ។

(៩) តេ កាមា បរិហាយន្តិ តេ វា កាមា បរិហាយន្តិ សោ វា កាមេហិ បរិហាយតិ ។

កថំ តេ កាមា បរិហាយន្តិ ។ តស្ស តិដ្ឋន្តស្សេវ តេ ភោគេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា វា ទាយាទា ហរន្តិ និហិតំ វា នាធិគច្ឆតិ[១] ទុប្បយុត្តា វា កម្មន្តា ភិជ្ជន្តិ កុលេ វា កុលង្គារោ[២] ឧប្បជ្ជតិ យោ តេ ភោគេ វិកិរតិ វិធមេតិ វិទ្ធំសេតិ អនិច្ចតាយេវ អដ្ឋមី ឯវំ តេ កាមា ហាយន្តិ បរិហាយន្តិ បរិទ្ធំសេន្តិ បរិបតន្តិ[៣] អន្តរធាយន្តិ វិប្បលុជ្ជន្តិ ។

កថំ សោ កាមេហិ បរិហាយតិ ។ តិដ្ឋន្តេវ តេ ភោគា សោ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ឯវំ សោ កាមេហិ ហាយតិ បរិហាយតិ បរិទ្ធំសេតិ បរិបតតិ អន្តរធាយតិ វិប្បលុជ្ជតិ ។

---

១ ឱ.ម. និហិតដ្ឋានា វា ចវន្តិ ។ ២ ឱ.ម. កុលង្គារោ ។ ៣ ឱ.ម. បរិបតន្តិ ។

(៩)ពាក្យថា កាមទាំងឡាយនោះ សាបសូន្យទៅ អធិប្បាយថា កាមទាំងឡាយនោះ សាបសូន្យ ឬសត្វនោះ សាបសូន្យចាកកាមទាំងឡាយ ។

កាមទាំងឡាយនោះ សាបសូន្យដោយប្រការដូចម្ដេច ។ ព្រះរាជាទាំងឡាយ នាំយកភោគៈទាំងឡាយនោះ របស់សត្វនោះ ដែលកំពុងរស់នៅ ឬពួកចោរនាំយកទៅ ឬភ្លើងឆេះ ឬទឹកបន្សាត់យកទៅ ឬញាតិសាច់មិនជាទីគាប់ចិត្តដណ្ដើមយក ឬសត្វនោះ មិនបានកំណប់ដែលខ្លួនកប់ទុក ការងារទាំងឡាយ ដែលប្រកបខុសទំនងខូចខាតទៅ បុគ្គលសម្លាប់ត្រកូល កើតឡើងក្នុងត្រកូល បុគ្គលណា (ជាខាងក្រោយ) ខ្ជះខ្ជាយ បំផ្លាញ កំចាត់បង់នូវភោគៈទាំងនោះ បុគ្គលនោះឈ្មោះថាអ្នកមានសេចក្ដីវិនាស ព្រោះភាពនៃការមិនទៀង កាមទាំងឡាយនោះសាបសូន្យ សាបសូន្យស្រឡះ ខ្ចាត់ព្រាត់ លះបង់ បាត់បង់ រលាយរលត់ទៅ យ៉ាងនេះ ។

បុគ្គលនោះ សាបសូន្យចាកកាមទាំងឡាយ ដោយប្រការដូចម្ដេច ។ ភោគៈទាំងឡាយនោះ ឋិតនៅ តែបុគ្គលនោះ ឃ្លាត ស្លាប់ អន្តរធាន វិនាសទៅ បុគ្គលនោះ ឈ្មោះថាសាបសូន្យ សាបសូន្យស្រឡះ ខ្ចាត់ព្រាត់ បាត់បង់ អន្តរធាន វិនាសទៅ យ៉ាងនេះ ។

ចោរា ហរន្តិ រាជានោ អគ្គិ ឌហតិ នស្សតិ
អត្ថោ អន្តេន ជហតិ(១) សរីរំ សបរិគ្គហំ
ឯតទញ្ញាយ មេធាវី ភុញ្ជេថ ច ទទេថ ច
ទត្វា ច ភុត្វា ច យថានុភាវំ
អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

តេ កាមា បរិហាយន្តិ ។

(១០) សល្លវិទ្ធោវ រុប្បតីតិ យថា អយោមយេន វា សល្លេន វិទ្ធោ អដ្ឋិមយេន វា សល្លេន ទន្តមយេន វា សល្លេន វិសាណមយេន វា សល្លេន កដ្ឋមយេន វា សល្លេន វិទ្ធោ រុប្បតិ កុប្បតិ ឃដ្ដិយតិ បីឡិយតិ ព្យាធិតោ ទោមនស្សិតោ ហោតិ ឯវមេវ វត្ថុកាមានំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា សោ កាមសល្លេន(២) វិទ្ធោ រុប្បតិ កុប្បតិ ឃដ្ដិយតិ បីឡិយតិ ព្យាធិតោ ទោមនស្សិតោ ហោតីតិ សល្លវិទ្ធោវ រុប្បតិ ។ តេនាហ ភគវា

តស្ស ចេ កាមយមានស្ស ឆន្ទជាតស្ស ជន្តុនោ
តេ កាមា បរិហាយន្តិ សល្លវិទ្ធោវ រុប្បតីតិ ។

---

១ ម. អសហន្តេន ជហតិ ។ ២ ឱ. កាមសល្លេន ប៊ សោកសល្លេន ប៊ ។

ចោរទាំងឡាយ ព្រះរាជាទាំងឡាយ នាំយកទ្រព្យទៅ ភ្លើងឆេះទ្រព្យ ប្រយោជន៍វិនាសទៅ បុគ្គលលះបង់សរីរៈ ព្រមទាំងរបស់ដែលហួងហែង ដោយមរណៈ អ្នកប្រាជ្ញ ជ្រាបសេចក្ដីនេះហើយ គប្បីបរិភោគផង ឲ្យទានផង លុះបានឲ្យទាន នឹងបរិភោគ តាមសមគួរដល់អានុភាពហើយ រមែងជាបុគ្គល ដែលមិនត្រូវគេនិន្ទា ហើយចូលទៅកាន់ឋានសួគ៌ ។

កាមទាំងឡាយនោះ ឈ្មោះថា រមែងសាបសូន្យ ។

(១០) ពាក្យថា សត្វរមែងក្ដៅក្រហាយ ដូចត្រូវព្រួញមុត គឺសត្វដែលត្រូវព្រួញដែកមុត ឬត្រូវព្រួញឆ្អឹង ត្រូវព្រួញភ្លុក ត្រូវព្រួញ-ស្នែង ឬត្រូវព្រួញឈើមុត រមែងក្ដៅក្រហាយ ញាប់ញ័រ ចង្អៀតចង្អល់ លំបាក ឈឺចាប់ តូចចិត្ត យ៉ាងណា សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស នឹងសេចក្ដីចង្អៀតចង្អល់ចិត្តទាំងឡាយ រមែងកើតឡើង ព្រោះប្រែប្រួល ព្រាត់ប្រាសចាកវត្ថុកាមទាំងឡាយ បុគ្គលនោះត្រូវព្រួញ គឺកាមមុត រមែងក្ដៅក្រហាយញាប់ញ័រ ចង្អៀតចង្អល់ លំបាក ឈឺចាប់ តូចចិត្ត យ៉ាងនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វក្ដៅក្រហាយ ដូចត្រូវព្រួញមុត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បើកាលសត្វនោះ មានឆន្ទៈកើតហើយ កំពុងប្រាថ្នា កាមទាំងឡាយ
នោះសាបសូន្យទៅវិញ សត្វរមែងក្ដៅក្រហាយ ដូចត្រូវព្រួញមុត ។

## បឋមោ កាមសុត្តនិទ្ទេសោ

(១១) យោ កាមេ បរិវជ្ជេតិ សប្បស្សេវ បទា សិរោ
សោមំ វិសត្តិកំ លោកេ សតោ សមតិវត្តតិ ។

(១២) យោ កាមេ បរិវជ្ជេតីតិ យោតិ យោ យាទិសោ យថាយុត្តោ យថាវិហិតោ យថាបការោ យំឋានប្បត្តោ យំធម្មសមន្នាគតោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វា គហដ្ឋោ វា បព្វជិតោ វា ទេវោ វា មនុស្សោ វា ។ កាមេ បរិវជ្ជេតីតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ កាមេ បរិវជ្ជេតីតិ ទ្វីហិ ការណេហិ កាមេ បរិវជ្ជេតិ វិក្ខម្ភនតោ វា សមុច្ឆេទតោ វា ។

កថំ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ។ អដ្ឋិកង្កលូបមា កាមា អប្បស្សាទដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ មំសបេសូបមា កាមា ពហុសាធារណដ្ឋេនាតិ

កាមសុត្តនិទ្ទេស ទី១

(១១) បុគ្គលណា វៀរកាមទាំងឡាយ ដូចបុគ្គលវៀរ
ក្បាលពស់ ដោយជើង បុគ្គលនោះ ជាអ្នកមានសតិ
រមែងកន្លងនូវវិសត្តិកាតណ្ហានេះ ក្នុងលោក ។

(១២) អធិប្បាយពាក្យថា បុគ្គលណា វៀរកាមទាំងឡាយ ត្រង់ពាក្យថា បុគ្គលណា គឺជនណា បែបណា ប្រកបដោយប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់ឋានៈណា ប្រកបដោយធម៌ណា ទោះជាក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្រៈ គ្រហស្ថ បព្វជិត ទេវតា ឬមនុស្ស ។ ពាក្យថា កាមទាំងឡាយ ក្នុងពាក្យថា វៀរកាមទាំងឡាយ ដូច្នេះ បើតាមឧទ្ទាន បានដល់កាម ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ ទាំងនេះ លោកហៅថា វត្ថុកាម ។បេ។ ទាំងនេះ លោកហៅថា កិលេស-កាម ។ ត្រង់ពាក្យថា វៀរកាមទាំងឡាយ គឺបុគ្គលវៀរកាមទាំងឡាយ ដោយហេតុ ២ គឺដោយកិរិយាសង្កត់សង្កិន ឬដោយការផ្តាច់ផ្តិល ។

បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន តើដូចម្តេច ។ បុគ្គល កាលឃើញថា កាមទាំងឡាយ មានឧបមាដូចកង្អឹង ដោយសេចក្តីថា មានសេចក្តីត្រេកអរតិច ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមា ដូចដុំសាច់ ដោយសេចក្តីថា ជារបស់សាធារណ៍ ដល់សត្វ មានប្រមាណច្រើន

បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ តិណុក្កូបមា កាមា អនុទហនដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ អង្គារកាសូបមា កាមា មហាបរិឡាហដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ សុបិនកូបមា កាមា ឥត្តរបច្ចុបដ្ឋានដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ យាចិតកូបមា កាមា តាវកាលិកដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ រុក្ខផលូបមា កាមា សម្ភញ្ជនបរិភញ្ជនដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ អសិសូនូបមា កាមា អធិកុដ្ដនដ្ឋេនាតិ[១] បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ សត្តិសូលូបមា កាមា វិនិវិជ្ឈនដ្ឋេនាតិ បស្សន្តោ

---

១ ឱ. ម. អធិកុន្តនដ្ឋេនាតិ ។

ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគប់ស្មៅ ដោយសេចក្តីថា ដុតកំដៅរឿយ ៗ ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចរណ្តៅរងើកភ្លើង ដោយសេចក្តីថា មានកិរិយាក្តៅពេលពលខ្លាំង ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចការយល់សប្តិ ដោយសេចក្តីថាមានកិរិយាតាំងឡើងដ៏ផ្តេសផ្តាស ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចរបស់ដែលខ្ចីគេ ដោយសេចក្តីថាជារបស់ប្រព្រឹត្តទៅមួយដងមួយកាលប៉ុណ្ណោះ ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចឈើមានផ្លែ ដោយសេចក្តីថាមានកិរិយាបាក់ខ្ទេចខ្ទី ឬបាក់ដាច់អស់ ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចកាំបិតនឹងជ្រញ់ ដោយសេចក្តីថាដាច់របិល ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចមុខលំពែង ដោយសេចក្តីថាចាក់ទម្លុះ ឈ្មោះថាវៀរកាម

បឋមោ កាមសុត្តនិទ្ទេសោ

វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ សប្បសិរូបមា កាមា សប្បដិភយដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ អគ្គិក្ខន្ធូបមា កាមា មហាគ្គិតាបនដ្ឋេនាតិ(១) បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ។ ពុទ្ធានុស្សតឹ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ធម្មានុស្សតឹ ភាវេន្តោបិ សង្ឃានុស្សតឹ ភាវេន្តោបិ សីលានុស្សតឹ ភាវេន្តោបិ ចាគានុស្សតឹ ភាវេន្តោបិ ទេវតានុស្សតឹ ភាវេន្តោបិ អានាបានស្សតឹ ភាវេន្តោបិ មរណានុស្សតឹ ភាវេន្តោបិ កាយគតាសតឹ ភាវេន្តោបិ ឧបសមានុស្សតឹ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ។ បឋមំ ឈានំ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ទុតិយំ ឈានំ ភាវេន្តោបិ តតិយំ ឈានំ ភាវេន្តោបិ ចតុត្ថំ ឈានំ ភាវេន្តោបិ អាកាសានញ្ចាយតនសមាបត្តឹ ភាវេន្តោបិ វិញ្ញាណញ្ចាយតនសមាបត្តឹ ភាវេន្តោបិ អាកិញ្ចញ្ញាយតនសមាបត្តឹ ភាវេន្តោបិ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ។

---

១ ឱ.ម. មហាភិតាបនដ្ឋេនាតិ ។

ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចក្បាលពស់វែក ដោយសេចក្តីថា ប្រកបដោយភ័យចំពោះមុខ ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគំនរភ្លើង ដោយសេចក្តីថា ក្តៅពេលពល ដោយភ្លើងធំ ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន ។ បុគ្គលកំពុងចំរើនពុទ្ធានុស្សតិក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កំពុងចំរើនធម្មានុស្សតិក្តី កំពុងចំរើនសង្ឃានុស្សតិក្តី កំពុងចំរើនសីលានុស្សតិក្តី កំពុងចំរើនចាគានុស្សតិក្តី កំពុងចំរើនទេវតានុស្សតិក្តី កំពុងចំរើនអានាបានុស្សតិក្តី កំពុងចំរើនមរណានុស្សតិក្តី កំពុងចំរើនកាយគតាសតិក្តី កំពុងចំរើនឧបសមានុស្សតិក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន ។ បុគ្គលកំពុងចំរើនបឋមជ្ឈានក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កំពុងចំរើនទុតិយជ្ឈានក្តី កំពុងចំរើនតតិយជ្ឈានក្តី កំពុងចំរើន ចតុត្ថជ្ឈានក្តី កំពុងចំរើនអាកាសានញ្ចាយតនសមាបត្តិក្តី កំពុងចំរើន វិញ្ញាណញ្ចាយតនសមាបត្តិក្តី កំពុងចំរើនអាកិញ្ចញ្ញាយតនសមាបត្តិក្តី កំពុងចំរើននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន ។

ឯវំ វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ ។

កថំ សមុច្ឆេទតោ កាមេ បរិវជ្ជេតិ ។ សោតាបត្តិមគ្គំ ភាវេន្តោបិ អបាយគមនីយេ កាមេ សមុច្ឆេទតោ បរិវជ្ជេតិ សកទាគាមិមគ្គំ ភាវេន្តោបិ ឱឡារិកេ កាមេ សមុច្ឆេទតោ បរិវជ្ជេតិ អនាគាមិមគ្គំ ភាវេន្តោបិ អណុសហគតេ កាមេ សមុច្ឆេទតោ បរិវជ្ជេតិ អរហត្តមគ្គំ ភាវេន្តោបិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ សមុច្ឆេទតោ កាមេ បរិវជ្ជេតិ ។ ឯវំ សមុច្ឆេទតោ កាមេ បរិវជ្ជេតីតិ យោ កាមេ បរិវជ្ជេតិ ។

(១៣) សប្បស្សេវ បទា សិរោតិ សប្បោ វុច្ចតិ អហិ ។ កេនដ្ឋេន សប្បោ ។ សំសប្បន្តោ គច្ឆតីតិ សប្បោ ។ ភុជន្តោ គច្ឆតីតិ ភុជគោ ។ ឧរេន គច្ឆតីតិ ឧរគោ ។ បន្នសិរោ គច្ឆតីតិ បន្នគោ ។ សិរេន សុបតីតិ(១) សរីសបោ ។

១ ម. សប្បតីតិ ។

បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន យ៉ាងនេះ ។

បុគ្គលវៀរកាម ដោយការផ្តាច់ផ្តិល តើដូចម្តេច ។ បុគ្គលកាលចំរើនសោតាបត្តិមគ្គ ឈ្មោះថាវៀរកាម ដែលជាហេតុទៅកាន់អបាយ ដោយកិរិយាផ្តាច់ផ្តិល កាលចំរើនសកទាគាមិមគ្គ ឈ្មោះថាវៀរកាម ដ៏គ្រោតគ្រាត ដោយកិរិយាផ្តាច់ផ្តិល កាលចំរើនអនាគាមិមគ្គ ឈ្មោះថា វៀរកាមដ៏ល្អិត ដោយកិរិយាផ្តាច់ផ្តិល កាលចំរើនអរហត្តមគ្គ ឈ្មោះថា វៀរកាម ដោយសព្វគ្រប់ គ្រប់ទាំងអស់ មិនមានសេសសល់ ឥតសេសសល់ ដោយកិរិយាផ្តាច់ផ្តិល ។ បុគ្គលវៀរកាម ដោយការផ្តាច់ផ្តិល យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាវៀរកាមទាំងឡាយ ។

(១៣) ពាក្យថា ដូចបុគ្គលវៀរក្បាលពស់ ដោយជើង អធិប្បាយថា អហិសត្វ លោកហៅថា ពស់ ។ ដែលហៅថា ពស់ ដោយសេចក្តីដូចម្តេច ។ សត្វណាលូនទៅ ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ ។ សត្វណា ពត់ពេន ហេតុនោះ សត្វនោះ ឈ្មោះថា ភុជគៈ ។ សត្វណាទៅដោយទ្រូង ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ ។ សត្វណា មានក្បាលឱនពប ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ ។ សត្វណា លូនទៅដោយក្បាល ហេតុនោះ សត្វនោះ ឈ្មោះថា ពស់ ។

វិលេ សយតីតិ វិលាសយោ[១] ។ គុហាយំ សេតីតិ[២] គុហាសយោ ។ ទាឍា តស្ស អាវុធោតិ ទាឍាវុធោ ។ វិសំ តស្ស ឃោរន្តិ ឃោរវិសោ ។ ជិវ្ហា តស្ស ទុវិធាតិ ទុជិវ្ហោ ។ ទ្វីហិ ជិវ្ហាហិ រសំ សាយតីតិ ទិរសញ្ញូ ។ យថា បុរិសោ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ បាទេន សប្បសិរំ វជ្ជេយ្យ វិវជ្ជេយ្យ បរិវជ្ជេយ្យ អភិនិវជ្ជេយ្យ ឯវមេវ សុខកាមោ ទុក្ខប្បដិក្កូលោ កាមេ វជ្ជេយ្យ វិវជ្ជេយ្យ បរិវជ្ជេយ្យ អភិនិវជ្ជេយ្យាតិ សប្បស្សេវ បទា សិរោ ។

(១៤) សោមំ វិសត្តិកំ លោកេ សតោ សមតិវត្តតីតិ សោតិ យោ កាមេ បរិវជ្ជេតិ ។ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទិ នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា

---

១– វិលសយោតិបិ បាឋោ ។ ២– ម. សយតីតិ ។

## កាមសុត្តនិទ្ទេសទី១

សត្វណាដេកក្នុងរន្ធ ហេតុនោះ សត្វនោះឈ្មោះថា វិលាស័យ ។ សត្វណា ដេកក្នុងគុហា ហេតុនោះ សត្វនោះ ឈ្មោះថា គុហាស័យ ។ សត្វនោះមានចង្កូមជាអាវុធ ហេតុនោះ សត្វនោះឈ្មោះថា ទាឍាវុធ ។ សត្វនោះ មានពិសដ៏ពន្ទឹក ហេតុនោះ សត្វនោះ ឈ្មោះថា ឃោរវិសៈ ។ សត្វនោះមានអណ្តាតពីរ ហេតុនោះ សត្វនោះឈ្មោះថា ទុជិវ្ហ ។ សត្វណា ជញ្ជក់រស ដោយអណ្តាតពីរ ហេតុនោះ សត្វនោះឈ្មោះថា ទិរសញ្ញូ ។ បុរសអ្នកចង់រស់ មិនចង់ស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ គួរវៀរ គួរបៀសចេញ គួរគេចចេញ គួរវៀរស្រឡះចេញ នូវក្បាលពស់ដោយជើង យ៉ាងណា បុគ្គលអ្នកប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ គួរវៀរ គួរបៀសចេញ គួរគេចចេញ គួរវៀរស្រឡះចេញ នូវកាមទាំងឡាយ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចបុគ្គលវៀរក្បាលពស់ ដោយជើង ។

(១៨) អធិប្បាយពាក្យថា បុគ្គលនោះ ជាអ្នកមានសតិ រមែងកន្លងវិសត្តិកាតណ្ហានេះ ក្នុងលោក ត្រង់ពាក្យថា បុគ្គលនោះ គឺបុគ្គលដែលវៀរកាម ។ តណ្ហា លោកហៅថា វិសត្តិកា បានដល់ តម្រេក តម្រេកមានកំឡាំង សេចក្តីកួចកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយ សេចក្តីរីករាយក្នុងតម្រេក តម្រេកមានកំឡាំងរបស់ចិត្ត សេចក្តីប្រាថ្នា

មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ សង្គោ[១] បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សុត្តំ វិសដា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវោ ស្នេហោ អបេក្ខា បដិពន្ធុ អាសា អាសីសនា អាសីសិតត្តំ រូបាសា សទ្ទាសា គន្ធាសា រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា[២] បុត្តាសា ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បា ជប្បនា ជប្បិតត្តំ លោលុប្បា លោលុប្បាយនា លោលុប្បាយិតត្តំ បុច្ឆញ្ជិកតា សាធុកម្យតា អធម្មរាគោ វិសមលោភោ និកន្តិ និកាមនា បត្ថនា បិហនា សម្បត្ថនា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ យោគោ

---

១ សត្តោតិបិ បាឋោ ។ ២ ម. ធិនាសា ។

សេចក្តីជ្រប់ចុះ កិរិយាជប់ចុះ សេចក្តីបំពាក់ចិត្ត សេចក្តីបំពាក់មាំ កិលេស ជាគ្រឿងជាប់ កិលេសដូចកក់ កិរិយាស្វែងរក ការលាក់ពុត កិលេស ជាតិជាគ្រឿងញុំាងសត្វឲ្យកើត គ្រឿងញុំាងទុក្ខឲ្យកើត គ្រឿងចាក់ស្រេះ កិលេសជាតិដូចជាបណ្តាញ កិលេសជាតិហូរទៅ ផ្សាយទៅ ក្រសែ គឺ តណ្ហា កិលេសជាតិដ៏ទូលាយ គ្រឿងញុំាងអាយុឲ្យវិនាស តណ្ហា ជាគំរប់ពីរ គ្រឿងតម្កល់ទុក គ្រឿងនាំសត្វទៅកាន់ភព កិលេស-ជាតិដូចជាព្រៃធំ ដូចជាព្រៃតូច ការស្និទ្ធស្នាល សេចក្តីស្នេហា សេចក្តី អាល័យ សេចក្តីជាប់ចំពាក់ សេចក្តីប៉ុនប៉ង សេចក្តីនឹកដញ្ញឹង ភាព នៃចិត្តនឹកដញ្ញឹង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងបុត្រ បំណងជីវិត ការជាប់ ការជាប់ទ្ញៅ ការជាប់ក្រៃលែង ការជាប់ កិរិយាជាប់ ភាពនៃចិត្តជាប់ ការជក់ស្អិត កិរិយាជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តឡៀបឡប់ ភាពនៃចិត្តប្រាថ្នាក្រៃពេក តម្រេកខុសគន្លងធម៌ សេចក្តីលោភមិនស្មើ សេចក្តីអាល័យ កិលេសជាតិជាទីអាល័យ សេចក្តីប្រាថ្នា សេចក្តី ស្រឡាញ់ សេចក្តីប្រាថ្នាគ្រប់យ៉ាង កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា អន្លង់ គ្រឿងប្រកបទុក

## បឋមោ កាមសុត្តនិទ្ទេសោ

គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆទនំ ពន្ធនំ[១] ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ[២] ទុក្ខប្បភវោ មារបាសោ មារពលិសំ មារវិសយោ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ ។

វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ វិសតាតិ វិសត្តិកា ។ វិសាលាតិ វិសត្តិកា ។ វិសដាតិ វិសត្តិកា ។ វិសក្កតីតិ វិសត្តិកា ។ វិសំហរតីតិ វិសត្តិកា ។ វិសំវាទិកាតិ វិសត្តិកា ។ វិសមូលាតិ វិសត្តិកា ។ វិសផលាតិ វិសត្តិកា ។ វិសបរិភោគាតិ វិសត្តិកា ។ វិសាលា វា បន សា រូបេ តណ្ហា សទ្ទេ គន្ធេ រសេ

---

១ ឆន្ទនន្តិ អដ្ឋកថាយំ ទិស្សតិ ។ ២ ទុក្ខនិទានន្តិបិ បាឋោ ។

គ្រឿងដាក់ស្រះ គ្រឿងប្រកាន់ទុក កិរិយាកកឹង កិរិយាទប់ កិរិយាប្រក់ កិរិយាចង កិរិយាសៅហ្មង កិរិយាដេកនៅរឿយ ៗ កិរិយាស្អាក់ វល្លិគឺតណ្ហា សេចក្តីប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ដែនកើតនៃទុក្ខ អន្ទាក់នៃមារ សន្ទូចនៃមារ វិស័យនៃមារ ស្ទឹងគឺតណ្ហា បណ្ដាញគឺតណ្ហា ដងផ្ទោយគឺតណ្ហា សមុទ្ទគឺតណ្ហា អភិជ្ឈា លោភៈ អកុសលមូល ។

សំនួរត្រង់ពាក្យថា វិសត្តិកា តើវិសត្តិកា ដោយសេចក្ដីដូចម្ដេច ។ តណ្ហាណា ផ្សាយទៅ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ជំទូលាយ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ជ្រួតជ្រាបទៅ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា អត់ទ្រាំ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ប្រមូលផ្សេង ៗ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា ញុំាងសត្វឲ្យពោលខុស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានឫសគល់ជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានផ្លែជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានគ្រឿងបរិភោគជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ មួយទៀត តណ្ហានោះជាកិលេសជាតទូលាយ ផាចសាចទៅ ផ្សាយទៅ ក្នុងរូប សំឡេង ក្លិន រស

ផោដ្ឋព្វេ កុលេ គណេ អាវាសេ លាភេ យសេ
បសំសាយ សុខេ ចីវរេ បិណ្ឌបាតេ សេនាសនេ គិលា-
នប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា
អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ
អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ
ចតុវោការភវេ បញ្ចវោការភវេ អតីតេ អនាគតេ
បច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ វិសដា
វិត្ថតាតិ វិសត្តិកា ។

លោកេតិ អបាយលោកេ មនុស្សលោកេ ទេវ-
លោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេ ។

សតោតិ ចតូហិ ការណេហិ សតោ កាយេ កា-
យានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ វេទនាសុ
ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ
សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ អសតិ-
បរិវជ្ជនាយ សតោ សតិករណីយានំ ធម្មានំ កតត្តា
សតោ សតិប្បដិបក្ខានំ(1) ធម្មានំ ហតត្តា សតោ
សតិនិមិត្តានំ ធម្មានំ អសម្មុដ្ឋត្តា សតោ ។ អបរេ-
ហិបិ ចតូហិ ការណេហិ សតោ សតិយា សមន្នាគតត្តា

---

១ ម. សតិបរិពន្ធានំ ។

ផ្សព្វ ក្នុងត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សុខ ក្នុងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បភេសជ្ជបរិក្ខារ ក្នុងកាមធាតុ រូបធាតុ អរូបធាតុ ក្នុងកាមភព រូបភព អរូបភព ក្នុងសញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ក្នុងកាលជាអតីត អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ទាំងឡាយដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវ-លោក ខន្ធលោក ធាតុលោក អាយតនលោក ។

ពាក្យថា ជាអ្នកមានសតិ គឺមានសតិ ដោយហេតុ ៤ យ៉ាងគឺ មានសតិ កាលបំរើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ក្នុងវេទនាទាំងឡាយ ក្នុងចិត្ត មានសតិ កាលបំរើនធម្មានុបស្សនាសតិ-ប្បដ្ឋាន ក្នុងធម៌ទាំងឡាយ ។ មានសតិ ដោយហេតុ ៤ យ៉ាងទៀត គឺមានសតិ ដោយការវៀរចាកការមិនមានសតិ មានសតិដោយការបានធ្វើធម៌ទាំងឡាយដែលខ្លួនគប្បីធ្វើដោយសតិ មានសតិ ដោយការបានកំចាត់ នូវធម៌ទាំងឡាយជាទីនាសដល់សតិ មានសតិដោយការមិនភ្លេចភ្លាំង នូវធម៌ទាំងឡាយជានិមិត្តរបស់សតិ ។ មានសតិ ដោយហេតុ៤យ៉ាងទៀត គឺមានសតិ ដោយការបានប្រកបដោយសតិ

សតោ សតិយា វសិតត្តា សតោ សតិយា បាគុញ្ញតាយ
សតោ សតិយា អបច្ចោរោហណតាយ សតោ ។
អបរេហិបិ ចតូហិ ការណេហិ សតោ សតត្តា សតោ
សន្តត្តា សតោ សមិតត្តា សតោ សន្តធម្មសមន្នាគ-
តត្តា សតោ ។ ពុទ្ធានុស្សតិយា សតោ ធម្មានុស្សតិ-
យា សតោ សង្ឃានុស្សតិយា សតោ សីលានុស្ស-
តិយា សតោ ចាគានុស្សតិយា សតោ ទេវតានុស-
តិយា សតោ អានាបានស្សតិយា សតោ មរណា-
នុស្សតិយា សតោ កាយគតាសតិយា សតោ ឧប-
សមានុស្សតិយា សតោ ។ យា សតិ អនុស្សតិ បដិស្ស-
តិ សតិ សរណតា ធារណតា អបិលាបនតា អស-
ម្មុស្សនតា សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ សតិ-
សម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។ ឥ-
មាយ សតិយា ឧបេតោ ហោតិ សមុបេតោ ឧបគតោ
សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ
វុច្ចតិ សតោ ។

មានសតិ ព្រោះជាអ្នកឃ្លាត់ក្នុងសតិ មានសតិ ព្រោះជាអ្នកចឹកក្នុងសតិ មានសតិ ព្រោះជាអ្នកមិនឃ្លៀងឃ្លាតចាកសតិ ។ មានសតិដោយហេតុ ៤ យ៉ាង ផ្សេងទៀតគឺ មានសតិ ព្រោះជាអ្នកមានស្មារតី មានសតិ ព្រោះជាអ្នកស្ងប់ មានសតិ ព្រោះជាអ្នករម្ងាប់ មានសតិ ព្រោះជាអ្នកប្រកបដោយសប្បុរិសធម៌ ។ មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះព្រះពុទ្ធ មានសតិ ព្រោះការរលឹករឿយៗ ចំពោះព្រះធម៌ មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះព្រះសង្ឃ មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះសីល មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះការលះ មានសតិ ព្រោះការរលឹករឿយៗ ចំពោះគុណធម៌នៃទេវតា មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះខ្យល់ដង្ហើមចេញចូល មានសតិ ព្រោះការរលឹករឿយៗ ចំពោះមរណៈ មានសតិ ព្រោះការរលឹករឿយៗ ចំពោះកាយ មានសតិ ព្រោះការរលឹករឿយ ៗ ចំពោះឧបសមៈគឺនិព្វាន ។ កិរិយារលឹក រលឹករឿយៗ រលឹកចំពោះ ឈ្មោះថាសតិ ភាពនៃកិរិយារលឹក ភាពនៃកិរិយាចាំទុក ភាពនៃកិរិយាមិនភ្លេចភ្លាំង ភាពនៃកិរិយាមិនវង្វេង ឈ្មោះថាសតិ សតិន្ទ្រិយ សតិពលៈ សម្មាសតិ សតិសម្ពោជ្ឈង្គ ឯកាយនមគ្គ (ផ្លូវជាទីប្រព្រឹត្តទៅនៃបុគ្គលម្នាក់ឯង) នេះលោកហៅថាសតិ ។ បុគ្គលណា កៀកកើយ អែបនែប ចូលទៅជិត ចូលផ្ដុកផ្ដិត មូលមិត្រ បរិបូណ៌ ប្រកបដោយសតិនេះ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។

សោ ឥមំ វិសត្តិកំ លោកេ សតោ សមតិវត្តតីតិ យា លោកេ វិសត្តិកា ឥមំ លោកេ វិសត្តិកំ សតោ តរតិ ឧត្តរតិ បតរតិ សមតិក្កមតិ វីតិវត្តតីតិ សោ ឥមំ វិសត្តិកំ លោកេ សតោ សមតិវត្តតិ ។ តេនាហ ភគវា

យោ កាមេ បរិវជ្ជេតិ សប្បស្សេវ បទា សិរោ
សោ ឥមំ វិសត្តិកំ លោកេ សតោ សមតិវត្តតីតិ ។

(១៥) ខេត្តំ វត្ថុំ ហិរញ្ញំ វា គវស្សំ ទាសបោរិសំ
ថិយោ ពន្ធូ បុថូ កាមេ យោ នរោ អនុគិជ្ឈតិ ។

(១៦) ខេត្តំ វត្ថុំ ហិរញ្ញំ វាតិ ខេត្តន្តិ សាលិក្ខេត្តំ វីហិក្ខេត្តំ មុគ្គក្ខេត្តំ មាសក្ខេត្តំ យវក្ខេត្តំ គោធុមក្ខេត្តំ តិលក្ខេត្តំ ។ វត្ថុន្តិ ឃរវត្ថុ កោដ្ឋវត្ថុ បុរេវត្ថុ បច្ឆាវត្ថុ អារាមវត្ថុ វិហារវត្ថុ ។ ហិរញ្ញន្តិ ហិរញ្ញំ វុច្ចតិ កហាបណោតិ ខេត្តំ វត្ថុំ ហិរញ្ញំ វា ។

ពាក្យថា បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លងនូវវិសត្តិកាតណ្ហា នេះ ក្នុងលោក សេចក្តីថា តណ្ហាឈ្មោះវិសត្តិកាណា ក្នុងលោក បុគ្គលមានស្មារតី រមែងឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវតណ្ហាឈ្មោះវិសត្តិកានេះ ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លងនូវវិសត្តិកាតណ្ហានេះ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា វៀរកាមទាំងឡាយ ដូចបុគ្គលវៀរក្បាលពស់
ដោយជើង បុគ្គលនោះ ជាអ្នកមានស្មារតី រមែងកន្លង
នូវវិសត្តិកាតណ្ហានេះ ក្នុងលោក ។

(១៨) ជនណា ប្រាថ្នាស្រើប ៗ នូវស្រែ ទីកន្លែង ប្រាក់ គោ សេះ
ទាសៈនិងពួកបុរស ស្ត្រី ផៅពង្សឬកាមទាំងឡាយ ច្រើន ។

(១៦) អធិប្បាយពាក្យថា ស្រែ ទីកន្លែង ប្រាក់ ត្រង់ពាក្យថា ស្រែ គឺ ស្រែស្រូវសាលី ស្រែស្រូវធម្មតា ចម្ការសណ្តែកបាយ ចម្ការសណ្តែកពជមាស ស្រែស្រូវដំណើប ស្រែស្រងែ ចម្ការល្ង ។ ពាក្យថា ទីកន្លែង គឺទីផ្ទះ ទីជង្រុក ទីមុខ (ផ្ទះ) ទីក្រោយ (ផ្ទះ) ទីសួនទីកន្លែងនៅ ។ កហាបណៈ លោកហៅថា ប្រាក់ ក្នុងបទថា ប្រាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) ស្រែ ទីកន្លែង ប្រាក់ ។

(១៧) គវស្សំ ទាសបោរិសន្តិ គវន្តិ គាវោ វុច្ចន្តិ ។ អស្សាតិ បសុកាទយោ វុច្ចន្តិ ។ ទាសាតិ ចត្តារោ ទាសា អន្តោជាតកោ ទាសោ ធនក្កីតកោ ទាសោ សាមំ វា ទាសវិយំ ឧបេតិ អកាមកោ វា ទាសវិយំ ឧបេតិ ។

អាមាយ ទាសាបិ ភវន្តិ ហេកេ
ធនេន កីតាបិ ភវន្តិ ទាសា
សាមញ្ច ឯកេ ឧបយន្តិ ទាសំ
ភយាបនុណ្ណាបិ ភវន្តិ ទាសា ។

បោរិសន្តិ តយោ បុរិសា ភដកា កម្មករា ឧបជីវិនោតិ គវស្សំ ទាសបោរិសំ ។

(១៨) ថិយោ ពន្ធូ បុថុ កាមេតិ ថិយោតិ ឥត្ថីបរិគ្គ-ហោ វុច្ចតិ ។ ពន្ធូតិ ចត្តារោ ពន្ធូ ញាតិពន្ធុបិ ពន្ធុ គោត្តពន្ធុបិ ពន្ធុ មន្តពន្ធុបិ ពន្ធុ សិប្បពន្ធុបិ ពន្ធុ ។

## កាមសុត្តនិទ្ទេស ទី ១

(១៧) ពាក្យថា គោ សេះ ទាសៈ នឹងពួកបុរស អធិប្បាយថា គោទាំងឡាយ លោកហៅថាគោ ។ ពួកសត្វ មានសត្វចិញ្ចឹមជាដើម លោក ហៅថា សេះ ។ ពាក្យថា ទាសៈ បានដល់ខ្ញុំ ៤ ពួក គឺខ្ញុំដែលកើតខាងក្នុងផ្ទះ(១) ១ ខ្ញុំដែលលោះ ដោយទ្រព្យ ១ បុគ្គលដែលចូលមកជាខ្ញុំដោយខ្លួនឯង ១ បុគ្គល ដែលមិនមានប្រាជ្ញា តែចូលមកជាខ្ញុំ(២) ១ ។

បុគ្គលពួកមួយ ជាខ្ញុំកើតអំពីទាសីក៏មាន ជាខ្ញុំដែលគេលោះ
ដោយទ្រព្យក៏មាន បុគ្គលពួកមួយ ចូលមកជាខ្ញុំដោយខ្លួនឯង
ក៏មាន បុគ្គលដែលត្រូវភ័យគ្របសង្កត់មកធ្វើជាខ្ញុំក៏មាន ។

ពាក្យថាពួកបុរស បានដល់បុរស ៣ ពួក គឺអ្នករាជការ ១ កម្មករ ១ អ្នកជំនួញ ១ ហេតុនោះ (ទ្រង់ត្រាស់ថា) គោ សេះ ទាសៈ នឹងពួកបុរស ។

(១៨) ពាក្យថា ស្ត្រី ផៅពង្ស ឬកាមទាំងឡាយច្រើន អធិប្បាយថា ស្ត្រីជាភរិយា លោកហៅថា ស្ត្រី ។ ពាក្យថា ផៅពង្ស បានដល់ផៅពង្ស ៤ ពួក គឺផៅពង្សជាប់ដោយញាតិ ១ ផៅពង្សជាប់ដោយគោត្រ ១ ផៅពង្សជាប់ដោយមន្ត ១(៣) ផៅពង្សជាប់ដោយសិល្បសាស្ត្រ ១(៤) ។

---

១ បានដល់ ខ្ញុំដែលកើតឡើង ក្នុងផ្ទៃម្តាយជាខ្ញុំគេស្រាប់ ។ ២ បានដល់ ខ្ញុំដែលគេរឹបជាន់ យកទាំងអំណាច ។ អដ្ឋកថា ។ ៣–៤ បុគ្គលដែលបានរៀនមន្ត ឬសិល្បៈ ក្នុងសំណាក់អាចារ្យជាមួយគ្នា ហៅថា មន្តពន្ធុ សិប្បពន្ធុ ។ អដ្ឋកថា ។

បុថុ កាមេតិ ពហូ កាមេ ។ យេ វា បុថុ កាមា មនា-
បិកា រូបា ។ បេ ។ មនាបិកា ផោដ្ឋព្វាតិ ឥតិយោ ពហូ
បុថុ កាមេ ។

(១៩) យោ នរោ អនុគិជ្ឈតីតិ យោតិ យោ យា-
ទិសោ យថាយុត្តោ យថាវិហិតោ យថាបការោ
យំឋានប្បត្តោ យំធម្មសមន្នាគតោ ខត្តិយោ វា ព្រាហ្ម-
ណោ វា វេស្សោ វា សុទ្ទោ វា គហដ្ឋោ វា បព្វជិតោ វា
ទេវោ វា មនុស្សោ វា ។ នរោតិ សត្តោ នរោ មានវោ
បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគុ មនុជោ ។
អនុគិជ្ឈតីតិ កិលេសកាមេន វត្ថុកាមេសុ គិជ្ឈតិ
អនុគិជ្ឈតិ បលិគិជ្ឈតិ បលិពជ្ឈតីតិ យោ នរោ
អនុគិជ្ឈតិ ។ តេនាហ គាថា

ខេត្តំ វត្ថុំ ហិរញ្ញំ វា គវស្សំ ទាសបោរិសំ
ថិយោ ពន្ធូ បុថុ កាមេ យោ នរោ អនុគិជ្ឈតីតិ ។

(២០) អពលា នំ ពលីយន្តិ មទ្ទន្តេ នំ បរិស្សយា

ពាក្យថា កាមទាំងឡាយច្រើន គឺកាមមានប្រមាណច្រើន ។ កាមមានប្រមាណច្រើននុ៎ះ គឺរូបទាំងឡាយជាទីគាប់ចិត្ត ។បេ។ ផ្សព្វជាទីគាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) ស្ត្រី ផៅពង្ស កាមទាំងឡាយ ច្រើន ។

(១៩) អធិប្បាយពាក្យថា ជនណាប្រាថ្នារឿយៗ ត្រង់ពាក្យថា ជនណា គឺបុគ្គលណា បែបណា ប្រកបដោយប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់នូវឋានៈណា ប្រកបដោយធម៌ណា ទោះបីជាក្សត្រ ឬព្រាហ្មណ៍ ជាវេស្សៈ ឬសុទ្រៈ ជាគ្រហស្ថ ឬបព្វជិត ជាទេវតា ឬមនុស្ស ។ ពាក្យថា ជន បានដល់ សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ប្រាថ្នារឿយៗ គឺចង់បាន ប្រាថ្នារឿយៗ ជាប់ចិត្ត ញ៉ាម ក្នុងវត្ថុកាមទាំងឡាយ ដោយសារកិលេសកាម ហេតុនោះ (ទ្រង់ត្រាស់ថា) ជនណាប្រាថ្នារឿយៗ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ជនណាប្រាថ្នារឿយៗ នូវស្រែ ទីកន្លែង ប្រាក់ គោ សេះ
ទាសៈនិងពួកបុរស ស្ត្រី ផៅពង្ស ឬកាមទាំងឡាយច្រើន ។
(២០) កិលេសមិនមានកំឡាំងទាំងឡាយ រមែងសង្កត់សង្កិន
បុគ្គលនោះ[1] អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ

១ សំដៅយកបុគ្គលប្រាសចាកពលៈ ៥ ប្រការមានសទ្ធាពលៈជាដើម ។ អដ្ឋកថា ។

តតោ នំ ទុក្ខមន្វេតិ នាវំ ភិន្នមិវោទកំ ។

(៤១) អពលា នំ ពលីយន្តីតិ អពលាតិ អពលា កិលេសា ទុព្វលា អប្បពលា អប្បថាមកា ហីនា និហីនា បរិហីនា ឱមកា លាមកា ជតុក្កា បរិត្តា ។ តេ កិលេសា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តីតិ ឯវម្បិ អពលា នំ ពលីយន្តិ ។ អថវា អពលំ បុគ្គលំ ទុព្វលំ អប្បពលំ អប្បថាមកំ ហីនំ និហីនំ បរិហីនំ ឱមកំ លាមកំ ជតុក្កំ បរិត្តំ យស្ស នត្ថិ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ហិរិពលំ ឱត្តប្បពលំ តេ កិលេសា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តីតិ ឯវម្បិ អពលា នំ ពលីយន្តិ ។

## កាមសុត្តនិទ្ទេសទី១

*ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះអត្តភាពនោះ ដូច*

*ជាទឹក កាលជ្រាបចូលកាន់នាវា ដែលបែកធ្លាយ ៗ*

(៥១) អធិប្បាយពាក្យថា កិលេស មិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ គឺពាក្យថា កិលេសមិនមានកម្លាំងទាំងឡាយ គឺកិលេសទាំងឡាយ មិនមានកម្លាំង មានកម្លាំងថយ មានកម្លាំងតិច មានសេចក្តីប្រឹងប្រែងតិច ថោកទាប ស្តួចស្តើង អូនថយ ជ្រោកជ្រោក លាមក អាក្រក់ តិចតួច ៗ កិលេសទាំងឡាយនោះ រមែងញាំញី ទន្ទ្រាន សង្កត់ គ្របសង្កត់ រួបរឹត ឈ្លបឈ្លីបុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិន បុគ្គលនោះ យ៉ាងនេះខ្លះ ៗ មួយទៀត កិលេសទាំងឡាយនោះ រមែងញាំញី ទន្ទ្រាន សង្កត់ គ្របសង្កត់ រួបរឹត ឈ្លបឈ្លីនូវបុគ្គលមិនមានកម្លាំង មានកម្លាំងថយ មានកម្លាំងតិច មានសេចក្តីប្រឹងប្រែងតិច ថោកទាប ស្តួចស្តើង អូនថយ ជ្រោកជ្រោក លាមក អាក្រក់ តិចតួច នូវបុគ្គល ដែលមិនមានកម្លាំងគឺសទ្ធា កម្លាំងគឺព្យាយាម កម្លាំងគឺសតិ កម្លាំងគឺសមាធិ កម្លាំងគឺបញ្ញា កម្លាំងគឺហិរិ កម្លាំងគឺឱត្តប្បៈ ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គលនោះ យ៉ាងនេះខ្លះ ៗ

(២២) មន្ត្វា នំ បរិស្សយានិ បរិស្សយានិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។

កតមេ បាកដបរិស្សយា ។ សីហា ព្យគ្ឃា ទីបិ អច្ឆតរច្ឆា កោកា គោមហឹសា ហត្ថី អហិ វិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា វា កតកម្មា វា អកតកម្មា វា ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌាហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សូលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ

(៤៤) អធិប្បាយពាក្យថា អន្តរាយទាំងឡាយ រមែងញាំញីបុគ្គល នោះ ត្រង់ពាក្យថា អន្តរាយទាំងឡាយ សំដៅយកអន្តរាយ ២ យ៉ាងគឺ អន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។

អន្តរាយប្រាកដ តើដូចម្ដេច ។ សីហៈ ខ្លាធំ ខ្លាដម្បង ខ្លាឃ្មុំទីន ខ្លាត្រី ឆ្កែ គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកមាណព កំពុងលួចក្ដី ធ្វើចោរកម្មហើយក្ដី (១) មិនទាន់ធ្វើចោរកម្មហើយក្ដី (២) រោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្ដាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់ធ្មេញ រោគក្អក រោគហឺត រោគក្រៅច្រមុះ រោគគ្រុនក្ដៅក្រហាយ រោគរីងរៃ រោគក្នុងពោះ រោគខ្យល់ចាប់ រោគធ្លាក់ឈាម រោគចុកសៀត ចុះរាក ឃ្លង់ រោគពក ស្រែង ស្រកីអណ្ដើង ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគអេះក្លាយ ឃ្លង់ដែក មួលឈាម រោគប្រមាត់ ប្រមេះទឹកបាយ ឫសដូងដុះ ក្អកឈាម ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំនៃ (ខ្យល់ប្រមាត់ស្លេស្ម) អាពាធកើតអំពីការផ្លាស់ប្ដូររដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីសេចក្ដីព្យាយាមខ្លាំង (៣) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ

---

១ សំដៅកំពុងកាត់ផ្ទាំងជាដើម ។ ២ ទើបនឹងចេញទៅ ។ ន័យអដ្ឋកថា ។

៣ អាពាធនេះ កើតអំពីការបៀតបៀន របស់អ្នកដទៃ មានសម្លាប់ឬចងជាដើម។ អដ្ឋកថា។

ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសរីសបសម្ផស្សា ឥតិ វា ឥមេ វុច្ចន្តិ បាកដបរិស្សយា ។

កតមេ បដិច្ឆន្នបរិស្សយា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ឥមេ វុច្ចន្តិ បដិច្ឆន្នបរិស្សយា ។

បរិស្សយាតិ កេនដ្ឋេន បរិស្សយា ។ បរិសហន្តីតិ បរិស្សយា ។ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តត្រាសយាតិ បរិស្សយា ។

កថំ បរិសហន្តីតិ បរិស្សយា ។ តេ បរិស្សយា តំ

ឃ្លាន ស្រេក ទុច្ចារៈ បស្សាវៈ សម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់តូចពស់ធំទាំងឡាយ ទាំងនេះ លោកហៅថា អន្តរាយប្រាកដ ដូច្នេះឯង ។

អន្តរាយកំបាំង តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ សេចក្តីក្រោធ ការចងក្រោធទុក ការលុបលាងគុណអ្នកដទៃ ការលើកខ្លួន សេចក្តីឈ្នានីស សេចក្តីកំណាញ់ ពុតត្បុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ខ្លួន ការមើលងាយគេ សេចក្តីស្រវឹង សេចក្តីប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ ទាំងនេះ លោកហៅថា អន្តរាយកំបាំង ។

សំនួរត្រង់ពាក្យថា អន្តរាយ តើអន្តរាយ ដោយអត្ថថាដូចម្តេច ។ អន្តរាយ ព្រោះហេតុទន្ទ្រាន អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស អន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

អន្តរាយព្រោះហេតុទន្ទ្រាន តើដូចម្តេច ។ អន្តរាយទាំងឡាយនោះ

បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តិ ។ ឯវំ បរិសហន្តីតិ បរិស្សយា ។

កថំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តេ បរិស្សយា កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ កតមេសំ កុសលានំ ធម្មានំ ។ សម្មាបដិបទាយ អនុលោមប្បដិបទាយ អបច្ចនីកប្បដិបទាយ អន្វត្ថប្បដិបទាយ ធម្មានុធម្មប្បដិបទាយ សីលេសុ បរិបូរការិតាយ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ភោជនេ មត្តញ្ញុតាយ ជាគរិយានុយោគស្ស សតិសម្បជញ្ញស្ស ចតុន្នំ សតិបដ្ឋានានំ ភាវនានុយោគស្ស ចតុន្នំ សម្មប្បធានានំ ភាវនានុយោគស្ស ចតុន្នំ ឥទ្ធិបាទានំ ភាវនានុយោគស្ស បញ្ចន្នំ ឥន្ទ្រិយានំ ភាវនានុយោគស្ស បញ្ចន្នំ ពលានំ ភាវនានុយោគស្ស សត្តន្នំ ពោជ្ឈង្គានំ ភាវនានុយោគស្ស អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគស្ស

ញាំញី ទន្ទ្រាន គ្របសង្កត់ រួបរឹត បំផ្លាញ ញាំញាក់ នូវបុគ្គលនោះ ។ អន្តរាយ ព្រោះហេតុទន្ទ្រាន យ៉ាងនេះ ។

អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស តើដូចម្តេច ។ អន្តរាយទាំងនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយជាកុសល ។ ធម៌ទាំងឡាយជាកុសល តើដូចម្តេច ។ អន្តរាយទាំងឡាយនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដើម្បីអន្តរាយដល់ធម៌ទាំងឡាយជាកុសលទាំងនេះ គឺសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិមិនជាសត្រូវ សេចក្តីប្រតិបត្តិសមគួរដល់អត្ថ សេចក្តីប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ភាពនៃបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពនៃបុគ្គលអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវធម៌ជាគ្រឿងភ្ញាក់រលឹក សតិនិងសម្បជញ្ញៈ ការប្រកបរឿយ ៗ ក្នុងកិរិយាចំរើនសតិប្បដ្ឋាន៤ ការប្រកបរឿយៗក្នុងកិរិយាចំរើនសម្មប្បធាន៤ ការប្រកបរឿយៗ ក្នុងកិរិយាចំរើនឥទ្ធិបាទ ៤ ការប្រកបរឿយ ៗ ក្នុងកិរិយាចំរើនឥន្ទ្រិយ ៥ ការប្រកបរឿយៗ ក្នុងកិរិយាចំរើនពលៈ ៥ ការប្រកបរឿយ ៗ ក្នុងកិរិយាចំរើនពោជ្ឈង្គ ៧ ការប្រកបរឿយៗ ក្នុងកិរិយាចំរើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ។

## បឋមោ កាមសុត្តនិទ្ទេសោ

ឥមេសំ កុសលានំ ធម្មានំ បរិហានាយ អន្តរាយាយ សំវត្តន្តិ ។ ឯវំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។

កថំ តត្រាសយាតិ បរិស្សយា ។ តត្ថេតេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយា ។ យថា ពិលេ ពិលាសយា បាណា សយន្តិ ទកេ ទកាសយា បាណា សយន្តិ វនេ វនាសយា បាណា សយន្តិ រុក្ខេ រុក្ខាសយា បាណា សយន្តិ ឯវមេវំ តត្ថេតេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយាតិ ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ ។

## កាមសុត្តនិទ្ទេស ទី ១

អន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស យ៉ាងនេះ ។

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ តើដូចម្តេច ។ ធម៌ទាំងឡាយដ៏លាមក ជាអកុសលទុះ អាស្រ័យនៅក្នុងអត្តភាព កើតឡើង ក្នុងសរីរៈនោះ ។ ពួកសត្វ អាស្រ័យនៅក្នុងរន្ធ ដេកនៅក្នុងរន្ធ ពួកសត្វអាស្រ័យនៅក្នុងទឹក ដេកនៅក្នុងទឹក ពួកសត្វអាស្រ័យនៅក្នុងព្រៃ ដេកនៅក្នុងព្រៃ ពួកសត្វ អាស្រ័យនៅលើដើមឈើ ដេកនៅលើដើមឈើ យ៉ាងណាមិញ ធម៌ទាំងឡាយដ៏លាមក ជាអកុសលទុះ អាស្រ័យនៅ ក្នុងអត្តភាព កើតឡើង ក្នុងសរីរៈនោះ យ៉ាងនោះដែរ ព្រោះហេតុនោះ អន្តរាយ ព្រោះអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នក នៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិន សប្បាយ តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌

ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ យេ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ យេ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតីតិ ។

ទាំងឡាយដ៏លាមក ជាអកុសល ណា ជាសេចក្តីត្រិះរិះ ដោយអំណាច នៃកិរិយាលើកឃើញ ជាទីតាំងនៃសំយោជនៈ កើតឡើងដល់ភិក្ខុ ក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងសន្តាន នៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្តេវាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ធម៌ទាំងឡាយដ៏លាមក ជាអកុសលណា ជាសេចក្តីត្រិះរិះដោយកិរិយាលើកឃើញ ជាទីតាំងនៃសំយោជនៈ កើតឡើងដល់ភិក្ខុ ព្រោះស្តាប់សម្លេងដោយត្រចៀក ហិតក្លិនដោយច្រមុះ លិទ្ធរសដោយអណ្តាត ប៉ះពាល់ផ្សព្វដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងនៅ រមែងជាប់តាមក្នុងសន្តាននៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអន្តេវាសិក ធម៌ទាំងឡាយដ៏លាមក ជាអកុសលនោះ រមែងត្រួតត្រាភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅជាមួយអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅជាមួយអន្តេវាសិក អ្នកនៅជាមួយអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយដោយប្រការយ៉ាងនេះឯង ។

ឯវម្បិ អន្តរាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោមេ ភិក្ខវេ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកា ។ កតមេ តយោ ។ លោភោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ទោសោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ មោហោ ភិក្ខវេ អន្តរាមលោ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ។ ឥមេ ខោ ភិក្ខវេ តយោ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកាតិ ។

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ

## កាមសុត្តនិទ្ទេស ទី ១

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ នេះ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ធម៌ទាំងឡាយ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាអមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាបច្ចាមិត្តខាងក្នុង ។

លោភៈជាកិលេសញុំាងសេចក្តីវិនាសឲ្យកើត លោភៈជាកិលេសញុំាងចិត្តឲ្យកំរើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកលោភ រមែងមិនដឹងអត្ថ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌ លោភៈគ្របសង្កត់ជនណា សេចក្តីងងឹតឈឹងសូន្យ (នៃជននោះ) ក៏រមែងមាន ក្នុងកាលនោះ

អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
កុទ្ធោ អត្ថំ ន ជានាតិ កុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ
អនត្ថជននោ មោហោ មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ មោហោ សហតេ នរន្តិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា តយោ ខោ មហារាជ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ។ កតមេ តយោ ។ លោភោ ខោ មហារាជ បុរិសស្ស ធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ

ទោសៈ ជាកិលេសញ៉ាំងសេចក្តីវិនាសឲ្យកើត ទោសៈជាកិលេសញ៉ាំងចិត្តឲ្យកំរើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកក្រោធ រមែងមិនដឹងអត្ថ បុគ្គលអ្នកក្រោធ រមែងមិនឃើញធម៌ សេចក្តីក្រោធគ្របសង្កត់ជនណា សេចក្តីងងឹតឈឹងសូន្យ (នៃជននោះ) ក៏រមែងមាន ក្នុងកាលនោះៗ មោហៈ ជាកិលេសញ៉ាំងសេចក្តីវិនាសឲ្យកើត មោហៈជាកិលេសញ៉ាំងចិត្តឲ្យកំរើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់ នូវភ័យនោះទេ បុគ្គលអ្នកវង្វេង រមែងមិនដឹងអត្ថ បុគ្គលអ្នកវង្វេង រមែងមិនឃើញធម៌ មោហៈគ្របសង្កត់ជនណា សេចក្តីងងឹតឈឹងសូន្យ (នៃជននោះ) ក៏រមែងមាន ក្នុងកាលនោះ ៗ អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

ន័យមួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ បុរិសធម៌ (ធម៌របស់បុរស) ៣ កាលកើតឡើងក្នុងសន្តាន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ ។ បុរិសធម៌ ៣ តើដូចម្តេច ។ បពិត្រមហារាជ លោភៈ ជាបុរិសធម៌ កាលកើតឡើងក្នុងសន្តាន រមែងកើតឡើង

អហិតាយ ទុក្ខាយ អផាសុវិហារាយ ទោសោ ខោ មហារាជ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ មោហោ ខោ មហារាជ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ។ ឥមេ ខោ មហារាជ តយោ បុរិសស្ស ធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

លោភោ ទោសោ ច មោហោ ច បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា តចសារំវ សម្ផលន្តិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

វុត្តំ ហេតំ ភគវតា

រាគោ ច ទោសោ ច ឥតោនិទានា
អរតី រតិ លោមហំសោ ឥតោ ជាតោ
ឥតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជន្តីតិ ។

## កាមសុត្តនិទ្ទេស ទី ១

ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហារាជ ទោសៈ ជាបុរិសធម៌ កាលកើតឡើងក្នុងសន្តាន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ បពិត្រមហារាជ មោហៈជាបុរិសធម៌ កាលកើតឡើងក្នុងសន្តាន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីការនៅមិនសប្បាយ ។ បពិត្រមហារាជ បុរិសធម៌ ៣ នេះឯង កាលកើតឡើងក្នុងសន្តាន រមែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ ដើម្បីការនៅមិនសប្បាយ ។

លោភៈ ទោសៈ នឹងមោហៈ កើតអំពីខ្លួន រមែងបៀតបៀន
នូវបុរស អ្នកមានចិត្តអាក្រក់ ដូចជាឈើមានសំបកជាខ្លឹម
(ឫស្សី) ដែលវិនាសដោយសារផ្លែរបស់ខ្លួន ។

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ មួយវិញទៀត ពាក្យនោះ ព្រះមានព្រះភាគត្រាស់ថា

រាគៈនឹងទោសៈ មានអត្តភាពនេះជាហេតុ សេចក្តីមិនត្រេក
អរ នឹងសេចក្តីត្រេកអរ នឹងការព្រឺរោម កើតអំពីអត្តភាព
នេះ មនោវិតក្កៈទាំងឡាយតាំងឡើងហើយ អំពីអត្តភាព
នេះ លែងទៅ (នូវចិត្ត) ដូចជាកុមារបង់បន្ទាយនូវក្អែក ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

មទ្ទន្តេ នំ បរិស្សយាតិ តេ បរិស្សយា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ មទ្ទន្តីតិ មទ្ទន្តេ នំ បរិស្សយា ។

(២៣) តតោ នំ ទុក្ខមន្វេតីតិ តតោ តតោ បរិស្សយតោ តំ បុគ្គលំ ទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ជាតិទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ជរាទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ព្យាធិទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ មរណទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ នេរយិកទុក្ខំ តិរច្ឆានយោនិកទុក្ខំ បេត្តិវិសយិកទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ មានុសិកទុក្ខំ គព្ភោក្កន្តិមូលកទុក្ខំ គព្ភេ ឋិតិមូលកទុក្ខំ គព្ភា វុដ្ឋានមូលកទុក្ខំ ជាតស្សូបនិពន្ធកទុក្ខំ ជាតស្ស បរាធេយ្យកទុក្ខំ អត្តុបក្កមទុក្ខំ បរូបក្កមទុក្ខំ អន្វេតិ

អន្តរាយ ព្រោះហេតុអាស្រ័យ ក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

ពាក្យថា អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ បានសេចក្តីថា អន្តរាយទាំងឡាយនោះ រមែងទន្ទ្រាន ជះជាន់ គ្របសង្កត់ រួបរឹត បំផ្លាញ ញាំញីនូវបុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ ។

(៤៣) ពាក្យថា ទុក្ខ រមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ អធិប្បាយថា ទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម នូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះ ។ គឺជាតិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ជរាទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ព្យាធិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម មរណទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខក្នុងនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ទុក្ខក្នុងពួកមនុស្ស ទុក្ខមានកិរិយាចុះកាន់គភ៌ជាមូល ទុក្ខមានកិរិយាតាំងនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខប្រកបដោយគ្រឿងចង (ថែទាំ) របស់សត្វដែលកើតហើយ ទុក្ខព្រោះអាស្រ័យអ្នកដទៃ របស់សត្វដែលកើតហើយ ទុក្ខព្រោះការព្យាយាមរបស់ខ្លួន ទុក្ខព្រោះការព្យាយាមរបស់អ្នកដទៃ រមែងជាប់តាម

អនុគច្ឆតិ អន្វាយិកំ ហោតិ ទុក្ខទុក្ខំ អន្វេតិ អនុ-
គច្ឆតិ អន្វាយិកំ ហោតិ សង្ខារទុក្ខំ វិបរិណាមទុក្ខំ ច-
ក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយ-
រោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ
កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ
មុច្ឆា បក្ខន្ទិកា សូលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលា-
សោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិ-
កា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទ-
លា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា
វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិ-
ណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិ-
កា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិ-
ឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតប-
សរីសបសម្ផស្សទុក្ខំ មាតុមរណទុក្ខំ បិតុមរណទុក្ខំ
ភាតុមរណទុក្ខំ ភគិនីមរណទុក្ខំ បុត្តមរណទុក្ខំ ធី-
តុមរណទុក្ខំ ញាតិព្យសនទុក្ខំ ភោគព្យសនទុក្ខំ
រោគព្យសនទុក្ខំ សីលព្យសនទុក្ខំ ទិដ្ឋិព្យសនទុក្ខំ

ទៅតាម ប្រព្រឹត្តតាម ទុក្ខទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម សង្ខារទុក្ខ វិបរិណាមទុក្ខ រោគក្នុងភ្នែក រោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្ដាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគត្រង់ធ្មេញ រោគក្អក រោគហឺត រោគក្រៅច្រមុះ រោគគ្រុនក្ដៅក្រហាយ រោគរង៉ៃ រោគក្នុងពោះ ខ្យល់ចាប់ រោគធ្លាក់ឈាម ចុកសៀត ចុះរាក ឃ្លង់ រោគពក ស្រែង ស្រកអណ្ដើន ឆ្អឹតជ្រូក ជំនួចពិស រមាស់ កម រោគអេះក្លាយ ឃ្លង់ដែក មួលឈាម រោគប្រមាត់ ប្រមេះទឹកផ្ញាយ ឫសដូងដុះ ក្អកឈាម ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំ (នៃខ្យល់ប្រមាត់ស្លេស្ម) អាពាធកើតអំពីការផ្លាស់ប្ដូររដូវ អាពាធកើតអំពីរក្សាឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីសេចក្ដីព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំ ទុក្ខព្រោះកិរិយាស្លាប់នៃមាតា ទុក្ខព្រោះកិរិយាស្លាប់នៃបិតា ទុក្ខព្រោះកិរិយាស្លាប់នៃបងប្អូនប្រុស ទុក្ខព្រោះកិរិយាស្លាប់នៃបងប្អូនស្រី ទុក្ខព្រោះកិរិយាស្លាប់កូនប្រុស ទុក្ខព្រោះកិរិយាស្លាប់កូនស្រី ទុក្ខព្រោះវិនាសញាតិ ទុក្ខព្រោះវិនាសភោគសម្បត្តិ ទុក្ខព្រោះវិនាសគឺរោគ ទុក្ខព្រោះវិនាសសីល ទុក្ខព្រោះវិនាសគឺទិដ្ឋិ

អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតីតិ តតោ នំ ទុក្ខ-
មន្វេតិ ។

(២៤) នាវំ ភិន្នមិវោទកន្តិ យថា ភិន្នំ នាវំ ឧទកំ អន្វាយិកំ(១) តតោ តតោ ឧទកំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ បុរតោបិ ឧទកំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ បច្ឆតោបិ ហេដ្ឋតោបិ បស្សតោបិ ឧទកំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ឯវមេវ តតោ តតោ បរិស្សយា តំ បុគ្គលំ ទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ជាតិទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតិ ។ បេ ។ ទិដ្ឋិព្យសនទុក្ខំ អន្វេតិ អនុគច្ឆតិ អន្វាយិកំ ហោតីតិ នាវំ ភិន្នមិវោទកំ ។

តេនាហ ភគវា

អពលា នំ ពលីយន្តិ មទ្ទន្តេ នំ បរិស្សយា
តតោ នំ ទុក្ខមន្វេតិ នាវំ ភិន្នមិវោទកន្តិ ។

---

១ ម. ឧទកំ អន្វាយិកន្តិ ន ទិស្សតិ ។

រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម (នូវបុគ្គលនោះ) ហេតុនោះ (ទ្រង់ត្រាស់ថា) ទុក្ខរមែងជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ។

[ ៦៤ ] ពាក្យថា ដូចជាទឹកកាលជ្រាបចូល កាន់នាវាដែលបែកធ្លាយ សេចក្តីថា ទឹកប្រព្រឹត្តតាមទូក ដែលបែកធ្លាយ គឺទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីដែលធ្លាយនោះៗ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងមុខខ្លះ ទឹករមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ត្រង់ទីខាងក្រោយខ្លះ ត្រង់ទីខាងក្រោមខ្លះ ត្រង់ទីខាងខ្លះ យ៉ាងណាមិញ សេចក្តីទុក្ខរមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម នូវបុគ្គលនោះ ព្រោះសេចក្តីអន្តរាយនោះៗ ជាតិទុក្ខ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ។ បេ ។ ទុក្ខព្រោះកិរិយាវិនាសគឺទិដ្ឋិ រមែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាទឹកកាលជ្រាបចូល កាន់នាវាដែលបែកធ្លាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

កិលេសមិនមានកម្លាំងទាំងឡាយ រមែងសង្កត់សង្កិនបុគ្គល
នោះ អន្តរាយទាំងឡាយ រមែងញាំញីបុគ្គលនោះ ទុក្ខរមែង
ជាប់តាមបុគ្គលនោះ ព្រោះអន្តរាយនោះ ដូចជាទឹកកាល
ជ្រាបចូល កាន់នាវាដែលបែកធ្លាយ ។

(២៨) តស្មា ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ នាវំ សិត្វាវ បារគូ ។

(២៩) តស្មា ជន្តុ សទា សតោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា(១) ឯតំ អាទីនវំ សម្បស្សមានោ កាមេសូតិ តស្មា ។ ជន្តូតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគូ មនុជោ ។ សទាតិ សទា សព្វទា សព្វកាលំ និច្ចកាលំ ធុវកាលំ សតតំ សមិតំ អព្វោកិណ្ណំ បោខានុបោខំ(២) ឧទកុម្មិកជាតំ អវីចិ សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ

១ តំនិទានត្តិបិ បាឋោ ។ ២ ម. បោង្ខានុបោង្ខំ ។

(២៥) ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល គប្បីវៀរស្រឡះនូវកាមទាំងឡាយ ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្ដារនាវ ។

(២៦) អធិប្បាយពាក្យថា ព្រោះហេតុនោះ ជនអ្នកមានស្មារតីគ្រប់កាល ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះអំពើនោះជាហេតុ ជនកាលឃើញច្បាស់នូវទោសនុ៎ះ ក្នុងកាមទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា ជន គឺ សត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា គ្រប់កាល គឺសព្វកាល រាល់វេលា អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ ឋិតថេរ រឿយ ៗ ប៉ុកប៉ឹន ញឹកញាប់ មានសភាពដូចជារលកទឹក មិនដាច់ ជាប់ត ប្រព្រឹត្តទៅជាមួយគ្នា ប៉ះជាប់គ្នា កាលមុនភត្ត កាលក្រោយភត្ត យាមខាងដើម យាមកណ្ដាល យាមទីបំផុត ក្នុងកាលរនោច ខ្នើត វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ ក្នុងវ័យខាងដើម ក្នុងវ័យកណ្ដាល ក្នុងវ័យទីបំផុត ។ ពាក្យថា មានសតិ គឺមានសតិ ដោយហេតុ ៤ យ៉ាង គឺមានសតិ កាលចំរើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ក្នុងវេទនាទាំងឡាយ

វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ ។ បេ ។ សោ វុច្ចតិ សតោតិ តស្មា ជន្តុ សទា សតោ ។

(២៧) កាមានិ បរិវជ្ជេយ្យាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ កាមានិ បរិវជ្ជេយ្យាតិ ទ្វីហិ ការណេហិ កាមេ បរិវជ្ជេយ្យ វិក្ខម្ភនតោ វា សមុច្ឆេទតោ វា ។ កថំ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ អដ្ឋិកង្កលូបមា កាមា អប្បស្សាទដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ មំសបេសូបមា កាមា ពហុសាធារណដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ តិណុក្កូបមា កាមា អនុទហនដ្ឋេនាតិ បស្សន្តោ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ ភាវេន្តោបិ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។

ក្នុងចិត្ត មានសតិ កាលចំរើនធម្មានុបស្សនាសតិប្បដ្ឋាន ក្នុងធម៌ទាំងឡាយ ។ មានសតិ ដោយហេតុ ៤ យ៉ាងដទៃទៀត ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល ។

(២៧) អធិប្បាយពាក្យថា គប្បីវៀរស្រឡះ នូវកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់កាមៈ ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ ហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា គប្បីវៀរស្រឡះនូវកាមទាំងឡាយ គឺគប្បីវៀរនូវកាម ដោយហេតុ ២ យ៉ាង គឺកិរិយាសង្កត់សង្កិន ១ កិរិយាផ្តាច់បង់១ ។ បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន តើដូចម្តេច ។ បុគ្គលកាលឃើញថា កាមទាំងឡាយ មានឧបមាដូចរាងឆ្អឹង ដោយសេចក្តីថាមានសេចក្តីត្រេកអរតិច ឈ្មោះថា វៀរកាមដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ដោយសេចក្តីថាជារបស់សាធារណ៍ ដល់សត្វមានប្រមាណច្រើនឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន កាលឃើញថា កាមទាំងឡាយ មានឧបមាដូចគប់ភ្លើងស្មៅ ដោយសេចក្តីថាដុតកំដៅរឿយ ៗ ឈ្មោះថា វៀរកាម ដោយកិរិយាសង្កត់សង្កិន ។ បេ ។ កំពុងចំរើននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ឈ្មោះថាវៀរកាម ដោយកិរិយាសង្កត់សង្កិន ។

ឯវំ វិក្ខម្ភនតោ កាមេ បរិវជ្ជេយ្យ ។ បេ ។ ឯវំ សមុច្ឆេទតោ កាមេ បរិវជ្ជេយ្យាតិ កាមានិ បរិវជ្ជយេ ។

(២៨) តេ បហាយ តរេ ឱឃន្តិ តេតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា កាមច្ឆន្ទនីវរណំ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ តេ បហាយ តរេ ឱឃំ ។

(២៩) នាវំ សិត្វាវ បារគូតិ យថា គរុកំ នាវំ ភារិកំ ឧទកំ សិញ្ចិត្វា ឱសិញ្ចិត្វា ឆឌ្ឌេត្វា លហុកាយ នាវាយ ខិប្បំ លហុំ អប្បកសិរេនេវ បារំ គច្ឆេយ្យ ឯវមេវ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា

បុគ្គលវៀរកាម ដោយកិរិយាសង្កត់សង្កិន ដោយប្រការយ៉ាងនេះ ។បេ។ បុគ្គលវៀរកាម ដោយកិរិយាផ្តាច់បង់ ដោយប្រការយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីវៀរស្រឡះ នូវកាមទាំងឡាយ ។

(២៨) ពាក្យថា កាមទាំងនោះ ក្នុងបទថា ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន គឺជនកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសកាមទាំងឡាយ លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមច្ឆន្ទនីវរណៈ លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ គប្បីឆ្លង គប្បីឆ្លងឡើង គប្បីឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវឱឃៈ គឺកាមឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ហេតុនោះ (ទ្រង់ត្រាស់ថា) ជនលុះលះបង់កាមទាំងនោះ ទើបឆ្លងឱឃៈបាន ។

(២៩) ពាក្យថា ដូចបុគ្គលអ្នកដល់ត្រើយ ព្រោះស្តារនាវា អធិប្បាយថា បុគ្គល បាច ស្តារ ដះបោលនូវទឹកក្នុងនាវា មានគ្រឿងផ្ទុកដ៏ធ្ងន់ ហើយដល់ត្រើយឆាប់រហ័ស មិនលំបាក ដោយសារនាវាស្រាលយ៉ាងណាមិញ បុគ្គលកំណត់ដឹងនូវវត្ថុកាមទាំងឡាយ លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសកាមទាំងឡាយ

កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា ខិប្បំ លហុំ អប្បកសិរេនេវ បារំ គច្ឆេយ្យ ។ បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ បារំ គច្ឆេយ្យ បារំ អធិគច្ឆេយ្យ បារំ ផុសេយ្យ បារំ សច្ឆិករេយ្យ ។ បារគូតិ យោបិ បារំ គន្តុកាមោ សោបិ បារគូ យោបិ បារំ គច្ឆតិ សោបិ បារគូ យោបិ បារំ គតោ សោបិ បារគូ ។ វុត្តំ ហេតំ ភគវតា តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោតិ ។ ព្រាហ្មណោតិ ខោ ភិក្ខវេ អរហតោ ឯតំ អធិវចនំ ។ សោ អភិញ្ញាបារគូ បរិញ្ញាបារគូ បហានបារគូ ភាវនាបារគូ សច្ឆិកិរិយាបារគូ សមាបត្តិបារគូ អភិញ្ញាបារគូ សព្វធម្មានំ បរិញ្ញាបារគូ សព្វទុក្ខានំ បហាន-

លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆាវរណៈ ហើយដល់ត្រើយឆាប់ហ័ស ដោយមិនលំបាក ក៏យ៉ាងនោះដែរ ៗ អមតនិព្វាន ការរម្ងាប់សង្ខារទាំងពួង កិរិយាលះបង់កិលេសទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ (នៃកិលេស) ការចេញចាកតណ្ហា លោកពោលថា ត្រើយ បុគ្គលគប្បីដល់ត្រើយ បានត្រើយ ប៉ះពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយនោះៗ ពាក្យថា បុគ្គលអ្នកដល់ត្រើយ គឺបុគ្គលណា ប្រាថ្នាដើម្បីទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ បុគ្គលណា កំពុងទៅកាន់ត្រើយ បុគ្គលនោះ ឈ្មោះថាអ្នកទៅកាន់ត្រើយ បុគ្គលណាដល់ហើយនូវត្រើយ បុគ្គលនោះ ឈ្មោះថា អ្នកទៅកាន់ត្រើយ ៗ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រាហ្មណ៍ឆ្លងដល់ត្រើយឋិតនៅលើគោក ៗ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ នេះជាឈ្មោះនៃព្រះអរហន្ត ព្រះអរហន្តនោះ ឈ្មោះថា អ្នកដល់ត្រើយដោយការត្រាស់ដឹង អ្នកដល់ត្រើយដោយការកំណត់ដឹង អ្នកដល់ត្រើយដោយការលះបង់ អ្នកដល់ត្រើយដោយការចំរើន អ្នកដល់ត្រើយ ដោយការធ្វើឲ្យជាក់ច្បាស់ អ្នកដល់ត្រើយដោយសមាបត្តិ អ្នកដល់ត្រើយ ដោយការត្រាស់ដឹងធម៌ទាំងពួង អ្នកដល់ត្រើយដោយការ

## បឋមោ កាមសុត្តនិទ្ទេសោ

បារគូ សព្វក្កិលេសានំ ភាវនា បារគូ ចតុន្នំ អរិយ-
មគ្គានំ សច្ឆិកិរិយា បារគូ និរោធស្ស សមាបត្តិ បារគូ
សព្វសមាបត្តីនំ សោ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ
សីលស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សមាធិស្មឹ
វសិប្បត្តោ បារមិប្បត្តោ អរិយាយ បញ្ញាយ វសិប្បត្តោ
បារមិប្បត្តោ អរិយាយ វិមុត្តិយា សោ បារគតោ បារប្ប-
ត្តោ អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ
បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសាន-
ប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណ-
ប្បត្តោ សរណគតោ សរណប្បត្តោ អភយគតោ អភយ-
ប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្ប-
ត្តោ និព្វានគតោ និព្វានប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណច-
រណោ គតទ្ធោ គតទិសោ គតកោដិកោ បាលិតព្រហ្ម-
ចរិយោ ឧត្តមទិដ្ឋិប្បត្តោ ភាវិតមគ្គោ បហីនក្កិលេសោ

## កាមសុត្តនិទ្ទេសទី ១

កំណត់ដឹងទុក្ខទាំងពួង អ្នកដល់ត្រើយ ដោយការលះបង់កិលេសទាំងពួង អ្នកដល់ត្រើយ ដោយការចំរើនអរិយមគ្គទាំង ៤ អ្នកដល់ត្រើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ អ្នកដល់ត្រើយ ដោយការចូលទៅកាន់សមាបត្តិទាំងពួង ព្រះអរហន្តនោះដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពក្នុងសីលដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាពក្នុងសមាធិដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាព ក្នុងបញ្ញាដ៏ប្រសើរ ដល់នូវភាពដ៏ស្ទាត់ ដល់នូវឧត្តមភាព ដោយវិមុត្តិដ៏ប្រសើរ ព្រះអរហន្តនោះ ឈ្មោះថា ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត (នៃសង្សារ) ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីអវសាន ដល់ទីអវសាន ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីពឹងពួន ដល់ទីពឹងពួន ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់និព្វាន ដល់និព្វាន ព្រះអរហន្តនោះ មានធម៌ជាគ្រឿងអប់រំនៅស្រេចហើយ មានកិរិយាប្រព្រឹត្ត ប្រព្រឹត្តហើយ មានផ្លូវឆ្ងាយគឺសង្សារកន្លងហើយ មានទិសគឺព្រះនិព្វានដល់ហើយ មានទីបំផុតនៃព្រះនិព្វានដល់ហើយ មានព្រហ្មចរិយធម៌រក្សាហើយ ដល់ហើយនូវការឃើញដ៏ឧត្តម មានមគ្គចំរើនហើយ មានកិលេសលះបង់ហើយ មាន

បដិវិទ្ធាកុប្បោ សច្ឆិកតនិរោធោ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ មគ្គោ ភាវិតោ និរោធោ សច្ឆិកតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ សោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិក្ខោ អព្វូឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ បញ្ចង្គវិប្បហីនោ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណបច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តបញ្ញោ កេវលី វុសិតវា ឧត្តមបុរិសោ បរមបុរិសោ

អរហត្តផលជាធម្មជាតមិនកម្រើកត្រាស់ដឹងហើយ មាននិរោធគឺព្រះនិព្វានធ្វើឲ្យជាក់ច្បាស់ហើយ ទុក្ខព្រះអរហន្តនោះកំណត់ដឹងហើយ សមុទយៈលះបង់ហើយ មគ្គចម្រើនហើយ និរោធធម៌បានធ្វើឲ្យជាក់ច្បាស់ហើយ ត្រាស់ដឹងហើយនូវហេតុដែលគួរត្រាស់ដឹង កំណត់ដឹងហើយនូវហេតុដែលគួរកំណត់ដឹង លះបង់ហើយនូវហេតុដែលគួរលះបង់ ចំរើនហើយនូវហេតុដែលគួរចំរើន ធ្វើឲ្យជាក់ច្បាស់ហើយនូវហេតុដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្តនោះ មានសសរគោល គឺអវិជ្ជាដកចេញហើយ មានស្នាមភ្លោះគឺជាតិសង្សារលុបអស់ហើយ មានសសរខឿនគឺតណ្ហាដកចេញហើយ មិនមានគន្លឹះទ្វារ គឺឱរម្ភាគិយសំយោជន៍ ជាអរិយៈ មិនមានកិលេស មានទង់គឺមានះទំលាក់ហើយ មានគ្រឿងធ្ងន់[១]ទំលាក់ចេញហើយ ជាអ្នកប្រាសចាកកិលេស លះបង់អង្គ៥គឺនីវរណៈហើយ ប្រកបព្រមហើយដោយអង្គប្រាំមួយ[២] មានការរក្សាដោយធម៌តែមួយគឺសតិ មានធម៌ជាគ្រឿងពឹងផ្អែក៤ប្រការ មានទិដ្ឋិសច្ចៈដោយឡែកលះបង់ហើយ មានការស្វែងរកទាំងពួងលះបង់ហើយដោយប្រពៃ មានសេចក្តីត្រិះរិះមិនល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ហើយ មានចិត្តផុតស្រឡះហើយដោយប្រពៃ មានបញ្ញាផុតស្រឡះហើយដោយប្រពៃ ជាបុគ្គលបរិបូណ៌ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ស្រេចហើយ ជាឧត្តមបុរស ជាបរមបុរស

---

១ ខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ បញ្ចកាមគុណភារៈ មានភារៈ ។ ២ ភិក្ខុមានសតិសម្បជញ្ញៈ ដោយអំណាចឧបេក្ខា កំចាត់បង់នូវសេចក្តីថ្នាំងថ្នាក់ ឬ សោមនស្សក្នុងអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ។ អដ្ឋកថា ។

បឋមោ កាមសុត្តនិទ្ទេសោ

បរមប្បត្តិប្បត្តោ សោ នេវ អាចិនាតិ ន អបចិនាតិ អប-
ចិនិត្វា ឋិតោ នេវ បជហតិ ន ឧបាទិយតិ បជហិត្វា
ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ
នេវ វិធុបេតិ ន សន្ធុបេតិ វិធុបេត្វា ឋិតោ អសេក្ខេ-
ន សីលក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន
សមាធិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន អសេក្ខេន
វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន
សមន្នាគតត្តា ឋិតោ សច្ចំ បដិបាទយិត្វា ឋិតោ ឯជំ
សមតិក្កមិត្វា ឋិតោ កិលេសគ្គឹ បរិយាទយិត្វា ឋិតោ
អបរិគមនតាយ ឋិតោ កដំ សមាទាយ ឋិតោ មុត្តិ-
ប្បដិសេវនតាយ ឋិតោ មេត្តាយ បារិសុទ្ធិយា ឋិតោ
ករុណាយ មុទិតាយ ឧបេក្ខាយ បារិសុទ្ធិយា ឋិតោ
អច្ចន្តបារិសុទ្ធិយា ឋិតោ អកម្មញ្ញតាយ បារិសុទ្ធិយា
ឋិតោ វិមុត្តត្តា ឋិតោ សន្តុសិតត្តា ឋិតោ ខន្ធបរិយន្តេ
ឋិតោ ធាតុបរិយន្តេ ឋិតោ អាយតនបរិយន្តេ ឋិតោ

ដល់នូវការដល់ដ៏ប្រសើរ ព្រះអរហន្តនោះ មិនសន្សំ មិនកំចាត់បង់ លោកនឹងធឹងព្រោះកំចាត់បង់ មិនលះបង់ មិនប្រកាន់ លោកនឹងធឹង ព្រោះលះបង់ មិនចាក់ស្រេះ មិនតំកើង (ដោយតណ្ហា និងមានះ) លោកនឹងធឹង ព្រោះចាក់ស្រេះ មិនរំលត់ មិនបង្កាត់ (នូវភ្លើងគឺកិលេស) លោកនឹងធឹង ព្រោះរំលត់ លោកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខៈ លោកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយបញ្ញាខន្ធជាអសេក្ខៈ ដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ លោកខ្ជាប់ខ្ជួន ព្រោះយល់ច្បាស់នូវសច្ចធម៌ លោកខ្ជាប់ខ្ជួន ព្រោះកន្លងផុតយ៉ាងនេះ លោកខ្ជាប់ខ្ជួន ព្រោះរំលត់ភ្លើងគឺកិលេស លោកខ្ជាប់ខ្ជួន ព្រោះមិនមានដំណើរតទៅទៀត លោកខ្ជាប់ខ្ជួន ព្រោះចាប់បាននូវកំពូល (ជ័យជំនះ) លោកខ្ជាប់ខ្ជួន ព្រោះកិរិយាសេពនូវធម៌ជាគ្រឿងផុតស្រឡះ លោកខ្ជាប់ខ្ជួន ព្រោះមេត្តាជាគុណជាតដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះករុណា មុទិតា ឧបេក្ខា ជាគុណជាតដ៏បរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះដល់ទីបំផុតនៃសេចក្តីបរិសុទ្ធ លោកខ្ជាប់ខ្ជួន ព្រោះសេចក្តីបរិសុទ្ធិ មិនគួរដល់ការដោរ (នៃតណ្ហាទិដ្ឋិមានះ) លោកខ្ជាប់ខ្ជួន ព្រោះផុតស្រឡះ លោកខ្ជាប់ខ្ជួន ព្រោះជាបុគ្គលសន្តោស លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃខន្ធ លោកខ្ជាប់ខ្ជួនក្នុងទីបំផុតនៃធាតុ លោកខ្ជាប់ខ្ជួនក្នុង

គតិបរិយន្តេ ឋិតោ ឧបបត្តិបរិយន្តេ ឋិតោ បដិសន្ធិ-
បរិយន្តេ ឋិតោ ភវបរិយន្តេ ឋិតោ សំសារបរិយន្តេ
ឋិតោ វដ្ដបរិយន្តេ ឋិតោ អន្តិមភវេ ឋិតោ អន្តិម-
សមុស្សយេ ឋិតោ អន្តិមទេហធរោ អរហា ។

តស្សាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ
ជាតិមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

នាវំ សិត្វា បារគូ ។ តេនាហ ភគវា

តស្មា ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ នាវំ សិត្វា បារគូតិ ។

បឋមោ កាមសុត្តនិទ្ទេសោ និដ្ឋិតោ ។

ទីបំផុតនៃអាយតនៈ លោកខ្ជាប់ខ្លួនកន្លងទីបំផុតនៃគតិ លោកខ្ជាប់ខ្លួនកន្លងទីបំផុតនៃឧបបត្តិភព លោកខ្ជាប់ខ្លួនកន្លងទីបំផុតនៃបដិសន្ធិ លោកខ្ជាប់ខ្លួនកន្លងទីបំផុតនៃភព លោកខ្ជាប់ខ្លួន កន្លងទីបំផុតនៃសង្សារ លោកខ្ជាប់ខ្លួនកន្លងទីបំផុតនៃវដ្ដៈ លោកខ្ជាប់ខ្លួន កន្លងភពជាទីបំផុត លោកខ្ជាប់ខ្លួនកន្លងសរីរៈ ជាទីប្រជុំកន្លងទីបំផុត ទ្រទ្រង់រាងកាយជាទីបំផុត ជាព្រះអរហន្ត ។

ភពនេះ ជាទីបំផុតរបស់ព្រះអរហន្តនោះ អត្តភាពនេះ
ជាខាងក្រោយបង្អស់ ការអន្ទោលទៅដោយជាតិ និង
មរណៈ ភពថ្មី របស់ព្រះអរហន្តនោះ មិនមានទេ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាបុគ្គលអ្នកដល់ត្រើយ ព្រោះស្ពាននាវា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុនោះ ជនអ្នកមានស្មារតី គ្រប់កាល គប្បីវៀរ
ស្រឡះ នូវកាមទាំងឡាយ ជនលុះលះបង់នូវកាមទាំង
នោះ ទើបឆ្លងឱឃៈបាន ដូចបុគ្គលអ្នកដល់នូវ ត្រើយ
ព្រោះស្ពាននាវា ។

ចប់ កាមសុត្តនិទ្ទេស ទី១ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

(៣០) សត្តោ គុហាយំ ពហុនាភិឆន្នោ
តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ
ទូរេ វិវេកា ហិ តថាវិធោ សោ
កាមា ហិ លោកេ ន ហិ សុប្បហាយា ។

(៣១) សត្តោ គុហាយំ ពហុនាភិឆន្នោតិ សត្តោតិ ហិ ខោ វុត្តំ ។ អបិច គុហា តាវ វត្តព្វា ។ គុហា វុច្ចតិ កាយោ ។ កាយោតិ វា គុហាតិ វា ទេហោតិ វា សន្ទេហោតិ វា នាវាតិ វា រថោតិ វា ធជោតិ វា វម្មិកោតិ វា និឌ្ឌន្តិ វា នគរន្តិ វា កុដីតិ(១) វា គណ្ឌោតិ វា កុម្ភោតិ វា កាយស្សេតំ(២) អធិវចនំ ។ សត្តោ គុហាយន្តិ គុហាយំ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។ យថា ភិត្តិខីលេ វា នាគទន្តេ វា ភណ្ឌំ សត្តំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ គុហាយំ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។

---

១ ម. វម្មិកោតិ វា នគរន្តិ វា និឌ្ឌន្តិ វា កុដីតិ វា ។ ២ ឱ. កុម្ភោតិ វា នាគោតិ វា កាយស្សេតំ ។ ម. កុម្ភោតិ វា នាគោតិ វា កាយស្សេតំ ។

# គុហដ្ឋកសុត្តនិទ្ទេស ទី ២

(៣០) (ព្រះមានព្រះភាគត្រាស់ថា) នរជនណា កាលឋិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើន បិទបាំង លិចចុះ ក្នុងមោហៈ (អារម្មណ៍ជាគ្រឿងវង្វេង) នរជនមានសភាពដូច្នោះនោះ រមែងឋិតនៅក្នុងទីឆ្ងាយអំពីវិវេក ដ្បិតកាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។

(៣១) អធិប្បាយពាក្យថា ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើន បិទបាំង ត្រង់ពាក្យថា ជាប់នៅ ព្រះអង្គពោលក៏ពិតហើយ ។ តែខ្ញុំសូមពោលត្រង់ពាក្យថា គុហា ជាមុនសិន ។ កាយ លោកហៅថា គុហា ។ ពាក្យថា កាយក្តី គុហាក្តី ទេហៈក្តី សន្ទេហៈក្តី នាវាក្តី រថក្តី ទង់ក្តី ដំបូកក្តី សម្បុកក្តី នគរក្តី កុដិក្តី បូសក្តី ក្អមក្តី នេះជាឈ្មោះនៃកាយ ។ ពាក្យថា ជាប់នៅក្នុងគុហា គឺជាប់នៅផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្ពក់នៅ ព័ន្ធព័ទ្ធនៅ ក្នុងគុហា ។ ភណ្ឌៈដែលជាប់នៅ ជាប់ផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្ពក់នៅ ព័ន្ធព័ទ្ធនៅ ដូចចម្រឹង ដែលដោតនឹងជញ្ជាំងក្តី ដូចដែកកែវក្តី យ៉ាងណា នរជនជាប់នៅ ជាប់ផ្សេងៗ ជាប់ទូទៅ ទាក់នៅ ជ្ពក់នៅ ព័ន្ធព័ទ្ធនៅ ក្នុងគុហា ក៏យ៉ាងនោះដែរ ។

វុត្តំ ហេតំ ភគវតា រូបេ ខោ[១] យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តត្រ សត្តោ[២] តស្មា សត្តោតិ វុច្ចតីតិ[៣] ។ សត្តោតិ លគ្គនាធិវចនន្តិ សត្តោ គុហាយំ ។ ពហុនាភិឆន្នោតិ ពហុកេហិ កិលេសេហិ ឆន្នោ រាគេន ឆន្នោ ទោសេន ឆន្នោ មោហេន ឆន្នោ កោធេន ឆន្នោ ឧបនាហេន ឆន្នោ មក្ខេន ឆន្នោ បឡាសេន ឆន្នោ ឥស្សាយ ឆន្នោ មច្ឆរិយេន ឆន្នោ មាយាយ ឆន្នោ សាឋេយ្យេន ឆន្នោ ថម្ភេន ឆន្នោ សារម្ភេន ឆន្នោ មានេន ឆន្នោ អតិមានេន ឆន្នោ មទេន ឆន្នោ បមាទេន ឆន្នោ សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ឆន្នោ ឧច្ឆន្នោ អាវុតោ និវុតោ ឱផុតោ បិហិតោ បដិច្ឆន្នោ បដិកុជ្ជិតោតិ សត្តោ គុហាយំ ពហុនាភិឆន្នោ ។

---

១ ម. រូបេ ខោ រាធ ។ ២ ឱ. ម តត្រ សត្តោ តត្រ វិសត្តោ ។ ៣ ម. តតោ បរំ វេទនាយ ខោ រាធ ។ បេ ។ សញ្ញាយ ខោ រាធ សង្ខារេសុ ខោ រាធ វិញ្ញាណេ ខោ រាធ យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តត្រ សត្តោ តត្រ វិសត្តោ តស្មា សត្តោតិ វុច្ចតីតិ ទិស្សន្តិ ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា សេចក្តីពេញចិត្តណា តម្រេកណា សេចក្តីត្រេកត្រអាលណា សេចក្តីប៉ុនប៉ងណា សេចក្តីប្រកាន់ដោយឧបាយ ដែលមានការតាំងចិត្ត និងការប្រកាន់ជាអនុស័យណា ក្នុងរូប នរជនជាប់ក្នុងកិលេសនោះៗ ហេតុនោះ (លោកពោលថា) ជាប់នៅ ។ ពាក្យថា ជាប់នៅ ជាឈ្មោះនៃការជាប់ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាប់នៅក្នុងគុហា ។ ពាក្យថា គ្រប់កិលេសដ៏ច្រើន បិទបាំង គឺគ្រប់កិលេសទាំងឡាយ ដ៏ច្រើនបិទបាំង គឺរាគៈបិទបាំង ទោសៈបិទបាំង មោហៈបិទបាំង កោធៈបិទបាំង ឧបនាហៈបិទបាំង មក្ខៈបិទបាំង បឡាសៈបិទបាំង ឥស្សាបិទបាំង មច្ឆរិយៈបិទបាំង មាយាបិទបាំង សាឋេយ្យៈបិទបាំង ថម្ភៈបិទបាំង សារម្ភៈបិទបាំង មានៈបិទបាំង អតិមានៈបិទបាំង មទៈបិទបាំង បមាទៈបិទបាំង កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង បិទបាំង ប្រកព្រំ ខ្ទប់ ពាំង ហ៊ុមក្តិត គ្រប បង្រួមផ្កាប់ហើយ ហេតុនោះ (ទ្រង់ត្រាសថា) ជាប់នៅក្នុងគុហា គ្រប់កិលេសដ៏ច្រើនបិទបាំង ។

(៣២) តិដ្ឋំ នរោ មោហនស្មិំ បគាឡ្ហោតិ តិដ្ឋំ នរោតិ តិដ្ឋន្តោ នរោ រត្តោ រាគវសេន តិដ្ឋតិ ទុដ្ឋោ ទោសវសេន តិដ្ឋតិ មូឡ្ហោ មោហវសេន តិដ្ឋតិ វិនិពទ្ធោ មានវសេន តិដ្ឋតិ បរាមដ្ឋោ ទិដ្ឋិវសេន តិដ្ឋតិ វិក្ខេបគតោ ឧទ្ធច្ចវសេន តិដ្ឋតិ អនិដ្ឋង្គតោ វិចិកិច្ឆាវសេន តិដ្ឋតិ ថាមគតោ អនុសយវសេន តិដ្ឋតីតិ ឯវម្បិ តិដ្ឋំ នរោ ។

វុត្តំ ហេតំ ភគវតា សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ សន្តិ ភិក្ខវេ សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា

(៣៤) អធិប្បាយពាក្យថា នរជនកាលបិតទៅ... លិចចុះក្នុងមោហៈ ត្រង់ពាក្យថា នរជនកាលបិតទៅ បានដល់នរជនកាលតំអក់ គឺត្រេកត្រអាលដោយអំណាចរាគៈ ហើយតំអក់ ប្រទូស្តដោយអំណាចទោសៈ ហើយតំអក់ វង្វេងដោយអំណាចមោហៈ ហើយតំអក់ ជាប់ក្នុងអារម្មណ៍ផ្សេង ៗ ដោយអំណាចមានះ ហើយតំអក់ ស្ទាបអង្អែលដោយអំណាចទិដ្ឋិ ហើយតំអក់ រាយមាយដោយអំណាចឧទ្ធច្ចៈ ហើយតំអក់ មិនដល់នូវសេចក្ដីបូលចិត្ត ដោយអំណាចវិចិកិច្ឆា ហើយតំអក់ មានកម្លាំងដោយអំណាចអនុស័យ ហើយតំអក់ នរជនកាលបិតទៅ យ៉ាងនេះខ្លះ ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានបុណ្យត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ បើភិក្ខុត្រេកអរ រីករាយនឹងរូបនោះហើយ រមែងតំអក់ក្នុងសេចក្ដីប្រាថ្នាមិនខាន ម្នាលភិក្ខុទាំងឡាយ សំឡេងទាំងឡាយដែលគប្បីដឹងច្បាស់ដោយត្រចៀក ក្លិនទាំងឡាយដែលគប្បីដឹងច្បាស់ដោយច្រមុះ រសទាំងឡាយដែលគប្បីដឹងច្បាស់ដោយអណ្ដាត ផ្សព្វទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ធម្មារម្មណ៍ទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់

កាមុបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិ-
វទតិ អជ្ឈោសាយ តិដ្ឋតីតិ ។ ឯវម្បិ តិដ្ឋំ នរោ ។

វុត្តំ ហេតំ ភគវតា រូបូបាយំ វា ភិក្ខវេ វិញ្ញាណំ
តិដ្ឋមានំ តិដ្ឋតិ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ
វិរូឡ្ហឹ វេបុល្លំ អាបជ្ជតិ វេទនូបាយំ វា ភិក្ខវេ សញ្ញូបាយំ
វា ភិក្ខវេ សង្ខារូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ
តិដ្ឋតិ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ
វិរូឡ្ហឹ វេបុល្លំ អាបជ្ជតីតិ ។ ឯវម្បិ តិដ្ឋំ នរោ ។

វុត្តំ ហេតំ ភគវតា កពឡីការេ ចេ ភិក្ខវេ អាហារេ
អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ
វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូប-
ស្សាវក្កន្តិ យត្ថ អត្ថិ នាមរូបស្សាវក្កន្តិ អត្ថិ តត្ថ សង្ខា-
រានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតឹ

ប្រកបដោយកាម គួររីករាយ បើភិក្ខុត្រេកអរ រីករាយ នឹងអារម្មណ៍នោះហើយ រមែងតាំងអក់ ក្នុងសេចក្តីប្រាថ្នា មិនខាន ។ នរជនកាលឋិតនៅ យ៉ាងនេះខ្លះ ។

មួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានរូបជាឧបាយក្តី មានរូបជាអារម្មណ៍ តាំងនៅក្នុងរូប សេពនូវសេចក្តីត្រេកអរ កាលស្ងំ រមែងស្ងំ (ក្នុងអារម្មណ៍នោះ) ក៏ដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានវេទនាជាឧបាយក្តី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសញ្ញាជាឧបាយក្តី ម្នាលភិក្ខុទាំងឡាយ វិញ្ញាណមានសង្ខារជាឧបាយក្តី មានសង្ខារជាអារម្មណ៍ តាំងនៅក្នុងសង្ខារ សេពសេចក្តីត្រេកអរ កាលស្ងំ រមែងស្ងំ (ក្នុងអារម្មណ៍នោះ) ដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ។ នរជនកាលឋិតនៅ យ៉ាងនេះខ្លះ ។

ន័យមួយទៀត ព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានរាគៈ មានសេចក្តីត្រេកអរ មានតណ្ហា ក្នុងកវឡិង្ការាហារ វិញ្ញាណតាំងនៅលូតលាស់ក្នុងទីណា វិញ្ញាណតាំងនៅលូតលាស់ ក្នុងទីនោះ ការចុះកាន់នៃនាមរូប មានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្តីចំរើនឡើង នៃសង្ខារទាំងឡាយ មានក្នុងទីណា សេចក្តីចំរើនឡើងនៃសង្ខារទាំងឡាយ ក៏មានក្នុងទីនោះ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតិំ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតិំ ជាតិជរាមរណំ យត្ថ អត្ថិ អាយតិំ ជាតិជរាមរណំ សសោកន្តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមិ ផស្សេ ចេ ភិក្ខវេ អាហារេ មនោសញ្ចេតនាយ ចេ ភិក្ខវេ អាហារេ វិញ្ញាណេ ចេ ភិក្ខវេ អាហារេ អត្ថិ រាគោ អត្ថិ នន្ទិ អត្ថិ តណ្ហា បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ យត្ថ បតិដ្ឋិតំ វិញ្ញាណំ វិរូឡ្ហំ អត្ថិ តត្ថ នាមរូបស្សាវក្កន្តិ យត្ថ អត្ថិ នាមរូបស្សាវក្កន្តិ អត្ថិ តត្ថ សង្ខារានំ វុឌ្ឍិ យត្ថ អត្ថិ សង្ខារានំ វុឌ្ឍិ អត្ថិ តត្ថ អាយតិំ បុនព្ភវាភិនិព្វត្តិ យត្ថ អត្ថិ អាយតិំ បុនព្ភវាភិនិព្វត្តិ អត្ថិ តត្ថ អាយតិំ ជាតិជរាមរណំ យត្ថ អត្ថិ អាយតិំ ជាតិជរាមរណំ សសោកន្តំ ភិក្ខវេ សរជំ សឧបាយាសន្តិ វទាមីតិ ។ ឯវម្បិ តិដ្ឋំ នរោ ។

មោហនស្មឹ បគាឡ្ហោតិ មោហនា វុច្ចន្តិ បញ្ចកាមគុណា ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយ-

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

ការកើតឡើង នៃភពថ្មីតទៅ មានក្នុងទីណា ការកើតឡើង នៃភពថ្មីតទៅ ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈ តទៅ មានក្នុងទីណា ជាតិ ជរា មរណៈ តទៅ មានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថា_គត ពោលនូវជាតិ ជរា មរណៈ នោះថា ប្រកបដោយសេចក្តីសោក ប្រកបដោយធូលី ប្រកបដោយសេចក្តីចង្អៀតចង្អល់ ម្នាលភិក្ខុទាំងឡាយ បើក្នុងផស្សាហារ ម្នាលភិក្ខុទាំងឡាយ បើក្នុងមនោសញ្ចេតនាហារ ម្នាលភិក្ខុទាំងឡាយ បើមានរាគៈ មានសេចក្តីត្រេកអរ មានតណ្ហា ក្នុងវិញ្ញាណាហារ វិញ្ញាណ តាំងនៅ ដុះដាលឡើង ក្នុងទីណា វិញ្ញាណក៏តាំងនៅដុះដាល ក្នុងទីនោះ ការចុះកាន់នៃនាមរូប មានក្នុងទីណា ការចុះកាន់នៃនាមរូប ក៏មានក្នុងទីនោះ សេចក្តីចំរើននៃសង្ខារទាំងឡាយ មានក្នុងទីណា សេចក្តីចំរើននៃសង្ខារទាំងឡាយ ក៏មានក្នុងទីនោះ ការកើតនៃភពថ្មីតទៅ មានក្នុងទីណា ការកើតនៃភពថ្មីតទៅ ក៏មានក្នុងទីនោះ ជាតិ ជរា មរណៈ តទៅ មានក្នុងទីណា ជាតិ ជរា មរណៈ តទៅ ក៏មានក្នុងទីនោះ ម្នាលភិក្ខុទាំងឡាយ តថាគត ពោល នូវជាតិ ជរា មរណៈ នោះថា ប្រកបដោយសេចក្តីសោក ប្រកបដោយធូលី ប្រកបដោយសេចក្តីចង្អៀតចង្អល់ ។ នរជនកាលឋិតនៅ យ៉ាងនេះខ្លះ ។

ពាក្យថា លិចចុះក្នុងមោហៈ សេចក្តីថា កាមគុណ៥ហៅថា មោហៈ បានដល់រូបដែលដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត

រូបា កាមុបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយ-វិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា ។ កឹការណា មោហនា វុច្ចន្តិ បញ្ច កាមគុណា ។ យេភុយ្យេន ទេវមនុស្សា បញ្ចសុ កាមគុណេសុ មុយ្ហន្តិ សម្មុយ្ហន្តិ សម្បមុយ្ហន្តិ មូឡ្ហា សម្មូឡ្ហា សម្បមូឡ្ហា អវិជ្ជាយ អន្ធីកតា អាវុតា និវុតា ឱផុតា បិហិតា បដិច្ឆន្នា បដិកុជ្ជិតា តំការណា មោហនា វុច្ចន្តិ បញ្ច កាមគុណា ។ មោហនស្មឹ បគា-ឡ្ហោតិ មោហនស្មឹ បគាឡ្ហោ ឱគាឡ្ហោ អជ្ឈោគាឡ្ហោ និមុគ្គោតិ តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ ។

(៣៣) ទូរេ វិវេកា ហិ តថាវិធោ សោតិ វិវេកាតិ តយោ វិវេកា កាយវិវេកោ ចិត្តវិវេកោ ឧបធិវិវេកោ ។

កតមោ កាយវិវេកោ ។ ឥធ ភិក្ខុ វិវិត្តំ សេនា-សនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុ-សានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ កាយេន ច វិវិត្តោ វិហរតិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ

មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ក្លិនដែលគប្បីដឹងដោយច្រមុះ រសដែលគប្បីដឹងដោយអណ្តាត ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ ។ កាមគុណ ៥ លោកហៅថា មោហៈ តើព្រោះហេតុអ្វី ។ ទេវតានិងមនុស្សដោយច្រើន វង្វេង ភ្លេចស្មារតី ភាន់ភាំងគំនិត ក្នុងកាមគុណទាំង ៥ ជាអ្នកវង្វេង ភ្លេចស្មារតី ភាន់ភាំងគំនិត ត្រូវអវិជ្ជាធ្វើឲ្យងងឹត ខ្ទប់ រាំង ហ៊ុម ក្តិត គ្រប បង្រួម ផ្កាប់ហើយ ព្រោះហេតុនោះ កាមគុណទាំង ៥ លោកហៅថា មោហៈ ។ ត្រង់ពាក្យថា លិចចុះក្នុងមោហៈ គឺចូលទៅ ផ្កាប់ចុះ ចូលទៅស៊ប់ ជ្រមុជចុះ ក្នុងមោហៈ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជន កាលឋិតនៅ លិចចុះ ក្នុងមោហៈ ។

(៣៣) អធិប្បាយពាក្យថា នរជនមានសភាពដូច្នោះនោះ (ឋិតនៅ) ក្នុងទីឆ្ងាយអំពីវិវេក ត្រង់ពាក្យថា វិវេក បានដល់វិវេក ៣ គឺ កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។

កាយវិវេក តើដូចម្តេច ។ ភិក្ខុ ក្នុងសាសនានេះ គប់រកសេនាសនៈស្ងាត់ គឺ ព្រៃ គល់ឈើ ភ្នំ ល្អាង គុហា ព្រៃស្មសាន ព្រៃឆ្ងាយ ទីវាល និងគំនរចំបើង ជាអ្នកនៅ ស្ងប់ស្ងាត់ដោយកាយ ភិក្ខុនោះ ទៅម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង

និសីទតិ វា សេយ្យំ កប្បេតិ វា បិណ្ឌាយ បវិសតិ វា បដិក្កមតិ វា រហោ និសីទតិ វា ចង្កមំ អធិដ្ឋាតិ វា ចរតិ វិហរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតិ អយំ កាយវិវេកោ ។

កតមោ ចិត្តវិវេកោ ។ បឋមំ ឈានំ សមាបន្នស្ស នីវរណេហិ ចិត្តំ វិវិត្តំ ហោតិ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារេហិ ចិត្តំ វិវិត្តំ ហោតិ តតិយំ ឈានំ សមាបន្នស្ស បីតិយា ចិត្តំ វិវិត្តំ ហោតិ ចតុត្ថំ ឈានំ សមាបន្នស្ស សុខទុក្ខេហិ ចិត្តំ វិវិត្តំ ហោតិ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ សោតាបន្នស្ស សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្វតបរាមាសា

ដេកម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយនៅក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានទីចង្រ្កមម្នាក់ឯង ត្រាច់ទៅ ទៅ (ញ៉ាំងឥរិយាបថ) ឲ្យប្រព្រឹត្តទៅ ប្រព្រឹត្ត រក្សា (ឥរិយាបថ) ប្រព្រឹត្តទៅ ដើរទៅ ម្នាក់ឯង នេះ ឈ្មោះថា កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ភិក្ខុចូលបឋមជ្ឈាន ចិត្តស្ងាត់ចាកនីវរណៈទាំងឡាយ ភិក្ខុចូលទុតិយជ្ឈាន ចិត្តស្ងាត់ចាកវិតក្កៈនិងវិចារៈ ចូលតតិយជ្ឈាន ចិត្តស្ងាត់ចាកបីតិ ភិក្ខុចូលចតុត្ថជ្ឈាន ចិត្តស្ងាត់ចាកសុខនិងទុក្ខ ភិក្ខុចូលអាកាសានញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាករូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ភិក្ខុចូលវិញ្ញាណញ្ចាយតនជ្ឈាន ចិត្តស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ភិក្ខុចូលអាកិញ្ចញ្ញាយតនជ្ឈាន ចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ភិក្ខុចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ចិត្តស្ងាត់ ចាកអាកិញ្ចញ្ញាយតនសញ្ញា ភិក្ខុដល់សោតៈ ចិត្តស្ងាត់ ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈ

ទិដ្ឋានុសយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ សកទាគាមិស្ស ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ អនាគាមិស្ស អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ អរហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេកដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្វនិមិត្តេហិ ចិត្តំ វិវិត្តំ ហោតិ អយំ ចិត្តវិវេកោ ។

កតមោ ឧបធិវិវេកោ ។ ឧបធិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិវិវេកោ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ អយំ ឧបធិវិវេកោ ។

ចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ នឹងកិលេសដែលឋិតនៅជាមួយនឹងកិលេសទាំងនោះ ភិក្ខុដល់សកទាគាមិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាតផង ចាកកាមរាគានុស័យ ចាកបដិឃានុស័យ យ៉ាងគ្រោតគ្រាត ចាកកិលេសទាំងឡាយដែលឋិតនៅជាមួយនឹងកិលេសទាំងនោះផង ភិក្ខុដល់អនាគាមិ ចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈយ៉ាងល្អិតផង ចាកកាមរាគានុស័យ ចាកបដិឃានុស័យ យ៉ាងល្អិតផង ចាកកិលេសទាំងឡាយដែលឋិតនៅជាមួយគ្នា នឹងកិលេសទាំងនោះផង ភិក្ខុដល់ព្រះអរហត្ត ចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យផង ចាកកិលេសទាំងឡាយ ដែលឋិតនៅជាមួយនឹងកិលេសទាំងនោះផង ចាកនិមិត្តគ្រប់យ៉ាងខាងក្រៅផង នេះឈ្មោះថា ចិត្តវិវេក ។

ឧបធិវិវេក តើដូចម្តេច ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ នឹងអភិសង្ខារទាំងឡាយ លោក ហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ (កងទុក្ខ) ការចេញចាកតណ្ហា នេះ ឈ្មោះថា ឧបធិវិវេក ។

កាយវិវេកោ ច វូបកដ្ឋកាយានំ នេក្ខម្មាភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទានប្បត្តានំ ឧបធិវិវេកោ ច និរុបធីនំ បុគ្គលានំ វិសង្ខារគតានំ ។

ទូរេ វិវេកា ហីតិ យោ សោ ឯវំ គុហាយំ សត្តោ ឯវំ ពហុកេហិ កិលេសេហិ ឆន្នោ ឯវំ មោហនស្មឹ បគាឡ្ហោ សោ កាយវិវេកាបិ ទូរេ ចិត្តវិវេកាបិ ទូរេ ឧបធិវិវេកាបិ ទូរេ វិទូរេ សុវិទូរេ ន សន្តិកេ ន សាមន្តា អនាសន្នេ អនុបកដ្ឋេ[១] ។ តថាវិធោតិ តថាវិធោ តាទិសោ តស្សណ្ឋិតោ តប្បការោ តប្បដិភាគោ យោ សោ មោហនស្មឹ បគាឡ្ហោតិ ទូរេ វិវេកា ហិ តថាវិធោ សោ ។

(៣៨) កាមា ហិ លោកេ ន ហិ សុប្បហាយាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។

---

១ ម. វិវេកដ្ឋេ ។

កាយវិវេក (កើតមាន) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្ដីផូរផង់ក្រៃលែងផង ឧបធិវិវេក (កើតមាន) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វាន ដែលប្រាសចាកសង្ខារផង ។

ពាក្យថា ក្នុងទីឆ្ងាយអំពីវិវេក បានដល់នរជនណា ជាប់ចំពាក់ក្នុងគុហាយ៉ាងនេះ ត្រូវពួកកិលេសដ៏ច្រើនបិទបាំងយ៉ាងនេះ លិចចុះក្នុងមោហៈយ៉ាងនេះ នរជននោះ (ឈ្មោះថាឋិតនៅ) ក្នុងទីឆ្ងាយ អំពីកាយវិវេកផង ក្នុងទីឆ្ងាយអំពីចិត្តវិវេកផង ក្នុងទីឆ្ងាយ ឆ្ងាយពេក ឆ្ងាយពេកណាស់ មិនមែនជិត មិនមែននៅក្បែរ មិនមែននៅប្រកៀក ឃ្លាតអំពីឧបធិវិវេកផង ។ ពាក្យថា មានសភាពដូច្នោះ គឺមានប្រការដូច្នោះ ប្រាកដដូច្នោះ ឋិតនៅដោយអាការនោះ ឋិតនៅដោយប្រការនោះ ជាចំណែកនៃប្រការនោះ ដែលលិចចុះក្នុងមោហៈនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនមានសភាពដូច្នោះនោះ (ឋិតនៅ) ក្នុងទីឆ្ងាយអំពីវិវេក ។

(៣៤) អធិប្បាយពាក្យថា ដ្បិតកាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់ កាម ២ យ៉ាង គឺ វត្ថុកាម ១ កិលេសកាម ១ ។

កតមេ វត្ថុកាមា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា អត្ថរណា បាបុរណា ទាសិទាសា អជេឡកា កុក្កុដសូករា ហត្ថិគវស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យំកិញ្ចិ រជនីយវត្ថុ វត្ថុកាមា ។ អបិច អតីតា កាមា អនាគតា កាមា បច្ចុប្បន្នា កាមា អជ្ឈត្តា កាមា ពហិទ្ធា កាមា អជ្ឈត្តពហិទ្ធា កាមា ហីនា កាមា មជ្ឈិមា កាមា បណីតា កាមា អាបាយិកា កាមា មានុសិកា កាមា ទិព្វា កាមា បច្ចុបដ្ឋិតា កាមា និម្មិតា កាមា បរនិម្មិតា កាមា បរិគ្គហិតា កាមា អបរិគ្គហិតា កាមា មមាយិតា កាមា អមមាយិតា កាមា សព្វេបិ កាមាវចរា ធម្មា សព្វេបិ រូបាវចរា ធម្មា សព្វេបិ អរូបាវចរា ធម្មា តណ្ហាវត្ថុកា តណ្ហារម្មណា កាមនីយដ្ឋេន រជនីយដ្ឋេន មទនីយដ្ឋេន កាមា ឥមេ វុច្ចន្តិ វត្ថុកាមា ។

វត្ថុកាម តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង និងវត្ថុដែលគួរត្រេកអរ ណាមួយ ហៅថា វត្ថុកាម ។ មួយទៀត កាមទាំងឡាយជាអតីត កាមទាំងឡាយជាអនាគត កាមទាំងឡាយជាបច្ចុប្បន្ន កាមទាំងឡាយជាខាងក្នុង កាមទាំងឡាយជាខាងក្រៅ កាមទាំងឡាយ ទាំងខាងក្នុងខាងក្រៅ កាមទាំងឡាយថោកទាប កាមទាំងឡាយជាកណ្តាល កាមទាំងឡាយដ៏ឧត្តម កាមទាំងឡាយមានក្នុងអបាយ កាមទាំងឡាយមានក្នុងមនុស្ស កាមទាំងឡាយជាទិព្វ កាមទាំងឡាយ ដែលតាំងឡើងឯង កាមទាំងឡាយ ដែលខ្លួននិម្មិត កាមទាំងឡាយ ដែលអ្នកដទៃនិម្មិត កាមទាំងឡាយ ដែលគេហួងហែង កាមទាំងឡាយដែលគេមិនហួងហែង កាមទាំងឡាយ ដែលគេប្រកាន់ថារបស់អញ កាមទាំងឡាយ ដែលគេមិនប្រកាន់ថារបស់អញ ពួកធម៌ជាកាមាវចរទាំងអស់ក្តី ពួកធម៌ជារូបាវចរទាំងអស់ក្តី ពួកធម៌ជាអរូបាវចរទាំងអស់ក្តី ដែលជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថា កាម ដោយអត្ថថាគួរប្រាថ្នា ដោយអត្ថថាគួរត្រេកអរ ដោយអត្ថថាជាហេតុញុាំងសេចក្តីស្រវឹងឲ្យកើត ទាំងនេះ ហៅថា វត្ថុកាម ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

កតមេ កិលេសកាមា ។ ឆន្ទោ កាមោ រាគោ
កាមោ ឆន្ទរាគោ កាមោ សង្កប្បោ កាមោ រាគោ
កាមោ សង្កប្បរាគោ កាមោ យោ កាមេសុ កាម-
ច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមស្នេហោ
កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោ-
ឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ
អទ្ទសំ កាម តេ មូលំ សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ ឯវំ កាម ន ហោហិសិ ។
ឥមេ វុច្ចន្តិ កិលេសកាមា ។ លោកេតិ អបាយ-
លោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ
ធាតុលោកេ អាយតនលោកេ ។ កាមា ហិ លោកេ
ន ហិ សុប្បហាយាតិ កាមា ហិ លោកេ ទុប្បហាយា

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

កិលេសកាម តើដូចម្តេច ។ សេចក្តីពេញចិត្ត ឈ្មោះថា កាម សេចក្តីត្រេកអរ ឈ្មោះថា កាម សេចក្តីត្រេកអរមានកម្លាំង ឈ្មោះថា កាម សេចក្តីត្រិះរិះ ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម សេចក្តីត្រេកអរដោយការត្រិះរិះ ឈ្មោះថាកាម បានដល់សេចក្តីពេញចិត្តគឺកាម សេចក្តីត្រេកអរគឺកាម សេចក្តីត្រេកត្រអាលគឺកាម សេចក្តីប្រាថ្នាគឺកាម សេចក្តីស្រឡាញ់គឺកាម សេចក្តីក្តៅក្រហាយ គឺកាម ការជ្រប់គឺកាម សេចក្តីចូលចិត្តមាំគឺកាម អន្លង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម និវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ (និងពាក្យ ដែលព្រះមានព្រះភាគត្រាស់ថា)

ម្នាលកាម តថាគតបានឃើញដើមកំណើតអ្នកហើយ ម្នាល
កាម អ្នកឯងកើតអំពីសេចក្តីត្រិះរិះ តថាគត មិនត្រិះរិះ
ចំពោះអ្នកទៀតទេ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹង
មិនមានឡើយ ។

ទាំងនេះ លោកហៅថា កិលេសកាម ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក ក្នុងមនុស្សលោក ក្នុងទេវលោក ក្នុងខន្ធលោក ក្នុងធាតុលោក ក្នុងអាយតនលោក ។ ពាក្យថា ដ្បិត កាមទាំងឡាយ ក្នុងលោក បុគ្គលមិនមែនលះបង់បាន ដោយងាយទេ បាន សេចក្តីថា ដ្បិតកាមទាំងឡាយ ក្នុងលោក គេលះបង់បានដោយក្រ

ទុច្ចជា ទុប្បរិច្ចជា ទុន្និម្មទយា ទុព្ពិនិវេឋយា ទុត្តរា ទុប្បតរា ទុស្សមតិក្កមា ទុព្វីតិវត្តាតិ កាមា ហិ លោកេ ន ហិ សុប្បហាយា ។ តេនាហ ភគវា

សត្តោ គុហាយំ ពហុនាភិឆន្នោ
តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ
ទូរេ វិវេកា ហិ តថាវិធោ សោ
កាមា ហិ លោកេ ន ហិ សុប្បហាយាតិ ។

(៣៩) ឥច្ឆានិទានា ភវសាតពទ្ធា(១)
តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា
បច្ឆា បុរេ វាបិ អបេក្ខមានា
ឥមេវ កាមេ បុរិមេវ ជប្បំ ។

---

១ កត្ថចិ បោត្ថកេ ភវសោតពទ្ធាតិ បាឋោ ទិស្សតិ ។

ព្រោះបង់បានដោយក្រ លះលែងបានដោយក្រ ញ៉ាំញីបានដោយក្រ ដោះស្រាយបានដោយក្រ ឆ្លងបានដោយក្រ ឆ្លងកាត់បានដោយក្រ កន្លងបានដោយក្រ វៀងបានដោយក្រ ហេតុនោះ (ទ្រង់ត្រាស់ថា) កាមទាំងឡាយក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

នរជនកាលឋិតនៅ ជាប់នៅក្នុងគុហា ត្រូវកិលេសដ៏ច្រើន
បិទបាំង លិចចុះក្នុងមោហៈ នរជនមានសភាពដូច្នោះ
នោះ (ឋិតនៅ) ក្នុងទីឆ្ងាយអំពីវិវេក ដ្បិតកាមទាំងឡាយ
ក្នុងលោក បុគ្គលមិនមែនលះបង់បានដោយងាយទេ ។

(៣៥) ពួកសត្វទាំងនោះ មានសេចក្តីប្រាថ្នាជាហេតុ ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការចំរើន អាឡោះអាល័យក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន ប្រាថ្នានូវកាមទាំងនេះ ឬនូវកាម ក្នុងកាលមុន រមែងរួចបានដោយក្រ ទាំងញ៉ាំងបុគ្គលដទៃឲ្យរួចមិនបាន ។

(៣៦) ពាក្យថា មានសេចក្តីប្រាថ្នាជាហេតុ ជាប់ចំពាក់ ដោយ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

(៣៦) ឥច្ឆានិទានា ភវសាតពទ្ធាតិ ឥច្ឆាតិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទិ នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ[(១)] សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សុត្តំ វិសដា អាយូហានី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវោ ស្នេហោ អបេក្ខា បដិពន្ធា អាសា អាសីសនា អាសីសិតត្តំ រូបាសា សទ្ទាសា គន្ធាសា រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា បុត្តាសា ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បា ជប្បនា ជប្បិតត្តំ លោលុប្បា លោលុប្បាយនា លោលុប្បាយិតត្តំ បុច្ឆញ្ចិកតា សាធុកម្យតា

---

១ ម. គេធោ បលិគេធោ ។

សេចក្តីត្រេកអរក្នុងការចំរើន អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកមានកម្លាំង សេចក្តីក្តួបកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយ សេចក្តីរីករាយនឹងតម្រេក តម្រេកដ៏មានកម្លាំងរបស់ចិត្ត សេចក្តីប្រាថ្នា សេចក្តីជ្រប់ចុះ កិរិយាងប់ចុះ សេចក្តីជំពាក់ចិត្ត សេចក្តីជំពាក់មាំ គ្រឿងជាប់ ភក់ កិរិយាស្វែងរក ការលាក់ពុត កិលេសជាតិជាគ្រឿងញុំាងសត្វឲ្យកើត ជាគ្រឿងញុំាងទុក្ខឲ្យកើត ជាគ្រឿងតាក់ស្រែះ កិលេសជាតិដូចជាសំណាញ់ ជាគ្រឿងហូរទៅ ផ្សាយទៅ ក្រសែ គឺតណ្ហា កិលេសជាតិដ៏ទូលាយ ជាគ្រឿងញុំាងអាយុឲ្យវិនាស (របស់សត្វ) ជាគំរប់ពីរ ជាគ្រឿងតំកល់ទុក ជាគ្រឿងនាំសត្វទៅកាន់ភព កិលេសជាតិដូចជាព្រៃធំ ដូចជាព្រៃតូច សេចក្តីស្និទ្ធស្នាល សេចក្តីស្នេហា សេចក្តីអាល័យ សេចក្តីជាប់ចំពាក់ សេចក្តីប៉ុនប៉ង សេចក្តីទឹកជញ្ជីង ភាពនៃចិត្តទឹកជញ្ជីង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងកូន បំណងជីវិត ការជាប់ ការជាប់ទួទៅ ការជាប់ក្រៃលែង ការជាប់ កិរិយាជាប់ ភាពនៃចិត្តជាប់ ការជក់ស្អិត កិរិយាជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តទៀបទៀប់ ភាពនៃចិត្តប្រាថ្នាខ្លាំងក្លា

អធម្មរាគោ វិសមលោភោ និកន្តិ និកាមនា បត្ថនា បិហនា សម្បត្ថនា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ យោគោ គន្ថោ ឧបាទានំ អាវរណំ និវរណំ ឆទនំ ពន្ធនំ ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្បភវោ មារបាសោ មារពឡិសំ មារវិសយោ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ ។ តណ្ហានិទានាតិ តណ្ហានិទានា(១) តណ្ហាហេតុកា តណ្ហាបច្ចយា តណ្ហាការណា តណ្ហាបភវាតិ តណ្ហានិទានា ។ កាមសោតព្ពាតិ ឯតំ កាមសាតំ សុខា វេទនា ។

---

១ ម. តណ្ហានិទានកា ។

តម្រេកមិនត្រូវតាមធម៌ សេចក្តីលោភមិនស្មើ សេចក្តីអាល័យ កិលេស–ជាតិជាទីអាល័យ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាគ្រប់យ៉ាង បំណងក្នុងកាម បំណងក្នុងសេចក្តីចំរើន បំណងក្នុងសេចក្តីវិនាស បំណងក្នុងរូប បំណងក្នុងអរូប បំណងក្នុងនិរោធ បំណងក្នុងរូប បំណងក្នុងសំឡេង បំណងក្នុងក្លិន បំណងក្នុងរស បំណងក្នុងផ្សព្វ បំណងក្នុងធម៌ អន្លង់ គ្រឿងប្រកបទុក គ្រឿងដោតក្រង គ្រឿងប្រកាន់ កិរិយារពាំង កិរិយាទប់ កិរិយាប្រក់ កិរិយាចង កិរិយាសៅហ្មង កិរិយាដេកត្រាំ កិរិយាស្អក់ វល្លិគឺតណ្ហា សេចក្តីប្រាថ្នាផ្សេងៗ ឫសគល់នៃសេចក្តីទុក្ខ ហេតុនៃសេចក្តីទុក្ខ ដែនកើតនៃសេចក្តីទុក្ខ អន្ទាក់នៃមារ សន្ទូចនៃមារ វិស័យនៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ដងដោយគឺតណ្ហា សមុទ្ទគឺតណ្ហា អភិជ្ឈា លោភៈ ឫសគល់នៃអកុសល ។ ពាក្យថា មានសេចក្តីប្រាថ្នាជាហេតុ គឺមានសេចក្តីប្រាថ្នាជានិទាន មានសេចក្តីប្រាថ្នាជាហេតុ មានសេចក្តីប្រាថ្នាជាបច្ច័យ មានសេចក្តីប្រាថ្នាជាការណ៍ មានសេចក្តីប្រាថ្នាជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) មានសេចក្តីប្រាថ្នាជាហេតុ ។ ពាក្យថា ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងការចំរើន គឺសេចក្តីត្រេកអរក្នុងការចំរើន១ គឺសុខវេទនា ។

ទ្វេ ភវសាតានិ សុខា ច វេទនា ឥដ្ឋញ្ច វត្ថុ ។ តីណិ ភវសាតានិ យោព្ពញ្ញំ អារោគ្យំ ជីវិតំ ។ ចត្តារិ ភវសាតានិ លាភោ យសោ បសំសា សុខំ ។ បញ្ច ភវសាតានិ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ។ ឆ ភវសាតានិ ចក្ខុសម្បទា សោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ។ ភវសាតពទ្ធាតិ[១] សុខាយ វេទនាយ ពទ្ធា[២] ឥដ្ឋស្មឹ វត្ថុស្មឹ ពទ្ធា យោព្ពញ្ញេ ពទ្ធា អារោគ្យេ ពទ្ធា ជីវិតេ ពទ្ធា លាភេ ពទ្ធា យសេ ពទ្ធា បសំសាយ ពទ្ធា សុខេ ពទ្ធា មនាបិកេសុ រូបេសុ ពទ្ធា សទ្ទេសុ គន្ធេសុ រសេសុ មនាបិកេសុ ផោដ្ឋព្វេសុ ពទ្ធា ចក្ខុសម្បទាយ ពទ្ធា សោតសម្បទាយ ឃានសម្បទាយ ជិវ្ហាសម្បទាយ កាយសម្បទាយ មនោសម្បទាយ ពទ្ធា វិពទ្ធា អាពទ្ធា លគ្គា លគ្គិតា បលិពុទ្ធាតិ ឥច្ឆានិទានា ភវសាតពទ្ធា ។

---

១ ម. តិសទ្ទោ នត្ថិ ។ ២ ម. វេទនាយ សាតពទ្ធា ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

សេចក្តីត្រេកអរ ក្នុងការចំរើន ២ គឺសុខវេទនា ១ វត្ថុជាទីប្រាថ្នា ១ ។ សេចក្តីត្រេកអរ ក្នុងការចំរើន ៣ គឺភាពនៅក្មេង ១ ការមិនមានរោគ ១ ជីវិត ១ ។ សេចក្តីត្រេកអរ ក្នុងការចំរើន ៤ គឺលាភ ១ យស ១ សេចក្តីសរសើរ ១ សុខ ១ ។ សេចក្តីត្រេកអរ ក្នុងការចំរើន៥ គឺរូបជាទីគាប់ចិត្ត ១ សំឡេងជាទីគាប់ចិត្ត ១ ក្លិនជាទីគាប់ចិត្ត ១ រសជាទីគាប់ចិត្ត ១ ផ្សព្វជាទីគាប់ចិត្ត ១ ។ សេចក្តីត្រេកអរ ក្នុងការចំរើន ៦ គឺចក្ខុសម្បទា ១ សោតសម្បទា ១ ឃានសម្បទា ១ ជិវ្ហាសម្បទា ១ កាយសម្បទា ១ មនោសម្បទា ១ ។ ពាក្យថា ជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងការចំរើន គឺ ជាប់ក្នុងសុខវេទនា ជាប់ក្នុងវត្ថុជាទីប្រាថ្នា ជាប់ក្នុងភាពនៅក្មេង ជាប់ក្នុងការមិនមានរោគ ជាប់ក្នុងជីវិត ជាប់ក្នុងលាភ ជាប់ក្នុងយស ជាប់ក្នុងសេចក្តីសរសើរ ជាប់ក្នុងសុខ ជាប់ក្នុងរូបជាទីគាប់ចិត្ត ក្នុងសំឡេង ក្នុងក្លិន ក្នុងរស ជាប់ក្នុងផ្សព្វជាទីគាប់ចិត្ត ជាប់ក្នុងចក្ខុសម្បទា ជាប់ចំពាក់ ជាប់ដោយអាការផ្សេងៗ ស្អិត ទាក់ ជ្ពក់ ពន្ធ័ពន្ធ័ ក្នុងសោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ហេតុនោះ (ទ្រង់ត្រាស់ថា) មានសេចក្តីប្រាថ្នាជាហេតុ ជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងការចំរើន ។

[៣៧] តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខាតិ តេ
វា វត្ថុកាមា ទុប្បមុញ្ចា សត្តា វា តតោ ទុម្មោចយា ។
កថំ តេ វត្ថុកាមា ទុប្បមុញ្ចា ។ សុខា វេទនា
ទុម្មុញ្ចា ឥដ្ឋំ វត្ថុ ទុម្មុញ្ចំ យោព្វនំ ទុម្មុញ្ចំ អារោគ្យំ
ទុម្មុញ្ចំ ជីវិតំ ទុម្មុញ្ចំ លាភោ ទុម្មុញ្ចោ យសោ ទុម្មុញ្ចោ
បសំសា ទុម្មុញ្ចា សុខំ ទុម្មុញ្ចំ មនាបិកា រូបា ទុម្មុញ្ចា
មនាបិកា សទ្ទា គន្ធា រសា ផោដ្ឋព្វា ទុម្មុញ្ចា ចក្ខុ-
សម្បទា ទុម្មុញ្ចា សោតសម្បទា ឃានសម្បទា ជិវ្ហា-
សម្បទា កាយសម្បទា មនោសម្បទា ទុម្មុញ្ចា
ទុប្បមុញ្ចា ទុម្មោចយា ទុប្បមោចយា ទុន្និម្មោចយា

(៣៧) ពាក្យថា ពួកសត្វទាំងនោះ រមែងរួចបានដោយក្រ ទាំងញុំាងបុគ្គលដទៃឲ្យរួចមិនបាន អធិប្បាយថា អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរ ក្នុងការបំរើនទាំងនោះ ពួកសត្វដោះបានដោយក្រ ឬពួកសត្វរួចបានដោយក្រ ចាកអារម្មណ៍នុ៎ះ ។

អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរ ក្នុងការបំរើនទាំងនោះ ពួកសត្វដោះបានដោយក្រ តើដូចម្តេច ។ សុខវេទនា សត្វដោះបានដោយកម្រ វត្ថុជាទីប្រាថ្នា សត្វដោះបានដោយកម្រ ភាពនៅក្មេង សត្វដោះបានដោយកម្រ ការមិនមានរោគ សត្វដោះបានដោយកម្រ ជីវិត សត្វដោះបានដោយកម្រ លាភ សត្វដោះបានដោយកម្រ យស សត្វដោះបានដោយកម្រ សេចក្តីសរសើរ សត្វដោះបានដោយកម្រ សុខ សត្វដោះបានដោយកម្រ រូបទាំងឡាយជាទីគាប់ចិត្ត សត្វដោះបានដោយកម្រ សំឡេង ក្លិន រស ផ្សព្វ ជាទីគាប់ចិត្ត សត្វដោះបានដោយកម្រ ចក្ខុសម្បទា សត្វដោះបានដោយកម្រ សោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា សត្វដោះបានដោយកម្រ ដោះស្រឡះបានដោយកម្រ ដោះចេញបានដោយកម្រ ដោះចេញស្រឡះបានដោយកម្រ ញុំាញើបានដោយកម្រ ដោះចេញបានដោយកម្រ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ទុព្វិនិវេឋយា ទុត្តរា ទុប្បតរា ទុស្សមតិក្កមា ទុព្វីតិវត្តា ។ ឯវំ តេ ករសាតវត្ថុ ទុប្បមុញ្ចា ។

កថំ សត្តា ឯត្ថ ទុម្មោចយា ។ សុខាយ វេទនាយ សត្តា ទុម្មោចយា ឥដ្ឋស្មា វត្ថុស្មា ទុម្មោចយា យោព្វញ្ញា ទុម្មោចយា អារោគ្យា ទុម្មោចយា ជីវិតា ទុម្មោចយា លាភា ទុម្មោចយា យសា ទុម្មោចយា បសំសាយ ទុម្មោចយា សុខា ទុម្មោចយា មនាបិកេហិ រូបេហិ ទុម្មោចយា មនាបិកេហិ សទ្ទេហិ គន្ធេហិ រសេហិ ផោដ្ឋព្វេហិ ទុម្មោចយា ចក្ខុសម្បទាយ ទុម្មោចយា សោតសម្បទាយ ឃានសម្បទាយ ជិវ្ហាសម្បទាយ កាយសម្បទាយ មនោសម្បទាយ ទុម្មោចយា ទុប្បមោចយា ទុរុទ្ធរា ទុស្សមុទ្ធរា ទុព្វុដ្ឋាបនា ទុស្សមុដ្ឋាបនា ។ ឯវំ សត្តា ឯត្ថ ទុម្មោចយាតិ តេ ទុប្បមុញ្ចា ។

ឆ្លងបានដោយកម្រ ឆ្លងកាត់បានដោយកម្រ កន្លងបានដោយកម្រ រំលងបានដោយកម្រ ។ អារម្មណ៍ជាវត្ថុនៃសេចក្តីត្រេកអរ ក្នុងការចំរើនទាំងនោះ សត្វរូបបានដោយក្រ យ៉ាងនេះ ។

ពួកសត្វរូបបានដោយក្រ តាមធម៌ទុះ តើដូចម្តេច ។ ពួកសត្វរូបបានដោយកម្រ តាមសុខវេទនា រូបបានដោយកម្រ តាមវត្ថុជាទីប្រាថ្នា រូបបានដោយកម្រ តាមភាពនៅក្មេង រូបបានដោយកម្រ តាមការមិនមានរោគ រូបបានដោយកម្រ តាមជីវិត រូបបានដោយកម្រ តាមលាភ រូបបានដោយកម្រ តាមយស រូបបានដោយកម្រ តាមសេចក្តីសរសើរ រូបបានដោយកម្រ តាមសុខ រូបបានដោយកម្រ តាមរូបទាំងឡាយជាទីគាប់ចិត្ត រូបបានដោយកម្រ តាមសំឡេង ក្លិន រស ផ្សព្វជាទីគាប់ចិត្ត រូបបានដោយកម្រ តាមចក្ខុសម្បទា រូបបានដោយកម្រ រូបស្រឡះបានដោយកម្រ រើចេញបានដោយកម្រ ស្ទុះឡើងបានដោយកម្រ ក្រោកឡើងបានដោយកម្រ លោតឡើងបានដោយកម្រ តាមសោតសម្បទា ឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា មនោសម្បទា ។ ពួកសត្វរូបបានដោយក្រ តាមធម៌ទុះ យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វទាំងនោះ រូបបានដោយក្រ ។

ន ហិ អញ្ញមោក្ខាតិ តេ អត្តនា បលិបបលិបន្នា ន សក្កោន្តិ បរំ បលិបបលិបន្នំ ឧទ្ធរិតុំ ។ វុត្តំ ហេតំ ភគវតា សោ វត ចុន្ទ អត្តនា បលិបបលិបន្នោ បរំ បលិបបលិបន្នំ ឧទ្ធរិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ចុន្ទ អត្តនា អទន្តោ អវិនីតោ អបរិនិព្វុតោ បរំ ទមេស្សតិ វិនេស្សតិ បរិនិព្វាបេស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ ឯវំ ន ហិ អញ្ញមោក្ខា ។ អថវា នត្ថញ្ញោ កោចិ មោចេតុំ តេ យេន មុច្ចេយ្យុំ សកេន ថាមេន សកេន ពលេន សកេន វីរិយេន សកេន បរក្កមេន សកេន បុរិសត្ថាមេន សកេន បុរិសពលេន សកេន បុរិសវីរិយេន សកេន បុរិសបរក្កមេន អត្តនា សម្មាបដិបទំ អនុលោមបដិបទំ អបច្ចនីកបដិបទំ អន្វត្ថបដិបទំ ធម្មានុធម្មបដិបទំ បដិបជ្ជមានា មុច្ចេយ្យុន្តិ ។ ឯវម្បិ ន ហិ អញ្ញមោក្ខា ។

ពាក្យថា ទាំងញុំាងអ្នកដទៃឲ្យរួចមិនបាន សេចក្តីថា សត្វទាំងនោះ ជាអ្នកលិចកប់ក្នុងភក់ដោយខ្លួនឯង មិនអាចនឹងស្រង់បុគ្គលដទៃ ដែលលិចកប់ក្នុងភក់បានទេ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទៈ បុគ្គលនោះឯង លិចកប់ក្នុងភក់ដោយខ្លួនឯង នឹងស្រង់បុគ្គលដទៃដែលលិចកប់ក្នុងភក់បាន ហេតុដូច្នេះនេះ មិនមានទេ ម្នាលចុន្ទៈ បុគ្គលនោះឯង មិនទាន់ទូន្មានខ្លួន មិនទាន់ប្រៀនប្រដៅខ្លួន មិនទាន់រលត់កិលេស ដោយខ្លួនឯងទេ នឹងទូន្មាន ប្រៀនប្រដៅបុគ្គលដទៃ (នឹងញុំាងបុគ្គលដទៃ) ឲ្យរលត់កិលេសបាន ហេតុដូច្នេះនេះ មិនមានទេ ។ ពួកសត្វមិនអាចញុំាងអ្នកដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។ ម្យ៉ាងទៀត បុគ្គលដទៃណាមួយ អាចញុំាងបុគ្គលដទៃឲ្យរួចបាន មិនមានទេ ប្រសិនបើ ពួកសត្វនោះគប្បីរួច លុះតែប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ដោយខ្លួនឯង ដោយកំឡាំងញាណរបស់ខ្លួន ដោយពលញាណរបស់ខ្លួន ដោយព្យាយាមរបស់ខ្លួន ដោយការប្រឹងប្រែងរបស់ខ្លួន ដោយកំឡាំងបុរសរបស់ខ្លួន ដោយពលញាណនៃបុរសរបស់ខ្លួន ដោយព្យាយាមនៃបុរសរបស់ខ្លួន ដោយការប្រឹងប្រែងនៃបុរសរបស់ខ្លួន ទើបរួចបាន ។ ពួកសត្វមិនអាចញុំាងអ្នកដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

វុត្តំ ហេតំ ភគវតា

នាហំ សហិស្សាមិ បមោចនាយ
កថំកថី(១) ធោតក កញ្ចិ លោកេ
ធម្មញ្ច សេដ្ឋំ អភិជានមានោ
ឯវំ តុវំ ឱឃមិមំ តរេសីតិ

ឯវម្បិ ន ហិ អញ្ញមោក្ខា ។ វុត្តំ ហេតំ ភគវតា

អត្តនា បកតំ បាបំ អត្តនា សំកិលិស្សតិ
អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេតិ ។

ឯវម្បិ ន ហិ អញ្ញមោក្ខា ។ វុត្តំ ហេតំ ភគវតា ឯវមេវ ខោ ព្រាហ្មណ តិដ្ឋតេវ និព្វានំ តិដ្ឋតិ និព្វានគាមិមគ្គោ តិដ្ឋាមហំ សមាទបេតា អថ ច បន មម សាវកា មយា ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អប្បេកច្ចេ អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ ឯកច្ចេ នារាធេន្តិ ឯត្ថ ក្យាហំ ព្រាហ្មណ ករោមិ មគ្គក្ខាយី ព្រាហ្មណ តថាគតោ មគ្គំ ពុទ្ធោ អាចិក្ខតិ អត្តនា បដិបជ្ជមានា មុច្ចេយ្យុន្តិ ។

---
១ ម. កថំកថំ ។

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

មួយទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា

ម្នាលធោតកៈ តថាគតមិនអាចញុំាងបុគ្គលណាមួយ ដែលមានសេចក្ដីសង្ស័យក្នុងលោក ឲ្យរួចបានទេ អ្នកកាលដឹងច្បាស់នូវធម៌ដ៏ប្រសើរ នឹងឆ្លងអន្លង់នេះ យ៉ាងនេះបាន ។

ពួកសត្វ មិនអាចនឹងញុំាងអ្នកដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។ មួយទៀត ពាក្យនេះ ព្រះមានព្រះភាគ ត្រាស់ហើយថា

បុគ្គលធ្វើបាប ដោយខ្លួនឯង នឹងសៅហ្មងដោយខ្លួនឯង មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធ ដោយខ្លួនឯង សេចក្ដីបរិសុទ្ធិ នឹងមិនបរិសុទ្ធិ កើតចំពោះខ្លួន បុគ្គលដទៃ នឹងញុំាងបុគ្គលដទៃឲ្យបរិសុទ្ធ មិនបានទេ ។

ពួកសត្វមិនអាចញុំាងបុគ្គលដទៃឲ្យរួចបាន យ៉ាងនេះខ្លះ ។ មួយវិញទៀត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា ម្នាលព្រាហ្មណ៍ ព្រះនិព្វានក៏តាំងនៅ ផ្លូវជាទីទៅកាន់ព្រះនិព្វានក៏តាំងនៅ តថាគតជាអ្នកណែនាំ ក៏ឋិតនៅ យ៉ាងនេះឯង ប៉ុន្តែសាវ័កទាំងឡាយរបស់តថាគត ដែលតថាគតកាលទូន្មានយ៉ាងនេះ កាលប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះបានព្រះនិព្វានជាទីសម្រេចទីបំផុត ពួកខ្លះមិនបាន ម្នាលព្រាហ្មណ៍ តថាគតនឹងធ្វើដូចម្ដេច ចំពោះសាវ័កទាំងនុ៎ះ ម្នាលព្រាហ្មណ៍ ព្រះតថាគតជាអ្នកប្រាប់ផ្លូវ ព្រះពុទ្ធរមែងប្រាប់ផ្លូវ ពួកសត្វកាលប្រតិបត្តិ គប្បីរួចដោយខ្លួនឯង ។

ឋបេត្វា ន ហិ អញ្ញមោក្ខាតិ តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា(១) ។

(៣៨) បច្ឆា បុរេ វាបិ អបេក្ខមានាតិ បច្ឆា វុច្ចតិ អនាគតំ បុរេ វុច្ចតិ អតីតំ ។ អបិច អតីតំ ឧបាទាយ អនាគតញ្ច បច្ចុប្បន្នញ្ច បច្ឆា អនាគតំ ឧបាទាយ អតីតញ្ច បច្ចុប្បន្នញ្ច បុរេ ។

កថំ បុរេ អបេក្ខំ ករោតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វាគមេតិ(២) ឯវំវេទនោ អហោសឹ ឯវំសញ្ញោ អហោសឹ ឯវំសង្ខារោ អហោសឹ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វាគមេតិ ។ ឯវម្បិ បុរេ អបេក្ខំ ករោតិ ។ អថវា ឥតិ មេ ចក្ខុ អហោសិ អតីតមទ្ធានំ ឥតិ រូបាតិ តត្ថ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ ឯវម្បិ បុរេ អបេក្ខំ ករោតិ ។

---

១ ម. តេ ទុប្បមុញ្ចា ន ហិ តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា ។ ២ ម. សមន្នានេតិ ។

ពួកសត្វមិនអាចញុំាងអ្នកដទៃឲ្យរួចយ៉ាងនេះខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វទាំងនោះ រួចបានដោយក្រ ពាំងញុំាងអ្នកដទៃឲ្យរួចមិនបាន ។

[ ៣៨ ] ពាក្យថា កាលប្រាថ្នាកាម ក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន អធិប្បាយថា អនាគត លោកហៅថា កាលជាខាងក្រោយ អតីត លោកហៅថា កាលមុន ។ ម្យ៉ាងទៀត អនាគតនឹងបច្ចុប្បន្ន ដែលអាស្រ័យនឹងអតីត ឈ្មោះថា កាលខាងក្រោយ អតីតនឹងបច្ចុប្បន្ន ដែលអាស្រ័យនឹងអនាគត ឈ្មោះថា កាលមុន ។

នរជនធ្វើ នូវសេចក្តីប្រាថ្នា ក្នុងកាលមុន តើដោយប្រការដូចម្តេច ។ នរជន ញុំាងសេចក្តីត្រេកអរឲ្យកើត ក្នុងរូបារម្មណ៍នោះថា អាត្មាអញ មានរូបយ៉ាងនេះហើយ ក្នុងអតីតកាល ដល់ព្រមនូវសេចក្តីត្រេកអរក្នុងវេទនាជាដើមនោះថា អាត្មាអញមានវេទនាយ៉ាងនេះហើយ មានសញ្ញាយ៉ាងនេះហើយ មានសង្ខារយ៉ាងនេះហើយ មានវិញ្ញាណយ៉ាងនេះហើយ ក្នុងអតីតកាល ។ នរជនធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលមុន យ៉ាងនេះខ្លះ ។ មួយវិញទៀត វិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគ ក្នុងអាយតនៈនោះថា អញមានចក្ខុដូចនេះ មានរូបដូចនេះហើយ ក្នុងអតីតកាល នរជនតែងត្រេកអរនឹងអាយតនៈនោះ ព្រោះវិញ្ញាណជាប់ចំពាក់ ដោយឆន្ទរាគ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថា ធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលមុន យ៉ាងនេះខ្លះ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

នត្ថិ មេ សោតំ អហោសិ អតីតមទ្ធានំ នត្ថិ សទ្ទាតិ ។ នត្ថិ មេ ឃានំ អហោសិ អតីតមទ្ធានំ នត្ថិ គន្ធាតិ ។ នត្ថិ មេ ជិវ្ហា អហោសិ អតីតមទ្ធានំ នត្ថិ រសាតិ ។ នត្ថិ មេ កាយោ អហោសិ អតីតមទ្ធានំ នត្ថិ ផោដ្ឋព្វាតិ ។ នត្ថិ មេ មនោ អហោសិ អតីតមទ្ធានំ នត្ថិ ធម្មាតិ តត្ថ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ ឯវម្បិ ពុរេ អបេក្ខំ ករោតិ ។ អថវា យានិស្ស តានិ បុព្វេ មាតុគាមេន សទ្ធិំ ហសិតលបិតកីឡិតានិ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តិំ អាបជ្ជតិ ។ ឯវម្បិ ពុរេ អបេក្ខំ ករោតិ ។

កថំ បច្ឆា អបេក្ខំ ករោតិ ។ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្នាគមេតិ ឯវំវេទនោ សិយំ ឯវំសញ្ញោ សិយំ ឯវំសង្ខារោ សិយំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្នាគមេតិ ។

ថា អញមានសោតៈ ដូច្នេះ មានសំឡេងដូច្នេះហើយ ក្នុងអតីតកាល ។ ថា អញមានឃានៈដូច្នេះ មានក្លិនដូច្នេះហើយ ក្នុងអតីតកាល ។ ថា អញមានជិវ្ហាដូច្នេះ មានរសដូច្នេះហើយ ក្នុងអតីតកាល ។ ថា អញមានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះហើយ ក្នុងអតីតកាល ។ វិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគ ក្នុងអាយតនៈនោះថា អញមានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះហើយ ក្នុងអតីតកាល នរជនរមែងត្រេកអរនឹងអាយតនៈនោះ ព្រោះវិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្ដីប្រាថ្នា ក្នុងកាលមុន យ៉ាងនេះខ្លះ ។ ម្យ៉ាងទៀត នរជននោះ សើច ចរចា ឬលេង ជាមួយនឹងមាតុគ្រាមក្នុងកាលមុន ក៏ត្រេកអរនឹងអារម្មណ៍នោះ ប្រាថ្នានូវអារម្មណ៍នោះ ដល់នូវសេចក្ដីត្រេកអរដោយអារម្មណ៍នោះ ។ នរជនធ្វើនូវសេចក្ដីប្រាថ្នា ក្នុងកាលមុន យ៉ាងនេះខ្លះ ។

នរជនធ្វើនូវសេចក្ដីប្រាថ្នា ក្នុងកាលជាខាងក្រោយ តើដូចម្ដេច ។ នរជន ញ៉ាំងសេចក្ដីត្រេកអរ ឲ្យកើតក្នុងរូបារម្មណ៍នោះថា អាត្មាអញ គប្បីជាអ្នកមានរូបយ៉ាងនេះ ក្នុងអនាគតកាល ដល់ព្រមនូវសេចក្ដីត្រេកអរ ក្នុងវេទនាជាដើមនោះថា អាត្មាអញ គប្បីជាអ្នកមានវេទនាយ៉ាងនេះ មានសញ្ញាយ៉ាងនេះ មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ។

ឯវម្បិ បច្ឆា អបេក្ខំ ករោតិ ។ អថវា ឥតិ មេ ចក្ខុ សិយា អនាគតមទ្ធានំ ឥតិ រូបាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ បណិទហតិ ចេតសោ បណិធានប្បច្ចយា តទភិនន្ទតិ តទភិនន្ទន្តោ ឯវម្បិ បច្ឆា អបេក្ខំ ករោតិ ។ ឥតិ មេ សោតំ សិយា អនាគតមទ្ធានំ ឥតិ សទ្ទាតិ ។ ឥតិ មេ ឃានំ សិយា អនាគតមទ្ធានំ ឥតិ គន្ធាតិ ។ ឥតិ មេ ជិវ្ហា សិយា អនាគតមទ្ធានំ ឥតិ រសាតិ ។ ឥតិ មេ កាយោ សិយា អនាគតមទ្ធានំ ឥតិ ផោដ្ឋព្វាតិ ។ ឥតិ មេ មនោ សិយា អនាគតមទ្ធានំ ឥតិ ធម្មាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ បណិទហតិ ចេតសោ បណិធានប្បច្ចយា តទភិនន្ទតិ តទភិនន្ទន្តោ ឯវម្បិ បច្ឆា អបេក្ខំ ករោតិ ។ អថវា ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ បណិទហតិ ចេតសោ បណិធានប្បច្ចយា

នរជន ធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលជាខាងក្រោយ យ៉ាងនេះខ្លះ ។ មួយទៀត នរជនតំកល់ចិត្ត ដើម្បីបានបំពោះនូវអាយតនៈ ដែលមិនទាន់បានថា អញគប្បីមានចក្ខុដូចនេះ មានរូបដូចនេះ ក្នុងអនាគតកាល ដូច្នេះ រមែងត្រេកអរនឹងអាយតនៈនោះ ព្រោះការតំកល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលជាខាងក្រោយ យ៉ាងនេះខ្លះ ។ ថា អញគប្បីមានសោតៈដូចនេះ មានសំឡេងដូចនេះ ក្នុងអនាគតកាល ។ ថា អញគប្បីមានឃានៈដូចនេះ មានគន្ធៈដូចនេះ ក្នុងអនាគតកាល ។ ថា អញគប្បីមានជីវ្ហាដូចនេះ មានរសដូចនេះ ក្នុងអនាគតកាល ។ ថាអញគប្បីមានកាយដូចនេះ មានផ្សព្វដូចនេះ ក្នុងអនាគតកាល ។ នរជនតំកល់ចិត្ត ដើម្បីបានបំពោះនូវអាយតនៈ ដែលខ្លួនមិនទាន់បានថា អញគប្បីមានចិត្តដូចនេះ មានធម្មារម្មណ៍ដូចនេះ ក្នុងអនាគតកាល ដូច្នេះ រមែងត្រេកអរនឹងអាយតនៈនោះ ព្រោះការតំកល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអាយតនៈនោះ ឈ្មោះថាធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលជាខាងក្រោយ យ៉ាងនេះខ្លះ ។ មួយទៀត នរជនតំកល់ចិត្ត ដើម្បីបានបំពោះនូវអត្តភាព ដែលខ្លួនមិនទាន់បានថា អាត្មាអញនឹងបានជាទេវតា (មានអានុភាពច្រើន) ឬជាទេវតាណាមួយ ដោយសារសីលក្តី វត្តក្តី តបៈក្តី ព្រហ្មចរិយៈនេះក្តី ដូច្នេះ រមែងត្រេកអរនឹងអត្តភាពនោះ ព្រោះការតំកល់ចិត្តជាបច្ច័យ កាលត្រេកអរនឹងអត្តភាពនោះ ឈ្មោះថាធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាល

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

តទភិនន្ទតិ តទភិនន្ទន្តោ ឯវម្បិ បច្ឆា អបេក្ខំ ករោ-
តីតិ បច្ឆា បុរេ វាបិ អបេក្ខមានា ។

(៣៩) ឥមេវ កាមេ បុរិមេវ ជប្បន្តិ ឥមេវ កា-
មេតិ បច្ចុប្បន្នេ បញ្ច កាមគុណេ ឥច្ឆន្តា សាទិយន្តា
បត្ថយន្តា បិហយន្តា អភិជប្បន្តា ។ បុរិមេវ ជប្បន្តិ
អតីតេ បញ្ច កាមគុណេ ជប្បន្តា បជប្បន្តា អភិជ-
ប្បន្តាតិ ឥមេវ កាមេ បុរិមេវ ជប្បំ ។ តេនាហ ភគវា

ឥច្ឆានិទានា ភវសាតពទ្ធា
តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា
បច្ឆា បុរេ វាបិ អបេក្ខមានា
ឥមេវ កាមេ បុរិមេវ ជប្បន្តិ ។

(៤០) កាមេសុ គិទ្ធា បសុតា បមូឡ្ហា
អវទានិយា តេ វិសមេ និវិដ្ឋា
ទុក្ខូបនីតា បរិទេវយន្តិ
កឹសុ ភវិស្សាម ឥតោ ចុតាសេ ។

ជាខាងក្រោយ យ៉ាងនេះខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វ កាលប្រាថ្នា (កាម) ក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន ៗ

(៣៩) អធិប្បាយពាក្យថា ប្រាថ្នានូវកាមទាំងនេះ ឬនូវកាមក្នុងកាលមុន ត្រង់ពាក្យថា កាមទាំងនេះ បានដល់ពួកសត្វកាលចង់បាន កាលត្រេកអរ កាលប្រាថ្នា កាលស្រឡាញ់ កាលជាប់ចិត្ត នូវកាមគុណទាំង ៥ ជាបច្ចុប្បន្ន ៗ ពាក្យថា ប្រាថ្នានូវកាមក្នុងកាលមុន បានដល់ពួកសត្វ កាលសរសើរ សរសើរសព្វ សរសើរក្រៃពេក នូវកាមគុណទាំង ៥ ជាអតីត ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាថ្នានូវកាមទាំងនេះ ឬនូវកាមក្នុងកាលមុន ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកសត្វទាំងនោះ មានសេចក្តីប្រាថ្នាជាហេតុ ជាប់ចំពាក់
ដោយសេចក្តីត្រេកអរ ក្នុងសេចក្តីចំរើន អាឡោះអាល័យកាម
ក្នុងកាលជាខាងក្រោយ ឬក្នុងកាលមុន ប្រាថ្នានូវកាមទាំង
នេះ ឬនូវកាមក្នុងកាលមុន រមែងរួចបានដោយក្រ ទាំង
ញុំាងអ្នកដទៃឲ្យរួចមិនបាន ៗ

(៤០) ជនអ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេងក្នុងកាមទាំង
ឡាយ អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើ
អ្នកដល់សេចក្តីទុក្ខទាំងនោះ រមែងខ្សឹកខ្សួលថា យើង
ទាំងឡាយ ច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎+ ៗ

(៤១) កាមេសុ គិទ្ធា បសុតា បមូឡ្ហាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ កិលេសកាមេន វត្ថុកាមេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធាតិ កាមេសុ គិទ្ធា ។ បសុតាតិ យេបិ កាមេ ឯសន្តិ គវេសន្តិ បរិយេសន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេបិ កាមប្បសុតា ។ យេបិ តណ្ហាវសេន រូបេ ឯសន្តិ គវេសន្តិ បរិយេសន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ឯសន្តិ គវេសន្តិ បរិយេសន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា

(៤១) អធិប្បាយពាក្យថា អ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេង ក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់កាម ២ យ៉ាង គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ លោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះលោកហៅថា កិលេសកាម ។ តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់ សេចក្តីត្រេកអរ សេចក្តីត្រេកអរមោទកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពួកសត្វជាអ្នកត្រេកអរ ជាប់ចំពាក់ ធ្លាក់ចុះ ផុលផប់ ជ្រុលជ្រប់ ទាក់ជ្ពក់ ពន្ធ័ពន្ធ័ ក្នុងវត្ថុកាម ព្រោះកិលេសកាម ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកជាប់ចំពាក់ ក្នុងកាមទាំងឡាយ ។ ពាក្យថា អ្នកខ្វល់ខ្វាយ សេចក្តីថា ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែង នូវកាមទាំងឡាយ ជាអ្នកត្រាច់ទៅរកកាមនោះ ច្រើនដោយកាមនោះ ធន់ក្នុងកាមនោះ ឱនទៅរកកាមនោះ សសៀរទៅរកកាមនោះ ឈមទៅរកកាមនោះ ស្ទុះទៅរកកាមនោះ ធ្វើនូវកាមនោះឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ។ ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែង នូវរូបទាំងឡាយ ប៉ុនប៉ង ស្វែងរក ស្វះស្វែង នូវសំឡេង ក្លិន រស ផស្សទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរក

តទធិមុត្តា តទាធិបតេយ្យា តេបិ កាមប្បសុតា ។ យេបិ តណ្ហាវសេន រូបេ បដិលភន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បដិលភន្តិ តច្ចរិតា តព្វហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេបិ កាមប្បសុតា ។ យេបិ តណ្ហាវសេន រូបេ បរិភុញ្ជន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បរិភុញ្ជន្តិ តច្ចរិតា តព្វហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេបិ កាមប្បសុតា ។ យថា កលហការកោ កលហប្បសុតោ កម្មការកោ កម្មប្បសុតោ គោចរេ ចរន្តោ គោចរប្បសុតោ ឈាយី ឈានប្បសុតោ ឯវមេវ

អារម្មណ៍នោះ ស្អិតទៅរកអារម្មណ៍នោះ ជ្រើអារម្មណ៍នោះ ឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ៗ មួយទៀត ពួកសត្វណា បានបំពោះ នូវរូបទាំងឡាយ បានបំពោះ នូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាប់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ទនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្អិតទៅរកអារម្មណ៍នោះ ជ្រើអារម្មណ៍នោះ ឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ៗ មួយទៀត ពួកសត្វណា បរិភោគនូវរូបទាំងឡាយ បរិភោគនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាប់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ទនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្អិតទៅរកអារម្មណ៍នោះ ជ្រើអារម្មណ៍នោះ ឲ្យជាធំ ពួកសត្វនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ៗ ជនអ្នកធ្វើនូវការឈ្លោះ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងការឈ្លោះ អ្នកធ្វើនូវការជារ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងការជារ អ្នកប្រព្រឹត្តក្នុងគោចរ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងគោចរ អ្នកមានឈាន ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងឈាន យ៉ាងណា ពួកសត្វណា ប៉ុនប៉ង

យេហិ កាមេ ឯសន្តិ គវេសន្តិ បរិយេសន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេហិ កាមប្បសុតា ។ យេហិ តណ្ហាវសេន រូបេ ឯសន្តិ គវេសន្តិ បរិយេសន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ ឯសន្តិ គវេសន្តិ បរិយេសន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេហិ កាមប្បសុតា ។ យេហិ តណ្ហាវសេន រូបេ បដិលភន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ បដិលភន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេហិ កាមប្បសុតា ។

ស្វែងរក ស្វះស្វែង នូវកាមទាំងឡាយ ជាអ្នកត្រាច់ទៅរកកាមនោះ ច្រើនដោយកាមនោះ ធ្ងន់ក្នុងកាមនោះ ឱនទៅរកកាមនោះ សសៀរទៅរកកាមនោះ ឈមទៅរកកាមនោះ ស្ងប់ទៅរកកាមនោះ ធ្វើកាមនោះឲ្យជាធំ ពួកសត្វនោះ ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ៗ មួយទៀត ពួកសត្វណា ប៉ុនប៉ង ស្វែងរក ស្វះស្វែង នូវរូបទាំងឡាយ ប៉ុនប៉ង ស្វែងរក ស្វះស្វែង នូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ងប់ទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះ ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ៗ មួយទៀត ពួកសត្វណា បានបំពោះនូវរូបទាំងឡាយ បានបំពោះនូវសំឡេង ក្លិន រស ផ្សព្វ ទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាច់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ងប់ទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វទាំងនោះ ឈ្មោះថា អ្នកខ្វល់ខ្វាយក្នុងកាម ៗ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

យេហិ តណ្ហាវសេន រូបេ បរិកុប្បន្តិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បរិកុប្បន្តិ តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យា តេហិ កាមបស្សុតា ។ បមូឡ្ហាតិ យេភុយ្យេន ទេវមនុស្សា បញ្ចសុ កាមគុណេសុ មុយ្ហន្តិ សម្មុយ្ហន្តិ សម្បមុយ្ហន្តិ មូឡ្ហា សម្មូឡ្ហា សម្បមូឡ្ហា អវិជ្ជាយ អន្ធីកតា[១] អាវុតា និវុតា ឱផុតា បិហិតា បដិច្ឆន្នា បដិកុជ្ជិតាតិ កាមេសុ គិទ្ធា បសុតា បមូឡ្ហា ។

(៤២) អវទានិយា តេ វិសមេ និវិដ្ឋាតិ អវទានិយាតិ អវគ្គច្ឆន្តីតិបិ អវទានិយា ។ មច្ឆរិនោបិ វុច្ចន្តិ អវទានិយា ។ ពុទ្ធានំ ពុទ្ធសាវកានំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ នាទិយន្តីតិ អវទានិយា ។

---

១ អន្ធិគតាតិបិ បាឋោ ។

មួយទៀត ពួកសត្វណា បរិភោគនូវរូបទាំងឡាយ បរិភោគនូវសំឡេង ក្លិន រស ផ្សព្វទាំងឡាយ ដោយអំណាចតណ្ហា ជាអ្នកត្រាប់ទៅរកអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ឱនទៅរកអារម្មណ៍នោះ សសៀរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ស្ទុងទៅរកអារម្មណ៍នោះ ធ្វើអារម្មណ៍នោះឲ្យជាធំ ពួកសត្វនោះឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ ពាក្យថា អ្នកវង្វេង បានដល់ទេវតានិងមនុស្សទាំងឡាយដោយច្រើន វង្វេង ភ្លេចស្មារតី ភាន់ភាំងគំនិតក្នុងកាមគុណទាំង ៥ ជាអ្នកវង្វេង ភ្លេចស្មារតី ភាន់ភាំងគំនិត ត្រូវអវិជ្ជាធ្វើឲ្យងងឹត ខ្ទប់ ពាំង ហ៊ុម គ្លិត គ្រប បង្រ្គប ផ្កាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេង ក្នុងកាមទាំងឡាយ ។

(៤២) អធិប្បាយពាក្យថា អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើទាំងនោះ ត្រង់ពាក្យថា អ្នកប្រកាន់ថោកទាប គឺអ្នកប្រកាន់ថោកទាប ព្រោះហេតុទៅកាន់ទីថោកទាប ក៏បាន ។ ពួកជនមានសេចក្តីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាប ក៏បាន ។ អ្នកប្រកាន់ថោកទាប ព្រោះហេតុមិនកាន់យកនូវសំដី នូវគន្លងពាក្យ នូវទេសនា នូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ របស់សាវកនៃព្រះពុទ្ធទាំងឡាយ ក៏បាន ។

កថំ អវគច្ឆន្តីតិ អវទានិយា ។ អវគច្ឆន្តិ និរយំ គច្ឆន្តិ តិរច្ឆានយោនឹ គច្ឆន្តិ បិត្តិវិសយំ គច្ឆន្តីតិ ឯវំ អវគច្ឆន្តីតិ អវទានិយា ។

កថំ មច្ឆរិនោ វុច្ចន្តិ អវទានិយា ។ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយម្បិ មច្ឆរិយំ ធាតុមច្ឆរិយម្បិ មច្ឆរិយំ អាយតនមច្ឆរិយម្បិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ ឥមិនា មច្ឆរិយេន អវទញ្ញុតាយ សមន្នាគតា ជនា បមត្តា ឯវំ មច្ឆរិនោ វុច្ចន្តិ អវទានិយា ។

អ្នកប្រកាន់ថោកទាប ព្រោះហេតុទៅកាន់ទីថោកទាប តើដូចម្ដេច ។ ត្រង់ពាក្យថា ទៅកាន់ទីថោកទាប គឺទៅកាន់នរក ទៅកាន់កំណើតតិរច្ឆាន ទៅកាន់បិត្តិវិស័យ ព្រោះហេតុនោះ អ្នកប្រកាន់ទីថោកទាប ព្រោះហេតុទៅកាន់ទីថោកទាប យ៉ាងនេះ ។

ពួកជនមានសេចក្ដីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាប តើដូចម្ដេច ។ សេចក្ដីកំណាញ់ ៥ យ៉ាងគឺ សេចក្ដីកំណាញ់អាវាស ១ សេចក្ដីកំណាញ់ត្រកូល ១ សេចក្ដីកំណាញ់លាភ ១ សេចក្ដីកំណាញ់វណ្ណៈ (សម្បុរ ឬគុណ) ១ សេចក្ដីកំណាញ់ធម៌ ១ សេចក្ដីកំណាញ់ អាការនៃសេចក្ដីកំណាញ់ ភាពនៃសេចក្ដីកំណាញ់ ភាពនៃសេចក្ដីកំណាញ់យ៉ាងល្មម ភាពនៃសេចក្ដីកំណាញ់វៃ សេចក្ដីរួញរា ភាវៈនៃការមិនយកចិត្តយកថ្លើមគេ មានសភាពយ៉ាងនេះ នេះ លោកហៅថា សេចក្ដីកំណាញ់ ។ មួយទៀត សេចក្ដីកំណាញ់ខន្ធក្ដី ក៏ឈ្មោះថា កំណាញ់ សេចក្ដីកំណាញ់ធាតុក្ដី ក៏ឈ្មោះថាកំណាញ់ សេចក្ដីកំណាញ់អាយតនៈក្ដី ក៏ឈ្មោះថាកំណាញ់ សេចក្ដីប្រកាន់ (ដោយអំណាចនៃសេចក្ដីប្រាថ្នា) នេះ លោកហៅថា សេចក្ដីកំណាញ់ ។ ពួកជនប្រកបដោយសេចក្ដីកំណាញ់នេះ ព្រោះមិនដឹង នូវការប្រកាន់ថោកទាប ឈ្មោះថាអ្នកប្រមាទ ពួកជនមានសេចក្ដីកំណាញ់ លោកហៅថា អ្នកប្រកាន់ថោកទាប យ៉ាងនេះ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ករជំ ពុទ្ធានំ ពុទ្ធសាវកានំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ នាទិយន្តីតិ អវទានិយា ។ ពុទ្ធានំ ពុទ្ធសាវកានំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ នាទិយន្តិ ន សុស្សូសន្តិ ន សោតំ ឱទហន្តិ ន អញ្ញា ចិត្តំ ឧបដ្ឋបេន្តិ អនស្សវា អវចនករា បដិលោមវុត្តិនោ អញ្ញេនេវ មុខំ ករោន្តិ ឃរំ ពុទ្ធានំ ពុទ្ធសាវកានំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ នាទិយន្តីតិ អវទានិយា ។

តេ វិសមេ និវិដ្ឋាតិ វិសមេ កាយកម្មេ និវិដ្ឋា វិសមេ វចីកម្មេ និវិដ្ឋា វិសមេ មនោកម្មេ និវិដ្ឋា វិសមេ បាណាតិបាតេ និវិដ្ឋា វិសមេ អទិន្នាទានេ និវិដ្ឋា វិសមេ កាមេសុ មិច្ឆាចារេ និវិដ្ឋា វិសមេ មុសាវាទេ និវិដ្ឋា វិសមាយ បិសុណាយ វាចាយ និវិដ្ឋា វិសមាយ ផរុសាយ វាចាយ និវិដ្ឋា វិសមេ សម្ផប្បលាបេ និវិដ្ឋា វិសមាយ អភិជ្ឈាយ និវិដ្ឋា វិសមេ ព្យាបាទេ និវិដ្ឋា វិសមាយ មិច្ឆាទិដ្ឋិយា និវិដ្ឋា វិសមេសុ សង្ខារេសុ និវិដ្ឋា វិសមេសុ បញ្ចសុ កាមគុណេសុ និវិដ្ឋា វិសមេសុ

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

អ្នកប្រកាន់ថោកទាប ព្រោះហេតុមិនកាន់យកនូវសិក្ខា នូវគន្ថពាក្យ នូវទេសនា នូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ តើដូចម្តេច ។ ពួកជនមិនកាន់យក មិនស្តាប់ មិនប្រុងត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹង នូវសិក្ខា គន្ថពាក្យ ទេសនា ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ ជាអ្នកមិនស្តាប់ឱវាទ មិនធ្វើតាមពាក្យ ប្រព្រឹត្តទទឹង បែរមុខទៅកាន់ទីដទៃវិញ មិនជឿកាន់សិក្ខា គន្ថពាក្យ ទេសនា និងពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ របស់សាវ័កនៃព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ឈ្មោះថា អ្នកប្រកាន់ថោកទាប យ៉ាងនេះ ។

ពាក្យថា ទាំងនោះ ... អ្នកតាំងនៅក្នុងអំពើមិនស្មើ អធិប្បាយថា ពួកសត្វតាំងនៅក្នុងកាយកម្មមិនស្មើ តាំងនៅក្នុងវចីកម្មមិនស្មើ តាំងនៅក្នុងមនោកម្មមិនស្មើ តាំងនៅ ក្នុងបាណាតិបាតមិនស្មើ តាំងនៅ ក្នុងអទិន្នាទានមិនស្មើ តាំងនៅ ក្នុងកាមេសុមិច្ឆាចារមិនស្មើ តាំងនៅ ក្នុងមុសាវាទមិនស្មើ តាំងនៅ ក្នុងបិសុណាវាចាមិនស្មើ តាំងនៅ ក្នុងផរុសវាចាមិនស្មើ តាំងនៅ ក្នុងសម្ផប្បលាបៈមិនស្មើ តាំងនៅ ក្នុងអភិជ្ឈាមិនស្មើ តាំងនៅ ក្នុងព្យាបាទមិនស្មើ តាំងនៅ ក្នុងមិច្ឆាទិដ្ឋិមិនស្មើ តាំងនៅ ក្នុងសង្ខារទាំងឡាយមិនស្មើ តាំងនៅ ក្នុងកាមគុណទាំង ៥ មិនស្មើ

បញ្ចសុ នីវរណេសុ និវិដ្ឋា វិសមាយ ចេតនាយ វិសមាយ បត្ថនាយ វិសមាយ បណិធិយា និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា លគ្គា លគ្គិតា បលិពុទ្ធាតិ អភិនាធិយា តេ វិសមេ និវិដ្ឋា ។

(៤៣) ទុក្ខូបនីតា បរិទេវយន្តីតិ ទុក្ខូបនីតាតិ ទុក្ខូបនីតា ទុក្ខប្បត្តា ទុក្ខសម្បត្តា ទុក្ខូបគតា មារប្បត្តា មារសម្បត្តា មារូបគតា មរណប្បត្តា មរណសម្បត្តា មរណូបគតាតិ ទុក្ខូបនីតា ។ បរិទេវយន្តីតិ លបន្តិ លាលបន្តិ សោចន្តិ កិលមន្តិ បរិទេវន្តិ ឧរត្តាឡឹ កន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ ទុក្ខូបនីតា បរិទេវយន្តិ ។

(៤៤) កឹសូ ភវិស្សាម ឥតោ ចុតា សេតិ ឥតោ ចុតា កឹសុ ភវិស្សាម នេរយិកា ភវិស្សាម តិរច្ឆានយោនិកា ភវិស្សាម បិត្តិវិសយិកា ភវិស្សាម មនុស្សា ភវិស្សាម ទេវា ភវិស្សាម រូបី ភវិស្សាម អរូបី ភវិស្សាម សញ្ញី ភវិស្សាម អសញ្ញី ភវិស្សាម នេវសញ្ញីនាសញ្ញី ភវិស្សាម

តាំងទៅ ក្នុងនីវរណៈទាំង៥មិនស្មើ តាំងទៅ តកល់នៅ ស្អិតជាប់ ចូលទៅជិតដល់ ជ្រួលជ្រប់ បង្អោនទៅ ជាប់នៅ ពាក់ ប្តក់ ព័ន្ធព័ន្ធ ក្នុងចេតនាមិនស្មើ ក្នុងសេចក្តីប្រាថ្នាមិនស្មើ ក្នុងការតាំងចិត្តមិនស្មើ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រកាន់ជោកពាប អ្នកតាំងទៅ ក្នុងអំពើមិនស្មើ ៗ

(៤៣) អធិប្បាយពាក្យថា អ្នកដល់សេចក្តីទុក្ខ រមែងខ្សឹកខ្សួល ត្រង់ពាក្យថា អ្នកដល់សេចក្តីទុក្ខ គឺអ្នកចូលទៅដល់ទុក្ខ ដល់នូវទុក្ខ ដល់ព្រមនូវទុក្ខ ចូលទៅរកទុក្ខ ដល់នូវមារ ដល់ព្រមនូវមារ ចូលទៅរកមារ ដល់នូវសេចក្តីស្លាប់ ដល់ព្រមនូវសេចក្តីស្លាប់ ចូលទៅរកសេចក្តីស្លាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកដល់សេចក្តីទុក្ខ ៗ ពាក្យថា រមែងខ្សឹកខ្សួល គឺរមែងយំរៀបរាប់ យំអណ្តឺតអណ្តក សោកសៅ លំបាក ខ្សឹកខ្សួល តក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកដល់សេចក្តីទុក្ខ រមែងខ្សឹកខ្សួល ៗ

(៤៤) ពាក្យថា យើងទាំងឡាយ ច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វី+ សេចក្តីថា ពួកយើង ច្យុតចាកអត្តភាពនេះទៅ តើទៅកើតជាអ្វី គឺទៅកើតជាសត្វនរក ឬកើតជាសត្វតិរច្ឆាន កើតជាបិត្តិវិស័យ កើតជាមនុស្ស កើតជាទេវតា កើតជារូបព្រហ្ម កើតជាអរូបព្រហ្ម កើតជាសញ្ញីព្រហ្ម កើតជាអសញ្ញីព្រហ្ម កើតជានេវសញ្ញីនាសញ្ញីព្រហ្ម

### ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ភវិស្សាម នុ ខោ មយំ អនាគតមទ្ធានំ ន នុ ខោ ភវិស្សាម អនាគតមទ្ធានំ កឹ នុ ខោ ភវិស្សាម អនាគតមទ្ធានំ កថំ នុ ខោ ភវិស្សាម អនាគតមទ្ធានំ កឹ ហុត្វា កឹ ភវិស្សាម នុ ខោ មយំ អនាគតមទ្ធានន្តិ សំសយបក្ខន្ទា វិមតិបក្ខន្ទា ទ្វេឡ្ហកជាតា លបន្តិ លាលបន្តិ សោចន្តិ កិលមន្តិ បរិទេវន្តិ ឧរត្តាឡឹ កន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ កឹសូ ភវិស្សាម ឥតោ ចុតាសេ ។ តេនាហ ភគវា

កាមេសុ គិទ្ធា បសុតា បមូឡ្ហា
អវទានិយា តេ វិសមេ និវិដ្ឋា
ទុក្ខូបនីតា បរិទេវយន្តិ
កឹសូ ភវិស្សាមឥតោ ចុតាសេតិ ។

(៤៥) តស្មា ហិ សិក្ខេថ ឥធេវ ជន្តុ
យង្កិញ្ចិ ជញ្ញា វិសមន្តិ លោកេ
ន តស្ស ហេតូ វិសមំ ចរេយ្យ
អប្បញ្ហិទំ ជីវិតមាហុ ធីរា ។

យើងទាំងឡាយនឹងកើត ក្នុងអនាគតកាល ឬហ្ន៎ ឬនឹងមិនកើតក្នុងអនាគតកាលទេ នឹងជាអ្វីហ្ន៎ ក្នុងអនាគតកាល នឹងកើតក្នុងអនាគតកាលដោយសណ្ឋានដូចម្តេចហ្ន៎ យើងទាំងឡាយនឹងបានជាអ្វី កើតជាអ្វី ក្នុងអនាគតកាល ពួកជនអ្នកកង្ខា ដោយសេចក្តីសង្ស័យ អ្នកទ្វេធា ដោយសេចក្តីងឿងឆ្ងល់ អ្នកបែកចេញជាពីរចំណែក រមែងយំរៀបរាប់ យំអណ្តិតអណ្តក សោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) យើងទាំងឡាយ ច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎ ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនអ្នកជាប់ចំពាក់ អ្នកខ្វល់ខ្វាយ អ្នកវង្វេង ក្នុងកាមទាំង
ឡាយ អ្នកប្រកាន់ថោកទាប អ្នកតាំងនៅក្នុងអំពើមិនស្មើ
អ្នកដល់សេចក្តីទុក្ខទាំងនោះ រមែងខ្សឹកខ្សួលថា យើងទាំង
ឡាយ ច្យុតចាកអត្តភាពនេះទៅ នឹងកើតជាអ្វីហ្ន៎ ៗ

[៤៨] ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា គប្បីដឹង
នូវកម្មណាមួយ ក្នុងលោក ថាមិនស្មើ មិនគប្បីប្រព្រឹត្តនូវ
កម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ ដ្បិតថា ធីរជន
ទាំងឡាយ បានពោលនូវជីវិតនេះ ថាតិច ៗ

(៦៦) តស្មា ហិ សិក្ខេថ ឥធេវ ជន្តូតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯតំ អាទីនវំ សម្បស្សមានោ កាមេសូតិ តស្មា ។ សិក្ខេថាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។

កតមា អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោ សីលក្ខន្ធោ មហន្តោ សីលក្ខន្ធោ សីលំ បតិដ្ឋា អាទិ ចរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា អយំ អធិសីលសិក្ខា ។

កតមា អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[៤៦] អធិប្បាយពាក្យថា ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា ត្រង់ពាក្យថា ព្រោះហេតុនោះ គឺ ព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ជនកាលឃើញច្បាស់នូវទោសនុ៎ះ ក្នុងកាមទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា (ការសិក្សា) ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសមានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីល ទីតំកល់ ទីខាងដើម ការប្រព្រឹត្តិ ការសង្រួម ការរវាំង ប្រធាន ប្រមុខ នៃការបាននូវកុសលធម៌ទាំងឡាយ នេះ ឈ្មោះថា អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់ ។ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង ញុំាងសមាធិចិត្តឲ្យកើត ឥតមានវិតក្កៈ និងវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោ-មនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

កតមា អធិបញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុ-ទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិប-ទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថា-ភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជា-នាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ អធិបញ្ញាសិក្ខា ។

ព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈានដែលព្រះអរិយៈទាំងឡាយ សរសើរបុគ្គលអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខដូច្នេះ ។ ព្រោះលះបង់សុខផង លះបង់ទុក្ខផង រំលត់សោមនស្សនិងទោមនស្សទាំងឡាយ ក្នុងកាលមុនផង ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា នេះ ឈ្មោះថា អធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាប្រព្រឹត្ត ក្នុងកិរិយាកើតឡើងនិងវិនាសទៅជាបញ្ញាដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយ ជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ភិក្ខុនោះ តែងដឹងច្បាស់តាមពិតថា នេះ ទុក្ខ ដឹងច្បាស់តាមពិតថា នេះ ហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះ ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះ អាសវៈ ដឹងច្បាស់តាមពិតថា នេះ ធម៌នាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះ ទីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់អាសវៈ នេះ ឈ្មោះថា អធិប្បញ្ញាសិក្ខា ។

ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឋហន្តោ សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ វីរិយំ បគ្គណ្ហន្តោ សិក្ខេយ្យ សតិំ ឧបដ្ឋហន្តោ សិក្ខេយ្យ ចិត្តំ សមាទហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខេយ្យ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខេយ្យ បហាតព្វំ បជហន្តោ សិក្ខេយ្យ ភាវេតព្វំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យ ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥមស្មឹ ធម្មេ ឥមស្មឹ វិនយេ ឥមស្មឹ ធម្មវិនយេ ឥមស្មឹ បាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុសាសនេ ឥមស្មឹ អត្តភាវេ ឥមស្មឹ មនុស្សលោកេ ។[១] ជន្តូតិ សត្តោ នរោ ។ បេ ។ មនុជោតិ តស្មា ហិ សិក្ខេថ ឥធេវ ជន្តុ ។

---

១ ម. ឯត្ថន្តរេ តេន វុច្ចតិ ឥធាតិ ទិស្សតិ ។

ភិក្ខុកាលនឹក ឈ្មោះថាសិក្សា កាលដឹង ឈ្មោះថាសិក្សា កាលឃើញ ឈ្មោះថាសិក្សា កាលពិចារណា ឈ្មោះថាសិក្សា កាលតំកល់ចិត្ត ឈ្មោះថាសិក្សា កាលបង្អោនចិត្តដោយសទ្ធា ឈ្មោះថាសិក្សា កាលផ្គងនូវព្យាយាម ឈ្មោះថាសិក្សា កាលតំកល់ស្មារតី ឈ្មោះថាសិក្សា កាលតំកល់ចិត្ត ឈ្មោះថាសិក្សា កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាសិក្សា កាលដឹងច្បាស់នូវអភិញ្ញេយ្យធម៌ ឈ្មោះថាសិក្សា កាលកំណត់ដឹង នូវបរិញ្ញេយ្យធម៌ ឈ្មោះថាសិក្សា កាលលះបង់នូវបហាតព្វធម៌ ឈ្មោះថាសិក្សា កាលចំរើននូវភាវេតព្វធម៌ ឈ្មោះថាសិក្សា កាលធ្វើឲ្យជាក់ច្បាស់ នូវសច្ឆិកាតព្វធម៌ ឈ្មោះថាសិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តដោយល្អ ប្រព្រឹត្ត សមាទាន នូវសិក្ខាទាំង ៣ នេះ ។ ពាក្យថា ក្នុងសាសនានេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្តីគួរនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ។ ពាក្យថា ជនបានដល់សត្វ នរជន ។ បេ ។ សត្វកើតអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

(៤៧) យង្កិញ្ចិ ជញ្ញា វិសមន្តិ លោកេតិ យង្កិ-
ញ្ចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ
បរិយាទាយវចនមេតំ យង្កិញ្ចីតិ ។ ជញ្ញា វិសមន្តីតិ
វិសមំ កាយកម្មំ វិសមន្តិ ជានេយ្យ វិសមំ វចីកម្មំ
វិសមន្តិ ជានេយ្យ វិសមំ មនោកម្មំ វិសមន្តិ ជានេយ្យ
វិសមំ ចាណាតិចាតំ វិសមោតិ ជានេយ្យ វិសមំ
អទិន្នាទានំ វិសមន្តិ ជានេយ្យ វិសមំ កាមេសុ មិច្ឆា-
ចារំ វិសមោតិ ជានេយ្យ វិសមំ មុសាវាទំ វិសមោតិ
ជានេយ្យ វិសមំ បិសុណំ វាចំ វិសមាតិ ជានេយ្យ
វិសមំ ផរុសំ វាចំ វិសមាតិ ជានេយ្យ វិសមំ សម្ផ-
ប្បលាបំ វិសមាតិ ជានេយ្យ វិសមំ អភិជ្ឈំ វិសមាតិ
ជានេយ្យ វិសមំ ព្យាបាទំ វិសមាតិ ជានេយ្យ វិសមំ
មិច្ឆាទិដ្ឋឹ វិសមាតិ ជានេយ្យ វិសមេ សង្ខារេ វិសមាតិ
ជានេយ្យ វិសមេ បញ្ច កាមគុណេ វិសមាតិ ជានេយ្យ
វិសមេ បញ្ច នីវរណេ វិសមាតិ ជានេយ្យ វិសមំ
ចេតនំ វិសមាតិ ជានេយ្យ វិសមំ បត្ថនំ វិសមាតិ
ជានេយ្យ វិសមំ បណិធឹ វិសមាតិ ជានេយ្យ អា-
ជានេយ្យ វិជានេយ្យ បដិវិជានេយ្យ បដិវិជ្ឈេយ្យ ។

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

(៤៧) អធិប្បាយពាក្យថា គប្បីដឹងនូវកម្មណាមួយ ក្នុងលោក ថាមិនស្មើ ត្រង់ពាក្យថា ណាមួយ គឺទាំងអស់ ដោយអាការទាំងអស់ ទាំងពួង ដោយប្រការទាំងពួង មិនមានសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយ នុះ ជាពាក្យប្រើរួម ។ ពាក្យថា គប្បីដឹងថាមិនស្មើ គឺគប្បីដឹងនូវកាយកម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវវចីកម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមនោកម្មមិនស្មើ ថាមិនស្មើ គប្បីដឹងនូវបាណាតិបាតមិនស្មើ ថាមិនស្មើ គប្បីដឹង នូវអទិន្នាទានមិនស្មើ ថាមិនស្មើ គប្បីដឹងនូវកាមេសុមិច្ឆាចារមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមុសាវាទមិនស្មើ ថាមិនស្មើ គប្បីដឹងនូវបិសុណាវាចាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវផរុសវាចាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសម្ផប្បលាបៈមិនស្មើ ថាមិនស្មើ គប្បីដឹងនូវអភិជ្ឈាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវព្យាបាទមិនស្មើ ថាមិនស្មើ គប្បីដឹងនូវមិច្ឆាទិដ្ឋិមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសង្ខារទាំងឡាយមិនស្មើ ថាមិនស្មើ គប្បីដឹងនូវកាមគុណទាំង ៥ មិនស្មើ ថាមិនៈស្មើ គប្បីដឹងនូវនីវរណៈទាំង ៥ មិនស្មើ ថាមិនស្មើ គប្បីដឹងនូវចេតនាមិនស្មើ ថាមិនស្មើ គប្បីដឹងនូវសេចក្តីប្រាថ្នាមិនស្មើ ថាមិនស្មើ គប្បីដឹង គប្បីដឹងទូទៅ គប្បីដឹងវិសេស គប្បីដឹងប្រាកដ គប្បីចាក់ធ្លុះនូវកិរិយាគិតគល់ (ចិត្ត) មិនស្មើ ថាមិនស្មើ ។

លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេ-តិ យង្កិញ្ចិ ជញ្ញា វិសមន្តិ លោកេ ។

(៤៨) ន តស្ស ហេតុ វិសមំ ចរេយ្យាតិ វិសមស្ស កាយកម្មស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស វចីកម្មស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស មនោកម្មស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស បាណាតិបាតស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស អទិន្នាទានស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស កាមេសុមិច្ឆាចារស្ស ហេតុ វិសមំ ន ចរេយ្យ វិសមស្ស មុសាវាទស្ស ហេតុ វិសមំ ន ចរេយ្យ វិសមាយ បិសុណាយ វាចាយ ហេតុ វិសមំ ន ចរេយ្យ វិសមាយ ផរុសាយ វាចាយ ហេតុ វិសមំ ន ចរេយ្យ វិសមស្ស សម្ផប្បលាបស្ស ហេតុ វិសមំ ន ចរេយ្យ វិសមាយ អភិជ្ឈាយ ហេតុ វិសមំ ន ចរេយ្យ វិសមស្ស ព្យាបាទស្ស ហេតុ វិសមំ ន ចរេយ្យ វិសមាយ មិច្ឆាទិដ្ឋិយា ហេតុ វិសមំ ន ចរេយ្យ វិសមានំ សង្ខារានំ ហេតុ វិសមេ

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីដឹង នូវកម្មណាមួយ ក្នុងលោក ថាមិនស្មើ ។

(៤៨) ពាក្យថា មិនគប្បីប្រព្រឹត្តនូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះ អធិប្បាយថា មិនគប្បីប្រព្រឹត្តកាយកម្មមិនស្មើ ព្រោះហេតុនៃកាយកម្មមិនស្មើ មិនគប្បីប្រព្រឹត្តវចីកម្មមិនស្មើ ព្រោះហេតុនៃវចីកម្មមិនស្មើ មិនគប្បីប្រព្រឹត្តមនោកម្មមិនស្មើ ព្រោះហេតុនៃមនោកម្មមិនស្មើ មិនគប្បីប្រព្រឹត្តបាណាតិបាតមិនស្មើ ព្រោះហេតុនៃបាណាតិបាតមិនស្មើ មិនគប្បីប្រព្រឹត្តអទិន្នាទានមិនស្មើ ព្រោះហេតុនៃអទិន្នាទានមិនស្មើ មិនគប្បីប្រព្រឹត្តកាមេសុមិច្ឆាចារមិនស្មើ ព្រោះហេតុនៃកាមេសុមិច្ឆាចារមិនស្មើ មិនគប្បីប្រព្រឹត្តមុសាវាទមិនស្មើ ព្រោះហេតុនៃមុសាវាទមិនស្មើ មិនគប្បីប្រព្រឹត្តបិសុណវាចាមិនស្មើ ព្រោះហេតុនៃបិសុណវាចាមិនស្មើ មិនគប្បីប្រព្រឹត្តផរុសវាចាមិនស្មើ ព្រោះហេតុនៃផរុសវាចាមិនស្មើ មិនគប្បីប្រព្រឹត្តសម្ផប្បលាបៈមិនស្មើ ព្រោះហេតុនៃសម្ផប្បលាបៈមិនស្មើ មិនគប្បីប្រព្រឹត្តអភិជ្ឈាមិនស្មើ ព្រោះហេតុនៃអភិជ្ឈាមិនស្មើ មិនគប្បីប្រព្រឹត្តព្យាបាទមិនស្មើ ព្រោះហេតុនៃព្យាបាទមិនស្មើ មិនគប្បីប្រព្រឹត្តមិច្ឆាទិដ្ឋិមិនស្មើ ព្រោះហេតុនៃមិច្ឆាទិដ្ឋិមិនស្មើ មិនគប្បីប្រព្រឹត្តសង្ខារទាំងឡាយមិនស្មើ ព្រោះហេតុនៃសង្ខារទាំងឡាយមិនស្មើ

ន ចរេយ្យ វិសមានំ បញ្ចន្នំ កាមគុណានំ ហេតុ វិសមេ ន ចរេយ្យ វិសមានំ បញ្ចន្នំ នីវរណានំ ហេតុ វិសមេ ន ចរេយ្យ វិសមាយ ចេតនាយ ហេតុ វិសមាយ បត្ថនាយ ហេតុ វិសមាយ បណិធិយា ហេតុ វិសមំ ន ចរេយ្យ ន អាចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យាតិ ន តស្ស ហេតុ វិសមំ ចរេយ្យ ។

(៤៩) អប្បញ្ហិទំ ជីវិតមាហុ ធីរាតិ ជីវិតន្តិ អាយុ ឋិតិ យបនា យាបនា ឥរិយនា វត្តនា បាលនា ជីវិតំ ជីវិតិន្ទ្រិយំ ។ អបិច ទ្វីហិ ការណេហិ អប្បកំ ជីវិតំ ឋិតិបរិត្តតាយ វា អប្បកំ ជីវិតំ សរសបរិត្តតាយ វា អប្បកំ ជីវិតំ ។

កថំ ឋិតិបរិត្តតាយ អប្បកំ ជីវិតំ ។ អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ។ អនាគតេ ចិត្តក្ខណេ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ ។ បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ ។

មិនគប្បីប្រព្រឹត្តកាមគុណ ទាំង៥ មិនស្មើ ព្រោះហេតុនៃកាមគុណទាំង៥ មិនស្មើ មិនគប្បីប្រព្រឹត្តនីវរណៈទាំង ៥ មិនស្មើ ព្រោះហេតុនៃនីវរណៈទាំង ៥ មិនស្មើ មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តទូទៅ មិនគប្បីប្រព្រឹត្តដោយប្រពៃ មិនគប្បីប្រព្រឹត្តសមាទាន (នូវចេតនាជាដើម) មិនស្មើ ព្រោះហេតុនៃចេតនាមិនស្មើ ព្រោះហេតុនៃសេចក្តីប្រាថ្នាមិនស្មើ ព្រោះហេតុនៃកិរិយាតាំងកល់ (ចិត្ត) មិនស្មើ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីប្រព្រឹត្តនូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ ។

(៤៩) អធិប្បាយពាក្យថា ធីរជនទាំងឡាយ បានពោលនូវជីវិតនេះ ថាតិច ត្រង់ពាក្យថា ជីវិត បានដល់អាយុ ការតាំងនៅ ការទៅ ការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ការដើរទៅ ការប្រព្រឹត្តទៅ ការរក្សា ការរស់នៅ ឥន្ទ្រិយគឺការរស់នៅ ។ ម្យ៉ាងទៀត ជីវិតតិច ដោយហេតុ ២ យ៉ាង គឺ ជីវិតតិច ព្រោះជាធម្មជាតតាំងនៅតិច ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច ។

ជីវិតតិច ព្រោះជាធម្មជាតតាំងនៅតិច តើដូចម្តេច ។ សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនរស់នៅ នឹងមិនរស់នៅ ។ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនរស់នៅ មិនរស់នៅហើយ ។ សត្វកំពុងរស់នៅ ក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយ នឹងមិនរស់នៅ ។

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា

ឯកចិត្តសមាយុត្តា លហុសោ វត្តតិក្ខណោ[1]

ចុល្លាសីតិសហស្សានិ កប្បា តិដ្ឋន្តិ យេ មរូ

ន ត្វេវ តេបិ ជីវន្តិ ទ្វីហិ ចិត្តេហិ សមោហិតា

យេ និរុទ្ធា មរន្តស្ស តិដ្ឋមានស្ស វា ឥធ

សព្វេវ សទិសា ខន្ធា គតា អប្បដិសន្ធិកា

អនន្តរា ច យេ ភគ្គា យេ ច ភគ្គា អនាគតា

តទន្តរេ និរុទ្ធានំ វេសម្មំ នត្ថិ លក្ខណេ

អនិព្វត្តេន ន ជាតោ បច្ចុប្បន្នេន ជីវតិ

ចិត្តភង្គមតោ[2] លោកោ បញ្ញត្តិ បរមត្ថិយា

យថា និន្នា បវត្តន្តិ ឆន្ទេន បរិណាមិតា

អច្ឆិន្នវារា[3] វត្តន្តិ សឡាយតនបច្ចយា

អនិធានគតា ភគ្គា បុញ្ជោ នត្ថិ អនាគតេ

---

១ ម. វត្តតេ ខណោ ។ ២ ម. ចិត្តភគ្គមតោ ។ ៣ ម. អច្ឆិន្នធារា ។

ជីវិត អត្តភាព សុខនិងទុក្ខទាំងអស់ ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តទៅរហ័ស ពួកទេវតាណាឋិតនៅអស់៨៤.០០០កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្តពីរ ហើយរស់នៅទេ ខន្ធទាំងឡាយណា របស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន ខន្ធទាំងឡាយណា ដែលកន្លងជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគតនឹងបែកធ្លាយផង សេចក្តីផ្សេងគ្នា នៃខន្ធទាំងឡាយជាបច្ចុប្បន្ន ដែលរលត់ហើយក្នុងបន្ទោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វ-លោកមិនមែនកើត ដោយអនាគតខន្ធ ដែលមិនទាន់កើត មិនមែនរស់នៅក្នុងបច្ចុប្បន្នទេ សត្វលោកស្លាប់ដោយការបែកធ្លាយនៃចិត្ត ការបញ្ញត្តិប្រកបដោយបរមត្ថ ប្រែប្រួលទៅដោយឆន្ទៈ ដូចជាទីទាប រមែងប្រព្រឹត្តទៅដូច្នោះ វេទនាទាំងឡាយ មានសឡាយតនៈជាបច្ច័យ មានវារៈមិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយដែលបែកធ្លាយហើយ ក៏មិនដល់នូវកិរិយាតាំងកល់ទុកទេ គំនរនៃខន្ធក្នុងអនាគតក៏មិនមាន

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

និព្វត្តា យេវ តិដ្ឋន្តិ អារគ្គេ សាសបូបមា
និព្វត្តានញ្ច ធម្មានំ ភង្គោ នេសំ បុរក្ខតោ[១]
បលោកធម្មា តិដ្ឋន្តិ បុរាណេហិ អមិស្សិតា
អទស្សនតោ អាយន្តិ ភគ្គា គច្ឆន្តិ ទស្សនំ
វិជ្ជុប្បាទោវ អាកាសេ ឧប្បជ្ជន្តិ វយន្តិ ចាតិ ។

ឯវំ ឋិតិបរិត្តតាយ អប្បកំ ជីវិតំ ។

កថំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។ អស្សាសូបនិពន្ធំ ជីវិតំ បស្សាសូបនិពន្ធំ ជីវិតំ អស្សាសបស្សាសូបនិពន្ធំ ជីវិតំ មហាភូតូបនិពន្ធំ ជីវិតំ ឧស្មូបនិពន្ធំ ជីវិតំ កពឡិង្ការាហារូបនិពន្ធំ ជីវិតំ វិញ្ញាណូបនិពន្ធំ ជីវិតំ ។ មូលម្បិ ឥមេសំ ទុព្វលំ ។ បុព្វហេតូបិ ឥមេសំ ទុព្វលា ។ យេបិ បច្ចយា តេបិ ទុព្វលា ។ យេបិ បភាវិកា តេបិ ទុព្វលា ។ សហភូបិ[២] ឥមេសំ ទុព្វលា ។

---

១ ម. បុរេក្ខតោ ។ ២ ម. សហភូមិ ។

> ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងតាំងទៅ ឧបមាដូចជាគ្រាប់ស្ពៃ ដែលជាប់នឹងចុងដែកស្រួច កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយ នៃខន្ធទាំងនោះក៏ឋិតនៅ ក្នុងខាងមុខ ឯសភាវៈដែលត្រូវវិនាសទាំងឡាយ (ខន្ធ) កំពុងឋិតនៅ មិនប្រឡូកប្រឡំ ដោយខន្ធចាស់ទេ ពួកសត្វមកអំពីទីមើលមិនឃើញ តែងទៅកាន់ទីមើលមិនឃើញ មុនអំពីការបែកធ្លាយ តែងកើតឡើង ទាំងតែងវិនាសទៅវិញ ដូចជាផ្លេកបន្ទោរ ក្នុងអាកាស ។

ជីវិតតិច ព្រោះការតាំងនៅតិច យ៉ាងនេះ ។

ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច តើដូចម្តេច ។ ជីវិតជាប់ចំពាក់ដោយដង្ហើមចូល ជីវិតជាប់ចំពាក់ដោយដង្ហើមចេញ ជីវិតជាប់ចំពាក់ដោយដង្ហើមចូលនឹងដង្ហើមចេញ ជីវិតជាប់ចំពាក់ដោយមហាភូតរូប ជីវិតជាប់ចំពាក់ដោយភ្លើងធាតុ ជីវិតជាប់ចំពាក់ដោយកវឡិង្ការាហារ ជីវិតជាប់ចំពាក់ដោយវិញ្ញាណ ។ មូលនៃធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ បុព្វហេតុទាំងឡាយ នៃធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ សូម្បីធម៌ទាំងឡាយណាជាបច្ច័យ ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីធម៌ទាំងឡាយណាជាដែនកើតមុន ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ ពួកធម៌ដែលកើតជាមួយ នឹងធម៌ទាំងនេះ ក៏មានកម្លាំងថយដូចគ្នា ។

សម្បយោគាបិ តេសំ ទុក្ខា ។ សហជាបិ តេសំ ទុក្ខា ។ យាបិ បយោជិកា សាបិ ទុក្ខា ។ អញ្ញមញ្ញំ និច្ចទុក្ខា តេ ។ អញ្ញមញ្ញំ អនវដ្ឋិតា តេ ។ អញ្ញមញ្ញំ បរិឃាតយន្តិ តេ ។ អញ្ញមញ្ញស្ស ហិ នត្ថិ តាយិតា ។ ន ចាបិ ឋបេន្តិ អញ្ញមញ្ញមិមេ ។ យោបិ និព្វត្តកោ សោ ន វិជ្ជតិ ។ ន ច កេនចិ កោចិ ហាយតិ ។ ភង្គព្យា[1] ច តេមេ ហិ សព្វសោ ។ បុរិមេហិ បភាវិតា តេមេ ។ យេបិ បភាវិតា តេ បុរេ មតា ។ បុរិមាបិច បច្ឆិមាបិច អញ្ញមញ្ញំ ន កទាចិ អទ្ទសំសូតិ ។ ឯវំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។

អបិច ចាតុម្មហារាជិកានំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ ជីវិតំ លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អនទ្ធនីយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ តាវត្តិំសានំ ទេវានំ ។ យាមានំ ទេវានំ ។ តុសិតានំ ទេវានំ ។ និម្មានរតីនំ ទេវានំ ។

១ ម. គន្ធព្វា ។

ពួកធម៌ដែលសម្បយោគនឹងធម៌ទាំងនេះ មានកម្លាំងថយ ៗ សហជាតធម៌នៃធម៌ទាំងនេះ មានកម្លាំងថយ ៗ តណ្ហាណាជាគ្រឿងប្រកប តណ្ហានោះ មានកម្លាំងថយ ៗ ធម៌ទាំងនេះ មានកម្លាំងថយជានិច្ច ចំពោះគ្នានឹងគ្នា ៗ ធម៌ទាំងនេះ មិនឱនរកគ្នានឹងគ្នា ៗ ធម៌ទាំងនេះ ញុំាងគ្នានឹងគ្នាឲ្យធ្លាក់ចុះ ៗ ព្រោះថា មិនបានជាទីពឹងដល់គ្នានឹងគ្នា ៗ មួយទៀត ធម៌ទាំងនេះ មិនលើកតំកើងគ្នានឹងគ្នា ៗ ធម៌ណា ជាអ្នកបង្កើត ធម៌នោះ មិនមានទេ ៗ ធម៌នីមួយ មិនមែនសាបសូន្យ ដោយធម៌ណាមួយទេ ៗ ព្រោះថា ធម៌ទាំងនេះ បែកធ្លាយទៅ ទាំងអស់ ៗ ធម៌ទាំងនេះ កើតហើយ ដោយសារហេតុនឹងបច្ច័យជាខាងដើម ៗ ហេតុនឹងបច្ច័យទាំងឡាយណាដែលឲ្យកើតមុន ហេតុនឹងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ៗ ធម៌ទាំងឡាយខាងដើមនឹងខាងចុង មិនបានឃើញគ្នានឹងគ្នាក្នុងកាលណាឡើយ ៗ ជីវិតតិច ព្រោះកិចរបស់ខ្លួនតិច យ៉ាងនេះ ៗ

មួយវិញទៀត មនុស្សទាំងឡាយ មានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតឆាត់ ជីវិតមិនមាំមួន ជីវិតមិនតាំងនៅអស់កាលយូរ បើប្រៀបធៀបនឹងជីវិតរបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ៗ របស់ពួកទេវតាជាន់តាវត្តិង្ស ៗ របស់ពួកទេវតាជាន់យាមៈ ៗ របស់ពួកទេវតាជាន់តុសិត ៗ របស់ពួកទេវតាជាន់និម្មានរតី ៗ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

បរនិម្មិតវសវត្តីនំ ទេវានំ ។ ព្រហ្មកាយិកានំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកកំ ជីវិតំ ខណិកំ ជីវិតំ លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អនទ្ធនិយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ វុត្តំ ហេតំ ភគវតា អប្បមិទំ ភិក្ខវេ មនុស្សានំ អាយុ គមនីយោ សម្បរាយោ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ។

អប្បមាយុ មនុស្សានំ ហីឡេយ្យ នំ សុបោរិសោ
ចរេយ្យាទិត្តសីសោវ នត្ថិ មច្ចុស្ស នាគមោ
អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ
អាយុ ខីយតិ មច្ចានំ កុន្នទីនំវ ឱទកន្តិ ។

អប្បញ្ហិនំ ជីវិតមាហុ ធីរាតិ ធីរាតិ ធិតិមាតិ ធីរា ។

របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ មនុស្សទាំងឡាយមានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតដាច់ ជីវិតមិនមាំមួន ជីវិតមិនតាំងនៅអស់កាលយូរ បើប្រៀបធៀបនឹងជីវិត របស់ពួកទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះតិច បរលោកត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ ដោយបញ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយៈ បុគ្គលដែលកើតហើយ មិនមែនមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា រស់នៅយ៉ាងយូរ បុគ្គលនោះ គប្បីរស់ នៅ ១០០ ឆ្នាំ តិចជាងនេះ ឬច្រើនជាងនេះ (មានខ្លះ) ។

> អាយុរបស់មនុស្សទាំងឡាយតិច បុរសអ្នកមានប្រាជ្ញា គួរ
> ធុញទ្រាននឹងអាយុ+នុ៎ះ គប្បីប្រព្រឹត្ត ឲ្យដូចបុគ្គលដែល
> ត្រូវភ្លើងឆេះក្បាល ការមិនមកនៃមច្ចុ មិនមានទេ ថ្ងៃនឹង
> យប់ រមែងកន្លងទៅ ជីវិតក៏រលត់ទៅដែរ អាយុនៃសត្វ
> ទាំងឡាយ រមែងអស់ទៅ ដូចទឹកនៃស្ទឹងតូច ៗ ។

អធិប្បាយពាក្យថា ធីរជនទាំងឡាយ ពោលនូវជីវិតនេះថា តិច ត្រង់ពាក្យថា ធីរជនទាំងឡាយ គឺឈ្មោះថា ធីរជន ព្រោះហេតុជាអ្នកមានប្រាជ្ញា ។

ធិតិសម្បន្នាតិ ធីរា ។ ធិក្កតបាបាតិ ធីរា ។ ធី វុច្ចតិ
បញ្ញា យា បញ្ញា បជាននា វិចយោ បវិចយោ
ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខ-
ណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបប-
រិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ
បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ
បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ
បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ
សម្មាទិដ្ឋិ តាយ បញ្ញាយ សមន្នាគតត្តា ធីរា ។
អបិច ខន្ធធីរា ធាតុធីរា អាយតនធីរា បដិច្ចសមុប្បា-
ទធីរា សតិបដ្ឋានធីរា សម្មប្បធានធីរា ឥទ្ធិបាទធីរា
ឥន្ទ្រិយធីរា ពលធីរា ពោជ្ឈង្គធីរា មគ្គធីរា ផលធីរា
និព្ពានធីរា ។ តេ ធីរា ឯវមាហំសុ មនុស្សានំ អប្បកំ
ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ ជីវិតំ
លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អនទ្ធនីយំ ជីវិតំ

ឈ្មោះថា ធីរជន ព្រោះហេតុជាអ្នកបរិបូណ៌ដោយប្រាជ្ញា ។ ឈ្មោះថា ធីរជន ព្រោះហេតុជាអ្នកគិះដៀលបាប ។ បញ្ញា លោកហៅថា ធី បានដល់ប្រាជ្ញា ការដឹង ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ ការកំណត់ចាំ ការកំណត់ចាំមុន ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាស ភាពជាអ្នកល្អិតល្អន់ ភាពជាអ្នកវាងវៃ ការគិត ការត្រិះរិះ ប្រាជ្ញាដូចជាផែនដី ប្រាជ្ញាជាគ្រឿងទំលាយបង់ (នូវកិលេស) ប្រាជ្ញាជាគ្រឿងដឹកនាំ ការឃើញច្បាស់ ការដឹងខ្លួន ជន្លួញគឺបញ្ញា បញ្ញា បញ្ញិន្ទ្រិយ កម្លាំងគឺបញ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា ការមិនភាន់ច្រឡំ ការពិចារណាធម៌ ការយល់ត្រូវ ឈ្មោះថា ធីរជន ព្រោះប្រកបព្រមដោយបញ្ញានោះ ។ មួយទៀត ពួកធីរជនខាងខន្ធ ធីរជនខាងធាតុ ធីរជនខាងអាយតនៈ ធីរជនខាងបដិច្ចសមុប្បាទ ធីរជនខាងសតិប្បដ្ឋាន ធីរជនខាងសម្មប្បធាន ធីរជនខាងឥទ្ធិបាទ ធីរជនខាងឥន្ទ្រិយ ធីរជនខាងពលៈ ធីរជនខាងពោជ្ឈង្គ ធីរជនខាងមគ្គ ធីរជនខាងផល ធីរជនខាងព្រះនិព្វាន ។ ពួកធីរជនទាំងនោះ បានពោលយ៉ាងនេះថា មនុស្សទាំងឡាយ មានជីវិតតិច ជីវិតស្តួចស្តើង ជីវិតខ្លី ជីវិតប្រកបដោយខណៈ ជីវិតរហ័ស ជីវិតឆាប់ ជីវិតមិនមាំមួន

ន ចិរដ្ឋិតិកំ ជីវិតន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ អប្បញ្ហិទំ ជីវិតមាហុ ធីរា ។ តេនាហ ភគវា

តស្មា ហិ សិក្ខេថ ឥធេវ ជន្តុ
យង្កិញ្ចិ ជញ្ញា វិសមន្តិ លោកេ
ន តស្ស ហេតុ វិសមំ ចរេយ្យ
អប្បញ្ហិទំ ជីវិតមាហុ ធីរាតិ ។

(៨០) បស្សាមិ លោកេ បរិផន្ទមានំ
បជំ ឥមំ តណ្ហាគតំ ភវេសុ
ហីនា នរា មច្ចុមុខេ លបន្តិ
អវីតតណ្ហាសេ ភវាភវេសុ ។

(៨១) បស្សាមិ លោកេ បរិផន្ទមានន្តិ បស្សាមីតិ មំសចក្ខុនាបិ បស្សាមិ ទិព្វចក្ខុនាបិ បស្សាមិ បញ្ញាចក្ខុនាបិ បស្សាមិ ពុទ្ធចក្ខុនាបិ បស្សាមិ សមន្តចក្ខុនាបិ បស្សាមិ ទក្ខាមិ ឱលោកេមិ និជ្ឈាយាមិ ឧបបរិក្ខាមិ ។ លោកោតិ អបាយលោកោ មនុស្សលោកោ

ជីវិតមិនតាំងនៅអស់កាលយូរ ធីរជនទាំងឡាយ បានពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ធីរជនទាំងឡាយ បានពោលនូវជីវិតនេះថា តិច ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ព្រោះហេតុនោះ ជនក្នុងសាសនានេះ គប្បីសិក្សា គប្បី
ដឹងនូវកម្មណាមួយ ក្នុងលោកថា មិនស្មើ មិនគប្បី
ប្រព្រឹត្ត នូវកម្មមិនស្មើ ព្រោះហេតុនៃកម្មមិនស្មើនោះទេ
ដ្បិតថា ធីរជនទាំងឡាយ បានពោលនូវជីវិតនេះថា តិច ៗ

(៤០) តថាគតឃើញ នូវពពួកសត្វនេះ ដែលលុះក្នុងអំណាច
តណ្ហា ក្នុងភពទាំងឡាយ កំពុងញាប់ញ័រ ក្នុងលោក
នរជនទាំងឡាយថោកទាប មិនទាន់កន្លងតណ្ហាក្នុងភពតូច
និងភពធំទាំងឡាយទេ រមែងយំរៀបរាប់ ក្នុងមាត់មច្ចុ ៗ

(៤១) អធិប្បាយពាក្យថា ឃើញ (នូវពពួកសត្វ) កំពុងញាប់ញ័រក្នុងលោក ត្រង់ពាក្យថា ឃើញ គឺឃើញដោយមំសចក្ខុ ឃើញដោយទិព្វចក្ខុ ឃើញដោយបញ្ញាចក្ខុ ឃើញដោយពុទ្ធចក្ខុ មើលឃើញ ក្រឡេកមើល សំឡឹងមើល ពិចារណាមើល ដោយសមន្តចក្ខុ ៗ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក

ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោ-
កេ ។ បរិឌឌ្ឍមានន្តិ តណ្ហាឌឌ្ឍនាយ ឌឌ្ឍមានំ ទិដ្ឋិ-
ឌឌ្ឍនាយ ឌឌ្ឍមានំ កិលេសឌឌ្ឍនាយ ឌឌ្ឍមានំ បយោ-
គឌឌ្ឍនាយ ឌឌ្ឍមានំ វិបាកឌឌ្ឍនាយ ឌឌ្ឍមានំ ទុច្ចរិ-
តឌឌ្ឍនាយ ឌឌ្ឍមានំ រត្តរាគេន ឌឌ្ឍមានំ ទុដ្ឋទោ-
សេន ឌឌ្ឍមានំ មុឡ្ហមោហេន ឌឌ្ឍមានំ វិនិពន្ធមា-
នេន ឌឌ្ឍមានំ បរាមដ្ឋទិដ្ឋិយា ឌឌ្ឍមានំ វិក្ខេបគត-
ឧទ្ធច្ចេន ឌឌ្ឍមានំ អនិដ្ឋង្គតវិចិកិច្ឆាយ ឌឌ្ឍមានំ ថាម-
គតអនុសយេហិ ឌឌ្ឍមានំ លាភេន ឌឌ្ឍមានំ អលា-
ភេន ឌឌ្ឍមានំ យសេន ឌឌ្ឍមានំ អយសេន ឌឌ្ឍមានំ
បសំសាយ ឌឌ្ឍមានំ និន្ទាយ ឌឌ្ឍមានំ សុខេន ឌឌ្ឍមានំ
ទុក្ខេន ឌឌ្ឍមានំ ជាតិយា ឌឌ្ឍមានំ ជរាយ ឌឌ្ឍមានំ
ព្យាធិនា ឌឌ្ឍមានំ មរណេន ឌឌ្ឍមានំ សោកបរិទេវ-
ទុក្ខទោមនស្សុបាយាសេហិ ឌឌ្ឍមានំ នេរយិកេន

ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា កំពុងញាប់ញ័រ គឺកំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះតណ្ហា កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះទិដ្ឋិ កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះកិលេស កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះធម៌ជាគ្រឿងប្រកប កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះវិបាក កំពុងញាប់ញ័រ ដោយការញាប់ញ័រព្រោះទុច្ចរិត កំពុងញាប់ញ័រ ដោយតម្រេកដែលត្រេកអរហើយ កំពុងញាប់ញ័រ ដោយទោសៈដែលប្រទូស្តហើយ កំពុងញាប់ញ័រ ដោយមោហៈដែលវង្វេងហើយ ញាប់ញ័រ ដោយមានះ ដែលជាប់ចំពាក់ហើយ ញាប់ញ័រ ដោយទិដ្ឋិដែលស្ទាបអង្អែលហើយ ញាប់ញ័រ ដោយឧទ្ធច្ចៈ ដែលដល់នូវសេចក្តីរាយមាយ ញាប់ញ័រ ដោយវិចិកិច្ឆា ដែលដល់នូវសេចក្តីមិនដាច់ស្រេច ញាប់ញ័រ ដោយអនុស័យ ដែលដល់នូវកំឡាំង ញាប់ញ័រ ដោយលាភ ញាប់ញ័រ ដោយអលាភ ញាប់ញ័រ ដោយយស ញាប់ញ័រ ដោយការមិនមានយស ញាប់ញ័រ ដោយសេចក្តីសរសើរ ញាប់ញ័រ ដោយនិន្ទា ញាប់ញ័រ ដោយសុខ ញាប់ញ័រ ដោយទុក្ខ ញាប់ញ័រ ដោយជាតិ ញាប់ញ័រ ដោយជរា ញាប់ញ័រ ដោយព្យាធិ ញាប់ញ័រ ដោយមរណៈ ញាប់ញ័រ ដោយសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈទាំងឡាយ ញាប់ញ័រ ដោយទុក្ខ ដែលកើតក្នុងនរក

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ទុក្ខេន ផុដ្ឋមានំ តិរច្ឆានយោនិកេន ទុក្ខេន ផុដ្ឋមានំ បេត្តិវិសយិកេន ទុក្ខេន ផុដ្ឋមានំ មានុសិកេន ទុក្ខេន ផុដ្ឋមានំ គព្ភោក្កន្តិមូលកេន ទុក្ខេន ផុដ្ឋមានំ គព្ភេ ឋិតិមូលកេន ទុក្ខេន ផុដ្ឋមានំ គព្ភាវុដ្ឋានមូលកេន ទុក្ខេន ផុដ្ឋមានំ ជាតស្សូបនិពន្ធិកេន ទុក្ខេន ផុដ្ឋមានំ ជាតស្សបរាធេយ្យកេន ទុក្ខេន ផុដ្ឋមានំ អត្តុបក្កមេន ទុក្ខេន ផុដ្ឋមានំ បរុបក្កមេន ទុក្ខេន ផុដ្ឋមានំ ទុក្ខទុក្ខេន ផុដ្ឋមានំ សង្ខារទុក្ខេន ផុដ្ឋមានំ វិបរិណាមទុក្ខេន ផុដ្ឋមានំ ចក្ខុរោគេន ទុក្ខេន ផុដ្ឋមានំ សោតរោគេន ទុក្ខេន ផុដ្ឋមានំ ឃានរោគេន ទុក្ខេន ជិវ្ហារោគេន ទុក្ខេន កាយរោគេន ទុក្ខេន សីសរោគេន ទុក្ខេន កណ្ណរោគេន មុខរោគេន ទន្តរោគេន កាសេន សាសេន បិនាសេន ឌហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខន្ទិកាយ សុលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុយា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន បិត្តេន មធុមេហេន

ញាប់ញ័រដោយទុក្ខ ដែលកើតក្នុងកំណើតតិរច្ឆាន ញាប់ញ័រ ដោយទុក្ខ ដែលកើតក្នុងបិត្តិវិស័យ ញាប់ញ័រដោយទុក្ខ ដែលកើតជាមនុស្ស ញាប់-ញ័រ ដោយទុក្ខមានចុះកាន់គភ៌ជាហេតុ ញាប់ញ័រ ដោយទុក្ខ មានការឋិតនៅក្នុងគភ៌ជាហេតុ ញាប់ញ័រ ដោយទុក្ខ មានការចេញចាកគភ៌ជាហេតុ ញាប់ញ័រ ដោយទុក្ខ ដែលជាប់ចំពាក់របស់សត្វ ដែលកើតហើយ ញាប់ញ័រ ដោយទុក្ខ ដែលបណ្ដាលអំពីបុគ្គលដទៃ របស់សត្វដែលកើតហើយ ញាប់ញ័រ ដោយទុក្ខ ព្រោះព្យាយាមសម្រាប់ខ្លួន ញាប់ញ័រ ដោយទុក្ខ ព្រោះព្យាយាមសម្រាប់អំពីបុគ្គលដទៃ ញាប់ញ័រដោយទុក្ខទុក្ខ (កាយិកទុក្ខនិងចេតសិកទុក្ខ) ញាប់ញ័រ ដោយសង្ខារទុក្ខ ញាប់ញ័រ ដោយទុក្ខ ព្រោះការប្រែប្រួល ញាប់ញ័រ ដោយទុក្ខ ព្រោះចក្ខុរោគ ញាប់ញ័រ ដោយទុក្ខ ព្រោះសោតរោគ ដោយទុក្ខ ព្រោះឃានរោគ ដោយទុក្ខ ព្រោះជិវ្ហារោគ ដោយទុក្ខ ព្រោះកាយរោគ ដោយទុក្ខ ព្រោះសីសរោគ ដោយទុក្ខ ព្រោះកណ្ណរោគ មុខរោគ ទន្តរោគ ក្អក ហឺត ឫសដូងច្រមុះ ក្ដៅក្រហាយ គ្រាំគ្រា រោគក្នុងផ្ទៃ ជ្រប់ ចុះឈាម ចុកសៀត ចុះរាគ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំនួបពិស រមាស់ កម រោគក្នុងទីខ្ញារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ទឹកមូត្រផ្អែម

អំសាយ បិឡកាយ ភគន្ទលាយ បិត្តសមុដ្ឋានេន អាពាធេន សេម្ហសមុដ្ឋានេន អាពាធេន វាតសមុដ្ឋានេន អាពាធេន សន្និបាតិកេន អាពាធេន ឧតុបរិណាមជេន អាពាធេន វិសមបរិហារជេន អាពាធេន ឱបក្កមិកេន អាពាធេន កម្មវិបាកជេន អាពាធេន សីតេន ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សាវេន ឌំសមកសវាតាតបសិរឹសបសម្ផស្សេន ទុក្ខេន មាតុមរណេន ទុក្ខេន បិតុមរណេន ទុក្ខេន ភាតុមរណេន ទុក្ខេន ភគិនីមរណេន ទុក្ខេន បុត្តមរណេន ទុក្ខេន ធីតុមរណេន ទុក្ខេន ញាតិព្យសនេន ភោគព្យសនេន រោគព្យសនេន សីលព្យសនេន ទិដ្ឋិព្យសនេន ទុក្ខេន ផន្ទមានំ សម្ផន្ទមានំ វិប្ផន្ទមានំ វេធមានំ បវេធមានំ សម្បវេធមានំ បស្សាមិ ទក្ខាមិ ឱលោកេមិ និជ្ឈាយាមិ ឧបបរិក្ខាមីតិ បស្សាមិ លោកេ បរិប្ផន្ទមានំ ។

(៨២) បជំ ឥមំ តណ្ហាគតំ ភវេសូតិ បជាតិ សត្តាធិវចនំ ។ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា

ឫសដូងដុះ ឫស ឫសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធកើតអំពីធាតុទាំង៤ប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាម (របស់គេមានវាយចងជាដើម) អាពាធកើតអំពីផលនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ទុច្ចារៈ បស្សាវៈ ទុក្ខដោយសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូចនិងពស់ធំ ទុក្ខព្រោះស្លាប់មាតា ទុក្ខព្រោះស្លាប់បិតា ទុក្ខព្រោះស្លាប់បងប្អូនប្រុស ទុក្ខព្រោះស្លាប់បងប្អូនស្រី ទុក្ខព្រោះស្លាប់កូនប្រុស ទុក្ខព្រោះស្លាប់កូនស្រី ទុក្ខព្រោះវិនាសពួកញាតិ វិនាសភោគៈ វិនាសគឺរោគ វិនាសសីល វិនាសទិដ្ឋិ តថាគត ឃើញ មើល ក្រឡេកមើល សំឡឹងមើល ពិចារណាឃើញ (នូវពួកសត្វ) កំពុងញាប់ញ័រញាប់ញ័ររំប្រប់ ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញ (នូវពួកសត្វ) កំពុងញាប់ញ័រក្នុងលោក ។

(៩២) អធិប្បាយពាក្យថា ពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហា ក្នុងភពទាំងឡាយ ត្រង់ពាក្យថា ពួកសត្វ គឺជាឈ្មោះនៃសត្វ ។ ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា

រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហាគតន្តិ តណ្ហាគតំ តណ្ហានុគតំ តណ្ហានុសដំ តណ្ហាយាបន្នំ តណ្ហាយ បតិតំ អភិភូតំ បរិយាទិន្នចិត្តំ ។ ភវេសូតិ កាមភវេ រូបភវេ អរូបភវេតិ បជំ ឥមំ តណ្ហាគតំ ភវេសុ ។

(៨៣) ហីនា នរា មច្ចុមុខេ លបន្តិ ហីនា នរាតិ ហីនេន កាយកម្មេន សមន្នាគតាតិ ហីនា ។ ហីនេន វចីកម្មេន សមន្នាគតាតិ ហីនា ។ ហីនេន មនោកម្មេន សមន្នាគតាតិ ហីនា ។ ហីនេន បាណាតិបាតេន សមន្នាគតាតិ ហីនា ។ ហីនេន អទិន្នាទានេន ។ ហីនេន កាមេសុមិច្ឆាចារេន ។ ហីនេន មុសាវាទេន ។ ហីនាយ បិសុណាយ វាចាយ ។ ហីនាយ ផរុសាយ វាចាយ ។ ហីនេន សម្ផប្បលាបេន ។ ហីនាយ អភិជ្ឈាយ ។ ហីនេន ព្យាបាទេន ។ ហីនាយ មិច្ឆាទិដ្ឋិយា ។ ហីនេហិ សង្ខារេហិ ។

រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា លុះក្នុងតណ្ហា គឺនៅក្នុងតណ្ហា ទៅតាមតណ្ហា ផ្សាយទៅតាមតណ្ហា លិចចុះក្នុងតណ្ហា ធ្លាក់ក្នុងតណ្ហា (ត្រូវតណ្ហា) គ្របសង្កត់ហើយ មានចិត្ត (ត្រូវតណ្ហា) សង្កត់សង្កិនហើយ ។ ពាក្យថា ភពទាំងឡាយ បានដល់ កាមភព រូបភព អរូបភព ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហា ក្នុងភពទាំងឡាយ ។

(៤៣) អធិប្បាយពាក្យថា នរជនទាំងឡាយ ថោកទាប រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ត្រង់ពាក្យថា នរជនទាំងឡាយថោកទាប គឺនរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយកាយកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយវចីកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយមនោកម្ម ដ៏ថោកទាប ។ នរជនថោកទាប ព្រោះហេតុជាអ្នកប្រកបដោយបាណាតិបាត ដ៏ថោកទាប ។ ដោយអទិន្នាទាន ដ៏ថោកទាប ។ ដោយកាមេសុមិច្ឆាចារដ៏ថោកទាប ។ ដោយមុសាវាទ ដ៏ថោកទាប ។ ដោយបិសុណាវាចា ដ៏ថោកទាប ។ ដោយផរុសវាចា ដ៏ថោកទាប ។ ដោយសម្ផប្បលាបៈ ដ៏ថោកទាប ។ ដោយអភិជ្ឈា ដ៏ថោកទាប ។ ដោយព្យាបាទ ដ៏ថោកទាប ។ ដោយមិច្ឆាទិដ្ឋិ ដ៏ថោកទាប ។ ដោយសង្ខារទាំងឡាយ ដ៏ថោកទាប ។

ហីនេហិ បញ្ចហិ កាមគុណេហិ ។ ហីនេហិ បញ្ចហិ នីវរណេហិ ។ ហីនាយ ចេតនាយ ។ ហីនាយ បត្ថនាយ ។ ហីនាយ បណិធិយា សមន្នាគតាតិ ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ ហីនា នរា ។ មច្ចុមុខេ លបន្តីតិ មច្ចុមុខេ មារមុខេ មរណមុខេ មច្ចុបត្តា មច្ចុសម្បត្តា មច្ចូបាគតា មារបត្តា មារសម្បត្តា មារូបាគតា មរណបត្តា មរណសម្បត្តា មរណូបាគតា លបន្តិ លាលបន្តិ សោចន្តិ កិលមន្តិ បរិទេវន្តិ ឧរត្តាឡឹ កន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ ហីនា នរា មច្ចុមុខេ លបន្តិ ។

(៨៤) អវីតតណ្ហាសេ ភវាភវេសូតិ តណ្ហាតិ រូបតណ្ហា ។ បេ ។ ធម្មតណ្ហា ។ ភវាភវេសូតិ ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ កម្មភវេ កាមភវេ បុនព្ភវេ រូបភវេ កម្មភវេ រូបភវេ បុនព្ភវេ អរូបភវេ កម្មភវេ អរូបភវេ បុនព្ភវេ

ដោយកាមគុណទាំង៥ ដ៏ថោកទាប ១ ដោយនីវរណៈទាំង ៥ ដ៏ថោកទាប ១ ដោយចេតនា ដ៏ថោកទាប ១ ដោយសេចក្តីប្រាថ្នា ដ៏ថោកទាប ១ នរជនថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ កំទេចកំទី ព្រោះហេតុជាអ្នកប្រកបដោយការតំកល់ចិត្ត ដ៏ថោកទាប ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនទាំងឡាយថោកទាប ១ ពាក្យថា រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ សេចក្តីថា ពួកជនដល់នូវមច្ចុ ដល់ព្រមនូវមច្ចុ ចូលទៅរកមច្ចុ ដល់នូវមារ ដល់ព្រមនូវមារ ចូលទៅរកមារ ដល់នូវមរណៈ ដល់ព្រមនូវមរណៈ ចូលទៅរកមរណៈ រមែងយំ យំរៀបរាប់ សៅសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវសេចក្តីវង្វេង ក្នុងមាត់នៃមច្ចុ ក្នុងមាត់នៃមារ ក្នុងមាត់នៃមរណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនទាំងឡាយថោកទាប រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ១

(៥៤) អធិប្បាយពាក្យថា មិនទាន់កន្លងនូវតណ្ហា ក្នុងភពតូចនិងភពធំទាំងឡាយ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា ១ បេ ១ ធម្មតណ្ហា ១ ពាក្យថា ក្នុងភពតូចនិងភពធំទាំងឡាយ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថាក្នុងភពតូចនិងភពធំ គឺថាក្នុងកាមភព ឈ្មោះកម្មភព ក្នុងកាមភព ឈ្មោះបុនព្ភព ក្នុងរូបភព ឈ្មោះកម្មភព ក្នុងរូបភព ឈ្មោះបុនព្ភព ក្នុងអរូបភព ឈ្មោះកម្មភព ក្នុងអរូបភព ឈ្មោះបុនព្ភព

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

បុនព្ភវំ ភវេ បុនព្ភវំ គតិយា បុនព្ភវំ ឧបបត្តិយា បុនព្ភវំ បដិសន្ធិយា បុនព្ភវំ អត្តភាវាភិនិព្វត្តិយា ។ អវីតតណ្ហាសេតិ អវីតតណ្ហា អវិគតតណ្ហា អចត្តតណ្ហា អវន្តតណ្ហា អមុត្តតណ្ហា អប្បហីនតណ្ហា អប្បដិនិស្សដ្ឋតណ្ហាតិ អវីតតណ្ហាសេ ភវាភវេសុ ។ តេនាហ ភគវា

បស្សាមិ លោកេ បរិផន្ទមានំ
បជំ ឥមំ តណ្ហាគតំ ភវេសុ
ហីនា នរា មច្ចុមុខេ លបន្តិ
អវីតតណ្ហាសេ ភវាភវេសូតិ ។

(៥៥) មមាយិតេ បស្សថ ផន្ទមានេ
មច្ឆេវ អប្បោទកេ ខីណសោតេ
ឯតម្បិ ទិស្វា អមមោ ចរេយ្យ
ភវេសុ អាសត្តិមកុព្វមានោ ។

(៥៦) មមាយិតេ បស្សថ ផន្ទមានេតិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។

គឺថា ក្នុងការកើតរឿយ ៗ ការទៅរឿយ ៗ ឧបបត្តិរឿយ ៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាព ឲ្យកើតឡើងរឿយៗ ។ ពាក្យថា មិនកន្លងតណ្ហា គឺ មិនកន្លងតណ្ហា មិនប្រាសចាកតណ្ហា មានតណ្ហាមិនឃ្លាតចេញ មានតណ្ហាមិនខ្ជាក់ចោល មិនរួចចាកតណ្ហា មិនលះបង់តណ្ហា មិនរលាស់ចោលតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) មិនកន្លងតណ្ហា ក្នុងភពតូចនិងភពធំទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតឃើញនូវពួកសត្វនេះ ដែលលុះក្នុងអំណាចតណ្ហា
ក្នុងភពទាំងឡាយ កំពុងញាប់ញ័រក្នុងលោក នរជនទាំង
ឡាយថោកទាប មិនកន្លងតណ្ហា ក្នុងភពតូចនិងភពធំ
ទាំងឡាយ រមែងយំរៀបរាប់ ក្នុងមាត់នៃមច្ចុ ។

(៨៥) អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ
កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែ
ទឹកអស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោស
នេះហើយ គប្បីប្រព្រឹត្ត មិនធ្វើការជាប់ចំពាក់ ក្នុងភព
ទាំងឡាយ ។

(៨៦) អធិប្បាយពាក្យថា អ្នកទាំងឡាយ ចូរមើលពួកសត្វ ដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ត្រង់ពាក្យថា អាល័យ បានដល់អាល័យ ២ យ៉ាង អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ ១ ។

កតមំ តណ្ហាមមត្តំ ។ យាវតា តណ្ហាសង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តិកតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា បាវុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបថវឹ តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិចរិតំ ឥទំ តណ្ហាមមត្តំ ។

កតមំ ទិដ្ឋិមមត្តំ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ ឥទំ ទិដ្ឋិមមត្តំ ។

អាល័យគឺតណ្ហា តើដូចម្តេច ។ កំណត់ដែន កំណត់ទី កំណត់ជួរ កំណត់ជុំវិញ ការហួងហែង ការអាល័យ ដោយចំណែកនៃតណ្ហា មានប្រមាណណាថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណេះរបស់អញ មានប្រមាណប៉ុណ្ណេះរបស់អញ រូបៈ សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ របស់អញ គ្រឿងកម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង របស់អញ សូម្បីបុគ្គលប្រកាន់ផែនដីធំទាំងអស់ ដោយអំណាចនៃតណ្ហា ទាំងតណ្ហាវិបរីត ១០៨ ជាកំណត់ នេះ ឈ្មោះថា អាល័យគឺតណ្ហា ។

អាល័យគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិណា មានសភាពយ៉ាងនេះ ដំណើរគឺទិដ្ឋិ ការសោរ៉ាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការញាប់ញ័រគឺទិដ្ឋិ សញ្ញោជនៈគឺទិដ្ឋិ ការកាន់ ការប្រកាន់ ប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់នៃអណ្តូង ការកាន់ដោយការស្វែងរកខុស ការប្រកាន់វិបរីត ការវិបល្លាស ការកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិត ថាជារបស់ពិត ទិដ្ឋិទាំង ៦២ ទាំងប៉ុន្មាន នេះ ឈ្មោះថា អាល័យគឺទិដ្ឋិ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

មមាយិតេ បស្សថ ផន្ទមានេតិ មមាយិតវត្ថុអច្ឆេទសង្កិនោបិ ផន្ទន្តិ អច្ឆិជ្ជន្តេបិ ផន្ទន្តិ អច្ឆិន្នេបិ ផន្ទន្តិ មមាយិតវត្ថុវិបរិណាមសង្កិនោបិ ផន្ទន្តិ វិបរិណាមន្តេបិ ផន្ទន្តិ វិបរិណតេបិ ផន្ទន្តិ សម្ផន្ទន្តិ (១) វិប្ផន្ទន្តិ វេធន្តិ បវេធន្តិ សម្បវេធន្តិ (២) ឯវំ ផន្ទមានេ សម្ផន្ទមានេ វិប្ផន្ទមានេ វេធមានេ បវេធមានេ សម្បវេធមានេ បស្សថ ទក្ខថ ឱលោកេថ និជ្ឈាយថ ឧបបរិក្ខថាតិ មមាយិតេ បស្សថ ផន្ទមានេ ។

(៥៧) មច្ឆេវ អប្បោទកេ ខីណសោតេតិ យថា មច្ឆា អប្បោទកេ បរិត្តោទកេ ឧទកបរិយាទានេ កាកេហិ វា កុលលេហិ វា ពលាកេហិ វា បរិឃាតិយមានា ឧក្ខិបិយមានា ខជ្ជមានា ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធន្តិ បវេធន្តិ សម្បវេធន្តិ ឯវមេវ បជា មមាយិតវត្ថុអច្ឆេទសង្កិនោបិ ផន្ទន្តិ

១ ខ.ម. បផន្ទន្តិ សម្ផន្ទន្តិ ។ ២ ខ.ម. វេធន្តិ បវេធន្តិ សម្បវេធន្តិ ។

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

ពាក្យថា ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងតែញាប់ញ័រ សេចក្តីថា ពួកនរជនមានសេចក្តីរង្កៀស ក្នុងការដណ្តើមយកវត្ថុ ដែលខ្លួនអាល័យ ញាប់ញ័រខ្លះ កាលគេកំពុងដណ្តើមយក ញាប់ញ័រខ្លះ កាលវត្ថុដែលគេដណ្តើមយកហើយ ញាប់ញ័រខ្លះ មានសេចក្តីរង្កៀស ក្នុងការប្រែប្រួល នៃវត្ថុដែលខ្លួនអាល័យ ញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួល ញាប់ញ័រខ្លះ កាលវត្ថុដែលប្រែប្រួលហើយ ញាប់ញ័រខ្លះ ញាប់ញ័រខ្លាំង ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួង អ្នកទាំងឡាយ ចូរមើល ចូរឃើញ ចូរក្រឡេកមើល ចូរសំឡឹងមើល ចូរពិចារណាមើល នូវពួកសត្វកំពុងញាប់ញ័រ ញាប់ញ័រដោយអាការទាំងពួង ញាប់ញ័រផ្សេងៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់ដោយអាការទាំងពួង យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសេចក្តីអាល័យ កំពុងញាប់ញ័រ ។

(៩៧) ពាក្យថា ដូចពួកត្រី ក្នុងទីមានទឹកតិច ទាំងមានខ្សែទឹកអស់ហើយ សេចក្តីថា ពួកត្រីក្នុងទីមានទឹកតិច មានទឹកស្តួចស្តើង មានទឹកអស់ហើយ ត្រូវពួកក្អែកក្តី ពួកត្រដក់ក្តី ពួកកុកក្តី បៀតបៀនចឹកលើកឡើង ពាំស៊ី ក៏ញាប់ញ័រ ញាប់ញ័រសព្វ ញាប់ញ័រផ្សេង ៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាប់ យ៉ាងណាមិញ ពួកសត្វដែលមានសេចក្តីរង្កៀស ក្នុងការដណ្តើមយកវត្ថុដែលខ្លួនអាល័យ ញាប់ញ័រខ្លះ

អច្ឆិជ្ជន្តេបិ ផន្ទន្តិ អច្ឆិន្នេបិ ផន្ទន្តិ មមាយិតវត្ថុបរិណាមសន្តេបិ ផន្ទន្តិ វិបរិណាមន្តេបិ ផន្ទន្តិ វិបរិណតេបិ ផន្ទន្តិ សម្ផន្ទន្តិ វិប្ផន្ទន្តិ វេធេន្តិ បវេធេន្តិ សម្បវេធេន្តីតិ មច្ឆេវ អប្បោទកេ ខីណសោតេ ។

(៥៨) ឯតម្បិ ទិស្វា អមមោ ចរេយ្យាតិ ឯតំ អាទីនវំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មមត្តេសុតិ ឯតម្បិ ទិស្វា ។ អមមោ ចរេយ្យាតិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា ចក្ខុំ អមមាយន្តោ សោតំ អមមាយន្តោ ឃានំ អមមាយន្តោ ជិវ្ហំ អមមាយន្តោ កាយំ អមមាយន្តោ មនំ អមមាយន្តោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ

កាលគេកំពុងដណ្ដើម ញាប់ញ័រខ្លះ កាលវត្ថុដែលគេ ដណ្ដើមហើយ ញាប់ញ័រខ្លះ មានសេចក្ដីភ្លៀសក្នុងការប្រែប្រួលនៃវត្ថុដែលខ្លួនអាល័យ ញាប់ញ័រខ្លះ កាលវត្ថុដែលកំពុងប្រែប្រួល ញាប់ញ័រខ្លះ កាលវត្ថុដែលប្រែប្រួលហើយ ញាប់ញ័រខ្លះ ញាប់ញ័រសព្វ ញាប់ញ័រផ្សេង ៗ រន្ធត់ រន្ធត់ខ្លាំង រន្ធត់សព្វសាច់ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចពួកត្រីក្នុងទឹកមានទឹកតិច ទាំងមានខ្សែទឹកអស់ហើយ ។

(៩៨) ពាក្យថា បុគ្គលមិនមានអាល័យ លុះឃើញទោសនេះហើយ គប្បីប្រព្រឹត្ត គឺឃើញ មើល ថ្លឹង ពិចារណា សំដែងឲ្យច្បាស់ ធ្វើឲ្យប្រាកដ នូវទោសនេះ ក្នុងអាល័យទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញទោសនេះ ។ ពាក្យថា អាល័យ ក្នុងបទថា បុគ្គលមិនមានអាល័យ គប្បីប្រព្រឹត្ត បានដល់អាល័យ ២ អាល័យគឺតណ្ហា ១ អាល័យគឺទិដ្ឋិ១ ។ បេ ។ នេះ អាល័យគឺតណ្ហា ។ បេ ។ នេះ អាល័យគឺទិដ្ឋិ ។ បុគ្គលលះអាល័យគឺតណ្ហា រលាស់ចោលអាល័យគឺទិដ្ឋិ មិនប្រកាន់ចក្ខុ មិនប្រកាន់សោតៈ មិនប្រកាន់ឃានៈ មិនប្រកាន់ជិវ្ហា មិនប្រកាន់កាយ មិនប្រកាន់ចិត្ត មិនប្រកាន់ មិនទទួល មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវរូប សំឡេង ក្លិន រស ផ្សព្វទាំងឡាយ ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ បរិក្ខារគឺថ្នាំ ជាបច្ច័យដល់ជម្ងឺ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អមមាយន្តោ អគ្គណ្ហន្តោ អបរាមសន្តោ អនភិនិវិសន្តោ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ ឯវម្បិ ទិស្វា អមមោ ចរេយ្យ ។

(៨៩) ភវេសុ អាសត្តិមកុព្វមានោតិ ភវេសូតិ កាមភវេ រូបភវេ អរូបភវេ ។ អាសត្តិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ភវេសុ អាសត្តិមកុព្វមានោតិ ភវេសុ អាសត្តឹ អកុព្វមានោ ឆន្ទំ បេមំ រាគំ ខន្តឹ អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ អនភិនិព្វត្តយមានោតិ ភវេសុ អាសត្តិមកុព្វមានោ ។

កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ធម៌ដែលគេគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង គប្បីប្រព្រឹត្ត គប្បីទៅ ដោយស្ងប់ស្ងាត់ គប្បីញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ គប្បីញុំាងឥរិយាបថឲ្យកើតឡើង គប្បីរក្សាឥរិយាបថ គប្បីបំពេញឥរិយាបថ គប្បីបង្គ្រប់ឥរិយាបថ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកមិនមានអាល័យ លុះឃើញទោសនេះហើយ គប្បីប្រព្រឹត្ត ។

(៤៩) ពាក្យថា ក្នុងភពទាំងឡាយ ក្នុងបទថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ គឺ ក្នុងកាមភព រូបភព អរូបភព ។ តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីរីករាយ ដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុ-សលមូល ។ ពាក្យថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ បានសេចក្តីថា មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ មិនធ្វើសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់ សេចក្តីត្រេកអរ សេចក្តីអត់-ធន់ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតបំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើការជាប់ចំពាក់ ក្នុងភពទាំងឡាយ ។

តេនាហ ភគវា

មមាយិតេ បស្សថ ផន្ទមានេ
មច្ឆេវ អប្បោទកេ ខីណសោតេ
ឯតម្បិ ទិស្វា អមមោ ចរេយ្យ
ភវេសុ អាសត្តិមកុព្វមានោតិ ។

(៦០) ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ
ផស្សំ បរិញ្ញាយ អនានុគិទ្ធោ
យទត្តគរហី តទកុព្វមានោ
ន លិម្បតី[១] ទិដ្ឋសុតេសុ ធីរោ ។

(៦១) ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទន្តិ អន្តាតិ ផស្សោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ។ អតីតោ ឯកោ អន្តោ អនាគតោ ទុតិយោ អន្តោ ។ សុខា វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ ។ នាមំ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ ។ ឆ អជ្ឈត្តិកានិ អាយតនានិ ឯកោ អន្តោ ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ ។ សក្កាយោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោតិ ។

---

១ ន លិម្បតីតិបិ បាឋោ ។

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកទាំងឡាយ ចូរមើលពួកសត្វ ដែលមានសេចក្ដីអាល័យ
កំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ទាំងមានខ្សែ
ទឹកអស់ហើយ បុគ្គលមិនមានអាល័យ លុះឃើញទោស
នេះហើយ គប្បីប្រព្រឹត្ត មិនធ្វើការជាប់ចំពាក់ ក្នុងភព
ទាំងឡាយ ។

(៦០) អ្នកប្រាជ្ញ រមែងបន្ទោបង់នូវសេចក្ដីពេញចិត្ត ក្នុងទីបំផុត
ទាំងពីរ រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់
ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ
មិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយ ដែលខ្លួនឃើញហើយ
ឮហើយឡើយ ។

(៦១) អធិប្បាយពាក្យថា រមែងបន្ទោបង់នូវសេចក្ដីពេញចិត្តក្នុងទីបំផុត ទាំងពីរ ត្រង់ពាក្យថា ទីបំផុត គឺ ផស្សៈ ជាទីបំផុតទី ១ ហេតុដែលកើតផស្សៈ ជាទីបំផុតទី ២ ។ អតីតកាល ជាទីបំផុតទី ១ អនាគតកាល ជាទីបំផុតទី ២ ។ សុខវេទនា ជាទីបំផុតទី ១ ទុក្ខវេទនា ជាទីបំផុតទី ២ ។ នាម ជាទីបំផុតទី ១ រូប ជាទីបំផុតទី ២ ។ អាយតនៈខាងក្នុង ៦ ជាទីបំផុតទី ១ អាយតនៈខាងក្រៅ ៦ ជាទីបំផុតទី ២ ។ សក្កាយៈ ជាទីបំផុតទី ១ ហេតុជាដែនកើតនៃសក្កាយៈ ជាទីបំផុតទី ២ ។

ឆន្ទោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាម-
នន្ទិ កាមតណ្ហា កាមស្នេហោ កាមបរិឡាហោ
កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោ-
គោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ ឧភោសុ
អន្តេសុ វិនេយ្យ ឆន្ទន្តិ ឧភោសុ អន្តេសុ ឆន្ទំ វិនេយ្យ
បដិវិនេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ
អនភាវង្គមេយ្យាតិ ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ ។

(៦២) ផស្សំ បរិញ្ញាយ អនានុគិទ្ធោតិ ផស្សោតិ
ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ
ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ អធិ-
វចនសម្ផស្សោ បដិឃសម្ផស្សោ សុខវេទនីយោ សម្ផ-
ស្សោ ទុក្ខវេទនីយោ សម្ផស្សោ អទុក្ខមសុខវេទនី-
យោ សម្ផស្សោ កុសលោ ផស្សោ អកុសលោ
ផស្សោ អព្យាកតោ ផស្សោ កាមាវចរោ ផស្សោ
រូបាវចរោ ផស្សោ អរូបាវចរោ ផស្សោ សុញ្ញតោ
ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោ

ពាក្យថា សេចក្តីពេញចិត្ត បានដល់សេចក្តីពេញចិត្តគឺកាម សេចក្តីត្រេកអរគឺកាម សេចក្តីរីករាយគឺកាម ចំណង់គឺកាម សេចក្តីស្រឡាញ់គឺកាម សេចក្តីក្តៅក្រហាយគឺកាម សេចក្តីងល់ងប់គឺកាម សេចក្តីជ្រុលជ្រប់គឺកាម អន្ទង់គឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា រមែងបន្ទោបង់ នូវសេចក្តីពេញចិត្តក្នុងទីបំផុតទាំងពីរ បានសេចក្តីថា រមែងបន្ទោបង់ បន្ទោបង់ បំពោះ លះបង់ កំចាត់បង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសេចក្តីពេញចិត្តក្នុងទីបំផុតទាំងពីរ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងបន្ទោបង់សេចក្តីពេញចិត្ត ក្នុងទីបំផុតទាំងពីរ ។

[៦៤] អធិប្បាយពាក្យថា រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់ ត្រង់ពាក្យថា ផស្សៈ បានដល់ចក្ខុសម្ផស្សៈ សោតសម្ផស្សៈ ឃានសម្ផស្សៈ ជិវ្ហាសម្ផស្សៈ កាយសម្ផស្សៈ មនោសម្ផស្សៈ អធិវចនសម្ផស្សៈ បដិឃសម្ផស្សៈ សុខវេទនីយសម្ផស្សៈ ទុក្ខវេទនីយសម្ផស្សៈ អទុក្ខមសុខវេទនីយសម្ផស្សៈ កុសលផស្សៈ អកុសលផស្សៈ អព្យាកតផស្សៈ កាមាវចរផស្សៈ រូបាវចរផស្សៈ អរូបាវចរផស្សៈ សុញ្ញតផស្សៈ អនិមិត្តផស្សៈ អប្បណិហិតផស្សៈ

លោកិយោ ផស្សោ លោកុត្តរោ ផស្សោ អតីតោ ផស្សោ អនាគតោ ផស្សោ បច្ចុប្បន្នោ ផស្សោ យោ ឯវរូបោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ផស្សោ ។ ផស្សំ បរិញ្ញាយាតិ ផស្សំ តីហិ បរិញ្ញាហិ បរិជានិត្វា ញាតបរិញ្ញាយ តីរណបរិញ្ញាយ បហានបរិញ្ញាយ ។

កតមា ញាតបរិញ្ញា ។ ផស្សំ ជានាតិ អយំ ចក្ខុសម្ផស្សោ អយំ សោតសម្ផស្សោ អយំ ឃានសម្ផស្សោ អយំ ជិវ្ហាសម្ផស្សោ អយំ កាយសម្ផស្សោ អយំ មនោសម្ផស្សោ អយំ អធិវចនសម្ផស្សោ អយំ បដិឃសម្ផស្សោ អយំ សុខវេទនីយោ ផស្សោ អយំ ទុក្ខវេទនីយោ ផស្សោ អយំ អទុក្ខមសុខវេទនីយោ ផស្សោ អយំ កុសលោ ផស្សោ អយំ អកុសលោ ផស្សោ អយំ អព្យាកតោ ផស្សោ អយំ កាមាវចរោ ផស្សោ អយំ រូបាវចរោ ផស្សោ អយំ អរូបាវចរោ ផស្សោ អយំ សុញ្ញតោ ផស្សោ អយំ អនិមិត្តោ ផស្សោ អយំ អប្បណិហិតោ ផស្សោ

លោកិយផស្សៈ លោកុត្តរផស្សៈ អតីតផស្សៈ អនាគតផស្សៈ បច្ចុប្បន្នផស្សៈ ការប៉ះពាល់ អាការនៃការប៉ះពាល់ ការពាល់ត្រូវព្រម ភាពនៃការពាល់ត្រូវព្រម ណា មានសភាពយ៉ាងនេះ នេះ ហៅថា ផស្សៈ ។ ពាក្យថា កំណត់ដឹងផស្សៈ គឺកំណត់ដឹងផស្សៈ ដោយ បរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) ដឹងនូវផស្សៈ គឺដឹង ឃើញថា នេះ ចក្ខុសម្ផស្សៈ នេះ សោតសម្ផស្សៈ នេះ ឃានសម្ផស្សៈ នេះ ជិវ្ហាសម្ផស្សៈ នេះ កាយសម្ផស្សៈ នេះ មនោសម្ផស្សៈ នេះ អធិវចនសម្ផស្សៈ នេះ បដិឃសម្ផស្សៈ នេះ សុខវេទនីយផស្សៈ នេះ ទុក្ខវេទនីយផស្សៈ នេះ អទុក្ខមសុខវេទនីយ-ផស្សៈ នេះ កុសលផស្សៈ នេះ អកុសលផស្សៈ នេះ អព្យាកតផស្សៈ នេះ កាមាវចរផស្សៈ នេះ រូបាវចរផស្សៈ នេះ អរូបាវចរផស្សៈ នេះ សុញ្ញតផស្សៈ នេះ អនិមិត្តផស្សៈ នេះ អប្បណិហិតផស្សៈ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

អយំ លោកិយោ ឆន្ទោ អយំ លោកុត្តរោ ឆន្ទោ អយំ អតីតោ ឆន្ទោ អយំ អនាគតោ ឆន្ទោ អយំ បច្ចុប្បន្នោ ឆន្ទោតិ ជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កតមា តីរណបរិញ្ញា ។ ឯវំ ញាតំ កត្វា ឆន្ទំ តីរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ ឦតិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ អលេណតោ អសរណតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វធកតោ វិភវតោ សាសវតោ សង្ខតតោ មារាមិសតោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សង្កិលេសិកធម្មតោ សមុទយតោ អត្ថង្គមតោ អស្សាទតោ អាទីនវតោ និស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

នេះ លោកិយផស្សៈ នេះ លោកុត្តរផស្សៈ នេះ អតីតផស្សៈ នេះ អនាគតផស្សៈ នេះ បច្ចុប្បន្នផស្សៈ នេះ ឈ្មោះថា ញាតបរិញ្ញា ។

តីរណបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) លុះដឹងនូវការដឹងយ៉ាងនេះហើយ ពិចារណាផស្សៈ គឺពិចារណាថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីលំបាក ជាអាពាធ ជារបស់អ្នកដទៃ ជារបស់ទ្រុឌទ្រោម ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនឋិតយូរ ជារបស់គ្មានទីពឹង គ្មានទីជ្រក គ្មានទីរលឹក ជារបស់ទទេ ជារបស់រលីងរេង ជារបស់សោះសូន្យ មិនមែនជារបស់ខ្លួន ជាទោស ជារបស់ប្រែប្រួលជាធម្មតា ជារបស់ឥតខ្លឹម ជាឫសនៃទុក្ខ ជាពេជ្ឈឃាត គ្មានសេចក្តីចំរើន ប្រកបដោយអាសវៈ មានបច្ច័យតាក់តែង ជាអាមិសៈនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈជាធម្មតា ប្រកបដោយគ្រឿងសៅហ្មងជាធម្មតា ជារបស់កើតឡើង ជារបស់វិនាសទៅវិញ ជារបស់គួរត្រេកអរ ជាទោស ជាគ្រឿងរលាស់ចេញ នេះ ឈ្មោះថា តីរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តីរយិត្វា ផស្សេ ឆន្ទរាគំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ វុត្តំ ហេតំ ភគវតា យោ ភិក្ខវេ ផស្សេសុ ឆន្ទរាគោ តំ បជហថ ឯវំ សោ ផស្សោ បហីនោ ភវិស្សតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ។ អយំ បហានបរិញ្ញា ។

ផស្សំ បរិញ្ញាយាតិ ផស្សំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានិត្វា ។ អនានុគិទ្ធោតិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសោ គេធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អគិទ្ធោ ។ សោ រូបេ អគិទ្ធោ សទ្ទេ អគិទ្ធោ គន្ធេ អគិទ្ធោ រសេ អគិទ្ធោ ផោដ្ឋព្វេ អគិទ្ធោ កុលេ គណេ

បហានបរិញ្ញា តើដូចម្តេច ។ (ភិក្ខុក្នុងសាសនានេះ) លុះពិចារណាយ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវឆន្ទរាគក្នុងផស្សៈ ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណា ក្នុងផស្សៈទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើយ៉ាងនេះបាន ផស្សៈនោះ ឈ្មោះថា អ្នកទាំងឡាយ បានលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាមិនមានទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមាន ធ្វើឲ្យជាធម៌លែងកើត តទៅទៀតហើយ ។ នេះ ឈ្មោះថា បហានបរិញ្ញា ។

ពាក្យថា កំណត់ដឹងផស្សៈហើយ គឺកំណត់ដឹងផស្សៈ ដោយបរិញ្ញាទាំង ៣ នេះ ។ ពាក្យថា មិនជាប់ចំពាក់ អធិប្បាយថា តណ្ហា លោកហៅថា ការជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការជាប់ចំពាក់នុ៎ះ បុគ្គលណាបានលះបង់ហើយ បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានរលាស់ចោលហើយ ធ្វើមិនឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនជាប់ចំពាក់ ។ បុគ្គលនោះ មិនជាប់ចំពាក់ក្នុងរូប មិនជាប់ចំពាក់ក្នុងសំឡេង មិនជាប់ចំពាក់ក្នុងក្លិន មិនជាប់ចំពាក់ក្នុងរស មិនជាប់ចំពាក់ក្នុងផ្សព្វ មិនជាប់ចំពាក់ក្នុងត្រកូល

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

អាវាសេ លាភេ យសេ បសំសាយ សុខេ ចីវរេ បិណ្ឌបាតេ សេនាសនេ គិលានប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការភវេ បញ្ចវោការភវេ អតីតេ អនាគតេ បច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ អគិទ្ធោ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ វិគតគេធោ ចត្តគេធោ វន្តគេធោ មុត្តគេធោ បហីនគេធោ បដិនិស្សដ្ឋគេធោ វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ ផស្សំ បរិញ្ញាយ អនានុគិទ្ធោ ។

(៦៣) យទត្តគរហី តទកុព្វមានោតិ យន្តិ យំ អត្តនា គរហតិ ។ ទ្វីហិ ការណេហិ អត្តានំ គរហតិ កតត្តា ច អកតត្តា ច ។

ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់ជម្ងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង មិនធ្លាក់ចុះ មិនជ្រុលជ្រប់ មិនងល់ងប់ មានការជាប់ចំពាក់កន្លងហើយ មានការជាប់ចំពាក់ទៅប្រាសហើយ មានការជាប់ចំពាក់លះហើយ មានការជាប់ចំពាក់ខ្ជាក់ចោលហើយ មានការជាប់ចំពាក់រួចហើយ មានការជាប់ចំពាក់លះបង់ហើយ មានការជាប់ចំពាក់រលាស់ចោលហើយ មានរាគៈកន្លងហើយ មានរាគៈទៅប្រាសហើយ មានរាគៈលះហើយ មានរាគៈខ្ជាក់ចោលហើយ មានរាគៈរួចស្រឡះហើយ មានរាគៈលះបង់ហើយ មានរាគៈរលាស់ចោលហើយ មិនមានសេចក្តីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលចំពោះសេចក្តីសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) កំណត់ដឹងផស្សៈហើយ ជាអ្នកមិនជាប់ចំពាក់ ។

[៦៣] អធិប្បាយពាក្យថា តិះដៀលអំពើណាដោយខ្លួនឯង មិនធ្វើអំពើនោះ ត្រង់ពាក្យថា អំពើណា គឺតិះដៀលអំពើណាដោយខ្លួនឯង ។ តិះដៀលខ្លួន ព្រោះហេតុ ២ យ៉ាង គឺព្រោះអំពើដែលខ្លួនធ្វើហើយ និង

កថំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ អត្តានំ គរហតិ ។ កតំ មេ វចីទុច្ចរិតំ អកតំ មេ វចីសុចរិតន្តិ អត្តានំ គរហតិ ។ កតំ មេ មនោទុច្ចរិតំ អកតំ មេ មនោសុចរិតន្តិ អត្តានំ គរហតិ ។ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ អត្តានំ គរហតិ ។ កតំ មេ អទិន្នាទានំ អកតា មេ អទិន្នាទានា វេរមណីតិ អត្តានំ គរហតិ ។ កតោ មេ កាមេសុ មិច្ឆាចារោ អកតា មេ កាមេសុ មិច្ឆាចារា វេរមណីតិ អត្តានំ គរហតិ ។ កតោ មេ មុសាវាទោ អកតា មេ មុសាវាទា វេរមណីតិ អត្តានំ គរហតិ ។ កតា មេ បិសុណា វាចា អកតា មេ បិសុណាយ វាចាយ វេរមណីតិ អត្តានំ គរហតិ ។ កតា មេ ផរុសា វាចា អកតា មេ ផរុសាយ វាចាយ វេរមណីតិ អត្តានំ គរហតិ ។

អំពើដែលខ្លួន មិនបានធ្វើហើយ ៗ

តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ និងអំពើដែលខ្លួន មិនបានធ្វើហើយ តើដូចម្តេច ៗ បុគ្គល តិះដៀលខ្លួនឯងថា កាយទុច្ចរិត អាត្មាអញបានធ្វើហើយ កាយសុចរិត អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា វចីទុច្ចរិត អាត្មាអញបានធ្វើហើយ វចីសុចរិត អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា មនោ-ទុច្ចរិត អាត្មាអញបានធ្វើហើយ មនោសុចរិត អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា បាណាតិបាត អាត្មាអញបានធ្វើហើយ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើទេ ។ តិះដៀលខ្លួនឯងថា អទិន្នា-ទាន អាត្មាអញបានធ្វើហើយ ការវៀរចាកអទិន្នាទាន អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា កាមេសុមិច្ឆាចារ អាត្មាអញបានធ្វើហើយ ការវៀរចាកកាមេសុមិច្ឆាចារ អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា មុសាវាទ អាត្មាអញបានធ្វើហើយ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា បិសុណា-វាចា អាត្មាអញបានធ្វើហើយ ការវៀរចាកបិសុណាវាចា អាត្មាអញមិនបានធ្វើទេ ៗ តិះដៀលខ្លួនឯងថា ផរុសវាចា អាត្មាអញបានធ្វើហើយ ការវៀរចាកផរុសវាចា អាត្មាអញ មិនបានធ្វើទេ ៗ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

កតោ មេ សម្ផប្បលាបោ អកតា មេ សម្ផប្ប-
លាបា វេរមណីតិ អត្តានំ គរហតិ ។ កតា មេ
អភិជ្ឈា អកតា មេ អនភិជ្ឈាតិ អត្តានំ គរហតិ ។
កតោ មេ ព្យាបាទោ អកតោ មេ អព្យាបាទោតិ
អត្តានំ គរហតិ ។ កតា មេ មិច្ឆាទិដ្ឋិ អកតា មេ
សម្មាទិដ្ឋីតិ អត្តានំ គរហតិ ។ ឯវំ កតត្តា ច
អកតត្តា ច អត្តានំ គរហតិ ។ អថវា សីលេសុម្ហិ
ន បរិបូរការីតិ អត្តានំ គរហតិ ។ ឥន្ទ្រិយេសុម្ហិ
អគុត្តទ្វារោតិ អត្តានំ គរហតិ ។ ភោជនេ អមត្តញ្ញុ-
ម្ហីតិ អត្តានំ គរហតិ ។ ជាគរិយំ អននុយុត្តោម្ហីតិ
អត្តានំ គរហតិ ។ ន សតិសម្បជញ្ញេន សមន្នាគ-
តោម្ហីតិ អត្តានំ គរហតិ ។ អភាវិតា មេ ចត្តារោ
សតិបដ្ឋានាតិ អត្តានំ គរហតិ ។ អភាវិតា មេ
ចត្តារោ សម្មប្បធានាតិ អត្តានំ គរហតិ ។ អភាវិតា
មេ ចត្តារោ ឥទ្ធិបាទាតិ អត្តានំ គរហតិ ។
អភាវិតានិ មេ បញ្ចិន្ទ្រិយានីតិ អត្តានំ គរហតិ ។

គិះដៀលខ្លួនឯងថា សម្ផប្បលាបៈ អាត្មាអញបានធ្វើហើយ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើទេ ។ គិះដៀលខ្លួនឯងថា អភិជ្ឈា អាត្មាអញបានធ្វើហើយ អនភិជ្ឈា អាត្មាអញមិនបានធ្វើទេ ។ គិះដៀលខ្លួនឯងថា ព្យាបាទ អាត្មាអញបានធ្វើហើយ អព្យាបាទ អាត្មាអញមិនបានធ្វើទេ ។ គិះដៀលខ្លួនឯងថា មិច្ឆាទិដ្ឋិ អាត្មាអញបានធ្វើហើយ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើទេ ។ គិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនបានធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយ យ៉ាងនេះឯង ។ ម្យ៉ាងទៀត បុគ្គលគិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយ ។ គិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ។ គិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនដឹងប្រមាណក្នុងភោជន ។ គិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបរឿយ ៗ នូវការភ្ញាក់រឭក ។ គិះដៀលខ្លួនឯងថា អាត្មាអញជាអ្នកមិនប្រកបដោយសតិសម្បជញ្ញៈ ។ គិះដៀលខ្លួនឯងថា សតិប្បដ្ឋានទាំង ៤ អាត្មាអញមិនបានចំរើនទេ ។ គិះដៀលខ្លួនឯងថា សម្មប្បធានទាំង ៤ អាត្មាអញមិនបានចំរើនទេ ។ គិះដៀលខ្លួនឯងថា ឥទ្ធិបាទទាំង ៤ អាត្មាអញមិនបានចំរើនទេ ។ គិះដៀលខ្លួនឯងថា ឥន្ទ្រិយទាំង ៥ អាត្មាអញមិនបានចំរើនទេ ។

អការិតានិ មេ បញ្ច ពលានីតិ អត្តានំ គរហតិ ។ អការិតា មេ សត្ត ពោជ្ឈង្គាតិ អត្តានំ គរហតិ ។ អការិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ អត្តានំ គរហតិ ។ ទុក្ខំ មេ អបរិញ្ញាតន្តិ អត្តានំ គរហតិ ។ សមុទយោ មេ អប្បហីនោតិ អត្តានំ គរហតិ ។ មគ្គោ មេ អភាវិតោតិ អត្តានំ គរហតិ ។ និរោធោ មេ អសច្ឆិកតោតិ អត្តានំ គរហតិ ។ ឯវំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ ឯវំ អត្តគរហិយំ កម្មំ អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ អនភិនិព្វត្តយមានោតិ យទត្តគរហី តទកុព្វមានោ ។

(៦៨) ន លិម្បតី ទិដ្ឋសុតេសុ ធីរោតិ លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។ បេ ។ អយំ តណ្ហាលេបោ ។ បេ ។ អយំ ទិដ្ឋិលេបោ ។

តិះដៀលខ្លួនឯងថា ពលៈទាំង ៥ អាត្មាអញមិនបានចំរើនទេ ៗ តិះដៀលខ្លួនឯងថា ពោជ្ឈង្គទាំង ៧ អាត្មាអញមិនបានចំរើនទេ ៗ តិះដៀលខ្លួនឯងថា អរិយមគ្គប្រកបដោយអង្គ ៨ អាត្មាអញមិនបានចំរើនទេ ៗ តិះដៀលខ្លួនឯងថា ទុក្ខ អាត្មាអញមិនបានកំណត់ទេ ៗ តិះដៀលខ្លួនឯងថា សមុទយៈ អាត្មាអញមិនបានលះបង់ទេ ៗ តិះដៀលខ្លួនឯងថា មគ្គ អាត្មាអញមិនបានចំរើនទេ ៗ តិះដៀលខ្លួនឯងថា និរោធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ៗ តិះដៀលខ្លួនឯង ព្រោះអំពើដែលបានធ្វើហើយ និងអំពើដែលខ្លួនមិនបានធ្វើហើយ យ៉ាងនេះឯង ៗ អ្នកប្រាជ្ញមិនធ្វើ គឺមិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវអំពើដែលគួរតិះដៀលខ្លួន យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញ ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ ៗ

(៦៤) អធិប្បាយពាក្យថា អ្នកប្រាជ្ញមិនប្រឡាក់ក្នុងអារម្មណ៍ទាំងឡាយដែលខ្លួនឃើញហើយ ឮហើយ ត្រង់ពាក្យថា ការប្រឡាក់ បានដល់ការប្រឡាក់ ២ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថាការប្រឡាក់គឺតណ្ហា ។ បេ ។ នេះ ឈ្មោះថាការប្រឡាក់គឺទិដ្ឋិ ៗ

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ធីរោតិ ធីរោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ ធីរោ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា ទិដ្ឋេ ន លិម្បតិ សុតេ ន លិម្បតិ មុតេ ន លិម្បតិ វិញ្ញាតេ ន លិម្បតិ ន សំលិម្បតិ ន ឧបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន[1] ចេតសា វិហរតីតិ ន លិម្បតី ទិដ្ឋសុតេសុ ធីរោ ។ តេនាហ ភគវា

ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ
ផស្សំ បរិញ្ញាយ អនានុគិទ្ធោ
យទត្តគរហី តទកុព្វមានោ
ន លិម្បតី ទិដ្ឋសុតេសុ ធីរោតិ ។

---

១ ម. វិបរិយាទិកតេន ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

អ្នកមានប្រាជ្ញា បណ្ឌិត អ្នកមានការដឹងសព្វ អ្នកមានការត្រាស់ដឹង អ្នកមានញាណ អ្នកមានប្រាជ្ញាភ្លឺច្បាស់ អ្នកមានប្រាជ្ញាជាគ្រឿងទំលាយបង់នូវកិលេស ឈ្មោះថា អ្នកប្រាជ្ញ ។ អ្នកប្រាជ្ញបានលះបង់ នូវការប្រឡាក់គឺតណ្ហា រលាស់ចោលនូវការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ក្នុងអារម្មណ៍ដែលឃើញហើយ មិនប្រឡាក់ក្នុងអារម្មណ៍ ដែលឮហើយ មិនប្រឡាក់ក្នុងអារម្មណ៍ ដែលទទួលហើយ មិនប្រឡាក់ មិនសៅហ្មង មិនចូលទៅជិតលាបក្នុងអារម្មណ៍ ដែលដឹងច្បាស់ហើយ គឺជាអ្នកមិនប្រឡាក់ មិនសៅហ្មង មិនចូលទៅជិតលាប ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ សម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញ មិនប្រឡាក់ ក្នុងអារម្មណ៍ ដែលខ្លួនឃើញហើយ ឮហើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកប្រាជ្ញ រមែងបន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងទីបំផុត
ទាំងពីរ រមែងកំណត់ដឹងផស្សៈ ហើយជាអ្នកមិនជាប់ចំពាក់
ជាអ្នកតិះដៀលអំពើណាដោយខ្លួនឯង តែងមិនធ្វើអំពើនោះ
មិនប្រឡាក់ក្នុងអារម្មណ៍ ដែលខ្លួនឃើញហើយឮហើយ ។

(៦៥) សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ
បរិគ្គហេសុ មុនិ នោបលិត្តោ
អព្ពូឡ្ហសល្លោ ចរមប្បមត្តោ
នាសីសតី លោកមិមំ បរញ្ច ។

(៦៦) សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃន្តិ សញ្ញាតិ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា យា ឯវរូបា សញ្ញា សញ្ជាននា សញ្ជានិតត្តំ អយំ វុច្ចតិ សញ្ញា ។ សញ្ញំ បរិញ្ញាតិ សញ្ញំ តីហិ បរិញ្ញាហិ បរិជានិត្វា ញាតបរិញ្ញាយ តីរណបរិញ្ញាយ បហានបរិញ្ញាយ ។

កតមា ញាតបរិញ្ញា ។ សញ្ញំ ជានាតិ អយំ កាមសញ្ញា អយំ ព្យាបាទសញ្ញា អយំ វិហឹសាសញ្ញា អយំ នេក្ខម្មសញ្ញា អយំ អព្យាបាទសញ្ញា អយំ អវិហឹសាសញ្ញា អយំ រូបសញ្ញា អយំ សទ្ទសញ្ញា អយំ គន្ធសញ្ញា អយំ រសសញ្ញា អយំ ផោដ្ឋព្វសញ្ញា

(៦៥) មុនិ កំណត់ដឹងសញ្ញាហើយ គប្បីឆ្លងនូវឱឃៈបាន ជាអ្នកមិនប្រកាន់ ក្នុងសេចក្ដីហួងហែងទាំងឡាយ ជាអ្នកមានព្រួញដកឡើងហើយ ប្រព្រឹត្តមិនប្រហែស មិនប្រាថ្នានូវលោកនេះ និងលោកដទៃ ។

(៦៦) អធិប្បាយពាក្យថា កំណត់ដឹងសញ្ញាហើយ គប្បីឆ្លងនូវឱឃៈបាន ត្រង់ពាក្យថា សញ្ញា បានដល់កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា សេចក្ដីសំគាល់ អាការនៃសេចក្ដីសំគាល់ ភាពនៃអារម្មណ៍ ដែលបុគ្គលសំគាល់ណា មានសភាព យ៉ាងនេះ នេះ លោកហៅថា សញ្ញា ។ ពាក្យថា កំណត់ដឹងនូវសញ្ញា គឺ កំណត់ដឹង នូវសញ្ញា ដោយបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្ដេច ។ ភិក្ខុដឹងនូវសញ្ញា គឺ ដឹង ឃើញថា នេះកាមសញ្ញា នេះព្យាបាទសញ្ញា នេះវិហឹសាសញ្ញា នេះនេក្ខម្មសញ្ញា នេះអព្យាបាទសញ្ញា នេះអវិហឹសាសញ្ញា នេះរូបសញ្ញា នេះសទ្ទសញ្ញា នេះគន្ធសញ្ញា នេះរសសញ្ញា នេះផោដ្ឋព្វសញ្ញា

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

អយំ ធម្មសញ្ញាតិ ជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កតមា តីរណបរិញ្ញា ។ ឯវំ ញាតំ កត្វា សញ្ញំ តីរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ ឦតិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ ។បេ។ សមុទយតោ អត្ថង្គមតោ អស្សាទតោ អាទីនវតោ និស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តីរេត្វា សញ្ញាយ ឆន្ទរាគំ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ វុត្តំ ហេតំ ភគវតា យោ ភិក្ខវេ សញ្ញាយ ឆន្ទរាគោ តំ បជហថ ឯវំ សា សញ្ញា បហីនា ភវិស្សតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មាតិ ។ អយំ បហានបរិញ្ញា ។

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

នេះធម្មសញ្ញា ដូច្នេះ នេះ ឈ្មោះថា ញាតបរិញ្ញា ។

តីរណបរិញ្ញា តើដូចម្ដេច ។ (ភិក្ខុ) លុះធ្វើនូវការដឹងយ៉ាងនេះហើយ ពិចារណានូវសញ្ញាគឺពិចារណាថា មិនទៀង ជាទុក្ខ ជារោគ ជាពក ជាព្រួញ ជាសេចក្ដីលំបាក ជាអាពាធ ជារបស់បុគ្គលដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់កម្រើក ជារបស់ពុករលួយ ។ បេ ។ ជាគ្រឿងកើតឡើង ជាគ្រឿងដល់នូវសេចក្ដីវិនាស ជាគ្រឿងត្រេកអរ ជាទោស ជាការរលាស់ចេញ នេះឈ្មោះថា តីរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្ដេច ។ (ភិក្ខុ) លុះពិចារណាយ៉ាងនេះហើយ ក៏លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានឆន្ទរាគក្នុងសញ្ញា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគណាក្នុងសញ្ញា អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើយ៉ាងនេះបាន សញ្ញានោះ ឈ្មោះថាអ្នកទាំងឡាយលះបង់ហើយ ផ្ដាច់ឬសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យលែងកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ។ នេះ ឈ្មោះថា បហានបរិញ្ញា ។

សញ្ញំ បរិញ្ញាតិ សញ្ញំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានិត្វា ។ វិតរេយ្យ ឱឃន្តិ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ វិតរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ ។

(៦៧) បរិគ្គហេសុ មុនិ នោបលិត្តោតិ បរិគ្គហាតិ ទ្វេ បរិគ្គហា តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។ បេ ។ អយំ តណ្ហាបរិគ្គហោ ។ បេ ។ អយំ ទិដ្ឋិបរិគ្គហោ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតោ មុនិ មោនប្បត្តោតិ ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។

កតមំ កាយមោនេយ្យំ ។ តិវិធានំ កាយទុច្ចរិតានំ បហានំ កាយមោនេយ្យំ ។ តិវិធំ កាយសុចរិតំ កាយមោនេយ្យំ ។ កាយារម្មណេ ញាណំ កាយមោនេយ្យំ ។ កាយបរិញ្ញា កាយមោនេយ្យំ ។

ពាក្យថា កំណត់ដឹងសញ្ញា គឺកំណត់ដឹងសញ្ញាដោយបរិញ្ញា ៣ នេះ ។ ពាក្យថា គប្បីឆ្លងឱឃៈបាន គឺគប្បីឆ្លង ឆ្លងឡើង កន្លង ប្រព្រឹត្តកន្លង នូវកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) កំណត់ដឹងសញ្ញាហើយ គប្បីឆ្លងឱឃៈបាន ។

(៦៧) អធិប្បាយពាក្យថា មុនិ ជាអ្នកមិនប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ត្រង់ពាក្យថា សេចក្តីហួងហែងទាំងឡាយ បានដល់សេចក្តីហួងហែង ២ គឺ សេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះឈ្មោះថា សេចក្តីហួងហែងគឺតណ្ហា ។ បេ ។ នេះឈ្មោះថា សេចក្តីហួងហែងគឺទិដ្ឋិ ។ ពាក្យថា មុនិ អធិប្បាយថា ការដឹង លោកហៅថា មោនៈ បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសន្ទ្យធម៌ ការយល់ឃើញត្រូវ មុនិ ប្រកបព្រមដោយការដឹងនោះ ឈ្មោះថា អ្នកដល់នូវមោនៈ ។ មោនេយ្យៈ មាន ៣ គឺ កាយមោនេយ្យៈ ១ វចីមោនេយ្យៈ ១ មនោមោនេយ្យៈ ១ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្យៈ ។ កាយសុចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្យៈ ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ។ ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្យៈ ។

បរិញ្ញាសហគតោ មគ្គោ កាយមោនេយ្យំ ។ កាយេ ឆន្ទរាគស្ស បហានំ កាយមោនេយ្យំ ។ កាយសង្ខារនិរោធោ ចតុត្ថជ្ឈានសមាបត្តិ កាយមោនេយ្យំ ។ ឥទំ កាយមោនេយ្យំ ។

កតមំ វចីមោនេយ្យំ ។ ចតុព្វិធានំ វចីទុច្ចរិតានំ បហានំ វចីមោនេយ្យំ ។ ចតុព្វិធំ វចីសុចរិតំ វចីមោនេយ្យំ ។ វាចារម្មណំ ញាណំ វចីមោនេយ្យំ ។ វាចាបរិញ្ញា វចីមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ វចីមោនេយ្យំ ។ វាចាយ ឆន្ទរាគស្ស បហានំ វចីមោនេយ្យំ ។ វចីសង្ខារនិរោធោ ទុតិយជ្ឈានសមាបត្តិ វចីមោនេយ្យំ ។ ឥទំ វចីមោនេយ្យំ ។

កតមំ មនោមោនេយ្យំ ។ តិវិធានំ មនោទុច្ចរិតានំ បហានំ មនោមោនេយ្យំ ។ តិវិធំ មនោសុចរិតំ មនោមោនេយ្យំ ។ ចិត្តារម្មណំ ញាណំ មនោមោនេយ្យំ ។ ចិត្តបរិញ្ញា មនោមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ មនោមោនេយ្យំ ។ ចិត្តេ ឆន្ទរាគស្ស បហានំ មនោមោនេយ្យំ ។

មគ្គប្រព្រឹត្តទៅមួយអន្លើ ដោយការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ ចតុត្ថជ្ឈានសមាបត្តិ ដែលរំលត់កាយសង្ខារ ឈ្មោះថា កាយមោនេយ្យៈ ។ នេះ ឈ្មោះថា កាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យ ។ វចីសុចរិត៤យ៉ាង ឈ្មោះថា វចីមោនេយ្យៈ ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ។ ការកំណត់ដឹងវាចា ឈ្មោះថា វចីមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅមួយអន្លើដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោនេយ្យៈ ។ ទុតិយជ្ឈានសមាបត្តិ ដែលរំលត់វចីសង្ខារ ឈ្មោះថា វចីមោនេយ្យៈ ។ នេះ ឈ្មោះថា វចីមោនេយ្យៈ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យៈ ។ មនោសុចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យៈ ។ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ។ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅមួយអន្លើ ដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។

ចិត្តសង្ខារនិរោធា សញ្ញាវេទយិតនិរោធសមាបត្តិ មនោមោនេយ្យំ ។ ឥទំ មនោមោនេយ្យំ ។

កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ សព្វប្បហាយិនំ ។
កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ និន្ហាតបាបកំ ។

ឥមេហិ តីហិ មោនេយ្យេហិ ធម្មេហិ សមន្នាគតា ឆ មុនយោ អាគារមុនយោ អនាគារមុនយោ សេក្ខមុនយោ អសេក្ខមុនយោ បច្ចេកមុនយោ មុនិមុនយោ[១] ។ កតមេ អាគារមុនយោ ។ យេ តេ អាគារិកា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អាគារមុនយោ ។ កតមេ អនាគារមុនយោ ។ យេ តេ បព្វជិតា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អនាគារមុនយោ ។ សត្ត សេក្ខា សេក្ខមុនយោ ។ អរហន្តោ អសេក្ខមុនយោ ។ បច្ចេកពុទ្ធា បច្ចេកមុនយោ ។ មុនិមុនយោ វុច្ចន្តិ តថាគតា អរហន្តោ សម្មាសម្ពុទ្ធា ។

---

១ ម. ធម្មមុនិនោ អាគារមុនិនោ អនាគារមុនិនោ សេខមុនិនោ អសេខមុនិនោ បច្ចេកមុនិនោ មុនិមុនិនោតិ ។

សញ្ញាវេទយិតនិរោធសមាបត្តិ ដែលរំលត់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យៈ ។ នេះ ឈ្មោះថា មនោមោនេយ្យៈ ។

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវកាយមុនិ វាចាមុនិ
មនោមុនិ អនាសវមុនិ អ្នកបរិបូណ៌ដោយមោនេយ្យធម៌
ថាជាអ្នកលះបង់បាបទាំងអស់ ។ អ្នកប្រាជ្ញទាំងឡាយ
បានពោលនូវកាយមុនិ វាចាមុនិ មនោមុនិ អនាសវ-
មុនិ អ្នកបរិបូណ៌ ដោយមោនេយ្យធម៌ ថាជាអ្នកលាង
ជម្រះបាបហើយ ។

មុនិដែលប្រកបដោយមោនេយ្យធម៌ នេះមាន ៦ គឺអាគារមុនិ ១ អនាគារមុនិ ១ សេក្ខមុនិ ១ អសេក្ខមុនិ ១ បច្ចេកមុនិ ១ មុនិមុនិ ១ ។ ពួកអាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកនៅគ្រប់គ្រងផ្ទះ ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អាគារមុនិ ។ ពួកអនាគារមុនិ តើដូចម្តេច ។ បុគ្គលទាំងឡាយណា ជាអ្នកបួស ឃើញបទគឺព្រះនិព្វាន ដឹងច្បាស់សាសនា បុគ្គលទាំងឡាយនេះ ឈ្មោះថា អនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះថា សេក្ខមុនិ ។ ព្រះអរហន្តទាំងឡាយ ឈ្មោះថា អសេក្ខមុនិ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនិ ។ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ លោកហៅថា មុនិមុនិ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ
បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេហិ បូជិតោ
យោ សោ សង្គជាលមតិច្ច សោ មុនិ ។

លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។ បេ ។ អយំ តណ្ហាលេបោ ។ បេ ។ អយំ ទិដ្ឋិលេបោ ។ មុនិ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា បរិគ្គហេសុ ន លិម្បតិ ន សំលិម្បតិ ន ឧបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ បរិគ្គហេសុ មុនិ នោបលិត្តោ ។

គុហដ្ឋកសុត្តនិទ្ទេស ទី ២

បុគ្គលមានសភាពជាអ្នកល្ងង់ខ្លៅ មិនចេះដឹង មិនមែនឈ្មោះថា មុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ ហើយវៀរចាកបាបទាំងឡាយ ដូចជាបុគ្គលអ្នកកាន់ជញ្ជីង បុគ្គលនោះ ឈ្មោះថា មុនិ ដោយហេតុនោះ បុគ្គលណាដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះឈ្មោះថា មុនិ បុគ្គលដែលលោកហៅថា មុនិ ដោយហេតុនោះៗ

បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង ពួកសប្បុ-
រសផង ខាងក្នុងផង ខាងក្រៅផង ក្នុងលោកទាំងអស់
ជាបុគ្គលដែលទេវតានិងមនុស្ស បូជាហើយ បានកន្លង
បណ្តាញគឺគ្រឿងជំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។

ពាក្យថា ការប្រឡាក់ បានដល់ការប្រឡាក់ ២ គឺ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះ ឈ្មោះថា ការប្រឡាក់គឺតណ្ហា ។បេ។ នេះ ឈ្មោះថា ការប្រឡាក់គឺទិដ្ឋិ ។ មុនិលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ មិនជាប់ មិនចូលទៅប្រឡាក់ ក្នុងសេចក្តីហួងហែងទាំងឡាយ គឺជាអ្នកមិនប្រឡាក់ មិនជាប់ មិនចូលទៅប្រឡាក់ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ សម្រេចដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ មិនប្រឡាក់ក្នុងសេចក្តីហួងហែងទាំងឡាយ ។

(៦៨) អព្វូឡ្ហសល្លោ ចរមប្បមត្តោតិ សល្លន្តិ សត្តសល្លានិ រាគសល្លំ ទោសសល្លំ មោហសល្លំ មានសល្លំ ទិដ្ឋិសល្លំ សោកសល្លំ កថំកថាសល្លំ ។ យស្សេតានិ សល្លានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អព្វូឡ្ហសល្លោ អព្វូហិតសល្លោ ឧទ្ធដសល្លោ សមុទ្ធដសល្លោ ឧប្បាដិតសល្លោ សមុប្បាដិតសល្លោ ចត្តសល្លោ វន្តសល្លោ មុត្តសល្លោ បហីនសល្លោ បដិនិស្សដ្ឋសល្លោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ អព្វូឡ្ហសល្លោ ។ ចរន្តិ ចរន្តោ វិហរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោ ។ អប្បមត្តោតិ សក្កច្ចការី សាតច្ចការី អដ្ឋិតការី អនោលីនវុត្តិកោ អនិក្ខិត្តច្ឆន្ទោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។

(២៨) អធិប្បាយពាក្យថា មានព្រួញដកហើយ ប្រព្រឹត្តមិនប្រមាទ ត្រង់ពាក្យថា ព្រួញ បានដល់ព្រួញ ៧ គឺ ព្រួញគឺរាគៈ ព្រួញគឺទោសៈ ព្រួញគឺមោហៈ ព្រួញគឺមានះ ព្រួញគឺទិដ្ឋិ ព្រួញគឺសោក ព្រួញគឺសេចក្តីសង្ស័យ ។ ព្រួញទាំងឡាយនេះ បុគ្គលណាបានលះបង់ហើយ បានផ្តាច់ផ្តិលហើយ បានរម្ងាប់ហើយ បានគ្រប់សង្កត់ហើយ មិនគួរឲ្យកើតបាន បានដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមានព្រួញដកហើយ មានព្រួញកើចឡើងហើយ មានព្រួញគាស់ឡើងហើយ មានព្រួញរំលើងឡើងហើយ មានព្រួញហូតឡើងហើយ មានព្រួញហូតឡើងព្រមហើយ មានព្រួញលះចេញហើយ មានព្រួញខ្ជាក់ចោលហើយ មានព្រួញរួចស្រឡះហើយ មានព្រួញលះបង់ហើយ មានព្រួញលោសចោលហើយ មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់ ទទួលសុខ សម្រេចនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ទ្រង់ត្រាស់ថា មានព្រួញដកឡើងហើយ ។ ពាក្យថា ប្រព្រឹត្ត គឺចរទៅ នៅ ដើរទៅ រក្សា ត្រាច់ទៅ ញុំាងឥរិយាបថឲ្យត្រាច់ទៅ ។ ពាក្យថា មិនប្រមាទ គឺធ្វើគោរព ធ្វើរឿយៗ ធ្វើមិនឈប់ ប្រព្រឹត្តមិនធូរថយ មិនទម្លាក់ចោលនូវឆន្ទៈ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

កថាហំ អបរិបូរំ វា សីលក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា សីលក្ខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គណ្ហេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិសម្បជញ្ញំ អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុ ។ កថាហំ អបរិបូរំ វា សមាធិក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា សមាធិក្ខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គណ្ហេយ្យន្តិ ។ បេ ។ កុសលេសុ ធម្មេសុ ។ កថាហំ អបរិបូរំ វា បញ្ញាក្ខន្ធំ វិមុត្តិក្ខន្ធំ វិមុត្តិញាណទស្សនក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា វិមុត្តិញាណទស្សនក្ខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គណ្ហេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិសម្បជញ្ញំ អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុ ។

សេចក្តីពេញចិត្ត ការព្យាយាម ការខំស្វាហាប់ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកំដៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននៃការប្រកបរឿយ ៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះ ថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះសីលក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ដូច្នេះ នេះ ឈ្មោះថា ការមិនប្រហែស ក្នុងកុសលធម៌ទាំងឡាយ ។ ថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបំពេញសមាធិក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះសមាធិក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ។ បេ ។ ក្នុងកុសលធម៌ទាំងឡាយ ។ សេចក្តីពេញចិត្ត ការព្យាយាម ការខំស្វាហាប់ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកំដៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននៃការប្រកបរឿយ ៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះ ថា ធ្វើម្តេចហ្ន៎ អាត្មាអញ គប្បីបំពេញបញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ ឬនឹងអនុគ្រោះវិមុត្តិញាណទស្សនក្ខន្ធ ដែលពេញលេញស្រាប់ហើយ ដោយបញ្ញា ក្នុងកិច្ចនោះ ៗ ដូច្នេះ នេះ ឈ្មោះថា ការមិនប្រហែស ក្នុងកុសលធម៌ទាំងឡាយ ។

នាមាហំ អបរិញ្ញាតំ វា ទុក្ខំ បរិជានេយ្យំ អប្បហីនេ វា កិលេសេ បជហេយ្យំ អភាវិតំ វា មគ្គំ ភាវេយ្យំ អសច្ឆិកតំ វា និរោធំ សច្ឆិករេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិសម្បជញ្ញញ្ច អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុ អព្ពូឡ្ហសល្លោ ចរមប្បមត្តោ ។

(៦៩) នាសីសតី លោកមិមំ បរញ្ចាតិ ឥមំ លោកំ នាសីសតិ សកត្តភាវំ បរលោកំ នាសីសតិ បរត្តភាវំ ។ ឥមំ លោកំ នាសីសតិ សករូបវេទនាសញ្ញាសង្ខារវិញ្ញាណំ បរលោកំ នាសីសតិ បររូបវេទនាសញ្ញាសង្ខារវិញ្ញាណំ ។ ឥមំ លោកំ នាសីសតិ ឆ អជ្ឈត្តិកានិ អាយតនានិ បរលោកំ នាសីសតិ ឆ ពាហិរានិ អាយតនានិ ។ ឥមំ លោកំ នាសីសតិ មនុស្សលោកំ បរលោកំ នាសីសតិ ទេវលោកំ ។ ឥមំ លោកំ នាសីសតិ កាមធាតុំ បរលោកំ នាសីសតិ រូបធាតុំ អរូបធាតុំ ។

សេចក្តីពេញចិត្ត ការព្យាយាម ការឧស្សាហ៍ សេចក្តីប្រឹងប្រែង ការមិនប្រព្រឹត្តិត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមដុតកំដៅកិលេស ការព្យាយាមដ៏ឧត្តម អធិដ្ឋាននឹងការប្រកបរឿយៗ ណា ក្នុងកុសលធម៌ទាំងឡាយនោះថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងកំណត់ដឹងនូវទុក្ខ ដែលមិនបានកំណត់ដឹងហើយ នឹងលះបង់កិលេសទាំងឡាយ ដែលមិនទាន់លះ នឹងចំរើនមគ្គដែលមិនទាន់ចំរើន ឬនឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលមិនទាន់ធ្វើឲ្យជាក់ ដូច្នេះ នេះឈ្មោះថា ការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) មានព្រួញដកហើយ ប្រព្រឹត្តមិនប្រហែស ។

(៦៩) ពាក្យថា មិនប្រាថ្នានូវលោកនេះ នឹងលោកដទៃ សេចក្តីថា មិនប្រាថ្នាលោកនេះ គឺអត្តភាពរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺអត្តភាពដទៃ ។ មិនប្រាថ្នាលោកនេះគឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណរបស់ខ្លួន មិនប្រាថ្នាលោកដទៃ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដទៃ ។ មិនប្រាថ្នាលោកនេះ គឺអាយតនៈខាងក្នុង ៦ មិនប្រាថ្នាលោកដទៃ គឺអាយតនៈខាងក្រៅ ៦ ។ មិនប្រាថ្នាលោកនេះ គឺមនុស្សលោក មិនប្រាថ្នាលោកដទៃ គឺទេវលោក ។ មិនប្រាថ្នាលោកនេះ គឺកាមធាតុ មិនប្រាថ្នាលោកដទៃ គឺរូបធាតុនឹងអរូបធាតុ ។

## ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ឥមំ លោកំ នាសីសតិ កាមធាតុំ រូបធាតុំ បរលោកំ នាសីសតិ អរូបធាតុំ ។ បុន គតឹ វា ឧបបត្តឹ វា បដិសន្ធឹ វា ភវំ វា សំសារំ វា វដ្ដំ វា នាសីសតិ ន ឥច្ឆតិ ន សាទិយតិ ន បត្ថេតិ ន បិហេតិ នាភិជប្បតីតិ នាសីសតិ លោកមិមំ បរញ្ច ។

តេនាហ ភគវា

សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ
បរិគ្គហេសុ មុនិ នោបលិត្តោ
អព្ពូឡ្ហសល្លោ ចរមប្បមត្តោ
នាសីសតី លោកមិមំ បរញ្ចាតិ ។

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

## គុហដ្ឋកសុត្តនិទ្ទេស ទី ២

មិនប្រាថ្នាលោកនេះ គឺកាមធាតុ រូបធាតុ មិនប្រាថ្នាលោកដទៃ គឺអរូបធាតុ ។ មិនប្រាថ្នា មិនត្រូវការ មិនត្រេកអរ មិនប៉ុនប៉ង មិនស្រឡាញ់ មិនជាប់ចិត្ត នូវគតិ ឧបបត្តិ បដិសន្ធិ ភព សំសារ ឬវដ្ដៈ ទៀតទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រាថ្នានូវលោកនេះ និងលោកដទៃ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មុនិកំណត់ដឹងសញ្ញាហើយ គប្បីឆ្លងឱឃៈបាន ជាអ្នកមិន
ប្រឡាក់ ក្នុងសេចក្ដីហួងហែងទាំងឡាយ ជាអ្នកមានព្រួញ
ដកឡើងហើយ ប្រព្រឹត្តមិនប្រមាទ មិនប្រាថ្នានូវលោក
នេះនិងលោកដទៃ ។

ចប់ គុហដ្ឋកសុត្តនិទ្ទេស ទី ២ ។

# តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

(៧០) វទន្តិ វេ ទុដ្ឋមនាបិ (១) ឯកេ

អញ្ញោបិ (២) វេ សច្ចមនា វទន្តិ

វាទញ្ច ជាតំ មុនិ នោ ឧបេតិ

តស្មា មុនី នត្ថិ ខិលោ កុហិញ្ចិ ។

(៧១) វទន្តិ វេ ទុដ្ឋមនាបិ ឯកេតិ តេ តិត្ថិយា ទុដ្ឋមនា បទុដ្ឋមនា វិរុទ្ធមនា បដិវិរុទ្ធមនា អាហតមនា បច្ចាហតមនា អាឃាដិតមនា បច្ចាឃាដិតមនា វទន្តិ ឧបវទន្តិ ភគវន្តញ្ច ភិក្ខុសង្ឃញ្ច អភូតេនាតិ វទន្តិ វេ ទុដ្ឋមនាបិ ឯកេ ។

(៧២) អញ្ញោបិ វេ សច្ចមនា វទន្តីតិ យេ តេសំ តិត្ថិយានំ សទ្ទហន្តា ឱកប្បេន្តា អធិមុច្ចន្តា សច្ចមនា សច្ចសញ្ញិនោ ភូតមនា ភូតសញ្ញិនោ តថមនា

---

១ ម. ទុមនាបិ ។ ២ ម. អថោបិ ។

# ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

[៧០] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) តិរ្ថិយពួកខ្លះ មានចិត្តខឹង ហើយដេរ ពួកជនឯទៀត មានចិត្តជឿថាមែន រមែងដេរតាម តែព្រះពុទ្ធជាមុនិ មិនអើពើនូវវាទៈ ដែលកើតហើយ ព្រោះហេតុនោះ បង្គោលគឺកិលេស របស់ព្រះពុទ្ធជាមុនី មិនមានក្នុងទីណាទេ ។

[៧១] ពាក្យថា តិរ្ថិយពួកខ្លះ មានចិត្តខឹងហើយដេរ គឺពួកតិរ្ថិយទាំងនោះ មានចិត្តខឹង មានចិត្តប្រទូស្ត មានចិត្តអាក់អន់ មានចិត្តអាក់អន់តប មានចិត្តបៀតបៀន មានចិត្តបៀតបៀនតប មានចិត្តគុំគួន មានចិត្តគុំគួនតប ហើយដេរប្រទេច នូវព្រះមានព្រះភាគនឹងព្រះភិក្ខុសង្ឃ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) តិរ្ថិយពួកខ្លះ មានចិត្តខឹង ហើយដេរ ។

[៧២] ពាក្យថា ពួកជនឯទៀត មានចិត្តជឿថាមែន រមែងដេរតាម គឺពួកជនណា ជឿ ជឿស៊ប់ ចុះចិត្តស៊ប់ តាមពាក្យ នៃតិរ្ថិយទាំងនោះ មានចិត្តជឿថាមែន មានសេចក្តីសំគាល់ថាមែន មានចិត្តជឿប្រាកដ មានសេចក្តីសំគាល់ថា ប្រាកដ មានចិត្តថាទៀងទាត់

តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

តថសញ្ញិនោ យាថាវមនា យាថាវសញ្ញិនោ អវិបរី-តមនា អវិបរីតសញ្ញិនោ វទន្តិ ឧបវទន្តិ ភតវន្តញ្ច កិច្ចសព្វញ្ច អភូតេនាតិ អញ្ញេបិ វេ សច្ចមនា វទន្តិ ។

(៧៣) វាទញ្ច ជាតំ មុនិ នោ ឧបេតីតិ វាទោ ជាតោ ហោតិ សញ្ជាតោ និព្វត្តោ អភិនិព្វត្តោ បាតុភូតោ បរតោ ឃោសោ អក្កោសោ ឧបវាទោ ភតវតោ ច កិច្ចសព្វស្ស ច អភូតេនាតិ វាទញ្ច ជាតំ ។ មុនិ នោ ឧបេតីតិ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតោ មុនិ មោនប្បត្តោ ។បេ។ សង្គជាលមតិច្ច សោ មុនីតិ ។ យោ វាទំ ឧបេតិ សោ ទ្វីហិ ការណេហិ វាទំ ឧបេតិ ។ ការកោ ការកតាយ វាទំ ឧបេតិ ។

មានសេចក្ដីសំគាល់ថាទៀនទាត់ មានចិត្តជាពិត មានសេចក្ដីសំគាល់ថាពិត មានចិត្តថាមិនប្រែប្រួល មានសេចក្ដីសំគាល់ថាមិនប្រែប្រួល ហើយដេរប្រទេច នូវព្រះមានព្រះភាគ នឹងព្រះភិក្ខុសង្ឃ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនឯទៀត មានចិត្តជឿថាមែន មែនដេរតាម ។

(៧៣) ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទៈ ដែលកើតឡើង គឺវាទៈនោះកើត កើតព្រម កើតហើយ កើតបំពោះហើយ កើតប្រាកដហើយ ជាវាទៈលាន់គន់រំពង់អំពីសំណាក់បុគ្គលដទៃ ជាពាក្យដេរប្រទេច នូវព្រះមានព្រះភាគនឹងព្រះភិក្ខុសង្ឃ ដោយហេតុមិនពិត ហេតុនោះ (ទ្រង់ត្រាស់ថា) នូវវាទៈដែលកើតហើយ ។ ពាក្យថា ព្រះពុទ្ធជាមុនិ រមែងមិនអើពើ សេចក្ដីថា ញាណ លោកហៅថា មោនៈ បានដល់ប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្ដីមិនវង្វេង ការពិចារណាធម៌ សេចក្ដីឃើញត្រូវ ព្រះពុទ្ធជាមុនិ ប្រកបដោយញាណនោះ ឈ្មោះថាទ្រង់ដល់នូវមោនៈ ។បេ។ ព្រះមានព្រះភាគនោះកន្លងនូវបណ្ដាញគឺសេចក្ដីជាប់ ទើបឈ្មោះថា មុនិ ។ បុគ្គលណាអើពើនូវវាទៈ បុគ្គលនោះ រមែងអើពើនូវវាទៈ ដោយហេតុ ២ យ៉ាង ។ គឺបុគ្គលអ្នកបង្កទោស រមែងអើពើនូវវាទៈ ព្រោះភាពនៃខ្លួនជាអ្នកបង្កទោស ១ ។

អថវា វុច្ចមានោ ឧបវទិយមានោ កុប្បតិ ព្យាបជ្ជតិ បតិដ្ឋិយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អការកោម្ហីតិ ។ យោ វាទំ ឧបេតិ សោ ឥមេហិ ទ្វីហិ ការណេហិ វាទំ ឧបេតិ ។ មុនិ ទ្វីហិ ការណេហិ វាទំ ន ឧបេតិ ។ អការកោ(១) អការកតាយ វាទំ ន ឧបេតិ ។ អថវា វុច្ចមានោ ឧបវទិយមានោ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិដ្ឋិយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អការកោម្ហីតិ ។ មុនិ ឥមេហិ ទ្វីហិ ការណេហិ វាទំ ន ឧបេតិ ន ឧបគច្ឆតិ ន គណ្ហាតិ ន បរាមសតិ ន អភិនិវិសតីតិ វាទញ្ច ជាតំ មុនិ នោ ឧបេតិ ។

(៧៤) តស្មា មុនី នត្ថិ ខិលោ កុហិញ្ចីតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា មុនិនោ អាហតចិត្តតា ខិលជាតតាបិ នត្ថិ ។ បញ្ចបិ ចេតោខិលា នត្ថិ តយោបិ ខិលា នត្ថិ រាគខិលោ

---

១ ម. ឯត្ថន្តរេ មុនីតិ ទិស្សតិ ។

មួយទៀត បុគ្គលត្រូវគេស្តី គេតិះដៀល រមែងខឹង ក្តៅក្រហាយ តបត ធ្វើសេចក្តីក្រោធផង ទោសៈផង សេចក្តីអាក់អន់ផង ឲ្យប្រាកដជា អញជាអ្នកមិនបង្កទោស ១ ។ បុគ្គលណារមែងអើពើនូវវាទៈ បុគ្គលនោះរមែងអើពើនូវវាទៈ ដោយហេតុ ២ នេះឯង ។ ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទៈ ដោយហេតុ ២ យ៉ាង ។ គឺព្រះពុទ្ធជាអ្នកមិនបង្កទោស រមែងមិនអើពើនូវវាទៈ ព្រោះភាពនៃព្រះអង្គ ជាអ្នកមិនបង្កទោស ១ ។ មួយទៀត ព្រះពុទ្ធ កាលគេស្តី គេតិះដៀល រមែងមិនខឹង មិនក្តៅក្រហាយ មិនតបត ទាំងមិនធ្វើសេចក្តីក្រោធផង ទោសៈផង សេចក្តីអាក់អន់ផង ឲ្យប្រាកដជា អញជាអ្នកមិនបង្កទោស ១ ។ ព្រះពុទ្ធជាមុនិ រមែងមិនអើពើ មិនរវល់ មិនកាន់យក មិនប៉ះពាល់ មិនប្រកាន់ទុកនូវវាទៈ ដោយហេតុ ២ នេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះពុទ្ធជាមុនិ រមែងមិនអើពើនូវវាទៈ ដែលកើតហើយ ។

[៧៤] អធិប្បាយពាក្យថា ព្រោះហេតុនោះ បង្គោលគឺកិលេសរបស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ព្រះពុទ្ធជាមុនិ មិនមានព្រះហឫទ័យត្រូវកិលេសបៀតបៀន ឬបង្គោលគឺកិលេសកើតហើយទេ ។ ចេតោខិលៈ (បង្គោលគឺកិលេសរបស់ចិត្ត) ៥ យ៉ាង ក៏មិនមាន ខិលៈ ៣ យ៉ាង គឺរាគខិលៈ

ទោសខីលោ មោហខីលោ នត្ថិ ន សន្តិ ន សំវិជ្ជតិ នុបលព្ភតិ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ កុហិញ្ចីតិ ។ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ តស្ស មុនី នត្ថិ ខិលោ កុហិញ្ចិ ។ តេនាហ ភគវា

វទន្តិ វេ ទុដ្ឋមនាបិ ឯកេ
អញ្ញេបិ វេ សច្ចមនា វទន្តិ
វាទញ្ច ជាតំ មុនិ នោ ឧបេតិ
តស្មា មុនី នត្ថិ ខិលោ កុហិញ្ចីតិ ។

(៧៥) សកញ្ហិ ទិដ្ឋឹ កថមច្ចយេយ្យ
ឆន្ទានុនីតោ រុចិយា និវិដ្ឋោ
សយំ សមត្តានិ បកុព្វមានោ
យថា ហិ ជានេយ្យ តថា វទេយ្យ ។

(៧៦) សកញ្ហិ ទិដ្ឋឹ កថមច្ចយេយ្យាតិ យេ តេ

ទោសខិលៈ មោហខិលៈ មិនមាន អង្គមាន ផុតមាន លែងកើតមាន គឺព្រះពុទ្ធជាមុនិ បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ មិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងកន្លែងណាមួយ ក្នុងជម្រនណាមួយ ក្នុងទីខ្លះ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ហេតុដូច្នោះ (ទ្រង់ត្រាស់ថា) ហេតុនោះ បង្គោលគឺកិលេស របស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

តួយ៉ាងពួកខ្លះ មានចិត្តខឹង ហើយដេរ ពួកជនឯទៀត
មានចិត្តជឿថាមែន រមែងដេរតាម តែព្រះពុទ្ធជាមុនិ មិន
អើពើ នូវវាទៈដែលកើតហើយ ព្រោះហេតុនោះ បង្គោល
គឺកិលេស របស់ព្រះពុទ្ធជាមុនិ មិនមានក្នុងទីណាទេ ។

(៧៥) បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន
បុគ្គល ដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ ក្នុង
សេចក្តីពេញចិត្ត រមែងធ្វើនូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់
ដោយខ្លួនឯង ដឹងយ៉ាងណា គំពោលយ៉ាងនោះ ។

(៧៦) ពាក្យថា បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្តេចបាន

តិត្ថិយា សុន្ទរឹ បរិព្វាជិកំ ហន្ត្វា សមណានំ សក្យបុត្តិយានំ អវណ្ណំ បកាសយិត្វា ឯវំ ឯតំ លាភំ យសំ សក្ការសម្មានំ បច្ចាហរិស្សាមាតិ ឯវំទិដ្ឋិកា ឯវំខន្តិកា ឯវំរុចិកា ឯវំលទ្ធិកា ឯវំអជ្ឈាសយា ឯវំអធិប្បាយា តេ នាសក្ខឹសុ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បាយំ អតិក្កមិតុំ ។ អថខោ ស្វេវ អយសោ តេ បច្ចាគតោតិ ឯវម្បិ សកំ ទិដ្ឋឹ កថមច្ចយេយ្យ ។ អថវា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ យោ សោ ឯវំវាទោ សោ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បាយំ កថំ អច្ចយេយ្យ អតិក្កមេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យ ។ តំ កិស្ស ហេតុ ។ តស្ស សា ទិដ្ឋិ តថា សមត្តា សមាទិន្នា គហិតា បរាមដ្ឋា

អធិប្បាយថា ពួកតិរ្ថិយណា មានទិដ្ឋិយ៉ាងនេះ មានសេចក្តីគួរយ៉ាងនេះ មានសេចក្តីពេញចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានសេចក្តីប្រកាន់យ៉ាងនេះថា ពួកយើងនឹងសម្លាប់នាងសុន្ទរីបរិព្វា–ជិកា ហើយប្រកាសទោស របស់ពួកសមណសក្យបុត្តិយ៍ កាលបើធ្វើយ៉ាងនេះ ពួកយើងនឹងប្រមូលយកនូវលាភ យស សក្ការៈ និងសេចក្តីរាប់អាន នុះបាន ទើបពួកតិរ្ថិយទាំងនោះ មិនអាចនឹងកន្លងនូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប្រកាន់របស់ខ្លួនបានឡើយ ។ តាមពិតការមិនមានយសនោះឯង ក៏ត្រឡប់មកដល់ពួកតិរ្ថិយនោះវិញទេ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលណាមានវាទៈយ៉ាងនេះថា លោក គឺអត្តភាព ទៀងទាត់ ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ បុគ្គលនោះ គប្បីកន្លង ឈានកន្លង កន្លងផុត ប្រព្រឹត្តកន្លង នូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប្រកាន់របស់ខ្លួន ដោយប្រការដូចម្តេចបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ (ព្រោះថា) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យក ស្ទាបអង្អែល

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

អភិនិវិដ្ឋា អជ្ឈោសិតា អធិមុត្តាតិ ឯវម្បិ សកញ្ហិ ទិដ្ឋឹ កថមច្ចយេយ្យ ។ សស្សតោ លោកោ អសស្សតោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ យោ សោ ឯវំវាទោ សោ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បាយំ កថំ អច្ចយេយ្យ អតិក្កមេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យ ។ តំ កិស្ស ហេតុ ។ តស្ស សា ទិដ្ឋិ តថា សមត្តា សមាទិន្នា គហិតា បរាមដ្ឋា អភិនិវិដ្ឋា អជ្ឈោសិតា អធិមុត្តាតិ ឯវម្បិ សកញ្ហិ ទិដ្ឋឹ កថមច្ចយេយ្យ ។

ឋិតនៅស៊ប់ ជ្រុលជ្រប់ ចុះចិត្តស៊ប់ហើយ ដោយប្រការដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្ទន់នូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ៗ បុគ្គលណាមានវាទៈយ៉ាងនេះថា លោកទៀងទាត លោកមិនទៀងទាត់ លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះ សរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វស្លាប់ទៅ រមែងកើតទៀត សត្វស្លាប់ទៅ រមែងមិនកើតទៀត សត្វស្លាប់ទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការឃើញនេះឯង ជាការពិត ការឃើញដទៃជាមោឃៈ បុគ្គលនោះ គប្បីកន្ទន់ ឈានកន្ទន់ កន្ទន់ផុត ប្រព្រឹត្តកន្ទន់នូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ដោយប្រការដូចម្តេចបាន ៗ ដំណើរនោះ តើព្រោះហេតុដូចម្តេច ៗ (ព្រោះថា) ទិដ្ឋិនោះ ដែលបុគ្គលនោះធ្វើឲ្យពេញលេញ សមាទាន កាន់យក ស្ទាបអង្អែល ឋិតនៅស៊ប់ ជ្រុលជ្រប់ ចុះចិត្តស៊ប់ហើយដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីកន្ទន់នូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្តេចបាន យ៉ាងនេះខ្លះ ៗ

(៧៧) ឆន្ទានុនីតោ រុចិយា និវិដ្ឋោតិ ឆន្ទានុនីតោតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា យាយតិ និយ្យតិ វុយ្ហតិ សំហរីយតិ ។ យថា ហត្ថិយានេន វា រថយានេន វា អស្សយានេន វា គោយានេន វា អជយានេន វា មេណ្ឌកយានេន វា ឱដ្ឋយានេន វា ខរយានេន វា យាយតិ និយ្យតិ វុយ្ហតិ សំហរីយតិ ឯវមេវ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា យាយតិ និយ្យតិ វុយ្ហតិ សំហរីយតីតិ ឆន្ទានុនីតោ ។ រុចិយា និវិដ្ឋោតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា និវិដ្ឋោ បតិដ្ឋិតោ អល្លីនោ ឧបគតោ អជ្ឈោសិតោ អធិមុត្តោតិ ឆន្ទានុនីតោ រុចិយា និវិដ្ឋោ ។

(៧៨) សយំ សមត្តានិ បកុព្វមានោតិ សយំ សមត្តំ[១] ករោតិ បរិបុណ្ណំ ករោតិ អនោមំ ករោតិ

---

១ ម. សត្តេ ។

(៧៧) អធិប្បាយពាក្យថា បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ ក្នុងសេចក្តីពេញចិត្ត ត្រង់ពាក្យថា បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ គឺបុគ្គលដែលត្រូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន នាំទៅ នាំចេញទៅ បន្សាត់ទៅ ប្រមូលទៅ ៗ បុគ្គល ដែលហត្ថិយាន ឬរថយាន អស្សយាន ឬគោយាន អជយាន ឬមេណ្ឌកយាន ឧដ្ឋយាន ឬខរយាន (យានដែលទឹមដោយលា) នាំទៅ នាំចេញទៅ បំផាយទៅ ប្រមូលទៅ យ៉ាងណាមិញ បុគ្គលដែលត្រូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីពេញចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន នាំទៅ នាំចេញទៅ បន្សាត់ទៅ ប្រមូលទៅ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ៗ ពាក្យថា ឋិតនៅស៊ប់ ក្នុងសេចក្តីពេញចិត្ត គឺ ឋិតនៅស៊ប់ តាំងនៅស៊ប់ ជាប់ស្អិត ប្រកាន់ស៊ប់ ជ្រុលជ្រប់ ចុះស៊ប់ ក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដែលត្រូវសេចក្តីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ ក្នុងសេចក្តីពេញចិត្ត ៗ

(៧៨) ពាក្យថា រមែងធ្វើនូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់ដោយខ្លួនឯង គឺរមែងធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត

អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ អយំ សត្ថា សព្វញ្ញូតិ សយំ សមត្តំ ករោតិ បរិបុណ្ណំ ករោតិ អនោមំ ករោតិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ អយំ ធម្មោ ស្វាក្ខាតោ អយំ គណោ សុប្បដិបន្នោ អយំ ទិដ្ឋិ ភទ្ទិកា អយំ បដិបទា សុប្បញ្ញត្តា អយំ មគ្គោ និយ្យានិកោតិ សយំ សមត្តំ ករោតិ បរិបុណ្ណំ ករោតិ អនោមំ ករោតិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ ជនេតិ សញ្ជនេតិ និព្វត្តេតិ អភិនិព្វត្តេតិ សយំ សមត្តានិ បកុព្វមានោ ។

(៧៩) យថា ហិ ជានេយ្យ តថា វទេយ្យាតិ យថា ជានេយ្យ តថា វទេយ្យ កថេយ្យ ភណេយ្យ ទីបេយ្យ វោហរេយ្យ ។ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ យថា ជានេយ្យ តថា វទេយ្យ កថេយ្យ ភណេយ្យ ទីបេយ្យ វោហរេយ្យ ។ អសស្សតោ លោកោ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ

ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លា ដោយខ្លួនឯង បុគ្គលរមែងធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លាដោយខ្លួនឯងថា សាស្តានេះ ជាសព្វញ្ញូ ធ្វើនូវទិដ្ឋិឲ្យគ្រប់គ្រាន់ ធ្វើឲ្យបរិបូណ៌ ធ្វើមិនឲ្យខ្វះខាត ធ្វើឲ្យខ្ពស់ ឲ្យប្រសើរ ឲ្យវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យថ្លៃថ្លា រមែងញុំាងទិដ្ឋិឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតប្រាកដ ដោយខ្លួនឯងថា នេះជាធម៌ ដែលខ្លួនសំដែងល្អហើយ នេះជាគណៈប្រតិបត្តិល្អហើយ នេះជាទិដ្ឋិដ៏ប្រសើរ នេះជាបដិបទាដែលបញ្ញត្តល្អហើយ នេះជាមគ្គ ជាឧបាយស្រោចស្រង់សត្វ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលធ្វើនូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់ដោយខ្លួនឯង ។

(៧៩) ពាក្យថា បុគ្គលដឹងយ៉ាងណា តែងពោលយ៉ាងនោះ គឺបុគ្គលដឹងយ៉ាងណា តែងពោល សំដែង បរិយាយ បំភ្លឺ និយាយបញ្ចេញយ៉ាងនោះ ។ បុគ្គលដឹងយ៉ាងណាថា លោក ទៀងទាត់ ការឃើញនេះឯង ជាការពិត ការឃើញដទៃ ជាមោឃៈ ដូច្នេះ គប្បីពោល សំដែង និយាយ បំភ្លឺ និយាយបញ្ចេញយ៉ាងនោះ ។ បុគ្គលដឹងយ៉ាងណាថា លោកមិនទៀងទាត់ ។ បេ ។ សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនមែនកើតទៀត ក៏មិនមែន ការឃើញនេះឯង ជាការពិត

ទោយមញ្ញតិ យថា ជានេយ្យ តថា វទេយ្យ កថេ-យ្យ ភណេយ្យ ទីបេយ្យ វោហរេយ្យាតិ យថា ហិ ជានេយ្យ តថា វទេយ្យ ។ តេនាហ ភគវា

សក្ខិ ទិដ្ឋី កថមច្ចយេយ្យ
ឆន្ទានុនីតោ រុចិយា និវិដ្ឋោ
សយំ សមត្តានិ បកុព្វមានោ
យថា ហិ ជានេយ្យ តថា វទេយ្យាតិ ។

(៨០) យោ អត្តនោ សីលវតានិ ជន្តុ
អនានុបុដ្ឋោ ច បរេស បាវ
អនរិយធម្ម កុសលា តមាហុ
យោ អាតុមានំ សយមេវ បាវ ។

(៨១) យោ អត្តនោ សីលវតានិ ជន្តូតិ យោតិ យោ យាទិសោ យថាយុត្តោ យថាវិហិតោ យថា-ប្បការោ យំឋានប្បត្តោ យំធម្មសមន្នាគតោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វា គហដ្ឋោ វា បព្វជិតោ វា ទេវោ វា មនុស្សោ វា ។ សីលវតានីតិ អត្ថិ សីលញ្ចេវ វតញ្ច អត្ថិ វតំ ន សីលំ ។

ការឃើញដទៃ ជាមោឃៈ ដូច្នេះ គប្បីពោល សំដែង និយាយ បំភ្លឺ និយាយបញ្ចេញ យ៉ាងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដឹងយ៉ាងណា ពោលយ៉ាងនោះ ។ ហេតុនោះ ព្រះមានបុណ្យត្រាស់ថា

បុគ្គលគប្បីកន្លងនូវទិដ្ឋិរបស់ខ្លួន ដោយប្រការដូចម្ដេចបាន
បុគ្គលដែលត្រូវសេចក្ដីប្រាថ្នាដឹកនាំ ឋិតនៅស៊ប់ ក្នុង
សេចក្ដីពេញចិត្ត រមែងធ្វើនូវទិដ្ឋិទាំងឡាយ ឲ្យគ្រប់គ្រាន់
ដោយខ្លួនឯង ដឹងយ៉ាងណា ក៏ពោលយ៉ាងនោះ ។

(៨០) ជនណា ដែលគេមិនបានសាកសួរ នូវសីលនិងវត្តរបស់ខ្លួន
ហើយពោលអួតប្រាប់ពួកបុគ្គលដទៃ ជនអ្នកឈ្លាសទាំង
ឡាយ ពោលនូវជន ដែលពោលអួតខ្លួន ដោយខ្លួនឯង
នោះ ថាជាអ្នកមិនមានអរិយធម៌ ។

(៨១) អធិប្បាយពាក្យថា ជនណា (ដែលគេមិនបានសាកសួរ) នូវសីលនិងវត្ត របស់ខ្លួន ត្រង់ពាក្យថា ណា គឺ ជនណា បែបណា ប្រកបដោយប្រការណា តាំងនៅដោយប្រការណា មានប្រការយ៉ាងណា ដល់នូវឋានៈបែបណា ប្រកបដោយធម៌ណា ទោះជាក្សត្រ ឬព្រាហ្មណ៍ វេស្សៈ ឬសុទ្រៈ គ្រហស្ថ ឬបព្វជិត ទេវតា ឬមនុស្ស ។ ពាក្យថា សីលនិងវត្ត គឺសីលផង វត្តផងក៏មាន វត្តមិនមែនសីលក៏មាន ។

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

កតមំ សីលញ្ច វត្តញ្ច ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ យោ តត្ថ សំយមោ សំវរោ អវីតិក្កមោ ឥទំ សីលំ ។ យំ សមាទានំ តំ វត្តំ ។ សំវរដ្ឋេន សីលំ សមាទានដ្ឋេន វត្តំ ឥទំ វុច្ចតិ សីលញ្ច វត្តញ្ច ។

កតមំ វត្តំ ន សីលំ ។ អដ្ឋ ធុតង្គានិ អារញ្ញិកង្គំ បិណ្ឌបាតិកង្គំ បំសុកូលិកង្គំ តេចីវរិកង្គំ សបទានចារិកង្គំ ខលុបច្ឆាភត្តិកង្គំ នេសជ្ជិកង្គំ យថាសន្ថតិកង្គំ ឥទំ វុច្ចតិ វត្តំ ន សីលំ ។ វីរិយសមាទានម្បិ វុច្ចតិ វត្តំ ន សីលំ ។ កាមំ តចោ ច នហារុ ច អដ្ឋិ ច អវសុស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិសត្ថាមេន បុរិសពលេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។

## ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

សីលនិងវត្ត តើដូចម្ដេច ៗ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ ដែលមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ការសង្រួម ការរវាំង ការមិនប្រព្រឹត្តិកន្លង ណាក្នុងសិក្ខាបទទាំងឡាយនោះ នេះឈ្មោះថាសីល ៗ ការកាន់យកដោយប្រពៃណា នោះឈ្មោះថាវត្ត ៗ សីល ដោយអត្ថថា សង្រួម វត្ត ដោយអត្ថថា ការកាន់យកដោយប្រពៃ នេះលោកហៅថា សីលផង វត្តផង ៗ

វត្តមិនមែនសីល តើដូចម្ដេច ៗ ធុតង្គវត្ត ៨ គឺអារញ្ញិកង្គៈ បិណ្ឌបាតិកង្គៈ បំសុកូលិកង្គៈ តេចីវរិកង្គៈ សបទានចារិកង្គៈ ខលុបច្ឆាភត្តិកង្គៈ នេសជ្ជិកង្គៈ យថាសន្ថតិកង្គៈ នេះលោកហៅថា វត្តមិនមែនសីល ៗ សូម្បីការកាន់យកដោយប្រពៃ ដោយវីរិយៈ លោកហៅថា វត្ត មិនមែនសីលដែរ ៗ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា ស្បែកសរសៃនិងឆ្អឹងចូរសល់នៅចុះ ឯសាច់និងឈាមក្នុងសរីរៈ ចូររីងស្ងួតទៅក៏ដោយចុះ ហេតុណាដែលអញគួរដល់ ដោយសេចក្ដីសង្វាតនៃបុរស ដោយកម្លាំងនៃបុរស ដោយព្យាយាមនៃបុរស ដោយសេចក្ដីប្រឹងប្រែងនៃបុរស បើការមិនសម្រេចនូវហេតុនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមឡើយ ការកាន់យកដោយប្រពៃ ដោយវីរិយៈមានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ៗ

ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ យាវ មេ ន អនុបា-ទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។

នាសិស្សំ ន បិវិស្សាមិ វិហារតោ ន និក្ខមិំ
នបិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេតិ

ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។ ន តាវាហំ ឥមម្ហា អាសនា វុដ្ឋហិស្សាមិ ចង្កមា ឱរោហិស្សាមិ វិហារា និក្ខមិស្សាមិ អឌ្ឍយោគា និក្ខមិស្សាមិ បាសាទា និក្ខមិស្សាមិ ហម្មិយា និក្ខមិស្សាមិ គុហាយ និក្ខមិស្សាមិ លេណា និក្ខមិស្សាមិ កុដិយា និក្ខមិស្សាមិ កូដាគារា និក្ខ-មិស្សាមិ អដ្ដា និក្ខមិស្សាមិ មាឡា និក្ខមិស្សាមិ ឧទ្ទណ្ឌា និក្ខមិស្សាមិ ឧបដ្ឋានសាលាយ និក្ខមិស្សាមិ មណ្ឌបា និក្ខមិស្សាមិ រុក្ខមូលា និក្ខមិស្សាមិ យាវ

បុគ្គលផ្គូរផ្គងចិត្ត តម្កល់ចិត្តថា ចិត្តអាត្មាអញនឹងមិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញ នឹងមិនដោះភ្នែននេះចេញ ដរាបនោះ ការកាន់យកដោយប្រពៃ ដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា

កាលបើសរគឺតណ្ហា ដែលអាត្មាដកមិនទាន់បានទេ អាត្មា
នឹងមិនបរិភោគ នឹងមិនផឹក នឹងមិនចេញ អំពីលំនៅ
នឹងមិនទម្រេតកាយទេ

ការកាន់យកដោយប្រពៃ ដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា ចិត្តរបស់អាត្មាអញ មិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដរាបណា ដរាបនោះ អាត្មាអញនឹងមិនក្រោកអំពីអាសនៈ មិនចុះអំពីចង្ក្រម មិនចេញអំពីវិហារ មិនចេញអំពីអឌ្ឍយោគៈ មិនចេញអំពីប្រាសាទ មិនចេញអំពីផ្ទះមានដំបូល មិនចេញអំពីគុហា មិនចេញអំពីលេនដ្ឋាន មិនចេញអំពីកុដិ មិនចេញអំពីផ្ទះ មានកំពូល មិនចេញអំពីជម្រំ មិនចេញអំពីរោង មិនចេញអំពីលំនៅដំបូក មិនចេញអំពីឧបដ្ឋានសាលា មិនចេញអំពីមណ្ឌប មិនចេញអំពីគល់ឈើនេះទេ

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។ ឥមស្មិញ្ញេវ បុព្វណ្ហសមយំ អរិយធម្មំ អាហរិស្សាមិ សមាហរិស្សាមិ អធិគច្ឆិស្សាមិ ផុសយិស្សាមិ សច្ឆិករិស្សាមីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។ ឥមស្មិញ្ញេវ មជ្ឈន្តិកសមយំ សាយណ្ហសមយំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ អរិយធម្មំ អាហរិស្សាមិ សមាហរិស្សាមិ អធិគច្ឆិស្សាមិ ផុសយិស្សាមិ សច្ឆិករិស្សាមីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវរូបម្បិ វីរិយសមាទានំ វុច្ចតិ វត្តំ ន សីលំ ។ ជន្តូតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគុ មនុជោតិ ។ យោ អត្តនោ សីលវតានិ ជន្តុ ។

ការកាន់យកដោយប្រពៃ ដោយវីរិយៈមានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា អាត្មាអញនឹងនាំមក ប្រមូលមក សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ក្នុងបុព្វណ្ហសម័យនេះឯង ការកាន់យកដោយប្រពៃ ដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ បុគ្គលផ្គងចិត្ត តម្កល់ចិត្តថា អាត្មាអញនឹងនាំមក ប្រមូលមក សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ក្នុងសម័យថ្ងៃត្រង់នេះឯង ក្នុងសម័យថ្ងៃរសៀល ក្នុងវេលាមុនភត្ត ក្នុងវេលាក្រោយភត្ត ក្នុងយាមជាខាងដើម ក្នុងយាមជាកណ្ដាល ក្នុងយាមជាទីបំផុត ក្នុងកាលខាងរនោច ក្នុងកាលខាងខ្នើត ក្នុងវស្សានរដូវ ក្នុងហេមន្តរដូវ ក្នុងគិម្ហរដូវ ក្នុងចំណែកនៃវ័យជាខាងដើម ក្នុងចំណែកនៃវ័យជាកណ្ដាល ក្នុងចំណែកនៃវ័យជាទីបំផុត ការកាន់យកដោយប្រពៃ ដោយវីរិយៈ មានសភាពយ៉ាងនេះ ក៏លោកហៅថា វត្ត មិនមែនសីល ។ ពាក្យថា ជន គឺសត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយត់ម្រិយ សត្វកើតអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ជនណា (ដែលគេមិនបានសាកសួរ) នូវសីលនិងវត្ត របស់ខ្លួន ។

(៨២) អនានុបុដ្ឋោ ច បរេស បាវាតិ បរេសន្តិ បរេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្វជិតានំ ទេវានំ មនុស្សានំ ។ អនានុបុដ្ឋោតិ អបុដ្ឋោ អបុច្ឆិតោ អយាចិតោ អនជ្ឈេសិតោ អប្បសាទិតោ ។ បាវាតិ អត្តនោ សីលំ វា វត្តំ វា សីលវត្តំ វា បាវទតិ ។ អហមស្មិ សីលសម្បន្នោតិ វា វត្តសម្បន្នោតិ វា សីលវត្តសម្បន្នោតិ វា ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា ឧច្ចាកុលា បព្វជិតោតិ វា មហាកុលា បព្វជិតោតិ វា មហាភោគកុលា បព្វជិតោតិ វា ឧឡារភោគកុលា បព្វជិតោតិ វា ញាតោ យសស្សី គហដ្ឋានំ បព្វជិតានន្តិ វា លាភិម្ហិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ វា

(៨៦) អធិប្បាយពាក្យថា ជនណា ដែលគេមិនបានសាកសួរ ហើយពោលសួត ប្រាប់បុគ្គលដទៃ ត្រង់ពាក្យថា បុគ្គលដទៃ បានដល់ជនដទៃ គឺ ក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា មនុស្សទាំងឡាយ ។ ពាក្យថា ដែលគេមិនបានសាកសួរ គឺ ដែលគេមិនបានដណ្តឹង មិនបានសួរ មិនបានអារាធនា មិនបានអញ្ជើញ មិនបានឲ្យជ្រះថ្លា ។ ពាក្យថា ពោលសួត គឺផ្តើមនិយាយនូវសីល ឬវត្ត ឬក៏សីលនិងវត្ត របស់ខ្លួន ។ បុគ្គលផ្តើមនិយាយ សំដែង ពោល បំភ្លឺ បញ្ចេញថា អាត្មាជាអ្នកបរិបូណ៌ ដោយសីលក្តី ថា បរិបូណ៌ដោយវត្តក្តី ថា បរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួន ជាកូនអ្នកមានត្រកូលក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនសូត្រក្តី ដោយការងារក្តី ដោយសិល្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយការវាងវៃក្តី ដោយវត្ថុណាមួយក្តី ថាជាអ្នក (ចេញ) អំពីត្រកូលខ្ពស់ ហើយបួសក្តី ថា (ចេញ) អំពីត្រកូលដ៏ប្រសើរ ហើយបួសក្តី ថា (ចេញ) អំពីត្រកូលមានទ្រព្យច្រើនហើយបួសក្តី ថា (ចេញ) អំពីត្រកូលមានទ្រព្យលើសលុបហើយបួសក្តី ថាជាអ្នកមានយស ល្បីល្បាញជាងគ្រហស្ថនិងបព្វជិតទាំងឡាយក្តី ថាអាត្មាអញជាអ្នកមានលាភ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារក្តី

សុត្តន្តិកោតិ វា វិនយធរោតិ វា ធម្មកថិកោតិ វា អារញ្ញិកោតិ វា បិណ្ឌបាតិកោតិ វា បំសុកូលិកោតិ វា តេចីវរិកោតិ វា សបទានចារិកោតិ វា ខលុបច្ឆាភត្តិកោតិ វា នេសជ្ជិកោតិ វា យថាសន្ថតិកោតិ វា បឋមស្ស ឈានស្ស លាភីតិ វា ទុតិយស្ស ឈានស្ស លាភីតិ វា តតិយស្ស ឈានស្ស លាភីតិ វា ចតុត្ថស្ស ឈានស្ស លាភីតិ វា អាកាសានញ្ចាយតនសមាបត្តិយា លាភីតិ វា វិញ្ញាណញ្ចាយតនសមាបត្តិយា លាភីតិ វា អាកិញ្ចញ្ញាយតនសមាបត្តិយា លាភីតិ វា នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា បាវទតិ កថេតិ ភណតិ ទីបយតិ វោហរតីតិ អនានុបុដ្ឋោ ច បរេស បាវ ។

(៨៣) អនរិយធម្មំ កុសលា តមាហុតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុសលា អាយតនកុសលា បដិច្ចសមុប្បាទកុសលា សតិប្បដ្ឋានកុសលា សម្មប្បធានកុសលា ឥទ្ធិបាទកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្វានកុសលា តេ កុសលា ឯវមាហំសុ

ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់វិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកកាន់អារញ្ញិកធុតង្គក្តី កាន់បិណ្ឌបាតិកធុតង្គក្តី កាន់បំសុកូលិកធុតង្គក្តី កាន់តេចីវរិកធុតង្គក្តី កាន់សបទានចារិកធុតង្គក្តី កាន់ខលុបច្ឆាភត្តិកធុតង្គក្តី កាន់នេសជ្ជិកធុតង្គក្តី កាន់សន្ថតិកធុតង្គក្តី ថាជាអ្នកបានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជនណាដែលគេមិនទាន់សាកសួរ ហើយពោលអួតប្រាប់បុគ្គលដទៃ ។

(៨៣) អធិប្បាយពាក្យថា ជនអ្នកឈ្លាសវៃទាំងឡាយ ពោលនូវជននោះថា ជាអ្នកមិនមានអរិយធម៌ ត្រង់ពាក្យថា ជនអ្នកឈ្លាសវៃ គឺជនទាំងឡាយណា ជាអ្នកឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពលៈ ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាសវៃក្នុងព្រះនិព្វាន ពួកអ្នកឈ្លាសវៃនោះ បានពោលយ៉ាងនេះថា

អនរិយានំ ឯសោ ធម្មោ នេសោ ធម្មោ អរិយានំ ពាលានំ ឯសោ ធម្មោ នេសោ ធម្មោ បណ្ឌិតានំ អសប្បុរិសានំ ឯសោ ធម្មោ នេសោ ធម្មោ សប្បុរិសានន្តិ ឯវមាហំសុ ឯវំ ភាសេន្តិ ឯវំ កថេន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ អនរិយធម្មំ កុសលា តមាហុ ។

(៨៤) យោ អាតុមានំ សយមេវ បាវាតិ អាតុមា វុច្ចតិ អត្តា ។ សយមេវ បាវាតិ សយមេវ អត្តានំ បាវទតិ អហមស្មិ សីលសម្បន្នោតិ វា វត្តសម្បន្នោតិ វា សីលវត្តសម្បន្នោតិ វា ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា ឧច្ចាកុលា បព្វជិតោតិ វា មហាកុលា បព្វជិតោតិ វា មហាភោគកុលា បព្វជិតោតិ វា ឧឡារភោគកុលា បព្វជិតោតិ វា ញាតោ យសស្សី គហដ្ឋានំ បព្វជិតានន្តិ វា លាភិម្ហិ

នុ៎ះជាធម៌របស់ពួកជនមិនមែនជាអរិយៈ នុ៎ះមិនមែនជាធម៌របស់ពួកអរិយៈ នុ៎ះជាធម៌របស់ពួកពាល នុ៎ះមិនមែនធម៌របស់ពួកបណ្ឌិត នុ៎ះជាធម៌របស់ពួកអសប្បុរស នុ៎ះមិនមែនជាធម៌របស់ពួកសប្បុរស ពួកជនអ្នកឈ្លាសវៃ បានពោលយ៉ាងនេះហើយ សំដែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកឈ្លាសវៃទាំងឡាយ បានពោលនូវជននោះថា ជាអ្នកមិនមានអរិយធម៌ ។

[៨៤] ពាក្យថា ជនណា ពោលអួតខ្លួនដោយខ្លួនឯង អធិប្បាយថា អត្តា លោកពោលថា ខ្លួន ។ ពាក្យថា ពោលអួតដោយខ្លួនឯង គឺបុគ្គលពោលអួតខ្លួនដោយខ្លួនឯង គឺថា ពោលអួត សំដែង និយាយ បំភ្លឺ បញ្ចេញថា អាត្មាអញជាអ្នកបរិបូណ៌ដោយសីលក្តី ជាបរិបូណ៌ដោយវត្តក្តី ជាបរិបូណ៌ដោយសីលនឹងវត្តក្តី ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពនៃខ្លួន មានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនសូត្រក្តី ដោយការងារក្តី ដោយសិល្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយការវាងវៃក្តី ដោយវត្ថុណាមួយក្តី ថាជាអ្នក (ចេញ) អំពីត្រកូលខ្ពស់ហើយបួសក្តី ថា (ចេញ) អំពីត្រកូលដ៏ប្រសើរហើយបួសក្តី ថា (ចេញ) អំពីត្រកូលមានទ្រព្យច្រើនហើយបួសក្តី ថា (ចេញ) អំពីត្រកូលមានទ្រព្យលើសលុបហើយបួសក្តី ថាជាអ្នកមានយសល្បីល្បាញជាងគ្រហស្ថនិងបព្វជិតទាំងឡាយក្តី

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខា-លាភិន្តិ វា សុត្តន្តិកោតិ វា វិនយធរោតិ វា ធម្ម-កថិកោតិ វា អារញ្ញិកោតិ វា បិណ្ឌបាតិកោតិ វា បំសុកូលិកោតិ វា តេចីវរិកោតិ វា សបទានចារិ-កោតិ វា ខលុបច្ឆាភត្តិកោតិ វា នេសជ្ជិកោតិ វា យថាសន្ថតិកោតិ វា បឋមស្ស ឈានស្ស លាភីតិ វា ទុតិយស្ស ឈានស្ស លាភីតិ វា តតិយស្ស ឈានស្ស លាភីតិ វា ចតុត្ថស្ស ឈានស្ស លាភីតិ វា អាកាសា-នញ្ចាយតនសមាបត្តិយា លាភីតិ វា វិញ្ញាណញ្ចា-យតនសមាបត្តិយា លាភីតិ វា អាកិញ្ចញ្ញាយតន-សមាបត្តិយា លាភីតិ វា នេវសញ្ញានាសញ្ញាយតន-សមាបត្តិយា លាភីតិ វា បាវទតិ កថេតិ ភណតិ ទីបយតិ វោហរតីតិ យោ អាតុមានំ សយមេវ បា-វ ។ តេនាហ ភគវា

យោ អត្តនោ សីលវតានិ ជន្តុ
អនានុបុដ្ឋោ ច បរេស បាវ
អនរិយធម្មំ កុសលា តមាហុ
យោ អាតុមានំ សយមេវ បាវាតិ ។

## ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

ថាអាត្មាជាអ្នកមានលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់វិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកកាន់អារញ្ញិកធុតង្គក្តី កាន់បិណ្ឌបាតិកធុតង្គក្តី កាន់បំសុកូលិកធុតង្គក្តី កាន់តេចីវរិកធុតង្គក្តី កាន់សបទានចារិកធុតង្គក្តី កាន់ខលុបច្ឆាភត្តិកធុតង្គក្តី កាន់នេសជ្ជិកធុតង្គក្តី កាន់យថាសន្ថតិកធុតង្គក្តី ថាជាអ្នកបានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ជនណា ពោលអួតខ្លួន ដោយខ្លួនឯង ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជនណា ដែលគេមិនបានសាកសួរ នូវសីលនិងវត្តរបស់ខ្លួន
ហើយពោលអួតប្រាប់ពួកបុគ្គលដទៃ ជនអ្នកឈ្លាសវៃទាំង
ឡាយពោលនូវជន ដែលពោលអួតខ្លួន ដោយខ្លួនឯងនោះ
ថាជាអ្នកមិនមានអរិយធម៌ ៗ

(៨៥) សន្តោ ច ភិក្ខុ អភិនិព្វុតត្តោ
ឥតិ(១) ហន្តិ សីលេសុ អកត្ថមានោ
តមរិយធម្មំ កុសលា វទន្តិ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ ។

(៨៦) សន្តោ ច ភិក្ខុ អភិនិព្វុតត្តោតិ សន្តោតិ រាគស្ស សន្តត្តា សន្តោ ទោសស្ស សន្តត្តា សន្តោ មោហស្ស សន្តត្តា សន្តោ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមាន-ស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ច-រិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបស-មិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ សន្តោ ។

១ ម. ឥទហេន្តិ ។

(៨៥) ភិក្ខុណា ជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង អ្នកមិនអួតអាង ចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះផង កិលេសដ៏ក្រាស់ណាមួយ ក្នុងលោក នៃភិក្ខុណា មិនមានផង ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោល នូវភិក្ខុនោះថា ជាអ្នកមានអរិយធម៌ ។

(៨៦) អធិប្បាយពាក្យថា ភិក្ខុណាជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង ត្រង់ពាក្យថា អ្នកស្ងប់រម្ងាប់ គឺអ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់រម្ងាប់រាគៈ អ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់រម្ងាប់ទោសៈ អ្នកស្ងប់រម្ងាប់ ព្រោះជាអ្នកស្ងប់រម្ងាប់មោហៈ អ្នកស្ងប់រម្ងាប់ ចូលទៅជិតស្ងប់ រលត់ រលាស់ចេញ ព្រោះជាអ្នកស្ងប់រម្ងាប់ ចូលទៅជិតស្ងប់ ផុត រលត់ ប្រាសចេញ រលាស់ចេញ នូវកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង ការតាក់តែងនូវអកុសលទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកស្ងប់រម្ងាប់ ។

ភិក្ខូតិ សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ ។ សក្កាយទិដ្ឋិ ភិន្នា ហោតិ វិចិកិច្ឆា ភិន្នា ហោតិ សីលព្វតបរាមាសោ ភិន្នោ ហោតិ រាគោ ភិន្នោ ហោតិ ទោសោ ភិន្នោ ហោតិ មោហោ ភិន្នោ ហោតិ មានោ ភិន្នោ ហោតិ ។ ភិន្នស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោភវិកា សទរា ទុក្ខវិបាកា អាយតិំ ជាតិជរាមរណីយា ។

បជ្ជេន កតេន អត្តនា (សភិយាតិ ភគវា)
បរិនិព្ពានគតោ វិតិណ្ណកង្ខោ
វិភវញ្ច ភវញ្ច វិប្បហាយ
វុសិតវា ខីណបុនព្ភវោតិ[1] ។

សន្តោ ច ភិក្ខុ ។ អភិនិព្ពុតត្តោតិ រាគស្ស និព្ពាបិតត្តា ទោសស្ស និព្ពាបិតត្តា មោហស្ស និព្ពាបិតត្តា អភិនិព្ពុតត្តោ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ

១ ម. ខីណបោនោព្ភវោ ស ភិក្ខូតិ ។

## ទុដ្ឋដ្ឋកបុគ្គនិទ្ទេស ទី ៣

ពាក្យថា ភិក្ខុ គឺឈ្មោះថា ភិក្ខុ ព្រោះទំលាយបោល នូវធម៌ទាំង ៧ ។ គឺជាអ្នកទំលាយសក្កាយទិដ្ឋិ ទំលាយវិចិកិច្ឆា ទំលាយសីលព្វតបរាមាសៈ ទំលាយរាគៈ ទំលាយទោសៈ ទំលាយមោហៈ ទំលាយមានះ ។ ពួកអកុសលធម៌ដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ប្រព្រឹត្តទៅក្នុងភពថ្មី ប្រកបដោយការក្រវល់ក្រវាយ មានផលជាទុក្ខ មានជាតិ ជរា មរណៈ ក្នុងខាងមុខ ភិក្ខុនោះ ទំលាយបង់ហើយ ។

(ព្រះមានព្រះភាគ ទ្រង់សំដែងថា ម្នាលសភិយៈ បុគ្គលណា) ដល់នូវការរលត់ ធ្លងសេចក្តីសង្ស័យ ដោយផ្លូវដែលខ្លួនធ្វើហើយ លះបង់នូវវិភវតណ្ហា និងភវតណ្ហា មានព្រហ្មចរិយធម៌ ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានភពថ្មីអស់ហើយ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុណា ជាអ្នកស្ងប់ម្ងាប់ផង ។ ពាក្យថា អ្នកមានចិត្តរលត់ គឺ អ្នកមានចិត្តរលត់ ព្រោះជាអ្នករំលត់ នូវរាគៈ ព្រោះជាអ្នករំលត់ទោសៈ ព្រោះជាអ្នករំលត់មោហៈ អ្នកមានចិត្តរលត់ ព្រោះជាអ្នករំលត់ នូវកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង

សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ និព្វាបិតត្តា អភិនិព្វុតត្តាតិ សន្តោ ច ភិក្ខុ អភិនិព្វុតត្តោ ។

(៨៧) ឥតិហន្តិ សីលេសុ អកត្ថមានោតិ ឥតិហន្តិ បទសន្ធិ បទសំសគ្គោ បទបារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ ឥតិហន្តិ ។ សីលេសុ អកត្ថមានោតិ ឥធេកច្ចោ កត្ថី ហោតិ វិកត្ថី ។ សោ កត្ថតិ វិកត្ថតិ អហមស្មិ សីលសម្បន្នោតិ វា វតសម្បន្នោតិ វា សីលវតសម្បន្នោតិ វា ជាតិយា វា គោត្តេន វា កោលបុត្តិកេន វា វណ្ណពោក្ខរតាយ វា ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា កត្ថតិ វិកត្ថតិ ។ ឯវំ ន កត្ថតិ ន វិកត្ថតិ កត្ថនា អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ឥតិហន្តិ សីលេសុ អកត្ថមានោ ។

សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង ការតាក់តែងអកុសលទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុណា ជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង ។

(៨៧) អធិប្បាយពាក្យថា អ្នកមិនអួតអាង ចំពោះសីលទាំងឡាយថា អាត្មាអញដូច្នេះ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យតបទ ជាប់ជាមួយដោយបទ ជាពាក្យបំពេញបទ រួបរួមអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់បទ ។ ពាក្យថា មិនអួតអាង ចំពោះសីលទាំងឡាយ គឺបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលអួតអាង ។ បុគ្គលនោះ រមែងពោលអួតអាងថា អាត្មាអញបរិបូណ៌ដោយសីលក្តី បរិបូណ៌ដោយវត្តក្តី បរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពនៃខ្លួនជាអ្នកមានសម្បុរល្អក្តី ។ បេ ។ ពោលអួតអាងថា អាត្មាអញជាអ្នកបាន នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ។ បុគ្គលរមែងមិនពោល មិនអួតអាងយ៉ាងនេះ គឺជាអ្នកវៀរ ជៀសវាង គេចចេញ រលាស់ចេញ ដោះចេញ ប្រាសចេញឆ្ងាយ ចាកការពោលអួត នៅដោយចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនអួតអាង ចំពោះសីលទាំងឡាយថា អាត្មាអញ ដូច្នេះ ។

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

(៨៨) តមរិយធម្មំ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុសលា អាយតនកុសលា បដិច្ចសមុប្បាទកុសលា សតិបដ្ឋានកុសលា សម្មប្បធានកុសលា ឥទ្ធិបាទកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្ពានកុសលា តេ កុសលា ឯវំ វទន្តិ អរិយានំ ឯសោ ធម្មោ នេសោ ធម្មោ អនរិយានំ បណ្ឌិតានំ ឯសោ ធម្មោ នេសោ ធម្មោ ពាលានំ សប្បុរិសានំ ឯសោ ធម្មោ នេសោ ធម្មោ អសប្បុរិសានន្តិ ឯវំ វទន្តិ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តមរិយធម្មំ កុសលា វទន្តិ ។

(៨៩) យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេតិ យស្សាតិ អរហតោ ខីណាសវស្ស ។ ឧស្សទាតិ សត្តុស្សទា រាគុស្សទោ ទោសុស្សទោ មោហុស្សទោ

## ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

(៨៨) អធិប្បាយពាក្យថា ជនអ្នកឈ្លាសវៃ រមែងពោលនូវបុគ្គលនោះថាជាអ្នកមានអរិយធម៌ ត្រង់ពាក្យថា ជនអ្នកឈ្លាសវៃ គឺជនទាំងឡាយណា ជាអ្នកឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពលៈ ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាសវៃក្នុងព្រះនិព្វាន ជនអ្នកឈ្លាសវៃនោះ រមែងពោលយ៉ាងនេះថា នុ៎ះជាធម៌ របស់ពួកអរិយៈ នុ៎ះមិនមែនជាធម៌ របស់ពួកអ្នកមិនមែនអរិយៈ នុ៎ះជាធម៌របស់ពួកបណ្ឌិត នុ៎ះមិនមែនជាធម៌របស់ពួកពាល នុ៎ះជាធម៌របស់ពួកសប្បុរស នុ៎ះមិនមែនជាធម៌របស់ពួកអសប្បុរស ពួកអ្នកឈ្លាសវៃ រមែងពោលយ៉ាងនេះ សំដែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោល នូវបុគ្គលនោះ ថាជាអ្នកមានអរិយធម៌ ។

(៨៩) អធិប្បាយពាក្យថា កិលេសដ៏ក្រាស់ណាមួយ ក្នុងលោក នៃភិក្ខុណា មិនមាន ត្រង់ពាក្យថា នៃភិក្ខុណា គឺនៃព្រះអរហន្ត-ខីណាស្រព ។ ពាក្យថា កិលេសដ៏ក្រាស់ បានដល់ កិលេសដ៏ក្រាស់ ៧ គឺ កិលេសដ៏ក្រាស់គឺរាគៈ កិលេសដ៏ក្រាស់គឺទោសៈ

មានុស្សទោ ទិដ្ឋុស្សទោ កិលេសុស្សទោ កម្មុស្ស-
ទោ ។ តស្សិមេ ឧស្សទា នត្ថិ ន សន្តិ ន
សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា
បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា ។
កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា
ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វា ។ លោកេតិ អបាយ-
លោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ
ធាតុលោកេ អាយតនលោកេតិ យស្សុស្សទា នត្ថិ
កុហិញ្ចិ លោកេ ។ តេនាហ ភគវា

សន្តោ ច ភិក្ខុ អភិនិព្វុតត្តោ
ឥតិហន្តិ សីលេសុ អកត្ថមានោ
តមរិយធម្មំ កុសលា វទន្តិ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេតិ ។

(៩០) បកប្បិតា សង្ខតា យស្ស ធម្មា
បុរក្ខតា សន្តិ អវីវទាតា
យទត្តនិ បស្សតិ អានិសំសំ
តន្និស្សិតោ កុប្បបដិច្ចសន្តឹ ។

កិលេសដ៏ក្រាស់គឺមោហៈ កិលេសដ៏ក្រាស់គឺមានះ កិលេសដ៏ក្រាស់គឺទិដ្ឋិ កិលេសដ៏ក្រាស់គឺកិលេស កិលេសដ៏ក្រាស់គឺកម្ម ៗ កិលេសដ៏ក្រាស់ទាំងនេះ នៃព្រះខីណាស្រពនោះ មិនមាន ត់តមាន គ្មានសោះ មិនកើតមាន គឺលោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនឲ្យកើតទៀត ដុតដោយភ្លើងគឺញាណហើយ ៗ ពាក្យថា ណាមួយ គឺណាមួយ និមួយ ណានិមួយ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ៗ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសដ៏ក្រាស់ណាមួយ ក្នុងលោក នៃភិក្ខុណាមិនមាន ៗ ហេតុនោះ ព្រះមានព្រះភាគ សំដែងថា

ភិក្ខុណាជាអ្នកស្ងប់រម្ងាប់ផង អ្នកមានចិត្តរលត់ផង អ្នកមិន
អួតអាង ចំពោះសីលទាំងឡាយថា អាត្មាអញ ដូច្នេះផង
កិលេសដ៏ក្រាស់ណាមួយក្នុងលោក នៃភិក្ខុណាមិនមានផង
ជនអ្នកឈ្លាសវៃទាំងឡាយ រមែងពោលនូវបុគ្គលនោះ ថា
ជាអ្នកមានអរិយធម៌ ៗ

[៩០] ធម៌ទាំងឡាយ ដែលបុគ្គលណាសម្រេចហើយ តាក់តែង
ហើយ ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់
បុគ្គលនោះឃើញនូវអានិសង្សណាក្នុងខ្លួន រមែងអាស្រ័យនូវ
អានិសង្សនោះ និងសេចក្តីស្ងប់ដែលអាស្រ័យនូវការកំរើក ៗ

(៩១) បកប្បិតា សង្ខតា យស្ស ធម្មាតិ បកប្បនាតិ ទ្វេ បកប្បនា តណ្ហាបកប្បនា ច ទិដ្ឋិបកប្បនា ច ។បេ។ អយំ តណ្ហាបកប្បនា ។បេ។ អយំ ទិដ្ឋិបកប្បនា ។ សង្ខតាតិ សង្ខតា វិសង្ខតា អភិសង្ខតា សណ្ឋបិតាតិបិ សង្ខតា ។ អថវា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មាតិបិ សង្ខតា ។ យស្សាតិ ទិដ្ឋិគតិកស្ស ។ ធម្មាតិ ទ្វាសដ្ឋី ទិដ្ឋិគតានីតិ បកប្បិតា សង្ខតា យស្ស ធម្មា ។

(៩២) បុរក្ខតា សន្តិ អវីវទាតាតិ បុរេក្ខារាតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។បេ។

[៩១] អធិប្បាយពាក្យថា ធម៌ទាំងឡាយ ដែលបុគ្គលណាសម្រេចហើយ តាក់តែងហើយ ត្រង់ពាក្យថា សម្រេច បានដល់កិរិយាសម្រេច ២ ប្រការ គឺ កិរិយាសម្រេចគឺតណ្ហា ១ កិរិយាសម្រេចគឺទិដ្ឋិ ១ ។ បេ ។ នេះហៅថា កិរិយាសម្រេចគឺតណ្ហា ។ បេ ។ នេះហៅថា កិរិយាសម្រេចគឺទិដ្ឋិ ។ ពាក្យថា តាក់តែងហើយ គឺធ្វើព្រមហើយ ចាត់ចែងហើយ តាក់តែងប្រាកដហើយ តាំងទុកព្រមហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) តាក់តែងហើយ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយមានសភាពមិនទៀង ដែលបច្ច័យតាក់តែងហើយ អាស្រ័យគ្នាទើបកើតឡើង មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការព្រាត់ប្រាសជាធម្មតា មានការរលត់ជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) តាក់តែងហើយ ។ ពាក្យថា ដែលបុគ្គលណា គឺ បុគ្គលដែលលុះក្នុងទិដ្ឋិ ។ ទិដ្ឋិ ៦២ លោកពោលថា ធម៌ទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ធម៌ទាំងឡាយដែលបុគ្គលណា សម្រេចហើយ តាក់តែងហើយ ។

[៩២] អធិប្បាយពាក្យថា ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ ត្រង់ពាក្យថា ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ បានដល់ ការធ្វើឲ្យតាំងនៅក្នុងខាងមុខ ២ គឺ ការធ្វើតណ្ហា ឲ្យតាំងនៅក្នុងខាងមុខ ១ ការធ្វើទិដ្ឋិ ឲ្យតាំងនៅក្នុងខាងមុខ ១ ។ បេ ។

អយំ តណ្ហាបុរេក្ខារោ ។ បេ ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តស្ស តណ្ហាបុរេក្ខារោ អប្បហីនោ ទិដ្ឋិបុរេក្ខារោ អប្បដិនិស្សដ្ឋោ តស្ស តណ្ហាបុរេក្ខារស្ស អប្បហីនត្តា តស្ស ទិដ្ឋិបុរេក្ខារស្ស អប្បដិនិស្សដ្ឋត្តា សោ តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរតិ តណ្ហាធជោ តណ្ហាកេតុ តណ្ហាធិបតេយ្យោ ទិដ្ឋិធជោ ទិដ្ឋិកេតុ ទិដ្ឋាធិបតេយ្យោ តណ្ហាយ វា ទិដ្ឋិយា វា បរិវារិតោ ចរតីតិ បុរក្ខតា ។ សន្តីតិ សន្តិ សំវិជ្ជន្តិ[១] ឧបលព្ភន្តិ ។ អវីវទាតាតិ អវីវទាតា អវោទាតា អបរិសុទ្ធា សង្កិលិដ្ឋា សង្កិលេសិកាតិ បុរក្ខតា សន្តិ អវីវទាតា ។

(៩៣) យទត្តនី បស្សតិ អានិសំសន្តិ យទត្តនីតិ យំ អត្តនិ ។ អត្តា វុច្ចតិ ទិដ្ឋិគតំ ។ អត្តនោ ទិដ្ឋិយា ទ្វេ អានិសំសេ បស្សតិ ទិដ្ឋធម្មិកញ្ច អានិសំសំ សម្បរាយិកញ្ច អានិសំសំ ។

---

១ ម. ឯត្ថន្តរេ អត្ថីតិ ទិស្សតិ ។

នេះ ឈ្មោះថា ការធ្វើតណ្ហាឲ្យតាំងនៅក្នុងខាងមុខ ។ បេ ។ នេះ ឈ្មោះថា ការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ។ ការធ្វើតណ្ហាឲ្យតាំងនៅក្នុងខាងមុខ ដែលបុគ្គលនោះ មិនទាន់លះបង់ហើយ ការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ដែលបុគ្គលនោះ មិនទាន់រលាស់ចេញហើយ បុគ្គលនោះ ធ្វើតណ្ហានិងទិដ្ឋិឲ្យតាំងនៅអំពីមុខ ហើយប្រព្រឹត្ត មានតណ្ហាដូចជាទង់ជ័យ មានតណ្ហាដូចជាទង់ មានតណ្ហាជាធំ មានទិដ្ឋិដូចជាទង់ជ័យ មានទិដ្ឋិដូចជាទង់ មានទិដ្ឋិជាធំ ត្រូវតណ្ហានិងទិដ្ឋិរួបរឹតហើយប្រព្រឹត្តទៅ ព្រោះហេតុនៃការធ្វើតណ្ហា ឲ្យតាំងនៅក្នុងខាងមុខ ដែលខ្លួនមិនទាន់លះបង់ ព្រោះហេតុនៃការធ្វើទិដ្ឋិឲ្យតាំងនៅក្នុងខាងមុខ ដែលខ្លួនមិនទាន់រលាស់ចេញ ហេតុនោះ (ទ្រង់ត្រាស់ថា) ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ។ ពាក្យថា រមែងមាន គឺ មាន មានគ្រប់គ្រាន់កើតមាន ។ ពាក្យថា មិនផូរផង់ គឺមិនផូរផង់ មិនថ្លាស្អាត មិនបរិសុទ្ធ ជាធម៌សៅហ្មង ប្រកបដោយសេចក្ដីសៅហ្មង ហេតុនោះ (ទ្រង់ត្រាស់ថា) ធ្វើឲ្យតាំងនៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ ។

(៩៣) អធិប្បាយពាក្យថា បុគ្គលនោះ ឃើញនូវអានិសង្សណាក្នុងខ្លួន ត្រង់ពាក្យថា អានិសង្សណាក្នុងខ្លួន គឺអានិសង្សណាចំពោះខ្លួន ។ ទិដ្ឋិ លោកហៅថា ខ្លួន ។ បុគ្គលរមែងឃើញអានិសង្ស ២ យ៉ាង នៃទិដ្ឋិរបស់ខ្លួន គឺអានិសង្សក្នុងបច្ចុប្បន្ន ១ អានិសង្សក្នុងបរលោក ១ ។

តតិយោ ទុដ្ឋិដ្ឋិកសុត្តន្តទ្វេកោ

កតមោ ឥទ្ធិយា ទិដ្ឋធម្មិកោ អានិសំសោ ។ យំ ឥទ្ធិកោ សត្ថា ហោតិ តំ ឥទ្ធិកា សាវកា ហោន្តិ។ តំ ឥទ្ធិកំ សត្ថារំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ អបចិតិំ ករោន្តិ លភន្តិ ច តតោនិទានំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អយំ ឥទ្ធិយា ទិដ្ឋធម្មិកោ អានិសំសោ។

កតមោ ឥទ្ធិយា សម្បរាយិកោ អានិសំសោ ។ អយំ ឥទ្ធិ អលំ នាគត្តាយ វា សុបណ្ណត្តាយ វា យក្ខត្តាយ វា អសុរត្តាយ វា គន្ធព្វត្តាយ វា មហារាជត្តាយ វា ឥន្ទត្តាយ វា ព្រហ្មត្តាយ វា ទេវត្តាយ វា អយំ ឥទ្ធិ អលំ សុទ្ធិយា វិសុទ្ធិយា បរិសុទ្ធិយា មុត្តិយា វិមុត្តិយា បរិមុត្តិយា ឥមាយ ឥទ្ធិយា សុជ្ឈន្តិ វិសុជ្ឈន្តិ បរិសុជ្ឈន្តិ មុច្ចន្តិ វិមុច្ចន្តិ បរិមុច្ចន្តិ ឥមាយ ឥទ្ធិយា សុជ្ឈិស្សាមិ វិសុជ្ឈិស្សាមិ បរិសុជ្ឈិស្សាមិ មុច្ចិស្សាមិ វិមុច្ចិស្សាមិ បរិមុច្ចិស្សាមីតិ អាយតឹ ឆន្ទជាតិកោ ហោតិ អយំ ឥទ្ធិយា សម្បរាយិកោ អានិសំសោ ។

## ទុដ្ឋិកសុត្តនិទ្ទេស ទី ៣

អានិសង្សនៃទិដ្ឋិក្នុងបច្ចុប្បន្ន តើដូចម្ដេច ។ សាស្ដាជាអ្នកមានទិដ្ឋិបែបណា ពួកសាវ័ក ក៏រមែងមានទិដ្ឋិបែបនោះ ។ ពួកសាវ័ករមែងធ្វើសក្ការៈ គោរព រាប់អាន បូជា ធ្វើនូវការកោតក្រែងចំពោះសាស្ដាមានទិដ្ឋិបែបនោះ ទាំងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះការធ្វើសក្ការៈ ជាដើមនោះជាហេតុ នេះឈ្មោះថា អានិសង្សនៃទិដ្ឋិក្នុងបច្ចុប្បន្ន ។

អានិសង្សនៃទិដ្ឋិក្នុងបរលោក តើដូចម្ដេច ។ ទិដ្ឋិនេះ គួរដើម្បីភាពជានាគក្តី ភាពជាគ្រុឌក្តី ភាពជាយក្ខក្តី ភាពជាអសុរក្តី ភាពជាគន្ធព្វក្តី ភាពជាមហារាជក្តី ភាពជាព្រះឥន្ទ្រក្តី ភាពជាព្រះព្រហ្មក្តី ភាពជាទេវតាក្តី ទិដ្ឋិនេះ គួរដើម្បីសេចក្តីមដ្ឋបត់ ស្អាតវិសេស បរិសុទ្ធ ផុត រួចស្រឡះ រួចចេញ ជនទាំងឡាយ រមែងមដ្ឋបត់ ស្អាតវិសេស បរិសុទ្ធ ផុត រួចស្រឡះ រួចចេញ (ចាកទុក្ខ) ដោយទិដ្ឋិនេះ អាត្មាអញ នឹងមដ្ឋបត់ ស្អាតវិសេស បរិសុទ្ធ ផុត រួចស្រឡះ រួចចេញ ដោយទិដ្ឋិនេះ បុគ្គលជាអ្នកប៉ុនប៉ង ចំពោះផលក្នុងខាងមុខ ដូច្នេះ នេះ ឈ្មោះថា អានិសង្សនៃទិដ្ឋិក្នុងបរលោក ។

អត្តនោ ទិដ្ឋិយា ឥមេ ទ្វេ អានិសំសេ បស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ យទត្តនិ បស្សតិ អានិសំសំ ។

(៩៤) តន្និស្សិតោ កុប្បបដិច្ចសន្តិន្តិ តិស្សោ សន្តិយោ អច្ចន្តសន្តិ តទង្គសន្តិ សម្មុតិសន្តិ ។

កតមា អច្ចន្តសន្តិ ។ អច្ចន្តសន្តិ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ អយំ អច្ចន្តសន្តិ ។

កតមា តទង្គសន្តិ ។ បឋមំ ឈានំ សមាបន្នស្ស នីវរណា សន្តា ហោន្តិ ។ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារា សន្តា ហោន្តិ ។ តតិយំ ឈានំ សមាបន្នស្ស បីតិ សន្តា ហោតិ ។ ចតុត្ថំ ឈានំ សមាបន្នស្ស សុខទុក្ខា សន្តា ហោន្តិ ។ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា សន្តា ហោន្តិ ។

បុគ្គលឃើញ មើល គន់គិត ពិនិត្យ ពិចារណា នូវអានិសង្សនៃទិដ្ឋិរបស់ខ្លួនពីរនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះឃើញនូវអានិសង្សណាក្នុងខ្លួន ។

(៩៤) ពាក្យថា រមែងអាស្រ័យ នូវអានិសង្សនោះ នឹងសេចក្តីស្ងប់ដែលអាស្រ័យនូវការកំរើក អធិប្បាយថា សេចក្តីស្ងប់ ៣ យ៉ាង គឺ អច្ចន្តសន្តិ (ស្ងប់ដោយដាច់ខាត) តទង្គសន្តិ (ស្ងប់ដោយអង្គឈាននោះ) សម្មុតិសន្តិ (ស្ងប់ដោយសេចក្តីសន្មតិ) ។

អច្ចន្តសន្តិ តើដូចម្តេច ។ អមតនិព្វាន លោកហៅថា អច្ចន្តសន្តិ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះលែងឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន នេះ ឈ្មោះថា អច្ចន្តសន្តិ ។

តទង្គសន្តិ តើដូចម្តេច ។ នីវរណៈរបស់បុគ្គលចូលបឋមជ្ឈាន រមែងស្ងប់រម្ងាប់ ។ វិតក្កៈនិងវិចារៈ របស់បុគ្គលចូលទុតិយជ្ឈាន រមែងស្ងប់រម្ងាប់ ។ បីតិរបស់បុគ្គលចូលតតិយជ្ឈាន រមែងស្ងប់រម្ងាប់ សុខនិងទុក្ខរបស់បុគ្គលចូលចតុត្ថជ្ឈាន រមែងស្ងប់រម្ងាប់ ។ រូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា របស់បុគ្គលចូលអាកាសានញ្ចាយតនៈ រមែងស្ងប់រម្ងាប់ ។

វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា សន្តា ហោតិ ។ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញា សន្តា ហោតិ ។ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា សន្តា ហោតិ ។ អយំ តទង្គសន្តិ ។

កតមា សម្មុតិសន្តិ ។ សម្មុតិសន្តិ វុច្ចតិ ទ្វាសដ្ឋិ ទិដ្ឋិគតានិ ទិដ្ឋិសន្តិយោ ។ អបិច សម្មុតិសន្តិ ឥមស្មឹ អធិប្បេតា សន្តីតិ ។

តន្និស្សិតោ កុប្បបដិច្ចសន្តិន្តិ កុប្បសន្តឹ បកុប្បសន្តឹ ឯរិតសន្តឹ សមេរិតសន្តឹ ចលិតសន្តឹ ឃដ្ដិតសន្តឹ កប្បិតសន្តឹ បកប្បិតសន្តឹ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ សន្តឹ និស្សិតោ អល្លីនោ ឧបគតោ អជ្ឈោសិតោ អធិមុត្តោតិ តន្និស្សិតោ កុប្បបដិច្ចសន្តឹ ។ តេនាហ ភគវា

អាកាសានញ្ចាយតនសញ្ញា របស់បុគ្គលចូលវិញ្ញាណញ្ចាយតនៈ រមែងស្ងប់រម្ងាប់ ៗ វិញ្ញាណញ្ចាយតនសញ្ញា របស់បុគ្គលចូលអាកិញ្ចញ្ញាយតនៈ រមែងស្ងប់រម្ងាប់ ៗ អាកិញ្ចញ្ញាយតនសញ្ញា របស់បុគ្គលចូលនេវសញ្ញានាសញ្ញាយតនៈ រមែងស្ងប់រម្ងាប់ ៗ នេះឈ្មោះថា តទង្គសន្តិ ៗ

សម្មតិសន្តិ តើដូចម្តេច ៗ សេចក្តីស្ងប់រម្ងាប់ដោយអំណាចទិដ្ឋិ គឺ ទិដ្ឋិ ៦២ លោកហៅថា សម្មតិសន្តិ ៗ មួយទៀត សេចក្តីស្ងប់ដែលលោកអធិប្បាយទុកក្នុងទីនេះ ក៏ឈ្មោះថា សម្មតិសន្តិ ៗ

ពាក្យថា រមែងអាស្រ័យ នូវអានិសង្សនោះ នឹង សេចក្តីស្ងប់អាស្រ័យនូវការកំរើក បានសេចក្តីថា បុគ្គលអាស្រ័យ ជាប់ចំពាក់ អែបនែប លិចចុះ ជឿស៊ប់នូវសេចក្តីស្ងប់ទៅកំរើក សេចក្តីស្ងប់ទៅកំរើកខ្លាំង សេចក្តីស្ងប់ទៅញាប់ញ័រ សេចក្តីស្ងប់ទៅញាប់ញ័រខ្លាំង សេចក្តីស្ងប់ទៅរំកើប សេចក្តីស្ងប់ទៅបៀតបៀន សេចក្តីស្ងប់ដែលគេបាត់បង់ សេចក្តីស្ងប់ដែលគេបាត់បង់ដោយវិសេស សេចក្តីស្ងប់ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង អាស្រ័យគ្នាកើតឡើង មានកិរិយាអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងអាស្រ័យ នូវអានិសង្សនោះនឹងសេចក្តីស្ងប់ អាស្រ័យនូវការកំរើក ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បកប្បិតា សង្ខតា យស្ស ធម្មា
បុរេក្ខតា សន្តិ អវីវទាតា
យទត្តនិ បស្សតិ អានិសំសំ
តន្និស្សិតោ កុប្បបដិច្ចសន្តិន្តិ ។

(៩៥) ទិដ្ឋីនិវេសា ន ហិ ស្វាតិវត្តា
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា នរោ តេសុ និវេសនេសុ
និរស្សតី អាទិយតិច្ច ធម្មំ ។

(៩៦) ទិដ្ឋីនិវេសា ន ហិ ស្វាតិវត្តាតិ ទិដ្ឋីនិវេសាតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ អភិនិវេសបរាមាសោ ទិដ្ឋិនិវេសនំ អសស្សតោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ

ធម៌ទាំងឡាយ ដែលបុគ្គលណា សម្រេចហើយ តាក់តែងហើយ ធ្វើឲ្យអាំងទៅក្នុងខាងមុខហើយ ជាធម៌មិនផូរផង់ បុគ្គលនោះ រមែងឃើញនូវអានិសង្សណាក្នុងខ្លួន រមែងអាស្រ័យនូវអានិសង្សនោះ នឹងសេចក្តីស្ងប់ អាស្រ័យនូវការកំរើក ។

(៩៥) ការជាប់ចំពាក់គឺទិដ្ឋិ នឹងការជ្រើសរើស ក្នុងធម៌ទាំងឡាយហើយប្រកាន់ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ព្រោះហេតុនោះ ទើបជន រមែងលះបង់ផង ប្រកាន់ផង នូវធម៌ក្នុងការជាប់ចំពាក់ទាំងនោះ ។

(៩៦) អធិប្បាយពាក្យថា ការជាប់ចំពាក់គឺទិដ្ឋិ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ត្រង់ពាក្យថា ការជាប់ចំពាក់គឺទិដ្ឋិ បានដល់ការចុះចិត្តស៊ប់ ការស្ទាបអង្អែល ការជាប់ចំពាក់គឺទិដ្ឋិថា លោកទៀង ការឃើញនេះឯងជាការពិត ការឃើញដទៃជាមោឃៈ ការចុះចិត្តស៊ប់ ការស្ទាបអង្អែល ការជាប់ចំពាក់គឺទិដ្ឋិថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះ សរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វស្លាប់ទៅ កើតទៀតក៏មាន សត្វស្លាប់ទៅ មិនកើតទៀតក៏មាន សត្វស្លាប់ទៅ កើតទៀតផង មិនកើតទៀតផង សត្វស្លាប់ទៅ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ការឃើញនេះឯងជាការពិត

អភិនិវេសបរាមាសោ ទិដ្ឋិនិវេសនន្តិ ទិដ្ឋិនិវេសា ។ ន ហិ ស្វាតិវត្តាតិ ទុរតិវត្តា ទុត្តរា ទុប្បតរា ទុស្សមតិក្កមា ទុព្វីតិវត្តាតិ ទិដ្ឋិនិវេសា ន ហិ ស្វាតិវត្តា ។

(៩៧) ធម្មេសុ និច្ឆេយ្យ សមុគ្គហីតន្តិ ធម្មេសូតិ ទ្វាសដ្ឋិទិដ្ឋិគតេសុ ។ និច្ឆេយ្យាតិ និច្ឆិនិត្វា វិនិច្ឆិនិត្វា វិចិនិត្វា បវិចិនិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា[1] ឱធិគ្គាហោ[2] វិលគ្គាហោ[3] វរគ្គាហោ កោដ្ឋាសគ្គាហោ ឧច្ចយគ្គាហោ សមុច្ចយគ្គាហោ ឥទំ សច្ចំ តច្ឆំ តថំ ភូតំ យាថាវំ អវិបរីតន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តន្តិ ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ ។

(៩៨) តស្មា នរោ តេសុ និវេសនេសូតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ។

---

១ ម ឯត្ថន្តរេ សមុគ្គហិតន្តិ និវេសនេសូតិ ទិស្សន្តិ ។ ២ ឱ. ឱធិសគ្គាហោ ។ ៣ ម. ពិលគ្គាហោ ។

ការឃើញដទៃ ជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ការជាប់ចំពាក់គ៍ទិដ្ឋិ ។ ពាក្យថា បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ គឺប្រព្រឹត្តកន្លងដោយលំបាក ឆ្លងដោយក្រ ឆ្លងចេញបានដោយកម្រ ប្រព្រឹត្តកន្លងបានដោយតឹង ឈានកន្លងបានដោយលំបាក ហេតុនោះ (ទ្រង់ត្រាស់ថា) ការជាប់ចំពាក់គ៍ទិដ្ឋិ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ ។

(៩៧) ពាក្យថា ការជ្រើសរើស ក្នុងធម៌ទាំងឡាយ ហើយប្រកាន់ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ជ្រើសរើស គឺ ការរើសរក វិនិច្ឆ័យ ជ្រើសរើស ពិនិត្យ ថ្លឹងមើល លៃលក ពិចារណា ធ្វើឲ្យច្បាស់ហើយ ប្រកាន់តាមផ្លូវ ប្រកាន់ស្អិត ប្រកាន់មាំ ប្រកាន់ចំណែក ប្រកាន់គំនរ ប្រកាន់ដោយការប្រមូល គឺថា ការប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ ការចូលចិត្ត ការចុះចិត្តជឿថា ហេតុនេះ ពិត ទៀង ទៀងទាត់ ប្រាកដ ពិតមែន មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) ការជ្រើសរើស ក្នុងធម៌ទាំងឡាយហើយប្រកាន់ ។

(៩៨) ពាក្យថា ព្រោះហេតុនោះ របស់បទថា ព្រោះហេតុនោះ ជន (រមែងប្រកាន់) ក្នុងការជាប់ចំពាក់ទាំងនោះគឺ ព្រោះ ហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។

នរោតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគុ មនុជោ ។ តេសុ និវេសនេសូតិ តេសុ ទិដ្ឋិនិវេសនេសូតិ តស្មា នរោ តេសុ និវេសនេសុ ។

(៩៩) និរស្សតី អាទិយតិ ច ធម្មន្តិ និរស្សតីតិ ទ្វីហិ ការណេហិ និរស្សតិ បរវិច្ឆិន្ទនាយ វា និរស្សតិ អនភិសម្ភុណន្តោ វា និរស្សតិ ។

កថំ បរវិច្ឆិន្ទនាយ និរស្សតិ ។ បរោ វិច្ឆិន្ទតិ សោ សត្ថា ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្បដិបន្នោ ទិដ្ឋិ ន ភទ្ទិកា បដិបទា ន សុប្បញ្ញត្តា មគ្គោ ន និយ្យានិកោ នត្ថេត្ថ សុទ្ធិ វា វិសុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា នត្ថេត្ថ សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ជតុក្កា[១] បរិត្តាតិ ។ ឯវំ បរោ វិច្ឆិន្ទតិ ។ ឯវំ វិច្ឆិន្ទិយមានោ សត្ថារំ និរស្សតិ ធម្មក្ខានំ

១ ម. ឆតុក្កា ។

ពាក្យថា ជន គឺសត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជន្តុ សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងការជាប់ចំពាក់ទាំងនោះ គឺក្នុងហេតុជាគ្រឿងជាប់ចំពាក់ គឺទិដ្ឋិទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ជន (រមែងប្រកាន់) ក្នុងការជាប់ចំពាក់ទាំងនោះ ។

(៩៩) អធិប្បាយពាក្យថា រមែងលះបង់ផង ប្រកាន់ផង នូវធម៌ ត្រង់ពាក្យថា រមែងលះបង់ គឺបុគ្គលលះបង់ដោយហេតុ ២ យ៉ាង គឺលះបង់ដោយកិរិយាកាត់ចោល អំពីបុគ្គលដទៃ ឬកាលមិនទាន់ដល់ លះបង់ ។

បុគ្គលលះបង់ដោយកិរិយាកាត់ចោល អំពីបុគ្គលដទៃ តើដូចម្តេច ។ បុគ្គលដទៃ កាត់ចោលថា សាស្តានោះ មិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសំដែងត្រូវទេ គណៈមិនមែនប្រតិបត្តិត្រូវទេ ទិដ្ឋិ មិនល្អទេ បដិបទា មិនមែនបញ្ញត្តល្អទេ មគ្គ មិនមែនជាឧបាយស្រោចស្រង់ទេ សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការរួច ការរួចវិសេសនឹងការរួចស្រឡះ ក្នុងធម៌នុ៎ះ ក៏មិនមាន ពួកជន រមែងស្អាត ស្អាតវិសេស បរិសុទ្ធ រួច រួចវិសេស រួចស្រឡះ ព្រោះធម៌នុ៎ះក៏ទេ បុគ្គលនោះ ជាអ្នកថោកទាប ខ្សត់ខ្សោយ អាប់ឱន លាមក ជ្រោកជ្រាក រំកោចរំកោច ។ បុគ្គលដទៃ កាត់ចោលយ៉ាងនេះ ។ បុគ្គលនោះ ដែលត្រូវគេកាត់ចោលយ៉ាងនេះ រមែងលះបង់សាស្តា

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

និរស្សតិ គណំ និរស្សតិ ទិដ្ឋឹ និរស្សតិ បដិបទំ និរស្សតិ មគ្គំ និរស្សតិ ។ ឯវំ បរិច្ចជ្ជនាយ និរស្សតិ ។

កថំ អនភិសម្ពុណន្តោ និរស្សតិ ។ សីលំ អនភិសម្ពុណន្តោ សីលំ និរស្សតិ វត្តំ អនភិសម្ពុណន្តោ វត្តំ និរស្សតិ សីលវត្តំ អនភិសម្ពុណន្តោ សីលវត្តំ និរស្សតិ ។ ឯវំ អនភិសម្ពុណន្តោ និរស្សតិ ។

អាទិយតិច ធម្មន្តិ សត្ថារំ គណ្ហាតិ ធម្មក្ខានំ គណ្ហាតិ គណំ គណ្ហាតិ ទិដ្ឋឹ គណ្ហាតិ បដិបទំ គណ្ហាតិ មគ្គំ គណ្ហាតិ បរាមសតិ អភិនិវិសតីតិ និរស្សតី អាទិយតិច ធម្មំ ។ តេនាហ ភគវា

ទិដ្ឋីនិវេសា ន ហិ ស្វាតិវត្តា
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា នរោ តេសុ និវេសនេសុ
និរស្សតី អាទិយតិច ធម្មន្តិ ។

លះបង់ធម៌ដែលសាស្តាសំដែង លះបង់គណៈ លះបង់ទិដ្ឋិ លះបង់សេចក្តីប្រតិបត្តិ លះបង់មគ្គ ។ បុគ្គលលះបង់ ដោយកិរិយាកាត់ចោលអំពីបុគ្គលដទៃ យ៉ាងនេះ ។

បុគ្គលកាលមិនទាន់ដល់ លះបង់ តើដូចម្តេច ។ បុគ្គលកាលមិនទាន់ដល់សីល លះបង់សីល មិនទាន់ដល់វត្ត លះបង់វត្ត មិនទាន់ដល់សីលនិងវត្ត លះបង់សីលនិងវត្ត ។ បុគ្គលកាលមិនទាន់ដល់ លះបង់ យ៉ាងនេះ ។

ពាក្យថា ប្រកាន់ផង នូវធម៌ គឺបុគ្គលប្រកាន់សាស្តា ប្រកាន់ធម៌ដែលសាស្តាសំដែង ប្រកាន់គណៈ ប្រកាន់ទិដ្ឋិ ប្រកាន់សេចក្តីប្រតិបត្តិ ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់ នូវមគ្គ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់ផង ប្រកាន់ផងនូវធម៌ ។ ហេតុនោះ ព្រះមានព្រះភាគ សំដែងថា

ការជាប់ចំពាក់ដោយទិដ្ឋិ និងការជ្រើសរើស ក្នុងធម៌ទាំង
ឡាយ ហើយប្រកាន់ បុគ្គលមិនងាយប្រព្រឹត្តកន្លងបានទេ
ព្រោះហេតុនោះ ទើបជន រមែងលះបង់ផង ប្រកាន់ផង
នូវធម៌ ក្នុងការជាប់ចំពាក់ទាំងនោះ ។

(១០០) ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ
បកប្បិតា ទិដ្ឋិ ភវាភវេសុ
មាយញ្ច មានញ្ច បហាយ ធោនោ
ស កេន គច្ឆេយ្យ អនូបយោ សោ ។

(១០១) ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ បកប្បិតា ទិដ្ឋិ ភវាភវេសូតិ ធោនោតិ ធោនា វុច្ចតិ បញ្ញា យា បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ កឹការណា ធោនា វុច្ចតិ បញ្ញា ។ តាយ បញ្ញាយ កាយទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ វចីទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ មនោទុច្ចរិតំ

[១០០] ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកំចាត់ មិនមានទេ បុគ្គលមានប្រាជ្ញាកំចាត់នោះ លះបង់មាយាផង មានះផង តើនឹងលុះដោយកិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបនែប ។

[១០១] អធិប្បាយពាក្យថា ទិដ្ឋិដែលគេកំណត់ហើយ ក្នុងភពតូចធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកំចាត់មិនមានទេ ត្រង់ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់ សេចក្តីថា បញ្ញា លោកហៅថា ប្រាជ្ញាកំចាត់ បានខាងប្រាជ្ញា ការដឹង ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ ការចូលទៅកំណត់ ការចូលទៅកំណត់ចំពោះ ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាស ភាពជាអ្នកល្អិតល្អន់ ភាពជាអ្នករៀនវៃ ការគិត ការត្រិះរិះ បញ្ញាដូចផែនដី បញ្ញាជាគ្រឿងទម្លាយបង់ (នូវកិលេស) បញ្ញាជាគ្រឿងដឹកនាំ ការឃើញច្បាស់ ការដឹងខ្លួន ជន្លួញគឺ (បញ្ញា) ការដឹងច្បាស់ បញ្ញិន្ទ្រិយ កម្លាំងគឺបញ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ សម្មាទិដ្ឋិ ។ ព្រោះហេតុអ្វី បញ្ញាលោកហៅថាប្រាជ្ញាកំចាត់ ។ (ព្រោះថា) ដោយបញ្ញានោះ កាយទុច្ចរិតបុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ វចីទុច្ចរិត បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ។ មនោទុច្ចរិត

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ រាគោ ធុតោ ច ធោតោ ច សន្ធោតោ ច និទ្ធោតោ ច ។ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ តំការណា ធោនា វុច្ចតិ បញ្ញា ។ អថវា សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិ ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ សម្មាសង្កប្បេន មិច្ឆាសង្កប្បោ ធុតោ ច ធោតោ ច សន្ធោតោ ច និទ្ធោតោ ច ។ សម្មាវាចាយ មិច្ឆាវាចា ធុតា ច ។ សម្មាកម្មន្តេន មិច្ឆាកម្មន្តោ ធុតោ ច ។ សម្មាអាជីវេន មិច្ឆាអាជីវោ ធុតោ ច ។ សម្មាវាយាមេន មិច្ឆាវាយាមោ ធុតោ ច ។ សម្មាសតិយា មិច្ឆាសតិ ធុតា ច ។ សម្មាសមាធិនា មិច្ឆាសមាធិ ធុតោ ច ។ សម្មាញាណេន មិច្ឆាញាណំ ធុតញ្ច ។

បុគ្គល កំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ៗ រាគៈ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ៗ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងនូវអកុសលទាំងអស់ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ៗ ព្រោះហេតុនោះ បញ្ញា លោកហៅថា ប្រាជ្ញាកំចាត់ ៗ មួយទៀត មិច្ឆាទិដ្ឋិ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ដោយសម្មាទិដ្ឋិ ៗ មិច្ឆាសង្កប្បៈ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ដោយសម្មាសង្កប្បៈ ៗ មិច្ឆាវាចា បុគ្គលកំចាត់បង់ ដោយសម្មាវាចា ៗ មិច្ឆាកម្មន្តៈ បុគ្គលកំចាត់បង់ ដោយសម្មាកម្មន្តៈ ៗ មិច្ឆាអាជីវៈ បុគ្គលកំចាត់បង់ ដោយសម្មាអាជីវៈ ៗ មិច្ឆាវាយាមៈ បុគ្គល កំចាត់បង់ ដោយសម្មាវាយាមៈ ៗ មិច្ឆាសតិ បុគ្គល កំចាត់បង់ ដោយសម្មាសតិ ៗ មិច្ឆាសមាធិ បុគ្គល កំចាត់បង់ ដោយសម្មាសមាធិ ៗ មិច្ឆាញាណៈ បុគ្គលកំចាត់បង់ ដោយសម្មាញាណៈ ៗ

សម្មាវិមុត្តិយា មិច្ឆាវិមុត្តិ ធុតា ច ធោតា ច សន្ធោ-
តា ច និទ្ធោតា ច ។ អថវា អរិយេន អដ្ឋង្គិកេន
មគ្គេន សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ
ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុ-
សលាភិសង្ខារា ធុតា ច ធោតា ច សន្ធោតា ច
និទ្ធោតា ច ។ អរហា ឥមេហិ ធោនេយ្យេហិ
ធម្មេហិ ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ
ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា អរហា
ធោនោ ។ សោ ធុតរាគោ ធុតទោសោ ធុតមោហោ ធុតកិ-
លេសោ ធុតបរិឡាហោតិ ធោនោ ។ កុហិញ្ចីតិ
កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា
អជ្ឈត្តពហិទ្ធា វា ។ លោកេតិ អបាយលោកេ
។បេ។ អាយតនលោកេ ។ បកប្បនាតិ ទ្វេ បកប្បនា
តណ្ហាបកប្បនា ច ទិដ្ឋិបកប្បនា ច ។បេ។ អយំ
តណ្ហាបកប្បនា ។បេ។ អយំ ទិដ្ឋិបកប្បនា ។
ភវាភវេសូតិ ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ

មិច្ឆាវិមុត្តិ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ដោយសម្មាវិមុត្តិ ។ មួយទៀត កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ បុគ្គលកំចាត់បង់ លាង លាងដោយល្អ លាងជំរះហើយ ដោយអរិយមគ្គមានអង្គ ៨ ។ ព្រះអរហន្ត ផ្តេកផ្តិត មូលមិត្រ បួលទៅជិត អែបនែប បួលទៅដល់ កើតឡើង ព្រម ប្រកបដោយគុណធម៌ទាំងឡាយ ជាគ្រឿងកំចាត់បង់នេះ ព្រោះហេតុនោះ ព្រះអរហន្ត ឈ្មោះថា អ្នកមានប្រាជ្ញាកំចាត់ ។ ព្រះអរហន្តនោះមានរាគៈកំចាត់ហើយ មានបាបកំចាត់ហើយ មានកិលេសកំចាត់ហើយ មានសេចក្តីអន្ទះអន្ទែងកំចាត់ហើយ ព្រោះហេតុនោះ ឈ្មោះថា អ្នកមានប្រាជ្ញាកំចាត់ ។ ពាក្យថា ណាមួយ គឺនមួយ ណានមួយ ណាក៏ដោយ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ។ ពាក្យថា កិរិយាកំណត់ បានដល់កិរិយាកំណត់ ២ យ៉ាង គឺ កិរិយាកំណត់គឺតណ្ហា ១ កិរិយាកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះឈ្មោះថា កិរិយាកំណត់គឺតណ្ហា ។ បេ ។ នេះឈ្មោះថា កិរិយាកំណត់គឺទិដ្ឋិ ។ ពាក្យថា ក្នុងភពតូចភពធំ បានដល់ ក្នុងកម្មភព បុនព្ភព ឈ្មោះថា ភពតូចភពធំ គឺក្នុងកាមភព កម្មភព

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

កម្មភវោ កាមភវោ បុនព្ភវោ រូបភវោ កម្មភវោ រូបភវោ បុនព្ភវោ អរូបភវោ កម្មភវោ អរូបភវោ បុនព្ភវោ បុនប្បុនំ ភវោ បុនប្បុនំ គតិយោ បុនប្បុនំ ឧបបត្តិយោ បុនប្បុនំ បដិសន្ធិយោ បុនប្បុនំ អត្តភាវាភិនិព្វត្តិយោ ។ ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ បកប្បិតា ទិដ្ឋិ ភវាភវេសូតិ ធោនស្ស កុហិញ្ចិ លោកេ ភវាភវេសុ ច កប្បិតា បកប្បិតា អភិសង្ខតា សណ្ឋបិតា ទិដ្ឋិ នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិបស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ បកប្បិតា ទិដ្ឋិ ភវាភវេសុ ។

(១០២) មាយញ្ច មានញ្ច បហាយ ធោនោតិ មាយា វុច្ចតិ វញ្ចនិកា ចរិយា ។ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា តស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ មា មំ ជញ្ញាតិ ឥច្ឆតិ មា មំ ជញ្ញាតិ សង្កប្បេតិ មា មំ ជញ្ញាតិ វាចំ ភាសតិ មា មំ ជញ្ញាតិ កាយេន បរក្កមតិ ។

ក្នុងកាមភព បុនព្ភព ក្នុងរូបភព កម្មភព ក្នុងរូបភព បុនព្ភព ក្នុងអរូប-ភព កម្មភព ក្នុងអរូបភព បុនព្ភព គឺថាក្នុងការកើតរឿយ ៗ ការប្រព្រឹត្តទៅរឿយ ៗ ការកើតរឿយ ៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាពឲ្យកើតរឿយៗ ។ ពាក្យថា ទិដ្ឋិដែលគេកំណត់ហើយ ក្នុងភពតូចភពធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកំចាត់ មិនមានទេ សេចក្តីថា ទិដ្ឋិដែលតែងតាំង បង្កើត តាក់តែង តម្កល់ទុកក្នុងភពតូចភពធំក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកំចាត់ មិនមាន ឥតមាន គ្មាន មិនកើតមាន គឺលោកលះបង់ ផ្តាច់បង់ រម្ងាប់ ស្ងប់អស់ហើយ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ទិដ្ឋិដែលគេកំណត់ ក្នុងភពតូចភពធំ ក្នុងលោកណាមួយ នៃបុគ្គលមានប្រាជ្ញាកំចាត់ មិនមានទេ ។

(១០២) ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់នោះ លះបង់ មាយាផង មានះផង អធិប្បាយថា ការប្រព្រឹត្តបញ្ឆោត លោកហៅថា មាយា ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងទុកនូវសេចក្តីប្រាថ្នា ដ៏លាមក ព្រោះហេតុនៃការបិទបាំងនូវទុច្ចរិតនោះ គឺ ប្រាថ្នាថា សូមកុំឲ្យជនដឹងអញ ត្រិះរិះថា សូមកុំឲ្យជនដឹងអញ ពោលវាចាថា សូមកុំឲ្យជនដឹងអញ ព្យាយាមដោយកាយថា សូមកុំឲ្យជនដឹងអញ ។

យា ឯវរូបា មាយា មាយាវិតា អច្ចសរា វញ្ចនា និកតិ និកិរណា បរិហរណា គុហនា បរិគុហនា ឆាទនា បរិច្ឆាទនា អនុត្តានីកម្មំ អនាវិកម្មំ វោច្ឆាទនា បាបកិរិយា អយំ វុច្ចតិ មាយា ។

មានោតិ ឯកវិធេន មានោ យា ចិត្តស្ស ឧណ្ណតិ ។ ទុវិធេន មានោ អត្តុក្កំសនមានោ បរវម្ភនមានោ ។ តិវិធេន មានោ សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ ។ ចតុព្វិធេន មានោ លាភេន មានំ ជនេតិ យសេន មានំ ជនេតិ បសំសាយ មានំ ជនេតិ សុខេន មានំ ជនេតិ ។ បញ្ចវិធេន មានោ លាភិម្ហិ មនាបិកានំ រូបានន្តិ មានំ ជនេតិ លាភិម្ហិ មនាបិកានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានន្តិ មានំ ជនេតិ ។ ឆព្វិធេន មានោ ចក្ខុសម្បទាយ មានំ ជនេតិ សោតសម្បទាយ មានំ ជនេតិ ឃានសម្បទាយ

មាយា ភាពនៃមាយា ការនិយាយលើស ការបញ្ឆោត ការបោកប្រាស ការលាក់កន្ទុច ការលួចគិត ការលាក់ពុត ការលាក់ទោសខ្លួន ការបិទបាំងមារយាទ ការបិទបាំងជិតស្និទ្ធ អំពើមិនពាក់ អំពើមិនប្រាកដ ការបំបាំងទោសដោយប្រួល កិរិយាអាក្រក់ ណា មានសភាពយ៉ាងនេះ នេះលោកហៅថា មាយា ។

ពាក្យថា មានះ អធិប្បាយថា មានះ ដោយចំណែកមួយ គឺការក្រអឺតក្រអោងនៃចិត្ត ។ មានះដោយចំណែក ២ គឺ សេចក្តីប្រកាន់ដោយការលើកខ្លួន សេចក្តីប្រកាន់ដោយការបន្តុះបង្អាប់អ្នកដទៃ ។ មានះដោយចំណែក ៣ គឺ ការប្រកាន់ថា អញជាមនុស្សប្រសើរ ការប្រកាន់ថា អញជាមនុស្សស្មើ ការប្រកាន់ថា អញជាមនុស្សថោកទាប ។ មានះដោយចំណែក ៤ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ញុំាងមានះឲ្យកើត ព្រោះយស ញុំាងមានះឲ្យកើត ព្រោះបសំសា ញុំាងមានះឲ្យកើត ព្រោះសុខ ។ មានះ ដោយចំណែក ៥ គឺ បុគ្គលញុំាងមានះឲ្យកើតថា អញជាអ្នកបានរូបទាំងឡាយ ជាទីគាប់ចិត្ត ញុំាងមានះឲ្យកើតថា អញជាអ្នកបានសំឡេង ក្លិន រស ផ្សព្វ ទាំងឡាយ ជាទីគាប់ចិត្ត ។ មានះ ដោយចំណែក ៦ គឺ បុគ្គលញុំាងមានះ ឲ្យកើត ព្រោះការបរិបូរដោយចក្ខុ ញុំាងមានះឲ្យកើត ព្រោះការបរិបូរដោយសោតៈ ញុំាងមានះ ឲ្យកើត ព្រោះការបរិបូរ ដោយឃានៈ

ជិវ្ហាសម្ផស្សជាយ កាយសម្ផស្សជាយ មនោសម្ផស្សជាយ
មានំ ជនេតិ ។ សត្តវិធេន មានោ មានោ អតិមានោ
មានាតិមានោ ឱមានោ អធិមានោ អស្មិមានោ
មិច្ឆាមានោ ។ អដ្ឋវិធេន មានោ លាភេន មានំ
ជនេតិ អលាភេន ឱមានំ ជនេតិ យសេន មានំ
ជនេតិ អយសេន ឱមានំ ជនេតិ បសំសាយ មានំ
ជនេតិ និន្ទាយ ឱមានំ ជនេតិ សុខេន មានំ
ជនេតិ ទុក្ខេន ឱមានំ ជនេតិ ។ នវវិធេន មានោ
សេយ្យស្ស សេយ្យោហមស្មីតិ មានោ សេយ្យស្ស
សទិសោហមស្មីតិ មានោ សេយ្យស្ស ហីនោហម-
ស្មីតិ មានោ សទិសស្ស សេយ្យោហមស្មីតិ មានោ
សទិសស្ស សទិសោហមស្មីតិ មានោ សទិសស្ស
ហីនោហមស្មីតិ មានោ ហីនស្ស សេយ្យោហម-
ស្មីតិ មានោ ហីនស្ស សទិសោហមស្មីតិ មានោ

បរិបូរដោយដិដ្ឋ បរិបូរដោយកាយ បរិបូរដោយចិត្ត ។ មានះដោយចំណែក៧ គឺ ការប្រកាន់ (ក្រអឺតក្រអោង) ការមើលងាយ ការប្រកាន់ថាអញប្រសើរជាង ការប្រកាន់ថាថោកទាប ការប្រកាន់ថាមានគុណវិសេសក្នុងខ្លួន ការប្រកាន់ថា អញមាន (ខន្ធគ្រប់គ្រាន់) ការប្រកាន់ខុស ។ មានះដោយចំណែក៨ គឺបុគ្គលញុំាងការក្រអឺតក្រអោងឲ្យកើត ព្រោះលាភៈ ញុំាងការប្រកាន់ថោកទាបឲ្យកើត ព្រោះមិនមានលាភ ញុំាងការក្រអឺតក្រអោងឲ្យកើត ព្រោះយស ញុំាងការប្រកាន់ថោកទាបឲ្យកើត ព្រោះមិនមានយស ញុំាងការក្រអឺតក្រអោងឲ្យកើត ព្រោះបសំសា ញុំាងការប្រកាន់ថោកទាបឲ្យកើត ព្រោះនិន្ទា ញុំាងការក្រអឺតក្រអោងឲ្យកើត ព្រោះសុខ ញុំាងការប្រកាន់ថោកទាបឲ្យកើត ព្រោះទុក្ខ ។ មានះដោយចំណែក៩ គឺបុគ្គលប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរ បុគ្គលប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើ បុគ្គលប្រសើរ មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាប បុគ្គលស្មើ មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរ បុគ្គលស្មើ មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើ បុគ្គលស្មើ មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាប បុគ្គលថោកទាប មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរ បុគ្គលថោកទាប មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើ បុគ្គលថោកទាប

ហីនស្ស ហីនោហមស្មីតិ មានោ ។ ឯកវិធេន មានោ ឥធេកច្ចោ មានំ ជនេតិ ជាតិយា វា គោត្តេន វា កោលបុត្តិកេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា ។ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានោ ។

មាយញ្ច មានញ្ច បហាយ ធោនោតិ មាយញ្ច មានញ្ច បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ មាយញ្ច មានញ្ច បហាយ ធោនោ ។

(១០៣) ស កេន គច្ឆេយ្យ អនូបយោ សោតិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច ។ បេ ។ អយំ តណ្ហូបយោ ។ បេ ។

មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាប ៗ មានះដោយចំណែក ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញាំងមានះ ឲ្យកើត ព្រោះ ជាតិ ព្រោះ គោត្រ ព្រោះភាពនៃខ្លួនជាកូនមានត្រកូល ព្រោះភាពនៃខ្លួនមានសម្បុរល្អ ព្រោះទ្រព្យ ព្រោះការរៀន ព្រោះការងារ ព្រោះសិល្ប-សាស្ត្រ ព្រោះហេតុជាទីតាំងនៃវិជ្ជា ព្រោះសុតៈនឹងបដិភាណៈ ព្រោះវត្ថុណាមួយ ៗ មានះ ការប្រកាន់ ភាពជាអ្នកប្រកាន់ ការក្រអឺតក្រអោង ការតម្កើង ការប្រកាន់ឬកខ្ពស់ដូចទង់ជ័យ ការផ្គងឡើង ភាពនៃចិត្តប្រាថ្នា ដូចជាទង់ ណា មានសភាពយ៉ាងនេះ នេះលោកហៅថា មានះ ។

ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់នោះ លះបង់មាយាផង មានះផង គឺលះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើត នូវមាយានឹងមានះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានប្រាជ្ញាកំចាត់នោះ លះបង់មាយាផង មានះផង ។

(១០៣) អធិប្បាយពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់នោះ គប្បីលុះដោយកិលេស ដូចម្តេចកើត ព្រោះលោកមិនមានការអែបនែប ត្រង់ពាក្យថា ការអែបនែប បានខាងការអែបនែប ២ គឺការអែបនែបគឺតណ្ហា១ ការអែបនែបគឺទិដ្ឋិ១ ។បេ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។បេ។

## តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

អយំ ទិដ្ឋុបយោ ។ តស្ស តណ្ហុបយោ បហីនោ ទិដ្ឋុបយោ បដិនិស្សដ្ឋោ តណ្ហុបយស្ស បហីនត្តា ទិដ្ឋុបយស្ស បដិនិស្សដ្ឋតា អនុបយោ ។ សោ កេន រាគេន គច្ឆេយ្យ កេន ទោសេន គច្ឆេយ្យ កេន មោហេន គច្ឆេយ្យ កេន មានេន គច្ឆេយ្យ កាយ ទិដ្ឋិយា គច្ឆេយ្យ កេន ឧទ្ធច្ចេន គច្ឆេយ្យ កាយ វិចិកិច្ឆាយ គច្ឆេយ្យ កេហិ អនុសយេហិ គច្ឆេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយោ កេន គច្ឆេយ្យ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។

នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ការអែបនែបគឺតណ្ហា រលាស់ចេញនូវការអែបនែបគឺទិដ្ឋិ ឈ្មោះថា អ្នកមិនមានការអែបនែប ព្រោះលះបង់ការអែបនែបគឺតណ្ហាហើយ ព្រោះរលាស់ចេញនូវការអែបនែបគឺទិដ្ឋិហើយ ។ បុគ្គលនោះ គប្បីលុះដោយរាគៈដូចម្ដេច លុះដោយទោសៈដូចម្ដេច លុះដោយមោហៈដូចម្ដេច លុះដោយមានះដូចម្ដេច លុះដោយទិដ្ឋិដូចម្ដេច លុះដោយឧទ្ធច្ចៈដូចម្ដេច លុះដោយវិចិកិច្ឆាដូចម្ដេច លុះដោយអនុសយក្កិលេសទាំងឡាយដូចម្ដេចកើត ថាជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ បុគ្គលមានប្រាជ្ញាកំចាត់លះបង់ហើយ បុគ្គលនោះ គប្បីទៅកាន់គតិទាំងឡាយ ថាជាបុគ្គលទៅកើតក្នុងនរកក្តី ថាទៅកើតក្នុងកំណើតតិរច្ឆានក្តី ថាទៅកើតក្នុងបិត្តិវិស័យក្តី ថាជាមនុស្សក្តី ថាជាទេវតាក្តី ថាមានរូបក្តី ថាមិនមានរូបក្តី ថាមានសញ្ញាក្តី ថាមិនមានសញ្ញាក្តី ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ដោយហេតុដូចម្ដេចកើត ព្រោះអភិសង្ខារទាំងឡាយ លោកលះបង់ហើយ ។

សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន គច្ឆេយ្យាតិ ស កេន គច្ឆេយ្យ អនូបយោ សោ ។ តេនាហ ភគវា

ធោនស្ស ហិ នត្ថិ កុហិញ្ចិ លោកេ
បកប្បិតា ទិដ្ឋិ ភវាភវេសុ
មាយញ្ច មានញ្ច បហាយ ធោនោ
ស កេន គច្ឆេយ្យ អនូបយោ សោតិ ។

(១០៤) ឧបយោ ហិ ធម្មេសុ ឧបេតិ វាទំ
អនូបយំ កេន កថំ វទេយ្យ
អត្តំ និរត្តំ ន ហិ តស្ស អត្ថិ
អធោសិ សោ ទិដ្ឋិមិធេវ សព្វំ ។

(១០៥) ឧបយោ ហិ ធម្មេសុ ឧបេតិ វាទន្តិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច

បុគ្គលមានប្រាជ្ញាកំចាត់ គប្បីទៅដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមានទេ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានប្រាជ្ញាកំចាត់នោះ គប្បីលុះដោយកិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបនែប ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ទិដ្ឋិដែលគេកំណត់ហើយក្នុងភពតូចភពធំ ក្នុងលោកណាមួយ
នៃបុគ្គលមានប្រាជ្ញាកំចាត់ មិនមានទេ បុគ្គលមានប្រាជ្ញា
កំចាត់នោះ លះបង់មាយាផង មានះផង តើនឹងលុះដោយ
កិលេសដូចម្តេចកើត ព្រោះលោកមិនមានការអែបនែប ។

(១០៨) បុគ្គលមានកិលេសជាគ្រឿងអែបនែប រមែងអើពើនឹងវាទៈ
ក្នុងធម៌ទាំងឡាយ ជនគប្បីពោលនូវបុគ្គលមិនមានការអែប
នែប ដោយកិលេសណាដូចម្តេចបាន ព្រោះអត្តទិដ្ឋិ (ការ
ឃើញថាមានខ្លួន) និរត្ថទិដ្ឋិ (ការឃើញថាមិនមានខ្លួន) នៃ
ព្រះអរហន្តនោះមិនមានទេ ព្រះអរហន្តនោះ បានលាងនូវ
ទិដ្ឋិទាំងអស់ ក្នុងលោកនេះហើយ ។

(១០៩) អធិប្បាយពាក្យថា បុគ្គលមានកិលេស ជាគ្រឿងអែបនែប រមែងអើពើនឹងវាទៈ ក្នុងធម៌ទាំងឡាយ ត្រង់ពាក្យថា កិលេសជាគ្រឿងអែបនែប បានខាង ការអែបនែប ២ យ៉ាង គឺ ការអែបនែបគឺតណ្ហា ១

ទិដ្ឋបយោ ច ។ បេ ។ អយំ តណ្ហាបយោ ។ បេ ។
អយំ ទិដ្ឋបយោ ។ តស្ស តណ្ហាបយោ អប្បហីនោ
ទិដ្ឋបយោ អប្បដិនិស្សដ្ឋោ តណ្ហាបយស្ស អប្បហី-
នត្តា ទិដ្ឋបយស្ស អប្បដិនិស្សដ្ឋត្តា ធម្មេសុ ភវំ
ឧបេតិ រត្តាតិ វា ទុដ្ឋាតិ វា មូឡ្ហាតិ វា វិនិពន្ធាតិ
វា បរាមដ្ឋាតិ វា វិក្ខេបគតាតិ វា អនិដ្ឋង្គតាតិ
វា ថាមគតាតិ វា ។ តេ អភិសង្ខារា អប្បហីនា
អភិសង្ខារានំ អប្បហីនត្តា គតិយា ភវំ ឧបេតិ
នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បេត្តិវិសយិ-
កោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា
អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាស-
ញ្ញីតិ វា ភវំ ឧបេតិ ឧបគច្ឆតិ គណ្ហាតិ បរាមសតិ
អភិនិវិសតិ ឧបយោ ហិ ធម្មេសុ ឧបេតិ ភវំ ។

## ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣

ការអែបនែបគឺទិដ្ឋិ ១ ។បេ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។បេ។ នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះ មិនទាន់លះបង់ការអែបនែបគឺតណ្ហា មិនទាន់រលាស់ចោលការអែបនែបគឺទិដ្ឋិ រមែងអើពើនូវវាទៈ ក្នុងធម៌ទាំងឡាយថា ជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ព្រោះការអែបនែបគឺតណ្ហា ខ្លួនមិនទាន់លះបង់ ព្រោះការអែបនែបគឺទិដ្ឋិ ខ្លួនមិនទាន់រលាស់ចេញ ។ អភិសង្ខារទាំងនោះ បុគ្គលមិនទាន់លះបង់ហើយ បុគ្គលរមែងអើពើនូវវាទៈដោយគតិ ព្រោះអភិសង្ខារទាំងឡាយដែលខ្លួនមិនទាន់លះបង់ គឺរមែងដល់ ចូលទៅជិត ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់នូវវាទៈថា ជាអ្នកកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងបិត្តិវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានកិលេសជាគ្រឿងអែបនែប រមែងអើពើនូវវាទៈក្នុងធម៌ទាំងឡាយ ។

(១០៦) អនុបយំ កេន កថំ វទេយ្យាតិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច ។ បេ ។ អយំ តណ្ហូបយោ ។ បេ ។ អយំ ទិដ្ឋូបយោ ។ តស្ស តណ្ហូបយោ បហីនោ ទិដ្ឋូបយោ បដិនិស្សដ្ឋោ តណ្ហូបយស្ស បហីនត្តា ទិដ្ឋូបយស្ស បដិនិស្សដ្ឋត្តា អនុបយំ កេន រាគេន វទេយ្យ កេន ទោសេន វទេយ្យ កេន មោហេន វទេយ្យ កេន មានេន វទេយ្យ កាយ ទិដ្ឋិយា វទេយ្យ កេន ឧទ្ធច្ចេន វទេយ្យ កាយ វិចិកិច្ឆាយ វទេយ្យ កេហិ អនុសយេហិ វទេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយោ កេន វទេយ្យ នេរយិកោតិ វា ។ បេ ។ នេវសញ្ញីនាសញ្ញីតិ វា ។

[១០៦] អធិប្បាយពាក្យថា ជនគប្បីពោលនូវបុគ្គលមិនមានការអែបនែបដោយកិលេសណា ដូចម្តេចបាន ត្រង់ពាក្យថា ការអែបនែប បានដល់ការអែបនែប ២ គឺការអែបនែបគឺតណ្ហា ១ ការអែបនែបគឺទិដ្ឋិ ១ ។ បេ ។ នេះឈ្មោះថា ការអែបនែបគឺតណ្ហា ។ បេ ។ នេះឈ្មោះថា ការអែបនែបគឺទិដ្ឋិ ។ បុគ្គលនោះលះបង់ការអែបនែបគឺតណ្ហា រលាស់ចោលការអែបនែបគឺទិដ្ឋិ ព្រោះការអែបនែបគឺតណ្ហា លោកលះបង់ហើយ ព្រោះការអែបនែបគឺទិដ្ឋិលោករលាស់ចេញហើយ ជនគប្បីពោលនូវបុគ្គលមិនមានកិលេសជាគ្រឿងអែបនែប ដោយរាគៈដូចម្តេច គប្បីពោលដោយទោសៈដូចម្តេច គប្បីពោលដោយមោហៈដូចម្តេច គប្បីពោលដោយមានៈដូចម្តេច គប្បីពោលដោយទិដ្ឋិដូចម្តេច គប្បីពោលដោយឧទ្ធច្ចៈដូចម្តេច គប្បីពោលដោយវិចិកិច្ឆាដូចម្តេច គប្បីពោលដោយអនុស័យទាំងឡាយដូចម្តេច ថាជាអ្នកត្រេកអរក្តី ថាជាអ្នកខឹងក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាបអង្អែលក្តី ថាជាអ្នកដល់នូវការរាយមាយក្តី ថាជាអ្នកដល់នូវការមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ បុគ្គលនោះ លះបង់ហើយ ជនគប្បីពោលនូវគតិទាំងឡាយថា ជាអ្នកកើតក្នុងនរកដូច្នេះក្តី ។ បេ ។ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនដូច្នេះក្តី ដោយហេតុដូចម្តេចបាន ព្រោះអភិសង្ខារទាំងឡាយ លោកលះបង់ហើយ ។

តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ

សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន វទេយ្យ ការេយ្យ ភណេយ្យ ទីបយេយ្យ វោហរេយ្យាតិ អនូបយំ កេន កថំ វទេយ្យ ។

(១០៧) អត្តំ និរត្តំ ន ហិ តស្ស អត្ថីតិ អត្តាតិ សស្សតទិដ្ឋិ នត្ថិ និរត្តាតិ ឧច្ឆេទទិដ្ឋិ នត្ថិ អត្តាតិ គហិតំ នត្ថិ និរត្តាតិ មុញ្ចិតព្វំ នត្ថិ ។ យស្សត្ថិ គហិតំ តស្សត្ថិ មុញ្ចិតព្វំ យស្សត្ថិ មុញ្ចិតព្វំ តស្សត្ថិ គហិតំ ។ គហណមុញ្ចនំ សមតិក្កន្តោ អរហា វុឌ្ឍិបរិហានិវីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។បេ។ នត្ថិ តស្ស បុនព្ភវោតិ អត្តំ និរត្តំ ន ហិ តស្ស អត្ថិ ។

(១០៨) អធោសិ សោ ទិដ្ឋិមិធេវ សព្វន្តិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ

ជនគប្បីពោល សំដែង និយាយ បំភ្លឺ បញ្ចេញ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ជនគប្បីពោល នូវបុគ្គលមិនមានការអែបនែប ដោយកិលេសណា ដូចម្ដេចបាន ។

(១០៧) អធិប្បាយពាក្យថា អត្តទិដ្ឋិនិងនិរត្តទិដ្ឋិ នៃបុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា អត្តទិដ្ឋិ គឺសស្សតទិដ្ឋិ មិនមាន ពាក្យថា និរត្តទិដ្ឋិ គឺឧច្ឆេទទិដ្ឋិ ក៏មិនមាន បានសេចក្ដីថា ការប្រកាន់ថាខ្លួន មិនមាន ការគួរដោះថាមិនមែនខ្លួន ក៏មិនមាន ។ ការប្រកាន់របស់បុគ្គលណាមាន ការគួរដោះរបស់បុគ្គលនោះក៏មាន ការគួរដោះរបស់បុគ្គលណាមាន ការប្រកាន់របស់បុគ្គលនោះក៏មាន ។ ព្រះអរហន្ត កន្លងផុតការប្រកាន់ និងការដោះ ហើយប្រព្រឹត្តកន្លងនូវសេចក្ដីចំរើននិងសេចក្ដីវិនាស ។ ព្រះអរហន្តនោះ មានព្រហ្មចរិយៈនៅហើយ មានធម៌ជាគ្រឿងប្រព្រឹត្ត ប្រព្រឹត្តហើយ ។ បេ ។ ព្រះអរហន្តនោះ មិនមានភពថ្មីទៀតទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អត្តទិដ្ឋិ (ការឃើញថាមានខ្លួន) និរត្តទិដ្ឋិ (ការឃើញថាមិនមានខ្លួន) នៃបុគ្គលនោះ មិនមានទេ ។

(១០៨) ពាក្យថា បុគ្គលនោះបានលាងនូវទិដ្ឋិទាំងអស់ ក្នុងលោកនេះហើយ សេចក្ដីថា ទិដ្ឋិទាំង ៦២ បុគ្គលនោះ លះបង់ ផ្ដាច់ផ្ដិល

ឧបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណា-គ្គិនា ទឌ្ឍានិ ។ សោ សព្វំ ទិដ្ឋិគតំ ឥធេវ អធោសិ ធុនិ សន្ធុនិ និទ្ធុនិ បជហិ វិនោទេសិ ព្យន្តីអកាសិ អនភាវង្គមេសីតិ អធោសិ សោ ទិដ្ឋិមិធេវ សព្វំ ។

តេនាហ ភគវា

ឧបយោ ហិ ធម្មេសុ ឧបេតិ វាទំ
អនូបយំ កេន កថំ វទេយ្យ
អត្តំ និរត្តំ ន ហិ តស្ស អត្ថិ
អធោសិ សោ ទិដ្ឋិមិធេវ សព្វន្តិ ។

តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរដល់ការកើតទៀត ដុតដោយភ្លើងគឺញាណហើយ ។ បុគ្គលនោះ បានលះ កំចាត់បង់ កំចាត់ដាច់ស្រឡះ កំចាត់ដោយមិនសល់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវទិដ្ឋិទាំងអស់ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ បានលះនូវទិដ្ឋិទាំងអស់ ក្នុងលោកនេះហើយ ។ ហេតុនោះព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមានកិលេសជាគ្រឿងអែបអប រមែងអើពើនូវវាទៈ
ក្នុងធម៌ទាំងឡាយ ជនគប្បីពោល នូវបុគ្គលមិនមានការអែប
អប ដោយកិលេសណាដូចម្តេចបាន ព្រោះអត្តទិដ្ឋិ (ការ
ឃើញថាមានខ្លួន) និរត្តទិដ្ឋិ (ការឃើញថាមិនមានខ្លួន)
នៃបុគ្គលនោះ មិនមានទេ បុគ្គលនោះបានលះនូវទិដ្ឋិ
ទាំងអស់ ក្នុងលោកនេះហើយ ។

ចប់ ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣ ។

# ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

[១០៩] បស្សាមិ សុទ្ធំ បរមំ អរោគំ
ទិដ្ឋេន សំសុទ្ធិ នរស្ស ហោតិ
ឯតាភិជានំ បរមន្តិ ញត្វា
សុទ្ធានុបស្សីតិ បច្ចេតិ ញាណំ ។

[១១០] បស្សាមិ សុទ្ធំ បរមំ អរោគន្តិ បស្សាមិ សុទ្ធន្តិ បស្សាមិ សុទ្ធំ ទក្ខាមិ សុទ្ធំ ឱលោកេមិ សុទ្ធំ និជ្ឈាយាមិ សុទ្ធំ ឧបបរិក្ខាមិ សុទ្ធំ ។ បរមំ អរោគន្តិ បរមំ អារោគ្យប្បត្តំ ខេមប្បត្តំ តាណប្បត្តំ លេណប្បត្តំ សរណប្បត្តំ បរាយនប្បត្តំ អភយប្បត្តំ អច្ចុតប្បត្តំ អមតប្បត្តំ និព្វានប្បត្តន្តិ បស្សាមិ សុទ្ធំ បរមំ អរោគំ ។

# សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

(១០៩) (ព្រះមានព្រះភាគត្រាស់ថា) អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ សេចក្តីបរិសុទ្ធិ ដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូប ដែលខ្លួនឃើញ បុគ្គលពាល អ្នកឃើញរឿយៗ នូវការបរិសុទ្ធិ កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ) ឧត្តម ហើយជឿនូវការឃើញនោះ ថាជាញាណ ។

(១១០) អធិប្បាយពាក្យថា អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ ត្រង់ពាក្យថា អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ គឺ អាត្មាអញឃើញ (រូប) បរិសុទ្ធ មើល (រូប) បរិសុទ្ធ ក្រឡេកមើល (រូប) បរិសុទ្ធ សម្លឹងមើល (រូប) បរិសុទ្ធ សង្កេតមើល (រូប) បរិសុទ្ធ ។ ពាក្យថា ឧត្តម មិនមានរោគ គឺឧត្តម ដល់នូវភាពមិនមានរោគ ដល់នូវសេចក្តីក្សេម ដល់នូវទីជ្រក ដល់នូវទីពឹងពំនាក់ ដល់នូវទីរលឹក ដល់នូវការប្រព្រឹត្តទៅខាងមុខ ដល់នូវការមិនមានភ័យ ដល់នូវភាពទៀងទាត់ ដល់នូវអមតៈ ដល់នូវភាព ប្រាសចាកតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញឃើញ (នូវរូប) បរិសុទ្ធ ឧត្តម មិនមានរោគ ។

(១១១) ទិដ្ឋេន សំសុទ្ធិ នរស្ស ហោតីតិ ចក្ខុវិញ្ញាណេន រូបទស្សនេន នរស្ស សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ ហោតិ នរោ សុជ្ឈតិ វិសុជ្ឈតិ បរិសុជ្ឈតិ មុច្ចតិ វិមុច្ចតិ បរិមុច្ចតីតិ ទិដ្ឋេន សំសុទ្ធិ នរស្ស ហោតិ ។

(១១២) ឯតាភិជានំ បរមន្តិ ញត្វាតិ ឯវំ អភិជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតាភិជានំ បរមន្តិ ញត្វា ។

(១១៣) សុទ្ធានុបស្សីតិ បច្ចេតិ ញាណន្តិ យោ សុទ្ធំ បស្សតិ សោ សុទ្ធានុបស្សី ។ បច្ចេតិ ញាណន្តិ ចក្ខុវិញ្ញាណំ រូបទស្សនំ ញាណន្តិ បច្ចេតិ មគ្គោតិ

(១១១) ពាក្យថា សេចក្តីបរិសុទ្ធិដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូប ដែលខ្លួនឃើញ សេចក្តីថា សេចក្តីស្អាត សេចក្តីស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ របស់នរជន រមែងកើតមាន បុរជន ស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីបរិសុទ្ធិ ដ៏ប្រពៃ របស់នរជន រមែងកើតមាន ដោយសាររូប ដែលខ្លួនឃើញ ។

(១១២) ពាក្យថា បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ) ឧត្តម គឺកាលដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ចាក់ធ្លុះចំពោះយ៉ាងនេះ រមែងយល់ ដឹង ថ្លឹងមើល ពិចារណាឃើញ យល់ច្បាស់ ធ្វើឲ្យប្រាកដថា ការឃើញនេះថ្លៃថ្នូ លើសលុប ប្រសើរ ប្រសើរវិសេស បវរ ឧត្តម ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពាលកាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញនេះ) ឧត្តម ។

(១១៣) ពាក្យថា អ្នកឃើញហើយ ៗ នូវការបរិសុទ្ធិ រមែងជឿ (នូវការឃើញនោះ) ថាជាញាណ សេចក្តីថា បុគ្គលណា ឃើញនូវសេចក្តីបរិសុទ្ធិ បុគ្គលនោះឈ្មោះថា អ្នកឃើញហើយ ៗ នូវសេចក្តីបរិសុទ្ធិ ៗ ពាក្យថា ជឿ (នូវការឃើញនោះ) ថាជាញាណ គឺជឿនូវការឃើញរូប ដោយចក្ខុវិញ្ញាណ ថាជាញាណ ជឿថាជាមគ្គ

បច្ចេតិ បដោតិ បច្ចេតិ និយ្យាតេន្តិ បច្ចេតីតិ សុទ្ធានុបស្សីតិ បច្ចេតិ ញាណំ ។ តេនាហ ភគវា

បស្សាមិ សុទ្ធំ បរមំ អរោគំ
ទិដ្ឋេន សំសុទ្ធិ នរស្ស ហោតិ
ឯតាភិជានំ បរមន្តិ ញត្វា
សុទ្ធានុបស្សីតិ បច្ចេតិ ញាណន្តិ ។

(១១៤) ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតិ
ញាណេន វា សោ បជហាតិ ទុក្ខំ
អញ្ញេន សោ សុជ្ឈតិ សោបធីកោ
ទិដ្ឋី ហិ នំ បាវ តថា វទានំ ។

(១១៥) ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតីតិ ចក្ខុវិញ្ញាណេន រូបទស្សនេន ចេ នរស្ស សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ ហោតិ នរោ សុជ្ឈតិ វិសុជ្ឈតិ បរិសុជ្ឈតិ មុច្ចតិ វិមុច្ចតិ បរិមុច្ចតីតិ ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតិ ។

ជឿថាជាផ្លូវ ជឿថាជាគ្រឿងដឹកនាំ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឃើញរឿយ ៗ នូវសេចក្តីបរិសុទ្ធិ ជឿ (នូវការឃើញនោះ) ថាជាញាណ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អាត្មាអញឃើញ (នូវរូប) ដ៏បរិសុទ្ធ ឧត្តម មិនមានរោគ
សេចក្តីបរិសុទ្ធិ ដ៏ប្រពៃ របស់នរជន រមែងមាន ដោយសារ
(រូប) ដែលខ្លួនឃើញ បុគ្គលពាលអ្នកឃើញរឿយៗ នូវការ
បរិសុទ្ធិ កាលដឹងច្បាស់យ៉ាងនេះ រមែងយល់ថា (ការឃើញ
នេះ) ឧត្តម ហើយជឿ (នូវការឃើញនោះ) ថាជាញាណ ៗ

(១១៨) បើសេចក្តីបរិសុទ្ធិ របស់នរជន កើតមាន ដោយសាររូបដែលខ្លួនឃើញ ឬនរជននោះលះបង់ទុក្ខ គឺរូបពាកទុក្ខ ដោយសារញាណបាន នរជនអ្នកមានឧបធិក្កិលេសនោះ ឈ្មោះថាបរិសុទ្ធ ដោយផ្លូវដទៃ ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ ៗ

(១១៩) ពាក្យថា បើសេចក្តីបរិសុទ្ធិ របស់នរជនកើតមាន ដោយសាររូប ដែលខ្លួនឃើញ គឺសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតដោយជុំវិញ របស់នរជន កើតមាន ឬនរជនស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) បើសេចក្តីបរិសុទ្ធិ របស់នរជន កើតមាន ដោយសាររូប ដែលខ្លួនឃើញ ៗ

(១១៦) ញាណេន វា សោ បជហាតិ ទុក្ខន្តិ ចក្ខុវិញ្ញាណេន រូបទស្សនេន ចេ នរោ ជាតិទុក្ខំ បជហាតិ ជរាទុក្ខំ បជហាតិ ព្យាធិទុក្ខំ បជហាតិ មរណទុក្ខំ បជហាតិ សោកបរិទេវទុក្ខទោមនស្សុ-បាយាសទុក្ខំ បជហាតីតិ ញាណេន វា សោ បជហាតិ ទុក្ខំ ។

(១១៧) អញ្ញេន សោ សុជ្ឈតិ សោបធីកោតិ អញ្ញេន អសុទ្ធិមគ្គេន មិច្ឆាបដិបទាយ អនិយ្យានប-ថេន អញ្ញត្រ សតិបដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិ-កា មគ្គា នរោ សុជ្ឈតិ វិសុជ្ឈតិ បរិសុជ្ឈតិ មុច្ចតិ វិមុច្ចតិ បរិមុច្ចតិ ។ សោបធីកោតិ សរាគោ សទោសោ សមោហោ សមានោ សតណ្ហោ សទិដ្ឋិ សកិលេសោ សឧបាទានោតិ អញ្ញេន សោ សុជ្ឈតិ សោបធីកោ ។

(១១៦) ពាក្យថា ឬនរជននោះ លះបង់ទុក្ខដោយសារញាណបាន គឺបើនរជន លះបង់ជាតិទុក្ខ លះបង់ជរាទុក្ខ លះបង់ព្យាធិទុក្ខ លះបង់មរណទុក្ខ លះបង់សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ ដោយសារការឃើញរូប ដោយចក្ខុវិញ្ញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) ឬនរជននោះ លះបង់ទុក្ខ គឺរួបហាកទុក្ខ ដោយសារញាណបាន ។

(១១៧) ពាក្យថា នរជនអ្នកមានឧបធិក្កិលេសនោះ ឈ្មោះថាបរិសុទ្ធ ដោយផ្លូវដទៃ សេចក្តីថា នរជនរមែងស្អាត ស្អាតវិសេស បរិសុទ្ធ ផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយផ្លូវមិនបរិសុទ្ធដទៃ ដោយបដិបទាខុស ដោយគន្លងមិនមែនជាទីដឹកនាំ ក្រៅអំពីសតិប្បដ្ឋាន ក្រៅអំពីសម្មប្បធាន ក្រៅអំពីឥទ្ធិបាទ ក្រៅអំពីឥន្ទ្រិយ ក្រៅអំពីពលៈ ក្រៅអំពីពោជ្ឈង្គ ក្រៅអំពីអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ពាក្យថា មានឧបធិក្កិលេស គឺប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានះ ប្រកបដោយតណ្ហា ប្រកបដោយទិដ្ឋិ ប្រកបដោយកិលេស ប្រកបដោយឧបាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនអ្នកមានឧបធិក្កិលេសនោះ ឈ្មោះថា បរិសុទ្ធ ដោយផ្លូវដទៃ ។

## ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

(២១៨) ទិដ្ឋី ហិ នំ បាវ តថា វទានន្តិ សាវ ទិដ្ឋិ តំ បុគ្គលំ បាវទតិ ឥតិ អយំ បុគ្គលោ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោតិ ។ តថា វទានន្តិ តថា វទន្តំ កថេន្តំ ភណន្តំ ទីបយន្តំ វោហរន្តំ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ តថា វទន្តំ កថេន្តំ ភណន្តំ ទីបយន្តំ វោហរន្តំ អសស្សតោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ តថា វទន្តំ កថេន្តំ ភណន្តំ ទីបយន្តំ វោហរន្តន្តិ ទិដ្ឋី ហិ នំ បាវ តថា វទានំ ។ តេនាហ ភគវា

ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតិ<br>
ញាណេន វា សោ បជហាតិ ទុក្ខំ<br>
អញ្ញេន សោ សុជ្ឈតិ សោបធីកោ<br>
ទិដ្ឋី ហិ នំ បាវ តថា វទានន្តិ ។

(១១៨) ពាក្យថា ព្រោះថាទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ សេចក្ដីថា ទិដ្ឋិនោះឯង រមែងប្រាប់បុគ្គលនោះដូច្នេះថា បុគ្គលនេះជាមិច្ឆាទិដ្ឋិ មានសេចក្ដីយល់ផ្ទុយ ។ ពាក្យថា ពោលដូច្នោះ គឺពោលថ្លែង ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះ គឺពោលថ្លែង ពណ៌នា ពន្យល់ ពោលប្រកាន់ដោយប្រការដូច្នោះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោលថ្លែង ពណ៌នា ពន្យល់ ពោលប្រកាន់ ដោយប្រការដូច្នោះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វស្លាប់ហើយ កើតទៀត សត្វស្លាប់ហើយ មិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ទិដ្ឋិរមែងប្រាប់នូវបុគ្គល អ្នកពោលដូច្នោះនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បើសេចក្ដីបរិសុទ្ធិ របស់នរជន កើតមាន ដោយសាររូប
ដែលខ្លួនឃើញ ឬនរជននោះ លះបង់ទុក្ខដោយញាណបាន
នរជនអ្នកមានឧបធិក្កិលេសនោះ រមែងបរិសុទ្ធ ដោយផ្លូវដទៃ
ព្រោះថា ទិដ្ឋិរមែងប្រាប់ នូវបុគ្គលអ្នកពោលដូច្នោះនោះ ។

(១១៩) ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
បុញ្ញេ ច បាបេ ច អនូបលិត្តោ
អត្តញ្ជហោ នយិធ បកុព្វមានោ ។

(១២០) ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ ទិដ្ឋេ សុតេ សីលវតេ មុតេវាតិ នាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្វតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ ទោសោ ពាហិតោ ហោតិ មោហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ។ ពាហិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

ពាហេត្វា សព្វបាបកានិ (សភិយាតិ ភគវា)
វិមលោ សាធុសមាហិតោ ឋិតត្តោ

(១១៩) ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញ ឬព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ដែលប៉ះពាល់ឡើយ ទាំងជាអ្នកមិនជាប់នៅ ក្នុងបុណ្យនិងបាប ជាអ្នកលះបង់នូវអត្តា ជាអ្នកលែងធ្វើ ក្នុងលោកនេះ ។

(១២០) អធិប្បាយពាក្យថា ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះផ្លូវដទៃ ព្រោះអារម្មណ៍ដែលខ្លួនឃើញ ឬព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ ដែលប៉ះពាល់ឡើយ ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ នូវធម៌ ៧ គឺ ជាអ្នកបន្សាត់បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាសៈ បន្សាត់បង់រាគៈ បន្សាត់បង់ទោសៈ បន្សាត់បង់មោហៈ បន្សាត់បង់មានៈ ។ លោកបន្សាត់បង់អកុសលធម៌ទាំងឡាយដ៏លាមក ជាធម៌ប្រកបដោយសេចក្តីសៅហ្មងព្រម មានកិរិយានាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ ជាបច្ច័យរបស់ជាតិ ជរា និងមរណៈតទៅទៀត ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា ដែលបន្សាត់ចោល នូវធម៌ដ៏លាមកទាំងពួង ជាអ្នកមាន មន្ទិលទៅប្រាសហើយ មានចិត្តតាំងមាំ ដោយប្រពៃ

## បតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

សំសារមតិច្ច កេវលី សោ
អនិស្សិតោ តាទិ បវុច្ចតេ ស ព្រហ្មា ។

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហាតិ ព្រាហ្មណោ អញ្ញេន អសុទ្ធិមគ្គេន មិច្ឆាបដិបទាយ អនិយ្យានបថេន អញ្ញត្រ សតិបដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិកា មគ្គា សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតីតិ ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ ។ ទិដ្ឋេ សុតេ សីលវតេ មុតេ វាតិ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិសុទ្ធិកា តេ ឯកច្ចានំ រូបានំ ទស្សនំ មង្គលំ បច្ចេន្តិ ឯកច្ចានំ រូបានំ ទស្សនំ អមង្គលំ បច្ចេន្តិ ។

មានចិត្តទឹងទឹង កន្លងហើយនូវសំសារ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានកិច្ច សម្រេចអស់ហើយ ជាអ្នកមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា ព្រាហ្មណ៍ មិនពោលនូវសេចក្ដីបរិសុទ្ធិ ព្រោះផ្លូវដទៃ គឺ ព្រាហ្មណ៍ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនពោលប្រកាន់ នូវសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធិ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយផ្លូវមិនបរិសុទ្ធិដទៃ ដោយមិច្ឆាបដិបទា ដោយគន្លងមិនជាទីដឹកនាំ ក្រៅចាកសតិប្បដ្ឋាន ក្រៅចាកសម្មប្បធាន ក្រៅចាកឥទ្ធិបាទ ក្រៅចាកឥន្ទ្រិយ ក្រៅចាកពលៈ ក្រៅចាកពោជ្ឈង្គៈ ក្រៅចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ មិនពោលនូវសេចក្ដីបរិសុទ្ធិ ព្រោះផ្លូវដទៃ ។

ពាក្យថា ព្រោះអារម្មណ៍ដែលខ្លួនឃើញ ឬឮ ព្រោះសីលនិងវត្ត ឬព្រោះអារម្មណ៍ដែលប៉ះពាល់ទៀត សេចក្ដីថា មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្ដីបរិសុទ្ធិដោយសាររូប ដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឃើញរូបទាំងឡាយខ្លះ ថាជាមង្គល ជឿនូវការឃើញរូបទាំងឡាយខ្លះ ថាមិនមែនជាមង្គល ។

កថមេសំ រូបានំ ទស្សនំ មង្គលំ បច្ចេន្តិ ។ តេ កាលតោ វុដ្ឋហិត្វា អភិមង្គលគតានិ រូបានិ បស្សន្តិ ចាតកសកុណំ(១) បស្សន្តិ ផុស្សវេឡុវលដ្ឋឹ បស្សន្តិ គព្ភិនិត្ថឹ បស្សន្តិ កុមារកំ ខន្ធេ អារោបេត្វា គច្ឆន្តំ បស្សន្តិ បុណ្ណឃដំ បស្សន្តិ រោហិតមច្ឆំ បស្សន្តិ អាជញ្ញំ បស្សន្តិ អាជញ្ញរថំ បស្សន្តិ ឧសភំ បស្សន្តិ គោកបិលំ បស្សន្តិ ឯវរូបានំ រូបានំ ទស្សនំ មង្គលំ បច្ចេន្តិ ។

កថមេសំ រូបានំ ទស្សនំ អមង្គលំ បច្ចេន្តិ ។ បលាលបុញ្ជំ បស្សន្តិ តក្កឃដំ បស្សន្តិ រិត្តឃដំ បស្សន្តិ នដំ បស្សន្តិ នគ្គសមណំ បស្សន្តិ ខរំ បស្សន្តិ ខរយានំ បស្សន្តិ ឯកយុត្តយានំ បស្សន្តិ កាណំ បស្សន្តិ កុណឹ បស្សន្តិ ខញ្ជំ បស្សន្តិ បក្ខហតំ(២) បស្សន្តិ ជិណ្ណកំ បស្សន្តិ ព្យាធិកំ បស្សន្តិ មតំ បស្សន្តិ ឯវរូបានំ រូបានំ ទស្សនំ អមង្គលំ បច្ចេន្តិ ។

---

១ ម. ចាបសកុណំ ។ ២ ម. បក្ខហតំ ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿនូវការឃើញរូបទាំងឡាយដូចម្តេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើងអំពីព្រលឹម ឃើញនូវរូបទាំងឡាយ ដែលសម្មតថាជាមង្គលដ៏ក្រៃលែង គឺឃើញសត្វត្រចៀកកាំ ឃើញដើមល្ពៅដែលដុះ ដោយបុស្សនក្ខត្តឫក្ស ឃើញស្ត្រីមានគភ៌ ឃើញបុគ្គលកំពុងបញ្ជិះនាងកុមារិកាលើ-ក ដើរទៅ ឃើញក្អមមានទឹកពេញ ឃើញត្រីឆ្ពិន ឃើញសេះអាជានេយ្យ ឃើញរថដែលទឹម ដោយសេះអាជានេយ្យ ឃើញគោឧសភ ឃើញមេគោក្រហម គឺប្រកាន់ជឿនូវការឃើញរូបទាំងឡាយ មានសភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ ជឿនូវការឃើញរូបទាំងឡាយដូចម្តេច ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ ទាំងនោះ ឃើញគំនរចំបើង ឃើញឆ្នាំងខ្លាញ់ ឃើញឆ្នាំងទទេ ឃើញស្ត្រីរបាំ ឃើញស្រមណ៍អាក្រាត ឃើញលា ឃើញយាន ដែលទឹមដោយលា ឃើញយាន ដែលទឹមដោយសត្វពាហនៈម្ខាង ឃើញមនុស្សខ្វាក់ ឃើញមនុស្សកែង ឃើញមនុស្សខ្ញក ឃើញមនុស្សខ្វិន ឃើញមនុស្សជរា ឃើញមនុស្សឈឺ ឃើញមនុស្សស្លាប់ គឺប្រកាន់ជឿនូវការឃើញរូបទាំងឡាយ មានសភាពយ៉ាងនេះ ថាមិនមែនជាមង្គល ។

ឥមេ តេ សមណព្រាហ្មណា ទិដ្ឋិសុទ្ធិកា តេ ទិដ្ឋេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា សុតសុទ្ធិកា តេ ឯកច្ចានំ សទ្ទានំ សវនំ មង្គលំ បច្ចេន្តិ ឯកច្ចានំ សទ្ទានំ សវនំ អមង្គលំ បច្ចេន្តិ ។

កតមេសំ សទ្ទានំ សវនំ មង្គលំ បច្ចេន្តិ ។ តេ កាលតោ វុដ្ឋហិត្វា អភិមង្គលគតានិ សទ្ទានិ សុណន្តិ វឌ្ឍាតិ វា វឌ្ឍមានាតិ វា បុណ្ណាតិ វា បុស្សាតិ វា អសោកាតិ វា សុមនាតិ វា សុនក្ខត្តាតិ វា សុមង្គលាតិ វា សិរីតិ វា សិរីវឌ្ឍាតិ វា ឯវរូបានំ សទ្ទានំ សវនំ មង្គលំ បច្ចេន្តិ ។

កតមេសំ សទ្ទានំ សវនំ អមង្គលំ បច្ចេន្តិ ។

សមណព្រាហ្មណ៍ទាំងឡាយនេះ ប្រកាន់សេចក្តីបរិសុទ្ធិដោយសាររូប ដែលឃើញ សមណព្រាហ្មណ៍ទាំងនោះ តែងជឿថា សេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយសាររូបដែលឃើញ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធិដោយសម្មុតិ ដែលឮ សមណព្រាហ្មណ៍ទាំងនោះ ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាជាមង្គល ជឿនូវការឮសំឡេងទាំងឡាយខ្លះ ថាមិនមែនជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ រមែងជឿនូវការឮសំឡេង ទាំងឡាយដូចម្តេច ថាជាមង្គល ។ សមណព្រាហ្មណ៍ទាំងឡាយនោះ ក្រោកឡើងអំពីព្រលឹម ឮសំឡេងទាំងឡាយ ដែលសម្មតថាជាមង្គល ដ៏ក្រៃលែង ដូចឮថាចំរើនក្តី កំពុងចំរើនក្តី ពេញក្តី សក្តី មិន មានសោកក្តី មានចិត្តល្អក្តី នក្ខត្តឫក្សល្អក្តី មង្គលល្អក្តី សិរីក្តី ចំរើនដោយសិរីក្តី ក៏ប្រកាន់ជឿ នូវការឮសំឡេងទាំងឡាយ មាន សភាពយ៉ាងនេះ ថាជាមង្គល ។

សមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះ ជឿនូវការឮសំឡេងទាំង ឡាយដូចម្តេច ថាមិនមែនជាមង្គល ។

កាណោតិ វា កុណីតិ វា ខញ្ជោតិ វា បក្ខហតោតិ វា ជិណ្ណកោតិ វា ព្យាធិកោតិ វា មតោតិ វា ឆិន្នន្តិ វា ភិន្នន្តិ វា ទឌ្ឍន្តិ វា នដ្ឋន្តិ វា នត្ថីតិ វា ឯវរូបានំ សទ្ទានំ សវនំ អមង្គលំ បច្ចេន្តិ ។ ឥមេ តេ សមណព្រាហ្មណា សុតសុទ្ធិកា តេ សុតេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា សីលសុទ្ធិកា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ សមណមុណ្ឌិកាបុត្តោ ឯវមាហ ចតូហិ ខោ អហំ ថបតិ[១] ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមបត្តិបត្តំ សមណំ អយោជ្ឈំ ។ កតមេហិ ចតូហិ[១] ។ ឥធ ថបតិ ន កាយេន បាបកម្មំ ករោតិ ន បាបិកំ វាចំ ភាសតិ

---
១ ម. គហបតិ ។

សមណព្រាហ្មណ៍ទាំងនោះ ពុំពាក្យថា មនុស្សខ្វាក់ក្តី ក្លែងក្តី ខ្ញក់ក្តី ខ្វិនក្តី ដពកក្តី ឈឺក្តី ស្លាប់ក្តី ដាច់ក្តី បែកក្តី ធ្លេះក្តី វិនាសក្តី មិនមានក្តី ក៏ប្រកាន់ជឿនូវការពួសំឡេង មានសភាពយ៉ាងនេះ ថាមិនមែនជាមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ អ្នកប្រកាន់សេចក្តីបរិសុទ្ធិដោយសម្មុតិដែលឮ គឺសមណព្រាហ្មណ៍ទាំងនោះ ជឿនូវសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះសម្មុតិដែលឮ ។

មានសមណព្រាហ្មណ៍ពួកខ្លះ ប្រកាន់សេចក្តីបរិសុទ្ធិដោយសីល សមណព្រាហ្មណ៍ទាំងនោះ តែងជឿថាសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរវាំង ត្រឹមតែការមិនប្រព្រឹត្តិកន្លង ។ សមណមុណ្ឌិកាបុត្រ បានពោលយ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្តនូវបុរសបុគ្គល ដែលប្រកបដោយធម៌ទាំងឡាយ ៤ យ៉ាង ថាជាបុគ្គលមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ ដែលគេគប្បីដល់ដ៏ឧត្តម ជាសមណៈមិនមានបរាជ័យ ។ ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលជាងឈើ បុរសបុគ្គលក្នុងលោកនេះ មិនធ្វើនូវអំពើលាមកដោយកាយ ១ មិនពោលនូវវាចាដ៏លាមក ១

ន ចាបកំ សង្កប្បំ សង្កប្បេតិ ន ចាបកំ អាជីវំ អាជីវតិ ។ ឥមេហិ ខោ អហំ ថបតិ ចតូហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិប្បត្តំ សមណំ អយោជ្ឈំ ។ ឯវមេវ សន្តេកេ សមណព្រាហ្មណា សីលសុទ្ធិកា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា វត្តសុទ្ធិកា តេ ហត្ថិវត្តិកា វា ហោន្តិ អស្សវត្តិកា វា ហោន្តិ គោវត្តិកា វា ហោន្តិ កុក្កុរវត្តិកា វា ហោន្តិ កាកវត្តិកា វា ហោន្តិ វាសុទេវវត្តិកា វា ហោន្តិ ពលទេវវត្តិកា វា ហោន្តិ បុណ្ណភទ្ទវត្តិកា វា ហោន្តិ មណិភទ្ទវត្តិកា វា ហោន្តិ អគ្គិវត្តិកា វា ហោន្តិ នាគវត្តិកា វា ហោន្តិ សុបណ្ណវត្តិកា វា ហោន្តិ យក្ខវត្តិកា វា ហោន្តិ អសុរវត្តិកា វា ហោន្តិ គន្ធព្វវត្តិកា វា ហោន្តិ មហារាជវត្តិកា វា ហោន្តិ ចន្ទវត្តិកា វា ហោន្តិ

មិនត្រិះរិះនូវសេចក្តីត្រិះរិះដ៏លាមក ១ មិនចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតដ៏លាមក ១ ម្នាលជាងឈើ ខ្ញុំតែងបញ្ញត្តនូវបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯង ថាជាបុគ្គល មានកុសលដ៏បរិបូណ៌ មានកុសលដ៏ឧត្តម ជាបុគ្គលដល់ហើយនូវធម៌ ដែលបុគ្គលគប្បីដល់ដ៏ឧត្តម ជាសមណៈ មិនមានបរាជ័យ ។ មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់នូវសេចក្តីបរិសុទ្ធិដោយសីល សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្តីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយហេតុត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរាំង ត្រឹមតែការមិនប្រព្រឹត្តកន្លង យ៉ាងនេះឯង ។

មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកាន់ នូវសេចក្តីបរិសុទ្ធិដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រព្រឹត្តវត្តដំរីក៏មាន ប្រព្រឹត្តវត្តសេះក៏មាន ប្រព្រឹត្តវត្តគោក៏មាន ប្រព្រឹត្តវត្តឆ្កែក៏មាន ប្រព្រឹត្តវត្តក្អែកក៏មាន ប្រព្រឹត្តវត្តរបស់វាសុទេពក៏មាន ប្រព្រឹត្តវត្តរបស់ពលទេពក៏មាន ប្រព្រឹត្តវត្តរបស់បុណ្ណភទ្ទក៏មាន ប្រព្រឹត្តវត្តរបស់មណិភទ្ទក៏មាន ប្រព្រឹត្តវត្តភ្លើងក៏មាន ប្រព្រឹត្តវត្តនាគក៏មាន ប្រព្រឹត្តវត្តគ្រុឌក៏មាន ប្រព្រឹត្តវត្តយក្ខក៏មាន ប្រព្រឹត្តវត្តអសុរក៏មាន ប្រព្រឹត្តវត្តគន្ធព្វក៏មាន ប្រព្រឹត្តវត្តមហារាជក៏មាន ប្រព្រឹត្តវត្តព្រះចន្ទក៏មាន

សុរិយវត្តិកា វា ហោន្តិ ឥន្ទវត្តិកា វា ហោន្តិ ព្រហ្មវត្តិកា វា ហោន្តិ ទេវវត្តិកា វា ហោន្តិ ទិសវត្តិកា វា ហោន្តិ ។ យេ តេ សមណព្រាហ្មណា វត្តសុទ្ធិកា តេ វត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

សន្តេកេ សមណព្រាហ្មណា មុតសុទ្ធិកា ។ តេ កាលតោ វុដ្ឋហិត្វា បឋវឹ អាមសន្តិ ហរិតំ អាមសន្តិ គោមយំ អាមសន្តិ កច្ឆបំ អាមសន្តិ ផាលំ អក្កមន្តិ តិលវាហំ អាមសន្តិ ផុស្សតិលំ ខាទន្តិ ផុស្សតេលំ មក្ខេន្តិ ផុស្សទន្តកដ្ឋំ ខាទន្តិ ផុស្សមត្តិកាយ នហាយន្តិ ផុស្សសាដកំ និវាសេន្តិ ផុស្សវេឋនំ វេឋេន្តិ ។ យេ តេ សមណព្រាហ្មណា មុតសុទ្ធិកា តេ មុតេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ

ប្រព្រឹត្តទៅព្រោះអាទិត្យក៏មាន ប្រព្រឹត្តទៅព្រោះឥន្ទ្រក៏មាន ប្រព្រឹត្តទៅព្រោះព្រហ្មក៏មាន ប្រព្រឹត្តទៅទេវតាក៏មាន ប្រព្រឹត្តទៅព្រោះទិសក៏មាន ។ សមណព្រាហ្មណ៍ទាំងឡាយនេះ ជាអ្នកប្រកាន់សេចក្ដីបរិសុទ្ធិដោយវត្ត សមណព្រាហ្មណ៍ទាំងនោះ រមែងជឿសេចក្ដីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ព្រោះវត្ត ។

មានសមណព្រាហ្មណ៍ពួកខ្លះ អ្នកប្រកាន់សេចក្ដីបរិសុទ្ធិដោយអារម្មណ៍ដែលប៉ះពាល់ ។ សមណព្រាហ្មណ៍ទាំងនោះ ក្រោកឡើងអំពីព្រលឹម ស្ទាបប្រថពី ស្ទាបស្មៅស្រស់ ស្ទាបអាចម៍គោ ស្ទាបអណ្ដើក ជាន់នូវបណ្ដាញ (ដែក) ស្ទាបរទេះដែលពេញដោយល្ង ស៊ីល្ងដែលជាមង្គល លាបប្រេងមង្គល ស៊ីឈើស្ទន់មង្គល ដុសធ្មេញដោយដីស្អិតមង្គល ស្លៀកសំពត់មង្គល ជួតឈ្នួតមង្គល ។ សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់សេចក្ដីបរិសុទ្ធិ ដោយអារម្មណ៍ដែលប៉ះពាល់ សមណព្រាហ្មណ៍ទាំងនោះ រមែងជឿ សេចក្ដីស្អាត ស្អាតវិសេស ស្អាតជុំវិញ ការផុត ផុតស្រឡះ ផុតដោយជុំវិញ ដោយអារម្មណ៍ដែលប៉ះពាល់ ។

ពាក្យថា ព្រាហ្មណ៍មិនពោលនូវសេចក្ដីបរិសុទ្ធិ ព្រោះផ្លូវដទៃ

## ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

ទិដ្ឋេ សុតេ សីលវតេ មុតេ វាតិ ព្រាហ្មណោ ទិដ្ឋសុទ្ធិយាបិ សុទ្ធឹ អាហ សុតសុទ្ធិយាបិ សុទ្ធឹ អាហ សីលសុទ្ធិយាបិ សុទ្ធឹ អាហ វតសុទ្ធិយាបិ សុទ្ធឹ អាហ មុតសុទ្ធិយាបិ សុទ្ធឹ អាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតិ ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហាតិ ទិដ្ឋេ សុតេ សីលវតេ មុតេ វា ។

(១២១) បុញ្ញេ ច បាបេ ច អនូបលិត្តោតិ បុញ្ញំ វុច្ចតិ យង្កិញ្ចិ តេធាតុកំ កុសលាភិសង្ខារំ ។ អបុញ្ញំ(១) វុច្ចតិ សព្វំ អកុសលំ ។ យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អានេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា

---

១ ម. អយំ ។

ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី បានសេចក្តីថា ព្រាហ្មណ៍មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធិ ព្រោះអារម្មណ៍ដែលឃើញផង មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធិ ព្រោះអារម្មណ៍ដែលឮផង មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធិ ព្រោះសីលផង មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធិ ព្រោះវត្តផង មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិននិយាយ នូវសេចក្តីបរិសុទ្ធិ ដោយសេចក្តីបរិសុទ្ធិ ព្រោះអារម្មណ៍ដែលប៉ះពាល់ផង ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍មិនពោល នូវសេចក្តីបរិសុទ្ធិ ដោយផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី ។

(១៦១) ពាក្យថា មិនជាប់នៅក្នុងបុណ្យនិងបាប មានសេចក្តីថា កុសលាភិសង្ខារណាមួយ ដែលឲ្យបដិសន្ធិក្នុងត្រៃធាតុ លោកហៅថា បុណ្យ ។ អកុសលទាំងអស់ លោកហៅថា បាប ។ កាលណា បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអានេញ្ជាភិសង្ខារ ដែលព្រាហ្មណ៍លះបង់ហើយ ផ្តាច់ឫសចោលហើយ ធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត

អនភាវង្កតា អាយតឹ អនុប្បាទធម្មា ឯត្តាវតា ច បុញ្ញេ ច បាបេ ច ន លិម្បតិ ន សំលិម្បតិ ន ឧបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ បុញ្ញេ ច បាបេ ច អនូបលិត្តោ ។

(១២២) អត្តញ្ជហោ នយិធ បកុព្ពមានោតិ អត្តញ្ជហោតិ អត្តទិដ្ឋិជហោ ។ អត្តញ្ជហោតិ គាហជហោ ។ អត្តញ្ជហោតិ តណ្ហាវសេន ទិដ្ឋិវសេន គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ សព្វំ(១) តំ ចត្តំ ហោតិ វន្តំ មុត្តំ បហីនំ បដិនិស្សដ្ឋំ ។ នយិធ បកុព្ពមានោតិ បុញ្ញាភិសង្ខារំ វា អបុញ្ញាភិសង្ខារំ វា អានេញ្ជាភិសង្ខារំ វា អកុព្ពមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ អនភិនិព្វត្តយមានោតិ អត្តញ្ជហោ នយិធ បកុព្ពមានោ ។ តេនាហ ភគវា

១ ម. សព្វស្ស ។

ដល់នូវភាពតាំងនៅមិនបាន មានសភាពមិនកើតតទៅទៀត ក្នុងកាលណា ព្រាហ្មណ៍ឈ្មោះថា មិនជាប់ មិនជាប់ព្រម មិនជាប់មាំ ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ ស្ទុះចេញ លះបង់រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកកិលេសដូចជាទំនប់ជាដើម ក្នុងបុណ្យនឹងបាប ព្រោះហេតុប៉ុណ្ណេះ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនជាប់នៅក្នុងបុណ្យនឹងបាប ។

(១៦៤) ពាក្យថា ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ អធិប្បាយថា អ្នកលះបង់នូវអត្តទិដ្ឋិ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ អ្នកលះបង់នូវសេចក្តីប្រកាន់ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ វត្ថុណា ដែលគេប្រកាន់ ឋបាសអង្អែល ត្រេកអរចំពោះ ចុះចិត្ត ចុះចិត្តស៊ប់ហើយ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ វត្ថុទាំងអស់នោះ ព្រាហ្មណ៍ បានកំចាត់ ខ្ជាក់ចោល ផុត លះបង់ រលាស់ចោលហើយ ឈ្មោះថា អ្នកលះបង់នូវអត្តា ។ ពាក្យថា លែងធ្វើក្នុងលោកនេះ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវបុញ្ញាភិសង្ខារក្តី នូវអបុញ្ញាភិសង្ខារក្តី នូវអានេញ្ជាភិសង្ខារក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកលះបង់នូវអត្តាលែងធ្វើក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

## ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
បុញ្ញេ ច បាបេ ច អនូបលិត្តោ
អត្តញ្ជហោ នយិធ បកុព្ពមានោតិ ។

(១២៣) បុរិមំ បហាយ អបរំ សិតាសេ
ឯជានុគា តេ ន តរន្តិ សង្គំ
តេ ឧគ្គហាយន្តិ និរស្សជន្តិ
កបីវ សាខំ បមុខំ គហាយ ។

(១២៤) បុរិមំ បហាយ អបរំ សិតាសេតិ បុរិមំ សត្ថារំ បហាយ អបរំ សត្ថារំ និស្សិតា បុរិមំ ធម្មក្ខានំ បហាយ អបរំ ធម្មក្ខានំ និស្សិតា បុរិមំ គណំ បហាយ អបរំ គណំ និស្សិតា បុរិមំ ទិដ្ឋឹ បហាយ អបរំ ទិដ្ឋឹ និស្សិ ។ បុរិមំ បដិបទំ បហាយ អបរំ បដិបទំ និស្សិតា បុរិមំ មគ្គំ បហាយ អបរំ មគ្គំ និស្សិតា សន្និស្សិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ បុរិមំ បហាយ អបរំ សិតាសេ ។

## សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

ព្រាហ្មណ៍ មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយផ្លូវដទៃ ព្រោះអារម្មណ៍ដែលឃើញក្តី ដែលឮក្តី ព្រោះសីលនិងវត្តក្តី ព្រោះអារម្មណ៍ដែលប៉ះពាល់ក្តី ទាំងមិនជាប់នៅក្នុងបុណ្យនិងបាប ជាអ្នកលះបង់នូវអត្តា លែងធ្វើក្នុងលោកនេះ ។

(១៤៣) ជនណា ជាអ្នកលង់តាមការញាប់ញ័រ លះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ជននោះ នឹងឆ្លងនូវការជាប់ចំពាក់មិនបានទេ ជននោះ តែងប្រកាន់ តែងលះបង់ ដូចជាស្វាតោងមែកឈើចំពោះមុខ ។

(១៤៤) ពាក្យថា លះបង់វត្ថុមុន ហើយអាស្រ័យវត្ថុក្រោយ គឺលះបង់សាស្តាមុន មកពឹងផ្អែកនឹងសាស្តាក្រោយ លះបង់ធម៌ដែលសាស្តាប្រាប់មុន មកអាស្រ័យធម៌ដែលសាស្តាប្រាប់ក្រោយ លះបង់ពួកមុន មកអាស្រ័យពួកក្រោយ លះបង់ទិដ្ឋិមុន មកអាស្រ័យទិដ្ឋិក្រោយ លះបង់បដិបទាមុន មកអាស្រ័យបដិបទាក្រោយ លះបង់មគ្គមុន ហើយអាស្រ័យ អាស្រ័យព្រម ជាប់នៅ ជក់នៅ ចុះចិត្ត ចុះចិត្តស៊ប់ នូវមគ្គក្រោយ ហេតុនោះ (ទ្រង់ត្រាស់ថា) តែងលះបង់វត្ថុមុន អាស្រ័យវត្ថុក្រោយ ។

(១២៥) ឯជានុគា តេ ន តរន្តិ សង្គន្តិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ឯជានុគាតិ ឯជានុគា ឯជានុគតា ឯជានុសដា ឯជាយ បន្នា បតិតា អភិភូតា បរិយាទិន្នចិត្តា ។ ន តរន្តិ សង្គន្តិ រាគសង្គំ ទោសសង្គំ មោហសង្គំ មានសង្គំ ទិដ្ឋិសង្គំ កិលេសសង្គំ ទុច្ចរិតសង្គំ ន តរន្តិ ន ឧត្តរន្តិ ន បតរន្តិ ន សមតិក្កមន្តិ ន វីតិវត្តន្តីតិ ឯជានុគា តេ ន តរន្តិ សង្គំ ។

(១២៦) តេ ឧគ្គហាយន្តិ និរស្សជន្តីតិ សត្ថារំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ សត្ថារំ គណ្ហន្តិ ធម្មក្ខានំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ ធម្មក្ខានំ គណ្ហន្តិ គណំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ គណំ គណ្ហន្តិ ទិដ្ឋឹ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ ទិដ្ឋឹ គណ្ហន្តិ បដិបទំ គណ្ហន្តិ តំ មុញ្ចិត្វា អញ្ញំ បដិបទំ គណ្ហន្តិ មគ្គំ គណ្ហន្តិ

(១៦៥) ពាក្យថា ជនណាជាអ្នកលង់តាមការញាប់ញ័រ... ជននោះ នឹងឆ្លងនូវការជាប់ចំពាក់មិនបានទេ អធិប្បាយថា តណ្ហា ហៅថា ការញាប់ញ័រ បានខាង តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ជាអ្នកលង់តាមការញាប់ញ័រ គឺជាអ្នកប្រព្រឹត្តតាមការញាប់ញ័រ ទៅតាមការញាប់ញ័រ ផ្សាយទៅតាមការញាប់ញ័រ ដល់នូវការញាប់ញ័រ ធ្លាក់ចុះ គ្របសង្កត់ មានចិត្តរួបរឹតដោយការញាប់ញ័រ ។ ពាក្យថា នឹងឆ្លងនូវការជាប់ចំពាក់ មិនបានទេ គឺនឹងឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងមិនផុត មិនកន្លងព្រម មិនប្រព្រឹត្តកន្លង នូវការចំពាក់គឺរាគៈ ការចំពាក់គឺទោសៈ ការចំពាក់គឺមោហៈ ការចំពាក់គឺមានះ ការចំពាក់គឺទិដ្ឋិ ការចំពាក់គឺកិលេស ការចំពាក់គឺទុច្ចរិត ហេតុនោះ (ទ្រង់ត្រាស់ថា) ជនណា ជាអ្នកលង់តាមការញាប់ញ័រ ជននោះ នឹងឆ្លងនូវការជាប់ចំពាក់បានទេ ។

(១៦៦) ពាក្យថា ជនទាំងនោះ តែងប្រកាន់ តែងលះបង់ សេចក្តីថា ប្រកាន់យកនូវសាស្តា លះបង់នូវសាស្តានោះ ហើយប្រកាន់សាស្តាដទៃវិញ ប្រកាន់ធម៌ដែលសាស្តាប្រាប់ លះបង់ធម៌ដែលសាស្តាប្រាប់នោះ ហើយប្រកាន់ធម៌ដទៃដែលសាស្តាប្រាប់វិញ ប្រកាន់ពួក លះបង់ពួកនោះហើយប្រកាន់ពួកដទៃវិញ ប្រកាន់ទិដ្ឋិ លះបង់ទិដ្ឋិនោះ ហើយប្រកាន់ទិដ្ឋិដទៃវិញ ប្រកាន់បដិបទា លះបង់បដិបទានោះ ហើយប្រកាន់បដិបទាដទៃវិញ

ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

តំ មុញ្ចិត្វា អញ្ញំ មគ្គំ គណ្ហន្តិ គណ្ហន្តិ ច មុញ្ចន្តិ ច អាទិយន្តិ ច និរស្សជ្ជន្តិ ចាតិ តេ ឧគ្គហាយន្តិ និរស្សជ្ជន្តិ ។

(១២៧) កបីវ សាខំ បមុញ្ចំ គហាយាតិ យថា មក្កដោ អរញ្ញេ បវនេ ចរមានោ សាខំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ សាខំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ សាខំ គណ្ហាតិ ឯវមេវ បុថុ សមណព្រាហ្មណា បុថុ ទិដ្ឋិគតានិ គណ្ហន្តិ ច មុញ្ចន្តិ ច អាទិយន្តិ ច និរស្សជ្ជន្តិ ចាតិ កបីវ សាខំ បមុញ្ចំ គហាយ ។ តេនាហ ភគវា

បុរិមំ បហាយ អបរំ សិតាសេ
ឯជានុគា តេ ន តរន្តិ សង្គំ
តេ ឧគ្គហាយន្តិ និរស្សជ្ជន្តិ
កបីវ សាខំ បមុញ្ចំ គហាយាតិ ។

(១២៨) សយំ សមាទាយ វតានិ ជន្តុ
ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោ
វិទ្វា ច (១) វេទេហិ សមេច្ច ធម្មំ
ន ឧច្ចាវចំ គច្ឆតិ ភូរិបញ្ញោ ។

១ ឧ. វិទា ។

ប្រកាន់មគ្គ លះបង់មគ្គនោះ ហើយប្រកាន់មគ្គដទៃវិញ ប្រកាន់ផល លះបង់ផល ប្រកាន់យកផល លែងចោលផល ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ តែងប្រកាន់ តែងលះបង់ ។

(១៤៧) ពាក្យថា ដូចជាស្វាតោងមែកឈើចំពោះមុខ សេចក្តីថា ស្វាកាលត្រាច់ទៅក្នុងព្រៃតូចព្រៃធំ តែងតោងមែកឈើ លែងនូវមែកឈើនោះចោល ហើយតោងមែកឈើដទៃ លែងមែកឈើនោះចោល ហើយតោងមែកឈើដទៃវិញ យ៉ាងណា ពួកសមណព្រាហ្មណ៍ ផ្តេសផ្តាស តែងប្រកាន់ផល លះបង់ផល កាន់យកផល លែងចោលផល នូវទិដ្ឋិផ្តេសផ្តាស ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាស្វាតោងមែកឈើចំពោះមុខ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនណា ជាអ្នកលង់តាមការញាប់ញ័រ លះបង់វត្ថុ
មុន អាស្រ័យវត្ថុក្រោយ ជននោះ នឹងឆ្លងនូវការជាប់
ចំពាក់មិនបាន ជននោះ តែងប្រកាន់ តែងលះបង់
ដូចជាស្វា តោងមែកឈើចំពោះមុខ ។

(១៤៨) ជនសមាទាននូវវត្តទាំងឡាយ ដោយខ្លួនឯង ជា
អ្នកជាប់ក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នក
ប្រាជ្ញ មានបញ្ញាដូចផែនដី ត្រាស់ដឹងនូវធម៌
ដោយវេទទាំងឡាយ មិនទៅរកវត្ថុខ្ពស់ទាបទេ ។

[១២៩] សយំ សមាទាយ វតានិ ជន្តូតិ សយំ សមាទាយាតិ សាមំ សមាទាយ ។ វតានីតិ ហត្ថិវត្តំ វា អស្សវត្តំ វា គោវត្តំ វា កុក្កុរវត្តំ វា កាកវត្តំ វា សុទេវវត្តំ វា ពលទេវវត្តំ វា បុណ្ណភទ្ទវត្តំ វា មណិភទ្ទវត្តំ វា អគ្គិវត្តំ វា នាគវត្តំ វា សុបណ្ណវត្តំ វា យក្ខវត្តំ វា អសុរវត្តំ វា ។បេ។ ទិសវត្តំ វា អាទាយ សមាទាយ អាទិយិត្វា សមាទិយិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា ។ ជន្តូតិ សត្តោ នរោ ។បេ។ មនុជោតិ សយំ សមាទាយ វតានិ ជន្តុ ។

[១៣០] ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោតិ សត្ថារតោ សត្ថារំ គច្ឆតិ ធម្មក្ខានតោ ធម្មក្ខានំ គច្ឆតិ គណតោ គណំ គច្ឆតិ ទិដ្ឋិយា ទិដ្ឋឹ គច្ឆតិ បដិបទាតោ បដិបទំ គច្ឆតិ មគ្គតោ មគ្គំ គច្ឆតិ ។ សញ្ញសត្តោតិ កាមសញ្ញាយ ព្យាបាទសញ្ញាយ វិហឹសាសញ្ញាយ ទិដ្ឋិសញ្ញាយ សត្តោ វិសត្តោ អាសត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។ យថា ភិត្តិខីលេ វា នាគទន្តេ វា ភណ្ឌំ សត្តំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ

(១២៩) អធិប្បាយពាក្យថា ជនសមាទាន នូវវត្តទាំងឡាយ ដោយខ្លួនឯង គ្រង់ពាក្យថា សមាទានដោយខ្លួនឯង គឺកាន់យកព្រម ដោយខ្លួនឯង ។ ពាក្យថា វត្តទាំងឡាយ សេចក្ដីថា កាន់យក កាន់យកព្រម ប្រកាន់ ប្រកាន់ព្រម ក្ដួបកាន់យក បរាមាសអង្អែល ជាប់ចិត្ត នូវវត្តដំរីក្ដី វត្តសេះក្ដី វត្តគោក្ដី វត្តឆ្កែក្ដី វត្តក្អែកក្ដី វត្តវាសុទេពក្ដី វត្តពលទេពក្ដី វត្តបុណ្ណភទ្រក្ដី វត្តមណិភទ្រក្ដី វត្តភ្លើងក្ដី វត្តនាគក្ដី វត្តគ្រុឌក្ដី វត្តយក្ខក្ដី វត្តអសុរក្ដី ។ បេ ។ វត្តទិសក្ដី ។ ពាក្យថា ជន គឺសត្វ នរៈ ។ បេ ។ សត្វមានជាតិជាមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ជនសមាទាននូវវត្តទាំងឡាយៈដោយខ្លួនឯង ។

(១៣០) ពាក្យថា ជាអ្នកជាប់ក្នុងសញ្ញា រមែងទៅរកវត្ថុខ្ពស់ទាប សេចក្ដីថា ចេញអំពីសាស្ដា ទៅរកសាស្ដា ចេញអំពីធម៌ដែលសាស្ដាប្រាប់ ទៅរកធម៌ដែលសាស្ដាប្រាប់ អំពីពួក ទៅរកពួក អំពីទិដ្ឋិ ទៅរកទិដ្ឋិ អំពីបដិបទា ទៅរកបដិបទា អំពីមគ្គ ទៅរកមគ្គ ។ ពាក្យថា ជាអ្នកជាប់នៅក្នុងសញ្ញា គឺ បំពាក់ បំពាក់ឆ្វាក់ បំពាក់ចាក់ស្រែះ ថ្ពក់ទាក់ជាប់មាំហើយ ក្នុងកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា ។ ភាណ្ឌៈដែលបំពាក់ បំពាក់ឆ្វាក់ បំពាក់ចាក់ស្រែះ ថ្ពក់ ទាក់ជាប់មាំហើយ ឰដ៏បង្រើងជញ្ជាំងឬដៃកែវ យ៉ាងណាមិញ

កាមសញ្ញាយ ព្យាបាទសញ្ញាយ វិហឹសាសញ្ញាយ ទិដ្ឋិសញ្ញាយ សត្តា វិសត្តា អាសត្តា លគ្គា លគ្គិតា បលិពុទ្ធាតិ ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោ ។

(១៣១) វិទ្វា ច វេទេហិ សមេច្ច ធម្មន្តិ វិទ្វាតិ វិទ្វា វិជ្ជាគតោ ញាណី ពុទ្ធិមា វិភាវី មេធាវី ។ វេទេហីតិ វេទា វុច្ចន្តិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ តេហិ វេទេហិ ជាតិជរាមរណស្ស អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្បត្តោ សរណគតោ សរណប្បត្តោ អភយគតោ អភយប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្បត្តោ និព្វានគតោ និព្វានប្បត្តោ ។

បុគ្គលអ្នកបំពាក់ បំពាក់ធ្លាក់ បំពាក់ចាក់ស្រេះ ជ្ពក់ ទាក់ជាប់មាំហើយ ក្នុងកាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកជាប់នៅក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ។

(១៣១) អធិប្បាយពាក្យថា អ្នកប្រាជ្ញ ត្រាស់ដឹងនូវធម៌ដោយវេទទាំងឡាយ ត្រង់ពាក្យថា អ្នកប្រាជ្ញ គឺអ្នកដឹង អ្នកប្រកបដោយវិជ្ជា អ្នកមានញាណ អ្នកមានប្រាជ្ញា មានបញ្ញាជាគ្រឿងត្រុះយល់ មានបញ្ញាជាគ្រឿងចំបង ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គទាំងឡាយ ៤ លោកហៅថា វេទ ក្នុងបទថា ដោយវេទទាំងឡាយ ។ បុគ្គលដល់នូវទីបំផុត សម្រេចនូវទីបំផុត ដល់នូវចុង សម្រេចនូវចុង ដល់នូវទីបំផុតដោយជុំវិញ សម្រេចនូវទីបំផុតដោយជុំវិញ ដល់នូវទីអវសាន សម្រេចនូវទីអវសាន នៃជាតិ ជរានឹងមរណៈ ដល់ហើយនូវទីជ្រកកោន សម្រេចនូវទីជ្រកកោន ដល់នូវទីពួន សម្រេចនូវទីពួន ដល់នូវទីពឹងទីរឭក សម្រេចនូវទីពឹងទីរឭក ដល់នូវទីមិនមានភ័យ សម្រេចនូវទីមិនមានភ័យ ដល់នូវទីមិនច្យុត សម្រេចនូវទីមិនច្យុត ដល់នូវអមតៈ សម្រេចនូវអមតៈ ដល់នូវព្រះនិព្វាន សម្រេចនូវព្រះនិព្វាន ដោយវេទទាំងនោះ ។

វេទានំ វា អន្តគតោតិ វេទគូ ។ វេទេហិ វា អន្ត-គតោតិ វេទគូ ។ សត្តន្នំ ធម្មានំ វិទិតត្តា វេទគូ សក្កាយទិដ្ឋិ វិទិតា ហោតិ វិចិកិច្ឆា វិទិតា ហោតិ សីលព្វត្តបរាមាសោ វិទិតោ ហោតិ រាគោ វិទិតោ ហោតិ ទោសោ វិទិតោ ហោតិ មោហោ វិទិតោ ហោតិ មានោ វិទិតោ ហោតិ ។ វិទិតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភ-វិកា សទរា ទុក្ខវិបាកា អាយតិំ ជាតិជរាមរណីយា ។

វេទានិ វិចេយ្យ កេវលានិ (សភិយាតិ ភគវា)
សមណានំ យានិ បត្ថិ ព្រាហ្មណានំ
សព្វវេទនាសុ វីតរាគោ
សព្វំ វេទមតិច្ច វេទគូ សោ ។

សមេច្ច ធម្មន្តិ សមេច្ច អភិសមេច្ច ធម្មំ ។ សព្វេ សង្ខារា អនិច្ចាតិ សមេច្ច អភិសមេច្ច ធម្មំ ។ សព្វេ សង្ខារា ទុក្ខាតិ សមេច្ច អភិសមេច្ច ធម្មំ ។ សព្វេ ធម្មា អនត្តាតិ សមេច្ច អភិសមេច្ច ធម្មំ ។

មួយទៀត បុគ្គលដល់នូវទីបំផុតនៃវេទទាំងឡាយ ឈ្មោះថា វេទគូ-បុគ្គល ។ បុគ្គលដល់នូវទីបំផុតដោយវេទទាំងឡាយ ឈ្មោះថា វេទគូ-បុគ្គល ។ បុគ្គលដែលឈ្មោះថា វេទគូ ព្រោះដឹងច្បាស់នូវធម៌ទាំងឡាយ ៧ ប្រការ គឺ ជាអ្នកដឹងច្បាស់សក្កាយទិដ្ឋិ១ ដឹងច្បាស់វិចិកិច្ឆា១ ដឹងច្បាស់សីលព្វតបរាមាសៈ១ ដឹងច្បាស់រាគៈ១ ដឹងច្បាស់ទោសៈ១ ដឹងច្បាស់មោហៈ១ ដឹងច្បាស់មានៈ១ ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ប្រកបដោយសេចក្តីសៅហ្មងក្រម ជាធម៌ញុំាងសត្វឲ្យកើត ក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ ជាធម៌មានសេចក្តីទុក្ខជាផល ជាបច្ច័យរបស់ជាតិ ជរានិងមរណៈតទៅទៀត វេទគូបុគ្គល ដឹងច្បាស់ហើយ ។

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា
ពិចារណាហើយ នូវវេទទាំងអស់ របស់ពួកសមណ
ព្រាហ្មណ៍ជាអ្នកប្រាសចាកតម្រេក ក្នុងវេទទាំងពួង កន្លង
នូវវេទទាំងពួង បុគ្គលនោះ ឈ្មោះថា វេទគូបុគ្គល ។

ពាក្យថា ត្រាស់ដឹងនូវធម៌ គឺត្រាស់ដឹង ត្រាស់ដឹងចំពោះ នូវធម៌ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួង មិនទៀង ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងពួងជាទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ធម៌ទាំងពួងជាអនត្តា ។

## ចតុត្ថោ សុទ្ធិកសុត្តន្តុទ្ទេសោ

អវិជ្ជាបច្ចយា សង្ខារាតិ សមេតុ អភិសមេតុ ធម្មំ ។ សង្ខារបច្ចយា វិញ្ញាណន្តិ សមេតុ អភិសមេតុ ធម្មំ ។ វិញ្ញាណបច្ចយា នាមរូបន្តិ ។ នាមរូបបច្ចយា សឡាយតនន្តិ ។ សឡាយតនបច្ចយា ផស្សោតិ ។ ផស្សបច្ចយា វេទនាតិ ។ វេទនាបច្ចយា តណ្ហាតិ ។ តណ្ហាបច្ចយា ឧបាទានន្តិ ។ ឧបាទានបច្ចយា ភវោតិ ។ ភវបច្ចយា ជាតីតិ ។ ជាតិបច្ចយា ជរាមរណន្តិ សមេតុ អភិសមេតុ ធម្មំ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ សមេតុ អភិសមេតុ ធម្មំ ។ សង្ខារនិរោធា វិញ្ញាណនិរោធោតិ សមេតុ អភិសមេតុ ធម្មំ ។ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ នាមរូបនិរោធា សឡាយតននិរោធោតិ ។ សឡាយតននិរោធា ផស្សនិរោធោតិ ។ ផស្សនិរោធា វេទនានិរោធោតិ ។ វេទនានិរោធា តណ្ហានិរោធោតិ ។ តណ្ហានិរោធា ឧបាទាននិរោធោតិ ។ ឧបាទាននិរោធា ភវនិរោធោតិ ។ ភវនិរោធា ជាតិនិរោធោតិ ។ ជាតិនិរោធា ជរាមរណនិរោធោតិ សមេតុ អភិសមេតុ ធម្មំ ។

ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា សង្ខារទាំងឡាយ (កើត) ព្រោះអវិជ្ជា ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វិញ្ញាណ (កើត) ព្រោះសង្ខារ ជាបច្ច័យ ។ នាមនិងរូប (កើត) ព្រោះវិញ្ញាណ ជាបច្ច័យ ។ អាយតនៈ ៦ (កើត) ព្រោះនាមរូប ជាបច្ច័យ ។ ផស្សៈ (កើត) ព្រោះអាយតនៈ ៦ ជាបច្ច័យ ។ វេទនា (កើត) ព្រោះផស្សៈ ជាបច្ច័យ ។ តណ្ហា (កើត) ព្រោះវេទនា ជាបច្ច័យ ។ ឧបាទាន (កើត) ព្រោះតណ្ហាជាបច្ច័យ ។ ភព (កើត) ព្រោះឧបាទាន ជាបច្ច័យ ។ ជាតិ (កើត) ព្រោះភព ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា ជរានិងមរណៈ (កើត) ព្រោះជាតិ ជាបច្ច័យ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់សង្ខារ ព្រោះការរលត់អវិជ្ជា ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ។ កិរិយារលត់នាមនិងរូប ព្រោះការរលត់វិញ្ញាណ ។ កិរិយារលត់អាយតនៈ ៦ ព្រោះការរលត់នាមនិងរូប ។ កិរិយារលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ។ កិរិយារលត់វេទនា ព្រោះការរលត់ផស្សៈ ។ កិរិយារលត់តណ្ហា ព្រោះការរលត់វេទនា ។ កិរិយារលត់ឧបាទាន ព្រោះការរលត់តណ្ហា ។ កិរិយារលត់ភព ព្រោះការរលត់ឧបាទាន ។ កិរិយារលត់ជាតិ ព្រោះការរលត់ភព ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា កិរិយារលត់ជរានិងមរណៈ ព្រោះការរលត់ជាតិ ។

ឥទំ ទុក្ខន្តិ សមេច្ច អភិសមេច្ច ធម្មំ ។ អយំ ទុក្ខសមុទយោតិ ។ អយំ ទុក្ខនិរោធោតិ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ សមេច្ច អភិសមេច្ច ធម្មំ ។ ឥមេ អាសវាតិ សមេច្ច អភិសមេច្ច ធម្មំ ។ អយំ អាសវសមុទយោតិ ។ អយំ អាសវនិរោធោតិ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ សមេច្ច អភិសមេច្ច ធម្មំ ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ ។ ឥមេ ធម្មា បរិញ្ញេយ្យាតិ ។ ឥមេ ធម្មា បហាតព្វាតិ ។ ឥមេ ធម្មា ភាវេតព្វាតិ ។ ឥមេ ធម្មា សច្ឆិកាតព្វាតិ សមេច្ច អភិសមេច្ច ធម្មំ ។ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច សមេច្ច អភិសមេច្ច ធម្មំ ។ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច សមេច្ច អភិសមេច្ច ធម្មំ ។ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច សមេច្ច អភិសមេច្ច ធម្មំ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សមេច្ច អភិសមេច្ច ធម្មន្តិ វិទិត្វា ច វេទេហិ សមេច្ច ធម្មំ ។

ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះទុក្ខ ។ នេះជាហេតុនាំឲ្យកើតទុក្ខ ។ នេះជាការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះជាបដិបទាទៅកាន់ការរលត់ទុក្ខ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកអាសវៈ ។ នេះជាហេតុនាំឲ្យកើតអាសវៈ ។ នេះជាការរំលត់អាសវៈ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះ នូវធម៌ថា នេះបដិបទាទៅកាន់ការរំលត់អាសវៈ ។ នេះពួកធម៌គួរត្រាស់ដឹង ។ នេះពួកធម៌គួរកំណត់ដឹង ។ នេះពួកធម៌គួរលះបង់ ។ នេះពួកធម៌គួរចំរើន ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា នេះពួកធម៌គួរធ្វើឲ្យជាក់ច្បាស់ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃផស្សាយតនៈ ៦ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃឧបាទានក្ខន្ធ ៥ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ គឺហេតុឲ្យកើតផង ឲ្យរលត់ផង សេចក្ដីរីករាយផង ទោសផង រលាស់ចេញផង នៃមហាភូត ៤ ។ ត្រាស់ដឹង ត្រាស់ដឹងចំពោះនូវធម៌ថា វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងពួងនោះ មានកិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ឯអ្នកប្រាជ្ញត្រាស់ដឹងនូវធម៌ ដោយវេទទាំងឡាយ ។

ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

(១៣២) ន ឧច្ចាវចំ គច្ឆតិ ភូរិបញ្ញោតិ ន សត្ថារតោ សត្ថារំ គច្ឆតិ ន ធម្មក្ខានតោ ធម្មក្ខានំ គច្ឆតិ ន គណតោ គណំ គច្ឆតិ ន ទិដ្ឋិយា ទិដ្ឋឹ គច្ឆតិ ន បដិបទាយ បដិបទំ គច្ឆតិ ន មគ្គតោ មគ្គំ គច្ឆតិ ។ ភូរិបញ្ញោតិ មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្វេធិកបញ្ញោ ។ ភូរី វុច្ចតិ បថវី ។ តាយ បថវីសមាយ បញ្ញាយ វិបុលាយ វិត្ថតាយ សមន្នាគតោតិ ន ឧច្ចាវចំ គច្ឆតិ ភូរិបញ្ញោ ។ តេនាហ ភគវា

សយំ សមាទាយ វតានិ ជន្តុ
ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោ
វិទ្វា ច វេទេហិ សមេច្ច ធម្មំ
ន ឧច្ចាវចំ គច្ឆតិ ភូរិបញ្ញោតិ ។

(១៣៣) ស សព្វធម្មេសុ វិសេនិភូតោ
យំ កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា

## សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

(១៣៦) ពាក្យថា មានបញ្ញាដូចផែនដី មិនទៅរកវត្ថុខ្ពស់ នឹងទាប គឺ មិនចេញ អំពីសាស្ដា ទៅរកសាស្ដា មិនចេញ អំពីធម៌ដែលសាស្ដាប្រាប់ ទៅរកធម៌ដែលសាស្ដាប្រាប់ មិនចេញ អំពីពួកទៅរកពួក មិនចេញអំពីទិដ្ឋិទៅរកទិដ្ឋិ មិនចេញ អំពីបដិបទាទៅរកបដិបទា មិនចេញ អំពីមគ្គ ទៅរកមគ្គ ។ ពាក្យថា មានបញ្ញាដូចផែនដី គឺ មានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាស្រស់ មានបញ្ញារហ័ស មានបញ្ញាមុត មានបញ្ញាជាគ្រឿងទំលាយបង់ នូវកិលេស ។ ប្រថពី ហៅថា ផែនដី ។ អ្នកប្រាជ្ញប្រកបព្រមហើយដោយបញ្ញាដ៏ទូលាយ លាតផ្សាយស្មើ ដោយប្រថពីនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មានបញ្ញាដូចផែនដី មិនទៅរកវត្ថុខ្ពស់ទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជនសមាទាននូវវត្តទាំងឡាយ ដោយខ្លួនឯង ជាអ្នកជាប់
នៅក្នុងសញ្ញា តែងទៅរកវត្ថុខ្ពស់ទាប ឯអ្នកប្រាជ្ញមាន
បញ្ញាដូចផែនដី ត្រាស់ដឹងនូវធម៌ ដោយវេទទាំងឡាយ
មិនទៅរកវត្ថុខ្ពស់នឹងទាបទេ ។

(១៣៧) អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយ
ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែល
លោកឃើញហើយក្ដី ឮហើយក្ដី ប៉ះពាល់ហើយក្ដី

តមេវ ទស្សឹ វិវដំ ចរន្តំ

កេនីធ លោកស្មិំ វិកប្បយេយ្យ ។

(១៣៤) ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វាតិ សេនា វុច្ចតិ មារសេនា ។ កាយទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ មារសេនា ទោសោ មារសេនា មោហោ មារសេនា កោធោ ឧបនាហោ ។ បេ ។ សព្វាកុសលាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា

កាមា តេ បឋមា សេនា ទុតិយារតិ វុច្ចតិ

តតិយោ ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ

បញ្ចមំ ថីនមិទ្ធន្តេ ឆដ្ឋា ភិរូ បវុច្ចតិ

ជនគប្បីកំណត់ នូវអ្នកប្រាជ្ញ ជាអ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។

(១៣៤) ពាក្យថា អ្នកប្រាជ្ញនោះ ជាអ្នកមានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី អធិប្បាយថា សេនារបស់មារ លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគៈ ជាមារសេនា ទោសៈ ជាមារសេនា មោហៈ ជាមារសេនា ក្រោធៈ ឧបនាហៈ ។ បេ ។ អកុសលាភិសង្ខារទាំងអស់ ជាមារសេនា ។ ដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ដូច្នេះថា

កាម ជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរ (ក្នុងធម៌ជាកុសល) លោកហៅថា សេនាទី២ សេចក្តីស្រេកឃ្លាន ជាសេនាទី៣ របស់អ្នក តណ្ហា លោកហៅថា សេនាទី៤ ថីនមិទ្ធៈ ជាសេនាទី ៥ របស់អ្នក សេចក្តីខ្លាច លោកហៅថា សេនាទី៦

សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ

លាភោ សិលោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ

យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ

ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិណី

ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខន្តិ ។

យតោ ចតូហិ អរិយមគ្គេហិ សព្វា ច មារសេនា សព្វេ ច បដិសេនិករា កិលេសា ជិតា ច បរាជិតា ច ភគ្គា វិប្បលុត្តា[១] បរម្មុខា សោ វុច្ចតិ វិសេនិភូតោ ។ សោ ទិដ្ឋេ វិសេនិភូតោ សុតេ វិសេនិភូតោ មុតេ វិសេនិភូតោ វិញ្ញាតេ វិសេនិភូតោតិ ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា ។

---

១ ខ. ម. វិប្បលុគ្គា ។

វិចិកិច្ឆា ជាសេនាទី ៧ របស់អ្នក ការលុបគុណ និងសេចក្ដីរឹងត្អឹង ជាសេនាទី ៨ របស់អ្នក លាភ សេចក្ដីសរសើរ និងសក្ការៈ (ជាសេនាទី៩) យសដែលបុគ្គលបានមកដោយការខុស បុគ្គលដែលលើកតម្កើងខ្លួនឯង ទាំងមើលងាយអ្នកដទៃ (នេះជា) សេនាទី ១០ ម្នាលមារ នេះជាសេនារបស់អ្នកឯងដែលមានធម៌ខ្មៅ ជាសេនាតែងបៀតបៀន (នូវពួកសមណព្រាហ្មណ៍) បុគ្គលមិនក្លៀវក្លា មិនអាចឈ្នះនូវសេនានោះទេ (លុះតែបុគ្គលក្លៀវក្លា) ទើបឈ្នះហើយបានសុខ ។

កាលណា មារសេនាទាំងពួង និងកិលេសជាសត្រូវទាំងពួង ដែលបុគ្គលណា ឈ្នះ ផ្ចាញ់ បំបាក់ កំទេច ធ្វើឲ្យមានមុខងាកចេញដោយអរិយមគ្គទាំង ៤ បានហើយ បុគ្គលនោះ លោកហៅថា អ្នកមានសេនាទៅប្រាសហើយ ។ បុគ្គលនោះមានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលឃើញ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលឮ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលប៉ះពាល់ មានសេនាទៅប្រាស ក្នុងអារម្មណ៍ដែលដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញនោះមានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្ដី ឮហើយក្ដី ប៉ះពាល់ហើយក្ដី ។

(១៣៥) តមេវ ទស្សឹ វិវដំ ចរន្តន្តិ តមេវ សុទ្ធទស្សឹ វិសុទ្ធទស្សឹ បរិសុទ្ធទស្សឹ វោទាតទស្សឹ បរិយោទាតទស្សឹ ។ អថវា សុទ្ធទស្សនំ វិសុទ្ធទស្សនំ បរិសុទ្ធទស្សនំ វោទាតទស្សនំ បរិយោទាតទស្សនំ ។ វិវដន្តិ តណ្ហាឆទនំ កិលេសឆទនំ អវិជ្ជាឆទនំ ។ តានិ ឆទនានិ វិវដានិ ហោន្តិ វិទ្ធំសិតានិ ឧគ្ឃាដិតានិ សមុគ្ឃាដិតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ ។ ចរន្តន្តិ ចរន្តំ វិចរន្តំ ឥរិយន្តំ វត្តន្តំ បាលេន្តំ យបេន្តំ យាបេន្តន្តិ តមេវ ទស្សឹ វិវដំ ចរន្តំ ។

(១៣៦) កេនីធ លោកស្មិំ វិកប្បយេយ្យាតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។បេ។ អយំ តណ្ហាកប្បោ ។បេ។ អយំ ទិដ្ឋិកប្បោ ។

(១៣៥) ពាក្យថា អ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង គឺអ្នកឃើញការស្អាត អ្នកឃើញការស្អាតវិសេស អ្នកឃើញការបរិសុទ្ធិ អ្នកឃើញការបរមត្ថ អ្នកឃើញការផូរផង់ ៗ ឬថា អ្នកមានសេចក្តីយល់ស្អាត អ្នកមានសេចក្តីយល់ស្អាតវិសេស អ្នកមានសេចក្តីយល់បរិសុទ្ធិ អ្នកមានសេចក្តីយល់បរមត្ថ អ្នកមានសេចក្តីយល់ផូរផង់ ៗ ពាក្យថា អ្នកមានដំបូលបើកហើយ សេចក្តីថា ដំបូលគឺតណ្ហា ដំបូលគឺកិលេស ដំបូលគឺអវិជ្ជា ។ គ្រឿងប្រក់ទាំងនោះ លោកបើក កំចាត់បង់ បំផ្លាញចោល ដករំលើងចោល លះបង់ ផ្តាច់បង់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា កំពុងប្រព្រឹត្ត គឺ កំពុងត្រាច់ទៅ កំពុងត្រាច់ទៅផ្សេងៗ កំពុងសម្រេចឥរិយាបថ កំពុងប្រព្រឹត្ត កំពុងរក្សា កំពុងរស់នៅ កំពុងញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឃើញ អ្នកមានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ។

(១៣៦) អធិប្បាយពាក្យថា គប្បីកំណត់ដោយកិលេស ដូចម្តេច ក្នុងលោកនេះ ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់មាន ២ គឺ ការកំណត់ គឺតណ្ហា ១ ការកំណត់ គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់ គឺតណ្ហា ។ បេ ។ នេះ ការកំណត់ គឺទិដ្ឋិ ។

តស្ស តណ្ហាកាយោ បហីនោ ទិដ្ឋិកាយោ បដិនិស្ស-
ដ្ឋោ តណ្ហាកាយស្ស បហីនត្តា ទិដ្ឋិកាយស្ស បដិនិ-
ស្សដ្ឋត្តា កេន រាគេន កប្បេយ្យ កេន ទោសេន
កប្បេយ្យ កេន មោហេន កប្បេយ្យ កេន មានេន
កប្បេយ្យ កាយ ទិដ្ឋិយា កប្បេយ្យ កេន ឧទ្ធច្ចេន
កប្បេយ្យ កាយ វិចិកិច្ឆាយ កប្បេយ្យ កេហិ អនុ-
សយេហិ កប្បេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ
វា វិនិពន្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ
វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។ តេ អភិ-
សង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយោ
កេន កប្បេយ្យ នេរយិកោតិ វា តិរច្ឆានយោនិ-
កោតិ វា បេត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ
វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា
នេវសញ្ញីនាសញ្ញីតិ វា ។ សោ ហេតុ នត្ថិ

## សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

ការកំណត់គឺតណ្ហា អ្នកប្រាជ្ញនោះ បានលះបង់ហើយ ការកំណត់គឺទិដ្ឋិ អ្នកប្រាជ្ញនោះ បានរលាស់ចោលហើយ ព្រោះលោកលះបង់ នូវការកំណត់គឺតណ្ហា ព្រោះលោករលាស់ចោល នូវការកំណត់គឺទិដ្ឋិ ជន គប្បីកំណត់ដោយរាគៈដូចម្តេច គប្បីកំណត់ដោយទោសៈដូចម្តេច គប្បីកំណត់ដោយមោហៈដូចម្តេច គប្បីកំណត់ដោយមានះដូចម្តេច គប្បីកំណត់ដោយទិដ្ឋិដូចម្តេច គប្បីកំណត់ដោយឧទ្ធច្ចៈដូចម្តេច គប្បីកំណត់ដោយវិចិកិច្ឆាដូចម្តេច គប្បីកំណត់ដោយអនុស័យទាំងឡាយ ដូចម្តេចបាន ថា លោក ទៅត្រេកត្រអាលក្តី ទៅប្រទូស្តក្តី ទៅវង្វេងក្តី ទៅជាប់ចំពាក់ក្តី ទៅប៉ោងសង្ហើលក្តី ដល់នូវការរាយមាយក្តី ដល់នូវការមិនដាច់ស្រេចក្តី ដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងនោះ អ្នកប្រាជ្ញនោះ លះបង់ហើយ ព្រោះលោកលះអភិសង្ខារហើយ ជន គប្បីកំណត់ នូវគតិទាំងឡាយថា លោក ទៅកើតក្នុងនរកក្តី កើតក្នុងកំណើតតិរច្ឆានក្តី កើតក្នុងប្រេតវិស័យក្តី ជាមនុស្សក្តី ជាទេវតាក្តី ព្រហ្មមានរូបក្តី ព្រហ្មឥតរូបក្តី ព្រហ្មមានសញ្ញាក្តី ព្រហ្មឥតសញ្ញាក្តី ព្រហ្មមានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែនក្តី ដោយប្រការដូចម្តេចបាន ។ មិនមានហេតុ

បច្ចយោ នត្ថិ ការណំ នត្ថិ យេន កប្បេយ្យ វិក-
ប្បេយ្យ វិកប្បំ អាបជ្ជេយ្យ ។ លោកស្មិន្តិ អបា-
យលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ
ធាតុលោកេ អាយតនលោកេតិ កេនចិ លោកស្មិំ
វិកប្បយេយ្យ ។ តេនាហ ភគវា

ស សព្វធម្មេសុ វិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា
តមេវ ទស្សឹ វិវដំ ចរន្តំ
កេនីធ លោកស្មិំ វិកប្បយេយ្យាតិ ។

(១៣៧) ន កប្បយន្តិ ន បុរេក្ខរោន្តិ
អច្ចន្តសុទ្ធីតិ ន តេ វទន្តិ
អាទានគន្ថំ គថិតំ វិសជ្ជ
អាសំ ន កុព្វន្តិ កុហិញ្ចិ លោកេ ។

(១៣៨) ន កប្បយន្តិ ន បុរេក្ខរោន្តីតិ ក-
ប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច
។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។

មិនមានបច្ច័យ មិនមានទិន្នន៍ ជាហេតុល្មមឲ្យជន គប្បីកំណត់ គប្បីកំណត់ទុក គប្បីដល់នូវការកំណត់ទុកបានឡើយ ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជន គប្បីកំណត់ ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អ្នកប្រាជ្ញនោះ មានសេនាទៅប្រាសហើយ ក្នុងធម៌ទាំងពួងទាំងឡាយ គឺអារម្មណ៍ណាមួយ ដែលលោកឃើញហើយក្តី ឮហើយក្តី ប៉ះពាល់ហើយក្តី ជនគប្បីកំណត់នូវអ្នកប្រាជ្ញ ជាអ្នកឃើញ មានដំបូលបើកហើយ កំពុងប្រព្រឹត្តនោះឯង ដោយកិលេសដូចម្តេច ក្នុងលោកនេះបាន ។

(១៣៧) ព្រះខីណាស្រពទាំងឡាយនោះ មិនកំណត់ មិនធ្វើឲ្យជាប្រធាន មិនពោលថា (ទិដ្ឋិ) មានសេចក្តីបរិសុទ្ធិជាទីបំផុត កាត់គ្រឿងចងស្រេះគឺសេចក្តីប្រកាន់ ដែលចងស្រេះហើយ មិនធ្វើនូវបំណង ក្នុងលោកណាមួយ ។

(១៣៨) អធិប្បាយពាក្យថា មិនកំណត់ មិនធ្វើឲ្យជាប្រធាន ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់ ២ គឺ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់គឺតណ្ហា ។ បេ ។

## ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

អយំ ទិដ្ឋិកប្បោ ។ តេសំ តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន កប្បយន្តិ ។ ន បុរេក្ខរោន្តីតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។បេ។ អយំ តណ្ហាបុរេក្ខារោ ។បេ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តេសំ តណ្ហាបុរេក្ខារោ បហីនោ ទិដ្ឋិបុរេក្ខារោ បដិនិស្សដ្ឋោ តណ្ហាបុរេក្ខារស្ស បហីនត្តា ទិដ្ឋិបុរេក្ខារស្ស បដិនិស្សដ្ឋត្តា ន តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរន្តិ ន តណ្ហាធជា ន តណ្ហាកេតូ ន តណ្ហាធិបតេយ្យា ន ទិដ្ឋិធជា ន ទិដ្ឋិកេតូ ន ទិដ្ឋាធិបតេយ្យា ន តណ្ហាយ វា ទិដ្ឋិយា វា បរិវារិតា ចរន្តីតិ ន កប្បយន្តិ ន បុរេក្ខរោន្តិ ។

## សុទ្ធិកសុត្តនិទ្ទេស ទី ៤

នេះការកំណត់គឺទិដ្ឋិ ។ ការកំណត់គឺតណ្ហា ព្រះខីណាស្រពតាំងនោះ បានលះបង់ហើយ ការកំណត់គឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះខីណាស្រពទាំងឡាយ មិនកំណត់ មិនបណ្ដុះ មិនឲ្យលូតលាស់ មិនបង្កើត មិនបង្កើតចំពោះ នូវការកំណត់គឺតណ្ហា ឬការកំណត់គឺទិដ្ឋិ ព្រោះការកំណត់គឺតណ្ហា លោកលះបង់ហើយ ព្រោះការកំណត់គឺទិដ្ឋិ លោករលាស់ចោលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនកំណត់ ។ ពាក្យថា មិនធ្វើឲ្យជាប្រធាន បានខាង ការធ្វើឲ្យជាប្រធាន ២ គឺ ការធ្វើឲ្យជាប្រធាន គឺតណ្ហា១ ការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ១ ។បេ។ នេះការធ្វើឲ្យជាប្រធានគឺតណ្ហា ។បេ។ នេះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រះខីណាស្រពតាំងនោះ លះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះខីណាស្រពទាំងឡាយ រមែងមិនធ្វើនូវតណ្ហានិងទិដ្ឋិឲ្យជាប្រធាន មិនមានតណ្ហាជាទង់ជ័យ មិនមានតណ្ហាជាទង់សំគាល់ មិនមានតណ្ហាជាអធិបតី មិនមានទិដ្ឋិជាទង់ជ័យ មិនមានទិដ្ឋិជាទង់សំគាល់ មិនមានទិដ្ឋិជាអធិបតី មិនមានតណ្ហានិងទិដ្ឋិចោមរោម ព្រោះការធ្វើឲ្យជាប្រធានគឺតណ្ហា លោកលះបង់ហើយ ព្រោះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនកំណត់ មិនធ្វើឲ្យជាប្រធាន ។

(១៣៩) អច្ចន្តសុទ្ធីតិ ន តេ វទន្តីតិ អច្ចន្តសុទ្ធីតិ អច្ចន្តសុទ្ធី សំសារសុទ្ធី អកិរិយសុទ្ធី សស្សតវាទំ ន វទន្តិ ន កថេន្តិ ន ភណន្តិ ន ទីបយន្តិ ន វោហារន្តីតិ អច្ចន្តសុទ្ធីតិ ន តេ វទន្តិ ។

(១៤០) អាទានគន្ថំ គថិតំ វិសជ្ជាតិ គន្ថាតិ ចត្តារោ គន្ថា អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិយា រាគោ អភិជ្ឈា កាយគន្ថោ ។ បរវាទេសុ អាឃាតោ អប្បច្ចយោ ព្យាបាទោ កាយគន្ថោ ។

(១៧៩) ពាក្យថា មានសេចក្ដីបរិសុទ្ធិជាទីបំផុត ក្នុងបទថា ព្រះខីណាស្រពទាំងនោះ មិនពោលថា ទិដ្ឋិមានសេចក្ដីបរិសុទ្ធិជាទីបំផុត គឺព្រះខីណាស្រពទាំងឡាយ មិនពោល មិនថ្លែង មិនពណ៌នា មិនសំដែង មិននិយាយ នូវអកិរិយទិដ្ឋិ នូវសស្សតវាទថា មានសេចក្ដីបរិសុទ្ធិជាទីបំផុត មានសេចក្ដីបរិសុទ្ធិព្រោះសំសារ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះខីណាស្រពទាំងនោះ មិនពោលថា (ទិដ្ឋិ) មានសេចក្ដីបរិសុទ្ធិជាទីបំផុត ។

(១៨០) អធិប្បាយពាក្យថា កាត់គ្រឿងចងស្រែះ គឺសេចក្ដីប្រកាន់ ដែលចងស្រែះហើយ ត្រង់ពាក្យថា គ្រឿងចងស្រែះ បានដល់ គ្រឿងចងស្រែះ ៤ គឺ អភិជ្ឈាកាយគន្ថៈ[1] ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ[2] ១ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ ការគំនុំ ការមិនពេញចិត្ត ក្នុងវាទៈរបស់បុគ្គលដទៃ ឈ្មោះថា ព្យាបាទកាយគន្ថៈ ។

---

១ កិលេសជាគ្រឿងចងនូវនាមកាយ ជាគ្រឿងបន្ត (នូវនាមកាយ) ក្នុងវដ្ដ ដោយអំណាចចុតិបដិសន្ធិ ហៅថា កាយគន្ថ ។ ២ ការចូលចិត្តដែលបដិសេធនូវភាសិតរបស់ព្រះសព្វញ្ញូដោយអាការថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហៅថា ឥទំសច្ចាភិនិវេសៈ ។ អដ្ឋកថា ។

អត្តនោ សីលំ វា វត្តំ វា សីលព្វតំ វា បរាមសតិ សីលព្វតបរាមាសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ កឹការណា វុច្ចន្តិ អាទានគន្ថោ ។ តេហិ គន្ថេហិ រូបំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧប្បត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្ដំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ តំការណា វុច្ចន្តិ អាទានគន្ថោ ។ វិសជ្ជាតិ គន្ថេ វោស្សជ្ជិត្វា វា វិសជ្ជ ។ អថវា គន្ថេ គធិតេ គន្ថិតេ ពន្ធេ វិពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ ផោដយិត្វា វា វិសជ្ជ ។ យថា វយ្ហំ វា រថំ វា សកដំ វា សន្ទមានិកំ វា សជ្ជំ វិសជ្ជំ ករោន្តិ វិកោបេន្តិ ឯវមេវ គន្ថេ វោស្សជ្ជិត្វា វា វិសជ្ជ អថវា គន្ថេ គធិតេ គន្ថិតេ ពន្ធេ វិពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ ផោដយិត្វា វា វិសជ្ជាតិ អាទានគន្ថំ គធិតំ វិសជ្ជ ។

បុគ្គលបរាមាសអង្អែល នូវសីលក្តី វត្តក្តី សីលនិងវត្តក្តី របស់ខ្លួន ឈ្មោះថាសីលព្វតបរាមាសកាយគន្ថៈ ។ ទិដ្ឋិរបស់ខ្លួន ឈ្មោះថា ឥទំសច្ចា-ភិនិវេសកាយគន្ថៈ ។ ព្រោះហេតុអ្វី (គន្ថៈទាំងឡាយ) លោកហៅថា គ្រឿងចងស្រែះគឺសេចក្តីប្រកាន់ ។ ពួកបុគ្គលកាន់យក ប្រកាន់ កួបកាន់ បរាមាសអង្អែល ចូលចិត្តរប កាន់យក ប្រកាន់ កួបកាន់ បរាមាសអង្អែល ចូលចិត្ត វេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧប្បត្តិ បដិសន្ធិ ភព សង្សារ វដ្តៈ ដោយគន្ថៈទាំងនោះ ព្រោះហេតុនោះ គន្ថៈទាំងនោះ លោកហៅថា គ្រឿងចងស្រែះគឺសេចក្តីប្រកាន់ ។ ពាក្យថា កាត់ គឺ លះបង់ ឬកំចាត់បង់ នូវគ្រឿងចងស្រែះទាំងឡាយ ។ មួយទៀតថា ស្រាយ ឬថាលះបង់នូវបំណង គ្រឿងចង ដែលចងស្រែះហើយ បំណងដែលចងហើយ ចងវិសេសហើយ ចងដោយប្រការដ៏ច្រើន ជាប់នៅ បំពាក់នៅ ទាក់នៅ ។ បុគ្គលទាំងឡាយរុះរើ ធ្វើឲ្យខ្ចប់ខ្ចី នូវវក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ មុនបោះបង់ ឬលះចោលនូវគន្ថៈទាំងឡាយ ឬថាស្រាយ ឬលះចោល នូវគន្ថៈទាំងឡាយ ដែលចាក់ស្រែះ ក្រង ចងឆ្នាក់ ពាក់ព័ន្ធ ព័ទ្ធមាំ ជាប់ បំពាក់ ចងមាំ ចងជាប់ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់នូវគ្រឿងចងស្រែះ គឺសេចក្តីប្រកាន់ ដែលចងស្រែះហើយ ។

[១៤១] អាសំ ន កុព្ពន្តិ កុហិញ្ចិ លោកេតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ អាសំ ន កុព្ពន្តីតិ អាសំ ន កុព្ពន្តិ ន ជនេន្តិ ន សញ្ជនេន្តិ ន និព្វត្តេន្តិ នាភិនិព្វត្តេន្តិ ។ កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វា ។ លោកេតិ អបាយលោកេ ។បេ។ អាយតនលោកេ ។ អាសំ ន កុព្ពន្តិ កុហិញ្ចិ លោកេ ។ តេនាហ ភគវា

ន កប្បយន្តិ ន បុរេក្ខរោន្តិ
អច្ចន្តសុទ្ធីតិ ន តេ វទន្តិ
អាទានគន្ថំ គថិតំ វិសជ្ជ
អាសំ ន កុព្ពន្តិ កុហិញ្ចិ លោកេតិ ។

[១៤២] សីមាតិគោ(១) ព្រាហ្មណោ តស្ស នត្ថិ
ញត្វា ច ទិស្វា ច សមុគ្គហីតំ
ន រាគរាគី ន វិរាគរត្តោ
តស្សីធ នត្ថិ បរមុគ្គហីតំ ។

១ ឱ. ម. សីមាតិតោ ។

(១៨១) ពាក្យថា មិនធ្វើនូវបំណងក្នុងលោកណាមួយ សេចក្ដីថា តណ្ហា លោក ហៅថា បំណង បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា មិនធ្វើនូវបំណង គឺមិនធ្វើ មិនបង្កើត មិនឲ្យកើតព្រម មិនឲ្យកើត មិនឲ្យកើតចំពោះ នូវបំណង ។ ពាក្យថា ណាមួយ គឺណាមួយ ឯណាមួយ ឯណានីមួយ ខាងក្នុងក្ដី ខាងក្រៅក្ដី ទាំងខាងក្នុង ខាងក្រៅក្ដី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើនូវបំណង ក្នុងលោកណាមួយ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះខីណាស្រពទាំងឡាយនោះ មិនកំណត់ មិនធ្វើឲ្យជា
ប្រធាន មិនពោលថា ទិដ្ឋិមានសេចក្ដីបរិសុទ្ធិជាទីបំផុត
កាត់គ្រឿងចងស្រែះ គឺសេចក្ដីប្រកាន់ ដែលចងស្រែះ
ហើយ មិនធ្វើនូវបំណង ក្នុងលោកណាមួយ ។

(១៨២) ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ
មិនមានការប្រកាន់មាំ ព្រោះដឹងព្រោះឃើញទេ ព្រាហ្មណ៍
នោះ មិនមានសេចក្ដីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុង
រូបរាគនិងអរូបរាគ ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា
នេះប្រសើរ ដូច្នេះឡើយ ។

## ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ

(១៤៣) សីមាតិគោ ព្រាហ្មណោ តស្ស នត្ថិ ញត្វា ច ទិស្វា ច សមុគ្គហីតន្តិ សីមាតិ ចតស្សោ សីមាយោ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ តទេកដ្ឋា ច កិលេសា អយ បឋមា សីមា ។ ឱឡារិកំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ឱឡារិកោ កាមរាគានុសយោ បដិឃានុសយោ តទេកដ្ឋា ច កិលេសា អយំ ទុតិយា សីមា ។ អណុសហគតំ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ អណុសហគតោ កាមរាគានុសយោ បដិឃានុសយោ តទេកដ្ឋា ច កិលេសា អយំ តតិយា សីមា ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ តទេកដ្ឋា ច កិលេសា អយំ ចតុត្ថា សីមា ។ យតោ ចតូហិ អរិយមគ្គេហិ ឥមា ចតស្សោ សីមាយោ អតិក្កន្តោ ហោតិ សមតិក្កន្តោ វីតិវត្តោ សោ វុច្ចតិ សីមាតិគោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ បេ ។

## សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤

(១៨៣) អធិប្បាយពាក្យថា ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ត្រង់ពាក្យថា ដែន បានដល់ ដែន ៤ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ព្រមទាំងកិលេស ដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ១ ។ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត កាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាត ព្រមទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ២ ។ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិត កាមរាគានុស័យ បដិឃានុស័យដ៏ល្អិត ព្រមទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានោះ នេះដែនទី ៣ ។ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុសយៈ ភវរាគានុសយៈ អវិជ្ជានុសយៈ ព្រមទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានោះ នេះ ដែនទី ៤ ។ កាលណា បុគ្គលកន្លង កន្លងព្រម ប្រព្រឹត្តកន្លងដែនទាំង ៤ នេះ ដោយអរិយមគ្គទាំង ៤ ហើយ បុគ្គលនោះ លោកហៅថា អ្នកកន្លងហួសដែន ។ ពាក្យថា ព្រាហ្មណ៍ សេចក្តីថា បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។ បេ ។

អនិស្សិតោ តានិ បវុច្ចតេ ស ព្រាហ្មណោ ។ តស្សាតិ អរហតោ ខីណាសវស្ស ។ ញត្វាតិ បរចិត្តញ្ញាណេន វា ញត្វា បុព្វេនិវាសានុស្សតិញ្ញាណេន វា ញត្វា ។ ទិស្វាតិ មំសចក្ខុនា វា ទិព្វចក្ខុនា វា ទិស្វាតិ សមាតិតោ ព្រាហ្មណោ តស្ស នត្ថិ ញត្វា ច ទិស្វា ច ។ សមុគ្គហីតន្តិ តស្ស ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ ។ នត្ថីតិ នត្ថិ ន សំវិជ្ជតិ[១] នុបលព្ភតិ ។ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិបស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ សមាតិតោ ព្រាហ្មណោ តស្ស នត្ថិ ញត្វា ច ទិស្វា ច សមុគ្គហីតំ ។

(១៤៤) ន រាគរាគី ន វិរាគរត្តោតិ រាគរត្តា វុច្ចន្តិ យេ បញ្ចសុ កាមគុណេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធា ។

---

១ ឱ. នត្ថីតិ នត្ថិ ន សន្តិ ។ ម. នត្ថិ ន សន្តិ ។

មិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍នោះ គឺ ព្រះអរហន្តខីណាស្រព ។ ពាក្យថា ព្រោះដឹង គឺព្រោះដឹងដោយបរចិត្តញាណក្តី ព្រោះដឹង ដោយបុព្វេនិវាសានុស្សតិញ្ញាណក្តី ។ ពាក្យថា ព្រោះឃើញ គឺ ព្រោះឃើញដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី ហេតុនោះ ទ្រង់ត្រាស់ថា ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់ ព្រោះដឹង ព្រោះឃើញទេ ។ ពាក្យថា ការប្រកាន់មាំ គឺការប្រកាន់ ការបបោសអង្អែល ការចូលចិត្ត ការជាប់ចិត្ត ការចុះចិត្តស៊ប់ នៃព្រាហ្មណ៍នោះថា នេះ ថ្លៃថ្លា ខ្ពង់ខ្ពស់ ប្រសើរ វិសេស ចម្បង ឧត្តម បវរ ។ ពាក្យថា មិនមាន គឺមិនមាន មិនមានព្រម មិនបាន ។ គឺលោក លះបង់ ផ្តាច់បង់ រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ។

[១៨៤] ពាក្យថា មិនមានសេចក្តីត្រេកអរ ក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគ សេចក្តីថា បុគ្គលទាំងឡាយណា ត្រេកអរ រីករាយ ជាប់ ជ្រប់ ងប់ ទាក់ ជ្ពក់ ចំពាក់ ក្នុងកាមគុណទាំងប្រាំ បុគ្គលទាំងនោះ លោកហៅថា អ្នកត្រេកអរ ក្នុងកាមរាគ ។

វិរាគរត្តា វុច្ចន្តិ យេ រូបាវចរារូបាវចរសមាបត្តីសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិ-ពុទ្ធា ។ ន រាគរាគី ន វិរាគរត្តោតិ យតោ កាមរាគោ ច រូបរាគោ ច អរូបរាគោ ច បហីនា ហោន្តិ ឧច្ឆិ-ន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុ-ប្បាទធម្មា ឯត្តាវតា ន រាគរាគី ន វិរាគរត្តោ ។

(១៤៥) តស្សីធំ នត្ថ(១) បរមុគ្គហីតន្តិ តស្សាតិ អរហតោ ខីណាសវស្ស ។ តស្ស ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ ។ នត្ថីតិ នត្ថិ ន សន្តិ ន សំវិជ្ជតិ នុបលព្ភតិ ។ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្ពុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ តស្សីធំ(២) នត្ថិ បរមុគ្គហីតំ ។

១ ម. នត្ថិ ។ ២ ម. តស្សីធ ។

បុគ្គលទាំងឡាយ ណា ត្រេកអរ រីករាយ ជាប់ ជ្រប់ ងប់ ទាក់ ជក់ បំពាក់ ក្នុងរូបាវចរសមាបត្តិ នឹងអរូបាវចរសមាបត្តិទាំងឡាយ បុគ្គលទាំងនោះ លោកហៅថា អ្នកត្រេកអរក្នុងរូបរាគនឹងអរូបរាគ ។ ពាក្យថា មិនមានសេចក្តីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនឹងអរូបរាគ បានសេចក្តីថា ក្នុងកាលណា កាមរាគ រូបរាគ នឹងអរូបរាគ ព្រះខីណាស្រពលះបង់ ផ្តាច់ឫសហើយ ធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដល់នូវភាពមិនមាន មានសភាពមិនកើតឡើង តទៅទៀត ព្រះខីណាស្រព មិនមានសេចក្តីត្រេកអរក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនឹងអរូបរាគ ក្នុងកាលនោះ ដោយកាលមានប្រមាណប៉ុណ្ណេះឯង ។

(១៨៩) អធិប្បាយពាក្យថា ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះប្រសើរដូច្នេះឡើយ ត្រង់ពាក្យថា ព្រាហ្មណ៍នោះ គឺព្រះអរហន្តខីណាស្រព ។ ការប្រកាន់ ការបោះបោសអង្អែល ការចូលចិត្ត ការជាប់ចិត្ត ការចុះចិត្តស៊ប់របស់លោកថា នេះថ្លៃថ្លា ខ្ពង់ខ្ពស់ ប្រសើរ វិសេស ចម្បង ឧត្តម បវរ ។ ពាក្យថា មិនមាន គឺមិនមាន មិនមានព្រម មិនបាន ។ គឺលោកលះបង់ ផ្តាច់បង់ រម្ងាប់បង់ កំចាត់ កំចាត់បង់ហើយ ធ្វើមិនគួរឲ្យកើត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះប្រសើរដូច្នេះឡើយ ។

តេនាហ ភគវា

សីមាតិគោ ព្រាហ្មណោ តស្ស នត្ថិ
ញត្វា ច ទិស្វា ច សមុគ្គហីតំ
ន រាគរាគី ន វិរាគរត្តោ
តស្សីធ នត្ថិ បរមុគ្គហីតន្តិ ។

ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

---

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ណា កន្លងហួសដែនហើយ ព្រាហ្មណ៍នោះ មិនមានការប្រកាន់មាំ ព្រោះដឹង ព្រោះឃើញទេ ព្រាហ្មណ៍នោះ មិនមានសេចក្ដីត្រេកអរ ក្នុងកាមរាគ មិនត្រេកអរក្នុងរូបរាគនិងអរូបរាគ ព្រាហ្មណ៍នោះ មិនមានការប្រកាន់ថា នេះប្រសើរ ដូច្នេះឡើយ ។

ចប់ សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤ ។

# បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

(១៤៦) បរមន្តិ ទិដ្ឋីសុ បរិព្វសានោ
យទុត្តរិ កុរុតេ ជន្តុ លោកេ
ហីនាតិ អញ្ញេ តតោ សព្វមាហ
តស្មា វិវាទានិ អវីតិវត្តោ ។

(១៤៧) បរមន្តិ ទិដ្ឋីសុ បរិព្វសានោតិ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ យថា អាគារិកា វា ឃរេសុ វសន្តិ សាបត្តិកា វា អាបត្តីសុ វសន្តិ សក្កិលេសា វា កិលេសេសុ វសន្តិ ឯវមេវ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ ឥទំ បរមំ អគ្គំ

# បរមដ្ឋកសុត្តនិទ្ទេស ទី ៥

(១៤៦) (ព្រះមានព្រះភាគត្រាស់ថា) សត្វក្នុងលោក កាលត្រាំក្នុងទិដ្ឋិទាំងឡាយ (របស់ខ្លួន) ថា ក្រៃលែង រមែងធ្វើនូវរបស់ណាឲ្យលើសលុប ក៏ពោលនូវរបស់ទាំងអស់ ដទៃ (អំពីរបស់ខ្លួន) នោះថា ថោកទាប ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។

(១៤៧) ពាក្យថា កាលត្រាំក្នុងទិដ្ឋិទាំងឡាយ (របស់ខ្លួន) ថា ក្រៃលែង អធិប្បាយថា សមណព្រាហ្មណ៍ពួកខ្លះ ប្រកបដោយទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ រៀនយក ក្តោបកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្តាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយ ថា នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួន ៗ ពួកអ្នកម្ចាស់ផ្ទះ តែងនៅក្នុងផ្ទះ ពួកអ្នកត្រូវអាបត្តិ តែងនៅក្នុងអាបត្តិទាំងឡាយ ឬពួកអ្នកមានកិលេស នៅក្នុងកិលេសទាំងឡាយ យ៉ាងណា មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកប្រកបក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ រៀនយក ក្តោបកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្តាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយ ថា នេះក្រៃលែង ជាកំពូល

សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តីតិ ឃរមន្តិ ទិដ្ឋីសុ បរិព្វាសោ ។

(១៤៨) យទុត្តរិ កុរុតេ ជន្តុ លោកេតិ យទន្តិ យំ ។ ឧត្តរិ កុរុតេតិ ឧត្តរិ ករោតិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ ។ អយំ សត្ថា សព្វញ្ញូតិ ឧត្តរិ ករោតិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ អយំ ធម្មោ ស្វាក្ខាតោ អយំ គណោ សុប្បដិបន្នោ អយំ ទិដ្ឋិ ភទ្ទិកា អយំ បដិបទា សុប្បញ្ញត្តា អយំ មគ្គោ និយ្យានិកោតិ ឧត្តរិ ករោតិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ករោតិ និព្វត្តេតិ អភិនិព្វត្តេតិ ។ ជន្តូតិ សត្តោ នរោ ។បេ។ មនុជោ ។ លោកេតិ អបាយលោកេ ។បេ។ អាយតនលោកេតិ យទុត្តរិ កុរុតេ ជន្តុ លោកេ ។

ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ហើយ ទៅ ទៅរួម ទៅគ្រប់គ្រង ទៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួនៗ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រាំក្នុងទិដ្ឋិទាំងឡាយ (របស់ខ្លួន) ថាក្រៃលែង ៗ

(១៤៨) អធិប្បាយពាក្យថា សត្វក្នុងលោក រមែងធ្វើនូវរបស់ណាឲ្យលើសលុប ត្រង់ពាក្យថា របស់ណា គឺរបស់ណាមួយ ៗ ពាក្យថា ធ្វើឲ្យលើសលុប គឺធ្វើឲ្យក្រៃលែង ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែង ៗ ធ្វើឲ្យលើសលុប ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែងថា សាស្តានេះជាសព្វញ្ញូ ធ្វើឲ្យលើសលុប ធ្វើឲ្យជាកំពូល ឲ្យប្រសើរ ឲ្យប្រសើរវិសេស ឲ្យជាប្រធាន ឲ្យឧត្តម ឲ្យប្រសើរក្រៃលែង ឲ្យកើត ឲ្យកើតចំពោះថា ធម៌នេះ លោកសំដែងល្អហើយ ពួកនេះប្រតិបត្តិល្អហើយ ទិដ្ឋិនេះល្អ បដិបទានេះ លោកបញ្ញត្តល្អហើយ មគ្គនេះជាទីស្រោចស្រង់សត្វ ៗ ពាក្យថា សត្វ គឺ សត្វ នរជន ៗ បេ ៗ សត្វកើតអំពីមនុស្ស ៗ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ៗ បេ ៗ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វក្នុងលោក រមែងធ្វើនូវរបស់ណាឲ្យលើសលុប ៗ

## បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

(១៤៩) ហីនាតិ អញ្ញេ តតោ សព្វមាហាតិ អត្តនោ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ ឋបេត្វា សព្វេ បរប្បវាទេ ខិបតិ ឧក្ខិបតិ បរិក្ខិបតិ សោ សត្ថា ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្បដិបន្នោ ទិដ្ឋិ ន ភទ្ទិកា បដិបទា ន សុប្បញ្ញត្តា មគ្គោ ន និយ្យានិកោ នត្ថេត្ថ សុទ្ធិ វា វិសុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា ន តត្ថ សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ ឯវមាហ ឯវំ កថេតិ ឯវំ ភណតិ ឯវំ ទីបយតិ ឯវំ វោហរតីតិ ហីនាតិ អញ្ញេ តតោ សព្វមាហ ។

(១៥០) តស្មា វិវាទានិ អវីតិវត្តោតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ទិដ្ឋិកលហានិ ទិដ្ឋិភណ្ឌនានិ ទិដ្ឋិវិគ្គហានិ ទិដ្ឋិវិវាទានិ

## បរមដ្ឋកសុត្តនិទ្ទេស ទី ៥

(១៨៩) ពាក្យថា ពោលនូវរបស់ទាំងអស់ ដទៃ (អំពីរបស់ខ្លួន) នោះថា ថោកទាប សេចក្តីថា បុគ្គលលើកតំកើងសាស្តា ធម៌ដែលសាស្តាសំដែង គណៈ ទិដ្ឋិ បដិបទា មគ្គរបស់ខ្លួន ហើយបោះលើកបោះ បោះបោល នូវវាទៈដទៃទាំងអស់ គឺពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះថា សាស្តានោះ មិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសំដែងដោយប្រពៃទេ គណៈប្រតិបត្តិមិនប្រពៃទេ ទិដ្ឋិមិនល្អទេ បដិបទាមិនមែនបញ្ញត្តល្អទេ មគ្គមិនមែនស្រោចស្រង់សត្វទេ សេចក្តីស្អាត ឬសេចក្តីស្អាតវិសេស សេចក្តីបរិសុទ្ធិ ការរួច រួចវិសេស ឬរួចស្រឡះ មិនមានក្នុងធម៌នុ៎ះទេ ពួកជនមិនមែនស្អាត ស្អាតវិសេស បរិសុទ្ធ រួច រួចវិសេស ឬរួចស្រឡះ ព្រោះធម៌នោះទេ បុគ្គលនោះជាអ្នកថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ ជាមនុស្សកំទេច ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលនូវរបស់ទាំងអស់ ដទៃ (អំពីរបស់ខ្លួន) នោះថា ថោកទាប ។

(១៩០) ពាក្យថា ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ គឺព្រោះដំណើរនោះ ការណ៍នោះ ហេតុនោះ បច្ច័យនោះ និទាននោះ សត្វមិនកន្លង មិនកន្លងផុត មិនកន្លងហួស នូវការឈ្លោះ ព្រោះទិដ្ឋិទាំងឡាយ ការដដែក ព្រោះទិដ្ឋិទាំងឡាយ សេចក្តីប្រ–កួតប្រកាន់ ព្រោះទិដ្ឋិទាំងឡាយ ការទាស់ទែង ព្រោះទិដ្ឋិទាំងឡាយ

ទិដ្ឋិមេធគានិ អវីតិវត្តោ អនតិក្កន្តោ អសមតិក្កន្តោតិ តស្មា វិវាទានិ អវីតិវត្តោ ។ តេនាហ ភគវា

បរមន្តិ ទិដ្ឋីសុ បរិព្វសានោ
យទុត្តរឹ កុរុតេ ជន្តុ លោកេ
ហីនាតិ អញ្ញេ តតោ សព្វមាហ
តស្មា វិវាទានិ អវីតិវត្តោតិ ។

(១៥១) យទត្តនី បស្សតិ អានិសំសំ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
តទេវ សោ តត្ថ សមុគ្គហាយ
និហីនតោ បស្សតិ សព្វមញ្ញំ ។

(១៥២) យទត្តនី បស្សតិ អានិសំសំ ទិដ្ឋេ សុតេ សីលវតេ មុតេ វាតិ យទត្តនីតិ យំ អត្តនិ ។ អត្តា វុច្ចតិ ទិដ្ឋិគតំ ។ អត្តនោ ទិដ្ឋិយា ទ្វេ អានិសំសេ បស្សតិ ទិដ្ឋធម្មិកញ្ច អានិសំសំ សម្បរាយិកញ្ច អានិសំសំ ។

កតមោ ទិដ្ឋិយា ទិដ្ឋធម្មិកោ អានិសំសោ ។ យំទិដ្ឋិកោ សត្ថា ហោតិ តំទិដ្ឋិកា សាវកា ហោន្តិ

ការបៀតបៀន ព្រោះទិដ្ឋិទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សត្វក្នុងលោក ត្រាំក្នុងទិដ្ឋិទាំងឡាយ (របស់ខ្លួន) ថា ក្រៃលែង រមែងធ្វើនូវរបស់ណាឲ្យលើសលុប ក៏ពោលនូវរបស់ទាំងអស់ដទៃ (អំពីរបស់ខ្លួន) នោះថា ថោកទាប ព្រោះហេតុនោះ សត្វមិនកន្លងវិវាទទាំងឡាយបានទេ ។

[១៩១] បុគ្គលឃើញអានិសង្សណា ចំពោះខ្លួន ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត បុគ្គលនោះ ក៏ប្រកាន់អានិសង្សនោះក្នុងទិដ្ឋិនោះ រមែងយល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប ។

[១៩២] អធិប្បាយពាក្យថា បុគ្គលឃើញអានិសង្សណាចំពោះខ្លួនក្នុងអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត ត្រង់ពាក្យថា អានិសង្សណា ចំពោះខ្លួន គឺអានិសង្សណាមួយ ចំពោះខ្លួន ។ ទិដ្ឋិ លោកហៅថា ខ្លួន ។ បុគ្គលឃើញអានិសង្ស នៃទិដ្ឋិរបស់ខ្លួន ២ យ៉ាងគឺ ទិដ្ឋធម្មិកានិសង្ស ១ សម្បរាយិកានិសង្ស ១ ។

ទិដ្ឋធម្មិកានិសង្ស នៃទិដ្ឋិ តើដូចម្តេច ។ គ្រូជាអ្នកប្រកប ដោយទិដ្ឋិណា ពួកសាវ័ក ក៏ជាអ្នកប្រកប ដោយទិដ្ឋិនោះ

## បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

តំ ទិដ្ឋិកំ សត្ថារំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ អបចិតឹ ករោន្តិ លភន្តិ ច តតោ និទានំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អយំ ទិដ្ឋិយា ទិដ្ឋធម្មិកោ អានិសំសោ ។

កតមោ ទិដ្ឋិយា សម្បរាយិកោ អានិសំសោ ។ អយំ ទិដ្ឋិ អលំ នាគត្តាយ វា សុបណ្ណត្តាយ វា យក្ខត្តាយ វា អសុរត្តាយ វា គន្ធព្វត្តាយ វា មហារាជត្តាយ វា ឥន្ទត្តាយ វា ព្រហ្មត្តាយ វា ទេវត្តាយ វា អយំ ទិដ្ឋិ អលំ សុទ្ធិយា វិសុទ្ធិយា បរិសុទ្ធិយា មុត្តិយា វិមុត្តិយា បរិមុត្តិយា ឥមាយ ទិដ្ឋិយា សុជ្ឈន្តិ វិសុជ្ឈន្តិ បរិសុជ្ឈន្តិ មុច្ចន្តិ វិមុច្ចន្តិ បរិមុច្ចន្តិ ឥមាយ ទិដ្ឋិយា សុជ្ឈិស្សាមិ វិសុជ្ឈិស្សាមិ បរិសុជ្ឈិស្សាមិ មុច្ចិស្សាមិ វិមុច្ចិស្សាមិ បរិមុច្ចិស្សាមីតិ អាយតឹ ផលបាដិកង្ខី ហោតិ ។ អយំ ទិដ្ឋិយា សម្បរាយិកោ អានិសំសោ ។ អត្តនោ ទិដ្ឋិយា ឥមេ ទ្វេ អានិសំសេ បស្សតិ ។

ពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជា ធ្វើការកោតក្រែង នូវគ្រូដែលប្រកបដោយទិដ្ឋិនោះ ហើយបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះហេតុតែគ្រូនោះ នេះឈ្មោះថា ទិដ្ឋធម្មិកានិសង្ស នៃទិដ្ឋិ ។

សម្បរាយិកានិសង្សនៃទិដ្ឋិ តើដូចម្តេច ។ បុគ្គលជាអ្នកប្រាថ្នាផលក្នុងអនាគតថា ទិដ្ឋិនេះ គួរដើម្បីបានជានាគ ជាគ្រុឌ ជាយក្ស ជាអសុរ ជាគន្ធព្វ ជាមហារាជ ជាឥន្ទ្រ ជាព្រហ្ម ឬជាទេវតា ទិដ្ឋិនេះ គួរដើម្បីការស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះ ពួកសត្វរមែងស្អាត ស្អាតវិសេស បរិសុទ្ធ រួច រួចវិសេស រួច-ស្រឡះ ដោយទិដ្ឋិនេះ អាត្មាអញនឹងស្អាត ស្អាតវិសេស បរិសុទ្ធ រួច រួចវិសេស រួចស្រឡះ ដោយទិដ្ឋិនេះ ។ នេះសម្បរាយិកានិសង្ស នៃទិដ្ឋិ ។ បុគ្គលឃើញអានិសង្ស ២ យ៉ាងនេះឯង នៃទិដ្ឋិរបស់ខ្លួន ។

ទិដ្ឋសុទ្ធិយាបិ ទ្វេ អានិសំសេ បស្សតិ សុតសុទ្ធិយាបិ ទ្វេ អានិសំសេ បស្សតិ សីលសុទ្ធិយាបិ ទ្វេ អានិសំសេ បស្សតិ វត្តសុទ្ធិយាបិ ទ្វេ អានិសំសេ បស្សតិ មុតសុទ្ធិយាបិ ទ្វេ អានិសំសេ បស្សតិ ទិដ្ឋធម្មិកញ្ច អានិសំសំ សម្បរាយិកញ្ច អានិសំសំ ។

កតមោ មុតសុទ្ធិយា ទិដ្ឋធម្មិកោ អានិសំសោ ។ យំទិដ្ឋិកោ សត្ថា ហោតិ តំទិដ្ឋិកា សាវកា ហោន្តិ ។ បេ ។ អយំ មុតសុទ្ធិយា ទិដ្ឋធម្មិកោ អានិសំសោ ។

កតមោ មុតសុទ្ធិយា សម្បរាយិកោ អានិសំសោ ។ អយំ ទិដ្ឋិ អលំ នាគត្តាយ វា ។ បេ ។ អយំ មុតសុទ្ធិយា សម្បរាយិកោ អានិសំសោ ។ មុតសុទ្ធិយាបិ ឥមេ ទ្វេ អានិសំសេ បស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ យទត្តនី បស្សតិ អានិសំសំ ទិដ្ឋេ សុតេ សីលវតេ មុតេ វា ។

(១៨៣) តទេវ សោ តត្ថ សមុគ្គហាយាតិ តទេវាតិ តំ ទិដ្ឋិគតំ ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ សមុគ្គហាយាតិ ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ

បុគ្គលឃើញអានិសង្ស ៦ យ៉ាង នៃទិដ្ឋសុទ្ធិផង ឃើញអានិសង្ស ៦ យ៉ាង នៃសុតសុទ្ធិផង ឃើញអានិសង្ស ៦ យ៉ាង នៃសីលសុទ្ធិផង ឃើញអានិសង្ស ៦ យ៉ាង នៃវត្តសុទ្ធិផង ឃើញអានិសង្ស ៦ យ៉ាងនៃមុតសុទ្ធិផង ដែលជាទិដ្ឋធម្មិកានិសង្សនឹងសម្បរាយិកានិសង្ស ។

ទិដ្ឋធម្មិកានិសង្ស នៃមុតសុទ្ធិ តើដូចម្តេច ។ គ្រូប្រកបក្នុងទិដ្ឋិណា ពួកសាវ័កក៏ប្រកបក្នុងទិដ្ឋិនោះ ។ បេ ។ នេះទិដ្ឋធម្មិកានិសង្ស នៃមុតសុទ្ធិ ។

សម្បរាយិកានិសង្សនៃមុតសុទ្ធិ តើដូចម្តេច ។ ទិដ្ឋិនេះ គួរដើម្បីបានជានាគ ។ បេ ។ នេះសម្បរាយិកានិសង្ស នៃមុតសុទ្ធិ ។ បុគ្គលឃើញ មើល រមិលមើល សំឡឹងមើល ពិចារណាឃើញនូវអានិសង្ស ៦ យ៉ាងនេះឯង នៃមុតសុទ្ធិ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញអានិសង្សណា ចំពោះខ្លួន ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនឹងវត្ត ។

[១៩៣] ពាក្យថា បុគ្គលនោះក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ ត្រង់ពាក្យថា នោះ គឺទិដ្ឋិនោះ ។ ពាក្យថា ក្នុងទិដ្ឋិនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការគួររបស់ខ្លួន ក្នុងសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ប្រកាន់ គឺប្រកាន់ គាំគេង កួចកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតថា នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស

ធាមោក្ខំ ឧត្តមំ បវរន្តិ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ តទេវ សោ តត្ថ សមុគ្គហាយ ។

(១៥៤) និហីនតោ បស្សតិ សព្វមញ្ញេតិ អញ្ញំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ ហីនតោ និហីនតោ ឱមកតោ លាមកតោ ជតុក្កតោ បរិត្តតោ បស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ និហីនតោ បស្សតិ សព្វមញ្ញំ ។ តេនាហ ភគវា

យទុត្តរិ បស្សតិ អានិសំសំ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
តទេវ សោ តត្ថ សមុគ្គហាយ
និហីនតោ បស្សតិ សព្វមញ្ញេតិ ។

(១៥៥) តំ វាបិ គន្ថំ កុសលា វទន្តិ
យំ និស្សិតោ បស្សតិ ហីនមញ្ញំ
តស្មា ហិ ទិដ្ឋំវ សុតំ មុតំ វា
សីលព្វតំ ភិក្ខុ ន និស្សយេយ្យ ។

ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ ។

(១៩៨) ពាក្យថា រមែងយល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប គឺឃើញ មើល រមិលមើល សំឡឹងមើល ពិចារណាឃើញ នូវគ្រូដទៃ ធម៌ដែលគ្រូនោះសំដែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ថា ថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងយល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលឃើញអានិសង្សណា ចំពោះខ្លួន ក្នុងអារម្មណ៍ដែល
ឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬក្នុងសីលនិងវត្ត
បុគ្គលនោះ ក៏ប្រកាន់អានិសង្សនោះ ក្នុងទិដ្ឋិនោះ រមែង
យល់ឃើញសភាពដទៃទាំងអស់ថា ថោកទាប ។

(១៩៩) បុគ្គល អាស្រ័យសភាពណាហើយ តែងឃើញសភាព
ដទៃថា ថោកទាប ពួកជនអ្នកឈ្លាសតែងពោលការឃើញ
នោះថាជាគ្រឿងជាប់ចំពាក់ ព្រោះហេតុនោះ ភិក្ខុមិនត្រូវ
អាស្រ័យអារម្មណ៍ ដែលឃើញ ដែលឮ ដែលប៉ះពាល់
ហើយ ឬសីលនិងវត្តឡើយ ។

(១៨៦) តំ ភវេ គន្ថំ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុសលា អាយតនកុសលា បដិច្ចសមុប្បាទកុសលា សតិបដ្ឋានកុសលា សម្មប្បធានកុសលា ឥទ្ធិបាទកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្ពានកុសលា តេ កុសលា ឯវំ វទន្តិ គន្ថោ ឯសោ លគ្គនំ ឯតំ ពន្ធនំ ឯតំ បលិពោធោ ឯសោតិ ឯវំ វទន្តិ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តំ ភវេ គន្ថំ កុសលា វទន្តិ ។

(១៨៧) យំ និស្សិតោ បស្សតិ ហីនមញ្ញន្តិ យំ និស្សិតោតិ យំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ និស្សិតោ សន្និស្សិតោ អល្លីនោ ឧបគតោ អជ្ឈោសិតោ អធិមុត្តោ ។

(១៩៦) អធិប្បាយពាក្យថា ពួកជនអ្នកឈ្លាស តែងពោលការឃើញនោះ ថាជាគ្រឿងជាប់ចំពាក់ ត្រង់ពាក្យថា ពួកជនអ្នកឈ្លាស បានដល់ពួកជនអ្នកឈ្លាសក្នុងខន្ធ អ្នកឈ្លាសក្នុងធាតុ អ្នកឈ្លាសក្នុងអាយតនៈ អ្នកឈ្លាសក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសក្នុងសតិប្បដ្ឋាន អ្នកឈ្លាសក្នុងសម្មប្បធាន អ្នកឈ្លាសក្នុងឥទ្ធិបាទ អ្នកឈ្លាសក្នុងឥន្ទ្រិយ អ្នកឈ្លាសក្នុងពលៈ អ្នកឈ្លាសក្នុងពោជ្ឈង្គ អ្នកឈ្លាសក្នុងមគ្គ អ្នកឈ្លាសក្នុងផល អ្នកឈ្លាសក្នុងព្រះនិព្វាន ពួកជនអ្នកឈ្លាសទាំងនោះ តែងពោលយ៉ាងនេះ គឺតែងពោលយ៉ាងនេះ និយាយយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះថា នុ៎ះជាគ្រឿងជាប់ចំពាក់ នុ៎ះជាគ្រឿងជាប់ស្អិត នុ៎ះជាគ្រឿងចង នុ៎ះជាគ្រឿងកង្វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនអ្នកឈ្លាស តែងពោលការឃើញនោះ ថាជាគ្រឿងជាប់ចំពាក់ ។

(១៩៧) អធិប្បាយពាក្យថា បុគ្គលអាស្រ័យសភាពណាហើយ តែងឃើញសភាពដទៃថា ថោកទាប ត្រង់ពាក្យថា បុគ្គលអាស្រ័យសភាពណាហើយ គឺអាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ជឿស៊ប់ ជឿជាក់នូវគ្រូណា ធម៌ដែលគ្រូនោះសំដែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ។

បស្សតិ ហីនមញ្ញតិ អញ្ញំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ បស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ យំ និស្សិតោ បស្សតិ ហីនមញ្ញំ ។

(១៥៨) តស្មា ហិ ទិដ្ឋីវ សុតំ មុតំ វា សីលព្វតំ ភិក្ខុ ន និស្សយេយ្យាតិ តស្មា(១) តំការណា តំហេតុ តប្បច្ចយា តំនិទានា ទិដ្ឋំ វា ទិដ្ឋសុទ្ធឹ វា សុតំ វា សុតសុទ្ធឹ វា មុតំ វា មុតសុទ្ធឹ វា សីលំ វា សីលសុទ្ធឹ វា វត្តំ វា វត្តសុទ្ធឹ វា ន និស្សយេយ្យ ន គណ្ហេយ្យ ន បរាមសេយ្យ នាភិនិវិសេយ្យាតិ តស្មា ហិ ទិដ្ឋីវ សុតំ មុតំ វា សីលព្វតំ ភិក្ខុ ន និស្សយេយ្យ ។ តេនាហ ភគវា

តំ វាបិ គន្ថំ កុសលា វទន្តិ
យំ និស្សិតោ បស្សតិ ហីនមញ្ញំ

១ ឱ. តស្មាតិ តស្មា ។

ពាក្យថា តែងឃើញសភាពដទៃ ថា ថោកទាប គឺឃើញ មើល រមិល មើល សំឡឹងមើល ពិចារណាឃើញ នូវគ្រូដទៃ ធម៌ដែលគ្រូនោះ សំដែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គ ថា ថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គល អាស្រ័យសភាពណាហើយ តែងឃើញសភាពដទៃ ថា ថោកទាប ។

(១៥៨) ពាក្យថា ព្រោះហេតុនោះ ភិក្ខុមិនត្រូវអាស្រ័យអារម្មណ៍ ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬសីលនិងវត្តឡើយ គឺ ព្រោះដំណើរនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យ នោះ ព្រោះនិទាននោះ ភិក្ខុមិនត្រូវអាស្រ័យ មិនត្រូវប្រកាន់ មិនត្រូវ ស្ទាបអង្អែល មិនត្រូវចុះចិត្តស៊ប់ នូវទិដ្ឋៈ(១) ឬទិដ្ឋសុទ្ធិ(២) សុតៈ(៣) ឬសុតសុទ្ធិ(៤) មុតៈ(៥) ឬមុតសុទ្ធិ(៦) សីល ឬសីលសុទ្ធិ វត្ត ឬវត្ត-សុទ្ធិទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ភិក្ខុមិនត្រូវ អាស្រ័យអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ហើយ ឬ សីល និងវត្តឡើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលអាស្រ័យសភាពណាហើយ តែងឃើញសភាពដទៃ
ថាថោកទាប ពួកជនអ្នកឈ្លាស តែងពោលការឃើញនោះ

---

១ អារម្មណ៍ដែលឃើញ ។ ២ បរិសុទ្ធិព្រោះឃើញ ។ ៣ អារម្មណ៍ដែលឮ ។
៤ បរិសុទ្ធិព្រោះឮ ។ ៥ អារម្មណ៍ដែលប៉ះពាល់ ។ ៦ បរិសុទ្ធិព្រោះប៉ះពាល់ ។

តស្មា ហិ ទិដ្ឋីវ សុតំ មុតំ វា
សីលព្វតំ ភិក្ខុ ន និស្សយេយ្យាតិ ។

(១៥៩) ទិដ្ឋិម្បិ លោកស្មិំ ន កប្បយេយ្យ
ញាណេន វា សីលវតេន វាបិ
សមោតិ អត្តានមនូបនេយ្យ
ហីនោ ន មញ្ញេថ វិសេសិ វាបិ ។

(១៦០) ទិដ្ឋិម្បិ លោកស្មិំ[១] ន កប្បយេយ្យ ញាណេន វា សីលវតេន វាបីតិ អដ្ឋសមាបត្តិញាណេន វា បញ្ចាភិញ្ញាញាណេន វា មិច្ឆាញាណេន វា សីលេន វា វតេន វា សីលវតេន វា ទិដ្ឋិំ ន កប្បយេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ។ លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេតិ ទិដ្ឋិម្បិ លោកស្មិំ ន កប្បយេយ្យ ញាណេន វា សីលវតេន វាបិ ។

(១៦១) សមោតិ អត្តានមនូបនេយ្យាតិ សទិសោហមស្មីតិ អត្តានំ ន ឧបនេយ្យ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា

១ ឱ. ម. លោកស្មឹ ។

ថាជាគ្រឿងជាប់ចំពាក់ ព្រោះហេតុនោះ ភិក្ខុមិនត្រូវអាស្រ័យអារម្មណ៍ ដែលឃើញ ដែលឮ ដែលប៉ះពាល់ ហើយ ឬសីលនិងវត្តឡើយ ។

(១៥៩) បុគ្គលមិនគប្បីតែងតាំងទិដ្ឋិ ក្នុងលោក ដោយញាណ ឬដោយសីលវត្ត មិនគប្បីប្រៀបធៀបខ្លួនថា ស្មើ (នឹងបុគ្គលដទៃ) មិនគប្បីសំគាល់ថា ថោកថយ ឬថាវិសេសឡើយ ។

(១៦០) ពាក្យថា បុគ្គលមិនគប្បីតែងតាំងទិដ្ឋិ ក្នុងលោកដោយញាណ ឬដោយសីលវត្ត គឺមិនគប្បីតែងតាំង មិនគប្បីបង្កើត មិនគប្បីបង្កើតព្រម មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតចំពោះ នូវទិដ្ឋិ ដោយអដ្ឋសមាបត្តិញាណ ដោយបញ្ចាភិញ្ញាញាណ ដោយមិច្ឆាញាណ ដោយសីល ដោយវត្ត ឬដោយសីលវត្ត ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីតែងតាំងទិដ្ឋិ ក្នុងលោក ដោយញាណ ឬដោយសីលវត្ត ។

(១៦១) ពាក្យថា មិនគប្បីប្រៀបធៀបខ្លួនថា ស្មើ គឺ មិនគប្បីប្រៀបធៀបខ្លួនថា អាត្មាអញជាអ្នកស្មើនឹងគេ ដោយជាតិ ដោយគោត្រ ដោយភាពនៃខ្លួន ជាកូនអ្នកមានត្រកូល ដោយភាពនៃខ្លួនជាអ្នកមានសម្បុរល្អ

ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិ-ភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនាតិ សមោតិ អត្តានមនុបនេយ្យ ។

(១៦២) ហីនោ ន មញ្ញេថ វិសេសិ វាបីតិ ហី-នោហមស្មីតិ អត្តានំ ន ឧបនេយ្យ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា សេ-យ្យោហមស្មីតិ អត្តានំ ន ឧបនេយ្យ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនាតិ ហីនោ ន មញ្ញេថ វិសេសិ វាបិ ។ តេនាហ ភគវា

ទិដ្ឋីបិ លោកស្មិំ ន កប្បយេយ្យ
ញាណេន វា សីលវតេន វាបិ
សមោតិ អត្តានមនុបនេយ្យ
ហីនោ ន មញ្ញេថ វិសេសិ វាបីតិ ។

(១៦៣) អត្តំ បហាយ អនុបាទិយានោ
ញាណេបិ សោ និស្សយ នោ ករោតិ
ស វេ វិយត្តេសុ ន វគ្គសារី
ទិដ្ឋីបិ សោ ន បច្ចេតិ កិញ្ចិ ។

ដោយទ្រព្យ ដោយការរៀនមន្ត ដោយកន្លែងធ្វើនូវការងារ ដោយកន្លែងរៀនសិល្បៈ ដោយកន្លែងនៃវិជ្ជា ដោយពហុស្សូត្រ ដោយបដិភាណ ឬដោយវត្ថុណាមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីប្រៀបផ្ទឹមខ្លួនថា ស្មើ ។

(១៦២) ពាក្យថា មិនគប្បីសំគាល់ថា ថោកទាប ឬវិសេស គឺ មិនគប្បីប្រៀបផ្ទឹមខ្លួនថា អាត្មាអញជាអ្នកថោកទាប ដោយជាតិ ដោយគោត្រ ។ បេ ។ ឬដោយវត្ថុណាមួយ មិនគប្បីប្រៀបផ្ទឹមខ្លួនថា អាត្មាអញជាអ្នកប្រសើរ ដោយជាតិ ដោយគោត្រ ។ បេ ។ ឬដោយវត្ថុណាមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីសំគាល់ថា ថោកទាប ឬវិសេស ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមិនគប្បីតែងតាំងទិដ្ឋិក្នុងលោក ដោយញាណ ឬដោយ
សីលវត្ត មិនគប្បីប្រៀបផ្ទឹមខ្លួនថា ស្មើ (នឹងបុគ្គលដទៃ)
មិនគប្បីសំគាល់ថា ថោកទាប ឬវិសេសឡើយ ។

(១៦៣) បុគ្គលនោះ លះបង់អត្តា មិនប្រកាន់ មិនធ្វើនិស្ស័យ
សូម្បីក្នុងញាណទេ កាលសត្វយល់បែកគ្នាផ្សេង ៗ បុគ្គល
នោះឯង ជាអ្នកមិនលុះតាមពួក បុគ្គលនោះ មិនត្រឡប់
មកកាន់ទិដ្ឋិណាមួយឡើយ ។

(១៦៨) អត្តំ បហាយ អនុបាទិយានោតិ អត្តំ បហាយាតិ អត្តទិដ្ឋឹ បហាយ ។ អត្តំ បហាយាតិ គាហំ(១) បហាយ ។ អត្តំ បហាយាតិ តណ្ហាវសេន ទិដ្ឋិវសេន គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា ។ អត្តំ បហាយ អនុបាទិយានោតិ ចតូហិ ឧបាទានេហិ អនុបាទិយមានោ អគ្គណ្ហមានោ អបរាមសមានោ អនភិនិវិសមានោតិ អត្តំ បហាយ អនុបាទិយានោ ។

(១៦៩) ញាណេបិ សោ និស្សយំ នោ ករោតីតិ អដ្ឋសមាបត្តិញាណេ វា បញ្ចាភិញ្ញាញាណេ វា មិច្ឆាញាណេ វា តណ្ហានិស្សយំ វា ទិដ្ឋិនិស្សយំ វា ន ករោតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ញាណេបិ សោ និស្សយំ នោ ករោតិ

(១៦៦) ស វេ វិយត្តេសុ ន វគ្គសារីតិ ស វេ វិយត្តេសុ ភិន្នេសុ ទ្វេជ្ឈាបន្នេសុ ទ្វេឡ្ហកជាតេសុ នានាទិដ្ឋិកេសុ នានាខន្តិកេសុ នានារុចិកេសុ

---

១ ឱ. ម. អត្តគាហំ ។

(១៦៤) អធិប្បាយពាក្យថា លះបង់អត្តា មិនប្រកាន់ ត្រង់ពាក្យថា លះបង់អត្តា គឺលះបង់អត្តទិដ្ឋិ ។ ពាក្យថា លះបង់អត្តា គឺ លះបង់សេចក្តីប្រកាន់ ។ ពាក្យថា លះបង់អត្តា គឺលះបង់ បន្សាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវសេចក្តីប្រកាន់ ការស្ទាបអង្អែល សេចក្តីប្រកាន់ស្អិត ការជ្រុលជ្រប់ ការខុនទៅ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ។ ពាក្យថា លះបង់អត្តា មិនប្រកាន់ គឺ មិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិត ដោយឧបាទាន៤ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់អត្តា មិនប្រកាន់ ។

(១៦៥) ពាក្យថា បុគ្គលនោះ មិនធ្វើនិស្ស័យសូម្បីក្នុងញាណទេ គឺ មិនធ្វើ មិនបង្កើត មិនបង្កើតព្រម មិនឲ្យកើត មិនឲ្យកើតចំពោះនូវតណ្ហានិស្ស័យ ឬទិដ្ឋិនិស្ស័យ ក្នុងអដ្ឋសមាបត្តិញាណ ក្នុងបញ្ចាភិញ្ញាញាណ ឬក្នុងមិច្ឆាញាណ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ មិនធ្វើនិស្ស័យក្នុងញាណ ។

(១៦៦) ពាក្យថា កាលសត្វយល់បែកគ្នាផ្សេង ៗ បុគ្គលនោះឯងជាអ្នកមិនលុះតាមពួក គឺកាលពួកសត្វ អ្នកកំណត់ហើយ បែកគ្នាហើយ បែកចិត្តជាពីរ កើតទៅជាពីរពួក ប្រកបដោយទិដ្ឋិផ្សេង ៗ ប្រកបដោយការគួរ ផ្សេង ៗ ប្រកបដោយសេចក្តីពេញចិត្ត ផ្សេង ៗ

បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

នានាលទ្ធិកេសុ នានាទិដ្ឋិនិស្សយនិស្សិតេសុ ឆន្ទា-គតឹ គច្ឆន្តេសុ ទោសាគតឹ គច្ឆន្តេសុ មោហាគតឹ គច្ឆន្តេសុ ភយាគតឹ គច្ឆន្តេសុ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយា-គតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យាយតិ វុយ្ហតិ សំហារិយតីតិ ស វេ វិយត្តេសុ ន វគ្គសារី ។

(១៦៧) ទិដ្ឋឹបិ សោ ន បច្ចេតិ កិញ្ចីតិ តស្ស ទ្វាសដ្ឋិទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ កិញ្ចិ ទិដ្ឋិគតំ ន បច្ចេតិ ន បច្ចាគច្ឆតីតិ ទិដ្ឋឹបិ សោ ន បច្ចេតិ កិញ្ចិ ។ តេនាហ ភគវា

ប្រកបដោយលទ្ធិផ្សេង ៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេង ៗ កាលលុះនូវឆន្ទាគតិ លុះនូវទោសាគតិ លុះនូវមោហាគតិ លុះនូវភយាគតិ បុគ្គលនោះ មិនលុះនូវឆន្ទាគតិ មិនលុះនូវទោសាគតិ មិនលុះនូវមោហាគតិ មិនលុះនូវភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺធម៌ជាពួកទាំងឡាយនាំទៅ នាំយកទៅ បន្សាត់ទៅ ដឹកនាំទៅ មិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) កាលសត្វយល់បែកគ្នាផ្សេង ៗ បុគ្គលនោះឯង មិនលុះតាមពួក ៗ

(១៦៧) ពាក្យថា បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ គឺទិដ្ឋិ ៦២ បុគ្គលនោះលះបង់ហើយ ផ្តាច់បង់ហើយ រម្ងាប់ហើយ ស្ងប់សន្ងត់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ បុគ្គលនោះ មិនត្រឡប់មក មិនវិលមកកាន់ទិដ្ឋិណាមួយទេ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អត្តំ បហាយ អនុបាទិយានោ
ញាណេបិ សោ និស្សយ នោ ករោតិ
ស វេ វិយត្តេសុ ន វគ្គសារី
ទិដ្ឋីបិ សោ ន បច្ចេតិ កិញ្ចិ ។

(១៦៨) យស្សូភយន្តេ បណិធីធ នត្ថិ
ភវាភវាយ ឥធ វា ហុរំ វា
និវេសនា តស្ស ន សន្តិ កេចិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ ។

(១៦៩) យស្សូភយន្តេ បណិធីធ នត្ថិ ភវាភវាយ ឥធ វា ហុរំ វាតិ យស្សាតិ អរហតោ ខីណាសវស្ស ។ អន្តាតិ ផស្សោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ។ អតីតំ ឯកោ អន្តោ អនាគតំ ទុតិយោ អន្តោ ។ សុខា វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ ។ នាមំ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ ។ ឆ អជ្ឈត្តិកានិ អាយតនានិ ឯកោ អន្តោ ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ ។ សក្កាយោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោ ។

បុគ្គលនោះ លះបង់អត្តា មិនប្រកាន់ មិនធ្វើនិស្ស័យ សូម្បីក្នុងញាណ កាលសត្វយល់បែកគ្នាផ្សេងៗ បុគ្គលនោះឯង មិនលុះតាមពួក បុគ្គលនោះ មិនត្រឡប់មកកាន់ទិដ្ឋិណាមួយឡើយ ។

(១៦៨) ការតាំងទុកអន្តៈទាំងពីរ ក្នុងលោកនេះ និងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណា មិនមានទេ ជម្រកទាំងឡាយណាមួយ និងការពិនិត្យ ហើយប្រកាន់ ក្នុងធម៌ទាំងឡាយ នៃបុគ្គលនោះ មិនមានឡើយ ។

(១៦៩) អធិប្បាយពាក្យថា ការតាំងទុកអន្តៈទាំងពីរ ក្នុងលោកនេះ និងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា អន្តៈ គឺផស្សៈ ជាអន្តៈមួយ ការកើតឡើងនៃផស្សៈ ជាអន្តៈទីពីរ ។ អតីត ជាអន្តៈមួយ អនាគត ជាអន្តៈទីពីរ ។ សុខវេទនា ជាអន្តៈមួយ ទុក្ខវេទនា ជាអន្តៈទីពីរ ។ នាម ជាអន្តៈមួយ រូបជាអន្តៈទីពីរ ។ អាយតនៈខាងក្នុង៦ ជាអន្តៈមួយ អាយតនៈខាងក្រៅ៦ ជាអន្តៈទីពីរ ។ សក្កាយ ជាអន្តៈមួយ ការកើតឡើងនៃសក្កាយ ជាអន្តៈទីពីរ ។

បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

បណិធិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ភវាភវាយាតិ ភវាភវាយ កម្មភវាយ បុនព្ភវាយ កាមភវាយ កម្មភវាយ កាមភវាយ បុនព្ភវាយ រូបភវាយ កម្មភវាយ រូបភវាយ បុនព្ភវាយ អរូបភវាយ កម្មភវាយ អរូបភវាយ បុនព្ភវាយ បុនប្បុនំ ភវាយ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា ។ ឥធាតិ សកត្តភាវោ ។ ហុរាតិ បរត្តភាវោ ។ ឥធាតិ សករូបវេទនាសញ្ញាសង្ខារវិញ្ញាណំ ។ ហុរាតិ បររូបវេទនាសញ្ញាសង្ខារវិញ្ញាណំ ។ ឥធាតិ ឆ អជ្ឈត្តិកានិ អាយតនានិ ។ ហុរាតិ ឆ ពាហិរានិ អាយតនានិ ។ ឥធាតិ មនុស្សលោកោ ។ ហុរាតិ ទេវលោកោ ។ ឥធាតិ កាមធាតុ ។ ហុរាតិ រូបធាតុ អរូបធាតុ ។ ឥធាតិ កាមធាតុ រូបធាតុ ។ ហុរាតិ អរូបធាតុ ។

តណ្ហា លោកហៅថា ការដំកល់ទុក បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ដើម្បីភពតូចនិងភពធំ គឺដើម្បីកម្មភព បុនព្ភព ឈ្មោះថាភពតូចនិងភពធំ គឺថាដើម្បីកាមភព កម្មភព កាមភព បុនព្ភព រូបភព កម្មភព រូបភព បុនព្ភព អរូបភព កម្មភព អរូបភព បុនព្ភព គឺថាដើម្បីការកើតរឿយ ៗ ការទៅរឿយ ៗ ឧបបត្តិរឿយ ៗ បដិសន្ធិរឿយៗ ការញុំាងអត្តភាពឲ្យកើតរឿយៗ ។ ពាក្យថា លោកនេះ គឺអត្តភាព របស់ខ្លួន ។ ពាក្យថា លោកដទៃ គឺអត្តភាព របស់បុគ្គលដទៃ ។ ពាក្យថា លោកនេះ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ របស់ខ្លួន ។ ពាក្យថា លោកដទៃ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ របស់បុគ្គលដទៃ ។ ពាក្យថា លោកនេះ គឺ អាយតនៈខាងក្នុង៦ ។ ពាក្យថា លោកដទៃ គឺ អាយតនៈខាងក្រៅ ៦ ។ ពាក្យថា លោកនេះ គឺមនុស្សលោក ។ ពាក្យថា លោកដទៃ គឺ ទេវលោក ។ ពាក្យថា លោកនេះ គឺ កាមធាតុ ។ ពាក្យថា លោកដទៃ គឺរូបធាតុ អរូបធាតុ ។ ពាក្យថា លោកនេះ គឺ កាមធាតុ រូបធាតុ ។ ពាក្យថា លោកដទៃ គឺអរូបធាតុ ។

យស្សូភយន្តេ បណិធីធ នត្ថិ ភវាភវាយ ឥធ វា ហុរំ វាតិ យស្ស ឧភោ អន្តេ ភវាភវាយេ ឥធ វា ហុរំ វា បណិធិ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ យស្សូភយន្តេ បណិធីធ នត្ថិ ភវាភវាយ ឥធ វា ហុរំ វា ។

(១៧០) និវេសនា តស្ស ន សន្តិ កេចីតិ និវេសនាតិ ទ្វេ និវេសនា តណ្ហានិវេសនា ច ទិដ្ឋិនិវេសនា ច ។ បេ ។ អយំ តណ្ហានិវេសនា ។ បេ ។ អយំ ទិដ្ឋិនិវេសនា ។ តស្សាតិ អរហតោ ខីណាសវស្ស ។ ន សន្តីតិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ និវេសនា តស្ស ន សន្តិ

ពាក្យថា ការតាំងទុកអន្តៈទាំងពីរក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណា មិនមានទេ បានសេចក្តីថា ការតាំងទុកអន្តៈទាំងពីរ ក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណា មិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណា លះបង់ហើយ ផ្តាច់ផ្តិលហើយ រម្ងាប់ហើយ ស្ងប់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការតាំងទុកអន្តៈទាំងពីរ ក្នុងលោកនេះនិងលោកដទៃ ដើម្បីភពតូចភពធំនេះ នៃបុគ្គលណា មិនមានទេ ។

[១៧០] អធិប្បាយពាក្យថា ដម្រេកទាំងឡាយណាមួយ នៃបុគ្គលនោះ មិនមាន ត្រង់ពាក្យថា ដម្រេកទាំងឡាយ បានដល់ ដម្រេក ២ យ៉ាង គឺដម្រេកគឺតណ្ហា ១ ដម្រេកគឺទិដ្ឋិ ១ ។ បេ ។ នេះដម្រេកគឺតណ្ហា ។ បេ ។ នេះដម្រេកគឺទិដ្ឋិ ។ ពាក្យថា នៃបុគ្គលនោះ គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា មិនមាន គឺ មិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គល លះបង់ហើយ ផ្តាច់ផ្តិលហើយ រម្ងាប់ហើយ គ្រប់សង្កត់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដម្រេកទាំងឡាយណាមួយ នៃបុគ្គលនោះ មិនមានឡើយ ។

## បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

[១៧១] ធម្មេសុ និច្ឆេយ្យ សមុគ្គហីតន្តិ ធម្មេសូតិ ទ្វាសដ្ឋិយា ទិដ្ឋិគតេសុ ។ និច្ឆេយ្យាតិ និច្ឆិនិត្វា វិនិច្ឆិនិត្វា វិចិនិត្វា បវិចិនិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ឱធិគ្គាហោ ពិលគ្គាហោ វរគ្គាហោ កោដ្ឋាសគ្គាហោ ឧច្ចយគ្គាហោ សមុច្ចយគ្គាហោ ឥទំ សច្ចំ តច្ឆំ តថំ ភូតំ យាថាវំ អវិបរីតន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ ។ តេនាហ ភគវា

យស្សូភយន្តេ បណិធីធ នត្ថិ
ភវាភវាយ ឥធ វា ហុរំ វា
និវេសនា តស្ស ន សន្តិ កេចិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតន្តិ ។

(១៧១) អធិប្បាយពាក្យថា ការពិនិត្យហើយប្រកាន់ ក្នុងធម៌ទាំងឡាយ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺ ក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ពិនិត្យ គឺការពិនិត្យ ពិចារណា សន្សំ ជ្រើសរើស ថ្លឹង ត្រិះរិះ សំដែងឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ហើយកាន់យកតាមផ្លូវ កាន់យកតាមចំណែក កាន់យកមាំ កាន់យកតាមសង្កាត់ កាន់យកជាគំនរ កាន់យកដោយការសន្សំព្រម គឺសេចក្ដីប្រកាន់ ការស្ទាបអង្អែល ការប្រកាន់ស្អិត ការប្រកាន់ស៊ប់ ការចុះចិត្តជឿថា នេះទៀង ពិត មិនឃ្លៀងឃ្លាត ប្រាកដ គួរតាមសភាពពិត មិនប្រែប្រួល រមែងមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលបានលះបង់ហើយ ផ្ដាច់ផ្ដិលហើយ រម្ងាប់ហើយ ស្ងប់ហើយ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការពិនិត្យហើយប្រកាន់ក្នុងធម៌ទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគសំដែងថា

ការតាំងទុកអន្តះទាំងពីរ ក្នុងលោកនេះនឹងលោកដទៃ ដើម្បី
ភពតូចភពធំនេះ នៃបុគ្គលណា មិនមានទេ ជម្រកទាំង
ឡាយណាមួយ (នឹង) ការពិនិត្យ ហើយប្រកាន់ ក្នុង
ធម៌ទាំងឡាយ នៃបុគ្គលនោះ មិនមានឡើយ ។

(១៧២) តស្សីធ ទិដ្ឋេវ សុតេ មុតេ វា
បកប្បិតា នត្ថិ អណូបិ សញ្ញា
តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានំ
កេនីធ លោកស្មិំ វិកប្បយេយ្យ ។

(១៧៣) តស្សីធ ទិដ្ឋេវ សុតេ មុតេ វា បកប្បិតា នត្ថិ អណូបិ សញ្ញាតិ តស្ស អរហតោ ខីណាសវស្ស(១) ទិដ្ឋេ វា ទិដ្ឋសុទ្ធិយា វា សុតេ វា សុតសុទ្ធិយា វា មុតេ វា មុតសុទ្ធិយា វា សញ្ញា បុព្វង្គមតា អធិបតេយ្យតា សញ្ញាវិភូតេន សញ្ញាយ ឧដ្ឋបិតា(២) កប្បិតា(៣) អភិសង្ខតា សណ្ឋាបិតា ទិដ្ឋិ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ(៤) បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តស្សីធ ទិដ្ឋេវ សុតេ មុតេ វា បកប្បិតា នត្ថិ អណូបិ សញ្ញា ។

(១៧៤) តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានន្តិ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ បេ ។

---

១ ឱ. ម. តស្សាតិ អរហតោ ខីណាសវស្ស តស្សាតិ ទិស្សតិ ។ ២ ឱ. ឧដ្ឋបិតោ ។ ម. ឧដ្ឋបិតា សមុដ្ឋបិតា ។ ៣ ម. កប្បិតា បកប្បិតា ។ ៤ ម. ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ ។

(១៧២) សេចក្ដីសំគាល់សូម្បីតូចមួយ ដែលកំណត់ហើយ ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះ មិនមានទេ អ្នកផងគប្បីកំណត់ បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ ក្នុងលោកនេះ ដោយកិលេស ដូចម្ដេចបាន ។

(១៧៣) ពាក្យថា សេចក្ដីសំគាល់សូម្បីតូចមួយ ដែលកំណត់ហើយ ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះ មិនមានទេ សេចក្ដីថា សេចក្ដីសំគាល់ ភាពជាប្រធាន ភាពជាធំ ក្នុងទិដ្ឋៈ ឬក្នុងទិដ្ឋសុទ្ធិ ក្នុងសុតៈ ឬក្នុងសុតសុទ្ធិ ក្នុងមុតៈ ឬក្នុងមុតសុទ្ធិ ដែលគេតាំងឡើង កំណត់តាក់តែង តាំងនៅព្រមដោយសញ្ញា ព្រោះសេចក្ដីប្រកាន់ខុសដោយសញ្ញា នៃព្រះអរហន្តខីណាស្រពនោះ មិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ ស្ងប់ ធ្វើមិនគួរឲ្យកើត ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីសំគាល់សូម្បីតូចមួយ ដែលកំណត់ហើយ ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះ មិនមានទេ ។

(១៧៤) អធិប្បាយពាក្យថា បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ ត្រង់ពាក្យថា ព្រាហ្មណ៍ គឺ បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បង់ នូវធម៌ទាំង ៧ ។ បេ ។

អនិស្សិតា តានិ បជហន្តេ តេ ព្រាហ្មណា ។ តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានន្តិ តំ ព្រាហ្មណំ ទិដ្ឋិំ អនាទិយន្តំ អគ្គណ្ហន្តំ អបរាមសន្តំ អនភិនិវិសន្តន្តិ(១) តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានំ ។

(១៧៨) កេនីធ លោកស្មិំ វិកប្បយេយ្យាតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។ តស្ស តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា កេន រាគេន កប្បេយ្យ កេន ទោសេន កប្បេយ្យ កេន មោហេន កប្បេយ្យ កេន មានេន កប្បេយ្យ កាយ ទិដ្ឋិយា កប្បេយ្យ កេន ឧទ្ធច្ចេន កប្បេយ្យ កាយ វិចិកិច្ឆាយ កប្បេយ្យ កេហិ អនុសយេហិ កប្បេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។

---

១ ឱ. អភិនិវិសន្តន្តិ ។

ជាអ្នកមិនអាស្រ័យ (នូវទិដ្ឋិ) ជាអ្នកទឹងទឹង បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ បានសេចក្តីថា បុគ្គលជាព្រាហ្មណ៍នោះ មិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ ។

(១៧៥) អធិប្បាយពាក្យថា គប្បីកំណត់ ក្នុងលោកនេះ ដោយកិលេសដូចម្តេចបាន ត្រង់ពាក្យថា កំណត់ បានដល់ការកំណត់ ២ គឺ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះការកំណត់គឺតណ្ហា ។ បេ ។ នេះការកំណត់គឺទិដ្ឋិ ។ ការកំណត់គឺតណ្ហា ព្រាហ្មណ៍នោះ លះបង់ហើយ ការកំណត់គឺទិដ្ឋិ ព្រាហ្មណ៍នោះ រលាស់ចោលហើយ ព្រោះលោកបានលះបង់ នូវការកំណត់ គឺតណ្ហា បានរលាស់ចោលនូវការកំណត់គឺទិដ្ឋិ អ្នកផងគប្បីកំណត់ដោយរាគៈដូចម្តេច កំណត់ដោយទោសៈដូចម្តេច កំណត់ដោយមោហៈដូចម្តេច កំណត់ដោយមានះដូចម្តេច កំណត់ដោយទិដ្ឋិដូចម្តេច កំណត់ដោយឧទ្ធច្ចៈដូចម្តេច កំណត់ដោយវិចិកិច្ឆាដូចម្តេច កំណត់ដោយអនុស័យទាំងឡាយដូចម្តេច ថា លោកជាអ្នកត្រេកអរ ថាជាអ្នកប្រទូស្ត ថាជាអ្នកវង្វេង ថាជាអ្នកជាប់ចំពាក់ ថាជាអ្នកស្ទាបអង្អែល ថាជាអ្នកដល់ នូវសេចក្តីរាយមាយ ថាជាអ្នកដល់ នូវការមិនដាច់ស្រេច ឬថាជាអ្នកដល់នូវកម្លាំង ។

តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយោ គមេន កប្បេយ្យ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បេត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។ សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន កប្បេយ្យ វិកប្បេយ្យ វិកប្បំ អាបជ្ជេយ្យ ។ លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេតិ កេនីធ លោកស្មិំ វិកប្បយេយ្យ ។ តេនាហ ភគវា

តស្សីធ ទិដ្ឋេវ សុតេ មុតេ វា
បកប្បិតា នត្ថិ អណូបិ សញ្ញា
តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានំ
កេនីធ លោកស្មិំ វិកប្បយេយ្យាតិ ។

(១៧៦) ន កប្បយន្តិ ន បុរេក្ខរោន្តិ
ធម្មាបិ តេសំ ន បដិច្ឆិតាសេ

អភិសង្ខារទាំងនោះ លោកលះបង់ហើយ ព្រោះលោកលះបង់អភិសង្ខារទាំងឡាយហើយ អ្នកផងឯណាប្រកំណត់គតិទាំងឡាយ ថាលោកទៅកើតក្នុងនរក ថាកើតក្នុងកំណើតតិរច្ឆាន ថាកើតជាបិត្តិវិស័យ ថាជាមនុស្ស ថាជាទេវតា ថាជាព្រហ្មមានរូប ថាជាព្រហ្មមិនមានរូប ថាជាសញ្ញីព្រហ្ម ថាជាអសញ្ញីព្រហ្ម ឬថាជានេវសញ្ញីនាសញ្ញីព្រហ្ម ដោយកិលេសដូចម្តេច ៗ អ្នកផងឯណាប្រកំណត់ គប្បីសំគាល់ គប្បីដល់នូវការកំណត់ ដោយហេតុណា ហេតុនោះ មិនមាន បច្ច័យមិនមាន ការណ៍មិនមានទេ ៗ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីកំណត់ក្នុងលោកនេះ ដោយកិលេសដូចម្តេចបាន ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> សេចក្តីសំគាល់សូម្បីតូចមួយ ដែលកំណត់ហើយ ក្នុងអារម្មណ៍ដែលឃើញ ដែលឮ ឬដែលប៉ះពាល់ហើយនេះ នៃបុគ្គលនោះ មិនមានទេ អ្នកផងឯណាប្រកំណត់ បុគ្គលដែលជាព្រាហ្មណ៍ មិនប្រកាន់ទិដ្ឋិនោះ ក្នុងលោកនេះ ដោយកិលេស ដូចម្តេចបាន ៗ

[១៧៦] ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ដ្បិត ធម៌ទាំងឡាយ លោកមិនទទួលយកទេ

ន ព្រាហ្មណោ សីលវតេន នេយ្យោ
បារង្គតោ ន បច្ចេតិ តាទិ ។

(១៧៧) ន កប្បយន្តិ ន បុរេក្ខរោន្តីតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។

កតមោ តណ្ហាកប្បោ ។ យាវតា តណ្ហាសង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តកតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មមំ រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា បាបុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបឋវី តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិចរិតំ អយំ តណ្ហាកប្បោ ។

កតមោ ទិដ្ឋិកប្បោ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិយា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ

ព្រាហ្មណ៍ មិនមែនសីលវត្ត ដឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញឡើយ ។

(១៧៧) អធិប្បាយពាក្យថា មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ត្រង់ពាក្យថា តែងតាំង បានដល់ ការតែងតាំង ២ គឺការតែងតាំងគឺតណ្ហា១ ការតែងតាំងគឺទិដ្ឋិ១ ។

ការតែងតាំងគឺតណ្ហា តើដូចម្តេច ។ ការកំណត់ដែន កំណត់ទី កំណត់ផ្លូវ កំណត់ដោយជុំវិញ ហួងហែង អាល័យ ដោយចំណែកតណ្ហា ទាំងប៉ុន្មានថា នេះរបស់អញ នុះរបស់អញ ប៉ុណ្ណេះរបស់អញ ទាំងប៉ុណ្ណោះ របស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ របស់អញ គ្រឿងកម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង របស់អញ បុគ្គលប្រកាន់ផែនដីទាំងអស់ ដោយអំណាចតណ្ហា តណ្ហាវិបរីត១០៨ ទាំងប៉ុន្មាន នេះការតែងតាំងគឺតណ្ហា ។

ការតែងតាំង គឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ២០ មិច្ឆាទិដ្ឋិ មានវត្ថុ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ១០ ទិដ្ឋិដំណើរ គឺទិដ្ឋិ ការសាំញ៉ាំ គឺទិដ្ឋិ ផ្លូវលំបាក គឺទិដ្ឋិ

ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ អយំ ទិដ្ឋិកប្បោ ។

តេសំ តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេន្តិ ន ជនេន្តិ ន សញ្ជនេន្តិ ន និព្វត្តេន្តិ នាភិនិព្វត្តេន្តីតិ ន កប្បយន្តិ ។

ន បុរេក្ខរោន្តីតិ បុរេក្ខារាតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។ បេ ។ អយំ តណ្ហាបុរេក្ខារោ ។ បេ ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តេសំ តណ្ហាបុរេក្ខារោ បហីនោ ទិដ្ឋិបុរេក្ខារោ បដិនិស្សដ្ឋោ

បម្រុងគឺទិដ្ឋិ សេចក្តីអន្ទះអន្ទែងគឺទិដ្ឋិ ការប្រកបព្រមគឺទិដ្ឋិ ការកាន់ ការទទួល ការប្រកាន់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់នៃអណ្តូង ការកាន់យកដោយការស្វែងរកខុស ការកាន់យកវិបរិត ការកាន់យកវិបល្លាស ការកាន់យកខុស ការកាន់យកក្នុងវត្ថុមិនពិត ថាជាសភាពពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន ណា មានសភាពយ៉ាងនេះ នេះការតែងតាំងគឺទិដ្ឋិ ។

ការតែងតាំងគឺតណ្ហា ព្រះអរហន្តទាំងនោះ លះបង់ហើយ ការតែងតាំងគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវការតែងតាំងគឺតណ្ហា ឬនូវការតែងតាំងគឺទិដ្ឋិ ព្រោះលោកលះបង់ការតែងតាំងគឺតណ្ហា រលាស់ចោលការតែងតាំងគឺទិដ្ឋិហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនតែងតាំង ។

ពាក្យថា ការធ្វើឲ្យជាប្រធាន ក្នុងបទថា មិនធ្វើឲ្យជាប្រធាន បាន ដល់ការធ្វើឲ្យជាប្រធាន ២ គឺការធ្វើឲ្យជាប្រធានគឺតណ្ហា១ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ១ ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺតណ្ហា ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រះអរហន្តទាំងនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោករលាស់ចោលហើយ ព្រះអរហន្តទាំងនោះ មិនធ្វើតណ្ហានិងទិដ្ឋិ ឲ្យជាប្រធានហើយប្រព្រឹត្ត

តណ្ហាបុរេក្ខារស្ស បហីនត្តា ទិដ្ឋិបុរេក្ខារស្ស បដិ-និស្សដ្ឋត្តា ន តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរន្តិ ន តណ្ហាធជា ន តណ្ហាកេតូ ន តណ្ហាធិបតេយ្យា ន ទិដ្ឋិទ្ធជា ន ទិដ្ឋិកេតូ ន ទិដ្ឋាធិបតេយ្យា ន តណ្ហាយ វា ទិដ្ឋិយា វា បរិវារិតា ចរន្តីតិ ន កប្ប-យន្តិ ន បុរេក្ខរោន្តិ ។

(១៧៨) ធម្មាបិ តេសំ ន បដិច្ឆិតាសេតិ ធម្មា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ តេសន្តិ តេសំ អរហន្តានំ ខីណាសវានំ ។ ន បដិច្ឆិតាសេតិ សស្សតោ លោ-កោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ន បដិច្ឆិតាសេ អសស្សតោ លោកោ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃ-មញ្ញន្តិ ន បដិច្ឆិតាសេតិ ធម្មាបិ តេសំ ន បដិច្ឆិតាសេ ។

(១៧៩) ន ព្រាហ្មណោ សីលវតេន នេយ្យោតិ នាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ បេ ។

ព្រោះលោកលះបង់ការធ្វើឲ្យជាប្រធានគឺតណ្ហា រលាស់ចោលការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ព្រោះអរហន្តទាំងឡាយមិនមានតណ្ហា ដូចជាទង់ជ័យ មិនមានតណ្ហាដូចជាទង់ មិនមានតណ្ហាជាអធិបតី មិនមានទិដ្ឋិដូចជាទង់ជ័យ មិនមានទិដ្ឋិដូចជាទង់ មិនមានទិដ្ឋិជាអធិបតី គឺតណ្ហានិងទិដ្ឋិមិនប្រព្រឹត្តចោមរោមហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនតែងតាំងមិនធ្វើឲ្យជាប្រធាន ។

(១៧៨) ទិដ្ឋិ ៦២ លោកហៅថា ធម៌ ក្នុងបទថា ដ្បិតធម៌ទាំងឡាយលោកមិនទទួលយកទេ ។ ពាក្យថា លោក គឺព្រះអរហន្តខីណាស្រពទាំងនោះ ។ ពាក្យថា មិនទទួលយកទេ គឺមិនទទួលថា លោកទៀង ពាក្យនេះពិត ពាក្យដទៃជាមោឃៈ មិនទទួលថា លោកមិនទៀង ។ បេ ។ សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏ទេ មិនកើតទៀតក៏ទេ ពាក្យនេះជាពាក្យពិត ពាក្យឯទៀតជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ដ្បិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ។

(១៧៩) ពាក្យថា មិនមែន ក្នុងបទថា ព្រាហ្មណ៍មិនមែនសីលវត្តដឹកនាំបានទេ ជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះលោក បន្សាត់បង់ នូវធម៌ទាំង ៧ ។ បេ ។

អភិសង្ខតោ តានិ បវុច្ចតេ ស ព្រហ្មា ។ ន ព្រាហ្មណោ សីលវតេន នេយ្យោតិ ព្រាហ្មណោ សីលេន វា វត្តេន វា សីលវត្តេន វា ន យាយតិ ន និយ្យាយតិ ន វុយ្ហតិ ន សំហារីយតីតិ ន ព្រាហ្ម-ណោ សីលវតេន នេយ្យោ ។

(១៨០) បារង្គតោ ន បច្ចេតិ តាទីតិ បារំ វុច្ចតិ អមតំ និព្វានំ ។ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ យោ បារគតោ បារប្បត្តោ អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ ។ បេ ។ នត្ថិ តស្ស បុនព្ភវោតិ បារង្គតោ ។ ន បច្ចេតីតិ សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ(១) ន បច្ចាគច្ឆតិ សកទាគាមិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆ-តិ អនាគាមិមគ្គេន យេ កិលេសា បហីនា

---

១ ឱ. ន បុន បច្ចេតិ ។

ជាអ្នកមិនអាស្រ័យ (នូវទិដ្ឋិ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍ មិនមែនសីលវត្ត ដឹកនាំបានទេ បានសេចក្តីថា ព្រាហ្មណ៍គឺសីល ឬវត្ត ឬសីលវត្តដឹកនាំមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន ទង់ទាញទៅមិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ មិនមែនសីលវត្ត ដឹកនាំបានទេ ។

(១៨០) ពាក្យថា លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ អធិប្បាយថា អមតនិព្វាន លោកហៅថា ត្រើយ បានខាងការរម្ងាប់សង្ខារទាំងអស់ ការលះបង់ឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ បុគ្គលណា ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ខាងចុង ដល់ខាងចុង ។ បេ ។ ភពថ្មីទៀត នៃបុគ្គលនោះ មិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយហើយ ។ ពាក្យថា មិនត្រឡប់មកវិញ គឺកិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះ វិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះ វិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអនាគាមិមគ្គ

តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតីតិ បារង្គតោ ន បច្ចេតិ ។ តាទីតិ អរហា បញ្ចាការេហិ តាទិ ឥដ្ឋានិដ្ឋេ តាទិ ចត្តាវីតិ តាទិ តិណ្ណាវីតិ តាទិ មុត្តាវីតិ តាទិ តំនិទ្ទេសា តាទិ ។

កថំ អរហា ឥដ្ឋានិដ្ឋេ តាទិ ។ អរហា លាភេបិ តាទិ អលាភេបិ តាទិ យសេបិ តាទិ អយសេបិ តាទិ បសំសាយបិ តាទិ និន្ទាយបិ តាទិ សុខេបិ តាទិ ទុក្ខេបិ តាទិ ។ ឯកញ្ចេ ពាហំ គន្ធេន លិម្បេយ្យុំ ឯកញ្ចេ ពាហំ វាសិយា តច្ឆេយ្យុំ អមុស្មឹ នត្ថិ រាគោ អមុស្មឹ នត្ថិ បដិឃំ អនុនយបដិឃវិប្បហីនោ ឧគ្ឃាតិនិគ្ឃាតិវីតិវត្តោ អនុរោធវិរោធសមតិក្កន្តោ ឯវំ អរហា ឥដ្ឋានិដ្ឋេ តាទិ ។

## បរមដ្ឋកសុត្តនិទ្ទេស ទី ៥

លោកមិនត្រឡប់ មិនមក មិនត្រឡប់មក រកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអរហត្តមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មក រកកិលេសទាំងនោះវិញទេ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយ ហើយមិនត្រឡប់មកវិញទេ ។ ពាក្យថា ជាអ្នកនឹងធឹង បានដល់ព្រះអរហន្ត លោកនឹងធឹងដោយអាការ ៥ យ៉ាង គឺលោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ ១ លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ ១ លោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយ ១ លោកនឹងធឹង ព្រោះជាអ្នករួចហើយ ១ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះ ១ ។

លោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ តើដូចម្តេច ។ ព្រះអរហន្ត លោកនឹងធឹងក្នុងលាភ នឹងធឹងក្នុងអលាភ នឹងធឹងក្នុងយស នឹងធឹងក្នុងអយស នឹងធឹងក្នុងសេចក្តីសរសើរ នឹងធឹងក្នុងនិន្ទា នឹងធឹងក្នុងសុខ នឹងធឹងក្នុងទុក្ខ ។ បើពួកជនលាបដៃម្ខាង ដោយគ្រឿងក្រអូប បើពួកជនប្រាសដៃម្ខាងដោយកាំបិត តម្រេកក្នុងការលាបឯណោះក៏មិនមាន សេចក្តីថ្នាំងថ្នាក់ ក្នុងការប្រាសឯណោះ ក៏មិនមាន ព្រះអរហន្ត លះបង់ស្រឡះនូវសេចក្តីត្រេកអរនឹងសេចក្តីថ្នាំងថ្នាក់ ប្រព្រឹត្តកន្លងនូវសេចក្តីលើកតំកើងនឹងសេចក្តីផ្ចាញ់ផ្ចាល់ កន្លងផុតនូវសេចក្តីស្រឡាញ់នឹងសេចក្តីស្អប់ហើយ ព្រះអរហន្ត លោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍យ៉ាងនេះ ។

កថំ អរហា ចត្តាវីតិ តាទិ ។ អរហតោ រា-
គោ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ ។
ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ
បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ
សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ
កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិ-
ឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា
ចត្តា វន្តា មុត្តា បហីនា បដិនិស្សដ្ឋា ឯវំ អរហា
ចត្តាវីតិ តាទិ ។

កថំ អរហា តិណ្ណាវីតិ តាទិ ។ អរហា កា-
មោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ
អវិជ្ជោឃំ តិណ្ណោ សព្វសំសារបថំ តិណ្ណោ ឧត្តិ-
ណ្ណោ និត្តិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោ
សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ នត្ថិ តស្ស
បុនព្ភវោតិ ឯវំ អរហា តិណ្ណាវីតិ តាទិ ។

កថំ អរហា មុត្តាវីតិ តាទិ ។ អរហតោ
រាគា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ ទោសា

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ តើដូចម្តេច ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយ នូវរាគៈ ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយ នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្ត លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយ តើដូចម្តេច ។ ព្រះអរហន្ត ឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លងផុត ឆ្លងស្រឡះ កន្លង កន្លងផុត កន្លងហួស នូវផ្លូវគឺសង្សារទាំងអស់ ព្រះអរហន្តនោះ លោកមានកិរិយានៅ នៅស្រេចហើយ មានការប្រព្រឹត្តិ ប្រព្រឹត្តហើយ ។បេ។ ភពថ្មីទៀត នៃព្រះអរហន្តនោះ មិនមានទេ ហេតុនោះ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកឆ្លងហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ តើដូចម្តេច ។ ចិត្តរបស់ព្រះអរហន្ត រួច រួចស្រឡះ រួចផុតស្រឡះ ចាករាគៈ ។

## បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ

ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ កោធា ឧបនាហា មក្ខា បឡាសា ឥស្សាយ មច្ឆរិយា មាយាយ សាឋេយ្យា ថម្ភា សារម្ភា មានា អតិមានា មទា បមាទា សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ឯវំ អរហា មុត្តាវីតិ តាទិ ។

កថំ អរហា តំនិទ្ទេសា តាទិ ។ អរហា សីលេ សតិ សីលវាតិ តំនិទ្ទេសា តាទិ ។ សទ្ធាយ សតិ សទ្ធោតិ តំនិទ្ទេសា តាទិ ។ វីរិយេ សតិ វីរិយវាតិ តំនិទ្ទេសា តាទិ ។ សតិយា សតិ សតិមាតិ តំនិទ្ទេសា តាទិ ។ សមាធិស្មឹ សតិ សមាហិតោតិ តំនិទ្ទេសា តាទិ ។ បញ្ញាយ សតិ បញ្ញវាតិ តំនិទ្ទេសា តាទិ ។

ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកទោសៈ ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកមោហៈ ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះ តើដូចម្តេច ។ ព្រះអរហន្តលោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសីលមាន លោកជាអ្នកមានសីល ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសទ្ធាមាន លោកជាអ្នកមានសទ្ធា ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើវីរិយៈមាន លោកជាអ្នកមានវីរិយៈ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសតិមាន លោកជាអ្នកមានសតិ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសមាធិមាន លោកជាអ្នកមានសមាធិ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើបញ្ញាមាន លោកជាអ្នកមានបញ្ញា ។

វិជ្ជាយ សតិ សោវិជ្ជោតិ តំនិទ្ទេសា តាទិ ។ អភិ-ញ្ញាយ សតិ ឆឡភិញ្ញោតិ តំនិទ្ទេសា តាទិ ឯវំ អរហា តំនិទ្ទេសា តាទីតិ បារង្គតោ ន បច្ចេតិ តាទិ ។

តេនាហ ភគវា

ន កប្បយន្តិ ន បុរេក្ខរោន្តិ
ធម្មាបិ តេសំ ន បដិច្ឆិតាសេ
ន ព្រាហ្មណោ សីលវតេន នេយ្យោ
បារង្គតោ ន បច្ចេតិ តាទីតិ ។

បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

លោកនឹងធំ ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើវិជ្ជាមាន លោកជាអ្នកមានវិជ្ជាបីប្រការ ។ លោកនឹងធំ ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើអភិញ្ញាមាន លោកជាអ្នកមានអភិញ្ញាប្រាំមួយ ព្រះអរហន្តលោកនឹងធំ ព្រោះការសំដែងចេញនូវហេតុនោះយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយហើយ ជាអ្នកនឹងធំ មិនត្រឡប់មកវិញទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនធ្វើឲ្យជាប្រធាន
ដ្បិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ព្រាហ្មណ៍
មិនមែនសីលវត្ត ដឹកនាំបានទេ លោកដល់ត្រើយហើយ
ជាអ្នកនឹងធំ មិនត្រឡប់មកវិញឡើយ ។

ចប់ បរមដ្ឋកសុត្តនិទ្ទេស ទី ៥ ។

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(១៨១) អប្បំ វត ជីវិតំ ឥទំ

ឱរំ វស្សសតាបិ មិយ្យតិ

យោ ចេបិ អតិច្ច ជីវតិ

អថខោ សោ ជរសាបិ មិយ្យតិ ។

(១៨២) អប្បំ វត ជីវិតំ ឥទន្តិ ជីវិតន្តិ អាយុ ឋិតិ យបនា យាបនា ឥរិយនា វត្តនា បាលនា ជីវិតំ ជីវិតិន្ទ្រិយំ ។ អបិច ទ្វីហិ ការណេហិ អប្បកំ ជីវិតំ ថោកំ ជីវិតំ ឋិតិបរិត្តតាយ វា អប្បកំ ជីវិតំ សរសបរិត្តតាយ វា អប្បកំ ជីវិតំ ។

កថំ ឋិតិបរិត្តតាយ អប្បកំ ជីវិតំ ។ អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ។ អនាគតេ ចិត្តក្ខណេ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ ។ បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ ។

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា

ឯកចិត្តសមាយុត្តា លហុសោ វត្តតិក្ខណោ

# ជរាសុត្តនិទ្ទេស ទី ៦

(១៨១) (ព្រះមានព្រះភាគត្រាស់ថា) ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស (អំពីមួយរយឆ្នាំ) ទៅ បុគ្គលនោះ គង់ស្លាប់ព្រោះជរាពុំខាន ។

(១៨២) អធិប្បាយពាក្យថា ជីវិតនេះតិចណាស់ ត្រង់ពាក្យថា ជីវិត គឺអាយុ ការតាំងនៅ ការរស់នៅ ការញុំាងអត្តភាពឲ្យរស់នៅ ការដើរទៅ ការប្រព្រឹត្តទៅ ការរក្សាជីវិត ជីវិតិន្ទ្រិយ ។ មួយទៀត ជីវិតតិច ជីវិតស្តួចស្តើង ដោយហេតុពីរ គឺជីវិតតិច ព្រោះជាធម្មជាតតាំងនៅតិច១ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច១ ។

ជីវិតតិច ព្រោះធម្មជាតតាំងនៅតិច តើដូចម្តេច ។ សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន នឹងមិនរស់នៅ ក្នុងអនាគតទេ ។ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន មិនរស់នៅហើយ ក្នុងអតីតទេ ។ សត្វកំពុងរស់នៅក្នុងខណៈចិត្ត ជាបច្ចុប្បន្ន មិនបានរស់នៅហើយ ក្នុងអតីត នឹងមិនរស់នៅ ក្នុងអនាគតទេ ។

ជីវិត អត្តភាព សុខនឹងទុក្ខទាំងអស់ ប្រកបដោយ
ខណៈចិត្តតែមួយ ព្រោះខណៈ ប្រព្រឹត្តទៅរហ័ស

ចុល្លាសីតិ សហស្សានិ កប្បា តិដ្ឋន្តិ យេ មរូ

ន ត្វេវ តេបិ ជីវន្តិ ទ្វីហិ ចិត្តេហិ សមាហិតា(១)

យេ និរុទ្ធា មរន្តស្ស តិដ្ឋមានស្ស វា ឥធ

សព្វេវ សទិសា ខន្ធា គតា អប្បដិសន្ធិកា

អនន្តរា ច យេ ភគ្គា យេ ច ភគ្គា អនាគតា

តទន្តរេ និរុទ្ធានំ វេសម្មំ នត្ថិ លក្ខណេ

អនិព្វត្តេន ន ជាតោ បច្ចុប្បន្នេន ជីវតិ

ចិត្តភង្គមតោ លោកោ បញ្ញត្តិ បរមត្ថិយា

យថា និន្នា បវត្តន្តិ ឆន្ទេន បរិណាមិតា

អច្ឆិន្នវារា(២) វត្តន្តិ សឡាយតនបច្ចយា

អនិធានគតា ភគ្គា បុញ្ជោ នត្ថិ អនាគតេ

និព្វត្តាយេវ តិដ្ឋន្តិ អារគ្គេ សាសបូបមា

---

១ ម. សមោហិតា ។ ២ ម. អច្ឆិន្នធារា ។

ពួកទេវតាណា ឋិតនៅអស់ ៨៤ ពាន់កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្ត ២ ហើយរស់នៅទេ ខន្ធទាំងឡាយណា របស់បុគ្គលដែលស្លាប់ទៅក្ដី រស់នៅក្ដី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន ខន្ធទាំងឡាយណា ដែលកន្លងទៅផុតលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគត នឹងបែកធ្លាយផង សេចក្ដីផ្សេងគ្នានៃខន្ធទាំងឡាយ ជាបច្ចុប្បន្ន ដែលរលត់ហើយ ក្នុងចន្លោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វលោក ដែលកើតហើយដោយអនាគតក្ខន្ធ ដែលមិនទាន់កើត មិនឈ្មោះថា រស់នៅហើយទាំងមិនឈ្មោះថា កំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត (នេះជា) បញ្ញត្តិនៃបរមត្ថ ការប្រែប្រួលទៅដោយឆន្ទៈ ដូចជាទីទាប រមែងប្រព្រឹត្តទៅដូច្នោះ វេទនាទាំងឡាយ មានសឡាយតនៈជាបច្ច័យ មានវារៈមិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយ ដែលបែកធ្លាយហើយ ក៏មិនដល់នូវការតំកល់ទុក គំនរនៃខន្ធ ក្នុងអនាគត ក៏មិនមាន ខន្ធទាំងឡាយ ដែលកើតឡើងហើយ រមែងឋិតនៅ ដូចគ្រាប់ស្ពៃ ដែលឋិតនៅ លើចុងដែកស្រួច

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

និព្វត្តានញ្ច ធម្មានំ ភង្គោ នេសំ បុរេក្ខតោ
បលោកធម្មា តិដ្ឋន្តិ បោរាណេហិ អមិស្សិតា
អទស្សនតោ អាយន្តិ ភគ្គា គច្ឆន្តិ ទស្សនំ
វិជ្ជុប្បាទោវ អាកាសេ ឧប្បជ្ជន្តិ វយន្តិ ចាតិ ។

ឯវំ ឋិតិបរិត្តតាយ អប្បកំ ជីវិតំ ។

កថំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។ អស្សាសុបនិពទ្ធំ ជីវិតំ បស្សាសុបនិពទ្ធំ ជីវិតំ អស្សាសបស្សាសុបនិពទ្ធំ ជីវិតំ មហាភូតុបនិពទ្ធំ ជីវិតំ ឧស្មូបនិពទ្ធំ ជីវិតំ កពឡិង្ការាហារុបនិពទ្ធំ ជីវិតំ វិញ្ញាណុបនិពទ្ធំ ជីវិតំ ។ មូលម្បិ ឥមេសំ ទុព្ពលំ ។ បុព្ពហេតូបិ ឥមេសំ ទុព្ពលា ។ យេបិ បច្ចយា តេបិ ទុព្ពលា ។ យេបិ បភវិកា តេបិ ទុព្ពលា ។ សហភូបិ ឥមេសំ ទុព្ពលា ។ សម្បយោគាបិ ឥមេសំ ទុព្ពលា ។ សហជាបិ ឥមេសំ ទុព្ពលា ។

## ជរាសុត្តនិទ្ទេស ទី ៦

កាលបើខន្ធទាំងឡាយ កើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះ ក៏ឋិតនៅក្នុងខាងមុខ សភាវៈដែលត្រូវវិនាសទាំងឡាយ (ខន្ធ) ក៏ពុំឋិតនៅ មិនប្រឡូកប្រឡំដោយខន្ធចាស់ទេ រមែងមកអំពីទីមើលមិនឃើញ លុះបែកធ្លាយហើយ តែងទៅកាន់ទីមើលមិនឃើញវិញ រមែងកើតឡើងផង រមែងវិនាសទៅផង ដូចជាផ្លេកបន្ទោរក្នុងអាកាស ។ ជីវិតតិច ព្រោះការឋិតនៅតិច យ៉ាងនេះ ។

ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច តើដូចម្តេច ។ ជីវិតជាប់ទាក់ទងដោយដង្ហើមចូល ជីវិតជាប់ទាក់ទងដោយដង្ហើមចេញ ជីវិតជាប់ទាក់ទងដោយដង្ហើមចូលនិងដង្ហើមចេញ ជីវិតជាប់ទាក់ទងដោយមហាភូតរូប ជីវិតជាប់ទាក់ទងដោយភ្លើងធាតុ ជីវិតជាប់ទាក់ទងដោយអាហារជាពិន្ទុ ជីវិតជាប់ទាក់ទងដោយវិញ្ញាណ ។ ឫសគល់របស់ធម៌ទាំងនេះ មានកម្លាំងថយ ។ បុព្វហេតុទាំងឡាយរបស់ធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណាជាបច្ច័យ ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណា ជាប្រភព ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ ពួកធម៌ដែលកើត ជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ពួកធម៌ប្រកបជាមួយគ្នា នឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ធម៌ដែលកើតឡើង ជាមួយគ្នានឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។

យាបិ បយោជិកា សាបិ ទុព្ពលា ។ អញ្ញមញ្ញំ និច្ចទុព្ពលា ទេមេ ។ អញ្ញមញ្ញំ អនត្ថិតា ទេមេ ។ អញ្ញមញ្ញំ បរិឃាតយន្តិ ទេមេ ។ អញ្ញមញ្ញស្ស ហិ នត្ថិ តាយិតា ។ ន ចាបិ ឋបេន្តិ អញ្ញមញ្ញិមេ ។ យោបិ និព្ពត្តកោ សោ ន វិជ្ជតិ ។ ន ច កេនចិ កោចិ ហាយតិ ។ កន្តព្យា(១) ច ទេមេ ហិ សព្វសោ ។ បុរិមេហិ បភាវិតា ទេមេ ។ យេបិ បភាវិតា តេ បុរេ មតា ។ បុរិមាបិច បច្ឆិមាបិច អញ្ញមញ្ញំ ន កទាចិ អន្ទុសំស្សតិ ។ ឯវំ សរសបរិត្តតាយ អប្បកំ ជីវិតំ ។

អបិច ចាតុម្មហារាជិកានំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ ជីវិតំ លហុកំ ជីវិតំ ឥត្តរំ ជីវិតំ អនទ្ធនីយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ តាវតឹសានំ ទេវានំ ។ យាមានំ ទេវានំ ។ តុសិតានំ ទេវានំ ។ និម្មានរតីនំ ទេវានំ ។ បរនិម្មិតវសវត្តីនំ ទេវានំ ។ ព្រហ្មកាយិកានំ ទេវានំ ជីវិតំ ឧបាទាយ មនុស្សានំ អប្បកំ ជីវិតំ បរិត្តកំ ជីវិតំ ថោកំ ជីវិតំ ខណិកំ

---

១ ម. គន្ធព្វា ។

ធម្មជាតិណាជាគ្រឿងប្រកប ធម្មជាតិនោះ ក៏មានកម្លាំងថយ ។ ធម៌ទាំងនេះ មានកម្លាំងថយជាន់ចុះដល់គ្នានឹងគ្នា ។ ធម៌ទាំងនេះ មិនទុនរកគ្នានឹងគ្នា ។ ធម៌ទាំងនេះ ញាំងគ្នានឹងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះមិនបានជាទីពឹងដល់គ្នានឹងគ្នា ។ មួយទៀត ធម៌ទាំងនេះ មិនតំកល់ទុកនូវគ្នានឹងគ្នា ។ សូម្បីធម៌ណា ជាអ្នកបង្កើត ធម៌នោះ ក៏មិនមាន ។ ធម៌ណាមួយ មិនមែនវិនាស ដោយធម៌ណាមួយទេ ។ ព្រោះថា ធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះ កើតហើយ ព្រោះហេតុនិងបច្ច័យអំពីមុន ។ ហេតុនិងបច្ច័យទាំងឡាយណា ដែលឲ្យកើតមុន ហេតុនិងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាងដើមនិងខាងចុង មិនបានឃើញគ្នានឹងគ្នា ក្នុងកាលណាមួយឡើយ ។ ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច យ៉ាងនេះ ។

មួយទៀត ពួកមនុស្ស មានជីវិតតិច ជីវិតស្ដួចស្ដើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតឆាប់ ជីវិតមិនមាំមួន ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិត របស់ពួកទេវតាជាន់ចាតុម្មហារាជិកា ។ របស់ពួកទេវតាជាន់តាវត្តិង្ស ។ របស់ទេវតាជាន់យាមៈ ។ របស់ទេវតាជាន់តុសិត ។ របស់ទេវតាជាន់និម្មានរតី ។ របស់ទេវតា ជាន់បរនិម្មិតវសវត្តី ។ ពួកមនុស្ស មានជីវិតតិច ជីវិតស្ដួចស្ដើង ជីវិតថោកថយ ជីវិតមានក្នុងមួយខណៈ

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

ជីវិតំ បហុតំ ជីវិតំ ឥត្តរំ ជីវិតំ អនទ្ធនីយំ ជីវិតំ ន ចិរដ្ឋិតិកំ ជីវិតំ ។ វុត្តំ ហេតំ ភគវតា អប្បមិទំ ភិក្ខវេ មនុស្សានំ អាយុ គមនីយោ សម្បរាយោ មន្តាយ ផោដ្ឋព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ

អប្បមាយុ មនុស្សានំ ហីឡេយ្យ នំ សុបោរិសោ
ចរេយ្យាទិត្តសីសោវ នត្ថិ មច្ចុស្ស នាគមោ
អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ
អាយុ ខីយតិ មច្ចានំ កុន្នទីនំវ ឱទកន្តិ ។

អប្បំ វត ជីវិតំ ឥទំ ។

(១៨៣) ឱរំ វស្សសតាបិ មិយ្យតីតិ កលលកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ អព្វុទកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ បេសិកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។

ជីវិតរហ័ស ជីវិតឆាប់ ជីវិតមិនមាំមួន ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះតិច បរលោកពួកសត្វត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយៈ (ព្រោះថា) សត្វដែលកើតហើយ មិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅអស់កាលយូរ បុគ្គលនោះ គប្បីរស់នៅ ១០០ ឆ្នាំ តិចពីមួយរយឆ្នាំ ឬច្រើនជាង ១០០ឆ្នាំ ។

អាយុរបស់ពួកមនុស្ស តិច បុរសល្អគប្បីនឿយណាយ នឹង
អាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គល ដែលភ្លើងឆេះក្បាល
ដំណើរមិនមកនៃមច្ចុ មិនមានទេ ថ្ងៃនឹងយប់តែងកន្លងទៅ
ជីវិតក៏ស្រកស្រុតទៅដែរ អាយុរបស់ពួកសត្វ រមែងអស់ទៅ
ដូចជាទឹកនៃស្ទឹងតូចទាំងឡាយ ។

ហេតុនេះ (ទ្រង់ត្រាស់ថា) ជីវិតនេះ តិចណាស់ ។

(១៨៣) ពាក្យថា សត្វរមែងស្លាប់ខាងអាយអំពីមួយរយឆ្នាំ អធិប្បាយថា សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាកលលៈ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាអព្ពុទៈ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាបេសិ ក៏មាន ។

ឃនកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ បញ្ចសាខកាលេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ជាតិមត្តោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ បសូតិឃរេបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ អឌ្ឍមាសិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ មាសិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ទ្វិមាសិកោបិ តិមាសិកោបិ ចតុម្មាសិកោបិ បញ្ចមាសិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ឆមាសិកោបិ សត្តមាសិកោបិ អដ្ឋមាសិកោបិ នវមាសិកោបិ ទសមាសិកោបិ សំវច្ឆរិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ទ្វិវស្សិកោបិ តិវស្សិកោបិ ចតុវស្សិកោបិ បញ្ចវស្សិកោបិ ឆវស្សិកោបិ សត្តវស្សិកោបិ អដ្ឋវស្សិកោបិ នវវស្សិកោបិ ទសវស្សិកោបិ វីសតិវស្សិកោបិ តឹសវស្សិកោបិ ចត្តាឡីសវស្សិកោបិ បញ្ញាសវស្សិកោបិ សដ្ឋីវស្សិកោបិ សត្តតិវស្សិកោបិ អសីតិវស្សិកោបិ នវុតិវស្សិកោបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតីតិ ឱរំ វស្សសតាបិ មិយ្យតិ ។

សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាឃនៈ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាល ជាបញ្ចសាខា ក៏មាន ។ សត្វគ្រាន់តែមានកំណើត ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងផ្ទះជាទីប្រសូតិ ក៏មាន ។ សត្វកើតបានកន្លះខែច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ១ ខែ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ខែខ្លះ បាន ៣ ខែខ្លះ បាន ៤ ខែខ្លះ បាន ៥ ខែខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ៦ ខែខ្លះ ៧ ខែខ្លះ ៨ ខែខ្លះ ៩ ខែខ្លះ ១០ ខែខ្លះ ១ ឆ្នាំខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ឆ្នាំខ្លះ ៣ ឆ្នាំខ្លះ ៤ ឆ្នាំខ្លះ ៥ ឆ្នាំខ្លះ ៦ ឆ្នាំខ្លះ ៧ ឆ្នាំខ្លះ ៨ ឆ្នាំខ្លះ ៩ ឆ្នាំខ្លះ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ៩០ ឆ្នាំខ្លះ ច្យុត ស្លាប់ បាត់បង់ វិនាសទៅវិញ ក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលរមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ ។

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(១៨៤) យោ ចេបិ អតិច្ច ជីវតីតិ យោ វស្សសតំ អតិក្កមិត្វា ជីវតិ សោ ឯកំ វា វស្សំ ជីវតិ ទ្វេ វា វស្សានិ ជីវតិ តីណិ វា វស្សានិ ជីវតិ ចត្តារិ វា វស្សានិ ជីវតិ បញ្ច វា វស្សានិ ជីវតិ ទស វា វស្សានិ ជីវតិ វីសតិ វា វស្សានិ ជីវតិ តឹស វា វស្សានិ ជីវតិ ចត្តាឡីសំ វា វស្សានិ ជីវតីតិ យោ ចេបិ អតិច្ច ជីវតិ ។

(១៨៥) អថខោ សោ ជរសាបិ មិយ្យតីតិ យទា ជិណ្ណោ ហោតិ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ ខណ្ឌទន្តោ បលិតកេសោ វិលូនំ ខលិតសិរោ វលីនំ តិលកាហតគត្តោ វង្កោ ភគ្គោ ទណ្ឌបរាយនោ សោ ជរាយបិ ចវតិ មរតិ អន្តរធាយតិ វិប្បលុជ្ជតិ ។

នត្ថិ មរណម្ហា មោក្ខោ

ផលានមិវ បក្កានំ ភាតោ បតនតោ ភយំ
ឯវំ ជាតានមច្ចានំ និច្ចំ មរណតោ ភយំ

## ជរាសុត្តនិទ្ទេស ទី ៦

[១៨៤] ពាក្យថា បើបុគ្គលណា រស់នៅកន្លងហួសទៅ គឺ បុគ្គលណា រស់នៅកន្លងមួយរយឆ្នាំ បុគ្គលនោះ រស់នៅអស់ ១ ឆ្នាំក្តី រស់នៅអស់ ២ ឆ្នាំក្តី រស់នៅអស់ ៣ ឆ្នាំក្តី រស់នៅអស់ ៤ ឆ្នាំក្តី រស់នៅអស់ ៥ ឆ្នាំក្តី រស់នៅអស់ ១០ ឆ្នាំក្តី រស់នៅអស់ ២០ ឆ្នាំក្តី រស់នៅអស់ ៣០ ឆ្នាំក្តី រស់នៅអស់ ៤០ ឆ្នាំក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បើបុគ្គលណា រស់នៅកន្លងហួសទៅ ។

[១៨៥] ពាក្យថា បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន អធិប្បាយថា កាលណា បុគ្គលចាស់ ចំរើនដោយវ័យ មានអាយុច្រើន កន្លងកាល ដល់ចូលក្នុងបច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលឆក ក្បាលថ្ពែក ស្បែកជ្រួញជ្រីវ មានខ្លួនរទុះដោយប្រជ្រុយ ខ្នងកោង កក់ កាន់ឈើច្រត់ បុគ្គលនោះ គង់ច្យុត ស្លាប់ បាត់បង់ វិនាស ព្រោះជរា ។

ការរួចចាកមរណៈ មិនមានទេ សត្វទាំងឡាយ ដែលកើត
ហើយ តែងមានភ័យអំពីមរណៈជានិច្ច ដូចជាផ្លែឈើទុំ
ទាំងឡាយ តែងមានភ័យអំពីការជ្រុះចុះ ក្នុងវេលាព្រឹក

យថាបិ កុម្ភការស្ស កតា មត្តិកភាជនា
សព្វេ ភេទបរិយន្តា(១) ឯវំ មច្ចាន ជីវិតំ
ទហរា ច មហន្តា ច យេ ពាលា យេ ច បណ្ឌិតា
សព្វេ មច្ចុវសំ យន្តិ សព្វេ មច្ចុបរាយនា
តេសំ មច្ចុបរេតានំ គច្ឆតំ បរលោកតោ
ន បិតា តាយតេ បុត្តំ ញាតី វា បន ញាតកេ
បេក្ខតញ្ញេវ ញាតីនំ បស្ស លាលបតំ បុថុ
ឯកមេកោវ មច្ចានំ គោវជ្ឈោ វិយ និយ្យតិ
ឯវំ អព្ភាហតោ លោកោ មច្ចុនា ច ជរាយ ចាតិ ។

អថវា សោ ជរសាបិ មិយ្យតិ ។ តេនាហ ភគវា

អប្បំ វត ជីវិតំ ឥទំ
ឱរំ វស្សសតាបិ មិយ្យតិ
យោ ចេបិ អតិច្ច ជីវតិ
អថវា សោ ជរសាបិ មិយ្យតីតិ ។

១ ឱ. ម. ភេទនបរិយន្តា ។

ភាជន៍ដី ដែលកុម្ភការធ្វើហើយ ទាំងអស់ មានការបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិត របស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ពួកជនណា ទាំងក្មេង ទាំងចាស់ ទាំងពាល ទាំងបណ្ឌិត ពួកជនទាំងអស់នោះ រមែងលុះអំណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅខាងមុខ កាលពួកជនទាំងនោះ ដែលមច្ចុគ្របសង្កត់ ទៅកាន់បរលោក បិតាពឹងបុត្តមិនបាន ឬថាពួកញាតិពឹងពួកញាតិក៏មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសំឡឹងមើល កំពុងយំរៀបរាប់ច្រើន សត្វលោក ដែលត្រូវមច្ចុនិងជរាបំផ្លាញហើយ ដូចជាបណ្ដាសត្វទាំងឡាយ គោមួយ ៗ ដែលគេត្រូវនាំទៅសម្លាប់ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន ។

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជីវិតនេះ តិចណាស់ រមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ
បើបុគ្គលណា រស់នៅកន្លងហួស (អំពីមួយរយឆ្នាំ) ទៅ
បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន ។

(១៨៦) សោចន្តិ ជនា មមាយិតេ
ន ហិ សន្តិ និច្ចា បរិគ្គហា
វិនាភាវសន្តមេវិទំ
ឥតិ ទិស្វា នាគារមាវសេ ។

(១៨៧) សោចន្តិ ជនា មមាយិតេតិ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុអច្ឆេទសង្កិនោបិ សោចន្តិ អច្ឆិជ្ជន្តេបិ សោចន្តិ អច្ឆិន្នេបិ សោចន្តិ មមាយិតវត្ថុវិបរិណាមសង្កិនោបិ សោចន្តិ វិបរិណាមន្តេបិ សោចន្តិ វិបរិណតេបិ សោចន្តិ កិលមន្តិ បរិទេវន្តិ ឧរត្តាឡឹ កន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ សោចន្តិ ជនា មមាយិតេ ។

(១៨៦) ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត បុគ្គលកាលឃើញដូច្នេះ ហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

(១៨៧) អធិប្បាយពាក្យថា ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនជាអ្នកមានសេចក្តីរង្កៀស ដោយការដណ្តើមយកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលគេកំពុងដណ្តើមយក ក៏មាន សោកស្តាយចំពោះវត្ថុដែលគេដណ្តើមយកហើយ ក៏មាន ពួកជន មានសេចក្តីរង្កៀសដោយការប្រែប្រួលចាកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្តាយចំពោះវត្ថុដែលប្រែប្រួលហើយ ក៏មាន រមែងលំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវការវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ។

[១៨៨] ន ហិ សន្តិ និច្ចា បរិគ្គហាតិ បរិគ្គហាតិ ទ្វេ បរិគ្គហា តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។ បេ ។ អយំ តណ្ហាបរិគ្គហោ ។ បេ ។ អយំ ទិដ្ឋិបរិគ្គហោ ។ តណ្ហាបរិគ្គហោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធធម្មោ វិបរិណាមធម្មោ ។ ទិដ្ឋិបរិគ្គហោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធធម្មោ វិបរិណាមធម្មោ ។ វុត្តំ ហេតំ ភគវតា បស្សថ នោ តុម្ហេ ភិក្ខវេ តំ បរិគ្គហំ យ្វាយំ បរិគ្គហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ អហម្បិ ខោ ឯតំ ភិក្ខវេ បរិគ្គហំ ន សមនុបស្សាមិ យ្វាយំ បរិគ្គហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតីតិ ។

(១៨៨) អធិប្បាយពាក្យថា ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ត្រង់ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ការហួងហែងគឺតណ្ហា ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ ការហួងហែងគឺទិដ្ឋិ ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ធ្លាប់ឃើញការហួងហែង ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅ ស្មើដោយសស្សតិវត្ថុ ដូច្នោះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនុ៎ះ យើងខ្ញុំមិនធ្លាប់ឃើញទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ តថាគត ក៏ពិចារណាមិនឃើញនូវការហួងហែងនុ៎ះ ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅស្មើដោយសស្សតិវត្ថុ ដូច្នោះដែរ ។

បរិគ្គហា និច្ចា ធុវា សស្សតា អវិបរិណាមធម្មា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ ន ហិ សន្តិ និច្ចា បរិគ្គហោ ។

(១៨៩) វិនាភាវសន្តមេវិទន្តិ នានាភាវេ វិនាភាវេ អញ្ញថាភាវេ សន្តេ សំវិជ្ជមានេ[1] ឧបលព្ភិយមានេ ។ វុត្តំ ហេតំ ភគវតា អលំ អានន្ទ មា សោចិ មា បរិទេវិ ននុ ឯតំ អានន្ទ មយា បដិកច្ចេវ[2] អក្ខាតំ សព្វេហេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ អានន្ទ លព្ភា យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតីតិ ។ បុរិមានំ បុរិមានំ ខន្ធានំ ធាតូនំ អាយតនានំ វិបរិណាមញ្ញថាភាវា បច្ឆិមា បច្ឆិមា ខន្ធា ច ធាតុយោ ច អាយតនានិ ច បវត្តន្តីតិ វិនាភាវសន្តមេវិទំ ។

១ ម. សំវិជ្ជមានេ អត្ថិ ។ ២ បដិគច្ចេវាតិបិ បាឋោ ។

## ជរាសុត្តនិទ្ទេស ទី ៦

ការហួងហែងទាំងឡាយ ជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួល ជាធម្មតា ឥតមាន មិនដែលមាន មិនមានប្រាកដ មិនកើតមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ។

( ១៨៩ ) ពាក្យថា វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត គឺ ភាវៈផ្សេង ៗ ភាវៈព្រាត់ប្រាស ភាវៈទៅជាយ៉ាងដទៃ កាលមាន កាលកានព្រម កាលកើតមាន ។ សមដូចពាក្យនេះ ដែលព្រះមានបុណ្យត្រាស់ហើយថា ម្នាលអានន្ទ មិនគួរទេ អ្នកកុំសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ ក្រែងតថាគតបានពោលហើយ ក្នុងកាលមុន នូវពាក្យនេះថា ភាវៈផ្សេង ៗ ភាវៈព្រាត់ប្រាស ភាវៈជាយ៉ាងដទៃ ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ពេញចិត្តដូច្នេះឬ ម្នាលអានន្ទ បុគ្គលគប្បីបាននូវហេតុនោះ ក្នុងសត្វនិងសង្ខារទាំងនោះ អំពីទីណាថា វត្ថុណាកើតហើយ ប្រាកដហើយ តាក់តែងហើយ មានកិរិយាវិនាសជាធម្មតា ឲ្យវត្ថុនោះ កុំវិនាសឡើយ ដំណើរនោះមិនសមហេតុទេ ។ ព្រោះសេចក្ដីប្រែប្រួលជាយ៉ាងដទៃ របស់ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលមុន ៗ ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលខាងក្រោយ ៗ ក៏រមែងប្រព្រឹត្តទៅ (ដូចគ្នា) ហេតុនោះ (ទ្រង់ត្រាស់ថា) វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត ។

(១៩០) នត្ថិ តស្ស ឃរមាវសេតិ នត្ថីតិ បទ-សន្ធិ បទសំសគ្គោ បទបារិបូរិ(១) អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ នត្ថីតិ ។ នត្ថិ តស្ស បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មមត្តស្សតិ នត្ថិ តស្ស ។ ឃរមាវសេតិ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ នត្ថិ តស្ស ឃរមាវសេ ។ តេនាហ ភគវា

សោចន្តិ ជនា មមាយិតេ
ន ហិ សន្តិ និច្ចា បរិគ្គហា

---

១ ម. បទបារិបូរី ។

(១៩៤) អធិប្បាយពាក្យថា បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យភ្ជាប់បទ ជាពាក្យជាប់ទាក់ទងដោយបទ ជាពាក្យញុំាងបទឲ្យពេញ ជាពាក្យប្រជុំដោយអក្ខរៈ ជាបទសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់នៃបទ ។ បុគ្គលឃើញ យល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដ នូវវត្ថុដែលហួងហែង ដូច្នេះហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ ។ ពាក្យថា មិនគួរនៅគ្រប់គ្រងផ្ទះ គឺគប្បីកាត់បលិពោធ ក្នុងឃរាវាសគ្រប់យ៉ាង កាត់បលិពោធ ក្នុងបុត្តភរិយា កាត់បលិពោធក្នុងពួកញាតិ កាត់បលិពោធក្នុងមិត្តនិងអាមាត្យ កាត់បលិពោធក្នុងការសន្សំ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ(ចេញ)ចាកផ្ទះ ហើយបួសដោយភេទជាបុគ្គលមិនមានផ្ទះ ដល់នូវភាពមិនមានកង្វល់ ត្រាច់ទៅ នៃបនៅ សម្រេចសម្រាន្ត ប្រព្រឹត្ត រក្សា សម្រួល រស់នៅតែម្នាក់ឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង
ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ

វិនាភាវសន្តមេវិទំ
ឥតិ ទិស្វា នាគារមាវសេតិ ។

(១៩១) មរណេនបិ តំ បហីយតិ
យំ បុរិសោ មមយិទន្តិ មញ្ញតិ
ឯតម្បិ វិទិត្វា បណ្ឌិតោ
ន មមត្តាយ នមេថ មាមកោ ។

(១៩២) មរណេនបិ តំ បហីយតីតិ មរណន្តិ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា(១) ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្សុបច្ឆេទោ ។ តន្តិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ បហីយតីតិ បហីយតិ ជហីយតិ វិជហីយតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ ភាសិតម្បិ ហេតំ

បុព្វេវ មច្ចំ វិជហន្តិ ភោគា
មច្ចោ ធនេ បុព្វតរំ ជហាតិ
អសស្សតា ភោគិនោ កាមកាមិ

---
១ ម. បវនតា ខន្ធានំ ។

វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

(១៩១) បុរសសំគាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធ-

បញ្ចកៈនោះ រមែងសាបសូន្យ ដោយមរណៈ បណ្ឌិត

ជាអ្នករាប់អាន ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោន

ទៅក្នុងសេចក្ដីហួងហែងឡើយ ។

(១៩២) អធិប្បាយពាក្យថា ខន្ធបញ្ចកៈនោះ រមែងសាបសូន្យ ដោយមរណៈ ត្រង់ពាក្យថា មរណៈ បានដល់ ការច្យុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចោលសាកសព ការផ្ដាច់បង់ជីវិតិន្ទ្រិយ ពាកសត្តនិកាយនោះ ៗ របស់សត្វទាំងឡាយនោះ ៗ ។ ពាក្យថា ខន្ធបញ្ចកៈនោះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា សាបសូន្យ គឺ សាបសូន្យ លះបង់ បោះបង់ បាត់ទៅ វិនាសទៅ ។

សមដូចភាសិតនេះថា

ភោគៈទាំងឡាយ រមែងលះបង់នូវសត្វក្នុងកាលមុន ក៏មាន

សត្វលះបង់ភោគៈទាំងនោះ មុនជាងទៅទៀត ក៏មាន

នែអ្នកប្រាថ្នាកាម ពួកជនអ្នកមានភោគៈ មិនទៀងទេ

តស្មា ន សោចាមហំ សោកកាលេ
ឧទេតិ អាបូរតិ វេតិ ចន្ទោ
អត្ថំ តបេត្វាន បលេតិ សូរិយោ
វិទិតា មយា សត្តុក លោកធម្មា
តស្មា ន សោចាមហំ សោកកាលេតិ ។

មរណេនបិ តំ បហីយតិ ។

(១៩៣) យំ បុរិសោ មមយិទន្តិ មញ្ញតីតិ យន្តិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ បុរិសោតិ សង្ខា សមញ្ញា បញ្ញត្តិ លោកវោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ។ មមយិទន្តិ មញ្ញតីតិ តណ្ហាមញ្ញនាយ មញ្ញតិ ទិដ្ឋិមញ្ញនាយ មញ្ញតិ មានមញ្ញនាយ មញ្ញតិ កិលេសមញ្ញនាយ មញ្ញតិ ទុច្ចរិតមញ្ញនាយ មញ្ញតិ បយោគមញ្ញនាយ មញ្ញតិ វិបាកមញ្ញនាយ មញ្ញតីតិ យំ បុរិសោ មមយិទន្តិ មញ្ញតិ ។

ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ព្រះចន្ទ្ររះឡើងពេញវង់ លិចទៅ ព្រះអាទិត្យរះឡើងហើយអស្តង្គតទៅ នែអ្នកជាសត្រូវ លោកធម៌ទាំងឡាយ ខ្ញុំដឹងច្បាស់ហើយ ព្រោះហេតុនោះ ខ្ញុំទើបមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) ខន្ធបញ្ចកៈរមែងសាបសូន្យដោយមរណៈ ។

(១៩៣) អធិប្បាយពាក្យថា បុរសសំគាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ត្រង់ពាក្យថា ខន្ធបញ្ចកៈណា គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា បុរស គឺ ការរាប់ ឈ្មោះ បញ្ញត្តិ លោកវោហារ នាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជនៈ ការហៅរក ។ ពាក្យថា សំគាល់ថា នេះរបស់អញ គឺសំគាល់ក្នុងការសំគាល់ដោយតណ្ហា សំគាល់ក្នុងការសំគាល់ដោយទិដ្ឋិ សំគាល់ក្នុងការសំគាល់ដោយមានះ សំគាល់ក្នុងការសំគាល់ ដោយកិលេស សំគាល់ក្នុងការសំគាល់ដោយទុច្ចរិត សំគាល់ក្នុងការសំគាល់ដោយបយោគៈ សំគាល់ក្នុងការសំគាល់ដោយវិបាក ហេតុនោះ (ទ្រង់ត្រាស់ថា) បុរសសំគាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(១៩៨) ឯតម្បិ វិទិត្វា(១) បណ្ឌិតោតិ ឯតំ អាទី-នវំ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មមត្តេសូតិ ឯតម្បិ វិទិត្វា ។ បណ្ឌិ-តោតិ(២) ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ឯតម្បិ វិ-ទិត្វា(៣) បណ្ឌិតោ ។

(១៩៩) ន មមត្តាយ នមេថ មាមកោតិ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិម-មត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ មាមកោតិ ពុទ្ធមាមកោ ធម្មមាមកោ សង្ឃមាមកោ សោ ភគវន្តំ មមាយតិ ភគវា តំ បុគ្គលំ បរិគ្គណ្ហាតិ ។ វុត្តំ ហេតំ ភគវតា យេ តេ ភិក្ខវេ ភិក្ខូ កុហា ថទ្ធា(៤) លបា សិង្គី ឧន្នឡា អសមាហិតា ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា

---

១ ម. ឯតំ វិទិត្វាន ។ ២ ម. បណ្ឌិតោ ធីរោ បណ្ឌិតោ បញ្ញវា ។ ៣ ម. ឯតំ វិទិត្វាន ។
៤ ម. ពទ្ធា ។

## ជរាសុត្តនិទ្ទេស ទី ៦

(១៩៨) ពាក្យថា បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ គឺ ដឹង ស្គាល់ ថ្លឹង ត្រិះរិះ ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវទោសនុ៎ះ ក្នុងវត្ថុដែលហួសហេតុទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងច្បាស់ដំណើរនុ៎ះ ។ ពាក្យថា បណ្ឌិត គឺអ្នកមានប្រាជ្ញា មានញាណ មានបញ្ញាភ្លឺច្បាស់ មានបញ្ញាផ្ទុះធ្លាយ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ ។

(១៩៩) អធិប្បាយពាក្យថា ជាអ្នកពប់អាន មិនគប្បីបង្អោនទៅក្នុងសេចក្ដីហួសហេតុឡើយ ត្រង់ពាក្យថា សេចក្ដីហួសហេតុ បានដល់ សេចក្ដីហួសហេតុ ២ គឺ សេចក្ដីហួសហេតុគឺតណ្ហា ១ សេចក្ដីហួសហេតុគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្ដីហួសហេតុគឺតណ្ហា ។ បេ ។ នេះ សេចក្ដីហួសហេតុគឺទិដ្ឋិ ។ ពាក្យថា អ្នកពប់អាន គឺអ្នកពប់អានព្រះពុទ្ធ អ្នកពប់អានព្រះធម៌ អ្នកពប់អានព្រះសង្ឃ បុគ្គលនោះ តែងពប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏ទ្រង់ពប់អានបុគ្គលនោះ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកកុហក មានចិត្តរឹងត្អឹង ចរចាហួសហេតុ មានការរាប់ចំពាក់ ជាអ្នកឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនពប់អានតថាគតទេ

អបគតា ច តេ ភិក្ខូ[១] ឥមស្មា ធម្មវិនយា ន ច តេ ឥមស្មិំ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ និក្កុហា និល្លបា ធីរា អថទ្ធា[២] សុសមាហិតា តេ ខោ មេ ភិក្ខវេ ភិក្ខូ មាមកា អនបគតា ច តេ ភិក្ខូ ឥមស្មា ធម្មវិនយា តេ ច ឥមស្មិំ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តីតិ ។

កុហា ថទ្ធា លបា សិង្គី ឧន្នឡា អសមាហិតា
ន តេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ
និក្កុហា និល្លបា ធីរា អថទ្ធា សុសមាហិតា
តេ វេ ធម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។

ន មមត្តាយ នមេថ មាមកោតិ មាមកោ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា មមត្តាយ

---

១ ម. តេ ភិក្ខវេ ភិក្ខូ ។ ២. ម. អពទ្ធា ។

មួយទៀត ភិក្ខុទាំងនោះ ប្រាសចាកធម្មវិន័យនេះហើយ ភិក្ខុទាំងនោះ មិនដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះទេ ម្នាលភិក្ខុទាំងឡាយ លុះតែពួកភិក្ខុណា មិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាខ្ជាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង ឈ្មោះថា អ្នកកាន់ពាក្យតថាគត មួយទៀត ភិក្ខុទាំងនោះ មិនប្រាសចាកធម្មវិន័យនេះទេ ភិក្ខុទាំងនោះ ដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម្មវិន័យនេះ ។

ពួកភិក្ខុណា ជាអ្នកកុហក រឹងត្អឹង ចរចាហួសហេតុ
មានការផាប់ចំពាក់ ឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ ភិក្ខុទាំង
នោះ មិនលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធ
សំដែងទេ ពួកភិក្ខុណា ជាអ្នកមិនកុហក មិនចរចាហួស
ហេតុ មានប្រាជ្ញាខ្ជាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ភិក្ខុ
ទាំងនោះ ទើបលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធ
សំដែងហើយ ។

ពាក្យថា បណ្ឌិតជាអ្នកកាន់ពាក្យ មិនគប្បីបន្ទោរទៅ ក្នុងសេចក្តីហួងហែង បានសេចក្តីថា បុគ្គលអ្នកកាន់ពាក្យ (ព្រះរតនត្រ័យ) គប្បីលះបង់សេចក្តីហួងហែងគិតណា រលាស់ចោលសេចក្តីហួងហែង គឺទិដ្ឋិ

ន នមេយ្យ ន ឱនមេយ្យ ន តន្និន្នោ អស្ស ន តប្បោណោ ន តប្បព្ភារោ ន តទធិមុត្តោ ន តទាធិបតេយ្យោតិ ន មមត្តាយ នមេថ មាមកោ ។

តេនាហ ភគវា

មរណេនបិ តំ បហីយតិ
យំ បុរិសោ មមយិទន្តិ មញ្ញតិ
ឯវម្បិ វិទិត្វា បណ្ឌិតោ
ន មមត្តាយ នមេថ មាមកោតិ ។

(១៩៦) សុបិនេន យថាបិ សង្គតំ
បដិពុទ្ធោ បុរិសោ ន បស្សតិ
ឯវម្បិ បិយាយិតំ ជនំ
បេតំ កាលកតំ ន បស្សតិ ។

(១៩៧) សុបិនេន យថាបិ សង្គតន្តិ សង្គតំ សមាគតំ សមាហិតំ សន្និបតិតន្តិ សុបិនេន យថាបិ សង្គតំ ។

ហើយមិនបង្អោនទៅ មិនបន្ទន់ទៅ ក្នុងសេចក្តីហួងហែង ជាអ្នកមិនឱន ទៅរកសេចក្តីហួងហែងនោះ មិនផ្អាកទៅរកសេចក្តីហួងហែងនោះ មិនឈមទៅរកសេចក្តីហួងហែងនោះ មិនចុះចិត្តស៊ប់ទៅរកសេចក្តីហួងហែងនោះ មិនយកសេចក្តីហួងហែងនោះជាធំ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតជាអ្នកកប់អាន មិនគប្បីបង្អោនទៅ ក្នុងសេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុរសសំគាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធបញ្ចកៈ
> នោះ រមែងសាបសូន្យដោយមរណៈ បណ្ឌិតជាអ្នកកប់អាន
> ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោនទៅក្នុងសេចក្តី
> ហួងហែងឡើយ ។

(១៩៦) បុរសភ្ញាក់ឡើងហើយ មិនឃើញអារម្មណ៍ ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

(១៩៧) ពាក្យថា អារម្មណ៍ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា គឺចួបប្រទះ គប់ប្រសប់ រួមគ្នា ចួបជុំគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) អារម្មណ៍ដែលចួបប្រទះ ដោយការយល់សប្តិ យ៉ាងណា ។

(១៩៨) បដិពុទ្ធោ បុរិសោ ន បស្សតីតិ យថា បុរិសោ សុបិនគតោ ចន្ទំ បស្សតិ សុរិយំ បស្សតិ មហាសមុទ្ទំ បស្សតិ សិនេរុបព្វតរាជំ បស្សតិ ហត្ថឹ បស្សតិ អស្សំ បស្សតិ រថំ បស្សតិ បត្តឹ បស្សតិ សេនាព្យូហំ បស្សតិ អារាមរាមណេយ្យកំ បស្សតិ វនរាមណេយ្យកំ បស្សតិ ភូមិរាមណេយ្យកំ បស្សតិ បោក្ខរណីរាមណេយ្យកំ បស្សតិ បដិពុទ្ធោ ន កិញ្ចិ បស្សតីតិ បដិពុទ្ធោ បុរិសោ ន បស្សតិ ។

(១៩៩) ឯវម្បិ បិយាយិតំ ជនន្តិ ឯវន្តិ ឱបម្មសម្បដិបាទនា ។ បិយាយិតំ ជនន្តិ បិយាយិតំ មមាយិតំ ជនំ មាតរំ វា បិតរំ វា ភាតរំ វា ភគិនឹ វា បុត្តំ វា ធីតរំ វា មិត្តំ វា អមច្ចំ វា ញាតិសាលោហិតំ វាតិ ឯវម្បិ បិយាយិតំ ជនំ ។

(២០០) បេតំ កាលកតំ ន បស្សតីតិ បេតា វុច្ចន្តិ មតា កាលកតា ។ ន បស្សតីតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិលភតីតិ បេតំ កាលកតំ ន បស្សតិ ។

តេនាហ ភគវា

(១៩៨) ពាក្យថា បុរសភ្ញាក់ឡើងហើយ មិនឃើញ សេចក្តីថា បុរសអ្នកយល់សប្តិឃើញព្រះចន្ទ្រ ឃើញព្រះអាទិត្យ ឃើញមហាសមុទ្រ ឃើញស្តេចភ្នំសិនេរុ ឃើញដំរី ឃើញសេះ ឃើញរថ ឃើញពលថ្មើរជើង ឃើញសេនាព្យូហៈ ឃើញសួនច្បារជាទីត្រេកអរ ឃើញព្រៃជាទីត្រេកអរ ឃើញផែនដីជាទីត្រេកអរ ឃើញស្រះបោក្ខរណីជាទីត្រេកអរ ភ្ញាក់ឡើងហើយ ក៏មិនឃើញអ្វីសោះ យ៉ាងណា ហេតុនោះ(ទ្រង់ត្រាស់ថា) បុរសភ្ញាក់ឡើងហើយមិនឃើញ ។

(១៩៩) ពាក្យថា ក៏យ៉ាងនោះដែរ របស់បទថា ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ គឺជាវាចាផ្តល់ដោយសេចក្តីឧបមា ។ ពាក្យថា ជនជាទីស្រឡាញ់ គឺជនដែលស្រឡាញ់ ដែលរាប់អាន ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្តក្តី ធីតាក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ ។

(២០០) ពាក្យថា បុគ្គលមិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ សេចក្តីថា ពួកជនស្លាប់ ធ្វើមរណកាលហើយ លោកហៅថា អ្នកទៅកាន់បរលោក ។ បុគ្គលមិនឃើញ មិនជួប មិនប្រទះ មិនបាន ឥតបាន ហេតុនោះ(ទ្រង់ត្រាស់ថា) មិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សុបិនេន យថាបិ សង្គតំ
បដិពុទ្ធោ បុរិសោ ន បស្សតិ
ឯវម្បិ បិយាយិតំ ជនំ
បេតំ កាលកតំ ន បស្សតីតិ ។

(២០១) ទិដ្ឋាបិ សុតាបិ តេ ជនា
យេសំ នាមមិទំ បវុច្ចតិ
នាមមេវាវសិស្សតិ
អក្ខេយ្យំ បេតស្ស ជន្តុនោ ។

(២០២) ទិដ្ឋាបិ សុតាបិ តេ ជនាតិ ទិដ្ឋាតិ យេ ចក្ខុវិញ្ញាណាភិសម្ភូតា ។ សុតាតិ យេ សោតវិញ្ញាណាភិសម្ភូតា ។ តេ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ចាតិ ទិដ្ឋាបិ សុតាបិ តេ ជនា ។

(២០៣) យេសំ នាមមិទំ បវុច្ចតីតិ យេសន្តិ យេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្វជិតានំ ទេវានំ មនុស្សានំ ។ នាមន្តិ សង្ខា សមញ្ញា បញ្ញត្តិ លោកវោហារោ នាមំ

បុរសម្នាក់ទៀតហើយ មិនឃើញអារម្មណ៍ដែលចួបប្រទះ ដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញ ជនជាទីស្រឡាញ់ ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

(២០១) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជននោះ គេឃើញខ្លះ ឮខ្លះ នាមប៉ុណ្ណឹងឯងរបស់សត្វទៅកាន់បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។

(២០២) អធិប្បាយពាក្យថា ពួកជននោះ គេឃើញខ្លះ ឮខ្លះ ត្រង់ពាក្យថា គេឃើញ គឺពួកជនណា ដែលចួបប្រទះ ដោយចក្ខុវិញ្ញាណ ។ ពាក្យថា ឮ គឺពួកជនណា ដែលចួបប្រទះ ដោយសោតវិញ្ញាណ ។ ពាក្យថា ពួកជននោះ គឺក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និង មនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជននោះ គេឃើញខ្លះ ឮខ្លះ ។

(២០៣) អធិប្បាយពាក្យថា នាមនេះ របស់ពួកជនណា ដែលគេតែងពោល ត្រង់ពាក្យថា របស់ពួកជនណា គឺរបស់ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ណា ៗ ពាក្យថា នាម គឺការរាប់ ឈ្មោះ បញ្ញត្តិ លោកវោហារ នាម

នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ។ បវុច្ចតីតិ កថិយតិ ភណិយតិ ទីបិយតិ វោហារិយតីតិ យេសំ នាមមិទំ បវុច្ចតិ ។

(២០៤) នាមមេវាវសិស្សតិ អក្ខេយ្យន្តិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ បហីយតិ ជហីយតិ វិជហីយតិ អន្តរធាយតិ វិប្បលុជ្ជតិ នាមមេវាវសិស្សតិ ។ អក្ខេយ្យន្តិ អក្ខាតុំ កថេតុំ ភណិតុំ ទីបយិតុំ វោហរិតុន្តិ នាមមេវាវសិស្សតិ អក្ខេយ្យំ ។ បេតស្ស ជន្តុនោតិ បេតស្សាតិ មតស្ស កាលកតស្ស ។ ជន្តុនោតិ សត្តស្ស នរស្ស មាណវស្ស បោសស្ស បុគ្គលស្ស ជីវស្ស ជាគុស្ស ជន្តុស្ស ឥន្ទគុស្ស[១] មនុជស្សាតិ អក្ខេយ្យំ បេតស្ស ជន្តុនោ ។ តេនាហ ភគវា

ទិដ្ឋាបិ សុតាបិ តេ ជនា
យេសំ នាមមិទំ បវុច្ចតិ
នាមមេវាវសិស្សតិ
អក្ខេយ្យំ បេតស្ស ជន្តុនោតិ ។

---

១ ម. ហិន្ទគុស្ស ។

អំពើរបស់នាម ពាក្យទ្រទ្រង់នូវនាម ភាសា ព្យញ្ជនៈ ការហៅគេ ។ ពាក្យថា គេតែងពោល គឺ គេតែងសំដែង តែងនិយាយ តែងបំភ្លឺ តែងបញ្ចេញ ហេតុនោះ (ទ្រង់ត្រាស់ថា) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ។

(២០៤) ពាក្យថា នាមហ្នឹងឯងដែលគួរហៅបាន រមែងសល់នៅ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលឃ្លាតចេញ លះចេញស្រឡះ បាត់បង់ វិនាស តែនាមរមែងសល់នៅ ។ ពាក្យថា គួរហៅបាន គឺ គួរពោល សំដែង បំភ្លឺ បញ្ចេញបាន ហេតុនោះ (ទ្រង់ត្រាស់ថា) នាមហ្នឹងឯង ដែលគួរហៅបាន រមែងសល់នៅ ។ ពាក្យថា ទៅកាន់បរលោក របស់បទថា របស់សត្វទៅកាន់បរលោក គឺ សត្វស្លាប់ ធ្វើមរណកាលហើយ ។ ពាក្យថា របស់សត្វ គឺរបស់សត្វ នរៈ មាណព បុរស បុគ្គល សត្វមានជីវៈ សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វមានជាតិអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) របស់សត្វទៅកាន់បរលោក ដែលគួរហៅបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជន
នោះ គេឃើញខ្លះ ឮខ្លះ នាមហ្នឹងឯងរបស់សត្វ ទៅកាន់
បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។

(២០៨) សោកបរិទេវមច្ឆរំ
ន ជហន្តិ គិទ្ធា មមាយិតេ
តស្មា មុនយោ បរិគ្គហំ
ហិត្វា អចរិំសុ ខេមទស្សិនោ ។

(២០៩) សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេតិ សោកោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្ត អន្តោសោកោ អន្តោបរិសោកោ អន្តោទាហោ អន្តោបរិទាហោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ ។ បរិទេវោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ។ បេ ។ ទិដ្ឋិព្យសនេន វា

(២០៥) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុ ដែលហួងហែង ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

(២០៦) អធិប្បាយពាក្យថា ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ត្រង់ពាក្យថា សេចក្តីសោកគឺការសោក ការសោកស្តាយ ភាពនៃចិត្តសោកស្តាយ សោកខាងក្នុង ស្តាយស្រណោះខាងក្នុង ក្តៅក្រហាយខាងក្នុង ក្តៅពេលពលខាងក្នុង ជ្រប់ ស្រពោនចិត្ត ទោមនស្ស សរគឺសោក របស់សត្វ ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគៈប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការយំរៀបរាប់ អាការយំ អាការយំរៀបរាប់ ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលឥតប្រយោជន៍ ការពោលរវើរវាយ ការពោលរឿយៗ អាការដោយពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ។ បេ ។

ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន វា ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយម្បិ មច្ឆរិយំ ធាតុមច្ឆរិយម្បិ មច្ឆរិយំ អាយតនមច្ឆរិយម្បិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុអច្ឆេទសង្កិនោបិ សោចន្តិ អច្ឆិជ្ជន្តេបិ សោចន្តិ អច្ឆិន្នេបិ សោចន្តិ មមាយិតវត្ថុវិបរិណាមសង្កិនោបិ

សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស១ សេចក្តីកំណាញ់ត្រកូល១ សេចក្តីកំណាញ់លាភ១ សេចក្តីកំណាញ់វណ្ណៈ១ សេចក្តីកំណាញ់ធម៌១ សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃការកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ ស្វកន្ទ្រឹះ ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេ ណាមានសភាពយ៉ាងនេះ នេះ ហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធ ក៏ឈ្មោះថាសេចក្តីកំណាញ់ សេចក្តីកំណាញ់ធាតុ ក៏ឈ្មោះថា សេចក្តីកំណាញ់ សេចក្តីកំណាញ់អាយតនៈ ក៏ឈ្មោះថាសេចក្តីកំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្តីកំណាញ់ ។ តណ្ហា លោកហៅថា ការចង់បាន បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ ការសំឡឹងរំពៃ លោភៈ អកុសលមូល ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ២ គឺ ការហួងហែងគឺតណ្ហា ១ ការហួងហែងគឺទិដ្ឋិ១ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនមានសេចក្តីរង្កៀស ដោយការដណ្តើមយកវត្ថុដែលហួងហែង សោកស្តាយក៏មាន សោកស្តាយវត្ថុដែលគេកំពុងដណ្តើមយក ក៏មាន សោកស្តាយវត្ថុដែលគេដណ្តើមយកហើយ ក៏មាន ពួកជន មានសេចក្តីរង្កៀសដោយការប្រែប្រួល នៃវត្ថុដែលហួងហែង

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

សោចន្តិ វិបរិណាមន្តេបិ សោចន្តិ វិបរិណតេបិ សោចន្តិ ។ មមាយិតវត្ថុអច្ឆេទសង្កិនោបិ បរិទេវន្តិ អច្ឆិជ្ជន្តេបិ បរិទេវន្តិ អច្ឆិន្នេបិ បរិទេវន្តិ ។ មមាយិ-តវត្ថុវិបរិណាមសង្កិនោបិ បរិទេវន្តិ វិបរិណាមន្តេបិ បរិទេវន្តិ វិបរិណតេបិ បរិទេវន្តិ ។ មមាយិតវត្ថុំ រក្ខន្តិ គោបេន្តិ បរិគ្គណ្ហន្តិ មមាយន្តិ មច្ឆាយន្តិ ។ មមាយិតស្មឹ វត្ថុស្មឹ សោចន្តិ សោកំ ន ជហន្តិ បរិទេវំ ន ជហន្តិ មច្ឆរិយំ ន ជហន្តិ គេធំ ន ជហន្តិ នប្បជហន្តិ ន វិនោទេន្តិ ន ព្យន្តីករោន្តិ ន អនភាវង្គមេន្តិ សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេ ។

(២០៧) តស្មា មុនយោ បរិគ្គហំ ហិត្វា អចរឹសុ ខេមទស្សិនោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯតំ

រមែងសោកស្ដាយ ក៏មាន សោកស្ដាយវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្ដាយវត្ថុដែលប្រែប្រួលហើយ ក៏មាន ។ អ្នកមានសេចក្ដីរង្កៀសដោយការដណ្ដើមយកវត្ថុដែលហួងហែង ខ្សឹកខ្សួល ក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេកំពុងដណ្ដើមយកក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលគេដណ្ដើមយកហើយក៏មាន អ្នកមានសេចក្ដីរង្កៀសដោយការប្រែប្រួល នៃវត្ថុដែលហួងហែង ខ្សឹកខ្សួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុដែលកំពុងប្រែប្រួលក៏មាន ខ្សឹកខ្សួលនឹងវត្ថុ ដែលប្រែប្រួលហើយក៏មាន ។ ពួកជនរមែងក្រេង គ្រប់គ្រង កួចកាន់ ហួងហែង កំណាញ់វត្ថុដែលហួងហែង ។ ពួកជនរមែងសោកស្ដាយ វត្ថុដែលហួងហែង មិនលះបង់សេចក្ដីសោក មិនលះបង់សេចក្ដីខ្សឹកខ្សួល មិនលះបង់សេចក្ដីកំណាញ់ មិនលះបង់ មិនលះចោល មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការមិនកើតមានសេចក្ដីប្រាថ្នាហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល និងសេចក្ដីកំណាញ់ ក្នុងវត្ថុដែលហួងហែង ។

(២០៧) អធិប្បាយពាក្យថា ព្រោះហេតុនោះ មុនិទាំងឡាយជាអ្នកឃើញសេចក្ដីក្សេម បានប្រព្រឹត្ត លះបង់សេចក្ដីហួងហែងចេញ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ

អាទីនវំ សម្បស្សមានោ មមត្តេសូតិ តស្មា ។ មុនយោតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតា មុនយោ មោនប្បត្តា ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។បេ។ សង្គជាលមតិច្ច សោ មុនិ ។ បរិគ្គហោតិ ទ្វេ បរិគ្គហា តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។បេ។ អយំ តណ្ហាបរិគ្គហោ ។បេ។ អយំ ទិដ្ឋិបរិគ្គហោ ។ មុនយោ តណ្ហាបរិគ្គហំ បហាយ ទិដ្ឋិបរិគ្គហំ បដិនិស្សជ្ជិត្វា អចរិំសុ វិចរិំសុ(១) ឥរិយិំសុ វត្តិំសុ បាលិំសុ យបិំសុ យាបិំសុ ។ ខេមទស្សិនោតិ ខេមំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ ខេមទស្សិនោតិ ខេមទស្សិនោ តាណទស្សិនោ

១ ម. វិហរិំសុ ។

មុនិកាលឃើញច្បាស់ នូវទោសនុ៎ះ ក្នុងវត្ថុដែលហួនហែនទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា មុនិទាំងឡាយ សេចក្ដីថា ញាណ ហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្ដីយល់ឃើញត្រូវ មុនិទាំងឡាយ ប្រកបដោយញាណនោះ ដល់ហើយនូវការដឹង ។ មោនេយ្យៈ មាន ៣ គឺកាយមោនេយ្យៈ វចីមោនេយ្យៈ មនោមោនេយ្យៈ ។ បេ ។ បុគ្គលណាកន្លងបង់បណ្ដាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ហៅថាមុនិ ។ ពាក្យថា សេចក្ដីហួនហែន បានដល់សេចក្ដីហួនហែន ២ គឺ សេចក្ដីហួនហែនគឺតណ្ហា ១ សេចក្ដីហួនហែនគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្ដីហួនហែនគឺតណ្ហា ។ បេ ។ នេះ សេចក្ដីហួនហែនគឺទិដ្ឋិ ។ មុនិទាំងឡាយ លះបង់សេចក្ដីហួនហែនគឺតណ្ហា រលាស់ចោលសេចក្ដីហួនហែនគឺទិដ្ឋិ បានរង្គាត់ទៅ ត្រាប់ទៅ ដើរទៅ សម្រេច ប្រព្រឹត្ត រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ពាក្យថា អ្នកឃើញសេចក្ដីក្សេម សេចក្ដីថា អមតនិព្វាន លោកហៅថា សេចក្ដីក្សេម បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់ទៅនៃតណ្ហា សេចក្ដីនឿយណាយ សេចក្ដីរលត់ ព្រះនិព្វាន ។ ពាក្យថា អ្នកឃើញសេចក្ដីក្សេម បានសេចក្ដីថា អ្នកឃើញសេចក្ដីក្សេម អ្នកឃើញទីជ្រកកោន

លេណទស្សិនោ សរណទស្សិនោ អភយទស្សិនោ អច្ចុតទស្សិនោ អមតទស្សិនោ និព្វានទស្សិនោតិ តស្មា មុនយោ បរិគ្គហំ ហិត្វា អចរិំសុ ខេមទស្សិនោ ។ តេនាហ ភគវា

សោកបរិទេវមច្ឆរំ
ន ជហន្តិ គិទ្ធា មមាយិតេ
តស្មា មុនយោ បរិគ្គហំ
ហិត្វា អចរិំសុ ខេមទស្សិនោតិ ។

(២០៨) បដិលីនចរស្ស ភិក្ខុនោ
ភជមានស្ស វិវិត្តមាសនំ
សាមគ្គិយមាហុ តស្ស តំ
យោ អត្តានំ ភវនេ ន ទស្សយេ ។

(២០៩) បដិលីនចរស្ស ភិក្ខុនោតិ បដិលីនចរា វុច្ចន្តិ សត្ត សេក្ខា អរហា បដិលីនោ ។ កិំការណា បដិលីនចរា វុច្ចន្តិ សត្ត សេក្ខា ។ តេ តតោ តតោ ចិត្តំ បដិលីនេន្តា បដិកុដេន្តា[1] បដិវដ្ដេន្តា សន្និរុទ្ធន្តា

១ ម. បដិកុដ្ដេន្តា ។

អ្នកឃើញទីពឹងពួន អ្នកឃើញទីពឹង អ្នកឃើញទីមិនមានភ័យ អ្នកឃើញទីមិនច្យុត អ្នកឃើញអមតៈ អ្នកឃើញព្រះនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្តលះបង់សេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តី
ខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ព្រោះ
ហេតុនោះ មុនិទាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម បាន
ប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

(២០៨) អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះថាជាសាមគ្គី របស់
ភិក្ខុអ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ ដែលមិនបង្ហាញ
ខ្លួនក្នុងទីកើត ។

(២០៩) ពាក្យថា របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ អធិប្បាយថា សេក្ខបុគ្គល ៧ លោកហៅថាអ្នកប្រព្រឹត្តរួញថយ ឯព្រះអរហន្ត ជាអ្នកប្រព្រឹត្តរួញថយហើយ ។ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយ ព្រោះហេតុអ្វី ។ សេក្ខបុគ្គល ៧ ពួកនោះ ញុំាងចិត្តឲ្យរួញថយ ឲ្យខ្ចូរ ឲ្យវិលវិញ អំពីអារម្មណ៍នោះ ៗ ខ្ទប់ សង្កត់សង្កិន

សន្និគណ្ហន្តា សន្និវារេន្តា រក្ខន្តា គោបេន្តា ចរន្តិ[១] វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ ចក្ខុទ្វារេ ចិត្តំ បដិលីនេន្តា បដិកុដេន្តា បដិវដ្ដេន្តា សន្និរុន្ធន្តា សន្និគណ្ហន្តា សន្និវារេន្តា រក្ខន្តា គោបេន្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ សោតទ្វារេ ចិត្តំ ឃានទ្វារេ ចិត្តំ ជិវ្ហាទ្វារេ ចិត្តំ កាយទ្វារេ ចិត្តំ មនោទ្វារេ ចិត្តំ បដិលីនេន្តា បដិកុដេន្តា បដិវដ្ដេន្តា សន្និរុន្ធន្តា សន្និគណ្ហន្តា សន្និវារេន្តា រក្ខន្តា គោបេន្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ យថា កុក្កុដបត្តំ វា នហារុទទ្ទុលំ វា អគ្គិម្ហិ បក្ខិត្តំ ហោតិ បដិលីយតិ បដិកុដតិ បដិវត្តតិ ន សម្បសារិយតិ ឯវមេវ តេ តតោ តតោ ចិត្តំ បដិលីនេន្តា បដិកុដេន្តា បដិវដ្ដេន្តា សន្និរុន្ធន្តា សន្និគណ្ហន្តា សន្និវារេន្តា រក្ខន្តា គោបេន្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ចក្ខុទ្វារេ ចិត្តំ សោតទ្វារេ ចិត្តំ ឃានទ្វារេ ចិត្តំ ជិវ្ហាទ្វារេ ចិត្តំ កាយទ្វារេ ចិត្តំ

---

១ ម. ចរន្តិ វិចរន្តិ ។

រាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ សេក្ខបុគ្គលទាំងនោះ ញុំាងចិត្តក្នុងចក្ខុទ្វារឲ្យរួញថយ ឲ្យខ្ចូរ ឲ្យវិលវិញ ខ្ទប់ សង្កត់សង្កិន រាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ញុំាងចិត្តក្នុងសោតទ្វារ ញុំាងចិត្តក្នុងឃានទ្វារ ញុំាងចិត្តក្នុងជិវ្ហាទ្វារ ញុំាងចិត្តក្នុងកាយទ្វារ ញុំាងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្ចូរ ឲ្យវិលវិញ ខ្ទប់ សង្កត់សង្កិន រាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ស្លាបមាន់ ឬទងសរសៃ ដែលគេដាក់ក្នុងភ្លើង រមែងរួញ ខ្ចូរ វិលវិញ មិនលា យ៉ាងណាមិញ សេក្ខបុគ្គលទាំងនោះ ញុំាងចិត្តឲ្យរួញថយ ឲ្យខ្ចូរ ឲ្យវិលវិញ អំពីអារម្មណ៍នោះ ៗ ខ្ទប់ សង្កត់សង្កិន រាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្តទៅ រក្សា ចិញ្ចឹម ទំនុកបម្រុង ក៏យ៉ាងនោះដែរ ញុំាងចិត្តក្នុងចក្ខុទ្វារ ញុំាងចិត្តក្នុងសោតទ្វារ ញុំាងចិត្តក្នុងឃានទ្វារ ញុំាងចិត្តក្នុងជិវ្ហាទ្វារ ញុំាងចិត្តក្នុងកាយទ្វារ

មនោទ្វារេ ចិត្តំ បដិលីនេត្វា បដិកុដេត្វា បដិវដ្ដេត្វា សន្និរុម្ភិត្វា សន្និគណ្ហិត្វា សន្និវារេត្វា រក្ខិត្វា គោបេត្វា ចរតិ វិហរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតិ ។ តំការណា បដិលីនចរោ វុច្ចតិ សត្ត សេក្ខា ។ ភិក្ខុនោតិ កល្យាណបុថុជ្ជនស្ស វា ភិក្ខុនោ សេក្ខស្ស វា ភិក្ខុនោតិ បដិលីនចរស្ស ភិក្ខុនោ ។

(២១០) ភជមានស្ស វិវិត្តមាសនន្តិ អាសនំ វុច្ចតិ យត្ថ និសីទតិ មញ្ចោ បីឋំ ភិសិ តដ្ដិកា ចម្មខណ្ឌោ តិណសន្ថារោ បណ្ណសន្ថារោ បលាសសន្ថារោ[(១)] ។ តំ អាសនំ អសប្បាយរូបទស្សនេន វិត្តំ[(២)] វិវិត្តំ បវិវិត្តំ អសប្បាយសទ្ទស្សវនេន វិត្តំ[(៣)] វិវិត្តំ បវិវិត្តំ អសប្បាយគន្ធឃាយនេន អសប្បាយរសសាយនេន អសប្បាយផោដ្ឋព្វផុសនេន អសប្បាយេហិ បញ្ចហិ កាមគុណេហិ វិត្តំ វិវិត្តំ បវិវិត្តំ ។ តំ អាសនំ ភជតោ សម្ភជតោ សេវតោ និសេវតោ សំសេវតោ បដិសេវតោតិ ភជមានស្ស វិវិត្តមាសនំ ។

---

១ ឱ. ម. បលាលសន្ថារោ ។ ២. ៣. ម. រិត្តំ ។

ញ៉ាំងចិត្តក្នុងមនោទ្វារ ឲ្យរួញថយ ឲ្យខ្សូរ ឲ្យវិលវិញ ខ្ទប់ សង្កត់ សង្កិន រារាំង រក្សា គ្រប់គ្រង ត្រាច់ទៅ សម្រេចឥរិយាបថ សម្រាន្តចិត្ត ប្រព្រឹត្ត រក្សា ចិញ្ចឹម ទំនុកបម្រុង ។ ព្រោះហេតុនោះ សេក្ខបុគ្គល ៧ ពួក លោកហៅថា អ្នកប្រព្រឹត្តរួញថយ ។ ពាក្យថា របស់ភិក្ខុ គឺរបស់ភិក្ខុជាកល្យាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ភិក្ខុអ្នកប្រព្រឹត្តរួញថយ ។

(២១០) ពាក្យថា គប់រកអាសនៈស្ងាត់ សេចក្តីថា ភិក្ខុអង្គុយក្នុងទីណា ទីនោះលោកហៅថាអាសនៈ គឺគ្រែ តាំង ពូក កន្ទេល ចម្មខ័ណ្ឌ កម្រាលស្មៅ កម្រាលស្លឹកឈើ កម្រាលចំបើង ។ អាសនៈនោះជាទីស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឃើញរូបមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការឮសំឡេងមិនជាទីសប្បាយ ស្ងាត់ ស្ងាត់ច្រៀប ស្ងាត់ឈឹង ចាកការធុំក្លិនមិនជាទីសប្បាយ ចាកការលិទ្ធភក្សរសមិនជាទីសប្បាយ ចាកការពាល់ត្រូវផ្សព្វមិនជាទីសប្បាយ ចាកកាមគុណទាំង ៥ មិនជាទីសប្បាយ ។ កាលគប់រក ភពប្រសព្វ សេពគប់ អាស្រ័យ ចូលចិត្ត ផ្តេកផ្តិត ចំពោះអាសនៈនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) គប់រកអាសនៈស្ងាត់ ។

(២១១) សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេតិ សាមគ្គិយាតិ តិស្សោ សាមគ្គិយោ គណសាមគ្គី ធម្មសាមគ្គី អនភិនិព្វត្តិសាមគ្គី ។

កតមា គណសាមគ្គី ។ ពហូ ចេបិ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ អយំ គណសាមគ្គី ។

កតមា ធម្មសាមគ្គី ។ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ តេ ឯកតោ បក្ខន្ទន្តិ បសីទន្តិ សម្បតិដ្ឋន្តិ វិមុច្ចន្តិ ន តេសំ ធម្មានំ វិវាទោ វិប្បវាទោ អត្ថិ អយំ ធម្មសាមគ្គី ។

កតមា អនភិនិព្វត្តិសាមគ្គី ។ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេសំ និព្វានធាតុយា ឱនត្តំ[១] វា បុណ្ណត្តំ វា បញ្ញាយតិ អយំ អនភិនិព្វត្តិសាមគ្គី ។

១ ខ. ម. ឩនត្តំ ។

(២១១) អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គីរបស់ភិក្ខុ ដែលមិនបង្ហាញខ្លួនកន្លងទៅកើត ត្រង់ពាក្យថា សាមគ្គី បានដល់សាមគ្គី ៣ យ៉ាង គឺ គណសាមគ្គី ធម្មសាមគ្គី អនភិនិព្វត្តិសាមគ្គី ។

គណសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយ ច្រើនរូប ព្រមព្រៀងគ្នា មានសេចក្តីស្មោះសរនឹងគ្នា មិនទាស់ទែងគ្នា មានសភាពហាក់ដូចទឹក ដែលលាយដោយទឹកដោះស្រស់ សំឡឹងមើលគ្នានឹងគ្នា ដោយចក្ខុជាទីស្រឡាញ់ នេះ ឈ្មោះថា គណសាមគ្គី ។

ធម្មសាមគ្គី តើដូចម្តេច ។ សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធម៌ទាំងនោះ រមែងលឿនទៅ ថ្លាស្អាត តាំងនៅល្អ រូបស្រឡះក្នុងទីជាមួយគ្នា ការជជែក ការទាស់ទែងនៃធម៌ទាំងនោះ រមែងមិនមាន នេះឈ្មោះថា ធម្មសាមគ្គី ។

អនភិនិព្វត្តិសាមគ្គី តើដូចម្តេច ។ បើភិក្ខុទាំងឡាយ ច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ការខ្វះខាត ឬការពេញក្នុងនិព្វានធាតុ នៃភិក្ខុទាំងនោះក៏មិនប្រាកដ នេះ ឈ្មោះថា អនភិនិព្វត្តិសាមគ្គី ។

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

ភវនេតិ នេរយិកានំ និរយោ ភវនំ តិរច្ឆានយោនិកានំ តិរច្ឆានយោនិ ភវនំ បេត្តិវិសយិកានំ បេត្តិវិសយោ ភវនំ មនុស្សានំ មនុស្សលោកោ ភវនំ ទេវានំ ទេវលោកោ ភវនំ ។ សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេតិ តស្សេសា សាមគ្គី ឯតំ ឆន្នំ ឯតំ បតិរូបំ ឯតំ អនុច្ឆវិកំ ឯតំ អនុលោមំ យោ ឯវំ បដិបន្នោ[១] និរយេ អត្តានំ ន ទស្សេយ្យ តិរច្ឆានយោនិយា អត្តានំ ន ទស្សេយ្យ បេត្តិវិសយេ អត្តានំ ន ទស្សេយ្យ មនុស្សលោកេ អត្តានំ ន ទស្សេយ្យ ទេវលោកេ អត្តានំ ន ទស្សេយ្យាតិ ឯវមាហុ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ ។ តេនាហ ភគវា

បដិលីនចរស្ស ភិក្ខុនោ
ភជមានស្ស វិវិត្តមាសនំ
សាមគ្គិយមាហុ តស្ស តំ
យោ អត្តានំ ភវនេ ន ទស្សយេតិ ។

---

១ ម. បដិប្បន្នោ ។

ជរាសុត្តនិទ្ទេស ទី ៦

ពាក្យថា ក្នុងទីកើត គឺនរកជាទីកើតរបស់ពួកសត្វនរក កំណើតតិរច្ឆានជាទីកើតរបស់ពួកសត្វ ក្នុងកំណើតតិរច្ឆាន បិត្តិវិស័យជាទីកើតរបស់ពួកសត្វក្នុងបិត្តិវិស័យ មនុស្សលោកជាទីកើតរបស់ពួកមនុស្ស ទេវលោកជាទីកើតរបស់ពួកទេវតា ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយពោលអំពើនោះថាជាសាមគ្គីរបស់ភិក្ខុដែលមិនបង្ហាញខ្លួនក្នុងទីកើត បានសេចក្តីថា ភិក្ខុណាប្រតិបត្តិយ៉ាងនេះ ឈ្មោះថា មិនគប្បីបង្ហាញខ្លួនក្នុងនរក មិនបង្ហាញខ្លួនក្នុងកំណើតតិរច្ឆាន មិនបង្ហាញខ្លួនក្នុងបិត្តិវិស័យ មិនបង្ហាញខ្លួនក្នុងមនុស្សលោក មិនបង្ហាញខ្លួនក្នុងទេវលោក អំពើនុះឈ្មោះថាសេចក្តីព្រមព្រៀង នុះឈ្មោះថាជាទីបំពុង នុះឈ្មោះថាជាទីសមរម្យ នុះឈ្មោះថាជាទីសមគួរ នុះឈ្មោះថាជាទីសមសួន របស់ភិក្ខុនោះ អ្នកប្រាជ្ញទាំងឡាយ ពោលហើយយ៉ាងនេះ បានពោលហើយយ៉ាងនេះ សំដែងយ៉ាងនេះ និយាយយ៉ាងនេះ បង្កុយ៉ាងនេះ បញ្ចេញយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គីរបស់ភិក្ខុដែលមិនបង្ហាញខ្លួនក្នុងទីកើត ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកប្រាជ្ញទាំងឡាយ ពោលអំពើនោះ ថាជាសាមគ្គី របស់
ភិក្ខុ អ្នកប្រព្រឹត្តរួញថយ គប់រកអាសនៈស្ងាត់ ដែលមិន
បង្ហាញខ្លួន ក្នុងទីកើត ។

(២១២) សព្វត្ថ មុនិ អនិស្សិតោ

ន បិយំ កុព្វតិ នោបិ អប្បិយំ

តស្មិំ បរិទេវមច្ឆរំ

បណ្ណេ វារិ យថា ន លិម្បតិ ។

(២១៣) សព្វត្ថ មុនិ អនិស្សិតោតិ សព្វំ វុច្ចតិ ទ្វាទសាយតនានិ ចក្ខុញ្ចេវ រូបា ច សោតញ្ច សទ្ទា ច ឃានញ្ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្វា ច មនោ ច ធម្មា ច ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានតា ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ អនិស្សិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ មុនិ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ជិវ្ហំ អនិស្សិតោ កាយំ អនិស្សិតោ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ

(២១២) មុនិមិនអាស្រ័យនៅ ក្នុងវត្ថុទាំងពួង មិនធ្វើសេចក្តី
ស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ (ចំពោះសត្វនិងសង្ខារ)
សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ មិនជាប់នៅក្នុង
មុនីនោះ ដូចជាពារិ មិនជាប់នៅលើស្លឹក (ឈូក) ។

(២១៣) ពាក្យថា មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង អធិប្បាយថា វត្ថុទាំងពួង លោកពោលសំដៅយកអាយតនៈ ១២ គឺ ភ្នែក ១ រូប ១ ត្រចៀក ១ សំឡេង ១ ច្រមុះ ១ ក្លិន ១ អណ្តាត ១ រស ១ កាយ ១ ផ្សព្វ ១ ចិត្ត ១ ធម៌ ១ ។ ពាក្យថា មុនិ សេចក្តីថា ញាណ ហៅថា មោនៈ គឺប្រាជ្ញា ការដឹងច្បាស់ ។បេ។ បុគ្គលណា ក្នុងបង់នូវបណ្តាញ គឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា មិនអាស្រ័យនៅ បានដល់និស្ស័យ ២ យ៉ាង គឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះទិដ្ឋិនិស្ស័យ ។ មុនិលះបង់តណ្ហានិស្ស័យ រលាស់ចោលទិដ្ឋិនិស្ស័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ មិនអាស្រ័យជិវ្ហា មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យរូប សំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ ត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សុខ

ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ អសន្និស្សិតោ អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដ្ឋោ[១] វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ សព្វត្ថ មុនិ អនិស្សិតោ ។

(២១៤) ន បិយំ កុព្វតិ នោបិ អប្បិយន្តិ បិយាតិ ទ្វេ បិយា សត្តា វា សង្ខារា វា ។

កតមេ សត្តា បិយា ។ ឥធ យស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា បុត្តា វា ធីតា វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា ឥមេ សត្តា បិយា ។

---

១ ម. និស្សដោ ។

ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ គិលានប្បច្ច័យភេ-សជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អារម្មណ៍ជាអតីត អនាគត បច្ចុប្បន្ន អារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង គឺមិនអាស្រ័យនៅព្រម មិនពួនសម្ងំ មិនចូលទៅជិត មិនជ្រុលជ្រប់ មិនចុះចិត្តស៊ប់ ជាអ្នកចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ មិនអាស្រ័យនៅកន្លែងតាំងពួន ។

(២១៤) អធិប្បាយពាក្យថា មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ ត្រង់ពាក្យថា សេចក្តីស្រឡាញ់ បានដល់ សេចក្តីស្រឡាញ់ ២ គឺ ពួកសត្វ ១ សង្ខារ ១ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្តេច ។ ពួកជនណាក្នុងលោកនេះ ជាអ្នកប្រាថ្នាសេចក្តីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសប្បាយ ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ដល់មុនិនោះ ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្តក្តី ធីតាក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី នេះពួកសត្វជាទីស្រឡាញ់ ។

កតមេ សង្ខារា បិយា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា បិយា ។

អប្បិយាតិ ទ្វេ អប្បិយា សត្តា ច សង្ខារា ច ។

កតមេ សត្តា អប្បិយា ។ ឥធ យស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកាមា អយោគក្ខេមកាមា ជីវិតា វោរោបេតុកាមា ឥមេ សត្តា អប្បិយា ។

កតមេ សង្ខារា អប្បិយា ។ អមនាបិកា រូបា អមនាបិកា សទ្ទា អមនាបិកា គន្ធា អមនាបិកា រសា អមនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា អប្បិយា ។

ន បិយំ កុព្វតិ នោបិ អប្បិយន្តិ អយំ មេ សត្តោ បិយោ ឥមេ ច មេ សង្ខារា មនាបាតិ រាគវសេន[១] បិយំ ន ករោតិ អយំ មេ សត្តោ អប្បិយោ ឥមេ ច មេ សង្ខារា អមនាបាតិ បដិឃវសេន អប្បិយំ ន ករោតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន បិយំ កុព្វតិ នោបិ អប្បិយំ ។

---

១ ឱ. រង្គវសេន ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា ស្អប់ បានដល់សេចក្តីស្អប់ ២ គឺពួកសត្វ ១ សង្ខារ ១ ។

ពួកសត្វជាទីស្អប់ តើដូចម្តេច ។ ពួកជនណា ក្នុងលោកនេះ ជាអ្នកមិនប្រាថ្នាសេចក្តីចំរើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសប្បាយ មិនប្រាថ្នាសេចក្តីក្សេម ចាកយោគៈ ជាអ្នកប្រាថ្នា ដើម្បីឲ្យវិនាស ចាកជីវិត ដល់មុនិនោះ នេះពួកសត្វជាទីស្អប់ ។

ពួកសង្ខារជាទីស្អប់ តើដូចម្តេច ។ រូបមិនជាទីពេញចិត្ត សំឡេងមិនជាទីពេញចិត្ត ក្លិនមិនជាទីពេញចិត្ត រសមិនជាទីពេញចិត្ត ផ្សព្វមិនជាទីពេញចិត្ត នេះពួកសង្ខារជាទីស្អប់ ។

ពាក្យថា មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ បានសេចក្តីថា បុគ្គលមិនធ្វើសេចក្តីស្រឡាញ់ ដោយអំណាចរាគៈថា សត្វនេះជាទីស្រឡាញ់របស់អញ សង្ខារទាំងនេះ ជាទីពេញចិត្តរបស់អញ បុគ្គលមិនធ្វើ មិនបង្កើត មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យកើតឡើង មិនឲ្យកើតចំពោះ នូវសេចក្តីស្អប់ ដោយអំណាចបដិឃៈថា សត្វនេះជាទីស្អប់របស់អញ សង្ខារទាំងនេះ ជាទីស្អប់របស់អញ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើសេចក្តីស្រឡាញ់ ទាំងមិនធ្វើសេចក្តីស្អប់ ។

(២១៨) តស្មឹ បរិទេវមច្ឆរំ បណ្ណេ វារិ យថា ន លិម្បតីតិ តស្មឹន្តិ តស្មឹ បុគ្គលេ អរហន្តេ ខីណាសវេ ។ បរិទេវោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆាយនា មច្ឆាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ អបិច ខន្ធមច្ឆរិយំបិ មច្ឆរិយំ ធាតុមច្ឆរិយំបិ មច្ឆរិយំ

ជរាសុត្តនិទ្ទេស ទី ៦

(២១៩) អធិប្បាយពាក្យថា សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ មិនជាប់នៅ ក្នុងមុនិនោះ ដូចជាវារិមិនជាប់នៅលើស្លឹក(ឈូក) ត្រង់ពាក្យថា ក្នុងមុនិនោះ គឺក្នុងបុគ្គលជាព្រះអរហន្តខីណាស្រព ។ ពាក្យថាសេចក្តីខ្សឹកខ្សួល គឺ ការយំ ការយំរៀបរាប់ អាការយំ អាការយំអណ្តឺតអណ្តក ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការនិយាយ ការពោលប៉ប៉ុះប៉ិប៉ប៉ោច ការពោលរវើរវាយ ការពោលរៀយៗ អាការជាទីពោលរៀយៗ ភាពនៃការពោលរៀយៗ របស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបព្រមដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១ សេចក្តីកំណាញ់លាភ ១ សេចក្តីកំណាញ់វណ្ណៈ ១ សេចក្តីកំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃចិត្តកំណាញ់ សេចក្តីចង់មានហួសហេតុ ស្ទុរក្រ្ទឹស ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេ ណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីកំណាញ់ មួយទៀត សូម្បីសេចក្តីកំណាញ់ខន្ធ ក៏ឈ្មោះថា កំណាញ់ សូម្បីសេចក្តីកំណាញ់ធាតុ ក៏ឈ្មោះថា កំណាញ់

អាយតនមច្ឆរិយំបិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ បណ្ណេ វារិ យថា ន លិម្បតីតិ បណ្ណំ វុច្ចតិ បទុមបត្តំ ។ វារិ វុច្ចតិ ឧទកំ ។ យថា វារិ បទុមបត្តេ ន លិម្បតិ ន សំលិម្បតិ នុបលិម្បតិ អលិត្តំ អសំលិត្តំ អនុបលិត្តំ ឯវមេវ តស្មឹ បុគ្គលេ អរហន្តេ ខីណាសវេ បរិទេវោ ច មច្ឆរិយញ្ច ន លិម្បតិ ន សំលិម្បតិ(១) នុបលិម្បតិ អលិត្តា អសំលិត្តា(២) អនុបលិត្តា សោ ច បុគ្គលោ តេហិ កិលេសេហិ ន លិម្បតិ ន សំលិម្បតិ នុបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ តស្មឹ បរិទេវមច្ឆរំ បណ្ណេ វារិ យថា ន លិម្បតិ ។ តេនាហ ភគវា

សព្វត្ថ មុនិ អនិស្សិតោ
ន បិយំ កុព្វតិ នោបិ អប្បិយំ
តស្មឹ បរិទេវមច្ឆរំ
បណ្ណេ វារិ យថា ន លិម្បតីតិ ។

---

១ ម. បលិម្បតិ ។ ២ ម. អបលិត្តា ។

សម្បីសេចក្ដីកំណាញ់អាយតនៈ ឈ្មោះថា កំណាញ់ ការគិតតែកាន់យកនេះលោកហៅថា សេចក្ដីកំណាញ់ ។ ពាក្យថា មិនជាប់នៅដូចជាវារិមិនជាប់លើស្លឹក(ឈូក) សេចក្ដីថា ស្លឹកឈូក លោកហៅថា ស្លឹក ។ ទឹក លោកហៅថា វារិ ។ វារិមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយនឹងស្លឹកឈូក យ៉ាងណាមិញ សេចក្ដីខ្សឹកខ្សួល នឹងសេចក្ដីកំណាញ់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ ក្នុងបុគ្គលនោះ គឺក្នុងព្រះអរហន្តខីណាស្រព ក៏យ៉ាងនោះដែរ ទាំងបុគ្គលនោះ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញរួចហើយ រលាស់ចេញហើយ រួចស្រឡះហើយប្រាសចេញហើយ ចាកកិលេសទាំងនោះ ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីខ្សឹកខ្សួល នឹងសេចក្ដីកំណាញ់ មិនជាប់ក្នុងបុគ្គលនោះ ដូចជាវារិ មិនជាប់លើស្លឹក(ឈូក) ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មុនិ មិនអាស្រ័យនៅក្នុងវត្ថុទាំងពួង មិនធ្វើសេចក្ដីស្រឡាញ់
ទាំងមិនធ្វើសេចក្ដីស្អប់ (ចំពោះសត្វនឹងសង្ខារ) សេចក្ដីខ្សឹក
ខ្សួលនឹងសេចក្ដីកំណាញ់ មិនជាប់នៅក្នុងមុនិនោះ ដូចជា
វារិ មិនជាប់នៅលើស្លឹក (ឈូក) ។

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(២១៦) ឧទពិន្ទុ យថាបិ បោក្ខរេ
បទុមេ វារិ យថា ន លិម្បតិ
ឯវំ មុនិ នោបលិម្បតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វា ។

(២១៧) ឧទពិន្ទុ យថាបិ បោក្ខរេតិ ឧទពិន្ទុ វុច្ចតិ ឧទកថេវោ ។ បោក្ខរំ វុច្ចតិ បទុមបត្តំ ។ យថា ឧទកពិន្ទុ បទុមបត្តេ ន លិម្បតិ ន សំលិម្បតិ នុបលិម្បតិ អលិត្តំ អសំលិត្តំ អនុបលិត្តន្តិ ឧទពិន្ទុ យថាបិ បោក្ខរេ ។

(២១៨) បទុមេ វារិ យថា ន លិម្បតីតិ បទុមំ វុច្ចតិ បទុមបុប្ផំ ។ វារិ វុច្ចតិ ឧទកំ ។ យថា វារិ បទុមបុប្ផេ ន លិម្បតិ ន សំលិម្បតិ នុបលិម្បតិ អលិត្តំ អសំលិត្តំ អនុបលិត្តន្តិ បទុមេ វារិ យថា ន លិម្បតិ ។

(២១៩) ឯវំ មុនិ នោបលិម្បតិ យទិទំ ទិដ្ឋសុតំ មុតេសុ វាតិ ឯវន្តិ ឱបម្មសម្បដិបាទនា ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។ បេ ។

(២១៦) ដំណក់ទឹក មិនជាប់នៅលើស្លឹកឈូក យ៉ាងណា វារិមិនជាប់នៅលើផ្កាឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះដែរ ។

(២១៧) ពាក្យថា ដំណក់ទឹកមិនជាប់លើស្លឹកឈូក យ៉ាងណា សេចក្តីថា គ្រាប់ទឹក លោកហៅថា ដំណក់ទឹក ។ ស្លឹកឈូកលោកហៅថាឈូក ។ ដំណក់ទឹកមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើស្លឹកឈូកយ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) ដំណក់ទឹកមិនជាប់លើស្លឹកឈូក យ៉ាងណា ។

(២១៨) ពាក្យថា វារិ មិនជាប់នៅលើផ្កាឈូក យ៉ាងណា សេចក្តីថា ផ្កាឈូក លោកហៅថា ឈូក ។ ទឹក លោកហៅថា វារិ ។ វារិ មិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់នៅ មិនជ្រួតជ្រាប មិនប្រឡាក់ហើយ លើផ្កាឈូក យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) វារិ មិនជាប់នៅលើផ្កាឈូក យ៉ាងណា ។

(២១៩) អធិប្បាយពាក្យថា មុនិមិនជាប់នៅក្នុងអារម្មណ៍ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ត្រង់ពាក្យថា យ៉ាងនោះ គឺជាពាក្យផ្តល់សេចក្តីឧបមា ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោក ហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។

សន្តិជាលមតិច្ច សោ មុនិ ។ លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។ បេ ។ អយំ តណ្ហាលេបោ ។ បេ ។ អយំ ទិដ្ឋិលេបោ ។ មុនិ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា ទិដ្ឋេ ន លិម្បតិ សុតេ ន លិម្បតិ មុតេ ន លិម្បតិ វិញ្ញាតេ ន លិម្បតិ ន សំលិម្បតិ នុបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ឯវំ មុនិ នោបលិម្បតិ យទិទំ ទិដ្ឋសុតំ មុតេសុ វា ។ តេនាហ ភគវា

ឧទវិន្ទុ យថាបិ បោក្ខរេ
បទុមេ វារិ យថា ន លិម្បតិ
ឯវំ មុនិ នោបលិម្បតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វាតិ ។

(២២០) ធោនោ ន ហិ តេន មញ្ញតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វា
នាញ្ញេន វិសុទ្ធិមិច្ឆតិ
ន ហិ សោ រជ្ជតិ នោ វិរជ្ជតីតិ ។

បុគ្គលណា កន្លងបណ្ដាញគឺគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។ ពាក្យថា ជាប់ បានដល់ការជាប់ ២ គឺការជាប់គឺតណ្ហា ១ ការជាប់គឺទិដ្ឋិ ១ ។ បេ ។ នេះការជាប់គឺតណ្ហា ។ បេ ។ នេះការជាប់គឺទិដ្ឋិ ។ មុនិ លះបង់ការជាប់គឺតណ្ហា រលាស់ចោលការជាប់គឺទិដ្ឋិ មិនជាប់ក្នុងរូបដែលឃើញ មិនជាប់ក្នុងសំឡេងដែលឮ មិនជាប់ក្នុងផស្សៈដែលប៉ះពាល់ មិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ គឺមិនជាប់ មិនជ្រួតជ្រាប មិនប្រឡាក់ ចេញទៅ រលាស់ចេញ រួចស្រឡះ ប្រាសចេញហើយ ក្នុងអារម្មណ៍ដែលដឹង ជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិមិនជាប់ក្នុងអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ យ៉ាងនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ដំណក់ទឹក មិនជាប់នៅលើស្លឹកឈូក យ៉ាងណា វារិ មិនជាប់
នៅលើផ្កាឈូក យ៉ាងណា មុនិ មិនជាប់ក្នុងអារម្មណ៍ ដែល
ខ្លួនឃើញ ឮ ឬប៉ះពាល់ ក៏យ៉ាងនោះ ។

(២២០) បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់នូវអារម្មណ៍
ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ មិនប្រាថ្នា
សេចក្ដីបរិសុទ្ធិដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកំចាត់
នោះ រមែងមិនត្រេក មិន(ត្រាន់) ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(២២១) ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋ-សុតំ មុតេសុ វាតិ ធោនោតិ ធោនា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ កិំការណា ធោនា វុច្ចតិ បញ្ញា ។ តាយ បញ្ញាយ កាយទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ វចីទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ មនោទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ រាគោ ធុតោ ច ធោតោ ច សន្ធោតោ ច និទ្ធោតោ ច ។ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ តំការណា ធោនា វុច្ចតិ បញ្ញា ។ អថវា សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិ ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។

(៤២១) អធិប្បាយពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់ចំពោះអារម្មណ៍ដែលខ្លួនឃើញ ឮ ប៉ះពាល់ ដោយវត្ថុនោះ ត្រង់ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់ សេចក្តីថា បញ្ញា លោកហៅថា ប្រាជ្ញាកំចាត់ បានខាងប្រាជ្ញា សេចក្តីដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ។ បញ្ញា លោកហៅថាប្រាជ្ញាកំចាត់ តើព្រោះហេតុដូចម្តេច ។ កាយទុច្ចរិត លោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ដោយបញ្ញានោះ ។ វចីទុច្ចរិតលោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ។ មនោទុច្ចរិត លោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ។ រាគៈលោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ។ ទោសៈ មោហៈ ក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ លោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ។ ហេតុនោះ បញ្ញាលោកហៅថាប្រាជ្ញាកំចាត់ ។ មួយទៀត មិច្ឆាទិដ្ឋិ លោកកំចាត់បង់ហើយ លាងហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាទិដ្ឋិ ។

សម្មាសង្កប្បេន មិច្ឆាសង្កប្បោ ធុតោ ច ធោតោ ច សន្ធោតោ ច និទ្ធោតោ ច ។ សម្មាវាចាយ មិច្ឆាវាចា ធុតា ច ។ សម្មាកម្មន្តេន មិច្ឆាកម្មន្តោ ធុតោ ច ។ សម្មាអាជីវេន មិច្ឆាអាជីវោ ធុតោ ច ។ សម្មាវាយាមេន មិច្ឆាវាយាមោ ធុតោ ច ។ សម្មាសតិយា មិច្ឆាសតិ ធុតា ច ។ សម្មាសមាធិនា មិច្ឆាសមាធិ ធុតោ ច ។ សម្មាញាណេន មិច្ឆាញាណំ ធុតញ្ច ។ សម្មាវិមុត្តិយា មិច្ឆាវិមុត្តិ ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ អថវា អរិយេន អដ្ឋង្គិកេន មគ្គេន សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ អរហា ឥមេហិ ធោតេយ្យេហិ ធម្មេហិ ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា អរហា ធោនោ ។ សោ ធុតរាគោ ធុតទោសោ ធុតកិលេសោ ធុតបរិឡាហោតិ ធោនោ ។

មិច្ឆាសង្កប្បៈ លោកកំចាត់បង់ហើយ លាង់ហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាសង្កប្បៈ ។ មិច្ឆាវាចា លោកកំចាត់បង់ហើយ ដោយសម្មាវាចា ។ មិច្ឆាកម្មន្តៈ លោកកំចាត់បង់ហើយ ដោយសម្មាកម្មន្តៈ ។ មិច្ឆាអាជីវៈ លោកកំចាត់បង់ហើយ ដោយសម្មាអាជីវៈ ។ មិច្ឆាវាយាមៈ លោកកំចាត់បង់ហើយ ដោយសម្មាវាយាមៈ ។ មិច្ឆាសតិ លោកកំចាត់បង់ហើយ ដោយសម្មាសតិ ។ មិច្ឆាសមាធិ លោកកំចាត់បង់ហើយ ដោយសម្មាសមាធិ ។ មិច្ឆាញាណៈ លោកកំចាត់បង់ហើយ ដោយសម្មាញាណៈ ។ មិច្ឆាវិមុត្តិ លោកកំចាត់បង់ហើយ លាង់ហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ដោយសម្មាវិមុត្តិ ។ មួយទៀត កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ ការតាក់តែងអកុសលទាំងអស់ លោកកំចាត់បង់ហើយ លាង់ហើយ សំអាតហើយ ជម្រះឲ្យស្អាតហើយ ដោយអរិយមគ្គមានអង្គ ៨ ប្រការ ។ ព្រះអរហន្ត ចូលទៅ ចូលទៅព្រម ចូលទៅជិត ផ្តេកផ្តិត កើត កើតឡើងជាមួយ ប្រកបដោយធោនេយ្យធម៌ទាំងនេះ ព្រោះហេតុនោះ ព្រះអរហន្តឈ្មោះថាអ្នកមានប្រាជ្ញាកំចាត់ ។ ព្រះអរហន្តនោះ កំចាត់បង់រាគៈ កំចាត់បង់បាប កំចាត់បង់កិលេស កំចាត់បង់សេចក្តីអន្ទះអន្ទែង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមានប្រាជ្ញាកំចាត់ ។

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋសុតំ មុតេសុ វាតិ ធោនោ ទិដ្ឋំ ន មញ្ញតិ ទិដ្ឋស្មឹ ន មញ្ញតិ ទិដ្ឋតោ ន មញ្ញតិ ទិដ្ឋំ មេតិ ន មញ្ញតិ ។ សុតំ ន មញ្ញតិ សុតស្មឹ ន មញ្ញតិ សុតតោ ន មញ្ញតិ សុតំ មេតិ ន មញ្ញតិ ។ មុតំ ន មញ្ញតិ មុតស្មឹ ន មញ្ញតិ មុតតោ ន មញ្ញតិ មុតំ មេតិ ន មញ្ញតិ ។ វិញ្ញាតំ ន មញ្ញតិ វិញ្ញាតស្មឹ ន មញ្ញតិ វិញ្ញាតតោ ន មញ្ញតិ វិញ្ញាតំ មេតិ ន មញ្ញតិ ។ វុត្តំ ហេតំ ភគវតា អស្មីតិ ភិក្ខវេ មញ្ញិតមេតំ អនស្មីតិ(១) មញ្ញិតមេតំ ភវិស្សន្តិ មញ្ញិតមេតំ ន ភវិស្សន្តិ មញ្ញិតមេតំ រូបី ភវិស្សន្តិ មញ្ញិតមេតំ អរូបី ភវិស្សន្តិ មញ្ញិតមេតំ សញ្ញី ភវិ-ស្សន្តិ មញ្ញិតមេតំ អសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ

---

១ ឱ. ម. អយមហមស្មីតិ ។

## ឆកបុគ្គនិទ្ទេស ទី ៦

ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ ដោយវត្ថុនោះ បានសេចក្តីថា បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់រូបដែលឃើញ មិនសំគាល់ក្នុងរូបដែលឃើញ មិនសំគាល់ដោយរូបដែលឃើញ មិនសំគាល់ថារូបដែលអញឃើញហើយ ៗ មិនសំគាល់សំឡេងដែលឮ មិនសំគាល់ក្នុងសំឡេងដែលឮ មិនសំគាល់ដោយសំឡេងដែលឮ មិនសំគាល់ថា សំឡេងដែលអញឮហើយ ៗ មិនសំគាល់អារម្មណ៍ដែលប៉ះពាល់ មិនសំគាល់ក្នុងអារម្មណ៍ដែលប៉ះពាល់ មិនសំគាល់ដោយអារម្មណ៍ដែលប៉ះពាល់ មិនសំគាល់ថា អារម្មណ៍ដែលអញប៉ះពាល់ហើយ ៗ មិនសំគាល់ហេតុដែលដឹង មិនសំគាល់ក្នុងហេតុដែលដឹង មិនសំគាល់ដោយហេតុដែលដឹង មិនសំគាល់ថា ហេតុដែលអញដឹងហើយ ៗ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញកំពុងមាន អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញកំពុងមិនមាន អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមាន អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមាន អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមានរូប អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានរូប អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញា អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមិនមានសញ្ញា

នេវសញ្ញីនាសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ មញ្ញិតំ ភិក្ខវេ រោគោ មញ្ញិតំ គណ្ឌោ មញ្ញិតំ សល្លំ មញ្ញិតំ ឧបទ្ទវោ តស្មាតិហ ភិក្ខវេ អមញ្ញមានេន ចេតសា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋសុតំ មុតេសុ វា ។

(២២២) នាញ្ញេន វិសុទ្ធិមិច្ឆតីតិ ធោនោ អញ្ញេន អសុទ្ធិមគ្គេន មិច្ឆាបដិបទាយ អនិយ្យានិកបថេន អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិកា មគ្គា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ ន ឥច្ឆតិ ន សាទិយតិ ន បត្ថេតិ ន បិហេតិ នាភិជប្បតីតិ នាញ្ញេន វិសុទ្ធិមិច្ឆតិ ។

អ្នកសំគាល់ហេតុនុ៎ះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេ ម្នាលភិក្ខុទាំងឡាយ អ្នកសំគាល់ថាជារោគ អ្នកសំគាល់ថាជាបូស អ្នកសំគាល់ថាជាសរ អ្នកសំគាល់ថាជាឧបទ្រព ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ (ប្រសិក្សា)ថា យើងទាំងឡាយ គប្បីនៅដោយចិត្តមិនបានសំគាល់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងហ្នឹងឯង ។ បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់អារម្មណ៍ដែលខ្លួនឃើញ ឮ ប៉ះពាល់ ដោយតែនោះ ។

(៥៥៥) ពាក្យថា មិនប្រាថ្នាសេចក្តីបរិសុទ្ធិ ដោយហេតុដទៃ គឺបុគ្គលមានប្រាជ្ញាកំចាត់ រមែងមិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនស្រឡាញ់ មិនជាប់ចំពោះនូវសេចក្តីស្អាត ការហ្មត់ចត់ ការបរិសុទ្ធិ ការរួច ការរួចស្រឡះ ការផុតស្រឡះ ដោយមគ្គមិនបរិសុទ្ធិ ដោយសេចក្តីប្រតិបត្តិខុស ដោយគន្លងមិនមែនជានិយ្យានិកធម៌ដទៃ វៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអរិយមគ្គមានអង្គ ៨ ហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រាថ្នាសេចក្តីបរិសុទ្ធិ ដោយហេតុដទៃៗ

## ឆដ្ឋោ ជរាសុត្តនិទ្ទេសោ

(២២៣) ន ហិ សោ រជ្ជតិ នោ វិរជ្ជតីតិ សព្វេ ពាលបុថុជ្ជនា រជ្ជន្តិ កល្យាណបុថុជ្ជនំ ឧបាទាយ សត្ត សេក្ខា វិរជ្ជន្តិ អរហា នេវ រជ្ជតិ នោ វិរជ្ជតិ ។ វិរត្តោ សោ ខយា រាគស្ស វីតរាគត្តា ខយា ទោសស្ស វីតទោសត្តា ខយា មោហស្ស វីតមោហត្តា ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ នត្ថិ តស្ស បុនព្ភវោតិ ន ហិ សោ រជ្ជតិ នោ វិរជ្ជតិ ។ តេនាហ ភគវា

ធោនោ ន ហិ តេន មញ្ញតិ
យទិទំ ទិដ្ឋសុតំ មុតេសុ វា
នាញ្ញេន វិសុទ្ធិមិច្ឆតិ
ន ហិ សោ រជ្ជតិ នោ វិរជ្ជតីតិ ។

ឆដ្ឋោ ជរាសុត្តនិទ្ទេសោ និដ្ឋិតោ ។

(៥២៣) ពាក្យថា បុគ្គលមានប្រាជ្ញាកំចាត់នោះ រមែងមិនត្រេក មិនត្រាន់ សេចក្តីថា ពាលបុថុជ្ជនទាំងអស់ រមែងត្រេក សេក្ខបុគ្គល ៧ ពួក រាប់ទាំងកល្យាណបុថុជ្ជនផង រមែងត្រាន់ ព្រះអរហន្ត រមែងមិនត្រេក មិនត្រាន់ ។ ព្រះអរហន្តនោះ ប្រាសចាកតម្រេក ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ។ ព្រះអរហន្តនោះ មានការអប់រំព្រហ្មចរិយធម៌ស្រេចហើយ មានការប្រព្រឹត្ត ប្រព្រឹត្តរួចហើយ ។បេ។ ភពថ្មីរបស់ព្រះអរហន្តនោះ មិនមានទេ ហេតុនោះ (ទ្រង់ត្រាស់) ថា បុគ្គលមានប្រាជ្ញាកំចាត់នោះ រមែងមិនត្រេក មិនត្រាន់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមានប្រាជ្ញាកំចាត់ មិនសំគាល់នូវអារម្មណ៍ ដែលខ្លួន
ឃើញឮ ឬប៉ះពាល់ ដោយវត្ថុនោះ មិនប្រាថ្នាសេចក្តីបរិសុទ្ធិ
ដោយហេតុដទៃ បុគ្គលមានប្រាជ្ញាកំចាត់នោះ រមែងមិនត្រេក
មិនត្រាន់ ។

ចប់ ជរាសុត្តនិទ្ទេស ទី ៦ ។

---

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

(២២៤) មេថុនមនុយុត្តស្ស (ឥច្ចាយស្មា
តិស្សោ មេត្តេយ្យោ)
វិឃាតំ ព្រូហិ មារិស
សុត្វាន តវ សាសនំ
វិវេកេ សិក្ខិស្សាមសេ ។

(២២៥) មេថុនមនុយុត្តស្សាតិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ គាមធម្មោ វសលធម្មោ ទុដ្ឋុល្លោ ឱទកន្តិកោ រហស្សោ ទ្វយទ្វយសមាបត្តិ ។ កិំការណា វុច្ចតិ មេថុនធម្មោ ។ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ ។ យថា ឧភោ កលហការកា មេថុនកាតិ វុច្ចន្តិ ឧភោ ភណ្ឌនការកា មេថុនកាតិ វុច្ចតិ ឧភោ ភស្សការកា មេថុនកាតិ វុច្ចន្តិ ឧភោ វិវាទការកា មេថុនកាតិ វុច្ចន្តិ ឧភោ អធិករណការកា មេថុនកាតិ វុច្ចន្តិ ឧភោ វាទិនោ មេថុនកាតិ វុច្ចន្តិ ឧភោ សល្លាបកា មេថុនកាតិ វុច្ចន្តិ

# តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

(២២៨) (ព្រះតិស្សមេត្តេយ្យៈ មានអាយុក្រាបទូលយ៉ាងនេះថា)

បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ សូមព្រះអង្គពោលសេចក្តីបង្អៀត
បង្អល់ របស់បុគ្គលដែលប្រកបរឿយ ៗ ក្នុងមេថុន យើង
ខ្ញុំស្តាប់ពាក្យប្រដៅរបស់ព្រះអង្គហើយ នឹងសិក្សាក្នុងវិវេក ។

(២២៩) ពាក្យថា បុគ្គលប្រកបរឿយៗក្នុងមេថុន អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានដល់ ធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការបួបផុំរបស់បុគ្គលពីរ ៗ នាក់ ។ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក (ដោយរាគៈ) រួបរឹត (ដោយរាគៈ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ជនពីរនាក់ ធ្វើជំលោះ លោកហៅថា គូជម្លោះ ជនពីរនាក់ ធ្វើសេចក្តីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ ចរចាគ្នាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់ និយាយឆ្លើយឆ្លងគ្នា លោកហៅថា គូឆ្លើយឆ្លង

ឃរមេវ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ ។ មេថុនមនុយុត្តស្សាតិ មេថុនធម្មេ យុត្តស្ស បយុត្តស្ស អាយុត្តស្ស សមាយុត្តស្ស តច្ចរិតស្ស តព្ពហុលស្ស តគ្គរុកស្ស តន្និន្នស្ស តប្បោណស្ស តប្បព្ភារស្ស តទធិមុត្តស្ស តទាធិបតេយ្យស្សាតិ មេថុនមនុយុត្តស្ស ។

(៤៤៦) ឥច្ចាយស្មា តិស្សោ មេត្តេយ្យោតិ ឥច្ចាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សវចនមេតំ អាយស្មាតិ ។ តិស្សោតិ តស្ស ថេរស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ។

យ៉ាងណា ធម៌របស់ជនពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក (ដោយរាគៈ) រួបរឹត (ដោយរាគៈ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យថា ប្រកបរឿយៗក្នុងមេថុន បានសេចក្តីថា ប្រកបតាក់តែង ប្រជុំប្រជា ប្រកបព្រមក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុនធម្មនោះ គោរពមេថុនធម្មនោះ ទុនទៅក្នុងមេថុនធម្មនោះ ទោរទៅក្នុងមេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ប់ទៅក្នុងមេថុនធម្មនោះ ធ្វើមេថុនធម្មនោះឲ្យជាធំ ហេតុនោះ (លោកពោលថា) ប្រកបរឿយ ៗ ក្នុងមេថុន ។

(៤៤៦) អធិប្បាយពាក្យថា ព្រះតិស្សមេត្តេយ្យៈមានអាយុ ក្រាបទូលយ៉ាងនេះ ត្រង់ពាក្យថា យ៉ាងនេះ គឺជាពាក្យភ្ជាប់បទ ជាប់ដោយបទ បំពេញបទ ប្រជុំនៃអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា យ៉ាងនេះ នុះជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកបដោយសេចក្តីគោរព ពាក្យថា មានអាយុនុះ ជាពាក្យប្រកបដោយសេចក្តីកោតក្រែង ។ ពាក្យថា តិស្សៈ គឺជានាម ការរាប់ ឈ្មោះ បញ្ញត្តិ វោហារ ជានាម អំពើរបស់នាម ពាក្យទ្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជនៈ ការហៅរក នៃព្រះថេរៈនោះ ។

មេត្តេយ្យោតិ តស្ស ថេរស្ស គោត្តំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោតិ ឥច្ចាយស្មា តិស្សោ មេត្តេយ្យោ ។

(២២៧) វិឃាតំ ព្រូហិ មារិសាតិ វិឃាតំ ឧបឃាតំ បីឡនំ ឃដ្ដនំ ឧបទ្ទវំ ឧបសគ្គំ ព្រូហិ អាចិក្ខ ទេសេហិ បញ្ញាបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហិ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវវចនំ សប្បតិស្សវចនមេតំ មារិសាតិ វិឃាតំ ព្រូហិ មារិស ។

(២២៨) សុត្វាន តវ សាសនន្តិ តុយ្ហំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ សុត្វាន តវ សាសនំ ។

(២២៩) វិវេកេ សិក្ខិស្សាមសេតិ វិវេកោតិ តយោ វិវេកា កាយវិវេកោ ចិត្តវិវេកោ ឧបធិវិវេកោ ។

ពាក្យថា មេត្តេយ្យៈ គឺជាគោត្រ ការរាប់ ឈ្មោះ បញ្ញត្តិ វោហារ របស់ព្រះថេរៈនោះ ហេតុនោះ (លោកពោល) ថា ព្រះតិស្សមេត្តេយ្យៈ មានអាយុ ក្រាបទូលយ៉ាងនេះ ។

[២២៧] ពាក្យថា បពិត្រព្រះអង្គទ្រង់និទុក្ខ សូមព្រះអង្គពោល សេចក្តីបង្អៀតបង្អល់ សេចក្តីថា សូមព្រះអង្គពោល ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាស នូវសេចក្តីបង្អៀតបង្អល់ សេចក្តីតានតឹង សេចក្តីបៀតបៀន សេចក្តីលំបាក សេចក្តីឧបទ្រព សេចក្តីខ្វាំងខ្វាស់ ឲ្យទាន ។ ពាក្យថា បពិត្រព្រះអង្គទ្រង់និទុក្ខ ទុះ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យប្រកបដោយសេចក្តីគោរព ពាក្យថា ព្រះអង្គទ្រង់និទុក្ខ ទុះជាពាក្យប្រកបដោយសេចក្តីកោតក្រែង ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គទ្រង់និទុក្ខ សូមព្រះអង្គពោលសេចក្តីបង្អៀតបង្អល់ ។

[២២៨] ពាក្យថា ខ្ញុំស្តាប់ពាក្យប្រដៅរបស់ព្រះអង្គ គឺខ្ញុំស្តាប់ ត្រងត្រាប់ រៀន ចំណាំ កំណត់ នូវពាក្យ គន្លងនៃពាក្យ ទេសនា ការប្រៀនប្រដៅរបស់ព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។

[២២៩] អធិប្បាយពាក្យថា សិក្សាក្នុងវិវេក ត្រង់ពាក្យថា វិវេក បានដល់ វិវេក ៣ គឺ កាយវិវេក ចិត្តវិវេក ឧបធិវិវេក ។

កតមោ កាយវិវេកោ ។ ឥធ ភិក្ខុ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ កាយេន ច វិវិត្តោ វិហរតិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ អយំ កាយវិវេកោ ។

កតមោ ចិត្តវិវេកោ ។ បឋមំ ឈានំ សមាបន្នស្ស នីវរណេហិ ចិត្តំ វិវិត្តំ ហោតិ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារេហិ ចិត្តំ វិវិត្តំ ហោតិ តតិយំ ឈានំ សមាបន្នស្ស បីតិយា ចិត្តំ វិវិត្តំ ហោតិ ចតុត្ថំ ឈានំ សមាបន្នស្ស សុខទុក្ខេហិ ចិត្តំ វិវិត្តំ ហោតិ អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញាយ

កាយវិវេក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ គប់សេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ជាអ្នកស្ងាត់ ដោយកាយ ភិក្ខុនោះ ដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចកិរិយាដេកម្នាក់ឯង ចូលទៅកាន់ស្រុកបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង ត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅតែម្នាក់ឯង នេះ កាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ចិត្តរបស់ភិក្ខុអ្នកចូលបឋមជ្ឈាន ជាចិត្តស្ងាត់ចាកនីវរណៈ ចិត្តរបស់ភិក្ខុអ្នកចូលទុតិយជ្ឈាន ជាចិត្តស្ងាត់ចាកវិតក្កៈនិងវិចារៈ ចិត្តរបស់ភិក្ខុអ្នកចូលតតិយជ្ឈាន ជាចិត្តស្ងាត់ចាកបីតិ ចិត្តរបស់ភិក្ខុ អ្នកចូលចតុត្ថជ្ឈាន ជាចិត្តស្ងាត់ចាកសុខនិងទុក្ខ ចិត្តរបស់ភិក្ខុ អ្នកចូលអាកាសានញ្ចាយតនៈ ជាចិត្តស្ងាត់ចាករូបសញ្ញា ចាកបដិឃសញ្ញា ចាកនានត្តសញ្ញា ចិត្តរបស់ភិក្ខុ អ្នកចូលវិញ្ញាណញ្ចាយតនៈ ជាចិត្តស្ងាត់ ចាកអាកាសានញ្ចាយតនសញ្ញា

ចិត្តំ វិវិត្តំ ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញាយ ចិត្តំ វិវិត្តំ ហោតិ សោតាបន្នស្ស សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្វតបរាមាសា ទិដ្ឋានុសយា វិចិកិច្ឆានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ សកទាគាមិស្ស ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ អនាគាមិស្ស អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា តទេកដ្ឋេហិ ច កិលេសេហិ ចិត្តំ វិវិត្តំ ហោតិ អរហតោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា តទេកដ្ឋេហិ ច កិលេសេហិ ពហិទ្ធា ច សព្វនិមិត្តេហិ ចិត្តំ វិវិត្តំ ហោតិ អយំ ចិត្តវិវេកោ ។

ចិត្តរបស់ភិក្ខុ អ្នកចូលអាកិញ្ចញ្ញាយតនៈ ជាចិត្តស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុ អ្នកចូលនេវសញ្ញានាសញ្ញាយតនៈ ជាចិត្តស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់ភិក្ខុអ្នកដល់សោតៈ ជាចិត្តស្ងាត់ចាកសក្កាយទិដ្ឋិ ចាកវិចិកិច្ឆា ចាកសីលព្វតបរាមាសៈ ចាកទិដ្ឋានុស័យ ចាកវិចិកិច្ឆានុស័យ ចាកកិលេសទាំងឡាយ ដែលតាំងនៅជាមួយគ្នានឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាសកទាគាមិ ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដ៏គ្រោតគ្រាត ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាអនាគាមិ ជាចិត្តស្ងាត់ចាកកាមរាគសញ្ញោជនៈ នឹងបដិឃសញ្ញោជនៈ ដែលលាយឡំនៅដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យ ដែលលាយឡំនៅដ៏ល្អិត ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចិត្តរបស់ភិក្ខុជាព្រះអរហន្ត ជាចិត្តស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចាកកិលេសដែលតាំងនៅ ជាមួយនឹងសញ្ញោជនៈទាំងនោះ ចាកនិមិត្តទាំងពួងជាខាងក្រៅ នេះ ចិត្តវិវេក ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

កតមោ ឧបធិវិវេកោ ។ ឧបធី វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិវិវេកោ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ អយំ ឧបធិវិវេកោ ។

កាយវិវេកោ ច វូបកដ្ឋកាយានំ(១) នេក្ខម្មាភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទានប្បត្តានំ ឧបធិវិវេកោ ច និរូបធីនំ បុគ្គលានំ វិសង្ខារគតានំ ។

វិវេកេ សិក្ខិស្សាមសេតិ សោ ថេរោ បកតិយា សិក្ខិតសិក្ខោ អបិច ធម្មទេសនំ យាចន្តោ(២) ឯវមាហ វិវេកេ សិក្ខិស្សាមសេតិ ។ តេនាហ ថេរោ តិស្សោ មេត្តេយ្យោ

មេថុនមនុយុត្តស្ស (ឥច្ចាយស្មា តិស្សោ
មេត្តេយ្យោ)
វិឃាតំ ព្រូហិ មារិស
សុត្វាន តវ សាសនំ
វិវេកេ សិក្ខិស្សាមសេតិ ។

---

១ ម. វិវេកដ្ឋកាយានំ ។ ២ ម. អបិច ធម្មទេសនំ ឧបាទាយ ធម្មទេសនំ សាវេន្តោ ។

## តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

ឧបធិវិវេក តើដូចម្តេច ។ កិលេស ខន្ធ និងអភិសង្ខារទាំងឡាយ លោកហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បាន ខាងការរម្ងាប់សង្ខារទាំងពួង ការលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន នេះ ឧបធិវិវេក ។

កាយវិវេក សម្រាប់អ្នកមានកាយគេចចេញ (ចាកពួក) អ្នកត្រេកអរចំពោះនេក្ខម្មៈ ចិត្តវិវេក សម្រាប់អ្នកមានចិត្តបរិសុទ្ធ អ្នកដល់សេចក្តីផូរផង់ដ៏ក្រៃលែង ឯឧបធិវិវេក សម្រាប់បុគ្គលមិនមានឧបធិ អ្នកដល់នូវវិសង្ខារ គឺព្រះនិព្វាន ។

ពាក្យថា សិក្ខាក្នុងវិវេក គឺព្រះថេរៈនោះ មានសិក្ខាសិក្សាហើយដោយប្រក្រតី តែ លោកសូមធម្មទេសនា បានពោលយ៉ាងនេះថា នឹងសិក្សាក្នុងវិវេក ។ ហេតុនោះ ព្រះថេរៈឈ្មោះតិស្សមេត្តេយ្យៈ ពោលថា

(ព្រះតិស្សមេត្តេយ្យៈមានអាយុក្រាបទូល យ៉ាងនេះថា) បពិត្រព្រះអង្គទ្រង់និទុក្ខ សូមព្រះអង្គពោលសេចក្តីបង្អៀតបង្អល់របស់បុគ្គលដែលប្រកបរឿយ ៗ ក្នុងមេថុន យើងខ្ញុំស្តាប់ពាក្យប្រដៅរបស់ព្រះអង្គហើយ នឹងសិក្សាក្នុងវិវេក ។

(២៣០) មេថុនមនុយុត្តស្ស (មេត្តេយ្យាតិ ភគវា)
មុស្សតេ វាបិ សាសនំ
មិច្ឆា ច បដិបជ្ជតិ
ឯតំ តស្មឹ អនារិយំ ។

(២៣១) មេថុនមនុយុត្តស្សាតិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ គាមធម្មោ វសលធម្មោ ទុដ្ឋុល្លោ ឱទកន្តិកោ រហស្សោ ទ្វយទ្វយសមាបត្តិ ។ កិំការណា វុច្ចតិ មេថុនធម្មោ ។ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ ។ យថា ឧភោ កលហការកា មេថុនកាតិ វុច្ចន្តិ ឧភោ ភណ្ឌនការកា មេថុនកាតិ វុច្ចន្តិ ឧភោ ភស្សការកា មេថុនកាតិ វុច្ចន្តិ ឧភោ វិវាទការកា មេថុនកាតិ វុច្ចន្តិ ឧភោ អធិករណការកា មេថុនកាតិ វុច្ចន្តិ ឧភោ វាទិនោ មេថុនកាតិ វុច្ចន្តិ ឧភោ សល្លាបកា មេថុនកាតិ វុច្ចន្តិ

[៥៣០] (ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យៈ) សាសនា របស់បុគ្គលអ្នកប្រកបរឿយ ៗ ក្នុងមេថុនធម្ម រមែងវិនាស ដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះ មិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ ។

[៥៣១] ពាក្យថា បុគ្គលអ្នកប្រកបរឿយ ៗ ក្នុងមេថុនធម្ម អធិប្បាយថា ឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់ជនថោកទាប ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កើតក្នុងទីកំបាំង ការចូលរួមរបស់បុគ្គលពីរ ៗ នាក់ ៗ ដែលលោកហៅថា មេថុនធម្ម តើព្រោះហេតុអ្វី ។ ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ជោក(ដោយរាគៈ) រួបរឹត(ដោយរាគៈ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ដូច្នេះ ។ ជនពីរនាក់ធ្វើជំលោះ លោកហៅថា គូជម្លោះ ជនពីរនាក់ធ្វើសេចក្តីប្រកួតប្រកាន់ លោកហៅថា គូប្រកួតប្រកាន់ ជនពីរនាក់ធ្វើការនិយាយគ្នា លោកហៅថា គូនិយាយគ្នា ជនពីរនាក់ធ្វើការជជែកគ្នា លោកហៅថា គូជជែកគ្នា ជនពីរនាក់ធ្វើអធិករណ៍ លោកហៅថា គូអធិករណ៍ ជនពីរនាក់ចរចាជាប្រក្រតី លោកហៅថា គូចរចា ជនពីរនាក់និយាយឆ្លើយឆ្លងគ្នា លោកហៅថា គូឆ្លើយឆ្លង យ៉ាងណា

ឃរមេរ ឧភិន្នំ រត្តានំ សារត្តានំ អវស្សុតានំ បរិយុដ្ឋិតានំ បរិយាទិន្នចិត្តានំ ឧភិន្នំ សទិសានំ ធម្មោតិ តំការណា វុច្ចតិ មេថុនធម្មោ ។ មេថុនមនុយុត្តស្សាតិ មេថុនធម្មេ យុត្តស្ស បយុត្តស្ស អាយុត្តស្ស សមាយុត្តស្ស តច្ចរិតស្ស តព្ពហុលស្ស តគ្គរុកស្ស តន្និន្នស្ស តប្បោណស្ស តប្បព្ភារស្ស តទធិមុត្តស្ស តទាធិបតេយ្យស្សាតិ មេថុនមនុយុត្តស្ស ។ មេត្តេយ្យាតិ ភគវា តំ ថេរំ គោត្តេន អាលបតិ ។ ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ដកោតិ ភគវា ។

ធម៌របស់បុគ្គលពីរនាក់ ដែលត្រេកអរ ត្រេកអរខ្លាំង ដោក (ដោយរាគៈ) រួបរឹត (ដោយរាគៈ) មានចិត្តត្រូវកិលេសគ្របសង្កត់ស្មើគ្នាទាំងពីរនាក់ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម យ៉ាងនោះដែរ ។ ពាក្យថា ប្រកបរឿយៗក្នុងមេថុន គឺប្រកប តាក់តែង ប្រដុំប្រដា ប្រកបព្រម ក្នុងមេថុនធម្ម ប្រព្រឹត្តមេថុនធម្មនោះ ក្រាស់ដោយមេថុនធម្មនោះ គោរពមេថុនធម្មនោះ ឱនទៅក្នុងមេថុនធម្មនោះ ទោរទៅក្នុងមេថុនធម្មនោះ ឈមមុខទៅក្នុងមេថុនធម្មនោះ ចុះចិត្តស៊ប់ក្នុងមេថុនធម្មនោះ ធ្វើមេថុនធម្មនោះឲ្យជាធំ ហេតុនោះ(ទ្រង់ត្រាស់ថា) បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្ម ។ ព្រះមានព្រះភាគ ត្រាស់ហៅព្រះថេរៈនោះតាមគោត្រថា ម្នាលមេត្តេយ្យៈ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។ មួយទៀត ព្រះពុទ្ធ មានរាគៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទោសៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមោហៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានមានៈបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានទិដ្ឋិបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានបន្លាគឺកិលេសបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។

ភគ្គកិលេសោតិ ភគវា ។ ភជិ វិភជិ បវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោ ភាវិតចិត្តោ ភាវិតបញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហស្សេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិបញ្ញាយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ

មានកិលេសបំបាក់បង់ហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ទ្រង់បែងចែក រំលែកធម្មរតនៈ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ជាអ្នកធ្វើនូវទីបំផុតនៃភព ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានព្រះកាយចំរើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មានសីលចំរើនហើយ មានចិត្តចំរើនហើយ មានប្រាជ្ញាចំរើនហើយ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ទ្រង់គប់រកសេនាសនៈស្ងាត់ គឺព្រៃតូច និងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីកាយនៃជន ជាទីស្ងាត់កំបាំងរបស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិបញ្ញា ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកវិមោក្ខ ៨ អភិភាយតនៈ ៨

នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ មេត្តេយ្យាតិ ភគវា ។

អនុបុព្វវិហារសមាបត្តិ ៩ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសញ្ញាភាវនា ១០ កសិណសមាបត្តិ១០ អានាបានស្សតិសមាធិ និងអសុភសមាបត្តិ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកសតិប្បដ្ឋាន៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ៧ អរិយមគ្គប្រកបដោយអង្គ៨ ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ មួយទៀត ព្រះមានបុណ្យ ព្រះអង្គមានចំណែកតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ធម៌របស់ព្រះពុទ្ធ៦យ៉ាង ហេតុនោះ ឈ្មោះថា ព្រះមានព្រះភាគ ។ ព្រះនាមថាមានព្រះភាគ នុះ មិនមែនព្រះមាតាធ្វើ មិនមែនព្រះបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនមិត្រនិងអាមាត្យធ្វើ មិនមែនញាតិសាលោហិតធ្វើ មិនមែនសមណៈនិងព្រាហ្មណ៍ធ្វើ មិនមែនទេវតាធ្វើទេ (ព្រះនាមថា មានព្រះភាគ) នុះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ គឺសេចក្តីបញ្ញត្តិថា មានព្រះភាគនេះ(កើត) អំពីការបានត្រាស់ ដំណាលគ្នានឹងការបានចំពោះសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យៈ ។

(២៣៤) មុស្សតេ វាបិ សាសនន្តិ ទ្វីហិ ការណេហិ សាសនំ មុស្សតិ បរិយត្តិសាសនម្បិ មុស្សតិ បដិបត្តិសាសនម្បិ មុស្សតិ ។

កតមំ បរិយត្តិសាសនំ ។ យំ តស្ស បរិយាបុដំ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ឥទំ បរិយត្តិសាសនំ ។ តម្បិ មុស្សតិ បរិមុស្សតិ បរិពាហិរោ ហោតីតិ ឯវម្បិ មុស្សតេ វាបិ សាសនំ ។

កតមំ បដិបត្តិសាសនំ ។ សម្មាបដិបទា អនុលោមបដិបទា អបច្ចនីកបដិបទា អន្វត្ថបដិបទា ធម្មានុធម្មបដិបទា សីលេសុ បរិបូរការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឥទំ បដិបត្តិសាសនំ ។ តម្បិ មុស្សតិ បរិមុស្សតិ[1] បរិពាហិរោ ហោតីតិ ឯវម្បិ មុស្សតេ វាបិ សាសនំ ។

---

១ ម. សំមុស្សតិ បមុស្សតិ សំបមុស្សតិ ។

(២៣២) ពាក្យថា សាសនាវិនាស បានដល់សាសនាវិនាស ដោយហេតុ ២ គឺ បរិយត្តិសាសនា ក៏វិនាស បដិបត្តិសាសនា ក៏វិនាស ។

បរិយត្តិសាសនា តើដូចម្ដេច ។ ពុទ្ធវចនៈណា គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ដែលបុគ្គលនោះរៀនហើយ នេះបរិយត្តិសាសនា ។ បរិយត្តិសាសនា វិនាស បាត់បង់ទៅ (បុគ្គលនោះ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ (ទ្រង់ត្រាស់ថា) សាសនាវិនាស យ៉ាងនេះខ្លះ ។

បដិបត្តិសាសនា តើដូចម្ដេច ។ សេចក្ដីប្រតិបត្តិដោយប្រពៃ សេចក្ដីប្រតិបត្តិដ៏សមគួរ សេចក្ដីប្រតិបត្តិមិនជាសឹកសត្រូវ សេចក្ដីប្រតិបត្តិចំពោះប្រយោជន៍មតាលំដាប់ សេចក្ដីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ភាពបុគ្គលអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពបុគ្គលមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ភាពបុគ្គលអ្នកដឹងប្រមាណក្នុងភោជន សេចក្ដីប្រកបរឿយៗក្នុងការភ្ញាក់រលឹក សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ នេះបដិបត្តិសាសនា ។ បដិបត្តិសាសនា នោះ រមែងវិនាស បាត់បង់ទៅ ( បុគ្គលនោះ ) ទៅជាបុគ្គលខាងក្រៅ ហេតុនោះ (ទ្រង់ត្រាស់ថា) សាសនាវិនាស យ៉ាងនេះខ្លះ ។

(២៣៣) មិច្ឆា ច បដិបជ្ជតីតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតីតិ មិច្ឆា ច បដិបជ្ជតិ ។

(២៣៤) ឯតំ តស្មិំ អនារិយន្តិ ឯតំ តស្មិំ បុគ្គលេ អនរិយធម្មោ ពាលធម្មោ មូឡ្ហធម្មោ អញ្ញាណធម្មោ អមរាវិក្ខេបធម្មោ យទិទំ មិច្ឆា បដិបទាតិ ឯតំ តស្មិំ អនារិយំ ។ តេនាហ ភគវា

មេថុនមនុយុត្តស្ស (មេត្តេយ្យាតិ ភគវា)
មុស្សតេ វាបិ សាសនំ
មិច្ឆា ច បដិបជ្ជតិ
ឯតំ តស្មិំ អនារិយន្តិ ។

(២៣៥) ឯកោ បុព្វេ ចរិត្វាន
មេថុនំ យោ និសេវតិ
យានំ ភន្តំវ តំ លោកេ
ហីនមាហុ បុថុជ្ជនំ ។

## តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

(២៣៣) ពាក្យថា រមែងប្រតិបត្តិខុស គឺបុគ្គលសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទី-តខ្លះ វាយប្រហារ ទាំងប្លន់ធំខ្លះ ធ្វើការបៀតបៀនទ្រព្យក្នុងផ្ទះមួយខ្លះ ចាំនៅក្បែរផ្លូវវៀរជាន់ខ្លះ គប់រកប្រពន្ធបុគ្គលដទៃខ្លះ ពោលកុហកខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងប្រតិបត្តិខុស ។

(២៣៤) ពាក្យថា អំពើនុ៎ះ មិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ គឺអំពើនុ៎ះ ជាធម៌មិនប្រសើរ ជាធម៌របស់បុគ្គលពាល ជាធម៌របស់បុគ្គលល្ងង់ខ្លៅ ជាធម៌របស់បុគ្គលមិនមានបញ្ញា ជាធម៌របស់បុគ្គលហោះទៅនូវពាក្យមិនឲ្យស្ដាប់សំដី គឺជាសេចក្ដីប្រតិបត្តិខុស ចំពោះបុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អំពើនុ៎ះមិនមែនជាអំពើប្រសើរ ក្នុងបុគ្គលនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យៈ) សាសនារបស់បុគ្គលអ្នកប្រកបរឿយៗក្នុងមេថុនធម្ម រមែងវិនាសទៅដោយពិត ទាំងបុគ្គលនោះ ក៏រមែងប្រតិបត្តិខុស អំពើនុ៎ះមិនមែនជាអំពើប្រសើរ ចំពោះបុគ្គលនោះទេ ។

(២៣៥) បុគ្គលណា ប្រព្រឹត្តម្នាក់ឯងក្នុងកាលមុន ហើយសេពមេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាបុថុជ្ជនថោកទាប ក្នុងលោក ដូចជាយានដែលក្ដូកហើយ ។

(២៣៦) ឯកោ បុព្វេ ចរិត្វានាតិ ទ្វីហិ ការណេហិ ឯកោ បុព្វេ ចរិត្វាន បព្វជ្ជាសង្ខាតេន វា គណាវវស្សគ្គដ្ឋេន វា ។

កថំ បព្វជ្ជាសង្ខាតេន ឯកោ បុព្វេ ចរិត្វាន ។ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវំ បព្វជ្ជាសង្ខាតេន ឯកោ បុព្វេ ចរិត្វាន ។

កថំ គណាវវស្សគ្គដ្ឋេន ឯកោ បុព្វេ ចរិត្វាន ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ ។

(២៣៦) ពាក្យថា ប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន អធិប្បាយថា បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយហេតុ ២ គឺ ដោយចំណែកបព្វជ្ជា ឬដោយការលះបង់ពួក ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ បុគ្គលកាត់បង់កង្វល់ គឺឃរាវាសទាំងអស់ កាត់បង់កង្វល់ គឺបុត្តភរិយា កាត់បង់កង្វល់ គឺញាតិ កាត់បង់កង្វល់គឺមិត្តនិងអាមាត្យ កាត់បង់កង្វល់ គឺការសន្សំ កោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកចត់ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដល់នូវភាពជាអ្នកមិនមានសេចក្តីកង្វល់ខ្វាយ ត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

បុគ្គលប្រព្រឹត្តម្នាក់ឯង ក្នុងកាលមុន ដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះ លុះបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង តែងគប់រកសេនាសនៈស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ ដែលកើតអំពីកាយនៃជន ជាទីស្ងាត់កំបាំង របស់មនុស្ស សមគួរដល់ការពួនសម្ងំ ។

សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវំ គណាវស្សគ្គដ្ឋេន ឯកោ បុព្វេ ចរិត្វាន ។

(២៣៧) មេថុនំ យោ និសេវតីតិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ ។ បេ ។ តំការណា វុច្ចតិ មេថុនធម្មោ ។ មេថុនំ យោ និសេវតីតិ សោ អបរេន សមយេន ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា មេថុនធម្មំ សេវតិ និសេវតិ សំសេវតិ បដិសេវតីតិ មេថុនំ យោ និសេវតិ ។

(២៣៨) យានំ ភន្តំវ តំ លោកេតិ យានន្តិ ហត្ថិយានំ អស្សយានំ គោយានំ អជយានំ

បុគ្គលនោះ ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង សម្រេចការដេកតែម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្ក្រមតែម្នាក់ឯង ត្រាច់ទៅ សម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គលប្រព្រឹត្តតែម្នាក់ឯង ក្នុងកាលមុនដោយការលះបង់ពួក យ៉ាងនេះ ។

(២៣៧) អធិប្បាយពាក្យថា បុគ្គលណា សេពមេថុនធម្ម ឈ្មោះថា មេថុនធម្ម បានខាង ធម៌របស់អសប្បុរស ។ បេ ។ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ពាក្យថា បុគ្គលណា សេពមេថុនធម្ម បានសេចក្តីថា បុគ្គលនោះ ពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងសិក្ខា ត្រឡប់ដើម្បីភាពជាបុគ្គលថោកទាប ហើយគប់រក សេពគប់ សេពសម្ពព សេពចំពោះមេថុនធម្ម ក្នុងសម័យដទៃ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណា សេពមេថុនធម្ម ។

(២៣៨) អធិប្បាយពាក្យថា ដូចជាយានដែលភ្លូកហើយក្នុងលោក ត្រង់ពាក្យថា យាន គឺ យានទឹម ដោយដំរី យានទឹម ដោយសេះ យានទឹម ដោយគោ យានទឹម ដោយពពែ

មេណ្ឌកយានំ ឱដ្ឋយានំ ខរយានំ ភន្តំ អទន្តំ អការិតំ អវិនីតំ ឧប្បថំ គណ្ហាតិ វិសមំ ខាណុម្បិ បាសាណម្បិ អភិរុហតិ(១) អារោហកម្បិ ភញ្ជតិ បបាតេបិ បបតតិ ។ យថា តំ ភន្តំ យានំ អទន្តំ អការិតំ អវិនីតំ ឧប្បថំ គណ្ហាតិ ឯវមេវ សោ វិព្ភន្តកោ ភន្តយានប្បដិភាគោ ឧប្បថំ គណ្ហាតិ មិច្ឆាទិដ្ឋឹ គណ្ហាតិ ។ បេ ។ មិច្ឆាសមាធឹ គណ្ហាតិ ។ យថា តំ ភន្តំ យានំ អទន្តំ អការិតំ អវិនីតំ វិសមំ ខាណុម្បិ បាសាណម្បិ អភិរុហតិ ឯវមេវ សោ វិព្ភន្តកោ ភន្តយានប្បដិភាគោ វិសមំ កាយកម្មំ អភិរុហតិ វិសមំ វចីកម្មំ អភិរុហតិ វិសមំ មនោកម្មំ អភិរុហតិ វិសមំ បាណាតិបាតំ អភិរុហតិ វិសមំ អទិន្នាទានំ អភិរុហតិ វិសមំ កាមេសុ មិច្ឆាចារំ អភិរុហតិ វិសមំ មុសាវាទំ អភិរុហតិ វិសមំ បិសុណំ វាចំ អភិរុហតិ វិសមំ ផរុសំ វាចំ អភិរុហតិ វិសមំ សម្ផប្បលាបំ អភិរុហតិ វិសមំ អភិជ្ឈំ អភិរុហតិ វិសមំ ព្យាបាទំ អភិរុហតិ វិសមំ មិច្ឆាទិដ្ឋឹ អភិរុហតិ

---

១ ឱ ម. ឯត្ថន្តរេ យានម្បីតិ អត្ថិ ។

យានទឹមដោយចៀម យានទឹមដោយឱដ្ឋ យានទឹមដោយលា ជាយានភ្លូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់ រមែងកាន់យកផ្លូវខុស ទៀងកាន់ទីមានជង្គត់ នឹងថ្មរដិបរដុបខ្លះ កិនជនអ្នកបរខ្លះ ភ្លូកធ្លាក់ទៅក្នុងជ្រោះខ្លះ ៗ យានភ្លូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកាន់យកផ្លូវខុស យ៉ាងណា បុគ្គលជាអ្នកភ្លាត់នោះ (សឹក) ប្រៀបដោយយានភ្លូកហើយ រមែងកាន់យកផ្លូវខុស គឺកាន់យកទិដ្ឋិខុស ។ បេ ។ កាន់យកសមាធិខុស យ៉ាងនោះដែរ ។ យានភ្លូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងទៀងកាន់ទីមានជង្គត់ នឹងថ្មរដិបរដុប យ៉ាងណា បុគ្គលអ្នកភ្លាត់នោះ ប្រៀបដោយយានភ្លូកហើយ រមែងទៀងកាន់កាយកម្មមិនស្មើ ទៀងកាន់វចីកម្មមិនស្មើ ទៀងកាន់មនោកម្មមិនស្មើ ទៀងកាន់បាណាតិបាតមិនស្មើ ទៀងកាន់អទិន្នាទានមិនស្មើ ទៀងកាន់កាមេសុមិច្ឆាចារមិនស្មើ ទៀងកាន់មុសាវាទមិនស្មើ ទៀងកាន់បិសុណាវាចាមិនស្មើ ទៀងកាន់ផរុសវាចាមិនស្មើ ទៀងកាន់សម្ផប្បលាបៈមិនស្មើ ទៀងកាន់អភិជ្ឈាមិនស្មើ ទៀងកាន់ព្យាបាទមិនស្មើ ទៀងកាន់មិច្ឆាទិដ្ឋិមិនស្មើ

វិសមេ សង្ខារេ អភិរុហតិ វិសមេ បញ្ច កាមគុណេ អភិរុហតិ វិសមេ នីវរណេ អភិរុហតិ ។ យថា តំ ភន្តំ យានំ អទន្តំ អការិតំ អវិនីតំ អារោហកម្បិ ភញ្ជតិ ឯវមេវ សោ វិព្ភន្តកោ ភន្តយានប្បដិភាគោ និរយេ អត្តានំ ភញ្ជតិ តិរច្ឆានយោនិយា អត្តានំ ភញ្ជតិ បិត្តិវិសយេ អត្តានំ ភញ្ជតិ មនុស្សលោកេ អត្តានំ ភញ្ជតិ ទេវលោកេ អត្តានំ ភញ្ជតិ ។ យថា តំ ភន្តំ យានំ អទន្តំ អការិតំ អវិនីតំ បបាតេបិ បបតតិ ឯវមេវ សោ វិព្ភន្តកោ ភន្តយានប្បដិភាគោ ជាតិបបាតម្បិ បបតតិ ជរាបបាតម្បិ បបតតិ ព្យាធិបបាតម្បិ បបតតិ មរណបបាតម្បិ បបតតិ សោកបរិទេវទុក្ខទោមនស្សុបាយាសបបាតម្បិ បបតតិ ។ លោកេតិ អបាយលោកេ ។ បេ ។ មនុស្សលោកេតិ យានំ ភន្តំវ តំ លោកេ ។

(២៣៩) ហីនមាហុ បុថុជ្ជនន្តិ បុថុជ្ជនាតិ កេនដ្ឋេន បុថុជ្ជនា ។ បុថុ កិលេសេ ជនេន្តីតិ បុថុជ្ជនា ។

ឡើងកាន់សង្ខារទាំងឡាយមិនស្មើ ឡើងកាន់កាមគុណ ៥ មិនស្មើ ឡើងកាន់និវរណៈទាំងឡាយមិនស្មើ យ៉ាងនោះដែរ ។ យានភ្លូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងកិនជនអ្នកបរ យ៉ាងណា បុគ្គលអ្នកភ្លាត់នោះ ប្រៀបដោយយានភ្លូកហើយ រមែងកិនខ្លួនក្នុងនរក កិនខ្លួនក្នុងកំណើតតិរច្ឆាន កិនខ្លួនក្នុងបិត្តិវិស័យ កិនខ្លួនក្នុងមនុស្សលោក កិនខ្លួនក្នុងទេវលោក យ៉ាងនោះដែរ ។ យានភ្លូកហើយ ដែលគេមិនបានទូន្មាន មិនបានធ្វើ មិនបានបង្ហាត់នោះ រមែងភ្លូកធ្លាក់ទៅក្នុងជ្រោះ យ៉ាងណា បុគ្គលអ្នកភ្លាត់នោះ ប្រៀបដោយយានភ្លូកហើយ រមែងធ្លាក់ចុះក្នុងជ្រោះគឺជាតិខ្លះ ធ្លាក់ចុះក្នុងជ្រោះគឺជរាខ្លះ ធ្លាក់ចុះក្នុងជ្រោះគឺព្យាធិខ្លះ ធ្លាក់ចុះក្នុងជ្រោះគឺមរណៈខ្លះ ធ្លាក់ចុះក្នុងជ្រោះគឺសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ខ្លះ យ៉ាងនោះដែរ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងមនុស្សលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាយាន ដែលភ្លូកហើយ ក្នុងលោក ។

(២៣៩) អធិប្បាយពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថាជាបុថុជ្ជនថោកទាប ត្រង់ពាក្យថា បុថុជ្ជន គឺឈ្មោះថាបុថុជ្ជន ដោយសេចក្ដីដូចម្ដេច ។ ឈ្មោះថាបុថុជ្ជន ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។

បុថុ អវិហតសក្កាយទិដ្ឋិកាតិ បុថុជ្ជនា ។ បុថុ សត្ថារានំ មុខុល្លោកិកាតិ បុថុជ្ជនា ។ បុថុ សព្វគតីហិ អវុដ្ឋិតាតិ បុថុជ្ជនា ។ បុថុ នានាភិសង្ខារេហិ អភិសង្ខរោន្តីតិ បុថុជ្ជនា ។ បុថុ នានាឱឃេហិ វុយ្ហន្តីតិ បុថុជ្ជនា ។ បុថុ នានាសន្តាបេហិ សន្តប្បេន្តីតិ បុថុជ្ជនា ។ បុថុ នានាបរិឡាហេហិ បរិឌយ្ហន្តីតិ បុថុជ្ជនា ។ បុថុ បញ្ចសុ កាមគុណេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធាតិ បុថុជ្ជនា ។ បុថុ បញ្ចហិ នីវរណេហិ អាវុដា និវុដា ឱផុដា បិហិតា បដិច្ឆន្នា បដិកុជ្ជិតាតិ បុថុជ្ជនា ។ ហីនមាហុ បុថុជ្ជនន្តិ បុថុជ្ជនំ ហីនំ និហីនំ ឱមកំ លាមកំ ឆតុក្កំ បរិត្តន្តិ ឯវមាហុ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ ហីនមាហុ បុថុជ្ជនំ ។ តេនាហ ភគវា

ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមានសក្កាយទិដ្ឋិដ៏ក្រាស់មិនទាន់លះបង់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកពោលប្ដេជ្ញា ចំពោះមុខសាស្តាទាំងឡាយច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ក្រាស់ចាក់ស្រែះ ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេង ៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱឃៈផ្សេងៗដ៏ក្រាស់បន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្តៅក្រហាយ ដោយកំដៅផ្សេង ៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះរោលរាលដោយកំដៅរោលរាលផ្សេងៗដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរ ញៀម ជាប់ចិត្ត ជ្រប់ និល់និប់ ជាប់ជំពាក់ ចាក់ស្រែះ រួបរឹតក្នុងកាមគុណ៥ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ៥ ដ៏ក្រាស់ ចាក់ស្រែះ រួបរឹត គ្របសង្កត់ សន្ធប់ បិទបាំង សណ្តំជាប់ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះ ថាជាបុថុជ្ជនថោកទាប គឺ អ្នកប្រាជ្ញទាំងឡាយ ពោលយ៉ាងនេះ បានពោលហើយយ៉ាងនេះ សំដែងយ៉ាងនេះ និយាយយ៉ាងនេះ បំភ្លឺយ៉ាងនេះ បញ្ចេញយ៉ាងនេះ នូវបុគ្គលនោះ ថាជាមនុស្សបុថុជ្ជន ថោកទាប ទន់ថយ ជ្រោកជ្រាក លាមក អាក្រក់ រំកាច់រំកោច ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញទាំងឡាយ ពោលនូវបុគ្គលនោះ ថាជាបុថុជ្ជន ថោកទាប ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ឯកោ បុព្វេ ចរិត្វាន មេថុនំ យោ និសេវតិ
យានំ ភន្តំវ តំ លោកេ ហីនមាហុ បុថុជ្ជនន្តិ ។

(២៨០) យសោ កិត្តិ ច យា បុព្វេ ហាយតេ វាបិ តស្ស សា
ឯតម្បិ ទិស្វា សិក្ខេថ មេថុនំ វិប្បហាតវេ ។

(២៨១) យសោ កិត្តិ ច យា បុព្វេ ហាយតេ វាបិ តស្ស សាតិ កតមោ យសោ ។ ឥធេកច្ចោ បុព្វេ សមណភាវេ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ អយំ យសោ ។ កតមា កិត្តិ ។ ឥធេកច្ចោ បុព្វេ សមណភាវេ កិត្តិវណ្ណគតោ ហោតិ បណ្ឌិតោ វិយត្តោ មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណបដិភាណោ សុត្តន្តិកោតិ វា វិនយធរោតិ វា

## តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

បុគ្គលណា ប្រព្រឹត្តតែម្នាក់ឯង ក្នុងកាលមុន ហើយសេព មេថុនធម្ម អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះ ថាជា បុថុជ្ជន ថោកទាប ក្នុងលោក ដូចជាយានដែលក្ងក់ហើយ ។

(២៨០) យសនិងកេរ្តិ៍ឈ្មោះណា (ធ្លាប់មាន) ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ ក៏សាបសូន្យទៅ បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុនធម្ម ។

(២៨១) ពាក្យថា យសៈនិងកេរ្តិ៍ឈ្មោះ ណា ធ្លាប់មាន ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ មានសេចក្ដីអធិប្បាយដូចតទៅនេះ ចុះយស តើដូចម្ដេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យ-ភេសជ្ជបរិក្ខារ ក្នុងភាពជាសមណៈក្នុងកាលមុន នេះ ឈ្មោះថា យស ។ ចុះកេរ្តិ៍ឈ្មោះ តើដូចម្ដេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ កាលនៅក្នុងភាពជាសមណៈក្នុងកាលមុន ជាអ្នកពេញដោយកេរ្តិ៍ឈ្មោះ និងសេចក្ដីសរសើរ ជាបណ្ឌិត វាងវៃ មានប្រាជ្ញា ជាពហុស្សូត មានពាក្យដ៏វិចិត្រ មានប្រាជ្ញាល្អ ជាអ្នកទ្រទ្រង់ព្រះសូត្រក្ដី ជាអ្នកទ្រទ្រង់វិន័យក្ដី

ធម្មកថិកោតិ វា អារញ្ញិកោតិ វា បិណ្ឌបាតិកោតិ វា បំសុកូលិកោតិ វា តេចីវរិកោតិ វា សបទាន-ចារិកោតិ វា ខលុបច្ឆាភត្តិកោតិ វា នេសជ្ជិកោ-តិ វា យថាសន្ថតិកោតិ វា បឋមស្ស ឈានស្ស លាភីតិ វា ទុតិយស្ស ឈានស្ស លាភីតិ វា តតិ-យស្ស ឈានស្ស លាភីតិ វា ចតុត្ថស្ស ឈានស្ស លាភីតិ វា អាកាសានញ្ចាយតនសមាបត្តិយា លាភី-តិ វា វិញ្ញាណញ្ចាយតនសមាបត្តិយា លាភីតិ វា អាកិញ្ចញ្ញាយតនសមាបត្តិយា លាភីតិ វា នេវស-ញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា អយំ កិត្តិ ។ យសោ កិត្តី ច យា បុព្ពេ ហាយតេ វាបិ តស្ស សាតិ តស្ស អបរេន សមយេន ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តស្ស សោ ច យសោ សា ច កិត្តិ ហាយតិ បរិហាយតិ បរិ-ធំសតិ បរិបតតិ អន្តរធាយតិ វិប្បលុជ្ជតីតិ យសោ កិត្តី ច យា បុព្ពេ ហាយតេ វាបិ តស្ស សា ។

ជាធម្មកថិកក្តី ជាអ្នកកាន់អារញ្ញិកធុតង្គក្តី ជាអ្នកកាន់បិណ្ឌបាតិកធុតង្គក្តី ជាអ្នកកាន់បំសុកូលិកធុតង្គក្តី ជាអ្នកកាន់តេចីវរិកធុតង្គក្តី ជាអ្នកកាន់សបទានចារិកធុតង្គក្តី ជាអ្នកកាន់ខលុបច្ឆាភត្តិកធុតង្គក្តី ជាអ្នកកាន់នេសជ្ជិកធុតង្គក្តី ជាអ្នកកាន់យថាសន្ថតិកធុតង្គក្តី ជាអ្នកបានបឋមជ្ឈានក្តី ជាអ្នកបានទុតិយជ្ឈានក្តី ជាអ្នកបានតតិយជ្ឈានក្តី ជាអ្នកបានចតុត្ថជ្ឈានក្តី ជាអ្នកបានអាកាសានញ្ចាយតនសមាបត្តិក្តី ជាអ្នកបានវិញ្ញាណញ្ចាយតនសមាបត្តិក្តី ជាអ្នកបានអាកិញ្ចញ្ញាយតនសមាបត្តិក្តី ជាអ្នកបាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី នេះឈ្មោះថា កេរ្តិ៍ឈ្មោះ ។ ពាក្យថា យសនឹងកេរ្តិ៍ឈ្មោះណា ធ្លាប់មានក្នុងកាលមុន យសនឹងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ បានសេចក្តីថា កាលបព្វជិតនោះពោលលា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងសិក្ខា ក្នុងសម័យដទៃ ហើយត្រឡប់ ដើម្បីភេទថោកទាប យសនឹងកេរ្តិ៍ឈ្មោះនោះ រមែងសូន្យ សាបរលាប ខ្ចាត់ចេញ ជ្រុះចេញ បាត់បង់ វិនាស ហេតុនោះ (ទ្រង់ត្រាស់ថា) យសនឹងកេរ្តិ៍ឈ្មោះណា ធ្លាប់មាន ក្នុងកាលមុន យសនឹងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

(២៤២) ឯតម្បិ ទិស្វា សិក្ខេថ មេថុនំ វិប្បហាតវេតិ ឯតន្តិ បុព្វេ សមណភាវេ យសោ ច កិត្តិ ច អបរភាគេ តុច្ឆំ ធម្មំ សេវិត្វា សិក្ខំ បច្ចក្ខាយ ហីនាយាវត្តស្ស អយសោ ច អកិត្តិ ច ឯតំ សម្បត្តិវិបត្តិំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតម្បិ ទិស្វា ។ សិក្ខេថាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។

កតមា អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោ សីលក្ខន្ធោ មហន្តោ សីលក្ខន្ធោ សីលំ បតិដ្ឋា អាទិ ចរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា អយំ អធិសីលសិក្ខា ។

កតមា អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ

(៤៤២) អធិប្បាយពាក្យថា បណ្ឌិតឃើញ នូវដំណើរទាំងពីរហើយ គប្បីសិក្សាដើម្បីលះបង់មេថុនធម្ម ត្រង់ពាក្យថា នូវដំណើរទាំងពីរ សេចក្ដីថា យសនឹងកេរ្តិ៍ឈ្មោះក្នុងភាពជាសមណៈ ក្នុងកាលមុន ការមិនមានយសនឹងការមិនមានកេរ្តិ៍ឈ្មោះ របស់បណ្ឌិត ដែលពោលលា នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងសិក្ខា ហើយត្រឡប់ដើម្បីភេទថោកទាប ក្នុងកាលជាចំណែកខាងក្រោយ បណ្ឌិតឃើញ ជួប ប្រទះ ជួន ពិចារណា ឈ្វេងយល់ ធ្វើឲ្យជាក់ច្បាស់ នូវសម្បត្តិនឹងវិបត្តិទាំងពីរ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតឃើញ នូវដំណើរទាំងពីរ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខា តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ នឹងគោចរៈ ឃើញភ័យក្នុងទោសមានប្រមាណបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីល ទីតាំង ខាងដើម ការប្រព្រឹត្ត ការសង្រួម ការរវាំង ប្រធាន ប្រមុខ នៃការបានធម៌ជាកុសលទាំងឡាយ នេះ អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈ

សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិ-សុខំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

កតមា អធិបញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខ-សមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោ-ធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ អធិបញ្ញាសិក្ខា ។

មេថុនន្តិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ

ប្រកបដោយវិចារៈ មានបីតិនិងសុខៈ កើតអំពីវិវេក ចូលទុតិយជ្ឈាន មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ប្រព្រឹត្តទៅខាងក្នុងសន្តាន ជាទីជ្រះថ្លាស៊ប់ គឺសទ្ធា មានសភាពជាចិត្តដ៏ខ្ពស់ឯក ព្រោះការរម្ងាប់នូវវិតក្កៈ និងវិចារៈ ចូលតតិយជ្ឈាន ចូលចតុត្ថជ្ឈាន នេះ អធិចិត្តសិក្ខា ។

អធិបញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹង នូវការកើតឡើងនិងការវិនាសទៅ ជាប្រាជ្ញាដ៏ប្រសើរ អាចទំលុះទំលាយ ជាគ្រឿងដល់នូវការអស់ទុក្ខ ដោយប្រពៃ ភិក្ខុនោះ ក៏ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាគ្រឿងរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាគ្រឿងដល់នូវការរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុកើតឡើងនៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាគ្រឿងរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាគ្រឿងដល់នូវការរលត់អាសវៈ នេះ អធិបញ្ញាសិក្ខា ។ ពាក្យថា មេថុនធម្ម សេចក្តីថា ដែលឈ្មោះថា មេថុនធម្ម បានខាងធម៌របស់អសប្បុរស

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

។ បេ ។ តំការណា វុច្ចតិ មេថុនធម្មោ ។ ឯតម្បិ តិស្សា សិក្ខេថ មេថុនំ វិប្បហាតវេតិ មេថុនធម្មស្ស បហានាយ វូបសមាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិប្បញ្ញម្បិ សិក្ខេយ្យ ។ ឥមា តិស្សោ សិក្ខា[១] អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឋហន្តោ សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ វីរិយំ បគ្គណ្ហន្តោ សិក្ខេយ្យ សតិំ ឧបដ្ឋបេន្តោ សិក្ខេយ្យ ចិត្តំ សមាទហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខេយ្យ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខេយ្យ បហាតព្វំ បជហន្តោ សិក្ខេយ្យ ភាវេតព្វំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ ឯតម្បិ តិស្សា សិក្ខេថ មេថុនំ វិប្បហាតវេ ។ តេនាហ ភគវា

---

១ ម. សិក្ខាយោ ។

។ បេ ។ ព្រោះហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។

ពាក្យថា បព្វជិតឃើញ នូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុនធម្ម បានសេចក្តីថា បព្វជិត គប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីលះបង់ ដើម្បីរម្ងាប់ ដើម្បីលាស់ចោល ដើម្បីរម្ងាប់ នូវមេថុនធម្ម ។ គប្បីពិចារណាសិក្សាសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីអធិដ្ឋានចិត្តសិក្សា គប្បីចុះចិត្តស៊ប់ដោយសទ្ធាសិក្សា គប្បីផ្គងព្យាយាមសិក្សា គប្បីតំកល់ស្មារតីសិក្សា គប្បីតំកល់ចិត្តសិក្សា គប្បីដឹងច្បាស់ដោយប្រាជ្ញាសិក្សា គប្បីដឹងច្បាស់នូវធម៌ដែលគួរដឹងច្បាស់សិក្សា គប្បីកំណត់ដឹងធម៌ដែលគួរកំណត់ដឹងសិក្សា គប្បីលះបង់ធម៌ដែលគួរលះបង់សិក្សា គប្បីចំរើនធម៌ដែលគួរចំរើនសិក្សា គប្បីធ្វើឲ្យជាក់ច្បាស់ធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា គប្បីប្រព្រឹត្តទៅ ប្រព្រឹត្តដោយប្រពៃ ប្រព្រឹត្តកាន់យក ហេតុនោះ (ទ្រង់ត្រាស់ថា) បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុនធម្ម ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

យសោ កិត្តិ ច យា បុព្វេ
ហាយតេ វាបិ តស្ស សា
ឯតម្បិ ទិស្វា សិក្ខេថ
មេថុនំ វិប្បហាតវេ ។

(២៤៣) សង្កប្បេហិ បរេតោ សោ កបណោ វិយ ឈាយតិ
សុត្វា បរេសំ និគ្ឃោសំ មង្កុ ហោតិ តថាវិធោ ។

(២៤៤) សង្កប្បេហិ បរេតោ សោ កបណោ វិយ ឈាយតីតិ កាមសង្កប្បេន ព្យាបាទសង្កប្បេន វិហឹសាសង្កប្បេន ទិដ្ឋិសង្កប្បេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ[1] កបណោ វិយ មន្ទោ វិយ មោមូហោ វិយ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អវជ្ឈាយតិ ។ យថា ឧលូកោ រុក្ខសាខាយំ មូសិកំ គមយមានោ[2] ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អវជ្ឈាយតិ យថា កោត្ថុ នទីតីរេ មច្ឆេ គមយមានោ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អវជ្ឈាយតិ យថា

១ ឱ. ម. សមន្នាគតោ បិហិតោ ។ ២ ឱ. ម. មគ្គយមានោ ។

យសនិងកេរ្តិ៍ឈ្មោះណា(ធ្លាប់មាន) ក្នុងកាលមុន យសនិងកេរ្តិ៍ឈ្មោះនោះ របស់បុគ្គលនោះ ក៏សាបសូន្យទៅ បព្វជិតឃើញនូវដំណើរនុ៎ះហើយ គប្បីសិក្សា ដើម្បីលះបង់មេថុន ។

(២៤៣) បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយ គ្របសង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដី របស់ពួកជនដទៃហើយ រមែងអៀនអន់ ។

(២៤៤) ពាក្យថា បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយ គ្របសង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា អធិប្បាយថា បព្វជិតត្រូវសេចក្តីត្រិះរិះប្រកបដោយកាម ត្រូវសេចក្តីត្រិះរិះប្រកបដោយព្យាបាទ ត្រូវសេចក្តីត្រិះរិះប្រកបដោយវិហឹសា ត្រូវសេចក្តីត្រិះរិះប្រកបដោយទិដ្ឋិប៉ះពាល់ គ្របសង្កត់ ជ្រួតជ្រាប ប្រកបហើយ រមែងក្តុកក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ ដូចមនុស្សកំព្រា ឬដូចជាអ្នកលង់ ឬក៏ដូចជាអ្នកវង្វេងទិស ។ មៀមកាលស្វែងរកកណ្តុរលើមែកឈើ រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា ចចកកាលស្វែងរកត្រី ទៀបឆ្នេរស្ទឹង រមែងក្តៅក្តួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា

វិឡារោ សន្ធិសមលសង្កដីរេ[១] មូសិកំ មគ្គយ-មានោ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈា-យតិ យថា គទ្រភោ វហច្ឆិន្នោ សន្ធិសមលសង្ក-ដីរេ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ឯវមេវ សោ វិព្ភន្តកោ កាមសញ្ញាយ ព្យាបាទ-សញ្ញាយ វិហឹសាសញ្ញាយ ទិដ្ឋិសញ្ញាយ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ កបណោ វិយ មន្ទោ វិយ មោមូហោ វិយ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតីតិ សញ្ញាហិ បរេតោ សោ កបណោ វិយ ឈាយតិ ។

[២៤៨] សុត្វា បរេសំ និគ្ឃោសំ មង្កុ ហោតិ តថាវិធោតិ បរេសន្តិ ឧបជ្ឈាយកា វា អាចរិយកា[២] វា សមានុបជ្ឈាយកា វា សមានាចរិយកា វា មិត្តា វា សន្ទិដ្ឋា វា សម្ភត្តា វា សហាយា វា ចោទេន្តិ

---

១ ម. សន្ទិសមលសង្កដិរេ ។ ២ ម. ឧបជ្ឈាយា វា អាចរិយា វា ។

ឆ្មាកាលស្វែងរកកណ្ដុរ ក្នុងទីជាបន្លោះតំណនៃផ្ទះ នឹងទីប្រកបដោយមន្ទិល ប្រកបដោយភក់នឹងធ្នេរ រមែងក្ដៅក្លួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ យ៉ាងណា លា មានការដឹកនាំជាប់ហើយ (គេប្រើមិនកើត) រមែងក្ដៅក្លួលសញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ ក្នុងទីជាបន្លោះតំណនៃផ្ទះ នឹងទីប្រកបដោយមន្ទិល ប្រកបដោយភក់នឹងធ្នេរ យ៉ាងណា បុគ្គលជាអ្នកក្វាត់នោះ ដែលត្រូវសេចក្ដីត្រិះរិះប្រកបដោយកាម ត្រូវសេចក្ដីត្រិះរិះប្រកបដោយព្យាបាទ ត្រូវសេចក្ដីត្រិះរិះប្រកបដោយវិហឹសា ត្រូវសេចក្ដីត្រិះរិះប្រកបដោយទិដ្ឋិប៉ះពាល់ គ្របសង្កត់ ជ្រួតជ្រាប ប្រកបហើយ រមែងក្ដុកក្ដួល សញ្ជប់សញ្ជឹង ស្រពាប់ស្រពោន ជ្រុលជ្រប់ដូចមនុស្សកំព្រា ឬដូចជាអ្នកល្ងង់ ឬក៏ដូចជាអ្នកវង្វេងទិស យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) បព្វជិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយ គ្របសង្កត់ហើយ រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា ។

(២៤៥) អធិប្បាយពាក្យថា បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ជនដទៃហើយ ក៏រមែងអៀនអន់ ត្រង់ពាក្យថា ជនដទៃ បានដល់ ពួកជនជាឧបជ្ឈាយ៍ក្ដី អាចារ្យក្ដី បុគ្គលមានឧបជ្ឈាយ៍ស្មើគ្នាក្ដី បុគ្គលមានអាចារ្យស្មើគ្នាក្ដី មិត្តក្ដី បុគ្គលដែលធ្លាប់ឃើញគ្នាម្ដងម្កាលក្ដី បុគ្គលដែលធ្លាប់គប់រកគ្នាក្ដី សំឡាញ់ក្ដី ដាស់តឿនថា

តស្ស តេ ខោ អាវុសោ អលាភា តស្ស តេ ទុល្លទ្ធំ យំ ត្វំ ឯវរូបំ ឧឡារំ សត្ថារំ លភិត្វា ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ឯវរូបំ អរិយគណំ លភិត្វា ហីនស្ស មេថុនធម្មស្ស ការណា ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោសិ សទ្ធាបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ ហិរិបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ ឱត្តប្បម្បិ នាម តេ អហោសិ កុសលេសុ ធម្មេសុ វីរិយម្បិ នាម តេ អហោសិ កុសលេសុ ធម្មេសុ សតិបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ បញ្ញាបិ នាម តេ អហោសិ កុសលេសុ ធម្មេសុ តេសំ វចនំ ព្យប្បថំ ទេសនំ អនុសិដ្ឋឹ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វា មង្កុ ហោតិ បីឡិតោ ឃដ្ដិតោ ព្យត្ថិតោ[1] ទោមនស្សិតោ ហោតិ ។ តថាវិធោតិ តថាវិធោ តាទិសោ តស្សណ្ឋិតោ តប្បការោ តប្បដិភាគោ យោ សោ វិត្ថទ្ធកោតិ សុត្វា បរេស និគ្គហំ មង្កុ ហោតិ តថាវិធោ ។ តេនាហ ភគវា

១ ម. ព្យាធិតោ ។

ម្នាលអាវុសោ អ្នកនោះពេញជាត់គលាភមែន ការបាន(អត្តភាពជាមនុស្ស) អ្នកបានដោយកម្រ ព្រោះថាជាអ្នកបានគ្រូដ៏ថ្លៃថ្លាមានសភាពយ៉ាងនេះ បួសក្នុងធម្មវិន័យដែលព្រះមានព្រះភាគ សំដែងល្អហើយយ៉ាងនេះ បានពួកព្រះអរិយៈ មានសភាពយ៉ាងនេះត្រឡាំង ហើយពោលលានូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសិក្ខា ហើយត្រឡប់មកកាន់ភេទថោកទាប ព្រោះហេតុមេថុនធម្មដ៏ថោកទាប សូម្បីតែសទ្ធារបស់អ្នកក្នុងកុសលធម៌ ក៏មិនមាន សូម្បីតែហិរិរបស់អ្នកក្នុងកុសលធម៌ ក៏មិនមាន សូម្បីតែឱត្តប្បៈរបស់អ្នកក្នុងកុសលធម៌ ក៏មិនមាន សូម្បីតែវីរិយៈ របស់អ្នកក្នុងកុសលធម៌ ក៏មិនមាន សូម្បីតែសតិរបស់អ្នកក្នុងកុសលធម៌ ក៏មិនមាន សូម្បីតែបញ្ញារបស់អ្នកក្នុងកុសលធម៌ ក៏មិនមាន បុគ្គលអ្នកភ្លាត់នោះ លុះស្តាប់ ឮ រៀន ពិចារណា កំណត់ នូវពាក្យ គន្លងពាក្យ ទេសនា ការប្រៀនប្រដៅ របស់ជនទាំងឡាយនោះ ក៏រមែងអៀនអន់ ចង្អៀត ចង្អល់ ក្រៀមក្រំ ឈឺចាប់ តូចចិត្ត ៗ ពាក្យថា បុគ្គលមានសភាពដូច្នោះ គឺបុគ្គលណា ជាអ្នកភ្លាត់ បុគ្គលនោះ ឈ្មោះថាមានសភាពដូច្នោះ ប្រាកដដូច្នោះ ឋិតនៅដូច្នោះ មានប្រការៈដូច្នោះ មានបំណែកប្រៀបដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា ) បព្វជិតមានសភាពដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយ រមែងអៀនអន់ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

សង្កប្បេហិ បរេតោ សោ កបណោ វិយ ឈាយតិ
សុត្វា បរេស និគ្ឃោសំ មង្កុ ហោតិ តថាវិធោ ។

(២៤៦) អថ សត្ថានិ កុរុតេ បរវាទេហិ ចោទិតោ
ឯស ខ្វស្ស មហាគេធោ មោសវជ្ជំ បគាហតិ ។

(២៤៧) អថ សត្ថានិ កុរុតេ បរវាទេហិ ចោទិ-តោតិ អថាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ អថាតិ ។ សត្ថានីតិ តីណិ សត្ថានិ កាយសត្ថំ វចី-សត្ថំ មនោសត្ថំ ។ តិវិធំ កាយទុច្ចរិតំ កាយសត្ថំ ចតុព្វិធំ វចីទុច្ចរិតំ វចីសត្ថំ តិវិធំ មនោទុច្ចរិតំ មនោ-សត្ថំ ។ បរវាទេហិ ចោទិតោតិ ឧបជ្ឈាយកេហិ វា អាចរិយកេហិ វា សមានុបជ្ឈាយកេហិ វា សមានាចរិយកេហិ វា មិត្តេហិ វា សន្ទិដ្ឋេហិ វា សម្ភត្តេហិ វា សហាយេហិ វា ចោទិតោ

បណ្ឌិតនោះ ដែលត្រូវសង្កប្បៈទាំងឡាយគ្របសង្កត់ហើយ
រមែងសញ្ជប់សញ្ជឹង ដូចមនុស្សកំព្រា បណ្ឌិតមានសភាព
ដូច្នោះ លុះឮពាក្យសំដីរបស់ពួកជនដទៃហើយរមែងអៀនអន់ ។

(៤៤៦) លំដាប់នោះ បុគ្គល ដែលត្រូវវាទៈជនដទៃដាស់តឿន
ហើយ រមែងធ្វើសស្ត្រាទាំងឡាយ នុ៎ះជាសេចក្តីជាប់ចំពាក់ធំ
របស់បុគ្គលនោះ បុគ្គលនោះ រមែងផ្គង់ពាក្យកុហក ។

(៤៤៧) អធិប្បាយពាក្យថា លំដាប់នោះបុគ្គលដែលត្រូវវាទៈជនដទៃដាស់តឿនហើយ រមែងធ្វើសស្ត្រាទាំងឡាយ ត្រង់ពាក្យថា លំដាប់នោះ គឺជាពាក្យភ្ជាប់បទ ជាពាក្យ ជាប់ចំពាក់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យ ប្រជុំអក្ខរៈ ជាពាក្យ សម្រួលព្យញ្ជនៈ ពាក្យថា លំដាប់នោះ គឺជាពាក្យលំដាប់បទ ។ ពាក្យថា សស្ត្រា បានដល់សស្ត្រា ៣ យ៉ាង គឺ សស្ត្រាគឺកាយ ១ សស្ត្រាគឺវាចា ១ សស្ត្រាគឺចិត្ត ១ ។ កាយទុច្ចរិត ៣ ឈ្មោះថា សស្ត្រាគឺកាយ វចីទុច្ចរិត ៤ ឈ្មោះថា សស្ត្រាគឺវាចា មនោទុច្ចរិត ៣ ឈ្មោះថា សស្ត្រាគឺចិត្ត ។ ពាក្យថា បុគ្គលដែលត្រូវវាទៈជនដទៃ ដាស់តឿនហើយ គឺបុគ្គលជាឧបជ្ឈាយ៍ក្តី អាចារ្យក្តី បុគ្គលមានឧបជ្ឈាយ៍ស្មើគ្នាក្តី បុគ្គលមានអាចារ្យស្មើគ្នាក្តី មិត្តក្តី បុគ្គលដែលធ្លាប់ឃើញគ្នាក្តី បុគ្គលដែលធ្លាប់គប់រកគ្នាក្តី សំឡាញ់ក្តី

សម្បជានមុសា ភាសតិ អភិរតោ អហំ ភន្តេ អហោសឹ បព្វជ្ជាយ មាតា មេ បោសេតព្វា តេនម្ហិ វិព្ភន្តោតិ ភណតិ បិតា មេ បោសេតព្វោ តេនម្ហិ វិព្ភន្តោតិ ភណតិ ភាតា មេ បោសេតព្វោ ភគិនី មេ បោសេតព្វា បុត្តោ មេ បោសេតព្វោ ធីតា មេ បោសេតព្វា មិត្តា មេ បោសេតព្វា អមច្ចា មេ បោសេតព្វា ញាតកា មេ បោសេតព្វា សាលោហិតា មេ បោសេតព្វា តេនម្ហិ វិព្ភន្តោតិ ភណតិ វចីសត្ថំ ករោតិ[១] ជនេតិ សញ្ជនេតិ និព្វត្តេតិ អភិនិព្វត្តេតិ អថ សត្ថានិ កុរុតេ បរេហិ ចោទិតោ ។

(២៤៨) ឯស ខ្វស្ស មហាគេធោតិ ឯសោ ខោ អស្ស មហាគេធោ មហាវនំ មហាគហនំ មហាកន្តារោ មហាវិសមោ មហាកុដិលោ មហាបង្កោ មហាបលិបោ មហាបលិពោធោ មហាពន្ធនំ យទិទំ សម្បជានមុសាវាទោតិ ឯស ខ្វស្ស មហាគេធោ ។

(២៤៩) មោសវជ្ជំ បគាហតីតិ មោសវជ្ជំ

១ ឱ. ម. ករោតិ សំករោតិ ។

ដាស់តឿន បុគ្គលនោះ រមែងពោលពាក្យកុហកទាំងដឹងខ្លួន គឺពោលថា បពិត្រលោកដ៏ចំរើន ខ្ញុំជាអ្នកត្រេកអរ ក្នុងបព្វជ្ជាហើយ តែថាខ្ញុំត្រូវចិញ្ចឹមមាតា ហេតុនោះ បានជាខ្ញុំវិលខុស ពោលថា ខ្ញុំត្រូវចិញ្ចឹមបិតា ហេតុនោះ បានជាខ្ញុំវិលខុស ពោលថា ខ្ញុំត្រូវចិញ្ចឹមបងប្អូនប្រុស ខ្ញុំត្រូវចិញ្ចឹមបងប្អូនស្រី ខ្ញុំត្រូវចិញ្ចឹមបុត្ត ខ្ញុំត្រូវចិញ្ចឹមធីតា ខ្ញុំត្រូវចិញ្ចឹមមិត្ត ខ្ញុំត្រូវចិញ្ចឹមអាមាត្យ ខ្ញុំត្រូវចិញ្ចឹមពួកញាតិ ខ្ញុំត្រូវចិញ្ចឹមសាលោហិត ហេតុនោះ បានជាខ្ញុំវិលខុស រមែងធ្វើឲ្យកើត ឲ្យកើតព្រម បង្កើត បង្កើតចំពោះនូវសក្រ្ដាគីវាចា ហេតុនោះ (ទ្រង់ត្រាស់ថា) លំដាប់នោះ បុគ្គលត្រូវវាទៈជនដទៃ ដាស់តឿនហើយ រមែងធ្វើសក្រ្ដាទាំងឡាយ ។

(២៤៨) ពាក្យថា នុះជាសេចក្ដីជាប់ចំពាក់ធំ របស់បុគ្គលនោះ គឺសភាពនុះឯងជាសេចក្ដីជាប់ចំពាក់ធំ ជាព្រៃធំ ជាញាតស្បាតធំ ជាផ្លូវដាច់ស្រយាលធំ ជាផ្លូវមិនស្មើ (បម្រូង បម្រាសធំ) ជាផ្លូវវៀចធំ ជាផ្លូវល្បាប់ធំ ជាផ្លូវមានភក់ច្រើន ជាផ្លូវមានសេចក្ដីខ្វល់ខ្វាយធំ ជាបំណងធំរបស់បុគ្គលនោះ គឺការពោលមុសាវាទទាំងដឹងខ្លួន របស់បុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) នុះជាសេចក្ដីជាប់ចំពាក់ធំ របស់បុគ្គលនោះ ។

(២៤៩) ពាក្យថា បុគ្គលនោះ រមែងផ្គងពាក្យកុហក អធិប្បាយថា

វុច្ចតិ មុសាវាទោ ។ ឥធេកច្ចោ សភគ្គតោ វា បរិសគ្គ-
តោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុល-
មជ្ឈគតោ វា អភិនីតោ សក្ខិបុដ្ឋោ ឯហិ ភោ បុរិស
យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ[១]
ជានាមីតិ ជានំ វា អាហ[២] ន ជានាមីតិ អបស្សំ
វា អាហ[៣] បស្សាមីតិ បស្សំ វា អាហ[៤] ន
បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា
អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសតិ
ឥទំ វុច្ចតិ មុសាវាទោ ។ អបិច តីហាការេហិ មុសា-
វាទោ ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ
ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស
ហោតិ មុសា មយា ភណិតន្តិ ឥមេហិ តីហាការេហិ
មុសាវាទោ ហោតិ ។ អបិច ចតូហាការេហិ ។ បញ្ច-
ហាការេហិ ។ ឆហាការេហិ ។ សត្តហាការេហិ ។
អដ្ឋហាការេហិ ។ មុសាវាទោ ហោតិ បុព្វេវស្ស

---

១ . ២ . ៣ . ៤ ម. អាហំ ។

តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

មុសាវាទ លោកហៅថា ពាក្យកុហក ៗ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់ពេនជាទីប្រជុំក្តី ទៅកាន់បរិសទ៍ក្តី ទៅក្នុងកណ្តាលញាតិក្តី ទៅក្នុងកណ្តាលពួកក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅសួរយកជាបន្ទាល់ថា ម្នាលបុរសដ៏ចំរើន អ្នកចូរមក អ្នកដឹងហេតុណា ចូរពោលហេតុនោះ ៗ បុរសនោះ កាលមិនដឹង ពោលថា ខ្ញុំដឹងក្តី កាលដឹង ពោលថា ខ្ញុំមិនដឹងក្តី កាលមិនឃើញ ពោលថា ខ្ញុំឃើញក្តី កាលឃើញ ពោលថា ខ្ញុំមិនឃើញក្តី ពោលសម្បជានមុសាវាទ ព្រោះហេតុខ្លួនក្តី ព្រោះហេតុបុគ្គលដទៃក្តី ព្រោះហេតុអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះលោកហៅថា ពាក្យកុហក ៗ មួយទៀត មុសាវាទ ដោយអាការ ៣ យ៉ាង គឺ មុសាវាទរបស់បុគ្គលនោះ ក្នុងកាលមុនថា អាត្មាអញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អាត្មាអញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលពោលហើយថា អាត្មាអញពោលពាក្យកុហកហើយ១ មុសាវាទ ដោយអាការ ៣ នេះ ៗ មួយវិញទៀត មុសាវាទ មានដោយអាការ ៤ យ៉ាង ៗ ដោយអាការ ៥ យ៉ាង ៗ ដោយអាការ ៦ យ៉ាង ៗ ដោយអាការ ៧ យ៉ាង ៗ មុសាវាទ ដោយអាការ ៨ យ៉ាង គឺ មុសាវាទ នៃបុគ្គលនោះ ក្នុងកាលមុនថា

ហោតិ មុសា គណិស្សន្តិ គណេន្តស្ស ហោតិ មុសា គណេមីតិ គណិតស្ស ហោតិ មុសា មយា គណិតន្តិ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ សញ្ញំ វិនិធាយ ភាវំ ឥមេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ ។ មោសវជ្ជំ បគ្គាហតីតិ មោសវជ្ជំ បគ្គាហតិ ឱគាហតិ អជ្ឈោគាហតិ បវិសតីតិ មោសវជ្ជំ បគ្គាហតិ ។ តេនាហ ភគវា

អថ សត្ថានិ កុរុតេ បរវាទេហិ ចោទិតោ

ឯស ខ្វស្ស មហាគេធោ មោសវជ្ជំ បគ្គាហតីតិ ។

(៤៩០) បណ្ឌិតោតិ សមញ្ញាតោ ឯកចរិយំ អធិដ្ឋិតោ

អថាបិ(១) មេថុនេ យុត្តោ មន្ទោវ បរិកិស្សតិ ។

(៤៩១) បណ្ឌិតោតិ សមញ្ញាតោតិ ឯកច្ចោ បុព្វេ សមណកាលេ កិត្តិវណ្ណកតោ(២) ហោតិ បណ្ឌិតោ វិយត្តោ

---

១ ម. សចាបិ ។ ២ ម. កិត្តិវណ្ណគតោ ។

អាត្មាអញ នឹងពោលពាក្យកុហក ១ មុសាវាទនៃបុគ្គលកំពុងពោលថា អាត្មាអញ ពោលពាក្យកុហក ១ មុសាវាទ នៃបុគ្គលពោលហើយថា អាត្មាអញ ពោលពាក្យកុហកហើយ ១ ព្រោះលាក់ទុក នូវទិដ្ឋិ ១ ព្រោះលាក់ទុកនូវការចូលចិត្ត ១ ព្រោះលាក់ទុកនូវសេចក្តីពេញចិត្ត ១ ព្រោះលាក់ទុកនូវសញ្ញា ១ ព្រោះលាក់ទុកនូវការកើតឡើង ១ មុសាវាទ ដោយអាការ ៨ នេះ ។ ពាក្យថា រមែងផ្គងពាក្យកុហក គឺ ផ្គង ផ្គូផ្គងទុក កំណត់ទុក ចូលទៅ កាន់ពាក្យកុហក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរមែងផ្គងពាក្យកុហក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

លំដាប់នោះ បុគ្គលដែលត្រូវវាទៈជនដទៃ ដាស់តឿន
ហើយ រមែងធ្វើសត្រូវទាំងឡាយ នុះជាសេចក្តីជាប់ចំពាក់ចំ
របស់បុគ្គលនោះ បុគ្គលនោះ រមែងផ្គងពាក្យកុហក ។

(៥៩០) បុគ្គលដែលគេដឹងច្បាស់ហើយថាជាបណ្ឌិត អធិដ្ឋាន
ការប្រព្រឹត្តិតែម្នាក់ឯង តែខាងក្រោយមក ជាអ្នកប្រកបក្នុង
មេថុនធម្ម នឹងត្រដាបត្រដួស ដូចបុគ្គលល្ងង់ខ្លៅ ។

(៥៩១) ពាក្យថា បុគ្គល ដែលគេដឹងច្បាស់ហើយថាជាបណ្ឌិត អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះ កាលនៅក្នុងភាពជាសមណៈក្នុងកាលមុន ជាអ្នកពេញដោយកេរ្តិ៍ឈ្មោះនឹងសេចក្តីសរសើរ ជាបណ្ឌិតវាងវៃ

មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណបដិភាណោ សុត្តន្តិកោតិ វា វិនយធរោតិ វា ធម្មកថិកោតិ វា ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា យំ ញាតោ ហោតិ សញ្ញាតោ[១] សម្មញ្ញាតោតិ បណ្ណាតោតិ សមញ្ញាតោ ។

[២៨២] ឯកចរិយំ អធិដ្ឋិតោតិ ទ្វីហិ ការណេហិ ឯកចរិយំ អធិដ្ឋិតោ បព្វជ្ជាសង្ខាតេន វា គណាវវស្សគ្គដ្ឋេន វា ។ កថំ បព្វជ្ជាសង្ខាតេន ឯកចរិយំ អធិដ្ឋិតោ ។ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា ។ បេ ។ ឯវំ បព្វជ្ជាសង្ខាតេន ឯកចរិយំ អធិដ្ឋិតោ ។ កថំ គណាវវស្សគ្គដ្ឋេន ឯកចរិយំ អធិដ្ឋិតោ ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ ។ បេ ។ ឯវំ គណាវវស្សគ្គដ្ឋេន ឯកចរិយំ អធិដ្ឋិតោតិ ឯកចរិយំ អធិដ្ឋិតោ ។

[២៨៣] អថាបិ មេថុនេ យុត្តោតិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ ។ បេ ។ តំការណា

---

១ ម. បញ្ញាតោ ។

មានប្រាជ្ញា ជាពហុស្សូត មានពាក្យដ៏វិចិត្រ មានប្រាជ្ញាល្អ ជាអ្នក-ដែលគេដឹងហើយ ដឹងច្បាស់ហើយ ដឹងសុសសាយហើយ យ៉ាងនេះថា ជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ទ្រទ្រង់វិន័យក្តី ជាធម្មកថិកក្តី ។ បេ ។ ជាអ្នកបាននៅសញ្ញានាសញ្ញាយតនសមាបត្តិក្តី ហេតុនោះ(ទ្រង់ត្រាស់ថា) បុគ្គលដែលគេដឹងច្បាស់ហើយថាជាបណ្ឌិត ។

(៥៩២) ពាក្យថា អធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង អធិប្បាយថា បុគ្គលអធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង ដោយហេតុ ២ គឺ ដោយចំណែកបព្វជ្ជាក្តី ដោយការលះបង់ពួកក្តី ។ បុគ្គលអធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ បុគ្គល ផ្តាច់បង់សេចក្តីខ្វល់ខ្វាយគឺយកវាសទាំងពួង ។ បេ ។ អធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង ដោយចំណែកបព្វជ្ជាយ៉ាងនេះឯង ។ បុគ្គល អធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង ដោយការលះបង់ពួក តើដូចម្តេច ។ បុគ្គលនោះ បួសយ៉ាងនេះហើយ ជាអ្នកម្នាក់ឯង គប់សេនាសនៈស្ងាត់ គឺព្រៃតូចព្រៃធំ ។ បេ ។ អធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯងដោយការលះបង់ពួកយ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) អធិដ្ឋានការប្រព្រឹត្តិតែម្នាក់ឯង ។

(៥៩៣) ពាក្យថា តែខាងក្រោយមក ជាអ្នកប្រកបក្នុងមេថុនធម្ម អធិប្បាយថា ឈ្មោះថាមេថុនធម្ម បានខាងធម៌របស់អសប្បុរស ។ បេ ។

វុច្ចតិ មេថុនធម្មោ ។ អថាបិ មេថុនេ យុត្តោតិ សោ អបរេន សមយេន ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា មេថុនធម្មេ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោតិ អថាបិ មេថុនេ យុត្តោ ។

(២៥៤) មន្ទោវ បរិកិស្សតីតិ កបណោ វិយ[១] មោមូហោ វិយ កិស្សតិ បរិកិស្សតិ បរិកិលិស្សតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ ឯវម្បិ កិស្សតិ បរិកិស្សតិ បរិកិលិស្សតិ ។ តមេនំ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ អឌ្ឍទណ្ឌកេហិបិ តាឡេន្តិ ហត្ថម្បិ ឆិន្ទន្តិ បាទម្បិ ឆិន្ទន្តិ ហត្ថបាទម្បិ ឆិន្ទន្តិ កណ្ណម្បិ ឆិន្ទន្តិ នាសម្បិ ឆិន្ទន្តិ កណ្ណនាសម្បិ ឆិន្ទន្តិ ពិលង្គថាលិកម្បិ ករោន្តិ សង្ខមុណ្ឌិកម្បិ ករោន្តិ រាហុមុខម្បិ ករោន្តិ

---

១ ម. ឯត្ថន្តរេ មន្ទោវិយាតិ ទិស្សតិ ។

ហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ ពាក្យថា តែខាងក្រោយមក ជាអ្នកប្រកបក្នុងមេថុនធម្ម គឺសម័យខាងក្រោយ បុគ្គលនោះពោលលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសិក្ខា វិលមកដើម្បីភេទថោកទាប ប្រកប តាក់តែង ប្រជុំប្រជា ប្រកបព្រមក្នុងមេថុនធម្ម ហេតុនោះ (ទ្រង់ត្រាស់ថា) តែខាងក្រោយមក ជាអ្នកប្រកបក្នុងមេថុនធម្ម ។

(២៥៤) ពាក្យថា នឹងត្រដាបត្រដួស ដូចបុគ្គលល្ងង់ខ្លៅ អធិប្បាយថា បុគ្គលនោះ នឹងលំបាក បង្អៀតបង្អល់ សៅហ្មង ដូចមនុស្សកំព្រា ឬដូចមនុស្សល្ងង់ខ្លៅ គឺរមែងសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនឲ្យខ្លះ កាត់តំណ (នៃផ្ទះ) ខ្លះ វាយប្រហារទាំងប្លន់ខ្លះ ធ្វើអាការកំហែងក្នុងផ្ទះមួយខ្លះ ឈរចាំស្កាត់ដណ្តើមយកខ្លះ គប់រកប្រពន្ធរបស់ជនដទៃខ្លះ ពោលពាក្យកុហកខ្លះ នឹងលំបាក បង្អៀតបង្អល់ សៅហ្មងយ៉ាងនេះខ្លះ ។ ព្រះរាជាទាំងឡាយឲ្យចាប់បុគ្គលនោះឯងហើយ ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យគេវាយដោយរំពាត់ខ្លះ ឲ្យគេវាយដោយផ្តៅខ្លះ ឲ្យគេវាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើក្បាល ឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ធ្វើសង្ខមុណ្ឌកកម្ម គឺអំពើដែលគេធ្វើក្បាល ឲ្យសលើងដូចជាសម្បកស័ង្ខខ្លះ ធ្វើរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ ឲ្យដូចជាមាត់រាហូខ្លះ

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

ជោតិមាលិកម្បិ ករោន្តិ ហត្ថបជ្ជោតិកម្បិ ករោន្តិ ឯរកវត្តិកម្បិ ករោន្តិ ចិរកវាសិកម្បិ ករោន្តិ ឯណេយ្យកម្បិ ករោន្តិ ពឡិសមំសិកម្បិ ករោន្តិ កហាបណកម្បិ ករោន្តិ ខារាបតច្ឆិកម្បិ ករោន្តិ បលិឃបរិវត្តិកម្បិ ករោន្តិ បលាលបីឋកម្បិ ករោន្តិ តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនាបិ សីសំ ឆិន្ទន្តិ ឯវម្បិ កិស្សតិ បរិកិស្សតិ បរិកិលិស្សតិ ។ អថវា កាមតណ្ហាយ អភិភូតោ បរិយាទិន្នចិត្តោ ភោគេ បរិយេសន្តោ នាវាយ មហាសមុទ្ទំ បក្ខន្ទតិ សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ រិស្សមានោ ខុប្បិបាសាយ មីយ្យមានោ គុម្ពំ គច្ឆតិ

ធ្វើជោតិមាលិកកម្ម គឺអំពើដែលគេដុតខ្លួន ឲ្យមានរបៀបនៃអណ្តាតភ្លើងខ្លះ ធ្វើហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ធ្វើឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ធ្វើចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ធ្វើឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ធ្វើពឡិសមំសិកកម្ម គឺអំពើដែលគេចក់មាត់ដោយកាង ឬសន្ទូចខ្លះ ធ្វើកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈ មួយៗខ្លះ ធ្វើខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ធ្វើបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើបលាលបីឋកកម្ម គឺអំពើដែលគេធ្វើ ឲ្យដូចជាកណ្តាប់ចំបើងខ្លះ ស្រោចដោយប្រេងកំពុងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តែតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ[១] បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មងដោយប្រការយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដែលត្រូវកាមតណ្ហាគ្របសង្កត់ មានចិត្តគឺកាមតណ្ហារួបរិត ស្វែងរកភោគៈទាំងឡាយ ចេញទៅកាន់មហាសមុទ្រដោយនាវា ត្រូវត្រជាក់ចោមរោម ត្រូវក្តៅចោមរោម លំបាកដោយសម្ផស្ស នៃរបោម មូស ខ្យល់ កំដៅ ពស់តូច នឹងពស់ធំ ត្រូវសេចក្តីស្រេកឃ្លានបៀតបៀន រមែងទៅកាន់ស្រុកគុម្ពៈ

---

១ មានក្នុងមជ្ឈិមនិកាយ ត្រង់មហាទុក្ខក្ខន្ធសូត្រ ។

តក្កោលំ គច្ឆតិ តក្កសិលំ គច្ឆតិ កាលមុខំ គច្ឆតិ មរណបារំ(១) គច្ឆតិ វេសុង្គំ គច្ឆតិ វេរាបថំ គច្ឆតិ ជវំ គច្ឆតិ តមលិំ(២) គច្ឆតិ វង្គំ គច្ឆតិ ឯឡពន្ធនំ គច្ឆតិ សុវណ្ណកូដំ គច្ឆតិ សុវណ្ណភូមឹ គច្ឆតិ តម្ពបណ្ណឹ(៣) គច្ឆតិ សុប្បារំ(៤) គច្ឆតិ ភរុកច្ឆំ(៥) គច្ឆតិ សុរដ្ឋំ(៦) គច្ឆតិ អង្គណេកំ(៧) គច្ឆតិ គង្គណំ(៨) គច្ឆតិ បរមគង្គណំ(៩) គច្ឆតិ យោនំ(១០) គច្ឆតិ បិនំ(១១) គច្ឆតិ អល្លសន្ទំ(១២) គច្ឆតិ មរុកន្តារំ គច្ឆតិ ជណ្ណុបថំ គច្ឆតិ អជបថំ គច្ឆតិ មេណ្ឌបថំ គច្ឆតិ សង្កុបថំ គច្ឆតិ ឆត្តបថំ គច្ឆតិ វំសបថំ គច្ឆតិ សកុណបថំ គច្ឆតិ មូសិកបថំ គច្ឆតិ ទរិបថំ គច្ឆតិ វេត្តាចារំ(១៣) គច្ឆតិ ឯវម្បិ កិស្សតិ បរិកិស្សតិ បរិកិលិស្សតិ ។ បរិយេសន្តោ ន លភតិ អលាភមូលកម្បិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ឯវម្បិ កិស្សតិ បរិកិស្សតិ បរិកិលិស្សតិ ។

---

១ ម. បុរបុរំ ។ ២ ខ. តមលំ ។ ៣ ម. តម្ពបាណិំ ។ ៤ ម. សុប្បារកំ ។ ៥ ខ. ភរុកច្ឆំ ។ ម. ភារុកច្ឆំ ។ ៦ ខ. ម. សុរដ្ឋំ ។ ៧ ម. អង្គណេកំ ។ ៨ ម. អង្គណំ ។ ៩ ម. សរមតំ គណំ ។ ១០ ខ. ម. យោនំ គច្ឆតិ បរមយោនំ គច្ឆតិ ។ ១១ ខ. បិនន្តិ ន ទិស្សតិ ។ ម. វិនកំ ។ ១២ ម. មូលបទំ ។ ១៣ ម. វេត្តាចារំ ។

ទៅកាន់ស្រុកតក្កោលៈ ទៅកាន់ស្រុកតក្កសិលា ទៅកាន់ស្រុកកាលមុខៈ ទៅកាន់ស្រុកមរណបារៈ ទៅកាន់ស្រុកវេសុង្គៈ ទៅកាន់ស្រុកវេរាបថៈ ទៅកាន់ស្រុកជវៈ ទៅកាន់ស្រុកកមលិ ទៅកាន់ស្រុកវង្កៈ ទៅកាន់ស្រុកឯឡវទ្ធនៈ ទៅកាន់ស្រុកសុវណ្ណកូដៈ ទៅកាន់ស្រុកសុវណ្ណភូមិ ទៅកាន់ស្រុកតម្ពបណ្ណិ ទៅកាន់ស្រុកសុប្បារៈ ទៅកាន់ស្រុកភរុកៈ ទៅកាន់ស្រុកសុរដ្ឋៈ ទៅកាន់ស្រុកអង្គណេកៈ ទៅកាន់ស្រុកគង្គណៈ ទៅកាន់ស្រុកបរមគង្គណៈ ទៅកាន់ស្រុកយោនៈ ទៅកាន់ស្រុកបិនៈ ទៅកាន់ស្រុកអល្លសន្ទៈ ទៅកាន់មរុកន្តារៈ ទៅកាន់ផ្លូវ ដែលគេគប្បីទៅដោយជង្គង់ ទៅកាន់ផ្លូវដែលគេគប្បីទៅដោយចៀម ទៅកាន់ផ្លូវដែលគេគប្បីទៅដោយពពែ ទៅកាន់ផ្លូវដង្គត់ ទៅកាន់ផ្លូវ ដែលគេគប្បីទៅដោយឆត្រ ទៅកាន់ផ្លូវប្រកបដោយព្រៃឫស្សី ទៅកាន់ផ្លូវសត្វស្លាប ទៅកាន់ផ្លូវកណ្តុរ ទៅកាន់ផ្លូវជ្រោះ ទៅកាន់ផ្លូវមានបន្ទាផ្តៅ បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ។ បុគ្គលកាលស្វែងរកមិនបាន រមែងទទួលទុក្ខនឹងទោមនស្ស ដែលមានការមិនបានជាមូល បុគ្គលនោះ នឹងលំបាក ចង្អៀតចង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ។

បរិយេសន្តោ លភតិ លទ្ធា ច អារក្ខមូលកម្បិ ទុក្ខ-
ទោមនស្សំ បដិសំវេទេតិ កិន្តិ មេ ភោគេ នេវ រាជា-
នោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ
ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ
តស្ស ឯវំ រក្ខតោ គោបយតោ(១) ភោគា វិប្បលុ-
ជ្ជន្តិ(២) វិប្បយោគមូលកម្បិ ទុក្ខទោមនស្សំ បដិសំ-
វេទេតិ ឯវម្បិ កិស្សតិ បរិកិស្សតិ បរិកិលិស្សតីតិ(៣)
មន្ទោវ បរិកិស្សតិ ។ តេនាហ ភគវា

បណ្ឌិតោតិ សមញ្ញាតោ ឯកចរិយំ អធិដ្ឋិតោ
អថាបិ មេថុនេ យុត្តោ មន្ទោវ បរិកិស្សតីតិ ។

(២៥៥) ឯតមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ
ឯកចរិយំ ទឡ្ហំ កយិរា ន និសេវេថ មេថុនំ ។

---

១ ខ. ម. ឯត្ថន្តរេ តេតិ ទិស្សតិ ។ ២ ខ. ម. ឯត្ថន្តរេ សោតិ ទិស្សតិ ។ ៣ ឯត្ថន្តរេ សថាបិ មេថុនេ យុត្តោតិ ទិស្សតិ ។ ខ. អជាបិ មេថុនេ យុត្តោតិ ទិស្សតិ ។

## តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

បុគ្គល កាលស្វែងរក ទ្រព្យបាន លុះបានហើយ ក៏ទទួលទុក្ខនឹងទោមនស្ស មានការថែរក្សាជាមូលថា ធ្វើដូចម្តេចហ្ន៎ ព្រះរាជាទាំងឡាយនឹងមិននាំយកទៅ ចោរទាំងឡាយ នឹងមិនលួចយក ភ្លើងនឹងមិនឆេះ ទឹកនឹងមិនបន្សាត់ទៅ ជនជាទាយាទមិនជាទីស្រឡាញ់ នឹងមិននាំយកភោគៈទាំងឡាយរបស់អញ កាលបុគ្គលនោះ កំពុងរក្សា កំពុងគ្រប់គ្រងយ៉ាងនេះ ភោគៈទាំងឡាយ ក៏វិនាសទៅ (បុគ្គលនោះ) រមែងទទួលទុក្ខនឹងទោមនស្ស មានការព្រាត់ប្រាសជាមូល បុគ្គលនោះនឹងលំបាក បង្អៀតបង្អល់ សៅហ្មង ដោយប្រការយ៉ាងនេះខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនឹងត្រជាបត្រដួស ដូចជាបុគ្គលលង់ទៅ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលដែលគេដឹងច្បាស់ហើយថាជាបណ្ឌិត អធិដ្ឋាន
ការប្រព្រឹត្តម្នាក់ឯង តែខាងក្រោយមក ជាអ្នកប្រកប
ក្នុងមេថុនធម្ម នឹងត្រជាបត្រដួស ដូចបុគ្គលលង់ទៅ ។

[២៤៥] មុនិក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះហើយ ក្នុងកាលមុន
នឹងកាលខាងក្រោយ គប្បីធ្វើការប្រព្រឹត្តម្នាក់ឯងឲ្យមាំ មិន
គប្បីសេពសមមេថុនធម្មទេ ។

(២៨៦) ឯវមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធាតិ ឯវន្តិ បុព្វេ សមណភាវេ យសោ ច កិត្តិ ច អបរភាគេ ពុទ្ធំ ធម្មំ សង្ឃំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តស្ស អយសោ ច អកិត្តិ ច ឯតំ សម្បត្តិវិបត្តិំ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មិំ អាទាយេ ឥមស្មិំ ធម្មេ ឥមស្មិំ វិនយេ ឥមស្មិំ ធម្មវិនយេ ឥមស្មិំ បាវចនេ ឥមស្មិំ ព្រហ្មចរិយេ ឥមស្មិំ សត្ថុសាសនេ ឥមស្មិំ អត្តភាវេ ឥមស្មិំ មនុស្សលោកេតិ ឯវមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ ។

(២៨៧) ឯកាចរិយំ ទឡ្ហំ កយិរាតិ ទ្វីហិ ការណេហិ ឯកាចរិយំ ទឡ្ហំ ការេយ្យ បព្វជ្ជាសង្ខាតេន វា គណាវវស្សគ្គដ្ឋេន វា ។

(២៨៦) អធិប្បាយពាក្យថា មុនិក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះ ហើយ ក្នុងកាលមុន នឹងកាលខាងក្រោយ ត្រង់ពាក្យថា នុ៎ះ សេចក្តីថា យសនឹងកេរ្តិ៍ឈ្មោះ ក្នុងភាពនៃបុគ្គលជាសមណៈក្នុងកាលមុន អាប់យស នឹងអាប់កេរ្តិ៍ឈ្មោះនៃបុគ្គលពោលលាព្រះពុទ្ធព្រះធម៌ព្រះសង្ឃ នឹងសិក្ខា ត្រឡប់មកកាន់ភេទថោកទាបក្នុងកាលខាងក្រោយ មុនិ ដឹង ស្គាល់ ស្ទង់ពិចារណា យល់ ធ្វើឲ្យជាក់ច្បាស់ នូវសម្បត្តិ នឹងវិបត្តិនុ៎ះ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានខាងប្រាជ្ញាការដឹងច្បាស់ ។ បេ ។ មុនិនោះ កន្លងបណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ក្នុងធម្មវិន័យនេះ គឺក្នុងទិដ្ឋិនេះ ក្នុងការគួរនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម៌វិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ ក្នុងធម្មវិន័យនេះ ដឹងច្បាស់នូវទោសនុ៎ះហើយ ក្នុងកាលមុន នឹងកាលខាងក្រោយ ។

(២៨៧) ពាក្យថា គប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ អធិប្បាយថា បុគ្គលគប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ដោយហេតុពីរ គឺដោយចំណែកបព្វជ្ជា ឬដោយការលះបង់ពួក ។

## សត្តមោ  តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

កថំ បព្វជ្ជាសង្ខាតេន ឯកចរិយំ អធិដ្ឋំ ការេយ្យ ។ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ[1] ឧបគន្ត្វា ឯកោ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យ ឯវំ បព្វជ្ជាសង្ខាតេន ឯកចរិយំ អធិដ្ឋំ ការេយ្យ ។

កថំ គណាវវស្សគ្គដ្ឋេន ឯកចរិយំ អធិដ្ឋំ ការេយ្យ ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវេយ្យ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ ។ សោ ឯកោ គច្ឆេយ្យ ឯកោ តិដ្ឋេយ្យ ឯកោ និសីទេយ្យ ឯកោ សេយ្យំ កប្បេយ្យ ឯកោ គាមំ បិណ្ឌាយ បវិសេយ្យ ឯកោ បដិក្កមេយ្យ ឯកោ រហោ

---

១ ម. អសញ្ញនភាវំ ។

## តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧

បុគ្គលគប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ដោយចំណែកបព្វជ្ជា តើដូចម្ដេច ។ បុគ្គលកាត់ការកង្វល់គឺឃរាវាសទាំងអស់ កាត់ការកង្វល់គឺបុត្តភរិយា កាត់ការកង្វល់គឺញាតិ កាត់ការកង្វល់គឺមិត្តនិងអាមាត្យ កាត់ការកង្វល់គឺការសន្សំ កោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់ជ្រលក់ដោយទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពនៃខ្លួនមិនមានកង្វល់ ត្រាច់ទៅ សម្រាកសម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ តែម្នាក់ឯង បុគ្គលគប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ដោយចំណែកបព្វជ្ជាយ៉ាងនេះ ។

បុគ្គលគប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ដោយការលះបង់ពួក តើដូចម្ដេច ។ បុគ្គលនោះ បួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង តែងគប់រកសេនាសនៈស្ងាត់ គឺព្រៃតូចនិងព្រៃធំ មិនមានសំឡេង មិនមានការគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីកាយនៃជន ស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ការពួនសម្ងំ ។ បុគ្គលនោះ ដើរតែម្នាក់ឯង ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង សម្រេចការដេកតែម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង

និសីទេយ្យ ឯកោ ចង្កមំ អធិដ្ឋេយ្យ ឯកោ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យ ឯវំ គណាវស្សគ្គេន ឯកចរិយំ ទឡ្ហំ ការេយ្យ(១) ។ ឯកចរិយំ ទឡ្ហំ ការេយ្យ ថិរំ ការេយ្យ ទឡ្ហសមាទានោ អស្ស អវដ្ឋិតសមាទានោ កុសលេសុ ធម្មេសូតិ ឯកចរិយំ ទឡ្ហំ កយិរា ។

[២៤៨] ន និសេវេថ មេថុនន្តិ មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ ។បេ។ តំការណា វុច្ចតិ មេថុនធម្មោ ។ មេថុនធម្មំ ន សេវេយ្យ ន និសេវេយ្យ ន សំសេវេយ្យ ន បដិសេវេយ្យាតិ(២) ន និសេវេថ មេថុនំ ។ តេនាហ ភគវា

ឯតមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ
ឯកចរិយំ ទឡ្ហំ កយិរា ន និសេវេថ មេថុនន្តិ ។

---

១ ឱ.ម. ករេយ្យាតិ ។ ២ ឱ.ម ន បដិសេវេយ្យ ន ចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យាតីតិ ទិស្សន្តិ ។

អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានបង្ក្រមតែម្នាក់ឯង ត្រាច់ទៅសម្រាក សម្រាន្ត សម្រេចឥរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្នាក់ឯង បុគ្គល គប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ដោយការលះបង់ពួកយ៉ាងនេះ ។ បុគ្គល គប្បីធ្វើនូវការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ធ្វើឲ្យខ្ជាប់ខ្ជួន មានការសមាទានដ៏មាំ មានការសមាទានតាំងនៅក្នុងធម៌ជាកុសលទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលគប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ។

(២៩៨) ពាក្យថា មិនគប្បីសេពសមមេថុនធម្ម សេចក្តីថា ដែលឈ្មោះថា មេថុនធម្ម បានដល់ធម៌របស់អសប្បុរស ។ បេ ។ ហេតុនោះ ទើបលោកហៅថា មេថុនធម្ម ។ បុគ្គល មិនគប្បីសេព មិនគប្បីសេពសម មិនគប្បីសេពព្រម មិនគប្បីសេពចំពោះនូវមេថុនធម្ម ហេតុនោះ (ទ្រង់ត្រាស់ថា ) មិនគប្បីសេពសមមេថុនធម្ម ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មុនិ ក្នុងធម្មវិន័យនេះ ដឹងទោសនុ៎ះហើយ ក្នុងកាលមុននឹង
កាលខាងក្រោយ គប្បីធ្វើការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ មិន
គប្បីសេពសមមេថុនធម្មទេ ។

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

[២៥៩] វិវេកញ្ញេវ សិក្ខេថ ឯតទរិយានមុត្តមំ

តេន សេដ្ឋោ ន មញ្ញេថ ស វេ និព្វានសន្តិកេ ។

(២៦០) វិវេកញ្ញេវ សិក្ខេថាតិ វិវេកោតិ តយោ វិវេកា កាយវិវេកោ ចិត្តវិវេកោ ឧបធិវិវេកោ ។ កតមោ កាយវិវេកោ ។ បេ ។ អយំ ឧបធិវិវេកោ ។ កាយវិវេកោ ច វូបកដ្ឋកាយានំ(១) នេក្ខម្មាភិរតានំ ចិត្តវិវេកោ ច បរិសុទ្ធចិត្តានំ បរមវោទានប្បត្តានំ ឧបធិវិវេកោ ច និរុបធីនំ បុគ្គលានំ វិសង្ខារគតានំ ។ សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។ បេ ។ អយំ អធិបញ្ញាសិក្ខា ។ វិវេកញ្ញេវ សិក្ខេថាតិ វិវេកញ្ញេវ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ វិវេកញ្ញេវ សិក្ខេថ ។

---

១ ម. វិវេកដ្ឋកាយានំ ។

(២៥៩) បុគ្គល គប្បីសិក្សាវិវេកតែម្យ៉ាង (ព្រោះថាវិវេក) នុ៎ះជាធម៌ដ៏ឧត្ដម របស់ព្រះអរិយៈទាំងឡាយ បុគ្គល មិនគប្បីសំគាល់ថាខ្លួនប្រសើរ ដោយវិវេកនោះទេ បុគ្គលនោះ (ទឹងឋិតនៅ) ក្នុងទីជិតព្រះនិព្វាន ។

(២៦០) ពាក្យថា បុគ្គល គប្បីសិក្សាវិវេកតែម្យ៉ាង សេចក្ដីថា វិវេកមាន ៣ គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។

កាយវិវេក តើដូចម្ដេច ។ បេ ។ នេះ ឧបធិវិវេក ។ វិវេករបស់បុគ្គលទាំងឡាយ ដែលមានកាយចៀសចេញ ចាកពួក ត្រេកអរចំពោះនេក្ខម្មៈ ឈ្មោះថា កាយវិវេក ១ វិវេករបស់បុគ្គលទាំងឡាយ ដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្ដីផូរផង់ដ៏ក្រៃលែង ឈ្មោះថា ចិត្តវិវេក ១ វិវេករបស់បុគ្គលទាំងឡាយ ដែលមិនមានឧបធិកិលេស ដល់នូវវិសង្ខារ គឺព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក ១ ។ ពាក្យថា សិក្សា បានដល់សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា គប្បីសិក្សាវិវេកតែម្យ៉ាង បាន សេចក្ដីថា គប្បីសិក្សា ប្រព្រឹត្ត ប្រព្រឹត្តព្រម សមាទាន ប្រព្រឹត្តទៅ នូវវិវេក ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីសិក្សាវិវេកតែម្យ៉ាង ។

(២៦១) ឯតទរិយានមុត្តមន្តិ អរិយា វុច្ចន្តិ ពុទ្ធា ច ពុទ្ធសាវកា ច បច្ចេកពុទ្ធា ច អរិយានំ ឯតំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ យទិទំ វិវេកចរិយាតិ ឯតទរិយានមុត្តមំ ។

(២៦២) តេន សេដ្ឋោ ន មញ្ញេថាតិ តាយ វិវេកចរិយាយ ឧណ្ណតិំ ន ករេយ្យ ឧណ្ណាមំ ន ករេយ្យ មានំ ន ករេយ្យ[១] ថម្ភំ ន ករេយ្យ ន តេន មានំ ជនេយ្យ ពន្ធំ ន ករេយ្យ ន តេន ថទ្ធោ អស្ស បត្ថទ្ធោ បគ្គហិតសិរោតិ តេន សេដ្ឋោ ន មញ្ញេថ ។

(២៦៣) ស វេ និព្វានសន្តិកេតិ សោ និព្វានស្ស សន្តិកេ សាមន្តា អាសន្នេ អវិទូរេ ឧបកដ្ឋេតិ ស វេ និព្វានសន្តិកេ ។ តេនាហ ភគវា

១ ម. ឯត្ថន្តរេ ថាមំ ន ករេយ្យាតិ ទិស្សតិ ។

(២៦១) ពាក្យថា នុ៎ះជាធម៌ដ៏ឧត្តម របស់ព្រះអរិយៈទាំងឡាយ សេចក្ដីថា ព្រះពុទ្ធទាំងឡាយក្ដី សាវ័កនៃព្រះពុទ្ធទាំងឡាយក្ដី ព្រះបច្ចេកពុទ្ធទាំងឡាយក្ដី លោកហៅថា ព្រះអរិយៈ គុណជាតណាដែលឈ្មោះថាវិវេកចរិយា គុណជាតនុ៎ះ ដ៏លើស ប្រសើរ ខ្ពង់ខ្ពស់ ជាប្រធាន ឧត្តម ថ្លៃថ្លា របស់ព្រះអរិយៈទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) នុ៎ះជាគុណជាតដ៏ឧត្តម របស់ព្រះអរិយៈទាំងឡាយ ។

(២៦២) ពាក្យថា មិនគប្បីសំគាល់ថាខ្លួនប្រសើរ ដោយវិវេកនោះទេ គឺមិនគប្បីធ្វើការតំកើង មិនគប្បីធ្វើអាការឆ្មើងឆ្មៃ មិនគប្បីធ្វើមានះ មិនគប្បីធ្វើសេចក្ដីរឹងត្អឹង ដោយវិវេកចរិយានោះ គឺមិនគប្បីញុំាងមានះឲ្យកើត មិនគប្បីធ្វើការជាប់ចំពាក់ដោយវិវេកនោះ មិនគប្បីជាអ្នករឹងត្អឹង រឹងរូស មានក្បាលងើបឡើងហើយ ដោយវិវេកនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនគប្បីសំគាល់ថាខ្លួនប្រសើរ ដោយវិវេកនោះទេ ។

(២៦៣) ពាក្យថា បុគ្គលនោះ (នឹងឋិតនៅ) ក្នុងទីជិតព្រះនិព្វាន គឺបុគ្គលនោះ (នឹងឋិតនៅ) ក្នុងទីជិត ក្នុងទីជុំវិញ ក្នុងទីអែបនែប ក្នុងទីមិនឆ្ងាយ ក្នុងទីក្បែរព្រះនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ (នឹងឋិតនៅ) ក្នុងទីជិតព្រះនិព្វាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

វិវេកញ្ញេវ សិក្ខេថ ឯតទរិយានមុត្តមំ
តេន សេដ្ឋោ ន មញ្ញេថ ស វេ និព្វានសន្តិកេតិ ។

(២៦៨) រិត្តស្ស មុនិនោ ចរតោ កាមេសុ អនបេក្ខិនោ
ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជា ។

(២៦៩) រិត្តស្ស មុនិនោ ចរតោតិ រិត្តស្សាតិ
រិត្តស្ស វិវិត្តស្ស បវិវិត្តស្ស កាយទុច្ចរិតេន រិត្តស្ស
វិវិត្តស្ស បវិវិត្តស្ស វចីទុច្ចរិតេន មនោទុច្ចរិតេន រា-
គេន ទោសេន មោហេន កោធេន ឧបនាហេន
មក្ខេន បឡាសេន ឥស្សាយ មច្ឆរិយេន មាយាយ
សាឋេយ្យេន ថម្ភេន សារម្ភេន មានេន អតិមានេន
មទេន បមាទេន សព្វកិលេសេហិ សព្វទុច្ចរិតេហិ
សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វា-
កុសលាភិសង្ខារេហិ រិត្តស្ស វិវិត្តស្ស បវិវិត្តស្ស ។
មុនិនោតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានា
។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ ចរតោតិ

បុគ្គលគប្បីសិក្សាវិវេកតែម្យ៉ាង (ព្រោះថាវិវេក) នុ៎ះ ជាធម៌ដ៏ឧត្តម របស់ព្រះអរិយៈទាំងឡាយ បុគ្គល មិនគប្បីសំគាល់ថា ខ្លួនប្រសើរ ដោយវិវេកនោះទេ បុគ្គលនោះ (ទើងឋិតនៅ) ក្នុងទីជិតព្រះនិព្វាន ។

[២៦៨] ប្រជាជន ដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់មុនិ ដែលជាអ្នកទទេ អ្នកប្រព្រឹត្ត អ្នកមិនមានសេចក្តីអាឡោះអាល័យ ក្នុងកាមទាំងឡាយ អ្នកឆ្លងឱឃៈ ។

[២៦៩] អធិប្បាយពាក្យថា មុនិ ជាអ្នកទទេ អ្នកប្រព្រឹត្ត ត្រង់ពាក្យថា ជាអ្នកទទេ គឺជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងៀម គឺថាជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងៀម ចាកកាយទុច្ចរិត ជាអ្នកទទេ ស្ងាត់ ស្ងាត់ស្ងៀម ចាកវចីទុច្ចរិត ចាកមនោទុច្ចរិត ចាករាគៈ ទោសៈ មោហៈ ក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីពេលពលទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ។ ពាក្យថា មុនិ សេចក្តីថា ញាណលោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ មុនិនោះ កន្លងបណ្តាញ គឺគ្រឿងជាប់ចំពាក់ ។ ពាក្យថា អ្នកប្រព្រឹត្ត

ចរតោ វិហរតោ ឥរិយតោ វត្តតោ បាលយតោ យបយតោ យាបយតោតិ វត្តស្ស មុនិនោ ចរតោ ។

(២៦៦) កាមេសុ អនបេក្ខិនោតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវំ គមិត្វា កាមេសុ អនបេក្ខោ[១] ចត្តកាមោ វន្តកាមោ មុត្តកាមោ បហីនកាមោ បដិនិស្សដ្ឋកាមោ ចត្តរាគោ[២] វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ កាមេសុ អនបេក្ខិនោ ។

(២៦៧) ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជាតិ បជាតិ សត្តាធិវចនំ ។ បជា កាមេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា

១ ម. អនបេក្ខមានោ ។ ២ ឱ. វិតរាគោ ។ ម. វីតរាគោ ចត្តរាគោ ។

អ្នកប្រព្រឹត្តសម្រាក សម្រាន្ត សម្រេចសិរិយាបថ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ ជាអ្នកទទេ អ្នកប្រព្រឹត្ត ។

[២៦៦] អធិប្បាយពាក្យថា អ្នកមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាមទាំងឡាយ បើតាមឧទ្ទាន បាន ដល់កាម ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថាវត្ថុកាម ។ បេ ។ នេះ ហៅថាកិលេសកាម ។ បុគ្គលកំណត់ដឹងវត្ថុកាម លះបង់កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេស–កាម មិនមានអាល័យក្នុងកាម មានកាមលះចោល មានកាមខ្ជាក់ចោល មានកាមដោះរួច មានកាមលះបង់ មានកាមរលាស់ចោលហើយ មានរាគៈលះបង់ មានរាគៈខ្ជាក់ចោល មានរាគៈដោះរួច មានរាគៈលះបង់ មានរាគៈរលាស់ចោលហើយ មិនមានប្រាថ្នា មានទុក្ខរលត់ ជាអ្នកមានចិត្តត្រជាក់ ទទួលសេចក្តីសុខ មានចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានសេចក្តីអាឡោះអាល័យ ក្នុងកាមទាំងឡាយ ។

[២៦៧] អធិប្បាយពាក្យថា ប្រជាជនដែលជាប់ចំពាក់ ក្នុងកាមទាំងឡាយ រមែងស្រឡាញ់ (មុនិ) អ្នកឆ្លងឱឃៈ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះរបស់សត្វ ។ ប្រជាជនត្រេកអរ ជាប់ចំពាក់ ជាប់ជំពាក់ ជាប់ចុះ នៅល់នៅ ជ្រួលជ្រប់ ពាក់ ចូក ព័ន្ធព័ទ្ធ ក្នុងកាម

## សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ

បលិពុទ្ធា តា (១) កាមោឃំ តិណ្ណស្ស ភវោឃំ តិណ្ណស្ស ទិដ្ឋោឃំ តិណ្ណស្ស អវិជ្ជោឃំ តិណ្ណស្ស សព្វសំសារបថំ (២) តិណ្ណស្ស ឧត្តិណ្ណស្ស និត្តិណ្ណស្ស អតិក្កន្តស្ស សមតិក្កន្តស្ស វីតិវត្តស្ស អន្តគតស្ស អន្តប្បត្តស្ស កោដិគតស្ស កោដិប្បត្តស្ស បរិយន្តគតស្ស បរិយន្តប្បត្តស្ស វោសានគតស្ស វោសានប្បត្តស្ស តាណគតស្ស តាណប្បត្តស្ស លេណគតស្ស លេណប្បត្តស្ស សរណគតស្ស សរណប្បត្តស្ស អភយគតស្ស អភយប្បត្តស្ស អច្ចុតគតស្ស អច្ចុតប្បត្តស្ស អមតគតស្ស អមតប្បត្តស្ស និព្វានគតស្ស និព្វានប្បត្តស្ស ឥច្ឆន្តិ សាទិយន្តិ បត្ថយន្តិ បិហយន្តិ អភិជប្បន្តិ ។ យថា ឥណាយិកា (៣) អាណណ្យំ បត្ថេន្តិ បិហយន្តិ យថា អាពាធិកា អារោគ្យំ បត្ថេន្តិ បិហយន្តិ យថា ពន្ធនពទ្ធា ពន្ធនមោក្ខំ បត្ថេន្តិ បិហយន្តិ យថា ទាសា ភុជិស្សំ បត្ថេន្តិ

១ ម. តេ ។ ២ ឧ. សព្វសង្ខារបថំ ។ ម. សព្វសង្ខារបុញ្ជំ ។ ៣ ម. ឥណាទាយិកា ។

ប្រជាជនទាំងនោះ រមែងប្រាថ្នា ត្រេកអរ រាប់រក ស្រឡាញ់ ក្តួចកាន់ (ចំពោះមុនិ) ដែលឆ្លងអន្លង់គឺកាម ឆ្លងអន្លង់គឺភព ឆ្លងអន្លង់គឺទិដ្ឋិ ឆ្លងអន្លង់គឺអវិជ្ជា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង ឈានកន្លង ប្រព្រឹត្តកំលងនូវផ្លូវនៃសង្សារទាំងពួង ជាអ្នកទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅហើយកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីជាទីចប់ស្រេច ដល់ទីជាទីចប់ស្រេច ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ។ ពួកជនអ្នកជំពាក់បំណុល រមែងប្រាថ្នា ស្រឡាញ់ នូវភាពជាអ្នកមិនមានបំណុល យ៉ាងណា ពួកជនមានជម្ងឺ រមែងប្រាថ្នា ស្រឡាញ់ នូវភាពជាអ្នកមិនមានរោគ យ៉ាងណា ពួកជនដែលជាប់ចំណង រមែងប្រាថ្នា ស្រឡាញ់ នូវការរួចចាកចំណង យ៉ាងណា ពួកជនជាទាសៈ រមែងប្រាថ្នា ស្រឡាញ់ នូវភាពនៃខ្លួនជាអ្នកជា យ៉ាងណា ពួកជន

បិហយន្តិ យថា កន្តារទ្ធានបក្ខន្ទា[១] ខេមន្តភូមឹ បត្ថេន្តិ បិហយន្តិ ឯវមេវ បជា កាមេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា[២] លគ្គា លគ្គិតា បលិពុទ្ធា តា[៣] កាមោឃតិណ្ណស្ស ភវោឃតិណ្ណស្ស ។ បេ ។ និព្វានគតស្ស និព្វានប្បត្តស្ស ឥច្ឆន្តិ សាទិយន្តិ បត្ថយន្តិ បិហយន្តិ អភិជប្បន្តិ ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជា ។ តេនាហ ភគវា

រិត្តស្ស មុនិនោ ចរតោ កាមេសុ អនបេក្ខិនោ
ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជាតិ ។

១ ម. បក្ខន្នា ។ ២ ម. អជ្ឈោសន្នា ។ ៣ ម. តេ ។

សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ និដ្ឋិតោ ។

ដែលចេញទៅ កាន់ផ្លូវឆ្ងាយដាច់ស្រយាល រមែងប្រាថ្នា ស្រឡាញ់ ទីដ៏ក្រៀម យ៉ាងណា ពួកប្រជាជន ត្រេកអរ ជាប់ចំពាក់ ធ្លាក់ចុះ ង៉ុលង៉ប់ ជ្រុលជ្រប់ ពាក់ ជ្ពក់ ព័ន្ធព័ទ្ធ ក្នុងកាមទាំងឡាយ ប្រជាជន ទាំងនោះ រមែងប្រាថ្នា ត្រេកអរ រាប់រក កួចកាន់ ( ចំពោះមុន៑ ) ដែលធ្លង់អន្លង់គឺកាម ធ្លង់អន្លង់គឺភព ។ បេ ។ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រជាជន ដែលជាប់ចំពាក់ក្នុងកាមទាំងឡាយ រមែងស្រឡាញ់មុន៑ អ្នកធ្លង់ឱឃៈ ។

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ប្រជាជន ដែលជាប់ចំពាក់ ក្នុងកាមទាំងឡាយ រមែង
ស្រឡាញ់មុន៑ ដែលជាអ្នកទទេ អ្នកប្រព្រឹត្ត អ្នកមិនមាន
សេចក្ដីអាឡោះអាល័យ ក្នុងកាមទាំងឡាយ អ្នកធ្លង់ឱឃៈ ។

ចប់ តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧ ។

# អដ្ឋមោ បសូរសុត្តនិទ្ទេសោ

[២៦៨] ឥធេវ សុទ្ធិ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
យំ និស្សិតា តត្ថ សុភាវទានា
បច្ចេកសច្ចេសុ បុថូ និវិដ្ឋា ។

[២៦៩] ឥធេវ សុទ្ធិ ឥតិ វាទយន្តីតិ ឥធេវ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា

# បសូរសុត្តនិទ្ទេស ទី ៨

(២៦៨) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ពួកសមណព្រាហ្មណ៍ ដ៏ច្រើន តែងពោលនូវការស្អាត ក្នុងធម៌របស់ខ្លួននេះ មិនពោលនូវការស្អាត ក្នុងធម៌ដទៃ អាស្រ័យសភាវៈណា រមែងពោលថាល្អក្នុងសភាវៈនោះ ជាអ្នកតាំងនៅមាំក្នុងពួកសច្ចៈ ដោយឡែក ៗ

(២៦៩) ពាក្យថា តែងពោលនូវការស្អាត ក្នុងធម៌របស់ខ្លួននេះ អធិប្បាយថា (សមណព្រាហ្មណ៍ទាំងឡាយ) តែងពោល សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ក្នុងធម៌នេះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោល សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វបន្ទាប់អំពីសេចក្ដីស្លាប់ កើតទៀតក៏មាន សត្វបន្ទាប់អំពីសេចក្ដីស្លាប់ មិនកើតទៀតក៏មាន សត្វបន្ទាប់អំពីសេចក្ដីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន

នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឥធេវ សុទ្ធិំ ឥតិ វាទយន្តិ ។

[២៧០] នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហូតិ អត្តនោ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋិំ បដិបទំ មគ្គំ ឋបេត្វា សព្វេ បរវាទេ ខិបន្តិ ឧក្ខិបន្តិ បរិក្ខិបន្តិ សោ សត្ថា ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្បដិបន្នោ ទិដ្ឋិ ន ភទ្ទិកា បដិបទា ន សុប្បញ្ញត្តា មគ្គោ ន និយ្យានិកោ នត្ថេត្ថ សុទ្ធិ វា វិសុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា ន ឥត្ថ(១) សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ ឯវមាហំសុ ឯវំ កថេន្តិ(២) ឯវំ ភណន្តិ

---

១ ខ. នត្ថេត្ថ ។ ២ ម. ឯវំ វទន្តិ ឯវំ កថេន្តិ ។

សត្វបន្ទាប់អំពីសេចក្តីស្លាប់ មិនកើតទៀតក៏មិនមែន កើតទៀតក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃ ជាមោឃៈ បានពោលសំដែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) តែងពោលនូវការស្អាត ក្នុងធម៌របស់ខ្លួននេះ ។

(២៧០) ពាក្យថា មិនពោលនូវការស្អាតក្នុងធម៌ដទៃ គឺលើកតំកើងនូវគ្រូរបស់ខ្លួន នូវធម៌ដែលគ្រូនោះពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទានិងមគ្គ ហើយបោះចោល លើកចោល ទំលាក់ចោលនូវវាទៈដទៃទាំងអស់ថា សាស្តានោះ មិនមែនជាសព្វញ្ញូ ធម៌សាស្តានោះ មិនមែនសំដែងដោយប្រពៃទេ គណៈមិនមែនប្រតិបត្តិដោយប្រពៃទេ ទិដ្ឋិ មិនមែនចំរើនទេ បដិបទា មិនមែនបញ្ញត្តដោយប្រពៃទេ មគ្គ មិនមែនជាទីស្រោចស្រង់សត្វទេ ការស្អាត ឬស្អាតវិសេស ឬសេចក្តីបរិសុទ្ធ ការរួច ឬរួចវិសេស ឬរួចស្រឡះ មិនមានក្នុងធម៌នុ៎ះឡើយ ពួកសត្វរមែងមិនស្អាត ឬមិនស្អាតវិសេស ឬមិនបរិសុទ្ធ មិនរួច ឬមិនរួចវិសេស ឬមិនរួចស្រឡះ ក្នុងធម៌នុ៎ះឡើយ ទិដ្ឋិនោះថោកទាប ទន់អន់ ទន់ទាប លាមក អាក្រក់ តិចតួច ពួកសមណព្រាហ្មណ៍ពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ

ឯវំ ទីបយន្តិ ឯវំ វោហរន្តិ នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ ។

(២៧១) យំ និស្សិតា តត្ថ សុភំវទានាតិ យំ និស្សិតាតិ យំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ និស្សិតា សន្និស្សិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ សុភំវទានាតិ សុភវាទា សោភនវាទា បណ្ឌិតវាទា ធីរវាទា ញាយវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ យំ និស្សិតា តត្ថ សុភំវទានា ។

(២៧២) បច្ចេកសច្ចេសុ បុថូ និវិដ្ឋាតិ បុថូ សមណព្រាហ្មណា បុថុបច្ចេកសច្ចេសុ និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា

ថ្លែងយ៉ាងនេះ ដោយប្រការដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនពោលនូវការស្អាតក្នុងធម៌ដទៃ ។

(២៧១) អធិប្បាយពាក្យថា អាស្រ័យសភាវៈណា រមែងពោលថាល្អក្នុងសភាវៈនោះ គ្រង់ពាក្យថា អាស្រ័យសភាវៈណា គឺអាស្រ័យពឹងផ្អែក ជាប់ស្អិត ដល់ស៊ប់ ចុះស៊ប់ ជឿជាក់នូវគ្រូ ធម៌ដែលគ្រូនោះពោលហើយ គណៈ ទិដ្ឋិ បដិបទា មគ្គណា ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន ។ ពាក្យថា ពោលថាល្អ គឺពោលថាល្អ ពោលថាស្អាត ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថារបស់គួរដឹង ពោលថាជាហេតុ ពោលថាជាលក្ខណៈ ពោលថាជាការណ៍ ពោលថាជាឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យសភាវៈណា រមែងពោលថាល្អ ក្នុងសភាវៈនោះ ។

(២៧២) ពាក្យថា ពួកសមណព្រាហ្មណ៍ ដ៏ច្រើន ជាអ្នកតាំងនៅមាំ ក្នុងពួកសច្ចៈដោយឡែក សេចក្តីថា ពួកសមណព្រាហ្មណ៍ដ៏ច្រើន ជាអ្នកមុតមាំ តាំងនៅ ជាប់ស្អិត ដល់ស៊ប់ ចុះស៊ប់ ជឿជាក់ក្នុងពួកសច្ចៈ ដោយឡែកដ៏ច្រើន គឺជាអ្នកមុតមាំ តាំងនៅជាប់ស្អិត ដល់ស៊ប់ ចុះស៊ប់ ជឿជាក់ថា លោកទៀង នេះជាពាក្យពិត ពាក្យដទៃជាមោឃៈ

អធិមុត្តា អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ បច្ចេកសច្ចេសុ បុថុ និវិដ្ឋា ។ តេនាហ ភគវា

ឥធេវ សុទ្ធី ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
យំ និស្សិតា តត្ថ សុភាវទានា
បច្ចេកសច្ចេសុ បុថុ និវិដ្ឋាតិ ។

[២៧៣] តេ វាទកាមា បរិសំ វិគយ្ហ
ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ
វទន្តិ តេ អញ្ញសិតា កថោជ្ជំ
បសំសកាមា កុសលាវទានា ។

[២៧៤] តេ វាទកាមា បរិសំ វិគយ្ហាតិ តេ វាទកាមាតិ តេ វាទកាមា វាទត្ថិកា វាទាធិប្បាយា វាទបុរេក្ខារា

ជាអ្នកមុតមាំ តាំងនៅ ជាប់ស្អិត ដល់ស៊ប់ ជឿជាក់ថា លោកមិនទៀង ។ បេ ។ សត្វបន្ទាប់អំពីសេចក្តីស្លាប់ កើតទៀតក៏មានមែន មិនកើតទៀតក៏មិនមែន នេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសមណព្រាហ្មណ៍ដ៏ច្រើន ជាអ្នកតាំងនៅមាំ ក្នុងពួកសច្ចៈដោយឡែក ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកសមណព្រាហ្មណ៍ដ៏ច្រើន តែងពោលនូវការស្អាត ក្នុងធម៌របស់ខ្លួននេះ មិនពោលនូវការស្អាត ក្នុងធម៌ដទៃ អាស្រ័យសភាវៈណា រមែងពោលថាល្អ ក្នុងសភាវៈនោះ ជាអ្នកតាំងនៅមាំ ក្នុងពួកសច្ចៈដោយឡែក ៗ

(២៧៣) ជនទាំងនោះ ជាអ្នកប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ជាជនមានគូ ផ្តុតគ្នាទៅវិញទៅមក ថាពាល ជនទាំងនោះ អាស្រ័យសភាពដទៃ ពោលពាក្យឥតគុណថា ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ។

(២៧៤) អធិប្បាយពាក្យថា ជនទាំងនោះ ប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ត្រង់ពាក្យថា ជនទាំងនោះប្រាថ្នាវាទៈ គឺជនទាំងនោះ ប្រាថ្នានូវវាទៈ ត្រូវការដោយវាទៈ ប៉ុនប៉ងនូវវាទៈ ធ្វើវាទៈឲ្យតាំងនៅខាងមុខ

វាទបរិយេសនំ ចរន្តា ។ បរិសាយ វិគ្គយ្ហាតិ ខត្តិយបរិសាយ ព្រាហ្មណបរិសាយ គហបតិបរិសាយ សមណបរិសាយ វិគ្គយ្ហ ឱគយ្ហ អជ្ឈោគហេត្វា បវិសិត្វាតិ តេ វាទកាមា បរិសាយ វិគ្គយ្ហ ។

(២៧៥) ពាលំ ទហន្តិ មិថុ អញ្ញមញ្ញន្តិ មិថូតិ ទ្វេ ជនា ទ្វេ កលហការកា ទ្វេ ភណ្ឌនការកា ទ្វេ ភស្សការកា ទ្វេ វិវាទការកា ទ្វេ អធិករណការកា ទ្វេ វាទិនោ ទ្វេ សល្លាបកា តេ អញ្ញមញ្ញំ ពាលតោ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ ទហន្តិ បស្សន្តិ ទក្ខន្តិ ឱលោកេន្តិ និជ្ឈាយន្តិ(១) ឧបបរិក្ខន្តីតិ ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ ។

(២៧៦) វទន្តិ តេ អញ្ញសិតា កថោជ្ជន្តិ អញ្ញំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ និស្សិតា សន្និស្សិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា ។ កថោជ្ជំ វុច្ចតិ កលហោ ភណ្ឌនំ វិគ្គហោ វិវាទោ មេធគំ ។ អថវា កថោជ្ជន្តិ អនោជវន្តី

---

១ ឱ. និជ្ឈាយន្តិ ។

ត្រាប់ទៅស្វែងរកវាទៈ ៗ ពាក្យថា ចុះកាន់បរិស័ទ គឺចុះទៅ លុកទៅ ចុះសំដៅ ចូលទៅរកខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតិ-បរិស័ទ សមណបរិស័ទ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ៗ

[២៧៥] អធិប្បាយពាក្យថា ជាជនមានគូ ជុតគ្នាទៅវិញទៅមក ថាពាល ត្រង់ពាក្យថា ជាជនមានគូ គឺគ្នាពីរនាក់ គឺថាអ្នកធ្វើនូវជំ-ឈោះពីរនាក់ អ្នកធ្វើនូវការប្រកួតប្រកាន់ពីរនាក់ អ្នកធ្វើនូវតិរច្ឆាន-កថាពីរនាក់ អ្នកធ្វើនូវវិវាទពីរនាក់ អ្នកធ្វើនូវអធិករណ៍ពីរនាក់ អ្នកឡោកនិយាយពីរនាក់ អ្នកចរចាទៅមកពីរនាក់ ជនទាំងនោះ តែងជុត មើលឃើញ ក្រឡេកមើល សំឡឹងមើល ពិចារណាមើលនូវគ្នានឹងគ្នា ថាពាលថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច ហេតុនោះ (ទ្រង់ត្រាស់ថា) ជាជនមានគូ ជុតនូវគ្នាទៅវិញទៅមក ថាពាល ៗ

[២៧៦] ពាក្យថា ជនទាំងនោះ អាស្រ័យសភាវៈដទៃ ពោលពាក្យឥតឱជា គឺអាស្រ័យ ពឹងផ្អែក ជាប់ស្អិត ដល់ស៊ប់ ចុះស៊ប់ ជឿជាក់នូវសាស្តា ធម៌ដែលសាស្តានោះសំដែងហើយ គណៈ ទិដ្ឋិ បដិបទា មគ្គដទៃ ៗ ការឈ្លោះ ប្រកួតប្រកាន់ ទាស់ទែង វិវាទ បែកខ្ញែកគ្នា លោកហៅថា ពាក្យឥតឱជា ៗ មួយទៀត ពាក្យថា ពាក្យឥតឱជា

សា កថា ។ កថោជ្ជំ វទន្តិ កលហំ វទន្តិ ភណ្ឌនំ វទន្តិ វិគ្គហំ វទន្តិ វិវាទំ វទន្តិ មេធគំ វទន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ វទន្តិ តេ អញ្ញសិតា កថោជ្ជំ ។

(២៧៧) បសំសកាមា កុសលាវទានាតិ បសំសកាមាតិ បសំសកាមា បសំសត្ថិកា បសំសាភិប្បាយា បសំសបុរេក្ខារា បសំសបរិយេសនំ ចរន្តា ។ កុសលាវទានាតិ កុសលវាទា បណ្ឌិតវាទា ធីរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ បសំសកាមា កុសលាវទានា ។ តេនាហ ភគវា

តេ វាទកាមា បរិសំ វិគយ្ហ
ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ
វទន្តិ តេ អញ្ញសិតា កថោជ្ជំ
បសំសកាមា កុសលាវទានាតិ ។

គឺសំដីនោះ មិនមានឱជា ។ ជនទាំងនោះ ពោលពាក្យ មិនមានឱជារស គឺពោលជំលោះ ពោលការប្រកួតប្រកាន់ ពោលការទាស់ទែង ពោលវិវាទ ពោល ពណ៌នា បក្ខ ថ្លែង នូវការបែកខ្ញែកគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ អាស្រ័យសការៈដទៃ ពោលពាក្យឥតឱជា ។

(២៧៧) ពាក្យថា ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ត្រង់ពាក្យថា ជាអ្នកប្រាថ្នាការសរសើរ គឺប្រាថ្នាការសរសើរ ត្រូវការការសរសើរ ប៉ុនប៉ងការសរសើរ ធ្វើការសរសើរ ឲ្យតាំងនៅខាងមុខ ត្រាច់ស្វែងរកការសរសើរ ។ ពាក្យថា ជាអ្នកមានវាទៈដ៏ឈ្លាស គឺ មានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈជាហេតុ មានវាទៈជាលក្ខណៈ មានវាទៈជាការណ៍ មានវាទៈជាឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកប្រាថ្នាការសរសើរ មានវាទៈដ៏ឈ្លាស ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជនទាំងនោះ ជាអ្នកប្រាថ្នាវាទៈ ចុះកាន់បរិស័ទ ជាជនមាន
គូ ដុតគ្នាទៅវិញទៅមក ថាពាល ជនទាំងនោះ អាស្រ័យ
សការៈដទៃ ពោលពាក្យឥតឱជា ជាអ្នកប្រាថ្នាការសរសើរ
មានវាទៈដ៏ឈ្លាស ។

(២៧៨) យុត្តា កថាយំ បរិសាយ មជ្ឈេ
បសំសមិច្ឆំ វិនិឃាតិ ហោតិ
អបាហតស្មឹ បន មង្កុ ហោតិ
និន្ទាយ សោ កុប្បតិ រន្ធមេសី ។

(២៧៩) យុត្តា កថាយំ បរិសាយ មជ្ឈេតិ ខត្តិយបរិសាយ វា ព្រាហ្មណបរិសាយ វា គហបតិបរិសាយ វា សមណបរិសាយ វា មជ្ឈេ អត្តនោ កថាយំ យុត្តា បយុត្តា អាយុត្តា សមាយុត្តា សម្បយុត្តា កថេតុន្តិ យុត្តា កថាយំ បរិសាយ មជ្ឈេ ។

(២៨០) បសំសមិច្ឆំ វិនិឃាតិ ហោតីតិ បសំសមិច្ឆន្តិ បសំសំ ថោមនំ កិត្តឹ វណ្ណហារិយំ ឥច្ឆន្តោ សាទិយន្តោ បត្ថយន្តោ បិហយន្តោ អភិជប្បន្តោ ។ វិនិឃាតិ ហោតីតិ បុព្វេវ សល្លាបា កថំកថី វិនិឃាតិ ហោតិ ជយោ នុ ខោ មេ ភវិស្សតិ បរាជយោ នុ ខោ មេ ភវិស្សតិ កថំ និគ្គហំ ករិស្សាមិ កថំ បដិកម្មំ ករិស្សាមិ កថំ វិសេសំ ករិស្សាមិ កថំ បដិវិសេសំ ករិស្សាមិ

## បសូរសុត្តនិទ្ទេស ទី ៨

(២៧៨) បុគ្គលណា ប្រកបការពោល ក្នុងកណ្ដាលបរិស័ទ ប្រាថ្នាសេចក្ដីសរសើរ បុគ្គលនោះ រមែងបង្អៀតបិត្ត កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹង ព្រោះការនិន្ទា ។

(២៧៩) ពាក្យថា ប្រកបការពោលក្នុងកណ្ដាលបរិស័ទ គឺប្រកប ប្រកបរឿយ ៗ ប្រកបទួទៅ ប្រកបទួទៅព្រម ប្រកបរឿយៗព្រម ក្នុងពាក្យរបស់ខ្លួន ដើម្បីពោល ក្នុងកណ្ដាលខត្តិយបរិស័ទក្ដី ព្រាហ្មណ-បរិស័ទក្ដី គហបតិបរិស័ទក្ដី សមណបរិស័ទក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រកបការពោល ក្នុងកណ្ដាលបរិស័ទ ។

(២៨០) អធិប្បាយពាក្យថា ប្រាថ្នាសេចក្ដីសរសើរ បុគ្គលនោះ រមែងបង្អៀតបិត្ត ត្រង់ពាក្យថា ប្រាថ្នាសេចក្ដីសរសើរ គឺប្រាថ្នា ត្រេកអរ ប៉ុនប៉ង ស្រឡាញ់ ជាប់ចិត្ត នូវសេចក្ដីសរសើរ សេចក្ដីស្ញើច កេរ្តិ៍ឈ្មោះ សេចក្ដីចំរើនដោយគុណ ។ ពាក្យថា រមែងបង្អៀតបិត្ត គឺមានសេចក្ដីសង្ស័យនឹងការបរាជ រមែងបង្អៀតបង្អល់មុនថា អាត្មាអញ នឹងមានជ័យឬ ឬថាអាត្មាអញ នឹងបរាជ័យ អាត្មាអញ នឹងធ្វើការផ្ចាញ់ផ្ចាល់ដូចម្ដេចហ្ន៎ នឹងធ្វើការបន្ទយដូចម្ដេចហ្ន៎ នឹងធ្វើឲ្យវិសេស ដូចម្ដេចហ្ន៎ នឹងធ្វើឲ្យវិសេសតបវិញ ដូចម្ដេចហ្ន៎

គាថំ អាវេណិយំ ការិស្សាមិ គាថំ និវេទនិយំ ការិស្សាមិ គាថំ ឆេទំ ការិស្សាមិ គាថំ មណ្ឌលំ ការិស្សាមីតិ ឃរំ បុរេត្វា សល្លាភា គាថំគាថី វិរិយាតិ ហោតីតិ បសំសមិច្ឆុំ វិរិយាតិ ហោតិ ។

[២៨១] អធាហាតស្មឹ បន មុញ្ញំ ហោតីតិ យេ តេ បញ្ហាវីមំសកា(១) ការិស្សា ភាសនិកា(២) តេ អបហារន្តិ អត្ថាបគតំ ករណិតន្តិ អត្ថតោ អបហារន្តិ ព្យញ្ជនាបគតំ ករណិតន្តិ ព្យញ្ជនតោ អបហារន្តិ អត្ថ-ព្យញ្ជនាបគតំ ករណិតន្តិ អត្ថព្យញ្ជនតោ អបហារន្តិ អត្ថោ តេ ទុដ្ឋតោ ព្យញ្ជនន្តេ ទុរោបិតំ អត្ថព្យញ្ជនន្តេ ទុដ្ឋិតំ ទុរោបិតំ និគ្គហោ តេ អគតោ បដិកម្មន្តេ ទុក្កដំ វិសេសោ តេ អគតោ បដិវិសេសោ តេ ទុក្ក-ដោ អាវេណិយោ តេ អភតា និវេទនិយា តេ ទុក្កដា ឆេទោ តេ អភតោ មណ្ឌលន្តេ ទុក្កដំ ទុក្កថិតំ ទុគ្គណិតំ ទុល្លបិតំ ទុរុត្តំ ទុព្ភាសិតន្តិ អបហារន្តិ ។

---

១ ម. បញ្ហោវីមំសកា ។ ២ ម. ញាសាទិកា ។

នឹងធ្វើឲ្យផ្ទុះធ្លាយដូចម្ដេចហ្ន៎ នឹងធ្វើឲ្យផ្ទុះធ្លាយរហូតដូចម្ដេចហ្ន៎ នឹងធ្វើឲ្យដាច់ដូចម្ដេចហ្ន៎ នឹងធ្វើឲ្យមានមណ្ឌលដូចម្ដេចហ្ន៎ ជាអ្នកមានសេចក្ដីសង្ស័យនឹងការចរចា រមែងចង្អៀតចង្អល់មុនយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាជ្ញាសេចក្ដីសរសើរ បុគ្គលនោះ រមែងចង្អៀតចិត្ត ។

(៤៨១) ពាក្យថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ អធិប្បាយថា ពួកជនណា ជាបរិស័ទ អ្នកពិចារណានូវប្រស្នា មានសេចក្ដីអាណិត ជនទាំងនោះ តែងបំបាត់ គឺបំបាត់ព្រោះអត្ថថា លោកពោល ប្រាសចាកអត្ថ បំបាត់ព្រោះព្យញ្ជនៈថា លោកពោល ប្រាសចាកព្យញ្ជនៈ បំបាត់ព្រោះអត្ថនឹងព្យញ្ជនៈថា លោកពោល ប្រាសចាកអត្ថនឹងព្យញ្ជនៈ បំបាត់ថា អត្ថ លោកនាំចេញខុស ព្យញ្ជនៈ លោកលើកឡើងខុស អត្ថនឹងព្យញ្ជនៈ លោកនាំចេញខុស លើកឡើងខុស លោកធ្វើការសង្កត់សង្កិនមិនកើតទេ លោកធ្វើការបន្ថយខុស លោកធ្វើឲ្យវិសេសមិនកើតទេ លោកធ្វើឲ្យវិសេសតបវិញខុស លោកធ្វើឲ្យផ្ទុះធ្លាយមិនកើតទេ លោកធ្វើឲ្យផ្ទុះធ្លាយរហូតខុស លោកធ្វើឲ្យដាច់មិនកើតទេ លោកធ្វើឲ្យមានមណ្ឌលខុស សំដែងមិនល្អទេ ពណ៌នាមិនល្អទេ ចរចាមិនល្អទេ និយាយមិនល្អទេ ថ្លែងមិនល្អទេ ។

អបាហតស្មឹ បន មង្កុ ហោតីតិ អបាហតស្មឹ មង្កុ ហោតិ បីឡិតោ ឃដ្ដិតោ ព្យថិតោ[១] ទោមនស្សិតោ ហោតីតិ អបាហតស្មឹ បន មង្កុ ហោតិ ។

(២៨២) និន្ទាយ សោ កុប្បតិ រន្ធមេសីតិ និន្ទាយាតិ និន្ទាយ គរហាយ អកិត្តិយា អវណ្ណហារិកាយ ។ កុប្បតីតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតីតិ និន្ទាយ សោ កុប្បតិ ។ រន្ធមេសីតិ រន្ធមេសី វិរន្ធមេសី អបរន្ធមេសី ខលិតមេសី គឡិតមេសី វិវរមេសីតិ និន្ទាយ សោ កុប្បតិ រន្ធមេសី ។

តេនាហ ភគវា

យុត្តា កថាយំ បរិសាយ មជ្ឈេ
បសំសមិច្ឆំ វិនិឃាតិ ហោតិ
អបាហតស្មឹ បន មង្កុ ហោតិ
និន្ទាយ សោ កុប្បតិ រន្ធមេសីតិ ។

១ ម. ព្យធិតោ ។

ពាក្យថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ បានសេចក្ដីថា កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ គឺ មានសេចក្ដីលំបាកចិត្ត បង្អៀតបង្អល់ចិត្ត តឹងចិត្ត ទោមនស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ ។

(៤៨២) អធិប្បាយពាក្យថា បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹងព្រោះការនិន្ទា ត្រង់ពាក្យថា ព្រោះការនិន្ទា គឺព្រោះការនិន្ទា ព្រោះការតិះដៀល ព្រោះការបន្ទាប ព្រោះការមិនចំរើនដោយគុណ ។ ពាក្យថា រមែងខឹង គឺរមែងខឹង ប្រទូស្ត ក្រេវក្រោធ ធ្វើសេចក្ដីក្រោធផង ទោសៈផង សេចក្ដីមិនត្រេកអរផង ឲ្យប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ រមែងខឹង ព្រោះការនិន្ទា ។ ពាក្យថា ស្វែងរកទោស គឺស្វែងរកទោស ស្វែងរកទោសផ្សេងៗ ស្វែងរកកំហុស ស្វែងរកសេចក្ដីកាំងក្លាត ស្វែងរកសេចក្ដីឃ្លៀងឃ្លាត ស្វែងរកចន្លោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹង ព្រោះការនិន្ទា ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> បុគ្គលណា ប្រកបការពោល ក្នុងកណ្ដាលបរិស័ទ ប្រាថ្នាសេចក្ដីសរសើរ បុគ្គលនោះ រមែងបង្អៀតចិត្ត កាលបើគេបំបាត់សំដីហើយ រមែងអៀនអន់ បុគ្គលអ្នកស្វែងរកទោសនោះ រមែងខឹង ព្រោះការនិន្ទា ។

(២៨៣) យមស្ស វាទំ បរិហីនមាហុ
អបាហតំ បញ្ហវីមំសកា យេ
បរិទេវតិ សោចតិ ហីនវាទោ
ឧបច្ចគា មន្តិ អនុត្ថុនាតិ ។

(២៨៤) យមស្ស វាទំ បរិហីនមាហូតិ យំ តស្ស វាទំ ហីនំ និហីនំ បរិហីនំ បរិហាបិតំ ន បរិបូរិតំ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ យមស្ស វាទំ បរិហីនមាហុ ។

(២៨៥) អបាហតំ បញ្ហវីមំសកា យេតិ យេ តេ បញ្ហវីមំសកា បារិសជ្ជា បាសនិកា តេ អបហរន្តិ អត្ថាបគតំ ភណិតន្តិ អត្ថតោ អបហរន្តិ ព្យញ្ជនាបគតំ ភណិតន្តិ ព្យញ្ជនតោ អបហរន្តិ អត្ថព្យញ្ជនាបគតំ ភណិតន្តិ អត្ថព្យញ្ជនតោ អបហរន្តិ អត្ថោ តេ ទុន្នីតោ ព្យញ្ជនន្តេ ទុរោបិតំ អត្ថព្យញ្ជនន្តេ ទុន្នីតំ ទុរោបិតំ និគ្គហោ តេ អកតោ បដិកម្មន្តេ ទុក្កដំ វិសេសោ

(៤៨៣) ពួកជន អ្នកពិចារណាប្រស្នា បានពោលវាទៈ របស់ជននោះ ថាថោកទាប ថាគួរបំបាត់ចោល បុគ្គលអ្នកមានវាទៈថោកទាប រមែងយំរៀបរាប់ សោកស្តាយ ត្អូញត្អែរថា គេកន្លងអាត្មាអញ ។

(៤៨៤) ពាក្យថា ពោលវាទៈ របស់ជននោះ ថាថោកទាប គឺពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវវាទៈ របស់បុគ្គលនោះ ថាថោកទាប ទន់អន់ ទន់ទាប សាបសូន្យ មិនបរិបូណ៌ ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលវាទៈ របស់ជននោះ ថាថោកទាប ។

(៤៨៥) ពាក្យថា ពួកជន អ្នកពិចារណានូវប្រស្នា...ថា គួរបំបាត់ចោល គឺពួកបរិស័ទណា ជាអ្នកពិចារណាប្រស្នា មានសេចក្តីអាណិត ពួកបរិស័ទនោះ តែងបំបាត់ គឺបំបាត់ព្រោះអត្ថថា លោកពោលប្រាសចាកអត្ថ បំបាត់ព្រោះព្យញ្ជនៈថា លោកពោលប្រាសចាកព្យញ្ជនៈ បំបាត់ព្រោះអត្ថនិងព្យញ្ជនៈថា លោកពោលប្រាសចាកអត្ថនិងព្យញ្ជនៈ បំបាត់ថា អត្ថលោកនាំចេញខុស ព្យញ្ជនៈលោកលើកឡើងខុស អត្ថនិងព្យញ្ជនៈ លោកនាំចេញខុស លើកឡើងខុស លោកធ្វើការសង្កត់សង្កិនមិនកើតទេ ធ្វើការបន្ទយខុស លោកធ្វើឲ្យវិសេសមិនកើតទេ

តេ អត្ថតោ បដិវិសេសេន តេ ទុក្កដោ អាវេធិយា តេ អត្ថតោ និព្ពេធិយា តេ ទុក្កដា ជេនោ តេ អត្ថតោ មណ្ឌលវេត្តិ ទុក្កដំ ទុក្កថិតំ ទុព្ភណិតំ ទុល្លបិតំ ទុរុត្តំ ទុព្ភាសិតន្តិ អបហរន្តិ អបាហតំ បញ្ហវីមំសកា យេ ។

[២៨៦] បរិទេវតិ សោចតិ ហីនវាទោតិ បរិទេវតីតិ អញ្ញំ មយា អាវជ្ជិតំ អញ្ញំ ចិន្តិតំ អញ្ញំ ឧបធារិតំ អញ្ញំ ឧបលក្ខិតំ សោ មហាបក្ខោ មហាបរិសោ មហាបរិវារោ បរិសា ចាយំ វគ្គា ន សមគ្គា សមគ្គាយ ហោតុ[១] វាចាសល្លាបោ បុន ករិស្សាមីតិ យោ ឯវរូបោ វាចាបលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តន្តិ បរិទេវតិ ។ សោចតីតិ តស្ស ជយោតិ សោចតិ មយ្ហំ បរាជយោតិ សោចតិ តស្ស លាភោតិ សោចតិ មយ្ហំ អលាភោតិ សោចតិ តស្ស យសោតិ សោចតិ មយ្ហំ អយសោតិ សោចតិ

---

១ ម. បរិសាយ ហោតុ ។

លោកធ្វើឲ្យវិសេសតបវិញខុស លោកធ្វើឲ្យផ្ដុះផ្ដាយមិនកើតទេ លោកធ្វើឲ្យផ្ដុះផ្ដាយល្ហុតខុស លោកធ្វើឲ្យដាច់មិនកើតទេ លោកធ្វើឲ្យមានមណ្ឌលខុស សំដែងមិនល្អទេ ពណ៌នាមិនល្អទេ ចរចាមិនល្អទេ និយាយមិនល្អទេ ថ្លែងមិនល្អទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនអ្នកពិចារណាប្រស្នា... ជាគួរបំបាត់ចោល ។

(២៨៦) អធិប្បាយពាក្យថា បុគ្គលអ្នកមានវាទៈដ៏ថោកទាប រមែងយំរៀបរាប់ សោកស្ដាយ ត្រង់ពាក្យថា រមែងយំរៀបរាប់ គឺការចរចាដោយវាចា ការចរចារឿយៗ ការយំរៀបរាប់ អាការយំរៀបរាប់ ភាពនៃការយំរៀបរាប់ណា មានសភាពយ៉ាងនេះថា អាត្មាអញនឹកឃើញរបស់ដទៃ គិតឃើញរបស់ដទៃ ចាំទុករបស់ដទៃ កត់ត្រាទុករបស់ដទៃ បុគ្គលនោះ ជាអ្នកមានពួកច្រើន មានបរិស័ទច្រើន មានបរិវារច្រើន ឯបរិស័ទនេះ ជាពួកមិនព្រមព្រៀងគ្នា ទាំងការចរចាដោយពាក្យ ដើម្បីសេចក្ដីព្រមព្រៀងគ្នា ប៉ុរមានចុះ អាត្មាអញនឹងបំបែកវិញ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងយំរៀបរាប់ ។ ពាក្យថា សោកស្ដាយ គឺ សោកស្ដាយថា គេមានជ័យ សោកស្ដាយថា អាត្មាអញបរាជ័យ សោកស្ដាយថា គេមានលាភ សោកស្ដាយថា អាត្មាអញឥតលាភ សោកស្ដាយថា គេមានយស សោកស្ដាយថា អាត្មាអញឥតយស

តស្ស បសំសាតិ សោចតិ មយ្ហំ និន្ទាតិ សោចតិ តស្ស សុខន្តិ សោចតិ មយ្ហំ ទុក្ខន្តិ សោចតិ សោ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខា-រានំ អហមស្មិ អសក្កតោ អគរុកតោ អមានិតោ អបូជិតោ អនបចិតោ ន លាភី ចីវរបិណ្ឌបាតសេ-នាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាប-ជ្ជតីតិ បរិទេវតិ សោចតិ ។ ហីនកោតិ ហីនកោ និហីនកោ បរិហីនកោ បរិហាបិតកោ ន បរិ-បូរកោតិ បរិទេវតី សោចតិ ហីនកោ ។

(២៨៧) ឧបច្ចគា មន្តិ អនុត្ថុនាតីតិ សោ មំ ភ-ណេន ភណំ អច្ចគា ឧបច្ចគា អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោតិ ឯវម្បិ ឧបច្ចគា មន្តិ ។ អថវា មំ ភណេន ភណំ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វា (១)

១ ម. មទ្ទយិត្វា ។

សោកស្តាយថា គេបានសេចក្តីសរសើរ សោកស្តាយថា អាត្មាអញបាននិន្ទា សោកស្តាយថា គេបានសុខ សោកស្តាយថា អាត្មាអញបានទុក្ខ សោកស្តាយ លំបាកចិត្ត យំរៀបរាប់ យំគក់ទ្រូង ដល់នូវសេចក្តីវង្វេងថា បុគ្គលនោះ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ អាត្មាអញ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែងមិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារទេ ហេតុនោះ (ទ្រង់ត្រាស់ថា) យំរៀបរាប់ សោកស្តាយ ។ ពាក្យថា មានវាទៈដ៏ថោកទាប គឺមានវាទៈដ៏ថោកទាប មានវាទៈទន់អន់ មានវាទៈសាបសូន្យ មានវាទៈខ្វះខាត មានវាទៈមិនបរិបូណ៌ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានវាទៈថោកទាប រមែងយំរៀបរាប់ សោកស្តាយ ។

[២៨៧] ពាក្យថា តួញត្អែរថា គេកន្លងអាត្មាអញ គឺតួញត្អែរថា គេបំពាន រំលោភលើ ប្រព្រឹត្តកន្លង រំលងពំពេក រំលោភពីលើវាទៈដោយវាទៈនៃអញ ហេតុនោះ (ទ្រង់ត្រាស់ថា) តួញត្អែរថា គេកន្លងអាត្មាអញយ៉ាងនេះខ្លះ ។ មួយទៀត តួញត្អែរថា បុគ្គលនោះ គ្របសង្កត់ ពន្ទិចពន្ទន់ រួបរឹត ញាំញីនូវវាទៈ ដោយវាទៈនៃអញ

អដ្ឋមោ បសូរសុត្តនិទ្ទេសោ

ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ ឯវម្បិ ឧបច្ចគា មន្តិ ។ អនុត្ថុនា ថុនតិ ភាបលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ឧបច្ចគា មន្តិ អនុត្ថុនាតិ ។

តេនាហ ភគវា

យមស្ស វាទំ បរិហីនមាហុ
អបាហតំ បញ្ហវិមំសកា យេ
បរិទេវតី សោចតិ ហីនវាទោ
ឧបច្ចគា មន្តិ អនុត្ថុនាតីតិ ។

(២៨៨) ឯតេ វិវាទា សមណេសុ ជាតា
ឯតេសុ ឧគ្ឃាតិនិឃាតិ ហោតិ
ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ
ន ហញ្ញទត្ថត្ថិ បសំសលាភា ។

(២៨៩) ឯតេ វិវាទា សមណេសុ ជាតា-តិ សមណាតិ យេ កេចិ ឥតោ ពហិទ្ធា

ហើយត្រាច់ទៅសម្រាន្តនៅ ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ញុំាងការប្រព្រឹត្តិឥរិយាបថឲ្យកើតឡើង រក្សាឥរិយាបថ បំពេញឥរិយាបថ បង្គ្រប់ឥរិយាបថ ហេតុនោះ (ទ្រង់ត្រាស់ថា) ត្អូញត្អែរថា គេកន្ទងអាត្មាអញ យ៉ាងនេះខ្លះ ៗ ការចរចាដោយវាចា ការចរចាផ្សេងៗ ការយំរៀបរាប់ អាការយំរៀបរាប់ ភាពនៃការយំរៀបរាប់ លោកហៅថា ការត្អូញត្អែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ត្អូញត្អែរថា គេកន្ទងអាត្មាអញ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជន អ្នកពិចារណាប្រស្នា បានពោលវាទៈ របស់ជន
នោះ ថាថោកទាប ថាគួរបំបាត់ពោល បុគ្គលអ្នកមានវាទៈ
ដ៏ថោកទាប រមែងយំរៀបរាប់ សោកស្តាយ ត្អូញត្អែរថា
គេកន្ទងអាត្មាអញ ៗ

(២៨៨) វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ កិរិយាផ្ទួបចិត្តនឹង
ការតឹងចិត្ត រមែងមាន ព្រោះវាទៈទាំងនេះ បុគ្គលឃើញ
ទោសនេះហើយ គួរវៀរបង់សំដីមិនមានទុំដា ដ្បិត
ប្រយោជន៍ដទៃមិនមាន ព្រោះកិរិយាបានពាក្យសរសើរទេ ៗ

(២៨៩) អធិប្បាយពាក្យថា វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ ត្រង់ពាក្យថា ពួកសមណៈ គឺពួកជនណាមួយ ដែលបួលទៅកាន់ផ្នួស

បរិព្វាជូបគតា បរិព្វាជកសមាបន្នា ឯតេ ទិដ្ឋិកលហា ទិដ្ឋិភណ្ឌនា ទិដ្ឋិវិគ្គហា ទិដ្ឋិវិវាទា ទិដ្ឋិមេធគា សមណេសុ ជាតា សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតាតិ ឯតេ វិវាទា សមណេសុ ជាតា ។

(២៩០) ឯតេសុ ឧគ្ឃាតិនិឃាតិ ហោតីតិ ជយបរាជយោ ហោតិ លាភាលាភោ ហោតិ យសាយសោ ហោតិ និន្ទាបសំសា ហោតិ សុខទុក្ខំ ហោតិ សោមនស្សទោមនស្សំ ហោតិ ឥដ្ឋានិដ្ឋំ ហោតិ អនុនយបដិឃំ ហោតិ ឧគ្ឃាតិនិឃាតិ ហោតិ អនុរោធវិរោធោ ហោតិ ជយេន ចិត្តំ ឧគ្ឃាតិតំ ហោតិ បរាជយេន ចិត្តំ និឃាតិតំ ហោតិ លាភេន ចិត្តំ ឧគ្ឃាតិតំ ហោតិ អលាភេន ចិត្តំ និឃាតិតំ ហោតិ យសេន ចិត្តំ ឧគ្ឃាតិតំ ហោតិ អយសេន ចិត្តំ និឃាតិតំ ហោតិ បសំសាយ ចិត្តំ ឧគ្ឃាតិតំ ហោតិ និន្ទាយ ចិត្តំ និឃាតិតំ ហោតិ សុខេន ចិត្តំ ឧគ្ឃាតិតំ ហោតិ ទុក្ខេន ចិត្តំ និឃាតិតំ ហោតិ សោមនស្សេន ចិត្តំ ឧគ្ឃាតិតំ ហោតិ ទោមនស្សេន ចិត្តំ

ជាបរិព្វាជក ឬលទ្ធិគេបរិព្វាជក ខាងក្រៅពីសាសនានេះ ដ៏នោះ ព្រោះទិដ្ឋិ ការប្រកួតប្រកាន់ព្រោះទិដ្ឋិ ការទាស់ទែងព្រោះទិដ្ឋិ ការវិវាទព្រោះទិដ្ឋិ ការបែកខ្ញែកគ្នាព្រោះទិដ្ឋិទាំងនុ៎ះ កើត កើតព្រម លេចឡើង លេចឡើងប្រាកដ កើតប្រាកដ ក្នុងពួកសមណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ ។

[២៩០] ពាក្យថា កិរិយាធូរចិត្តនិងការតឹងចិត្ត រមែងមាន ព្រោះវាទៈទាំងនេះ អធិប្បាយថា ជ័យនិងបរាជ័យ រមែងមាន លាភនិងឥតលាភ រមែងមាន យសនិងឥតយស រមែងមាន និន្ទានិងសេចក្តីសរសើរ រមែងមាន សុខនិងទុក្ខ រមែងមាន សោមនស្សនិងទោមនស្ស រមែងមាន របស់ជាទីប្រាថ្នានិងមិនជាទីប្រាថ្នា រមែងមាន សេចក្តីត្រេកអរនិងការថ្នាំងថ្នាក់ រមែងមាន កិរិយាធូរចិត្តនិងការតឹងចិត្ត រមែងមាន សេចក្តីត្រេកអរនិងការខឹង រមែងមាន ចិត្តធូរព្រោះការឈ្នះ ចិត្តតឹងព្រោះការចាញ់ ចិត្តធូរ ព្រោះលាភ ចិត្តតឹង ព្រោះឥតលាភ ចិត្តធូរ ព្រោះយស ចិត្តតឹង ព្រោះឥតយស ចិត្តធូរ ព្រោះសេចក្តីសរសើរ ចិត្តតឹង ព្រោះនិន្ទា ចិត្តធូរ ព្រោះសុខ ចិត្តតឹង ព្រោះទុក្ខ ចិត្តធូរ ព្រោះសោមនស្ស ចិត្តតឹង ព្រោះទោមនស្ស ចិត្តធូរ

និគ្ឃាតិតំ ហោតិ ឧណ្ណតិយា ចិត្តំ ឧគ្ឃាតិតំ ហោតិ ឱណតិយា ចិត្តំ និគ្ឃាតិតំ ហោតីតិ ឯវម្បិ ឧគ្ឃាតិនិឃាតិ ហោតិ ។

(២៩១) ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ ឯតម្បិ ទិស្វាតិ ឯតំ អាទីនវំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ទិដ្ឋិកលហេសុ ទិដ្ឋិភណ្ឌនេសុ ទិដ្ឋិវិគ្គហេសុ ទិដ្ឋិវិវាទេសុ ទិដ្ឋិមេធគេសូតិ ឯតម្បិ ទិស្វា ។ វិរមេ កថោជ្ជន្តិ កថោជ្ជំ វុច្ចតិ កលហោ ភណ្ឌនំ វិគ្គហោ វិវាទោ មេធគំ ។ អថវា កថោជ្ជន្តិ អនោជវន្តី សា កថា ។ កថោជ្ជំ ន ករេយ្យ កលហំ ន ករេយ្យ ភណ្ឌនំ ន ករេយ្យ វិគ្គហំ ន ករេយ្យ វិវាទំ ន ករេយ្យ មេធគំ ន ករេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ។ កលហភណ្ឌនវិគ្គហវិវាទមេធគា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ

ព្រោះការប៉ោងឡើង ចិត្តតឹង ព្រោះការទ្រោមចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ការផូរចិត្តនិងការតឹងចិត្ត រមែងមានព្រោះវាទៈទាំងនេះ ។

(២៩១) អធិប្បាយពាក្យថា បុគ្គលឃើញទោសនេះហើយ គួរវៀរបង់សំដីមិនមានឱជា ត្រង់ពាក្យថា ឃើញទោសនេះ គឺឃើញ យល់ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវទោសនេះ ក្នុងការឈ្លោះព្រោះទិដ្ឋិ ក្នុងការប្រកួតប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញទោសនេះ ។ ពាក្យថា គួរវៀរបង់សំដីមិនមានឱជា គឺជំលោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទ ការបែកខ្ញែកគ្នា លោកហៅថា សំដីមិនមានឱជា ។ មួយទៀត ពាក្យមិនមានឱជានោះ ហៅថាសំដីមិនមានឱជា ។ បុគ្គលមិនគប្បីធ្វើសំដីមិនមានឱជា គឺមិនគប្បីធ្វើជំលោះ មិនគប្បីធ្វើការប្រកួតប្រកាន់ មិនគប្បីធ្វើការទាស់ទែង មិនគប្បីធ្វើការវិវាទ មិនគប្បីធ្វើការបែកខ្ញែកគ្នា គប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីឲ្យដល់នូវការមិនកើតមានជំលោះ ការប្រកួតប្រកាន់ការទាស់ទែង ការវិវាទ និងការបែកខ្ញែកគ្នា ។ បុគ្គលគប្បីជាអ្នកឆ្ងាយវៀរស្រឡះ វៀរបំពោះ ចៀសវាង លះបង់ ផុតស្រឡះ ប្រកបប្រាសចាកជំលោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នា

វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ ។

(២៩២) ន ហញ្ញទត្ថត្ថិ បសំសលាភាតិ បសំសលាភា អញ្ញោ អត្ថោ នត្ថិ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា អត្ថោ គូឡ្ហោ វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា អត្ថោ អនវជ្ជោ វា អត្ថោ និក្កិលេសោ វា អត្ថោ វោទានោ វា អត្ថោ បរមត្ថោ វា អត្ថោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតីតិ ន ហញ្ញទត្ថត្ថិ បសំសលាភា ។ តេនាហ ភគវា

ឯតេ វិវាទា សមណេសុ ជាតា
ឯតេសុ ឧគ្ឃាតិនិឃាតិ ហោតិ
ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ
ន ហញ្ញទត្ថត្ថិ បសំសលាភាតិ ។

ហើយសម្រាន្តនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញទោសនេះហើយ ត្រូវវៀរបង់សំដីមិនមានខុជា ។

[២៩២] ពាក្យថា ដ្បិតប្រយោជន៍ដទៃមិនមាន ព្រោះការបានសេចក្តីសរសើរ សេចក្តីថា ប្រយោជន៍ដទៃមិនមាន ព្រោះការបានសេចក្តីសរសើរ គឺប្រយោជន៍របស់ខ្លួនក្តី ប្រយោជន៍របស់បុគ្គលដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍បច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់ក្តី ប្រយោជន៍កំបាំងក្តី ប្រយោជន៍ដែលត្រូវដឹកនាំក្តី ប្រយោជន៍ដែលដឹកនាំហើយក្តី ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផូរផង់ក្តី ប្រយោជន៍មានអត្ថដ៏ឧត្តមក្តី រមែងមិនមាន មិនមានព្រម មិនកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ដ្បិតប្រយោជន៍ដទៃ មិនមាន ព្រោះការបានសេចក្តីសរសើរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

វិវាទទាំងនុ៎ះ កើតក្នុងពួកសមណៈ ការយោធូរចិត្តនិងការតឹង
ចិត្ត រមែងមាន ព្រោះវិវាទទាំងនេះ បុគ្គលឃើញទោស
នេះហើយ ត្រូវវៀរបង់សំដីមិនមានខុជា ដ្បិតប្រយោជន៍
ដទៃ មិនមាន ព្រោះការបានពាក្យសរសើរទេ ។

(២៩៣) បសំសិតោ វា បន តត្ថ ហោតិ
អក្ខាយ វាទំ បរិសាយ មជ្ឈេ
សោ ហស្សតិ ឧណ្ណមតិ ច តេន
បប្បុយ្យ(១) តមត្ថំ យថាមនោ អហុ ។

(២៩៤) បសំសិតោ វា បន តត្ថ ហោតីតិ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា បសំសិតោ ថោមិតោ កិត្តិតោ វណ្ណិតោ ហោតីតិ បសំសិតោ វា បន តត្ថ ហោតិ ។

(២៩៥) អក្ខាយ វាទំ បរិសាយ មជ្ឈេតិ ខត្តិយបរិសាយ វា ព្រាហ្មណបរិសាយ វា គហបតិបរិសាយ វា សមណបរិសាយ វា មជ្ឈេ អត្តនោ វាទំ អក្ខាយ អាចិក្ខិត្វា អនុវាទំ អក្ខាយ អាចិក្ខិត្វា ថម្ភយិត្វា ព្រូហយិត្វា ទីបយិត្វា ជោតយិត្វា វោហរិត្វា បរិគ្គណ្ហិត្វាតិ អក្ខាយ វាទំ បរិសាយ មជ្ឈេ ។

(២៩៦) សោ ហស្សតិ ឧណ្ណមតិ ច តេនាតិ សោ តេន ជយត្ថេន តុដ្ឋោ ហោតិ ហដ្ឋោ បហដ្ឋោ អត្តមនោ បរិបុណ្ណសង្កប្បោ ។

---

១ ម. សម្បុយ្យ ។

(២៩៣) មួយទៀត បុគ្គលនោះពោលវាទៈ ក្នុងកណ្ដាលបរិស័ទ ត្រូវគេសរសើរ ក្នុងសភាៈនោះហើយ រមែងរីករាយក្រអឺត ក្រអោង ដោយហេតុនោះ ដល់នូវប្រយោជន៍នោះហើយ ជាបុគ្គលមានចិត្តតាំងទៅដូចដើម ។

(២៩៤) ពាក្យថា ក្នុងសភាៈនោះ របស់ពាក្យថា មួយទៀត ត្រូវគេសរសើរហើយ ក្នុងសភាៈនោះ គឺត្រូវគេសរសើរ លើកតំកើង ប្រកាសគុណ ពណ៌នាគុណក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការគួររបស់ខ្លួន ក្នុងសេចក្ដីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត ត្រូវគេសរសើរហើយ ក្នុងសភាៈនោះ ។

(២៩៥) ពាក្យថា ពោលវាទៈក្នុងកណ្ដាលបរិស័ទ គឺពោល ប្រាប់វាទៈរបស់ខ្លួន ពោល ប្រាប់ បំពេញ បំភ្លឺ សំដែង បក្តិ ថ្លែង កំណត់អនុវាទៈរបស់ខ្លួន ក្នុងកណ្ដាលខត្តិយបរិស័ទក្ដី ព្រាហ្មណបរិស័ទក្ដី គហបតិបរិស័ទក្ដី សមណបរិស័ទក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលវាទៈ ក្នុងកណ្ដាលបរិស័ទ ។

(២៩៦) ពាក្យថា បុគ្គលនោះ រមែងរីករាយ ក្រអឺតក្រអោងដោយហេតុនោះ គឺបុគ្គលនោះ រមែងត្រេកអររីករាយ ស្រស់ស្រាយ មានចិត្តត្រេកអរ មានចិត្តត្រេះរិះពេញលេញ ដោយប្រយោជន៍គឺការឈ្នះនោះ ។

អថវា ឧទ្ធំសិតំ ហាសមានោតិ សោ ហស្សតិ ។ ឧណ្ណមតិចូ តេនាតិ សោ តេន ជយត្ថេន ឧណ្ណតោ ហោតិ ឧណ្ណមោ ធជោ សម្បគ្គាហោ កេតុកម្យ-តា ចិត្តស្សាតិ សោ ហស្សតិ ឧណ្ណមតិចូ តេន ។

(២៩៧) បប្បុយ្យ តមត្ថំ យថាមនោ អហូតិ តំ ជយត្ថំ បប្បុយ្យ បាបុណិត្វា អធិគន្ត្វា វិន្ទិត្វា បដិល-ភិត្វា ។ យថាមនោ អហូតិ យថាមនោ អហុ យថា-ចិត្តោ អហុ យថាសង្កប្បោ អហុ យថាវិញ្ញាណោ អហូតិ បប្បុយ្យ តមត្ថំ យថាមនោ អហុ ។ តេនាហ ភគវា

បសំសិតោ វា បន តត្ថ ហោតិ
អក្ខាយ វាទំ បរិសាយ មជ្ឈេ
សោ ហស្សតិ ឧណ្ណមតិចូ តេន
បប្បុយ្យ តមត្ថំ យថាមនោ អហូតិ ។

មួយទៀត បុគ្គលកាលសើចបញ្ចេញធ្មេញ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរីករាយ ៗ ពាក្យថា ក្រអឺតក្រអោងដោយហេតុនោះ គឺបុគ្គលនោះ មានចិត្តប៉ោងឡើង មានចិត្តខ្ពស់ឡើង មានចិត្តដូចជាទង់ជ័យ មានចិត្តផ្គងឡើង ភាពនៃចិត្តមានសេចក្ដីប្រាថ្នាដូចជាទង់ ដោយប្រយោជន៍គឺការឈ្នះនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរីករាយ ក្រអឺតក្រអោង ដោយហេតុនោះ ៗ

(២៩៧) ពាក្យថា ដល់នូវប្រយោជន៍នោះ ជាអ្នកមានចិត្តតាំងនៅដូចដើម គឺដល់ លុះ សម្រេច បាន បានចំពោះនូវប្រយោជន៍ គឺការឈ្នះនោះ ៗ ពាក្យថា ជាអ្នកមានចិត្តតាំងនៅដូចដើម គឺជាអ្នកមានចិត្តដូចដើម មានគំនិតដូចដើម មានសេចក្ដីត្រិះរិះដូចដើម មានការដឹងដូចដើម ហេតុនោះ (ទ្រង់ត្រាស់ថា) បានដល់នូវប្រយោជន៍នោះ ជាអ្នកមានចិត្តតាំងនៅដូចដើម ៗ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត បុគ្គលនោះពោលវាទៈ ក្នុងកណ្ដាលបរិស័ទ
ត្រូវគេសរសើរហើយ ក្នុងសភាវៈនោះ រមែងរីករាយក្រអឺត
ក្រអោង ដោយហេតុនោះ ដល់នូវប្រយោជន៍នោះហើយ
ជាបុគ្គលមានចិត្តតាំងនៅដូចដើម ៗ

## អដ្ឋមោ បសូរសុត្តនិទ្ទេសោ

(២៩៨) យា ឧណ្ណតី សាស្ស វិឃាតភូមិ
មានាតិមានំ វទតេ[១] បនេសោ
ឯតម្បិ ទិស្វា ន វិវាទយេថ
ន ហិ តេន សុទ្ធី កុសលា វទន្តិ ។

(២៩៩) យា ឧណ្ណតី សាស្ស វិឃាតភូមីតិ យា ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស សា តស្ស វិឃាតភូមិ ឧគ្ឃាតភូមិ បីឡនភូមិ ឃដ្ដនភូមិ ឧបទ្ទវភូមិ ឧបសគ្គភូមីតិ យា ឧណ្ណតី សាស្ស វិឃាតភូមិ[២] ។

(៣០០) មានាតិមានំ វទតេ បនេសោតិ សោ បុគ្គលោ មានញ្ច វទតិ អតិមានញ្ច វទតីតិ មានាតិមានំ វទតេ បនេសោ ។

(៣០១) ឯតម្បិ ទិស្វា ន វិវាទយេថាតិ

---

១ ម. បរតេ ។ ២ ម. បិតស្សាតិ យា ឧណ្ណតិ ។ សាស្ស វិឃាតភូមីតិ សា តស្ស វិឃាតភូមិ ឧបឃាតភូមិ បីឡនភូមិ ឃដ្ដនភូមិ ឧបទ្ទវភូមិ ឧបសគ្គភូមីតិ សា ឧណ្ណតិ សាស្ស វិឃាតភូមីតិ ទិស្សន្តិ ។

## បសូរសុត្តនិទ្ទេស ទី ៨

(២៩៨) ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីបង្អៀតបង្អល់របស់បុគ្គលនោះ មួយទៀត បុគ្គលនុ៎ះ រមែងពោលនូវមានៈ នឹងអតិមានៈ បុគ្គលឃើញទោសនេះហើយ មិនគួរវិវាទទេ ព្រោះពួកអ្នកឈ្លាសទាំងឡាយ មិនពោលនូវការស្អាត ដោយវិវាទនោះឡើយ ។

(២៩៩) ពាក្យថា ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីបង្អៀតបង្អល់ របស់បុគ្គលនោះ គឺការប៉ោងឡើង ការខ្ពស់ឡើង ចិត្តដូចទង់ជ័យ ការផ្គងឡើង ភាពនៃចិត្តមានប្រាថ្នាដូចជាទង់ណា នោះជាភូមិនៃការបង្អៀតបង្អល់ ជាភូមិនៃសេចក្តីតានតឹង ជាភូមិនៃការបៀតបៀន ជាភូមិនៃសេចក្តីខាំងខប់ ជាភូមិនៃឧបទ្រព ជាភូមិនៃឧបសគ្គរបស់បុគ្គលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ការប៉ោងឡើងណា ការប៉ោងឡើងនោះ ជាភូមិនៃសេចក្តីបង្អៀតបង្អល់ របស់បុគ្គលនោះ ។

(៣០០) ពាក្យថា មួយទៀត បុគ្គលនោះ រមែងពោលនូវមានៈ នឹងអតិមានៈ គឺបុគ្គលនោះ ពោលនូវមានៈផង ពោលនូវអតិមានៈផង ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលនោះ រមែងពោលនូវមានៈ នឹងអតិមានៈ ។

(៣០១) ពាក្យថា បុគ្គលឃើញទោសនេះហើយ មិនគួរវិវាទទេ

ឯតំ អាទីនវំ ញត្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវ-យិត្វា វិភូតំ កត្វា ទិដ្ឋិកលហេសុ ទិដ្ឋិភណ្ឌនេសុ ទិដ្ឋិវិគ្គហេសុ ទិដ្ឋិវិវាទេសុ ទិដ្ឋិមេធគេសូតិ ឯតម្បិ ទិស្វា ។ ន វិវាទយេថាតិ ន កលហំ ករេយ្យ ន ភណ្ឌនំ ករេយ្យ ន វិគ្គហំ ករេយ្យ ន វិវាទំ ករេយ្យ ន មេធគំ ករេយ្យ កលហភណ្ឌនវិ-គ្គហវិវាទមេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ ។ កលហភណ្ឌនវិគ្គហវិវាទមេធគា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ឯតម្បិ ទិស្វា ន វិវាទយេថ ។

(៣០៦) ន ហិ តេន សុទ្ធិំ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុស-លា អាយតនកុសលា បដិច្ចសមុប្បាទកុស-លា សតិបដ្ឋានកុសលា សម្មប្បធានកុសលា

សេចក្ដីថា បុគ្គលឃើញ យល់ ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដនូវទោសនេះ ក្នុងជម្លោះព្រោះទិដ្ឋិ ក្នុងការប្រកួតប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញទោសនេះ ។ ពាក្យថា មិនគួរវិវាទទេ គឺមិនគួរធ្វើជម្លោះ មិនគួរធ្វើការប្រកួតប្រកាន់ មិនគួរធ្វើការទាស់ទែង មិនគួរធ្វើការវិវាទ មិនគួរធ្វើការបែកខ្ញែកគ្នា គប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីធ្វើមិនកើតមាននូវជម្លោះ ការប្រកួតប្រកាន់ ការទាស់ទែង ការវិវាទនិងការបែកខ្ញែកគ្នា ។ គឺជាអ្នកឆ្ងាយ វៀរស្រឡះ វៀរបំពោះ ចៀសចេញ លះបង់ ផុតស្រឡះ ការប្រកបប្រាសចាកជម្លោះ ការប្រកួតប្រកាន់ ទាស់ទែង ការវិវាទ និងការបែកខ្ញែកគ្នា គប្បីសម្រេចនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញទោសនេះហើយមិនគួរវិវាទទេ ។

(៣០២) អធិប្បាយពាក្យថា ដ្បិតជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវការស្អាតដោយវិវាទនោះទេ ត្រង់ពាក្យថា អ្នកឈ្លាសទាំងឡាយ គឺពួកជនណា ជាអ្នកឈ្លាសក្នុងខន្ធ ឈ្លាសក្នុងធាតុ ឈ្លាសក្នុងអាយតនៈ ឈ្លាសក្នុងបដិច្ចសមុប្បាទ ឈ្លាសក្នុងសតិប្បដ្ឋាន ឈ្លាសក្នុងសម្មប្បធាន

អដ្ឋមោ បច្ចុសុត្តន្តិទ្ទេសោ

សទ្ធិធានកុសលា សទ្ធិន្ទ្រិយកុសលា ពលកុសលា ពោ-
ជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្វាន-
កុសលា តេ កុសលា និដ្ឋគតា ហោន្តិ និដ្ឋកល្យាណា ហោន្តិ
និដ្ឋវិគ្គ ហោន្តិ និដ្ឋវិភា ទេន្តិ និដ្ឋមេន តេន សុទ្ធី វិសុទ្ធី បរិ-
សុទ្ធី មុត្តី វិមុត្តី បរិមុត្តី ច វទន្តិ ច ការេន្តិ ច កលាន្តិ
ច ទីបយន្តិ ច វោហារន្តីតិ ច ហិ តេន សុទ្ធី កុសលា
វទន្តិ ។ តេនាហ ភគវា

យា ឧណ្ហីតិ សភស្ស វិយាគក្ខុមិ
មានាតិមានំ វទតេ បនេសោ
ឋគម្ភិ និស្សា ន វិភនយេន
ន ហិ តេន សុទ្ធី កុសលា វទន្តីតិ ។

(៣០៣) ស្វាកេ យតា ភជ១នាយ បុដ្ឋា
អភិតជ្ជមេតិ បដិស្សរម្ពិ

បសូរសុត្តនិទ្ទេស ទី ៨

ឈ្លាសក្នុងឥទ្ធិបាទ ឈ្លាសក្នុងឥន្ទ្រិយ ឈ្លាសក្នុងពលៈ ឈ្លាសក្នុងពោជ្ឈង្គ ឈ្លាសក្នុងមគ្គ ឈ្លាសក្នុងផល ឈ្លាសក្នុងនិព្វាន ជនអ្នកឈ្លាសទាំងនោះ មិនពោល មិនសំដែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយជម្លោះព្រោះទិដ្ឋិ ដោយការប្រកួតប្រកាន់ ព្រោះទិដ្ឋិ ដោយការទាស់ទែងព្រោះទិដ្ឋិ ដោយការវិវាទព្រោះទិដ្ឋិ ដោយការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវការស្អាត ដោយការវិវាទនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការហ៊ោនហ៊ើនណា ការហ៊ោនហ៊ើននោះ ជាភូមិនៃសេចក្តី
ចង្អៀតចង្អល់របស់បុគ្គលនោះ មួយទៀត បុគ្គលនោះ រមែង
ពោលនូវមានះ និងអតិមានះ បុគ្គលឃើញទោសនេះហើយ
មិនគួរវិវាទទេ ដ្បិតជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវ
ការស្អាត ដោយវិវាទនោះឡើយ ។

[១០៣] ដូចបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹម ដោយខាទនីយ-
ភោជនីយាហារ របស់ព្រះរាជា កាលប្រាថ្នា បុគ្គល
អ្នកក្លៀវក្លាតប រមែងគ្រហឹមចូលមក ម្នាលអ្នកក្លៀវក្លា

យេនេវ សោ តេន បលេហិ សូរ

បុព្វេវ នត្ថិ យទិទំ យុទ្ធាយ ។

[៣០៤] សូរោ យថា រាជខាទាយ[១] បុដ្ឋោតិ សូរោតិ សូរោ វីរោ វិក្កន្តោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី ។ រាជខាទាយ បុដ្ឋោតិ រាជខាទនីយេន រាជភោជនីយេន បុដ្ឋោ បោសិតោ អាបាទិតោ វឌ្ឍិតោ វឌ្ឍិតោតិ សូរោ យថា រាជខាទាយ បុដ្ឋោ ។

[៣០៥] អភិគជ្ជមេតិ បដិសូរមិច្ឆន្តិ សោ គជ្ជន្តោ ឧគ្គជ្ជន្តោ អភិគជ្ជន្តោ ឯតិ ឧបេតិ ឧបគច្ឆតិ បដិសូរំ បដិបុរិសំ បដិសត្តុំ បដិមល្លំ ឥច្ឆន្តោ សាទិយន្តោ បត្ថយន្តោ បិហយន្តោ អភិជប្បន្តោតិ អភិគជ្ជមេតិ បដិសូរមិច្ឆំ ។

---

១ ម. រាជខាទាយ ។

បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ (នៅ) ក្នុងទីណា អ្នកឯងចូរទៅ

ក្នុងទីនោះចុះ ដ្បិតអំពើដែលប្រព្រឹត្តទៅ ដើម្បីតយុទ្ធគ្នា

មិនមានតាំងអំពីដើមមក ។

[៣០៨] អធិប្បាយពាក្យថា ដូចជាបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហារ របស់ព្រះរាជា ត្រង់ពាក្យថា អ្នកក្លៀវក្លា គឺបុគ្គលអ្នកក្លៀវក្លា អ្នកប្រឹងប្រែង អ្នកខ្លាំងពូកែ មិនរន្ធត់ មិនរំភើប មិនតក់ស្លុត មិនរត់ ។ ពាក្យថា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហារ របស់ព្រះរាជា គឺ គេចិញ្ចឹម រក្សា បីបាច់ ថែទាំឲ្យចំរើនដោយខាទនីយៈរបស់ព្រះរាជា ដោយភោជនីយៈរបស់ព្រះរាជា ហេតុនោះ (ទ្រង់ត្រាស់ថា) ដូចជាបុគ្គលអ្នកក្លៀវក្លា ដែលគេចិញ្ចឹមដោយខាទនីយភោជនីយាហារ របស់ព្រះរាជា ។

[៣០៩] ពាក្យថា កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លាតប រមែងគំរាមចូលមក គឺបុគ្គលនោះ កាលគំរាម កាលសង្រ្កេក កាលសន្ធឹកចូល ដើរចូលទៅ ឈានចូលទៅ ដើរចូលទៅជិត កាលចង់ ត្រេកអរ ប្រាថ្នា ស្រឡាញ់ ជាប់ចិត្ត នូវបុគ្គល អ្នកក្លៀវក្លាតប នូវបុរសជាសត្រូវ នូវសត្រូវតប នូវអ្នកដាល់តបតប ហេតុនោះ (ទ្រង់ត្រាស់ថា) កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លា រមែងគំរាមចូលមក ។

## អដ្ឋមោ បសូរសុត្តនិទ្ទេសោ

[៣០៦] យេនេវ សោ តេន បលេហិ សូរាតិ យេនេវ សោ ទិដ្ឋិគតិកោ តេន បលេហិ តេនេវ វជ តេន គច្ឆ តេន អតិក្កម សោ តុយ្ហំ បដិសូរោ បដិបុរិសោ បដិសត្តុ បដិមល្លោតិ យេនេវ សោ តេន បលេហិ សូរ ។

[៣០៧] បុព្វេវ នត្ថិ យទិទំ យុធាយាតិ បុព្វេវ ពោធិយា មូលេ យេ បដិសេនិករា កិលេសា បដិលោមករា បដិកណ្ដកករា បដិបក្ខករា តេ នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា ។ យទិទំ យុធាយាតិ យទិទំ យុទ្ធត្ថាយ កលហត្ថាយ ភណ្ឌនត្ថាយ វិគ្គហត្ថាយ វិវាទត្ថាយ មេធគត្ថាយាតិ បុព្វេវ នត្ថិ យទិទំ យុធាយ ។

## បសូរសុត្តនិទ្ទេស ទី ៨

[៣០៦] ពាក្យថា ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ (ទៅ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះចុះ សេចក្តីថា បុគ្គល លុះក្នុងទិដ្ឋិនោះ (ទៅ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះ ចូរឈានទៅក្នុងទីនោះ ចូរដើរទៅក្នុងទីនោះ ចូរដើរតម្រង់ទៅក្នុងទីនោះ បុគ្គលនោះ ជាអ្នកក្លៀវក្លាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកជល់តប់តបរបស់អ្នក ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ (ទៅ) ក្នុងទីណា អ្នកចូរទៅក្នុងទីនោះចុះ ។

[៣០៧] ពាក្យថា ដ្បិតអំពើដែលប្រព្រឹត្តទៅ ដើម្បីតយុទ្ធគ្នាមិនមានតាំងអំពីដើមមក អធិប្បាយថា កិលេសទាំងឡាយណា ធ្វើជាសេនាតប ធ្វើទាស់ ធ្វើជាបច្ចាតប ធ្វើជាបដិបក្ខ កិលេសទាំងឡាយនោះ មិនមាន មិនកើត មិនមានព្រម មិនកើតមាន គឺតថាគត លះបង់ ផ្តាច់ផ្តិល រម្ងាប់ ក្របសង្កត់ ធ្វើមិនគួរឲ្យកើតបាន ដុតបំផ្លាញ ដោយភ្លើងគឺញាណហើយ ជិតគល់ពោធិព្រឹក្ស តាំងអំពីដើមមក ។ ពាក្យថា អំពើដែលប្រព្រឹត្តទៅ ដើម្បីតយុទ្ធគ្នា គឺអំពើណាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍តយុទ្ធគ្នា ដើម្បីប្រយោជន៍ដល់ជម្លោះ ដើម្បីប្រយោជន៍ដល់ការប្រកួតប្រកាន់ ដើម្បីប្រយោជន៍ដល់ការទាស់ទែង ដើម្បីប្រយោជន៍ដល់ការវិវាទ ដើម្បីប្រយោជន៍ដល់ការបែកខ្ញែកគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) អំពើដែលប្រព្រឹត្តទៅ ដើម្បីតយុទ្ធគ្នា មិនមានតាំងអំពីដើមមក ។

តេនាហ ភគវា

សូរោ យថា រាជខាទាយ បុដ្ឋោ
អភិគជ្ជមេតិ បដិសូរមិច្ឆំ
យេនេវ សោ តេន បលេហិ សូរ
បុព្វេវ នត្ថិ យទិទំ យុធាយ ។

[៣០៨] យេ ទិដ្ឋិមុគ្គយ្ហ វិវាទយន្តិ
ឥទមេវ សច្ចន្តិ ច វាទយន្តិ
តេ ត្វំ វទស្សុ ន ហិ តេធ អត្ថិ
វាទម្ហិ ជាតេ បដិសេនិកត្តា ។

[៣០៩] យេ ទិដ្ឋិមុគ្គយ្ហ វិវាទយន្តីតិ យេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា វិវាទយន្តិ កលហំ ករោន្តិ ភណ្ឌនំ ករោន្តិ វិគ្គហំ ករោន្តិ វិវាទំ ករោន្តិ មេធគំ ករោន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ដូចបុគ្គលអ្នកក្លៀវក្លា ដែលគេបញ្ចឹមដោយខាទនីយភោជនី-យាហារ របស់ព្រះរាជា កាលប្រាថ្នាបុគ្គលអ្នកក្លៀវក្លាតប រមែងគំរាមចូលមក ម្នាលអ្នកក្លៀវក្លា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះ (ទៅ) ក្នុងទីណា អ្នកឯងចូរទៅ ក្នុងទីនោះចុះ ដ្បិតអំពើដែលប្រព្រឹត្តទៅ ដើម្បីតយុទ្ធគ្នា មិនមានតាំងអំពីដើមមក ។

(៣០៨) ពួកជនណា ប្រកាន់ទិដ្ឋិហើយរមែងតាស់ទែងគ្នា មួយទៀត តែងពោលថា នេះឯងជាពាក្យពិត អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះ មិនមានក្នុងទីនេះទេ ។

(៣០៩) ពាក្យថា ពួកជនណា ប្រកាន់ទិដ្ឋិហើយ រមែងតាស់ទែងគ្នា សេចក្ដីថា ពួកជនណា ប្រកាន់ កួបកាន់ ទទួលយក ស្ទាបអង្អែល ជឿស៊ប់ នូវទិដ្ឋិ ៦២ ទិដ្ឋិណាមួយហើយ រមែងតាស់ទែងគ្នា ធ្វើជម្លោះ ធ្វើការប្រកួតប្រកាន់ ធ្វើការតាស់ទែង ធ្វើការវិវាទ ធ្វើការបែកខ្ញែកគ្នាថា អ្នកមិនដឹងច្បាស់នូវធម្មវិន័យនេះទេ ខ្ញុំដឹងច្បាស់នូវធម្មវិន័យនេះ អ្នកដឹងច្បាស់នូវធម្មវិន័យនេះដូចម្ដេចបាន អ្នកជាបុគ្គលប្រតិបត្តិខុស ខ្ញុំជាអ្នកប្រតិបត្តិត្រូវ

សហិតម្មេ អសហិតន្តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អចិណ្ណន្តេ វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ ចរ វាទប្ប-មោក្ខាយ និព្វេឋេហិ វា សចេ បហោសីតិ យេ ទិដ្ឋិមុគ្គយ្ហ វិវាទយន្តិ ។

(៣១០) ឥទមេវ សច្ចន្តិ ច វាទយន្តីតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វាទយន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥ-ទមេវ សច្ចំ មោឃមញ្ញន្តិ វាទយន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឥទមេវ សច្ចន្តិ ច វាទយន្តិ ។

(៣១១) តេ ត្វំ វទស្សុ ន ហិ តេធ អត្ថិ វា-ទម្ហិ ជាតេ បដិសេនិកត្តាតិ តេ ត្វំ ទិដ្ឋិគតិកេ វទស្សុ

សំដីរបស់ខ្ញុំ ប្រកបដោយប្រយោជន៍ សំដីរបស់អ្នក មិនប្រកបដោយប្រយោជន៍ សំដីដែលត្រូវនិយាយមុន អ្នកបែរជានិយាយក្រោយ សំដីដែលត្រូវនិយាយក្រោយ អ្នកបែរជានិយាយមុន ពាក្យដែលអ្នកសន្សំមកអស់ហើយ ត្រូវខ្ញុំឲ្យវិលត្រឡប់ហើយ វាទៈ (ទោស) ខ្ញុំលើកដាក់លើអ្នកហើយ អ្នកជាបុគ្គលត្រូវខ្ញុំ ផ្ចាញ់ផ្ចាល់បានហើយ អ្នកចូរត្រាច់ទៅ ដើម្បីដោះវាទៈចុះ ឬបើអ្នកអាច ចូរដោះចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនណា ប្រកាន់ទិដ្ឋិហើយ រមែងទាស់ទែងគ្នា ។

(៣១០) ពាក្យថា មួយទៀត តែងពោលថា នេះឯង ជាពាក្យពិត គឺតែងពោល និយាយ ពណ៌នា បំភ្លឺ ថ្លែងថា លោកទៀង ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ តែងពោល និយាយ ពណ៌នា បំភ្លឺ ថ្លែងថា លោកមិនទៀង ។ បេ ។ សត្វបន្ទាប់អំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត តែងពោលថា នេះ ជាពាក្យពិត ។

(៣១១) ពាក្យថា អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាគប់ កិលេសទាំងឡាយនោះ មិនមានក្នុងទីនេះទេ អធិប្បាយថា អ្នកចូរនិយាយ

និគ្គហេន និគ្គហំ បដិកម្មេន បដិកម្មំ វិសេសេន វិសេសំ បដិវិសេសេន បដិវិសេសំ អាវេឋិយាយ អាវេឋិយំ និព្ពេឋិយាយ និព្ពេឋិយំ ឆេទេន ឆេទំ មណ្ឌលេន មណ្ឌលំ តេ តុយ្ហំ បដិសូរា បដិបុរិសា បដិសត្តូ បដិមល្លាតិ តេ តំ វទស្សុ ។ ន ហិ តេធ អត្ថិ វាទម្ហិ ជាតេ បដិសេនិកត្តាតិ វាទេ ជាតេ សញ្ជាតេ និព្វត្តេ អភិនិព្វត្តេ បាតុភូតេ យេ បដិសេនិកត្តា បដិលោមកត្តា បដិកណ្ដកកត្តា បដិបក្ខកត្តា កលហំ ការេយ្យុំ ភណ្ឌនំ ការេយ្យុំ វិគ្គហំ ការេយ្យុំ វិវាទំ ការេយ្យុំ មេធគំ ការេយ្យុំ តេ នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តេ តំ វទស្សុ ន ហិ តេធ អត្ថិ វាទម្ហិ ជាតេ បដិសេនិកត្តា ។

ពាក្យផ្ទុញផ្ទាល់ ដោយពាក្យផ្ទុញផ្ទាល់ ពាក្យតបត ដោយពាក្យតបត ពាក្យវិសេស ដោយពាក្យវិសេស ពាក្យវិសេសតប ដោយពាក្យវិសេសតប ពាក្យទំលុះទំលាយ ដោយពាក្យទំលុះទំលាយ ពាក្យដោះស្រាយ ដោយពាក្យដោះស្រាយ ពាក្យកាត់ផ្តាច់ ដោយពាក្យកាត់ផ្តាច់ ពាក្យមានមណ្ឌល ដោយពាក្យមានមណ្ឌល នឹងជនៈដែលប្រកបដោយទិដ្ឋិទាំងនោះ (ព្រោះថា) ជនទាំងនោះ ជាអ្នកក្រៀវក្រាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកជាលតបតបនឹងអ្នក ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរពោលនឹងជនទាំងនោះចុះ ។ ពាក្យថា កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះ មិនមានក្នុងទីនេះទេ គឺកាលដែលវាទៈកើតមាន កើតព្រម កើតឡើង កើតច្បាស់ កើតប្រាកដហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប ជាទំនាស់ ជាបច្ចាមិត្ត ជាសត្រូវ គប្បីធ្វើជម្លោះ ធ្វើការប្រកួតប្រកាន់ ធ្វើការទាស់ទែង ធ្វើការវិវាទ ធ្វើការបែកខ្ញែកគ្នា កិលេសទាំងឡាយនោះ មិនមាន មិនកើត មិនមានព្រម មិនកើតមាន គឺតថាគតលះបង់ផ្តាច់ផ្តិល រម្ងាប់ រម្ងាប់ គ្រប់សង្កត់ មិនគួរឲ្យកើតបាន បានដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះ មិនមាន ក្នុងទីនេះទេ ។

## អដ្ឋមោ បសូរសុត្តនិទ្ទេសោ

តេនាហ ភគវា

យេ ទិដ្ឋិមុគ្គយ្ហ វិវាទយន្តិ
ឥទមេវ សច្ចន្តិ ច វាទយន្តិ
តេ ត្វំ វទស្សុ ន ហិ តេធ អត្ថិ
វាទម្ហិ ជាតេ បដិសេនិកត្តាតិ ។

(៣១២) វិសេនិកត្វា បន យេ ចរន្តិ
ទិដ្ឋីហិ ទិដ្ឋឹ អវិរុជ្ឈមានា
តេសុ ត្វំ កឹ លភេថ បសូរ
យេសីធ នត្ថី បរមុគ្គហីតំ ។

(៣១៣) វិសេនិកត្វា បន យេ ចរន្តីតិ សេនា វុច្ចតិ មារសេនា ។ កាយទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ មារសេនា ទោសោ មារសេនា មោហោ មារសេនា កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ

## បសូរសុត្តនិទ្ទេស ទី ៨

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជនណា ប្រកាន់ទិដ្ឋិហើយរមែងទាស់ទែងគ្នា មួយទៀត តែងពោលថា នេះឯងជាពាក្យពិត អ្នកចូរពោលនឹងពួកជននោះចុះ កាលដែលវាទៈកើតហើយ កិលេសទាំងឡាយណា ធ្វើជាសេនាតប កិលេសទាំងឡាយនោះ មិនមានក្នុងទីនេះទេ ។

(៣១២) មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយប្រព្រឹត្តទៅ ពួកជននោះ មិនប្រទូស្តទិដ្ឋិដោយទិដ្ឋិទាំងឡាយ ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប ការប្រកាន់ថាក្រៃលែង ក្នុងលោកនេះ នៃពួកជនណាមិនមាន អ្នកគប្បីបានអ្វី ក្នុងពួកជននោះ ។

(៣១៣) ពាក្យថា មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយប្រព្រឹត្តទៅ អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគៈជាមារសេនា ទោសៈជាមារសេនា មោហៈជាមារសេនា កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ ការក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់

ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុស-
លាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា កាមា
តេ បឋមា សេនា ទុតិយារតិ វុច្ចតិ ។ បេ ។ ជេត្វា
ច លភតេ សុខន្តិ ។ យតោ ចតូហិ អរិយមគ្គេហិ
សព្វា ច មារសេនា សព្វេ ច បដិសេនិករា កិលេ-
សា ជិតា ច បរាជិតា ច ភគ្គា វិប្បលុគ្គា បរម្មុខា
តេន វុច្ចតិ វិសេនិកត្វា ។ យេតិ អរហន្តោ ខីណា-
សវា ។ ចរន្តីតិ ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ
យបេន្តិ យាបេន្តីតិ វិសេនិកត្វា បន យេ ចរន្តិ ។

(៣១៤) ទិដ្ឋីហិ ទិដ្ឋឹ អវិរុជ្ឈមានាតិ តេសំ ទ្វាសដ្ឋី
ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្ប-
ស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ តេ
ទិដ្ឋីហិ ទិដ្ឋឹ អវិរុជ្ឈមានា អឃដ្ដិយមានា អប្បដិហញ្ញ-
មានា អប្បដិហតមានាតិ ទិដ្ឋីហិ ទិដ្ឋឹ អវិរុជ្ឈមានា ។

សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ជាមារសេនា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ ជាសេនាទីមួយរបស់អ្នក អរតិលោកហៅថាជាសេនាទី ២ របស់អ្នក ។ បេ ។ លុះតែបុគ្គលឈ្នះសេនានោះ ទើបបានសេចក្តីសុខ ។ ព្រោះមារសេនាទាំងអស់ និងកិលេសធ្វើជាសេនាគបទាំងអស់ ពួកជនទាំងនោះ បានឈ្នះ បានផ្ចាញ់ បានកាប់បំបាក់ បានកំទេចកំទី ដោយអរិយមគ្គទាំង៤ ជាសភាពមានមុខកន្លងទីដទៃ ហេតុនោះ លោកពោលថា ធ្វើសេនាឲ្យវិនាស ។ ពាក្យថា ពួកជនណា បានដល់ព្រះអរហន្តខីណាស្រព ។ ពាក្យថា ប្រព្រឹត្តទៅ គឺប្រព្រឹត្តទៅ សម្រេចនៅ ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ញុំាងការប្រព្រឹត្តិឥរិយាបថឲ្យកើត រក្សាឥរិយាបថ បំពេញឥរិយាបថ បន្តប់ឥរិយាបថ ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាសហើយប្រព្រឹត្តទៅ ។

(៣១៤) ពាក្យថា មិនប្រទូស្តទិដ្ឋិ ដោយទិដ្ឋិទាំងឡាយ គឺទិដ្ឋិទាំង ៦២ ពួកជននោះ បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ក្រេបសង្កត់ ធ្វើមិនគួរឲ្យកើតបាន ដុតបំផ្លាញដោយភ្លើងគឺញាណ ពួកជននោះ មិនប្រទូស្ត មិនទាំងខ្ទប់ មិនបង្អៀតបង្អល់ មិនទន្ទុកទិដ្ឋិ ដោយទិដ្ឋិទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រទូស្តទិដ្ឋិ ដោយទិដ្ឋិទាំងឡាយ ។

## អដ្ឋមោ បសូរសុត្តនិទ្ទេសោ

(៣១៥) តេសុត្វំ កឹ លភេថោ(១) បសូរាតិ តេសុ អរហន្តេសុ ខីណាសវេសុ កឹ លភេថោ បដិសូរ បដិបុរិស បដិសត្តុ បដិមល្លាតិ តេសុ ត្វំ កឹ លភេថោ បសូរ ។

(៣១៦) យេសីធ នត្ថី បរមគ្គហីតន្តិ យេសំ អរហន្តានំ ខីណាសវានំ ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ គហិតំ បរាមដ្ឋំ(២) អជ្ឈោសិតំ អធិមុត្តំ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ(៣) បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ យេសីធ នត្ថី បរមគ្គហីតំ ។ តេនាហ ភគវា

វិសេនិកត្វា បន យេ ចរន្តិ
ទិដ្ឋីហិ ទិដ្ឋី អវិរុជ្ឈមានា
តេសុ ត្វំ កឹ លភេថោ បសូរ
យេសីធ នត្ថី បរមគ្គហីតន្តិ ។

---

១ ម. កញ្ច លភេថ ។ ២ ម. ឯត្តួរ អភិនិវិដ្ឋន្តិ ទិស្សតិ ។ ៣ ម. នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ ។

បសូរសុត្តនិទ្ទេស ទី ៨

(៣១៥) ពាក្យថា ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប អ្នកគប្បីបានអ្វី ក្នុងពួកជននោះ សេចក្ដីថា ម្នាលអ្នកជាបុគ្គលក្លៀវក្លាតប ជាបុរសសត្រូវ ជាសត្រូវតប ជាអ្នកផាល់តប់តប អ្នកនឹងបានអ្វី ក្នុងពួកព្រះអរហន្តខីណាស្រពនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលអ្នកជាបុគ្គលក្លៀវក្លា អ្នកគប្បីបានអ្វី ក្នុងពួកជននោះ ។

(៣១៦) ពាក្យថា ការប្រកាន់ថាក្រៃលែង ក្នុងលោកនេះ នៃពួកជនណាមិនមាន គឺការប្រកាន់ ការស្ទាបអង្អែល ការចុះចិត្តស៊ប់ ការបង្អោនទៅថា របស់នេះក្រៃលែង ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ដ៏ឧត្តម ប្រសើរក្រៃលែងដូច្នេះ នៃពួកព្រះអរហន្តខីណាស្រពណា មិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ ផ្ដាច់ផ្ដិល រម្ងាប់ គ្រប់សង្កត់ មិនគួរឲ្យកើតបាន ដុតបំផ្លាញដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការប្រកាន់ថាក្រៃលែង ក្នុងលោកនេះ នៃពួកជនណាមិនមាន ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មួយទៀត ពួកជនណា ធ្វើសេនាឲ្យវិនាស ហើយប្រព្រឹត្តទៅ
ពួកជននោះ មិនប្រទូស្តទិដ្ឋិ ដោយទិដ្ឋិទាំងឡាយ ម្នាលអ្នក
ជាបុគ្គលក្លៀវក្លាតប ការប្រកាន់ថាក្រៃលែង ក្នុងលោកនេះ
នៃពួកជនណាមិនមាន អ្នកគប្បីបានអ្វី ក្នុងពួកជននោះ ។

[៣១៧] អថ ត្វំ បវិតក្កមាគមា
មនសា ទិដ្ឋិគតានិ ចិន្តយន្តោ
ធោនេន យុគំ សមាគមា
ន ហិ ត្វំ សក្ខសិ សម្បយាតវេ ។

[៣១៨] អថ ត្វំ បវិតក្កមាគមាតិ អថាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរី អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ អថាតិ ។ បវិតក្កមាគមាតិ តក្កេត្វា វិតក្កេត្វា សង្កប្បេត្វា(១) ជយោ នុ ខោ មេ ភវិស្សតិ បរាជយោ នុ ខោ មេ ភវិស្សតិ កថំ និគ្គហំ ករិស្សាមិ កថំ បដិកម្មំ ករិស្សាមិ កថំ វិសេសំ ករិស្សាមិ កថំ បដិវិសេសំ ករិស្សាមិ កថំ អាវេឋិយំ ករិស្សាមិ កថំ និព្ពេឋិយំ ករិស្សាមិ កថំ ឆេទំ ករិស្សាមិ កថំ មណ្ឌលំ ករិស្សាមីតិ ឯវំ តក្កេត្វា វិតក្កេត្វា សង្កប្បេត្វា អាគតោសិ ឧបាគតោសិ សម្បត្តោសិ មយា សទ្ធិំ សមាគតោសីតិ អថ ត្វំ បវិតក្កមាគមា ។

[៣១៩] មនសា ទិដ្ឋិគតានិ ចិន្តយន្តោតិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ

---

១ ឱ. ម. តក្កេន្តោ វិតក្កេន្តោ សង្កប្បេន្តោ ។

(៣១៧) មួយទៀត អ្នកត្រិះរិះហើយមក កាលគិតនូវទិដ្ឋិទាំងឡាយ ដោយចិត្ត ហើយមកជួបជុំជាគូ នឹងព្រះពុទ្ធអ្នកមានប្រាជ្ញាកំចាត់ អ្នកមិនអាចដើម្បីដល់នូវគូទេ ។

(៣១៨) អធិប្បាយពាក្យថា មួយទៀត របស់បទថា មួយទៀត អ្នកត្រិះរិះហើយមក ត្រង់ពាក្យថា មួយទៀត គឺជាពាក្យតបទ ជាពាក្យជាប់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត នុះជាលំដាប់បទ ។ ពាក្យថា ត្រិះរិះហើយមក គឺអ្នកកាលត្រិះរិះ ត្រិះរិះផ្សេងៗ ត្រិះរិះព្រម ថាអាត្មាអញនឹងមានជ័យជំនះឬ ឬថាអាត្មាអញនឹងបរាជ័យ អាត្មាអញនឹងធ្វើការសង្កត់សង្កិនដូចម្តេច នឹងធ្វើការដោះតបតដូចម្តេច នឹងធ្វើឲ្យវិសេសដូចម្តេច នឹងធ្វើឲ្យវិសេសតបដូចម្តេច នឹងធ្វើឲ្យច្រុះឆ្ងាយដូចម្តេច នឹងធ្វើនូវការដោះស្រាយដូចម្តេច នឹងធ្វើឲ្យជាប់ដូចម្តេច នឹងធ្វើឲ្យមានមណ្ឌលដូចម្តេច ត្រិះរិះ ត្រិះរិះផ្សេងៗ ត្រិះរិះព្រមយ៉ាងនេះ ហើយមក ចូលមក ដល់មក មកជួបជុំជាមួយនឹងតថាគត ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត អ្នកត្រិះរិះហើយមក ។

(៣១៩) អធិប្បាយពាក្យថា កាលគិតនូវទិដ្ឋិទាំងឡាយ ដោយចិត្ត ត្រង់ពាក្យថា ចិត្តបានដល់ចិត្ត គឺចិត ចំណងក្នុងចិត្ត ហឫទ័យ

មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ ចិត្តេន និដ្ឋិតតានិ ចិន្តេន្តោ វិចិន្តេន្តោ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ មនសា និដ្ឋិតតានិ ចិន្តយន្តោ ។

(៣២០) ធោនេន យុគំ សមាគមា ន ហិ ត្វំ សក្ខសិ សម្បយាតវេតិ ធោនា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ កឹការណា ធោនា វុច្ចតិ បញ្ញា ។ កាយ បញ្ញាយ កាយទុច្ចរិតំ ធុតញ្ច ធោតញ្ច សន្ធោតញ្ច និទ្ធោតញ្ច ។ បេ ។ សព្វាកុសលាភិសង្ខារា ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ អថវា សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋិ ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។ បេ ។ សម្មាវិមុត្តិយា មិច្ឆាវិមុត្តិ ធុតា ច ធោតា ច សន្ធោតា ច និទ្ធោតា ច ។

ភវង្គចិត្ត មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោ-វិញ្ញាណធាតុ កើតអំពីវិញ្ញាណក្ខន្ធនោះ ។ កាលគិត កាលគិតផ្សេងៗ នូវទិដ្ឋិទាំងឡាយដោយចិត្តថា លោកទៀង ឬថា លោកមិនទៀង ។បេ។ ឬថា សត្វបន្ទាប់អំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ហេតុនោះ (ទ្រង់ត្រាស់ថា) កាលគិតនូវទិដ្ឋិទាំងឡាយដោយចិត្ត ។

[៣៤០] ពាក្យថា មកជួបជុំជាគូនឹងព្រះពុទ្ធអ្នកមានប្រាជ្ញាកំចាត់អ្នកមិនអាចដើម្បីដល់នូវគូឡើយ អធិប្បាយថា បញ្ញា លោកហៅថាប្រាជ្ញាកំចាត់ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញប្រពៃ ។ ប្រាជ្ញាដែលលោកហៅថាប្រាជ្ញាកំចាត់ តើព្រោះហេតុអ្វី ។ កាយទុច្ចរិតបុគ្គលកំចាត់បង់ផង លាងផង លាងសំអាតផង កំចាត់ចេញផង ដោយប្រាជ្ញានោះ ។បេ។ អកុសលាភិសង្ខារទាំងអស់ បុគ្គលកំចាត់បង់ផង លាងផង លាងសំអាតផង កំចាត់ចេញផង ។ មួយទៀត មិច្ឆាទិដ្ឋិបុគ្គលកំចាត់បង់ផង លាងផង លាងសំអាតផង កំចាត់ចេញផង ដោយសម្មាទិដ្ឋិ ។បេ។ មិច្ឆាវិមុត្តិ បុគ្គលកំចាត់បង់ផង លាងផង លាងសំអាតផង កំចាត់ចេញផង ដោយសម្មាវិមុត្តិ ។

អថវា អរិយេន អដ្ឋង្គិកេន មគ្គេន សព្វេ អកុស-
លា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា
សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ធុតា ច
ធោតា ច សន្ធោតា ច និទ្ធោតា ច ។ ភគវា ឥ-
មេហិ ធោនេយ្យេហិ ធម្មេហិ ឧបេតោ សមុបេតោ
ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សម-
ន្នាគតោ តស្មា ភគវា ធោនោ ។ សោ ធុតរាគោ
ធុតបាបោ ធុតក្កិលេសោ ធុតបរិឡាហោតិ ធោនោ ។
ធោនេន យុគំ សមាគមា ន ហិ ត្វំ សក្ខសិ សម្បយា-
តវេតិ បសូរោ បរិព្វាជកោ នប្បដិពលោ ធោនេន
ពុទ្ធេន ភគវតា សទ្ធឹ យុគំ សមាគមា សមាគន្ត្វា
យុគគ្គាហំ គណ្ហិតុំ សាកច្ឆេតុំ សល្លបិតុំ សាកច្ឆំ
សមាបជ្ជិតុំ ។ តំ កិស្ស ហេតុ ។ បសូរោ បរិព្វា-
ជកោ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ
បរិត្តោ ។ សោ ហិ ភគវា អគ្គោ ច សេដ្ឋោ ច
វិសេដ្ឋោ ច បាមោក្ខោ ច បវរោ ច ។

មួយទៀត អកុសលទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ សេចក្ដីក្ដៅក្រហាយទាំងអស់ សេចក្ដីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ បុគ្គលកំចាត់បង់ផង លាងផង លាងសំអាតផង កំចាត់ចេញផង ដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ។ ព្រះមានព្រះភាគទ្រង់ចូលទៅដល់ ចូលទៅដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅកៀក ចូលទៅកៀកព្រម ប្រកបដោយគោនេយ្យធម៌ទាំងនេះ ហេតុនោះ ព្រះមានព្រះភាគ ព្រះនាមថា មានប្រាជ្ញាកំចាត់ ។ ព្រះមានព្រះភាគនោះ ទ្រង់បានកំចាត់រាគៈ កំចាត់បាប កំចាត់កិលេស កំចាត់សេចក្ដីក្ដៅក្រហាយ ហេតុនោះ ទ្រង់ព្រះនាមថា មានប្រាជ្ញាកំចាត់ ។ ពាក្យថា មកជួបជុំជាគូនឹងព្រះពុទ្ធ អ្នកមានប្រាជ្ញាកំចាត់ អ្នកឯងមិនអាចដើម្បីដល់នូវគូឡើយ បានសេចក្ដីថា អ្នកជាបរិព្វាជក អ្នកមានសេចក្ដីក្លៀវក្លា មកជួប មកប្រទះ ជាគូនឹងព្រះពុទ្ធ មានព្រះភាគ មានប្រាជ្ញាកំចាត់ មិនអាចនឹងឆ្លើយសាកសួរ ចរចាទៅមក ដល់ព្រមនូវការសាកសួរទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាអ្នកជាបរិព្វាជក មានសេចក្ដីក្លៀវក្លា ជាបុគ្គលថោកទាប ទន់ខ្សោយ ទន់ទាប លាមក អាក្រក់ កំទេចមនុស្ស ។ ចំណែកព្រះមានព្រះភាគនោះ ជាកំពូលផង ប្រសើរផង ប្រសើរវិសេសផង ជាប្រធានផង ប្រសើរក្រៃលែងផង ។

យថា សរភោ អប្បដិពលោ មត្តេន មាតង្គេន សទ្ធឹ
យុទ្ធំ សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ គណ្ហិតុំ យថា
កោដ្ឋុកោ អប្បដិពលោ សីហេន មិគរញ្ញា សទ្ធឹ យុទ្ធំ
សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ គណ្ហិតុំ យថា វច្ឆកោ
តរុណកោ ធេនុបកោ អប្បដិពលោ ឧសភេន ចលក-
ក្កកុធា សទ្ធឹ យុទ្ធំ សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ
គណ្ហិតុំ យថា ធង្កោ អប្បដិពលោ គរុឡេន វេនតេ-
យ្យេន សទ្ធឹ យុទ្ធំ សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ
គណ្ហិតុំ យថា ចណ្ឌាលោ អប្បដិពលោ រញ្ញា ចក្ក-
វត្តិនា សទ្ធឹ យុទ្ធំ សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ
គណ្ហិតុំ យថា បំសុបិសាចកោ អប្បដិពលោ ឥន្ទេន
ទេវរញ្ញា សទ្ធឹ យុទ្ធំ សមាគមា សមាគន្ត្វា យុទ្ធគ្គាហំ
គណ្ហិតុំ ឯវមេវ បសូរោ បរិព្វាជកោ អប្បដិពលោ
ធោនេន ពុទ្ធេន ភគវតា សទ្ធឹ យុទ្ធំ សមាគមា
សមាគន្ត្វា យុទ្ធគ្គាហំ គណ្ហិតុំ សាកច្ឆិតុំ សល្ល-
បិតុំ សាកច្ឆំ សមាបជ្ជិតុំ ។ តំ កិស្ស ហេតុ ។

## បសូរសុត្តនិទ្ទេស ទី ៨

ទន្សាយបានមកប្ជួប មកប្រទះ ជាគូគ្នានឹងដំរីសារដែលចុះប្រេង មិនអាចផ្គួបានយ៉ាងណា ចចកមកប្ជួប មកប្រទះ ជាគូគ្នានឹងសីហៈ ជាមិគរាជ មិនអាចផ្គួបានយ៉ាងណា កូនគោនៅតូចកំពុងបៅមេ បានមកប្ជួប មកប្រទះ ជាគូគ្នានឹងគោឧសភដែលមានបូកដ៏មាំ មិនអាចផ្គួបានយ៉ាងណា ក្អែកបានមកប្ជួប មកប្រទះ ជាគូគ្នានឹងគ្រុឌ វេនតេយ្យ មិនអាចផ្គួបានយ៉ាងណា មនុស្សចណ្ឌាល បានមកប្ជួប មកប្រទះ ជាគូគ្នានឹងស្តេចចក្រពត្តិ មិនអាចផ្គួបានយ៉ាងណា បំសុបិសាច បានមកប្ជួប មកប្រទះ ជាគូគ្នានឹងព្រះឥន្ទ្រជាស្តេចទេវតា មិនអាចផ្គួបានយ៉ាងណា អ្នកជាបរិព្វាជក មានសេចក្តីក្លៀវក្លា បានមកប្ជួប មកប្រទះ ជាគូគ្នានឹងព្រះពុទ្ធមានព្រះភាគ អ្នកមានប្រាជ្ញាកំពាត់ មិនអាចនឹងផ្គួ សាកសួរ ចរចាទៅមក ដល់នូវការសាកសួរ ក៏យ៉ាងនោះដែរ ៗ ដំណើរនោះ ព្រោះហេតុអ្វី ៗ

បស្សេក បរិញ្ញាជកោ ហីនបញ្ញោ និហីនបញ្ញោ ឱមកបញ្ញោ លាមកបញ្ញោ ជតុក្កបញ្ញោ បរិត្តបញ្ញោ ។ សោ ហិ ភគវា មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្វេធិកបញ្ញោ បញ្ញាបភេទកុសលោ បភិន្នញាណោ អធិគតបដិសម្ភិទោ ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរយ្ហោ អនន្តញាណោ អនន្តតេជោ អនន្តយសោ អឌ្ឍោ មហទ្ធនោ ធនវា នេតា វិនេតា អនុនេតា សញ្ញាបេតា និជ្ឈាបេតា បេក្ខេតា បសាទេតា ។ សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ ។ មគ្គានុគា ច បនស្ស ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតា ។ សោ ហិ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ

ព្រោះថាអ្នកជាបរិព្វាជក មានសេចក្តីក្រៀវក្រា តែមានប្រាជ្ញាថោកទាប មានប្រាជ្ញាទន់អន់ មានប្រាជ្ញាទន់ទាប មានប្រាជ្ញាលាមក មានប្រាជ្ញាអាក្រក់ មានប្រាជ្ញាតិចតួច ។ ចំណែកព្រះមានព្រះភាគ អង្គនោះ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមុត មានប្រាជ្ញាជាគ្រឿងទំលុះទំលាយ ទ្រង់ឈ្លាសក្នុងប្រភេទប្រាជ្ញា ទ្រង់បែកព្រះញាណ ទ្រង់បានសម្រេចបដិសម្ភិទា ទ្រង់ដល់នូវចតុវេសារជ្ជញាណ ទ្រទ្រង់នូវកំឡាំង ១០ ជាបុរសអាសភៈ ជាបុរសសីហៈ ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសអាចនាំទៅនូវធុរៈបាន មានអនន្តញាណ មានតេជៈ មិនមានទីបំផុត មានយសមិនមានទីបំផុត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធន ជាអ្នកណែនាំ ទូន្មាន ប្រៀនប្រដៅ ពន្យល់ ឲ្យពិនិត្យ សំឡឹង ឲ្យរំលឹក ។ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ញុំាងមគ្គដែលមិនទាន់កើតព្រមឲ្យកើតព្រម ប្រាប់ផ្លូវដែលគេមិនធ្លាប់ប្រាប់ ទ្រង់ស្គាល់ផ្លូវ ជ្រាបច្បាស់នូវផ្លូវ វាងវៃក្នុងផ្លូវ ។ មួយទៀត ឥឡូវនេះ ពួកសាវ័កនៃព្រះមានព្រះភាគនោះ ជាអ្នកដើរតាមផ្លូវប្រកប (ដោយគុណ) ក្នុងកាលជាខាងក្រោយ ។ ព្រោះព្រះមានព្រះភាគនោះ ទ្រង់ជ្រាបហេតុ ដែលគួរជ្រាប ទ្រង់ឃើញហេតុ ដែលគួរឃើញ ព្រះអង្គមានចក្ខុ មានញាណ មានធម៌

ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ ។ នត្ថិ តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុស្សិតំ បញ្ញាយ ។ អតីតំ អនាគតំ បច្ចុប្បន្នំ ឧបាទាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ ។ យង្កិញ្ចិ នេយ្យំ នាម អត្ថិ(១) ជានិតព្វំ ។ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា អត្ថោ គូឡ្ហោ វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា អត្ថោ អនវជ្ជោ វា អត្ថោ និក្កិលេសោ វា អត្ថោ វោទានោ វា អត្ថោ បរមត្ថោ វា អត្ថោ សព្វន្តំ អន្តោពុទ្ធញាណេ បរិវត្តតិ ។ សព្វំ កាយកម្ម ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ សព្វំ វចីកម្មំ ញាណានុបរិវត្តិ សព្វំ មនោកម្មំ ញាណានុបរិវត្តិ ។ អតីតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ

---

១. ម. អត្ថិ សព្វំ ។

## បញ្ហាសុត្តនិទ្ទេស ទី ៨

ព្រះអគ្គជាបុគ្គលប្រសើរ ពោលធម៌ ពោលដោយប្រការផ្សេងៗ ទ្រង់នាំចេញនូវប្រយោជន៍ ទ្រង់ឲ្យអមតៈ ជាធម្មស្សាមី ជាតថាគត ។ ការមិនដឹង មិនឃើញ មិនយល់ច្បាស់ មិនធ្វើឲ្យជាក់ច្បាស់ មិនប៉ះពាល់ដោយប្រាជ្ញា នៃព្រះមានព្រះភាគនោះ មិនមានទេ ។ ធម៌ទាំងអស់ដែលអាស្រ័យអតីត អនាគត និងបច្ចុប្បន្ន រមែងមកកាន់គន្លងចំមុខព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ ដោយអាការសព្វគ្រប់ ។ ធម្មជាតអ្វីមួយដែលគួរដឹង ត្រូវដឹង ។ ប្រយោជន៍ខ្លួនផង ប្រយោជន៍បុគ្គលដទៃផង ប្រយោជន៍ទាំងពីរផង ប្រយោជន៍ជាបច្ចុប្បន្នផង ប្រយោជន៍ក្នុងខាងមុខផង ប្រយោជន៍រាក់ផង ប្រយោជន៍ជ្រៅផង ប្រយោជន៍លាក់ផង ប្រយោជន៍កំបាំងផង ប្រយោជន៍ ដែលត្រូវនាំចេញផង ប្រយោជន៍ដែលនាំចេញហើយផង ប្រយោជន៍មិនមានទោសផង ប្រយោជន៍មិនមានកិលេសផង ប្រយោជន៍ផូរផង់ផង ប្រយោជន៍ដ៏ក្រៃលែងផង ធម្មជាតទាំងអស់នោះ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងពុទ្ធញាណ ។ កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ មនោកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះមានព្រះភាគ ។ ព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ មិនទើសទាល់ក្នុងអតីតកាល

អនាគតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ បច្ចុប្បន្នេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ ។ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ ។ នេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា នេយ្យបថោ នត្ថិ ។ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ តេ ធម្មា ។ យថា ទ្វិន្នំ សមុគ្គបដលានំ សម្មាផុសិតានំ ហេដ្ឋិមំ សមុគ្គបដលំ ឧបរិមំ នាតិវត្តតិ ឧបរិមំ សមុគ្គបដលំ ហេដ្ឋិមំ នាតិវត្តតិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ ឯវមេវ ពុទ្ធស្ស ភគវតោ នេយ្យញ្ច ញាណញ្ច អញ្ញមញ្ញបរិយន្តដ្ឋាយិនោ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ នេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា នេយ្យបថោ នត្ថិ អញ្ញមញ្ញបរិយន្តដ្ឋាយិនោ តេ ធម្មា ។ សព្វធម្មេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។

ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនទើសទាល់ក្នុងអនាគតកាល ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនទើសទាល់ក្នុងបច្ចុប្បន្នកាល របស់ដែលត្រូវដឹងមានចំនួនប៉ុន្មាន ព្រះញាណក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានចំនួនប៉ុន្មាន របស់ដែលត្រូវដឹងក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានរបស់ដែលត្រូវដឹង ជាទីបំផុត របស់ដែលត្រូវដឹងមានព្រះញាណជាទីបំផុត ។ ព្រះញាណមិនប្រព្រឹត្តកន្លងរបស់ ដែលត្រូវដឹង ឯគន្លងដែលត្រូវដឹង ក៏មិនកន្លងព្រះញាណ ។ ធម៌ទាំងនោះ ឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ បាតស្មុគទាំងពីរ ដែលគេត្របយ៉ាងជិតស្និទ្ធ បាតស្មុគខាងក្រោម រមែងមិនប្រព្រឹត្តកន្លងបាតស្មុគខាងលើ បាតស្មុគខាងលើ រមែងមិនប្រព្រឹត្តកន្លងបាតស្មុគខាងក្រោម បាតស្មុគទាំងពីរ ឋិតនៅក្នុងទីបំផុត នៃគ្នានឹងគ្នា យ៉ាងណាមិញ របស់ដែលត្រូវដឹងនឹងព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ឋិតនៅក្នុងទីបំផុត នៃគ្នានឹងគ្នា ក៏យ៉ាងនោះដែរ របស់ដែលត្រូវដឹងមានចំនួនប៉ុន្មាន ព្រះញាណក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានចំនួនប៉ុន្មាន របស់ដែលត្រូវដឹងក៏មានចំនួនប៉ុណ្ណោះ ព្រះញាណមានរបស់ដែលត្រូវដឹងជាទីបំផុត របស់ដែលត្រូវដឹង មានព្រះញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងរបស់ដែលត្រូវដឹង ឯគន្លងដែលត្រូវដឹង ក៏មិនកន្លងព្រះញាណ ធម៌ទាំងនោះ ឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ

អដ្ឋមោ បស្សរសុត្តនិទ្ទេសោ

សព្វេ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនប្បដិពទ្ធា អាកង្ខប្បដិពទ្ធា មនសិការប្បដិពទ្ធា ចិត្តុប្បាទប្បដិពទ្ធា ។ សព្វសត្តេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេសំ សត្តានំ ភគវា អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ ។ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោមហាសមុទ្ទេ បរិវត្តន្តិ ឯវមេវ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ បក្ខី អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវ យេបិ តេ សារីបុត្តសមា បញ្ញាយ

ប្រព្រឹត្តទៅ ក្នុងធម៌ទាំងពួង ធម៌ទាំងអស់ ជាប់ចំពោះ ដោយការនឹក ជាប់ដោយការប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទ របស់ព្រះពុទ្ធ មានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធ មានព្រះភាគ ប្រព្រឹត្តទៅក្នុងសត្វទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យ ជ្រាបអនុស័យ ជ្រាបចរិត ជ្រាបការចុះចិត្តស៊ប់ របស់សត្វទាំងអស់ ជ្រាបពួកសត្វមានធូលី ក្នុងភ្នែកតិច មានធូលីក្នុងភ្នែកច្រើន មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងដោយងាយ ឲ្យដឹងដោយលំបាក មានភ័ព្វនឹងឥតភ័ព្វ ។ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងព្រះពុទ្ធញ្ញាណ ។ ពួកត្រីនឹងអណ្តើកណាមួយ រាប់យកត្រីឈ្មោះតិមិតិមិង្គលៈ ដោយហោចទៅ រមែងប្រព្រឹត្តទៅ ក្នុងខាងក្នុងមហាសមុទ្រ យ៉ាងណា លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ មនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅក្នុងខាងក្នុងពុទ្ធញ្ញាណ យ៉ាងនោះដែរ ។ ពួកបក្សីណាមួយ រាប់យកគ្រុឌវេនតេយ្យដោយទីបំផុត រមែងប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាស យ៉ាងណា ជនទាំងឡាយណា មានប្រាជ្ញាស្មើនឹងព្រះសារីបុត្រ

តេបិ ពុទ្ធញាណស្ស បទេសេ បវត្តន្តិ ។ ពុទ្ធញាណំ ទេវមនុស្សានំ បញ្ញំ ផរិត្វា អភិភវិត្វា តិដ្ឋតិ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា វោភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ តេ បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ ។ កថិតា ច វិសជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច ។ តេ ភគវតោ សម្បជ្ជន្តិ ។ អថ ខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញាយាតិ ធោនេន យុគំ សមាគមា ន ហិ ត្វំ សក្ខសិ សម្បយាតវេ ។ តេនាហ ភគវា

អថ ត្វំ បវិតក្កមាគមា
មនសា ទិដ្ឋិគតានិ ចិន្តយន្តោ
ធោនេន យុគំ សមាគមា
ន ហិ ត្វំ សក្ខសិ សម្បយាតវេតិ ។

អដ្ឋមោ បសូរសុត្តនិទ្ទេសោ និដ្ឋិតោ ។

ជនទាំងនោះ រមែងប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញាណ យ៉ាងនោះដែរ ៖ ព្រះពុទ្ធញាណ ផ្សាយទៅគ្របសង្កត់នូវប្រាជ្ញានៃទេវតានិងមនុស្ស ។ ទោះបីជនពួកណា ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី មានបញ្ញាល្អិត ស្គាល់វាទៈរបស់ជនដទៃ កាលទំលាយទិដ្ឋិទាំងឡាយរបស់ជនដទៃ ដោយប្រាជ្ញារបស់ខ្លួន ទំនងដូចជាខ្មាន់ធ្នូស្ទាត់បាញ់រោមទ្រាយ ពួកជននោះ តាក់តែងរឿយៗនូវប្រស្នា រួចចូលទៅសួរព្រះតថាគត ។ ប្រស្នាទាំងនោះ ដែលព្រះមានព្រះភាគទ្រង់សំដែងដោះស្រាយហើយផង ជាប្រស្នាមានហេតុដែលសំដែងចេញហើយផង ជាប្រស្នាដែលដាក់ហើយផង ។ បណ្ឌិតទាំងនោះ បានសម្រេច (សម្បត្តិជាសាវកឬឧបាសក ដោយការដោះស្រាយ) របស់ព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងដោយបញ្ញាក្នុងកណ្តាលបរិស័ទនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) មកបួបជុំជាគូនឹងព្រះពុទ្ធព្រះអង្គមានធោនា អ្នកមិនអាច ដើម្បីដល់នូវគូទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មួយទៀត អ្នកត្រិះរិះហើយមក កាលគិតនូវទិដ្ឋិទាំងឡាយ
ដោយចិត្ត ហើយមកបួបជុំ ជាគូនឹងព្រះពុទ្ធ ទ្រង់មាន
ប្រាជ្ញាកំចាត់អ្នកឯងមិនអាច ដើម្បីដល់នូវគូទេ ។

ចប់ បសូរសុត្តនិទ្ទេស ទី ៨ ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

## តេរសមោ ភាគោ

---

| មាតិកា | | អង្កេ |
|---|---|---|
| មហានិទ្ទេសេ | បឋមោ កាមសុត្តនិទ្ទេសោ | ១ |


ទ្វេ កាមា . . . . . . . . . . . ,,

មនាបិករូបាទយោ វត្ថុកាមា . . . . . ៣

កាមា បរិហាយន្តិ . . . . . . . . . ៧

ទ្វីហិ ការណេហិ កាមេ បរិវជ្ជេតិ . . ៩

វិក្ខម្ភនតោ កាមេ បរិវជ្ជេតិ . . . . . ,,

សមុច្ឆេទតោ កាមេ បរិវជ្ជេតិ . . . . ១២

តណ្ហា វិសត្តិកា . . . . . . . . ១៣

ចតូហិ ការណេហិ សតោ . . . . . ១៦

យវត្ថអាទីនិ . . . . . . . . . ,,

ចត្តារោ ពាសា . . . . . . . ១៩

តយោ បុរិសា . . . . . . . . . ,,

ចត្តារោ ពន្ថ . . . . . . . . . ១៩

ខត្តិយាទយោ នរ . . . . . . . . ២០

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# តេរសមភាគ

---

មាតិកា ទំព័រ


| | | |
|---|---|---|
| មហានិទ្ទេស | កាមសុត្តនិទ្ទេស ទី ១ | ១ |
| | *កាម ២ យ៉ាង* . . . . . . . . . . . . . . | ,, |
| | *រូបជាទីគាប់ចិត្តជាដើម ជាវត្ថុកាម* . . . . . | ៣ |
| | *កាមសាបសូន្យ (ចាកសត្វ)* . . . . . . . . . | ៧ |
| | *លះវៀរកាមដោយហេតុ ២ យ៉ាង* . . . . . . . | ៩ |
| | *លះវៀរកាមដោយវិក្ខម្ភនៈ* . . . . . . . . . . . | ,, |
| | *លះវៀរកាមដោយសមុច្ឆេទ* . . . . . . . . . | ១២ |
| | *តណ្ហា ជាវិសត្តិកា* . . . . . . . . . . . . . . | ១៣ |
| | *មានស្មារតី ដោយហេតុ ៤ យ៉ាង* . . . . . . . | ១៦ |
| | *ទីផ្ទះជាដើម* . . . . . . . . . . . . . . . . . | ១៨ |
| | *ទាសៈ (បាវ) ៤ ពួក* . . . . . . . . . . . | ១៩ |
| | *បុរស ៤ ពួក* . . . . . . . . . . . . . . . . | ,, |
| | *ផៅពន្ធ ៤* . . . . . . . . . . . . . . . . . | ,, |
| | *នរៈ មានខត្តិយៈជាដើម* . . . . . . . . . . . | ២០ |

# មាតិកាបត្តានិ

មាតិកា អង្កេ

មហានិទ្ទេសេ បឋមោ កាមសុត្តនិទ្ទេសោ

ទ្វេ បរិស្សយា . . . . . . . . . . ២២

សាន្តេវាសិកោ ភិក្ខុ . . . . . . . ២៥

សាចរិយកោ ភិក្ខុ . . . . . . . ”

តយោ អន្តរាមលា . . . . . . . ២៧

អមតំ បុរំ . . . . . . . . . . ៣៦

ព្រាហ្មណោ បារគូ . . . . . . . . ”

ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ ៤១

កាយោ គុហា . . . . . . . . . ”

មោហនស្មិំ បគាឡ្ហា នរា . . . . . ៤៥

បញ្ច កាមគុណា មោហនា . . . . . ”

តយោ វិវេកា . . . . . . . . . . ៤៦

ខន្ធកិលេសាភិសង្ខារ ឧបធី . . . . . ៤៨

ទ្វេ កាមា . . . . . . . . . . ៤៩

អបាយាទយោ លោកា . . . . . . . ៥១

តណ្ហា ឥញ្ជា . . . . . . . . . . ៥៣

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ


មហានិទ្ទេស កាមសុត្តនិទ្ទេស ទី ១

បរិស្សយៈ (អន្តរាយ) ២ យ៉ាង . . . . . . . . ២២

ភិក្ខុមានបាបធម៌ជាអន្តេវាសិក . . . . . . . . ២៥

ភិក្ខុមានបាបធម៌ ជាអាចារ្យ . . . . . . . . . . ,,

ធម៌ ៣ យ៉ាង ជាមន្ទិលខាងក្នុង . . . . . . . . ២៧

ព្រះនិព្វាន ជាបារៈ (ត្រើយ) . . . . . . . . . . ៣៦

ព្រាហ្មណ៍ (អរហន្ត) ជាបារគូ . . . . . . . . . ,,

គុហដ្ឋកសុត្តនិទ្ទេស ទី ២ ៤១

កាយ ឈ្មោះថាគុហា . . . . . . . . . . . . . ,,

ជនលិចចុះក្នុងគ្រឿងវង្វេង . . . . . . . . . . ៤៥

កាមគុណ ៥ ឈ្មោះថាមោហនៈ (គ្រឿងវង្វេង) . ,,

វិវេក (ការស្ងាត់) ៣ យ៉ាង . . . . . . . . . . ៤៦

ខន្ធ កិលេស និងអភិសង្ខារ ជាឧបធិ . . . . . ៤៨

កាម ២ យ៉ាង . . . . . . . . . . . . . . . . ៤៩

លោកមានអបាយលោកជាដើម . . . . . . . ៥១

តណ្ហា ជាឥច្ឆា (សេចក្តីប្រាថ្នា) . . . . . . . ៥៣

# មាតិកាបត្តានិ

មាតិកា — អង្កេ


មហានិទ្ទេសេ ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ

ទ្វិភវសាតាទីនិ . . . . . . . . . ៥៥

ភវសាតវត្ថុ ទុប្បមុញ្ចា . . . . . . . ៥៦

បុរេ អបេក្ខំ ករោតិ . . . . . . . . ៦០

បច្ឆា អបេក្ខំ ករោតិ . . . . . . . . ៦១

ទ្វេ កាមា . . . . . . . . . . . . ៦៤

មច្ឆរិនោ អវទានិយា . . . . . . . . . ៦៨

បញ្ច មច្ឆរិយានិ . . . . . . . . . . . ,,

វិសមេ និវិដ្ឋា សត្តា . . . . . . . . . ៦៩

តិស្សោ សិក្ខា . . . . . . . . . . . . ៧២

ទ្វីហិ ការណេហិ អប្បកំ ជីវិតំ . . . . ៧៧

កាយកម្មាទីហិ ហីនា សត្តា . . . . . . ៨៧

ទ្វេ មមត្តា . . . . . . . . . . . . . ៨៩

តណ្ហាមមត្តំ . . . . . . . . . . . . . ៩០

ទិដ្ឋិមមត្តំ . . . . . . . . . . . . . ,,

តណ្ហា អាសត្តិ . . . . . . . . . . . ៩៣

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## មហានិទ្ទេស គុហដ្ឋកសុត្តនិទ្ទេស ទី ២


ភវសាតៈ ២ យ៉ាងជាដើម . . . . . . . . . ៥៥

វត្ថុនៃភវសាតៈ ដែលសត្វដោះបានដោយក្រ . ៥៦

ធ្វើនូវសេចក្តីប្រាថ្នាក្នុងកាលមុន . . . . . . . ៦០

ធ្វើនូវសេចក្តីប្រាថ្នា ក្នុងកាលខាងក្រោយ . . . ៦១

កាម ២ យ៉ាង . . . . . . . . . . . . . . ៦៤

ជនកំណាញ់ ឈ្មោះអវទានិយៈ (អ្នកប្រកាន់ថោក) ៦៨

សេចក្តីកំណាញ់ ៥ យ៉ាង . . . . . . . . . . ,,

ពួកសត្វ តាំងនៅក្នុងវិសមកម្ម . . . . . . . ៦៩

សិក្ខា ៣ យ៉ាង . . . . . . . . . . . . . . ៧២

ជីវិតតិច ដោយហេតុ ២ យ៉ាង. . . . . . ៧៧

សត្វថោកទាបដោយកាយកម្មជាដើម . . . ៨៧

ការប្រកាន់ ២ យ៉ាង. . . . . . . . . ៨៩

ការប្រកាន់ដោយតណ្ហា . . . . . . . ៩០

ការប្រកាន់ដោយទិដ្ឋិ . . . . . . . . ,,

តណ្ហា ជាគ្រឿងជាប់ចំពាក់ . . . . . . . ៩៣

# មាតិកាបត្តានិ

មាតិកា អង្កេ

## មហានិទ្ទេសេ ទុតិយោ គុហដ្ឋកសុត្តនិទ្ទេសោ


ទ្វេ ទ្វេ អត្តា . . . . . . . . . . . . . . ៩៤

តិស្សោ បរិញ្ញា . . . . . . . . . . . . . ៩៦

តណ្ហា គេហោ . . . . . . . . . . . . . ៩៨

ទ្វីហិ ការណេហិ អត្តានំ គរហតិ . . . ៩៩

ទ្វេ លេបា . . . . . . . . . . . . . . ១០២

សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ . . . . . ១០៤

កាមសញ្ញាទិកា . . . . . . . . . . . ”

ទ្វេ បរិគ្គហា . . . . . . . . . . . . . ១០៦

តីណិ មោនេយ្យានិ . . . . . . . . . ”

ឆ មុនយោ . . . . . . . . . . . . . . ១០៨

សត្ត សល្លានិ . . . . . . . . . . . . . ១១០

តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ ១១៤

ទ្វីហិ ការណេហិ វាទំ ឧបេតិ . . . . . ១១៥

មុនិ ទ្វីហិ ការណេហិ វាទំ ន ឧបេតិ . ១១៦

សីលញ្ច វត្តញ្ច . . . . . . . . . . . . ១២៣

# សន្លឹកប្រាប់មាតិកា

| មាតិកា | ទំព័រ |
|---|---|

## មហានិទ្ទេស

### គុហដ្ឋកសុត្តនិទ្ទេស ទី ២


ទីបំផុតពីរ ៗ យ៉ាង . . . . . . . . . ៩៤

បរិញ្ញា (ការកំណត់ដឹង) . . . . . . . ៩៦

តណ្ហា ជាគេធៈ (គ្រឿងជាប់ចំពាក់) . . . ៩៨

តិះដៀលខ្លួនដោយហេតុ ២ យ៉ាង . . . . ៩៩

គ្រឿងប្រឡាក់ ២ យ៉ាង . . . . . . . . ១០២

បណ្ឌិតគប្បីឆ្លងឱឃៈ ព្រោះកំណត់ដឹងនូវសញ្ញា . ១០៤

កាមសញ្ញាជាដើម . . . . . . . . . . . . ,,

ការហួងហែង ២ យ៉ាង . . . . . . . . . . ១០៦

មោនេយ្យៈ ៣ យ៉ាង . . . . . . . . . . . ,,

មុនិ ៦ យ៉ាង . . . . . . . . . . . . . ១០៨

ព្រួញ ៧ យ៉ាង . . . . . . . . . . . . ១១០


### ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣ ១១៤


អើពើនូវវាទៈ ដោយហេតុ ២ យ៉ាង . . . . . ១១៥

មុនិ មិនអើពើនូវវាទៈ ដោយហេតុ ២ យ៉ាង . . ១១៦

សីលនឹងវត្ត . . . . . . . . . . . . . ១២៣

# មាតិកាបត្តានិ

| មាតិកា | អង្ក |
|---|---|

## មហានិទ្ទេសេ តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ


អដ្ឋ ធុតង្គានិ . . . . . . . . . . . . . . . ១២៣

រាគាទីនំ សន្តត្តា សន្តោ . . . . . . . . ១៣០

សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ . . . . . . . ១៣១

សត្តុស្សទា . . . . . . . . . . . . . . . . ១៣៣

ទ្វេ បកប្បនា . . . . . . . . . . . . . . . ១៣៤

ទ្វេ បុរេក្ខារា . . . . . . . . . . . . . . . ”

អត្តនោ ទិដ្ឋិយា ទ្វេ អានិសង្សេ បស្សតិ ១៣៦

ទិដ្ឋិយា ទិដ្ឋធម្មិកោ អានិសង្សោ . . . . ១៣៧

ទិដ្ឋិយា សម្បរាយិកោ អានិសង្សោ . . . ”

តិស្សោ សន្តិយោ . . . . . . . . . . . . . ១៣៨

ទ្វីហិ ការណេហិ និទស្សេតិ . . . . . . . ១៤៣

ទុវិធេន មានោ . . . . . . . . . . . . . ១៤៨

តិវិធេន មានោ . . . . . . . . . . . . . ”

ចតុព្វិធេន មានោ . . . . . . . . . . . ”

បញ្ចវិធេន មានោ . . . . . . . . . . . ”

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| **មហានិទ្ទេស** ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣ | |
| ធុតង្គ ៨ យ៉ាង | ១៦៣ |
| ដែល ជាសន្តៈ ព្រោះស្ងប់រាគៈជាដើម | ១៣០ |
| ដែលជាភិក្ខុ ព្រោះទំលាយធម៌ ៧ យ៉ាង | ១៣១ |
| ឧស្សទៈ (កិលេសដ៏ក្រាស) ៧ យ៉ាង | ១៣៣ |
| គ្រឿងសម្រេច ២ យ៉ាង | ១៣៥ |
| បុរេក្ខារៈ (ការធ្វើឲ្យតាំងនៅក្នុងខាងមុខ) ២ យ៉ាង | ” |
| ឃើញអានិសង្ស ២ យ៉ាងនៃទិដ្ឋិរបស់ខ្លួន | ១៣៦ |
| អានិសង្សក្នុងបច្ចុប្បន្ននៃទិដ្ឋិ | ១៣៧ |
| អានិសង្សក្នុងបរលោកនៃទិដ្ឋិ | ” |
| សន្តិ (សេចក្តីស្ងប់) ៣ យ៉ាង | ១៣៨ |
| លះបង់ (នូវសាស្តាជាដើម) ដោយហេតុ ២ យ៉ាង | ១៤៣ |
| មានះដោយចំណែក ២ | ១៤៨ |
| មានះដោយចំណែក ៣ | ” |
| មានះដោយចំណែក ៤ | ” |
| មានះដោយចំណែក ៥ | “ |

# មាតិកាបត្តានី


| មាតិកា | អង្កេ |
|---|---|
| មហានិទ្ទេសេ តតិយោ ទុដ្ឋដ្ឋកសុត្តនិទ្ទេសោ | |
| ឆព្វិធេន មានោ . . . . . . . . . . . . . | ១៤៨ |
| សត្តវិធេន មានោ . . . . . . . . . . . | ១៤៩ |
| អដ្ឋវិធេន មានោ . . . . . . . . . . . . | ,, |
| នវវិធេន មានោ . . . . . . . . . . . . | ,, |
| ទសវិធេន មានោ . . . . . . . . . . . . | ១៥០ |
| ទ្វេ ឧបយា . . . . . . . . . . . . . . | ,, |
| ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ | ១៥៧ |
| រូបានំ ទស្សនំ មង្គលំ . . . . . . . . | ១៦៤ |
| រូបានំ ទស្សនំ អមង្គល . . . . . . . | “ |
| វត្តសុទ្ធិកា សមណព្រាហ្មណា . . . . . | ១៦៧ |
| មុតសុទ្ធិកា សមណព្រាហ្មណា . . . . | ១៦៨ |
| ហត្ថិវត្តាទីនិ . . . . . . . . . . . . . | ១៧៤ |
| បត្តស្ស មគ្គស្ស ញាណំ វេទោ . . . | ១៧៥ |
| សត្តន្នំ ធម្មានំ វិទិតត្តា វេទគូ . . . . | ១៧៦ |
| កាយទុច្ចរិតាទិកា មារសេនា . . . . . | ១៨០ |

# សន្លឹកប្រាប់មាតិកា

| មាតិកា | ទំព័រ |
|---|---|

## មហានិទ្ទេស ទុដ្ឋដ្ឋកសុត្តនិទ្ទេស ទី ៣


មានះដោយចំណែក ៦ . . . . . . . . . . . ១៤៨

មានះដោយចំណែក ៧ . . . . . . . . . . . ១៤៩

មានះដោយចំណែក ៨ . . . . . . . . . . . „

មានះដោយចំណែក ៩ . . . . . . . . . . . „

មានះដោយចំណែក ១០ . . . . . . . . . . . ១៥០

ឧបយៈ (ការអែបអែប) ២ យ៉ាង . . . . . . . „

សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤ ១៥៧

ការឃើញរូប ជាមង្គល . . . . . . . . . . ១៦៤

ការឃើញរូប ជាអមង្គល . . . . . . . . . . „

ពួកសមណព្រាហ្មណ៍ ជាវត្តសុទ្ធិកៈ . . . . ១៦៧

ពួកសមណព្រាហ្មណ៍ ជាមុតសុទ្ធិកៈ . . . . ១៦៨

វត្ថុ ៨ ជាដើម . . . . . . . . . . . . . ១៧៤

ញាណក្នុងមគ្គ ៤ ឈ្មោះថាវេទ . . . . . . . ១៧៥

ឈ្មោះថាវេទគូ ព្រោះដឹងធម៌ ៧ . . . . . . ១៧៦

មារសេនា មានកាយទុច្ចរិតជាដើម . . . . ១៨១

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
| --- | --- | --- |
| មហានិទ្ទេសេ | ចតុត្ថោ សុទ្ធដ្ឋកសុត្តនិទ្ទេសោ | |
| | ទ្វេ កប្បា | ១៨២ |
| | ទ្វេ បុរេក្ខារា | ១៨៥ |
| | ចត្តារោ គន្ថា | ១៨៦ |
| | ចតស្សោ សីមាយោ | ១៨៩ |
| | បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ | ១៩៣ |
| | ទិដ្ឋិយា ទិដ្ឋធម្មិកា អានិសំសា | ១៩៦ |
| | ទិដ្ឋិយា សម្បរាយិកា អានិសំសា | ១៩៧ |
| | មុតសុទ្ធិយា ទិដ្ឋធម្មិកា អានិសំសា | ១៩៨ |
| | មុតសុទ្ធិយា សម្បរាយិកា អានិសំសា | ,, |
| | ទ្វេ ទ្វេ អន្តា | ២០៦ |
| | ទ្វេ និវេសនា | ២០៨ |
| | ទ្វេ កប្បា | ២១៣ |
| | ទ្វេ បុរេក្ខារា | ២១៤ |
| | អមតំ និព្ពានំ បារំ | ២១៦ |
| | អរហា បញ្ចហាការេហិ តាទិ | ២១៧ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | **សុទ្ធដ្ឋកសុត្តនិទ្ទេស ទី ៤** | |
| | កប្បៈ (ការកំណត់) ២ យ៉ាង ....... | ១៨២ |
| | បុរេក្ខារៈ (ការធ្វើឲ្យជាប្រធាន) ២យ៉ាង ... | ១៨៥ |
| | គន្ថៈ ៤ យ៉ាង ............... | ១៨៦ |
| | សីមា (ព្រំដែន) ៤ យ៉ាង ....... | ១៨៩ |
| | **បរមដ្ឋកសុត្តនិទ្ទេស ទី ៥** | ១៩៣ |
| | ទិដ្ឋធម្មិកានិសង្ស នៃទិដ្ឋិ ......... | ១៩៦ |
| | សម្បរាយិកានិសង្សនៃទិដ្ឋិ ....... | ២៩៧ |
| | ទិដ្ឋធម្មិកានិសង្ស នៃមុតសុទ្ធិ ...... | ១៩៨ |
| | សម្បរាយិកានិសង្ស នៃមុតសុទ្ធិ .... | ,, |
| | ទីបំផុត ពីរ ៗ ............. | ២០៦ |
| | និវេសនា (ជម្រក) ២ យ៉ាង ...... | ២០៨ |
| | កប្បៈ (ការកំណត់) ២ យ៉ាង ...... | ២១៣ |
| | បុរេក្ខារៈ (ការធ្វើឲ្យជាប្រធាន) ២ យ៉ាង .. | ២១៤ |
| | អមតនិព្វាន ឈ្មោះថាបារៈ (ត្រើយ) .. | ២១៦ |
| | ព្រះអរហន្ត នឹងធឹងដោយអាការៈ៥ យ៉ាង . | ២១៧ |

# មាតិកាបត្តានិ


| មាតិកា | | អង្កេ |
|---|---|---|
| មហានិទ្ទេសេ | ឆដ្ឋោ ជរាសុត្តនិទ្ទេសោ | ២២១ |
| | ទ្វីហិ ការណេហិ អប្បកំ ជីវិតំ .... | " |
| | កលលកាលាទីសុ មរតិ សត្តោ ..... | ២២៤ |
| | ទ្វេ មមត្តា ............... | ២២៩ |
| | ទ្វេ បរិគ្គហា ............... | ២៣០ |
| | បញ្ច មច្ឆរិយានិ ............ | ២៤២ |
| | តីណិ មោនេយ្យានិ ............ | ២៤៤ |
| | សត្ត សេខា បដិលីនចរា ....... | ២៤៥ |
| | តិស្សោ សាមគ្គិយោ .......... | ២៤៨ |
| | ទ្វេ និស្សយា ............... | ២៥០ |
| | ទ្វេ បិយា ................. | ២៥១ |
| | ទ្វេ អប្បិយា ............... | ២៥២ |
| | បញ្ច មច្ឆរិយានិ ............ | ២៥៣ |
| | ទ្វេ លេបា ................. | ២៥៦ |
| | បញ្ញា ធោនា ............... | ២៥៧ |
| | អបរា ធោនា ............... | ២៥៨ |

# សន្ទឹកប្រាប់មាតិកា

| មាតិកា | | ទំព័រ |
|---|---|---|
| មហានិទ្ទេស | ជរាសុត្តនិទ្ទេស ទី ៦ | ២២១ |


ជីវិត មានប្រមាណតិច ដោយហេតុ ២ យ៉ាង ,,

សត្វ ស្លាប់ក្នុងកលលកាលជាដើម . . . . ២២៥

មមត្ត (ការប្រកាន់) ២ យ៉ាង . . . . . . . ២២៩

បរិគ្គហៈ (ការហួងហែង) ២ យ៉ាង . . . . ២៣០

មច្ឆរិយៈ (សេចក្ដីកំណាញ់) ៥ យ៉ាង . . . ២៤២

មោនេយ្យៈ (ភាពជាមុនិ) ៣ យ៉ាង . . . . ២៤៤

សេក្ខបុគ្គល៧ពួក ឈ្មោះថាអ្នកប្រព្រឹត្តរួញថយ ២៤៥

សាមគ្គី ៣ យ៉ាង . . . . . . . . . . . ២៤៨

និស្ស័យ ២ យ៉ាង . . . . . . . . . . . ២៥០

សភាវៈជាទីស្រឡាញ់ ២ យ៉ាង . . . . . ២៥១

របស់មិនជាទីស្រឡាញ់ ២ យ៉ាង . . . . ២៥២

សេចក្ដីកំណាញ់ ៥ យ៉ាង . . . . . . . ២៥៣

ការជាប់ ២ យ៉ាង . . . . . . . . . . . ២៥៦

បញ្ញាជាធោនា (គ្រឿងជម្រះមន្ទិល) . . ២៥៧

ព្រះអរហន្ត ជាធោនៈ (អ្នកជម្រះមន្ទិល) . ២៥៨

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| មហានិទ្ទេសេ សត្តមោ តិស្សមេត្តេយ្យសុត្តនិទ្ទេសោ | ២៦២ |
| តយោ វិវេកា | ២៦៤ |
| ទ្វីហិ ការណេហិ សាសនំ មុស្សតិ | ២៧២ |
| ទ្វីហិ ការណេហិ ឯកោ បុព្វេ អចរិ | ២៧៤ |
| តិស្សោ សិក្ខា | ២៨១ |
| មិច្ឆាសង្កប្បេន បរេតោ ភិក្ខុ | ២៨៤ |
| តីណិ សត្ថានិ | ២៨៧ |
| ត្យាការទីហិ មុសាវាទោ | ២៨៩ |
| តិវិធា កម្មការណា | ២៩២ |
| ទ្វីហិ ការណេហិ ឯកចរិយា | ២៩៦ |
| តយោ វិវេកា | ២៩៩ |
| ពុទ្ធាទយោ អរិយា | ៣០០ |
| អដ្ឋមោ បស្សូរសុត្តនិទ្ទេសោ | ៣០៥ |
| បច្ចេកសច្ចេសុ និវិដ្ឋា | ៣០៧ |
| នានា ការណេហិ ឧគ្ឃាតិនិគ្ឃាតិ | ៣១៨ |
| កាយទុច្ចរិតាទិកា មារសេនា | ៣៣១ |
| ភគវា ធោនោ | ៣៣៦ |
| ភគវា មហាបញ្ញោ | ៣៣៨ |

## មាតិកា ទំព័រ


មហានិទ្ទេស តិស្សមេត្តេយ្យសុត្តនិទ្ទេស ទី ៧ ២៦២

វិវេក (សេចក្ដីស្ងាត់) ៣ យ៉ាង ...... ២៦៤

សាសនា វិនាស ដោយហេតុ ២ .... ២៧២

ប្រព្រឹត្តម្នាក់ឯងក្នុងកាលមុនដោយហេតុ២ ២៧៤

សិក្ខា ៣ ................ ២៨១

កិច្ចដែលមិច្ឆាសង្កប្បៈគ្របសង្កត់ហើយ ... ២៨៤

សត្ថា ៣ យ៉ាង .......... ២៨៧

មុសាវាទ ដោយអាការៈ ៣ យ៉ាងជាដើម . ២៨៩

កម្មការណា មានប្រការផ្សេងៗ .... ២៩២

ការប្រព្រឹត្តម្នាក់ឯង ដោយហេតុ ២ ... ២៩៦

វិវេក (ការស្ងាត់) ៣ យ៉ាង ....... ២៩៩

ព្រះពុទ្ធជាដើម ជាព្រះអរិយៈ ...... ៣០០

បសូរសុត្តនិទ្ទេស ទី ៨ ៣០៥

(សមណព្រាហ្មណ៍)តាំងនៅក្នុងបច្ចេកសច្ចៈ . ៣០៧

ការធូរចិត្តនឹងតឹងចិត្ត ព្រោះហេតុផ្សេងៗ . . ៣១៨

មារសេនាមានកាយទុច្ចរិតជាដើម .... ៣៣១

ព្រះមានព្រះភាគជាធោនៈ ....... ៣៣៦

ព្រះមានព្រះភាគ មានប្រាជ្ញាច្រើន .... ៣៣៨

# សុទ្ធាសុទ្ធបត្តំ

| សុទ្ធបាឋោ | អសុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| អន្តភនាយតិ | អន្តរធាយតិ | ៧ | ១៥ |
| កុដ្ឋិ | កុដ្ឋិ– | ២២ | ៩ |
| ១ ឧ. | ១ ឪ. | ៣២ | ១៦ |
| មនោញ្ញេយ្យា | មនោវិញ្ញេយ្យា | ៤៣ | ១៤ |
| ទុព្វិនិវេធយា | ទុព្វិនិវេធយា | ៥៧ | ២ |
| ចុពោស | ចុតាសេ | ៦៣ | ១៦ |
| បុរក្ខេពោ | បុរក្ខពោ | ៧៩ | 〃 |
| បច្ចុប្បន្នោ | បច្ចុប្បន្នោ | ៩៦ | ៣ |
| ញាណា | ញាណំ | ១០៦ | ១០ |
| កោបញ្ច | ន កោបញ្ច | ១១៦ | ៨ |
| បរិញ្ញាដីកំ | បរិញ្ញាដិកំ | ១១៨ | ២ |
| អវសុស្សតុ | អវសិស្សតុ | ១២៣ | ១៤ |
| បុនព្ភវេតិ(១)។ | បុនព្ភវេតិ(១) | ១៣១ | ១២ |
| អាទិ យន្តិ | អាទិយន្តិ | ១៧៣ | ៣ |
| ឯត្តាវតា មម | ឯត្តាវតា មមំ | ២១៣ | ៩ |
| ទិន្និ– | ទិន្និ | 〃 | ១៧ |
| សមន្នាកពោ | សមន្នាគពោ | ២៨៤ | 〃 |
| មងិគពោ | មង្ឃគពោ | ២៨៩ | ៤ |
| វិរត្តស្ស | វិរត្តស្ស | ៣០១ | ៨ |
| សព្វទរថេហិ | សព្វទរថេហិ | 〃 | ១៣ |
| កហោន្តិ | កហោន្តិ | ៣០៩ | ១៧ |
| ១. ម. អត្ថី សម្ម៍ | ១ ម. អត្ថិ សម្ម | ៣៣៩ | 〃 |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| កើតអំពីធម៌ | សមគួរដល់ធម៌ | ៤ | ១២ |
| សុទ្រះ | សូទ្រះ | ៩ | ៨ |
| គិលានប្បភេសជ្ជបរិក្ខារ | គិលានប្បច្ចយភេសជ្ជបរិក្ខារ | ១៦ | ៣ |
| ផ្សព្វជាទីគាប់ចិត្ត | ផ្សព្វទាំងឡាយជាទីគាប់ចិត្ត | ២០ | — |
| នីទ្ទេស | និទ្ទេស | ២៥ | ១ |
| ព្រោះបាក់ស្រេះ | ព្រោះមិនបាក់ស្រេះ | ៣៩ | ៥ |
| អាម្មណ៍ | អារម្មណ៍ | ៤៤ | ២ |
| ព្រៃលង | ព្រៃលែង | ៥៣ | ១៥ |
| កំឡាំងញាណ | កំឡាំងញាណ | ៥៨ | ១៤ |
| មោនេយ្យធម៌នេះ | មោនេយ្យធម៌ ៣ នេះ | ១០៩ | ១០ |
| បរីបូណ៌ | បរិបូណ៌ | ១២០ | ១៩ |
| គោចារៈ | គោចរៈ | ១២៣ | ៣ |
| បញ្ញា ភត្តិកង្កៈ | បញ្ញាភត្តិកង្គៈ | — | ១១ |
| សីល្បៈ | សិល្បៈ | ១២៨ | ១៤ |
| ភិក្ខុ ។ | ភិក្ខុ | ១៣១ | ១២ |
| ពឹងផ្អែក | ពឹងផ្អែក | ១៧១ | ១១ |
| មិនកានទេ | មិនមានទេ | ២០៩ | ១៥ |
| ជាបិត្តិវិស័យ | ក្នុងបិត្តិវិស័យ | ២១២ | ៤ |
| មិនត្រឡប | មិនត្រឡប់ | ២១៦ | ៨ |
| ថ្មើជើង | ថ្មើរជើង | ២៣៨ | ៤ |
| ឈ្មោះថា | ក៏ឈ្មោះថា | ២៥៤ | ២ |
| មិន(ទ្រាន់) | មិនទ្រាន់ | ២៥៦ | ១៩ |
| បពិត | បពិត្រ | ២៦៤ | ១២ |
| មពាលំដាប់ | តាមលំដាប់ | ២៧២ | " |
| មិនកើតមាន | មិនឲ្យកើតមាន | ៣២៤ | ៨ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

**Wat. Sotoshu Fukusenji Temple**
The Rev. Seiyu Muchaku · Kiyomi Muchaku
292 Hitokuwada, Tako-machi, Katori-gun, Chiba Prefecture 289-22 Japan

この本は次の方によって復刻されました。

宗教法人 曹洞宗 福泉寺 副住職　無着成融・無着清美
〒289-22　日本国千葉県香取郡多古町一鍬田292
☎0479-75-0894

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤

សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. **64** (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

**トリピタカ（南伝大蔵経）全110巻・第64巻スッタンタピタカ（経部）**

---

**発　　行：プノンペン仏教研究所**
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月 8 日

---

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE